# សាកលវិទ្យាល័យជាតិ ជា ស៊ីមកំចាយមារ

NATTONAL UNIVERSTT OF CHEASIM KAMCHAYMEAR


# តម្លៃអប់រំអក្សរសិល្ប៍ពុទ្ធនិយមក្រោយសម័យអង្គរ រឿងទសជាតក រឿងបញ្ញាសជាតក រឿងនានាជាតក

The Values Education of Post Angkorian Period Buddhist literature

## និក្ខេបបទ ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ការសិក្សា ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ អក្សរសាស្ត្រខ្មែរ

A thesis in fulfilment of the requirement for the degree of

Master in Khmer Literature

**ខែធ្នូ ឆ្នាំ២០២៣**

December 2023

# សាកលវិទ្យាល័យជាតិជាស៊ីមកំចាយមារ

NATTONAL UNIVERSTT OF CHEASIM KAMCHAYMEAR

# តម្លៃអប់រំអក្សរសិល្ប៍ពុទ្ធនិយមក្រោយសម័យអង្គរ រឿងទសជាតក បញ្ញាសជាតក នានាជាតក

The Values Education of Post Angkorian Period Buddhist literature

**និក្ខេបបទ ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ការសិក្សា**

**ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ អក្សរសាស្ត្រខ្មែរ**

A thesis in Fulfillment of the Requirement for the Degree of

Master of Arts in Khmer Literature

**និស្សិតឈ្មោះ ឡច់ យា**

**សាស្ត្រាចារ្យដឹកនាំ មិ សុវណ្ណា**

**ខែធ្នូ ឆ្នាំ២០២៣**

December 2023

# មូលន័យសង្ខេប

ដោយហេតុការសិក្សាស្រាវជ្រាវទាក់ទងនឹងស្នាដៃអក្សរសិល៍្បពុទ្ធនិយមនៅមានកម្រិតនៅឡើយ ទើបស្មេរសម្រេចចិត្តលើកយកប្រធានបទនេះមកសាកល្បងសិក្សា  ក្រោមប្រធានបទមានចំណងជើងថា « **តម្លៃអប់រំអក្សរសិល៍្បពុទ្ធនិយមក្រោយសម័យអង្គរ**»។ ការសិក្សាពីប្រធានបទមួយនេះ ធ្វើឡើងក្នុងគោលបំណងចម្បងៗចំនួនពីរគឺ   ទីមួយដើម្បីសិក្សាស្វែងយល់ឱ្យបានកាន់តែច្បាស់ពីតួនាទីអប់រំនៅសម័យក្រោយអង្គរនៃស្នាដៃរឿងក្នុងអក្សរសិល៍្បប្រពុទ្ធនិយមខ្មែរ។ ទីពីរ ដើម្បីស្វែងយល់ដឹងពីតម្លៃអប់រំអក្សរសិល៍្បពុទ្ធនិយម នៅក្នុងស្នាដៃរឿង ផ្សាភ្ជាប់នឹងសង្គមដែលមនុស្សបានរស់នៅសព្វថ្ងៃនេះ។ នៅក្នុងការសរសេរនិក្ខេបទមួយនេះ ស្មេរបានប្រើប្រាស់វិធីសាស្ត្របែបគុណវិស័យ ក្នុងការសិក្សាអំពីប្រធានបទ។ បន្ទាប់ពីស្មេរបានប្រមូលទិន្នន័យទាក់ទងនឹងសៀវភៅ អក្សរសិល៍្ប មកពីសៀវភៅអក្សរសិល៍្បពុទ្ធនិយមដែលមាន ទសជាតក ឬពុទ្ធនិយមសុទ្ធសាទ ពុទ្ធនិយមក្លាយឬ បញ្ញាសជាតក នានាជាតក ឬពុទ្ធនិយមក្លាយហួសហេតុ និងអក្សរសិល្ប៍ពីគម្ពីរត្រៃបិតកខ្មែរដទៃទៀតមកសិក្សាជាមួយផងដែរ។ នៅក្នុងស្នាដៃអក្សរសិល៍្បពុទ្ធនិយមខ្មែរ  ជាស្នាដៃដែលបានបង្ហាញឱ្យអ្នកសិក្សាបានឃើញពីតម្លៃអប់រំនៅក្នុងរឿងនីមួយៗរបស់អ្នកនិពន្ធ  ដោយឆ្លុះបញ្ចាំងតាមរយៈស្នាដៃដែលមានដូចជា ប្រវត្តិសាស្ត្រ ជំនឿលិទ្ធិព្រះពុទ្ធសាសនា ឱ្យជឿលើទស្សនៈកម្មផល ប្រពៃណី ទំនៀមទម្លាប់ ជីវភាពរស់នៅរបស់ប្រជាជន និងរបបគ្រប់គ្រង់ក្នុងសង្គម។

តាមរយៈការសិក្សាទៅលើស្នាដៃរឿងទាំងនោះ ស្មេរបានធ្វើការសិក្សាវិភាគលើចំណុចសំខាន់ៗមួយចំនួនដូចជា តម្លៃអប់រំតាមរយៈរឿងអក្សរសិល៍្បពុទ្ធនិយមការគោរពព្រះពទ្ធសាសនា  ការគោរពដូនតា ទំនៀមទម្លាប់ប្រពៃណីជាដើម។ ចំពោះទិដ្ឋភាពនៅក្នុងការសិក្សាស្រាវជ្រាវនេះ ស្មេរមើលឃើញថា អក្សរសិពុទ្ធនិយមខ្មែរពិតជាមានលក្ខណៈអស្ចារ្យណាស់ ដែលមនុស្សចេះប្រើប្រាស់ភាសារបស់ខ្លួនយ៉ាងប៉ិនប្រសប់ ដើម្បីឆ្លុះបញ្ចាំងនូវបាតុភូតផ្សេងៗ និងបញ្ហាជីវិតដែលកើតមាននៅក្នុងសង្គម។ ដូច្នេះហើយទើបក្រោយមកនេះ មានកត់ត្រាទុកជាសៀវភៅប្រជុំរឿងពុទ្ធប្រវត្តិខ្មែរសម្រាប់ផ្ដល់ជាប្រយោជន៍ដល់មនុស្សបានរៀនសូត្រ និងស្វែងយល់ពីរឿងរ៉ាវផ្សេងៗ នាអតីតកាលរបស់ខ្មែរយើង។ **ឯស្នាដៃអក្សរសិល្ប៏ខ្មែរបែបពុទ្ធនិយម ដែលកើតនៅក្នុងសម័យលង្វែកនិងឧដុង្គ ក៏សុទ្ធតែទទួលឥទ្ធិពលពុទ្ធសាសនាថេរវាទយ៉ាងជ្រាលជ្រៅ ហើយបានរីកចម្រើនយ៉ាងខ្លាំងក្នុង សតវត្សរ៍ទី១៨-១៩ នៃប្រវត្តិអក្សរសិល្ប៍របស់ខ្មែរ។ ឯប្រធានបទដែលអ្នកនិពន្ធជ្រើសយក មកសរសេរក្នុងស្នាដៃរបស់ខ្លួន គឺទាក់នឹងការបំពេញបារមីរបស់ព្រះពោធិសត្វដើម្បីបានត្រាស់ ជាព្រះសម្មាសម្ពុទ្ធ ទាក់នឹងការធ្វើទាន ទាក់នឹងការ  កសាងអំពើជាកុសលផ្សេងៗរបស់ពោធិ សត្វ ទាក់ទងនឹងកម្មពៀរ បាបនិងបុណ្យ ជាដើម។ ឯការផ្សព្វផ្សាយវប្ប**

ធម៌ អក្សរសាស្ត្រ អក្សរសិល្ប៍ និងព្រឹត្តិការណ៍សង្គមផ្សេងៗនៅសម័យនោះ គឺតាមរយៈសាស្ត្រា ដែលគេតម្កល់នៅក្នុង វត្តសម្រាប់បង្រៀនសិស្ស ក្រាំងព្រះសង្ឃទេសនា ភាវនិយាយរឿងប្រាប់គ្នាតៗជាដើម។ មិន តែប៉ុណ្ណោះ សិស្សដែលចូលរៀនក្នុងសាលាវត្ត ក្រោយពីទទួលបានចំណេះដឹងពីព្រះសង្ឃសព្វសារពើហើយ ពួកគេត្រូវចារសាស្ត្រ ហើយចែកជូនតាមវត្តអារាមដែលត្រូវការ ដើម្បីឱ្យអ្នក សិក្សានៅសាសារវត្តក្រោយៗទៀតបានរៀនសូត្រ រាល់ខ្លឹមសារក្នុងស្នាដៃនីមួយៗពោរពេញ ទៅដោយការអប់រំឱ្យមនុស្សប្រព្រឹត្តនូវអំពើល្អ បណ្ដុះស្មារតីអហឹង្សា ក្នុងការប្រាស្រ័យទាក់គ្នា នៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។ ស្នាដៃទាំងនេះ ទទួលបាននូវការពេញនិយមពីសំណាក់ប្រជា ពលរដ្ឋខ្មែរទាំងក្នុងសម័យមុននិងសម័យបច្ចុប្បន្ន ហើយមានឥទ្ធិពលយ៉ាងជ្រៅទៅលើសង្គម វប្បធម៌ខ្មែរ ដូចជា ក្នុង វិស័យហោរាសាស្ត្រ វិស័យសិល្បៈ វិស័យតុលាការ វិស័យនយោបាយ វិស័យច្បាប់ ។

## Abstract

Since of the researching related to the Buddhist literature is still limited, So Writer decided to try on this topic in the research studying entitled that ,"The Values of Post-Buddhist Buddhist of Education after Angkorian period". The reaching about this topic found on two purpose such as To find a good way the best education in the after Angkorian period of Khmer Buddhist literature. The second purpose is to find the value of Buddhist literature education interature  the story to connect the social media who lived nowadays. Next the writer collected the data related to the books Literature from Buddhist Literature what there Tosacheatak or a real Buddhist, fake Buddhist too, Panha Cheatak, NeathCheatak, fake excess Buddhist and the literature of each other Khmer Traibeytak bible to study.In the main point of story is shown to the learners know the value of education in each other story of writers Reflecting through the story existing are history, beliefs, Buddhism, believe on Karmic Perspectives, traditional, living of the peoples and Social regime.

Through the Studying  those stories writers analysed each major like value on the Buddhist and respect to the buddism, Respect to the old people and traditional. For view or in this situation of researching writers seen that the Khmer litter Buddhist is truly an amazing characteristic who the people can use their proficiency languages to reflect various phenomena and problems of life that happened in the society. Thus these last noted are  books, storytelling, Khmer Buddism of history to give the advantage for people learns and find to study a lot of stories and the past .The works, however, of Khmer Literature in Buddhist that appeared in the period of Long Vek and Udong were comprehensively full of Theravada Buddhist influences in the 18-19 century of the history of Khmer literature. To the topics were chosen to write by the authors for their works were related to the performing of Bodhisatta's perfections in order to attain enlightenment as the Buddha, but some performing of the perfections, such as charity and so on were only concerning with cause and effect and virtuous things. While, the propagation of culture, literature and social events at that times were through Sotra documents written on palm

leaves ) keeping on the monasteries for teachings students, scroll or documents( ancient parchment book folded into section ) for monks preaching, selling from one to one person etc. Moreover, students who enrolled to study at school of monasteries ( Pagoda school ) were well educated from the Buddhist monks, they wrote, recorded these works and distributed to other monsterios nooded for the next students to study. All meanings and essences of each works were full of educations, personal growth, building non-violence spirits in communication with daily lives. These works received the prestige, popularity of the former and present Khmer citizen and influenced deeply on the cultural sociology such as the aspect of astrology, arts, court, politics and law so on.

# លិខិតបញ្ជាក់របស់សាស្ត្រាចារ្យដឹកនាំសារណាបទ

កម្មវិធីថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ **អក្សរសាស្ត្រខ្មែរ**

ឈ្មោះបេក្ខជនៈ ឡុង ឃា

ចំណងជើងសារណាបទៈ តម្លៃអប់រំអក្សរសិល្ប៍ពុទ្ធនិយមក្រោយសម័យអង្គរ

សូមបញ្ជាក់ថា ការស្រាវជ្រាវដែលជាសារណាបទសម្រាប់បំពេញលក្ខខណ្ឌ ដើម្បីយកសញ្ញាបត្រថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ដែលមានចំណងជើងដូចខាងលើនេះ ត្រូវបានចង់ក្រងឡើយដោយបេក្ខជនដែលមានឈ្មោះខាងលើ ក្រោមការដឹកនាំរបស់ខ្ញុំផ្ទាល់។ ខ្លឹមសារសារណាបទនេះ ពុំទាន់មាននៅក្នុងការសរសេរយកសញ្ញាបត្រកម្រិតណាមួយនៅឡើយទេ។ ក្នុងការរៀបចំសារណាបទនេះ ខ្ញុំបានដឹកនាំពិនិត្យផ្ទាល់ដូចជាៈ ការសរសេរលំនាំនៃការស្រាវជ្រាវជ្រាវ ការកំណត់បញ្ហាស្រាវជ្រាវ ការកំណត់វត្ថុបំណងនៃស្រាវជ្រាវ ការជ្រើសរើសវិធីសាស្ត្រស្រាវជ្រាវ ការពិភាក្សា លទ្ធផលស្រាវជ្រាវការសន្និដ្ឋាន និងការផ្តល់អនុសាសន៍ជាដើម។

កាលបរិច្ឆេទៈ

ហត្ថលេខា និងឈ្មោះសាស្ត្រាចារ្យដឹកនាំ

កម្រិតសញ្ញាបត្រ

# លិខិតបញ្ជាក់បេក្ខជន

នាងខ្ញុំ សូមបញ្ជាក់ថា សារណាបទ ដែលមានចំណងជើងថាតម្លៃអប់រំអក្សរសិល្ប៍ពុទ្ធនិយមក្រោយសម័យអង្គរ សម្រាប់បំពេញលក្ខខណ្ឌយកសញ្ញាបត្របជាន់ខ្ពស់ អក្សរសាស្ត្រខ្មែរ នៅសាកលវិទ្យាល័យជាតិជាស៊ីមកំចាយមារ គឺជាស្នាដៃ ស្រាវជ្រាវផ្ទាល់របស់នាងខ្ញុំទាំងស្រុង ដោយគ្មានការពាក់ព័ន្ធជាមួយនឹងសារណបទ ឬនិក្ខេបបទ ឬជារបាយការណ៍របស់អ្នកផ្សេងណាមួយឡើយ។ ចំពោះទិន្នន័យ និងលទ្ធផលនៃការស្រាវជ្រាវ ដែលមាននៅក្នុងសារណាបទនេះ គឺថ្មី ហើយក៏មិនទាន់មានជនណាម្នាក់យកទៅ ប្រើប្រាស់ដើម្បីបំពេញលក្ខខណ្ឌយកសញ្ញាបត្រ នៅសាកលវិទ្យាល័យណាមួយនោះដែរ។ ពុំមានសេចក្តីដកស្រង ឬខ្លឹមសារអ្វីមួយត្រូវបានប្រើក្នុងអត្ថបទស្រាវជ្រាវនេះ ដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ ឬចុះបញ្ជីឯកសារយោងឡើយ។ ខ្លឹមសារទាំងអស់ក្នុងសារណាបទនេះគឺសម្រាប់ប្រើប្រាស់ដើម្បីបំពេញលក្ខខណ្ឌយកសញ្ញាបត្រថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អក្សរសាស្ត្រខ្មែរតែប៉ុណ្ណោះ។

ហត្ថលេខាបេក្ខជន៖……………………..

កាលបរិច្ឆេទ៖……………………………..

ហត្ថលេខាសាស្ត្រចារ្យដឹកនាំ……………..

កាបរិច្ឆេទ……………………………………

# សេចក្តីថ្លែងអំណរគុណចំពោះ

នាងខ្ញុំ សូមលើកហត្ថាគោរពសំដែងនូវកត្តញ្ញូតាធម៌ដ៏ខ្ពង់ខ្ពស់ និងសូមលំឱនកាយ ថ្លែង អំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ លោកអ្នកមានគុណទាំងពីររូបរបស់ខ្ញុំទាំងអស់ គឺលោកឪពុក អ្នកម្តាយ ដែលបានហែលឆ្លងនូវសមុទ្រឧបសគ្គគ្រប់បែបយ៉ាង ផ្តល់កំណើត ចិញ្ចឹមបីបាច់ថែរក្សា ទំនុកបម្រុងនិងអប់រំទូលន្មានបៀបប្រដៅ ផ្តល់ដំបូន្មានប្រកបទៅដោយព្រហ្មវិហារធម៌ ព្រមទាំងផ្តល់នូវ ឱកាសយ៉ាងធំធេងជាងបំផុតដល់កូនបានចុលរៀនតាំងពីថ្នាក់បឋមរហូតដល់ថ្នក់បរិញ្ញាបត្រជាន់ខ្ពស់។ នេះគឺជាឧបការៈគុណមានតម្លៃដោយដោយមិនអាចយកវត្ថុអ្វីមកប្រៀបស្មើរបានឡើយ។

មួយវិញទៀតនាងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **លោកបណ្ឌិត មិ សុវណ្ណ** ដែលបានខិតខំប្រឹងប្រែងយកចិត្តទុកដាក់មិនដែលរុញរាម្តងណាឡើយ និងការចំណាយពេលវេលា ដ៏មានតម្លៃឆ្លៀតឱកាសដ៏មមាញឹករបស់លោកក្នុងការជួយជ្រោមជ្រែង ផ្តល់ជាទស្សនៈ គំនិត យោបល់ ទ្រឹស្តី ក៏ដូចជាវិធីសាស្ត្រផ្សេងៗ ជាច្រើនដើម្បីជំរុញដល់ការសរសេរសារណាបតនេះឱ្យទទួលបានជោគជ័យ។ គុណណូបការៈរបស់លោក នាងខ្ញុំពុំអាចរកពាក្យអ្វីមកបរិយាឱ្យស័ក្តិសមបានឡើយ ក្រៅពីកិច្ចនៃការគោរពដឹងគុណចំពោះលោកជាប់ក្នុងដួងចិត្តជានិច្ច ហើយនេះ គឺចាការចងចាំដ៏វិសេសវិសាលពេញមួយជីវិត។

នាងខ្ញុំសូមថ្លែងអំណគុណផងដែរ ចំពោះសាកលវិទ្យាល័យជាតិជាស៊ីមកំចាយមារ ព្រមទាំងគណៈគ្រប់គ្រងសាលាគ្រប់រូប ដែលបានការផ្តល់ការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ជំនាញអក្សរសាស្ត្រខ្មែរ ដើម្បីឱ្យរូបខ្ញុំនាងខ្ញុំមានឱកាសបានបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ជំនាញអក្សរសាស្ត្រខ្មែរ នៅសាខាខេត្តកំពង់ចាម ដោយមិនចាំបាច់ទៅរៀននៅភ្នំពេញ។ លើសពីនេះទៅទៀតនាងខ្ញុំសូនថ្លែងអំណរគុណចំពោះលោកគ្រូ អ្នកគ្រូ ជាសាស្ត្រចារ្យ ដែលបានខិតខំបង្ហាត់បង្រៀនផ្តល់ចំណេះវិជ្ជា និងដំបូន្មានល្អៗ ដល់យើងខ្ញុំជានិស្សិតគ្រប់រូបឱ្យទទួលបាននុវចំណេះដឹងនិងក្លាយទៅជាមនុស្សពេញលេញ។

ជាចុងបញ្ចប់នាងខ្ញុំសូម ថ្លែងអំណរគុណ កត្តញ្ញូតាធម៌ដ៏ជ្រាលជ្រៅ គោរពចំពោះ លោកយាយ លោកតា អ៊ំប្រុស អ៊ំស្រី លោកពូ អ្នកមីង បងប្រុស បងស្រី ប្អូនប្រុស ប្អូនស្រី និងមិត្តភ័ក្ត រួមជំនាន់ទាំងអស់ដែលតែងតែលើកទឹកចិត្តជម្រុញឲ្យនាងខ្ញុំ តស៊ូព្យាយាមតស៊ូសិក្សារហូតដល់ចប់ជាស្ថាពរ។ នាងខ្ញុំគ្មានអ្វីជាកិច្ចតបស្នងគុណឱ្យសាកសម និងដួងចិត្តដ៏ល្អប្រពៃរបស់លោកដែលមានចំពោះនាងខ្ញុំទេ ក្រៅអំពីការគោរព និងដួងចិត្តស្មោះសដែលមានជាប់ជានិច្ចក្នុងបេះដូងនូវគុណូបការៈរបស់ងស់លោក គ្មានថ្ងៃបំភ្លេចបាន។ នាងខ្ញុំសូមបួងសួងដល់គុណបុណ្យបារមី ទេវតា និងវត្ថុស័ក្តិសិទ្ធិក្នុងលោកតាមជួយបីបាច់ថែរក្សា ជ្រោមជ្រែងអស់លោកឱ្យសមប្រកបតែសេចក្តីសុខទាំងអស់គ្នាជួបតែនូវពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លាងឃ្លាតឡើយ។

## មាតិកា


**មូលន័យសង្ខេប ..... i**

**Abstract ..... iii**

**លិខិតបញ្ជាក់របស់សាស្ត្រាចារ្យដឹកនាំសារណាបទ ..... v**

**លិខិតបញ្ជាក់បេក្ខជន ..... vi**

**សេចក្ដីថ្លែងអំណរគុណចំពោះ ..... vii**

**ជំពូក ១ សេចក្ដីផ្ដើម ..... 1**

១.១. លំនាំដើមនៃការស្រាវជ្រាវ ..... 1

១.២. បញ្ហានៃការស្រាវជ្រាវ ..... 2

១.៣. វត្ថុបំណងនៃការស្រាវជ្រាវ ..... 3

១.៤. សំណួរស្រាវជ្រាវ ..... 3

១.៥. សារៈសំខាន់នៃការស្រាវជ្រាវ ..... 3

១.៦. ដែនកំណត់នៃការស្រាវជ្រាវ ..... 3

១.៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ..... 4

**ជំពូក ២ រំលឹកទ្រឹស្ដី ..... 6**

២.១. និយមន័យអក្សរសិល្ប៍ ..... 6

២.២. និយមន័យអក្សរសិល្ប៍ពុទ្ធនិយ ..... 8

២.៣. ប្រភពអក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយម ..... 10

២.៤ គំណែងនិពន្ធអក្សរសិល្ប៍ពុទ្ធនិយម ..... 12

២.៥. ប្រភេទអក្សរសិល្ប៍ពុទ្ធនិយម ..... 13

**ជំពូក ៣ វិធីសាស្ត្រស្រាវជ្រាវ ..... 14**

៣.១. ប្រភេទនិង ប្រភពនៃការស្រាវជ្រាវ ..... 14

៣.២. វិធីសាស្ត្រស្រាវជ្រាវតាមបែបបគុណវិស័យ ..... 14

៣.៣. វិធីសាស្ត្រនៃការប្រមូលទិន្នន័យ ..... 15

៣.៤. វិធីសាស្ត្រវិភាគទន្នន័យ ..... 15

**ជំពូក ៤ ការវិភាគទិន្នន័យ លទ្ធផល ..... 1**

៤.១. ទិដ្ឋភាពទូទៅនៃអក្សរសិល្ប៍ពុទ្ធនិយម ..... 1

៤.១.១. ការបែងចែកប្រវត្តិអក្សរសាស្ត្រខ្មែរ ..... 4

៤.២. ទិដ្ឋភាពទូទៅសម័យលង្វែក ..... 7

៤.២.១.ប្រភេទអក្សរ ..... 11

៤.២.២. អំពីសិលាចារឹក ..... 11

៤.៣. អក្សរសិល្ប៍សាស្ត្រល្បែង ..... 12

៤.៤.ទិដ្ឋភាពទូទៅនៅសម័យឧត្ដុង ..... 13

៤.៤.១.អក្សរសាស្ត្រសម័យឧត្ដុង ..... 14

៤.៥. ព្រះពុទ្ធសាសនា ..... 20

៤.៥.១. ព្រះពុទ្ធសាសនាក្នុងសង្គមខ្មែរ ....20
៤.៥.២ ឥទ្ធិពលព្រះពុទ្ធសាសនាសម័យក្រោយអង្គរ ....20
៤.៦. ទស្សនៈកម្មផល ....22
៤.៧ អក្សរសិល្ប៍ពុទ្ធនិយមក្លាយ ....34
៤.៨.១.អក្សរសិល្ប៍ពុទ្ធិនិយមក្លាយហួសហេតុហួសហេតុ....65
**ជំពូក ៥ វិភាគក្សាលើលិទ្ធិផលស្រាវជ្រាវ ....124**
៥.១ តម្លៃអប់រំនៃរឿងអក្សរសិល្ប៍ពុទ្ធនិយម .... 124
៥.២ តម្លៃអប់រំចរិយាសាស្ត្រ .... 128
៥.២.តម្លៃអប់រំចរិយាសាស្ត្រ .... 128
៥.៣.តម្លៃអប់រំពុទ្ធិសោភ័ណជីវិត .... 129
៥.៤.តម្លៃអប់រំឱ្យស្រឡាញ់សន្តិភាពនិងការអភិវឌ្ឍន៍សង្គម.... 130
៥.៥.តម្លៃអប់រំការព្យាបាលផ្លូវចិត្តនិងកំសាន្តអារម្មណ៍.... 132
**ជំពូក ៦ សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍ ....133**
៦.១.សង្ខេបលិទ្ធផល .... 133
៦.២.អនុសាសន៍ .... 133
**ឯកសារយោង ....135**

# ជំពូក ១ សេចក្ដីផ្ដើម

## ១.១. លំនាំដើមនៃការស្រាវជ្រាវ

ក្នុងការសិក្សាអក្សរសិល្ប៍ខ្មែរសម័យបុរាណមានរឿងជាច្រើន ដែលទាក់ទងនឹងទស្សនៈគោលសំខាន់ៗក្នុងព្រះពុទ្ធសាសនា ពិសេសក្នុងសម័យអង្គរដែលយើងឃើញមានស្នាដៃជាច្រើនដែល បុព្វបុរស និងព្រះមហាក្សត្រគ្រប់ព្រះអង្គបានកសាងមានប្រាសាទជំស្កឹមស្កៃសម្រាប់បូជាថ្វាយអាទិទេពរបស់ព្រះអង្គនៅក្នុងលិទ្ធិសាសនានីមួយៗ ហើយប្រទេសកម្ពុជាក្លាយជាចក្រភពអង្គរដ៏ល្បីល្បាញធ្វើឱ្យមានកេរ្តិ៍ឈ្មោះល្បីសុសសាយពេញសកលលោក។ ប៉ុន្តែគួរឱ្យសោកស្ដាយសម័យអង្គរមិនអាចឈរជើងបានស្ថិតស្ថេររហូតបានដល់ទីបញ្ចប់នៃសម័យកាលដ៏រុងរឿងនោះផងដែរ។ ក្រោយការបែកបាក់នេះប្រទេសកម្ពុជាចូលទៅក្នុងភ្នក់ភ្លើងនៃសង្គ្រាមច្បាំងរាំងជល់ វិបត្តិផ្ទៃក្នុងរហូតស្ទើរផុតដង្ហើមពីផែនទីពិភពលោកនេះ។ សម័យក្រោយអង្គរ ឬសម័យកណ្ដាលដែលគេផ្ដោតសំខាន់ទៅលើសម័យកាលពីរសំខាន់គឺ លង្វែក និងឧដុង្គ(១៤៣១-១៨៦០)។

ជាមួយគ្នានេះអក្សរសិល្ប៍ខ្មែរត្រូវបានវិវត្តន៍ទៅតាមដំណាក់កាលនីមួយៗ នៃប្រវត្តិសាស្ត្រ កំឡុងសម័យអង្គរ យើងរកឃើញត្រឹមតែអត្ថបទជាសិលាចារឹកតែប៉ុណ្ណោះ។ ក្រោយសម័យដ៏រុងរឿងនេះ ត្បិតសង្គមខ្មែរធ្លាក់ក្នុងកលិយុគយ៉ាងណាក្ដី ក៏យើងអាចឃើញអត្ថបទអក្សរសិល្ប៍ហាក់មានសន្ទុះឡើងវិញ រហូតអ្នកប្រាជ្ញអក្សរសាស្ត្រលោកចាត់ទុកថា «យុគមាសនៃអក្សរសិល្ប៍» ទៀតផង។ សម័យក្រោយអង្គរប្រជារាស្ត្រខ្មែរបានធ្លាក់ក្នុងវិបត្តិផ្លូវចិត្ត ភ័យខ្លាច តក់ស្លុត ព្រាត់ប្រាស់គ្រួសារ ទុក្ខសោកញាំញីជារឿយៗ។ ត្រង់នេះជាឱកាសមួយដ៏ល្អនៃលទ្ធិពុទ្ធសាសនាបានពង្រីកខ្លួនឱ្យកាន់តែខ្លាំងក្នុងសង្គមខ្មែរ។ ពុទ្ធសាសនាបានឈានជើងចូលក្នុងសង្គមខ្មែរតាំងពីសម័យមុនអង្គរម្ល៉េះក្រោមទម្រង់ជាមហានិកាយ។ ប៉ុន្តែក្រោយការដួលរលំនៃអាណាចក្រអង្គរ សាសនាព្រាហ្មណ៍ដែលគោលសាសនាមួយដែលទ្រទ្រង់សម័យអង្គរឱ្យរឹងមាំនោះក៏បានសាបសូន្យផងដែរ។ ស្ថិតក្នុងរង្វង់នៃឥទ្ធិពលពុទ្ធសាសនានេះ អក្សរសិល្ប៍សម័យក្រោយអង្គរ ឬសម័យកណ្ដាលចង់ឬមិនចង់ ក៏គង់តែទទួលឥទ្ធិពលនេះដោយខានពុំបាន។ លក្ខណៈពិសេសមួយរបស់អក្សរសិល្ប៍ ពុទ្ធសាសនានោះគឺ ការលួងលោម និងផ្ដេកផ្ដួលឱ្យមនុស្សជឿលើបុណ្យបាប កម្មផល សាងល្អទទួលបានផលល្អ សាងអាក្រក់ទទួលបានផលអាក្រក់ នូវអំពើដែលបុគ្គលម្នាក់ៗបានប្រព្រឹត្តខ្លួនឯងពីបច្ចុប្បន្នជាតិ ពីអតីតជាតិ ប្រការនេះវាបានចូលរួមចំណែកបន្ធូរបន្ថយភាពតានតឹងអារម្មណ៍ប្រជាជនខ្មែរឱ្យសាយផុតពីទុក្ខកង្វល់ ភាពរញ៉េរញ៉ៃញាំញីនៃវិបត្តិសង្គមជាតិ។ តែនេះមិនមែនជាមុខងារតែមួយគត់របស់អក្សរសិល្ប៍ពុទ្ធនិយមនោះទេ បើយើងស្រាយរាំងននៃទ្រឹស្ដីពុទ្ធសាសនា យើងនឹងឃើញលំហនៃទស្សនវិជ្ជាខ្មែរក្នុងការអប់រំ និងទិដ្ឋភាពតថភាពនៃសង្គមមនុស្សនាសម័យនោះតាមរយៈផ្ទៃរឿង។

អក្សរសិល្ប៍ពុទ្ធសាសនាដែលអ្នកនិពន្ធលើកយករឿងបុណ្យបាប កម្មផលល្អអាក្រក់ធ្វើឱ្យមនុស្សចេះខ្លាចអំពើបាបដែលយើងឃើញជាក់ស្ដែងក្នុងអក្សរសិល្ប៍ពុទ្ធនិយម។ ហើយរឿងទាំងឡាយរៀបរៀងជាភាសាបាលី ក្រោយមកគេបានប្រែសម្រួលមកសម្រាយជាខេមរភាសាហើយដែលសរសេរជាពាក្យកាព្យមានអត្ថបទសរសេរជាពាក្យរាយគេច្រើនឱ្យឈ្មោះថា រឿងជាតក ឬគម្ពីរជាតកមានគម្ពីរបញ្ញាសជាតក គម្ពីនានាជាតកជាដើម។

ព្រះពុទ្ធសាសនាមានដើមកំណើតនៅប្រទេសឥណ្ឌាក្នុងសតវត្សទី៦មុនគ្រិស្តសករាជ។ មុនគ្រិស្តរាជក្នុងរាជកាលព្រះបាទអសោកព្រះពុទ្ធសាសនាបានផ្សព្វផ្សាយពេញប្រទេសឥណ្ឌា និងនៅក្រៅប្រទេសផងដែរ។ តាមប្រវត្តិសាស្ត្រកន្លងមកគេបានដឹងថានៅពុទ្ធសតវត្សទី៣ មុនព.ស.២៣៨ គ.ស. ៣០០ឆ្នាំម្លេះ ព្រះបាទអសោក ពុទ្ធសាសនិកដ៏ឆ្នើមនៅប្រទេសឥណ្ឌាបានបញ្ជូនសមណទូតពីរអង្គ និងព្រះឧត្ដមត្ថេរ នាំយកពុទ្ធសាសនាថេរវាទមកផ្សាយនៅសុវណ្ណភូមិអាស៊ីអាគ្នេយ៍។ ស្ថាបនិកនៃព្រះពុទ្ធសាសនាគឺព្រះពុទ្ធគោតម៥៦៤-៤៨មុនគ.ស.។ អក្សរសិល្ប៍ពុទ្ធនិយទទួលឥទ្ធិពលពី ព្រះពុទ្ធសាសនា។ រឿងក្នុងគោលពុទ្ធនិយមមានលក្ខណៈខុសប្លែកពីគោលព្រាហ្មណ៍សាសនា គោលគំនិតជំមូលបញ្ហាក្នុងរឿងពុទ្ធនិយម គឺការកសាងបារមីរបស់ព្រះពោធិសត្វដើម្បីបានត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធ។

ដំណោះស្រាយក្នុងរឿងពុទ្ធនិយមគឺ អហិង្សា ឬសន្តិវិធី។ រីឯតួអង្គឯកប្រុសជាព្រះពោធិសត្វ និងតួអង្គឯកស្រីជាកន្សែសារពេជ្ញ។ ចុងបញ្ចប់នៃរឿងគឺការសជាតិរឿងក្នុង

អក្សរសិល្ប៍ពុទ្ធនិយមមានពីរបែបគឺ រឿងពុទ្ធនិយមសុទ្ធសាធ និងរឿងពុទ្ធនិយមក្លាយ។ ចំពោះអក្សរសិល្ប៍ពុទ្ធនិយម គឺជាស្នាដៃដែលមានតម្លៃអប់រំយ៉ាងសំខាន់សម្រាប់សង្គមជាតិ។

ថ្វីត្បិតតែនៅសម័យនេះសង្គមខ្មែរយើង មានការវិវត្តន៍ទៅមុខយ៉ាងជឿនលឿនយ៉ាងណាក៏ដោយ សង្គមខ្មែរមិនអាចប្រានចោលការសិក្សាបែបក្បួនខ្នាតអប់រំពីសម័យមុនបានដែលមានតាំងពីបុរាណកាលមកក្នុងនោះរួមមាន ពាក្យស្លោក សុភាសិត រឿងព្រេង ល្ខោននិយាយ កំណាព្យ រឿងក្នុងអក្សរសិល្ប៍ជាដើម ដែលបុព្វបុរសយើងបានចងក្រងឡើងក្នុងគោលបំណងអប់រំដល់កុលបុត្រកុលធីតាកូនចៅជាច្រើនជំនាន់បានសិក្សាបន្ត។ ជាក់ស្តែងដូចជាវិស័យអប់រំនៅក្នុងសតវត្សទី២១ យើងឃើញថារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានខិតខំបន្តការកែទម្រង់វិស័យអប់រំគ្រប់កម្រិតនៅកម្ពុជានៅក្នុងប៉ុន្មានឆ្នាំនេះយើងឃើញគោលនយោបាយ និងបទបញ្ញត្តិបានអនុវត្តន៍ឡើងដើម្បីបង្កើតគុណភាពនៃការអប់រំឱ្យកាន់តែល្អប្រសើរឡើងមានភាពងាយស្រួល ប្រសិទ្ធភាព បរិយាប័ន្ន និងតម្លាភាពពីព្រោះការអភិវឌ្ឍន៍ធនធានមនុស្សនៅក្នុងប្រទេសកម្ពុជា។ ការសិក្សាបែបបច្ចេកទេសវិទ្យាសាស្ត្រ និងការអភិវឌ្ឍផ្នែកសេដ្ឋកិច្ចក្នុងយុគសម័យមាសឌីជីថល។ ទោះជាយ៉ាងណាក៏ដោយការសិក្សាអំពីអក្សរសិល្ប៍ក៏នៅមានប្រជាប្រិយភាពនៅគ្រប់សម័យកាលទាំងអស់ ពីព្រោះនៅក្នុងស្នាដៃអក្សរសិល្ប៍នីមួយៗ អ្នកនិពន្ធបានចងក្រងលាតត្រដាងឱ្យមនុស្សយើងគ្រប់គ្នាបានមើលឃើញពីតថភាពពិតជាក់ស្តែងនៅក្នុងសង្គមជាតិទាំងមូល និងបានសិក្សាពីតម្លៃនៃជីវិតរស់នៅដែលអ្នកនិពន្ធបានជួបប្រទះផ្ទាល់ខ្លួន ដោយការប្រើប្រាស់សិល្បវិធីខ្ពស់ និងភាពយ៉ាងប៉ិនប្រសព្វក្នុងការអប់រំដាស់តឿនដល់មនុស្សគ្រប់រូបឆ្លុះបញ្ចាំងតាមរយៈស្នាដៃរបស់ខ្លួន។ ដោយមើលឃើញពីភាពប៉ិនប្រសព្វ និងអស្ចារ្យរបស់អ្នកនិពន្ធស្នាដៃអក្សរសិល្ប៍ពុទ្ធនិយមបែបនេះហើយ ទើបបានជាស្ទេរបានចងក្រងជាសៀវភៅនេះឡើងក្រោមប្រធានបទ "តម្លៃអប់រំអក្សរសិល្ប៍ពុទ្ធនិយមក្រោយសម័យអង្គរ"។

ហើយស្នាដៃនិពន្ធមួយនេះ មានកង្វះខាតពិតមែនស្ទេររង់ចាំទទួលការរិះគន់ពីមិត្តអ្នកអានទាំងអស់គ្រប់ពេលវេលាដើម្បីស្ថាបនាកែលម្អ និងទទួលការស្វាគមន៍ដោយក្តីរីករាយ។ នៅត្រង់ណាដែលមានកង្វះខាតខុសឆ្គង យើងខ្ញុំពិចារណារកផ្លូវដោះស្រាយទាំងអស់គ្នាក្នុងបុព្វហេតុនៃការស្រាវជ្រាវឱ្យមានការរីកចម្រើនជឿនលឿនទៅមុខ។ ស្ទេរនៅរង់ចាំទទួលយកនូវការរិះគន់ស្ថាបនាដើម្បីឱ្យវាល្អប្រសើរជាងមុនទាំងអស់គ្នាដោយក្តីរីករាយ ព្រោះវាជាគុណតម្លៃសម្រាប់ស្ទេរបែបវិទ្យាសាស្ត្រសង្គមខាងជំនាញអក្សរសាស្ត្រខ្មែរមួយផងដែរ។

## ១.២. បញ្ហានៃការស្រាវជ្រាវ

យើងបានដឹងហើយថាអក្សរសិល្ប៍ពុទ្ធនិយម បានផ្សារភ្ជាប់ស្ថិតនៅក្នុងផ្នត់គំនិតរបស់ប្រជាជនខ្មែរ និងមានឥទ្ធិពលយ៉ាងខ្លាំងនៅក្នុងការរស់នៅរបស់មនុស្សខ្មែរសម័យបុព្វកាល ព្រមទាំងគ្រប់សម័យកាលទាំងអស់ដែលយើងបានឃើញរហូតមកដល់បច្ចុប្បន្ននេះមិនចេះសាបសូន្យបាន ពីព្រោះវាជាអត្តសញ្ញាណជាតិខ្មែរ ដួងព្រលឹងរបស់ជាតិខ្មែរ ប៉ុន្តែសាសនាមួយចំនួនក៏ត្រូវបានស្ទើរសាបសូន្យផងដែរពីចិត្តគំនិតមនុស្សលោកសម័យថ្មីនេះ ហើយក៏មានសាសនាមួយចំនួនទៀតត្រូវបានជនទុចរិតយកទៅកេងប្រវ័ញ្ចក្លែងបំពុលដល់សង្គម ធ្វើឱ្យសាសនាអាប់ឱនហើយជនទាំងនេះបានទាញយកផលប្រយោជន៍ផ្ទាល់ខ្លួន និងនាំទុក្ខដល់បុគ្គលផ្សេងៗទៀត ក៏ជាឱកាសក្នុងការធ្វើអាជីវកម្មដើម្បីផលប្រយោជន៍របស់ខ្លួនប្រសិនបើប្រជាជនខ្មែរយើងមិនបានគិតវែងឆ្ងាយថែរក្សាទុកមុន និងដាក់ចិត្តជឿទៅលើអ្វីមួយដែលឥតហេតុផលជឿលើកម្លាំងក្រៅខ្លួនណាមួយនេះទេ។ ទោះបីជាយ៉ាងនេះក្តីក៏សាសនានៅតែមានសារៈសំខាន់ ព្រោះថាសាសនាជាផ្នែកមួយនៃអត្តសញ្ញាណជាតិខ្មែរ ជាពិសេសជាដួងព្រលឹងរបស់បុព្វបុរសសម្រាប់ឱ្យអ្នកសិក្សាបានជ្រោតជ្រាបដើមកំណើតរបស់មនុស្សជាតិ ដើម្បីការអភិវឌ្ឍន៍ឱ្យកាន់តែរីកចម្រើន ការអភិរក្សនិងលើកស្ទួយសាសនាវប្បធម៌ជាតិរបស់ខ្លួនគ្រប់ៗសម័យកាលទាំងអស់។ ដោយឡែកបើយើងក្រឡេកមើលក្នុងស្នាដៃអក្សរសិល្ប៍ពុទ្ធនិយមវិញ បុព្វបុរសបានបង្ហាញអំពីតម្លៃអប់រំដល់មនុស្សគ្រប់ស្រទាប់វណ្ណៈទាំងអស់ដែលមាននៅក្នុងសង្គមមានដូចជា ឱ្យយើងជឿលើទស្សនៈកម្មផល ចេះខ្លាចចំពោះអំពើអកុសល ការចេះចែករំលែកធ្វើបុណ្យដាក់ទាន ជឿលើបុណ្យបាប ធ្វើល្អបានល្អធ្វើអាក្រក់បានផលអាក្រក់ ជឿថាមានឋាននរកប្រែត ឋានសួគ៌កើតចាស់ឈឺការស្លាប់ ហើយមានការមានការអន្ទោលជាតិចាប់កំណើតជាថ្មីមកវិញជាដើម។

ការសិក្សាលើប្រធានបទតម្លៃអប់រំអក្សរសិល្ប៍ពុទ្ធនិយមក្រោយសម័យអង្គរ គឺការសិក្សាស្វែងយល់ពីបញ្ហាដូចជា៖

១. តើតម្លៃអប់រំមានវត្តមាននៅក្នុងស្នាដៃអក្សរសិល្ប៍ពុទ្ធនិយមក្រោមរូបភាពណាខ្លះ?

២. តើតម្លៃអប់រំមានឥទ្ធិពលបែបណាខ្លះក្នុងការអប់រំដល់មនុស្សគ្រប់រូប?

៣.តើតម្លៃអប់រំរបស់អក្សរសិល្ប៍ពុទ្ធនិយមមានចំណុចវិជ្ជមាន និងអវិជ្ជមានដូចម្ដេចនៅក្នុងសង្គមខ្មែរដូចម្ដេច?

## ១.៣. វត្ថុបំណងនៃការស្រាវជ្រាវ

១.ដើម្បីសិក្សាស្វែងយល់ឱ្យកាន់តែច្បាស់ពីតម្លៃអក្សរសិល្ប៍ពុទ្ធនិយមខ្មែរ។

២.ដើម្បីយល់ដឹងពីតម្លៃអប់រំដែលមាននៅក្នុងស្នាដៃសាច់រឿងផ្សារភ្ជាប់និងសង្គមខ្មែរ។

## ១.៤. សំណួរស្រាវជ្រាវ

១. តើតម្លៃអប់រំរបស់អក្សរសិល្ប៍ពុទ្ធនិយមគឺជាអ្វី?

២. តើអក្សរសិល្ប៍ខ្មែរបង្កប់អត្ថន័យយ៉ាងដូចម្ដេចខ្លះ?

៣. តើតម្លៃអប់រំអក្សរសិល្ប៍ពុទ្ធនិយមខ្មែរផ្ដល់គុណតម្លៃអ្វីខ្លះ?

## ១.៥. សារៈសំខាន់នៃការស្រាវជ្រាវ

រាល់ប្រភេទស្នាដៃទាំងអស់ដែលអ្នកសិក្សាស្រាវជ្រាវគ្រប់ៗរូបបានខំព្យាយាមតស៊ូគ្រប់កាលៈទេសៈចំណាយទាំងពេលវេលា កម្លាំងកាយ កម្លាំងចិត្ត ទាំងពុទ្ធិដែលមាននៅក្នុងខ្លួនទាំងប៉ុន្មានបានប្រឹងប្រែងធ្វើអស់ពីសមត្ថភាពដើម្បីតាក់តែងរៀបចំចងក្រងប្រមូលឯកសារឡើង គឺសុទ្ធតែមានអត្ថប្រយោជន៍ទាំងអស់។ ទោះជាកិច្ចការស្រាវជ្រាវមួយនេះបរិមាណច្រើនក្ដី តិចក្ដីមានសារៈប្រយោជន៍ដល់អ្នកសិក្សាផ្ទាល់ និងអ្នកសិក្សាជំនាន់ក្រោយមានភាពងាយស្រួលក្នុងការសិក្សាស្វែងយល់បន្ថែម និងសង្គមមនុស្សផងដែរ។

ដូច្នេះការសិក្សាស្រាវជ្រាវចំពោះប្រធានបទមួយនេះគឺមានសារៈប្រយោជន៍យ៉ាងខ្លាំងដូចជា៖

- ចូលរួមចំណែកក្នុងការជួយការអភិរក្សលើកកម្ពស់គុណភាព និងតម្លៃអប់រំនៃអក្សរសិល្ប៍ពុទ្ធនិយម។
- ជួយមនុស្សឱ្យស្គាល់អំពើល្អអំពើអាក្រក់ និងជៀសវាងប្រព្រឹត្តិនូវអំពើជាអកុសលទាំងឡាយ
- ធ្វើឱ្យមនុស្សគ្រប់រូបបានយល់កាន់តែច្បាស់ នូវការអប់រំទូន្មាននៃព្រះពុទ្ធសាសនា យល់ច្បាស់នឹងសម្ព័ន្ធភាពយ៉ាងស៊ិជម្រៅរវាងព្រះពុទ្ធសាសនា និងសង្គមមនុស្សដោយមិនអាចញែកចេញពីគ្នាបានឡើយ។
- បង្ហាញឱ្យឃើញអំពីរូបនិម្មតិកម្មនៅក្នុងរឿងពុទ្ធនិយម ឬការបង្ហាញអត្តសញ្ញាណដែលជាភាពតំណាងរបស់ជាតិ។

## ១.៦. ដែនកំណត់នៃការស្រាវជ្រាវ

ដើម្បីឱ្យមានភាពងាយស្រួល និងច្បាស់លាស់ក្នុងការស្រាវជ្រាវលើប្រធានបទ "តម្លៃអប់រំអក្សរសិល្ប៍ពុទ្ធនិយមក្រោយសម័យអង្គរ" នាងខ្ញុំសូមធ្វើការវិភាគវែកញែក និងផ្ដោតសំខាន់ដោយពឹងផ្អែកទៅតាមវិធីសាស្ត្រស្រាវជ្រាវបែបគុណវិស័យ ការប្រមូលឯកសារប្រជុំរឿងពុទ្ធនិយម ... ដោយធ្វើការសិក្សាទៅលើតម្លៃអប់រំអក្សរសិល្ប៍ពុទ្ធនិយមក្រោយសម័យអង្គរតាមរយៈស្នាដៃអក្សរសិល្ប៍ពុទ្ធនិយម ទសជាតក ឬពុទ្ធនិយមសុទ្ធ ពុទ្ធនិយមក្លាយ ឬបញ្ញាសជាតក ពុទ្ធនិយមក្លាយហួសហេតុ ឬ នានាជាតក នៃរឿងនីមួយៗមកបង្ហាញ។ យើងសូមលើកយកនូវរឿងចំនួនម្ភៃប្រាំរឿង មកឆ្លុះបញ្ចាំងជាតួយ៉ាងនៃអក្សរសិល្ប៍ពុទ្ធនិយមដោយអក្សរសិល្ប៍ពុទ្ធនិយមសុទ្ធយើងលើកយក ប្រាំពីររឿងមាន ទសជាតក រឿង មហាជនក រឿង

សុវណ្ណសាម រឿង នេមិយ រឿង មហោសថ រឿង ភូរិទត្ត រឿង ចន្ទកុមារ និង រឿង ព្រះវេស្សន្តរ ដោយហេតុរឿងទាំងនេះពេញនិយមមានរឿងពីរគូរនៅលើវត្តអារាមនាសម័យកណ្តាល។ រីឯអក្សរសិល្ប៍ពុទ្ធនិយមក្លាយយើងសូមលើកយក ប្រាំបី រឿងមាន រឿង ព្រះសុធនកុមារ រឿង ទុលកបណ្ឌិត រឿង ទុកម្មានិកៈ រឿង សុវណ្ណកុមារ រឿង វត្តង្គលិរាជ រឿង សេតបណ្ឌិត រឿង វិបុលតិត្តិ រឿងទេវន្ទមកឆ្លុះបញ្ចាំង។ ចំណែកឯអក្សរសិល្ប៍ពុទ្ធនិយមក្លាយហួសហេតុយើងសូមលើកយក ដប់ រឿងមាន រឿង ហង្សយន្ត រឿង ខ្យងសង្ខ រឿង សង្ខសិល្បជ័យ រឿង មរណមាតា រឿង កាកី រឿង ចៅស្រទបចេក រឿង ពុទ្ធិសែននាងកង្រី រឿង ព្រះគោព្រះកែវ រឿង ក្រុងសុភមិត្រ រឿង ទេវន្ទមកឆ្លុះបញ្ចាំងតែប៉ុណ្ណោះ។

## ១.៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ក្នុងការស្រាវជ្រាវដែលទទួលបានលទ្ធផលល្អ គឺអាស្រ័យទៅលើភាពមានសណ្តាប់ធ្នាប់ និងរបៀបរៀបរយនៃកិច្ចការនោះ។ ដូច្នេះដើម្បីឱ្យការសិក្សាស្រាវជ្រាវមួយនេះប្រព្រឹត្តទៅបានដោយរលូនមានភាពងាយស្រួល និងមានសណ្តាប់ធ្នាប់ល្អផងនោះនាងខ្ញុំបានដាក់កិច្ចការស្រាវជ្រាវជាផ្នែកៗទៅតាមរចនាសម្ព័ន្ធនៃជំពូកនីមួយៗដូចខាងក្រោម៖

- ជំពូក១ សេចក្តីផ្តើម៖ ស្ថិតនៅក្នុងជំពូកនេះ គឺជាផ្នែកសំខាន់មួយដែលមានការរៀបរាប់អំពីលំនាំដើមនៃកាស្រាវជ្រាវ បញ្ហានៃការស្រាវជ្រាវ វត្ថុបំណងនៃការស្រាវជ្រាវ សំណួរនៃការស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ ដែនកំណត់នៃការស្រាវជ្រាវ និង រចនាសម្ព័ន្ធនៃការស្រាវជ្រាវ។
- ជំពូក២ ការរំលឹកទ្រឹស្តី៖ គឺជាជំពូកមួយបង្ហាញអំពីនិយមន័យមូលដ្ឋានទ្រឹស្តីក្នុងការសិក្សាទៅលើប្រធានបទដែលមានជាប់ទាក់ទងទៅនឹងទ្រឹស្តីទាំងអស់ដែលបានដាក់បញ្ចូលនៅក្នុងជំពូកនេះគឺជាដើមទុន ឬជាមូលដ្ឋានទស្សនៈមួយសម្រាប់ធ្វើជាទីអាងសម្រាប់វិភាគទិន្នន័យដែលបានប្រមូលបាន។
- ជំពូក៣ វិធីសាស្ត្រស្រាវជ្រាវ៖ ចំពោះជំពូកនេះ គឺជាជំពូកមួយដែលបានបង្ហាញអំពីវិធីសាស្ត្រផ្សេងៗក៏ដូចជាដំណើរកានៃការស្រាវជ្រាវដែលមានចំណុចគោលដូចជា ប្រភេទនៃការស្រាវជ្រាវតាមបែបគុណវិស័យ វិធីសាស្ត្រស្រាវជ្រាវតាមបែបបរិមាណវិស័យ មធ្យោបាយសម្ភារប្រមូលព័ត៌មាន ដំណើរការនៃការប្រមូលទិន្នន័យ និងការវិភាគទិន្នន័យ។
- ជំពូក៤ ការវិភាគទិន្នន័យលទ្ធផល៖ ក្នុងជំពូកនេះគឺជាជំពូកដ៏សំខាន់មួយទៀតដែលយើងត្រូវការធ្វើការសិក្សាស្រាវជ្រាវលើប្រធានបទដើម្បីស្វែងរកឱ្យឃើញពីទំនាក់ទំនងរវាងមនុស្ស និងសាសនាតំណាងពុទ្ធសាសនានៅក្នុងអក្សរសិល្ប៍ពុទ្ធនិយម។
- ជំពូក៥ ពិភាក្សាលិទ្ធិផលស្រាវជ្រាវ៖ លទ្ធិផលស្រាវជ្រាវនៅក្នុងជំពូកនេះទទួលបានមកពីជំពូកខាងលើ ក្រោយដែលវិភាគទិន្នន័យរួច។ ក្នុងនោះនាងខ្ញុំបានរកឃើញទំនាក់ទំនងគ្នាយ៉ាងជិតស្និតរវាងមនុស្សនិងសាសនានិងដែលមាននៅក្នុងរឿងពុទ្ធនិយម។
- ជំពូក៦ ការសន្និដ្ឋាន៖ ត្រង់នេះគឺជាជំពូកមួយដែលបង្ហាញអំពីការធ្វើសេចក្តីសន្និដ្ឋានចុងក្រោយទៅលើការសិក្សាប្រធានបទទាំងមូល និងធ្វើការវិភាគរួចរាល់ព្រមទាំងផ្តល់អនុសាសន៍ចុងក្រោយ

# ជំពូក ២ រំលឹកទ្រឹស្តី

## ២.១. និយមន័យអក្សរសិល្ប៍

### ក.តាមន័យជាតិសព្ទ

អក្សរសិល្ប៍ < អក្សរ + សិល្ប៍ ឬសិល្បៈ

អក្សរ ៖ ស្នាមគំនូសដែលគូសសម្រាប់កត់ត្រាភាសា បង្កើត ឡើងដោយក្រុមមនុស្ស។

សិល្ប៍ ឬសិល្បៈ ៖ ជាការតាក់តែង ការរចនា ឆ្លាក់ គូរ ច្រៀងរាំ។

បើតាមវចនានុក្រមខ្មែរបានផ្តល់និយមន័យចំពោះពាក្យ «អក្សរ» និង«សិល្ប៍»ជាមុនថា

អក្សរ (ន.)(សំ.បា.)អក្ខរៈ។ រីឯសិល្ប៍ (ន) (សំ.បា. សិប្បៈ) សិល្បៈ។ ហេតុនេះគេអាចទាញបានថា «អក្សរសិល្ប៍»ជាសិល្បៈនៃការប្រើប្រាស់តួអក្សរដើម្បីបង្កើតទៅជាសាច់រឿង។

ពាក្យ "អក្សរសិល្ប៍ នេះ ត្រូវនឹងពាក្យក្នុងភាសាបារាំង "littérature" និងពាក្យក្នុងភាសាអង់គ្លេសថា "literature" ដែលបានមកពីពាក្យនៃភាសាឡាតាំងថា "littératura" (ដែលមានន័យថា សំណេរ)។

អក្សរសិល្ប៍ជាសព្ទមួយ ដែលមាននិយមន័យទីទៃពីគ្នាដ៏ច្រើន ពីសំណាក់អ្នកសិក្សាខាងវិជ្ជាមួយនេះតែប្រសិនបើយោងតាមវចនានុក្រមខ្មែរ បោះពុម្ពគ្រាទី៥នៅឆ្នាំ១៩៦៧បានបង្ហាញថា៖

អក្សរសិល្ប៍ អក្សរ+សិល្ប៍

- អក្សរស្នាមគំនូសមានស្នាមផ្សេងៗសម្រាបប្រើសរសេរកត់ត្រាពាក្យសក្តិ និងសម្តីទាំងពួងមិនចេះអស់។
- សិល្ប៍សំដៅដល់ការរចនាតាក់តែងដ៏វិចិតផ្សេងៗ។ ខ្មែរច្រើហៅចំមន្តអគមផ្សេងៗមតិជារួមមកវិញអក្សរសិល្ប៍គឺជាការសិក្សាអំពីតថៈភាពសង្គម ផ្នត់គំនិត សកម្មភាព និងសង្គមមនុស្សទាំងមូល តាមរយៈពាក្យពេចន៍ដ៏មានសោភ័ណ ជីវភាពរស់នៅរបស់មនុស្ស និងអព្ភន្តរញ្ញាណ ដែលបង្កើតបានជាកម្រងស្នាដៃអក្សរសិល្ប៍ដ៏ពេញនិយមរស់ររើកគ្រប់សម័យកាលគ្រប់ស្រទាប់វណ្ណៈហើយស្នាដៃមានច្រើនប្រភេទ។

អក្សរសិល្ប៍សំដៅលើស្នាដៃនិពន្ធ ជាពិសេស ស្នាដៃសិល្បៈដែលចាត់ទុកថាមានឧត្តមភាព ឬយូរអង្វែង។ នេះរួមបញ្ចូលទាំងកំណាព្យ កំណាព្យ រឿងល្ខោន និងការតែងនិពន្ធ។

### ខ.តាមន័យទស្សនៈ

ចំពោះនិយមន័យអក្សរសិល្ប៍នេះ មានទស្សនៈជាច្រើនផ្សេងៗគ្នា។

១. ទសសនៈលោក អេដេនឡាប្រេនី ៖លោកបានឱ្យនិយមន័យទៅលើអក្សរសិល្ប៍ថា "អក្សរសិល្ប៍ជាមែកធាងមួយនៃសិល្បៈ"។

២. ទសសនៈលោក សង់ប៉ូសាត លោកបានឱ្យនិយមន័យទៅលើអក្សរសិល្ប៍ថា អក្សរសិល្ប៍ គឺជាការបញ្ចេញគំនិតទាក់ទង ដោយអារម្មណ៍ មនោសញ្ចេតនា មតិ និងដោយពាក្យសម្តី ជាសម្លេងកត់ត្រា ទុកដើម្បីជាមធ្យោបាយធ្វើសកម្មភាពផង និងជាសិល្បៈផង"។

៣. ទសសនៈលោក កេង វ៉ាន់សាក់ លោកបានឱ្យនិយមន័យថា "អក្សរសិល្ប៍ជាវិទ្យាស្ង់ដែល

ចោទ និងដោះស្រាយបញ្ហាមនុស្សទៅតាមសង្គមនីមួយៗ និង ដោយសិល្ប៍វិធី"។

៤. ទសសនៈ ម៉ាក្ស-លេនីន លោកបានឱ្យនិយមន័យថា 'អក្សរសិល្ប៍ជាមធ្យោបាយដ៏ស្តួចស្តើង វិសេសវិសាល សម្រាប់យល់ដឹងពីតថភាពសង្គម និងជាកត្តាសំខាន់មួយនៃជីវភាពរស់នៅ"។

៥. លោក ម៉ាស៊ីម ក័រគី បានផ្តល់និយមន័យចំពោះអក្សរសិល្ប៍ថា«អក្សរសិល្ប៍ជាការសិក្សាពីមនុស្ស»។

៦. លោក ..ធ សោ «អក្សរសិល្ប៍ជាវិទ្យាសាស្ត្រមួយសិក្សាពីមនុស្សដោយលើកយកបញ្ហាមនុស្សមក ចោទ និងដោះស្រាយតាមសិល្បៈរូបារម្មណ៍»។

៧. ស្តង់ដាល់ «អក្សរសិល្ប៍គឺជាកញ្ចក់ដែលគេដាក់តាមដងផ្លូវ»។ ពាំនោលនេះបានន័យសេចក្តីថា អក្សរសិល្ប៍បានឆ្លុះបញ្ចាំងឱ្យឃើញនូវរាល់សកម្មភាពទាំងឡាយដែលបានឆ្លងកាត់វា។ អក្សរសិល្ប៍ ជាសិល្បៈនៃការប្រើប្រាស់តួអក្សរប្រកបទៅដោយសិល្បៈក្នុងការសម្តែងនូវអារម្មណ៍ចិត្តគំនិតព្រលឹងស្មារតី។

ជាមតិរួមអក្សរសិល្ប៍ជាកញ្ចក់សម្រាប់បំភ្លឺផ្លូវ សម្រាប់មនុស្សក្នុងការមើលឃើញពីគតិភាពសង្គមដែលបានកើតឡើងនៅគ្រប់សម័យកាល ទាំងការរស់នៅរបស់មនុស្ស ជីវភាពរស់នៅប្រចាំថ្ងៃ បង្ហាញឃើញស្នាដៃរបស់អ្នកនិពន្ធគ្រប់សម័យកាល ទិដ្ឋភាពក្នុងប្រវត្តិសាស្ត្រក្នុងការដឹកនាំបានទាំងអស់។

៨. Matthew Arnold៖Arnold បានចាត់ទុកអក្សរសិល្ប៍ថាជាមធ្យោបាយនៃការសម្រេចបាននូវ “អ្វីដែលល្អបំផុតដែលបានគិតនិងនិយាយ” នៅក្នុងពិភពលោកដោយសង្កត់ធ្ងន់លើតួនាទីរបស់វាក្នុងការអភិវឌ្ឍសីលធម៌និងបញ្ញា។

៩.អេលីយ៉ូត៖ • Eliot ជឿថាអក្សរសិល្ប៍គួរត្រូវបានវាយតម្លៃដោយផ្អែកលើសមត្ថភាពបង្កើតទំនាក់ទំនងរវាងអតីតកាល និងបច្ចុប្បន្ន ដោយលើកហេតុផលថាអក្សរសិល្ប៍ដ៏អស្ចារ្យឆ្លងកាត់ពេលវេលា និងមានឥទ្ធិពលលើការងារនាពេលអនាគត។

១០.Northrop Frye៖ • Frye បានស្នើថាអក្សរសិល្ប៍គួរតែត្រូវបានយល់តាមរយៈ archetypes និង genres ដែលបង្ហាញថាស្នាដៃអក្សរសិល្ប៍ឆ្លុះបញ្ចាំងពីគំរូសកលនៃបទពិសោធន៍របស់មនុស្ស។

១១.លោក Mikhail Bakhtin៖ • Bakhtin បានសង្កត់ធ្ងន់លើលក្ខណៈសន្ទនានៃអក្សរសិល្ប៍ ដោយស្នើថាអត្ថបទមានអន្តរកម្មជាប់លាប់ជាមួយអត្ថបទ និងបរិបទវប្បធម៌ផ្សេងទៀត ដោយបញ្ជាក់ពីសារៈសំខាន់នៃសំឡេង និងទស្សនៈ។

១២.Roland Barthes៖• Barthes បានណែនាំគំនិតនៃ “ការស្លាប់របស់អ្នកនិពន្ធ” ដោយលើកហេតុផលថា អត្ថន័យនៃអត្ថបទត្រូវបានបង្កើតឡើងដោយការបកស្រាយរបស់អ្នកអានជាជាងចេតនារបស់អ្នកនិពន្ធ។

១៣.Julia Kristeva៖ • គំនិតរបស់ Kristeva នៃអន្តរអត្ថបទសង្កត់ធ្ងន់ថា អត្ថបទទាំងអស់មានទំនាក់ទំនងគ្នាទៅវិញទៅមក និងមានឥទ្ធិពលដោយអត្ថបទផ្សេងទៀត ដែលប្រកួតប្រជែងនឹងគំនិតប្រពៃណីនៃភាពជាអ្នកនិពន្ធ និងប្រភពដើម។

១៤.Terry Eagleton៖• Eagleton រិះគន់សញ្ញាណនៃអក្សរសិល្ប៍ថាជាប្រភេទដាច់ស្រយាល ដោយជជែកវែកញែកអំពីវិមាត្រសង្គម-នយោបាយ និងតួនាទីរបស់វាក្នុងការឆ្លុះបញ្ចាំង និងបង្កើតមនោគមវិជ្ជាវប្បធម៌។

១៥.Cleanth Brooks៖ • Brooks បានផ្តោតលើធាតុផ្លូវការនៃអក្សរសិល្ប៍ គស្ស៊ូមតិសម្រាប់ការអានយ៉ាងជិតស្និទ្ធ និងការវិភាគនៃអត្ថបទដោយផ្អែកលើរចនាសម្ព័ន្ធផ្ទៃក្នុង និងអត្ថន័យជាជាងបរិបទខាងក្រៅ។

ជាមតិរួមអក្សរសិល្ប៍ជាកញ្ចក់សម្រាប់បំភ្លឺផ្លូវសម្រាប់មនុស្សក្នុងការមើលឃើញពីគតិភាពសង្គមដែលបានកើតឡើងនៅគ្រប់សម័យកាល ទាំងការរស់នៅរបស់មនុស្ស ជីវភាពរស់នៅប្រចាំថ្ងៃ បង្ហាញឃើញស្នាដៃរបស់អ្នកនិពន្ធគ្រប់សម័យកាល ទិដ្ឋភាពក្នុងប្រវត្តិសាស្ត្រក្នុងការដឹកនាំបានទាំងអស់។ ជាមតិរួមអក្សរសិល្ប៍គឺជាគំនិតពហុមុខ ដែលត្រូវបានបកស្រាយតាមវិធីផ្សេងៗដោយអ្នកប្រាជ្ញទូទាំងវិញ្ញាសា។ និយមន័យ និងទស្សនៈទាំងនេះបង្ហាញពីភាពស្មុគស្មាញនៃអក្សរសិល្ប៍ជាទម្រង់សិល្បៈដែលឆ្លុះបញ្ចាំងពីបទពិសោធន៍របស់មនុស្ស តម្លៃវប្បធម៌ និងការសាកសួរទស្សនវិជ្ជា។ ការសិក្សាអក្សរសិល្ប៍នៅតែបន្តវិវឌ្ឍនៅពេលដែលមានទស្សនៈថ្មីៗបានផុសឡើង ពង្រីងការយល់ដឹងរបស់យើងអំពីអ្វីជាអក្សរសិល្ប៍ និងសារៈសំខាន់របស់វានៅក្នុងសង្គម។

## ២.២. និយមន័យអក្សរសិល្ប៍ពុទ្ធនិយ

### ក.តាមន័យជាតិសព្ទ

អក្សរសិល្ប៍ពុទ្ធនិយមនិយ អក្សរសិល្ប៍+ ពុទ្ធនិយម

ពុទ្ធនិយម > ពុទ្ធ + និយម

ពាក្យ «ពុទ្ធ» មានន័យថា លោកអ្នកត្រាស់ដឹងធម៌ ដែលកំបាំងដូចយ៉ាងអរិយសច្ចៈ៤ជាដើម រហូតដល់មគ្គផលនិព្វាន ឬលោកអ្នកភ្ញាក់រឭក គឺមានសតិសម្បជញ្ញៈសព្វកាល ឬលោកអ្នករីកេញទីដូចជាផ្កាឈូក ដែលរីកគ្រប់ស្រទាប់ គឺមានព្រះហឫទ័យដោយអំណាចនៃបរិសុទ្ធ ព្រោះកម្ចាត់កិលេសអស់ហើយ (ព្រះសម្មាសម្ពុទ្ធ) : ព្រះពុទ្ធ, ព្រះពុទ្ធជាបរមគ្រូ, ព្រះពុទ្ធជាម្ចាស់។»3
ពាក្យ និយម មានន័យថា សេចក្ដីកំណត់ ធម្មតា ធម្មជាតិ អនុលោមតាម។

«ពុទ្ធនិយម» ៖ មានន័យសេចក្ដីសំដៅដល់ ជំនឿនៃការនិយមរាប់អានព្រះពុទ្ធ ឬព្រះពុទ្ធសាសនា ដោយកាយ វិចា ចិត្ត។

ដូចនេះ អក្សរសិល្ប៍ពុទ្ធនិយម គឺជាកម្រងស្នាដៃអក្សរសិល្ប៍ដែលលើកនិទានអំពីព្រះពុទ្ធ អង្គនូវអតីតជាតិនានារបស់ព្រះអង្គមានទសជាតក បញ្ញាសជាតក និងហារយជាតកជាដើម។

### ខ.តាមន័យទស្សនៈ

អ្នកកប្រាជ្ញបានចូលទៅជិតអក្សរសិល្ប៍ពុទ្ធនិយមតាមទស្សនៈផ្សេងៗគ្នា រួមទាំងប្រវត្តិសាស្ត្រ អត្ថបទ ទស្សនៈវិជ្ជា និងការវិភាគប្រៀបធៀប។ ខាងក្រោមនេះគឺជាអ្នកប្រាជ្ញល្បីៗមួយចំនួន និងទស្សនៈរបស់ពួកគេលើអក្សរសាស្ត្រពុទ្ធនិយម៖

១.លោកបណ្ឌិត ជ សោបានឱ្យនិយមន័យអក្សរសិល្ប៍ថា អក្សរសិល្ប៍គឺ ជាពាក្យបណ្ដាំពាក្យពេជន៍ ឃ្លាប្រយោគ។

២. ក្នុងវចនានុក្រមខ្មែរ បោះពុម្ពគ្រាទី៥នៅឆ្នាំ១៩៦៧ បានបង្ហាញថា៖ អក្សរសិល្ប៍ > អក្សរ + សិល្ប៍ អក្សរ ស្នាមគំនូសមានរាងផ្សេងៗសម្រាប់ប្រើសរសេរកត់ត្រាពាក្យសេចក្ដី និងសម្ដីទាំងពួងមិនចេះអស់។ សិល្ប៍ សំដៅដល់ការរចនាតាក់តែងដ៏វិចិត្រផ្សេងៗ។ ម្យ៉ាងទៀតខ្មែរច្រើនហៅចំមន្តអាគមផ្សេងៗ។ លោក កេង វ៉ាន់សាក់ (១៩២៥-២០០៨) នៅក្នុង ទិដ្ឋភាពខ្លះចំពោះអក្សរសិល្ប៍ខ្មែរ បានឱ្យនិយមន័យ អក្សរសិល្ប៍នេះថា អក្សរសិល្ប៍គឺជាវិទ្យាស្បង់ ដែលចោទ និងដោះស្រាយបណ្ដ នីមួយៗ និងដោយសិល្ប៍វិធី”។

៣. លោក លាង ហាប់អាន បានកំណត់និយមន័យនៃពាក្យអក្សរសិល្ប៍ថា ៖ “អក្សរសិល្ប៍ជាការសម្គាល់អត្ត សាស្ត្រដែលទាក់ទងនឹងផ្នែកផ្សេងៗនៃការតែងនិពន្ធដូចជា សទ្ទស្សន៍អក្សរសិល្ប៍ (បទ) ណមអ សិល្ប៍ (មនោគតិ) នាដ្យកម្មអក្សរសិល្ប៍ ឧបទេសអក្សរសិល្ប៍ ឧបារម្ភអក្សរសិល្ប៍ និងសុត្ថុះរាជា»និ លោកបណ្ឌិត ឆសោ បានឱ្យនិយមន័យអក្សរសិល្ប៍ថា ៖ “អក្សរសិល្ប៍ គឺជាពាក្យបណ្ឌិតជន៍ មា

ប្រយោគ”។

៤ .លោក កេងវ៉ាន់សាក់ ១៩២៥ ២០០៨ នៅក្នុង ទិដ្ឋភាពខ្លះនៅក្នុងអក្សរសិល្ប៍ខ្មែរ បានឱ្យនិយមន័យអក្សរសិល្ប៍ថា អក្សរសិល្ប៍គឺ ជាវិទ្យាស្បង់ ដែលចោទនិងដោះស្រាយបញ្ហាមនុស្សទៅតាមសង្គមនីៗមួយនិងដោយសិល្ប៍វិធី។

៥.លោក លាង ហាប់អាន បានកំណត់និយមន័យនៃអក្សរសិល្ប៍ថា អក្សរសិល្ប៍ជាការសម្គាល់អក្សរសាស្ត្រដែលទាក់ទងនិងផ្នែកផ្សេងៗនៃការតែងនិពន្ធដូចជា សន្ទស្សអក្សរសិល្ប៍ប្រភេទ ប្រលោមអក្សរសិល្ប៍ មនោគតិ នាដ្យកម្មអក្សរសិល្ប៍ ឱបទេសអក្សរសិល្ប៍ ឱបារម្ភអក្សរសិល្ប៍ និងសន្ទរកថា។

៦.តាមគណៈកម្មការភាសាវិទ្យា និងអក្សរសិល្ប៍បានកំណត់ថា អក្សរសិល្ប៍ជាផ្នែកមួយនៃអក្សរសាស្ត្រ ដែលអ្នកនិពន្ធលើកពីបញ្ហមនុស្ស បញ្ហសង្គមមកចោទ មកដោះស្រាយដោយប្រើសិល្បវិធី។

លោកហ្សង់ ប៉ូលសាត (១៩០៥ ១៩៨០) បានបញ្ចេញទស្សនៈនៅក្នុងការកំណត់និយម ន័យអក្សរសិល្ប៍នេះថា ៖ "អក្សរសិល្ប៍ គឺជាការបញ្ចេញមតិយោបល់ គំនិត ទាក់ទងគ្នាដោយអារម្មណ៍ សញ្ចេតនា តាមរយៈពាក្យសម្តី ដែលសរសេរកត់ត្រារឿងរ៉ាវអំពីមនុស្ស ដើម្បីជាមធ្យោ បាយសម្រាប់អនុវត្តសកម្មភាពផង និងសម្រាប់សម្តែងសិល្បៈផង។

៧.ចំពោះលោកម៉ាក់ស៊ីម គ័រគី (១៨៦៨-១៩៣៦) បានឲ្យនិយមន័យស្តីពីអក្សរសិល្ប៍ថា ៖ "អក្សសិល្ប៍ គឺជាមនុស្សវិទ្យា (ការសិក្សាពីមនុស្ស) ព្រោះមនុស្សដែលអក្សរសិល្ប៍បង្ហាញ និងឆ្លុះ បញ្ចាំងជាមនុស្សពេញលេញរស់រវើកមានជីវភាពផ្សារភ្ជាប់ទៅនឹងលក្ខណៈពិសេស ទំនាក់ទំនងទាំងឡាយណារបស់មនុស្សក្នុងតថភាពសង្គមជាក់ស្តែង"។

៨.ឯលោក ម៉ាក្ស លេនីន វិញបានកំណត់ថា ៖ "អក្សរសិល្ប៍សិល្បៈ ជាមធ្យោបាយដ៏ស្រួចស្រាវ បំផុត សម្រាប់យល់ដឹងពីតថភាពសង្គមជាក់ស្តែង និងជាកត្តាសំខាន់នៃជីវភាពសង្គម។ ចំណែកលោក ឆេនីនូវស្គី បានកំណត់ថា ៖ "អក្សរសិល្ប៍ជាអាវុធសម្រាប់សង្គមនិងជាកម្រងឯកសារនៃជីវិត"។

៩. ចំពោះលោក ស្តង់ដាល (១៧៨៣-១៨៤២) បានបញ្ជាក់ថា "អក្សរសិល្ប៍ជាកញ្ចក់ដែលគ ដាក់តាមដងផ្លូវ។

អ្នកប្រាជ្ញបានចូលទៅជិតអក្សរសិល្ប៍ពុទ្ធសាសនាតាមទស្សនៈផ្សេងៗគ្នា រួមទាំងប្រវត្តិសាស្ត្រ អត្ថបទ ទស្សនវិជ្ជា និងការវិភាគប្រៀបធៀប។ ខាងក្រោមនេះគឺជាអ្នកប្រាជ្ញល្បីៗមួយចំនួន និងទស្សនៈរបស់ពួកគេលើអក្សរសាស្ត្រពុទ្ធសាសនាៈ

១០. Edward Conze: អ្នកប្រាជ្ញជនជាតិអង់គ្លេសម្នាក់ដែលស្គាល់សម្រាប់ការងាររបស់គាត់លើព្រះពុទ្ធសាសនាមហាយាន Conze បានសង្កត់ធ្ងន់លើសារៈសំខាន់នៃអត្ថបទ Prajnaparamita ដែលពិភាក្សាអំពីគំនិតនៃភាពទទេ (śūnyatā) ។ គាត់បានចាត់ទុកអត្ថបទទាំងនេះថាជាចំណុចកណ្តាលនៃការយល់ដឹងអំពីទស្សនៈវិជ្ជាមហាយាន និងអត្ថន័យរបស់វាចំពោះការអនុវត្តព្រះពុទ្ធសាសនា។

១២. Gail Omori៖ Omori បានចូលរួមចំណែកក្នុងការសិក្សាអំពីព្រះពុទ្ធសាសនាជប៉ុន ជាពិសេសការងាររបស់ Dōgen និងប្រពៃណី Soto Zen ។ នាងផ្តោតលើរបៀបដែលអក្សរសិល្ប៍ពុទ្ធសាសនាអាចយល់បាននៅក្នុងបរិបទនៃការអនុវត្ត Zen និងការរួមបញ្ចូលនៃទស្សនវិជ្ជា និងសមាធិ។

១៣John Strong: Strong បានស្វែងយល់ពីទិដ្ឋភាពនិទានកថានៃអក្សរសិល្ប៍ព្រះពុទ្ធសាសនាជាពិសេសនៅក្នុងបរិបទនៃអត្ថបទពុទ្ធសាសនាសម័យដើម។ ព្រះអង្គបានសង្កត់ធ្ងន់លើតួនាទីនៃរឿង និងប្រស្នាក្នុងការបង្ហាញការប្រៀនប្រដៅរបស់ព្រះពុទ្ធសាសនា និងសារៈសំខាន់របស់វាក្នុងការអភិវឌ្ឍគំនិតព្រះពុទ្ធសាសនា។

១៤. David Kalupahana: អ្នកប្រាជ្ញនៃព្រះពុទ្ធសាសនាថេរវាទ Kalupahana បានផ្តោតលើបាលី Canon និងការបង្រៀនដំបូងរបស់ព្រះពុទ្ធ។ លោកអះអាងថា ការយល់ដឹងអំពីបរិបទប្រវត្តិសាស្ត្រនៃអត្ថបទទាំងនេះគឺមានសារៈសំខាន់ណាស់សម្រាប់ការយល់ឃើញពីអត្ថន័យទស្សន វិជ្ជារបស់ពួកគេ។

១៥.Nina van Gorkom : Van Gorkom បានធ្វើការយ៉ាងទូលំទូលាយលើអក្សរសិល្ប៍ Abhidhamma ដែលនិយាយអំពីចិត្តវិទ្យានិងទស្សនៈវិជ្ជាព្រះពុទ្ធសាសនា។ នាងសង្កត់ធ្ងន់លើវិធីសាស្ត្រជាប្រព័ន្ធនៃអត្ថបទទាំងនេះក្នុងការវិភាគដំណើរការផ្លូវចិត្ត និងការប្រព្រឹត្តប្រកបដោយសីលធម៌។

១៦. Roger Jackson: Jackson បានសិក្សាព្រះពុទ្ធសាសនាទីបេ និងទំនៀមទម្លាប់អក្សរសាស្ត្ររបស់វា។ គាត់បានលើកឡើងពីសារៈសំខាន់នៃអក្សរសិល្ប៍អត្ថាធិប្បាយនៅក្នុងព្រះពុទ្ធសាសនាទីបេ និងរបៀបដែលវាបង្ហាញការបកស្រាយនៃអត្ថបទជាមូលដ្ឋាន។

១៧ Daisetz Teitaro Suzuki: ជាតួអង្គសំខាន់ក្នុងការណែនាំព្រះពុទ្ធសាសនា Zen ទៅលោកខាងលិច ការសរសេររបស់ Suzuki ជារឿយៗសង្កត់ធ្ងន់លើទិដ្ឋភាពបទពិសោធន៍នៃការអនុវត្តព្រះពុទ្ធសាសនាដែលមាននៅក្នុងអក្សរសិល្ប៍។ គាត់បានចាត់ទុកអត្ថបទ Zen ជាការណែនាំទៅកាន់បទពិសោធន៍ផ្ទាល់ ជាជាងគ្រាន់តែជាសុន្ទរកថាទស្សនវិជ្ជា។

១៨.Janet Gyatso: ការងាររបស់ Gyatso ផ្តោតលើព្រះពុទ្ធសាសនាទីបេ និងចំណុចប្រសព្វនៃទស្សនៈវិជ្ជា សីលធម៌ និងយេនឌ័រនៅក្នុងអត្ថបទព្រះពុទ្ធសាសនា។ នាងពិនិត្យមើលពីរបៀបដែលអក្សរសិល្ប៍ព្រះពុទ្ធសាសនាឆ្លុះបញ្ចាំងពីបរិបទវប្បធម៌ និងមានឥទ្ធិពលលើការបកស្រាយសហសម័យ។

១៩. Donald Lopez៖ Lopez បានពិនិត្យយ៉ាងត្រចះត្រចង់ពីរបៀបដែលអ្នកប្រាជ្ញលោកខាងលិចបានចូលទៅជិតអត្ថបទ និងការអនុវត្តព្រះពុទ្ធសាសនា។ លោកសង្កត់ធ្ងន់លើសារៈសំខាន់នៃការយល់ដឹងអំពីព្រះពុទ្ធសាសនានៅក្នុងបរិបទវប្បធម៌ និងប្រវត្តិសាស្ត្ររបស់ខ្លួន ជាជាងការដាក់ក្របខ័ណ្ឌខាងក្រៅ។

២០.. Bhikkhu Bodhi: ជាព្រះសង្ឃថេរវាទដ៏លេចធ្លោ និងជាអ្នកប្រាជ្ញ, Bodhi បានបកប្រែនិងអត្ថាធិប្បាយលើគម្ពីរបាលីជាច្រើន។ លោកសង្កត់ធ្ងន់លើការអនុវត្តជាក់ស្តែងនៃការបង្រៀនព្រះពុទ្ធសាសនាដែលមាននៅក្នុងអត្ថបទទាំងនេះ និងភាពពាក់ព័ន្ធរបស់ពួកគេចំពោះអ្នកប្រតិបត្តិសម័យទំនើប។

២១.អ្នកប្រាជ្ញទាំងនេះតំណាងឱ្យទស្សនវិស័យជាច្រើនលើអក្សរសិល្ប៍ពុទ្ធសាសនា ដែលរួមចំណែកដល់ការយល់ដឹងកាន់តែស៊ីជម្រៅអំពីទិដ្ឋភាពទស្សនវិជ្ជា ប្រវត្តិសាស្ត្រ និងវប្បធម៌របស់វា។ ការងាររបស់ពួកគេជួយបំភ្លឺពីរបៀបដែលអត្ថបទពុទ្ធសាសនិកអាចត្រូវបានបកស្រាយ និងអនុវត្តក្នុងបរិបទផ្សេងៗ ពង្រឹងទាំងការសិក្សា និងការអនុវត្តផ្ទាល់ខ្លួន។

មតិជារួមមកវិញអក្សរសិល្ប៍គឺជាការសិក្សាអំពីគថ:ភាពសង្គម ផ្ទត់គំនិតសកម្មភាព និងសង្គមមនុស្សទាំងមូល តាមរយ:ពាក្យពេចន៍ដ៏មានសោភ័ណ ជីវភាពរស់នៅរបស់មនុស្ស និងអព្ភន្តរញាណ ដែលបង្កើតបានជាកម្រងស្នាដៃអក្សរសិល្ប៍ដ៏ពេញនិយមរស់រវើកគ្រប់សម័យកាលគ្រប់ស្រទាប់វណ្ណ:ហើយស្នាដៃមានច្រើនប្រភេទ

## ២.៣. ប្រភពអក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយម

គោលគំនិតសំខាន់ៗនៃព្រះពុទ្ធសាសនាត្រូវបានបែកចែកចេញជាបីដែលគេហៅថា ព្រះត្រៃបិដក។ ព្រះត្រៃបិដកមានបីផ្នែកគឺ វិន័យបិដក(ព្រះវិន័យ) សុត្តន្តបិដក(ព្រះសូត្រ) និង អភិធម្មបិដក(ព្រះអភិធម្ម។

អក្សរសិល្ប៍អ្នកនិពន្ធគាត់តែងឡើងជាវណ្ណកម្មស្នាដៃទៅតាមទេពកុសលរបស់ខ្លួនឱ្យយល់ច្បាស់ពីព្រះពុទ្ធអង្គក្នុងពុទ្ធកប្បនីមួយៗនិងអប់រំដល់មនុស្សឱ្យខំកសាងអំពើល្អគ្រប់យ៉ាងផងដែរ។

យោងទៅតាមលោក លាង ហាប់អាន លោកបានចែកអក្សរសិល្ប៍ពុទ្ធនិយមជាបីផ្នែក ពុទ្ធនិយមសុទ្ធ ពុទ្ធនិយមក្លាយ និង ពុទ្ធនិយមក្លាយហួសហេតុ(ពុទ្ធនិយមផ្លួម)។

- អក្សរសិល្ប៍ពុទ្ធនិយមសុទ្ធគឺជារឿងដែលស្ថិតនៅក្នុងជាតិទាំង១០របស់ព្រះពោធិសត្វមុនត្រាស់ដឹងជាព្រះ សម្មាសម្ពុទ្ធ។ ពុទ្ធនិយមសុទ្ធនេះស្ថិតក្នុងគម្ពីរទសជាតក។

- អក្សរសិល្ប៍ពុទ្ធនិយមក្លាយ គឺជាអក្សរសិល្ប៍ដែលអ្នកនិពន្ធបានដកស្រង់ ចេញអំពីគម្ពីរបញ្ញាសជាតក ជាគម្ពីរ អដ្ឋកថាកើតមាននៅប្រទេសលាវ ត្រង់ឈៀងម៉ៃ ប្រហែល៥០០ឆ្នាំប៉ុណ្ណោះ37 ។រឿងទាំងនោះមានដូចជា ព្រះសមុទ្ទ ឃោស រឿងព្រះសុធនកុមារ រឿងក្រុងសុភមិត្រ រឿងទេវន្ទ រឿងសុបិនកុមារ ជាដើម។

- អក្សរសិល្ប៍ពុទ្ធនិយមក្លាយហួសហេតុ(ពុទ្ធនិយមផ្លួម)គឺជារឿងដែលពុំស្ថិតនៅក្នុងគម្ពីរក្បួនខ្នាតអំពីបុរាណ ណាមួយឱ្យបានច្បាស់លាស់ទេ ប្រសិនបើមានបញ្ជាក់នាម ក្បួនខ្នាតដើម គម្ពីរដើម គឺអ្នកនិពន្ធគ្រាន់តែថាប៉ុណ្ណោះ ពុំ មានដំណើររឿងដូចគ្នាបេះបិទឡើយ ឧទាហរណ៍រឿងកាកី38។

**និយមន័យ**

អក្សរសិល្ប៍ពុទ្ធនិយម ជាអត្ថបទរឿងរ៉ាវផ្សេងៗដែលទាក់ ទងនឹងការលើកយកទ្រឹស្តីពុទ្ធសាសនាធ្វើជាគោល ហើយទ្រឹស្តី ទាំងនោះស្ថិតនៅក្នុងគម្ពីរព្រះត្រៃបិដក ដែលអ្នកនិពន្ធលើកយក បញ្ហាបុណ្យ បាប ផលល្អ អាក្រក់របស់តួអង្គមកចោទ និងដោះស្រាយ ។

អក្សរសិល្ប៍ពុទ្ធនិយមសម្គាល់អត្ថបទណាដែលមានទំនាក់ ទំនងទៅនឹងលិទ្ធិពុទ្ធសាសនា គឺលើកយកសកម្មភាពពោធិសត្វក្នុង ការកសាងបារមី ឬដែលបានលើកទស្សនៈសំខាន់ៗក្នុងពុទ្ធសាសនា មានបញ្ហាកម្មផល បុណ្យបាបជាដើមមកបង្ហាញ ។

ឬអក្សរសិល្ប៍ពុទ្ធនិយមគឺជាស្នាដៃអក្សរសិល្ប៍ទាំងឡាយ ណាដែលដំណើររឿងនិយាយអំពីការកសាងសន្សំបារមីរបស់ព្រះពោធិសត្វដើម្បីបានត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធ។

## លក្ខណៈសំខាន់ខ្លះៗនៃរឿងក្នុងគោលពុទ្ធនិយម

រឿងទាំងឡាយដែលស្ថិតនៅក្នុងគោលពុទ្ធនិយមច្រើនមានលក្ខណៈពិសេសប្លែកអំពីរឿងធម្មតានានាដូចតទៅៈ

### ក. ផ្នែកអត្ថន័យ

ជារឿងដែលមានទាក់ទងទៅនឹងពុទ្ធសាសនា។ គោល រឿងក្នុងពុទ្ធសាសនានោះគឺមានៈ

### រឿងកម្មផល

- កម្មល្អបានផលល្អ កម្មអាក្រក់បានផលអាក្រក់ - ធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់

- កម្មសឱ្យផលស កម្មខ្មៅឱ្យផលខ្មៅ

- នរណាសាបព្រោះខ្យល់ អ្នកនោះទទួលផលព្យុះសង្ឃរា

គេយករឿងបុព្វជាតិរបស់ពោធិសត្វដែលជាតួអង្គឯកក្នុង រឿងមកលាតត្រដាង

### រឿងកម្មពៀរ

កម្មពៀរមិនអាចរំងាប់ដោយពៀរ “ពៀរអាចរំងាប់ដោយការមិនចងពៀរ” រឿងភូរិទត កាលព្រះពោធិសត្វរក្សាសិលក្នុងតួអង្គជាសត្វនាគ ពេលនោះនាយព្រាហ្មណ៍អាលម្ពាយបានចូលទៅចាប់ព្រះអង្គព្រះអង្គមិនតបតទៅៈព្រាហ្មណ៍ធ្វើបាបគ្រប់ឱ្យសម្តែងគ្រប់បែបយ៉ាងព្រះអង្គខន្តីទាំងអស់។

### ខ. ផ្នែក អត្ថរូប

រឿងជាតក ឬអក្សរសិល្ប៍បែបពុទ្ធនិយមច្រើនមាន ប្រភេទជាអត្ថបទៈ

- ពាក្យកម្រងកែវ (ឧ. រឿងមហាវេស្សន្តរ, ទសជាតក៍, នានាជាតក)
- ពាក្យកាព្យ (សាស្ត្រាល្បែងគោលពុទ្ធនិយម) ។
- ជារឿងដែលគេយកទៅអានសម្រាប់ទេសនា ឬកម្សាន្តកែប្រែចិត្តគំនិត ឬសម្រាប់ស្មូត។ ល ។
- អត្ថបទទាំងនោះមានចារជាសៀវភៅស្លឹករឹត ក្នុងក្រាំង គម្ពីរ សៀវភៅសម្រាប់ជាក្បួនខ្នាតសិក្សា និងសម្រាប់បូជា។
- ជារឿងស្របទៅនឹងជំនឿមហាជន ដោយយក ឬជ្រៅជ្រះមកនិយាយបែបបុគ្គលាធិដ្ឋាន4 តែងជារឿងជាឧទាហរណ៍ ធ្វើឱ្យងាយស្តាប់ ងាយយល់ដើម្បី ប្រតិបត្តិ ជឿស៊ប់ក្នុងសាសនា (មានកម្មផលជាប្រធាន) ។
- ពាក្យពេចន៍ប្រើសម្រាប់តែងច្រើនជាភាសាលាយចម្រុះច្រើន ។

- ឃ្លាប្រយោគច្រើនវែងៗ ហើយទាក់ទងពាក្យសម្តី ក្នុងសាសនា (ឧ. សីលទាន, ភាវនា, ព្រះតថាគត, ព្រះដ៏មានបុណ្យ ព្រះពោធិសត្វ, ទ្រង់ផ្សាន, ឈានសមាបត្តិ។ល។)

- បើរឿងជាជាតកដើម (គម្ពីរដើម) គេច្រើនចែកជា ច្រើនកណ្ឌ ច្រើនវគ្គ (ឧ. មានព្រះមហាវេស្សន្តរជាតក, ទសជាតក ជាដើម) ។

## ២.៤ គំរូលំនាំនិពន្ធអក្សរសិល្ប៍ពុទ្ធនិយម

ចំពោះអក្សរសិល្ប៍ពុទ្ធនិយមសុទ្ធនិងក្លាយ គេច្រើនសរសេរជាពាក្យរាយនិងកម្រងកែវ។ រីឯអក្សរសិល្ប៍ពុទ្ធ និយមក្លាយនិងក្លាយហួសហេតុត្រូវបានអ្នកនិពន្ធ ប្រើវិធីតែងជាពាក្យកាព្យរឿងសឹងតែទូទៅតែងឡើងជាកំណាព្យដ៏មានបទ ផ្សេងៗគ្នា មានបទកាកគតិ ព្រហ្មគីតិ ភុជង្គលីលា បន្ទោលកាក ឬពំនោលជាដើម។ ការដែលយកពាក្យកាព្យមកប្រើ បែបនេះជាមធ្យោបាយសម្របសម្រួលទៅតាមគោលបំណង ក្នុងឧត្តមគតិរឿងដែលបំពេរអារម្មណ៍ បន្ទូរក្តីទុក្ខព្រួយឱ្យរសាយនេះឯង។

### ក. ផ្តើមរឿង

ច្រើនមានបទនមស្ការ មានតំណាលថាព្រះពុទ្ធគង់ នៅក្នុងអារាមណាមួយ ទ្រង់សម្តែងឡើងនូវរឿង អតីតជាតិរបស់ព្រះអង្គទៅកាន់ពុទ្ធបរិស័ទ។

### ខ. ដំណើររឿង

ជាធម៌ទេសនារបស់ព្រះពុទ្ធអង្គ (នេះចំពោះជាតក ដើម ឧ. នានាជាតក, ទសជាតក, មហាវេស្សន្តរជាតក)

- ជាអត្ថបទបំពេរចិត្តគំនិតឱ្យជឿបុណ្យបាបឱ្យខ្លាច អំពើអាក្រក់ ស៊ប់ចិត្តក្នុងសាសនា (រឿងផ្សេងៗក្នុង សាស្ត្រារយ)

### គ. បញ្ចប់រឿង

- ព្រះពុទ្ធ (ពោធិសត្វ) ទ្រង់បញ្ចប់ទេសនាដោយមាន ការសរជាតិ ឧ. ក្នុងរឿងតេមិយជាតកព្រះពុទ្ធទ្រង់ប្រជុំការសរជាតិថា៖

- ព្រះនាងទេពី បានមកជានាងឧប្បលវណ្ណី
- នាយសុនន្ទសារថី បានមកជាព្រះសារីបុត្តត្ថេរ
- ព្រះនាងចន្ទទេវី បានមកជាព្រះនាងសិរិមហាមាយា
- ព្រះបាទកាសិករាជ បានមកជាព្រះបាទសិរីសុទ្ធោទន
- ព្រះតេមិយតាបស បានមកជាព្រះបរមពោធិសត្វ

### ផ្នែកអត្ថរស

តម្លៃនៃរឿងជាតក ឬក្នុងគោលពុទ្ធនិយមដែលសំខាន់ជាងគឺ៖

- កម្សត់រស
- មនុស្សរស

### យោបល់រួម

ជាសេចក្តីវិនិច្ឆ័យរឿងក្នុងទសជាតក(ឬក្នុងគោលពុទ្ធនិយម) គឺជារឿងដែលបានអប់រំឱ្យយើងដឹងអំពី វាលវដ្តសង្សារការកើតចាស់ឈឺស្លាប់ របស់មនុស្ស សត្វ គ្រប់រូប ការកសាងបារមីរបស់ព្រះពុទ្ធគ្រប់ព្រះអង្គដើម្បីត្រាស់ដឹងពោធិញ្ញាណ ស្រោចស្រង់សត្វលោក រួចផុតពី អំពើអាក្រក់ទាំងឡាយផងដែរ។

## ២.៥. ប្រភេទអក្សរសិល្ប៍ពុទ្ធនិយម

គេចែកអក្សរសិល្ប៍បែបពុទ្ធនិយមជាបីប្រភេទគឺៈ

- ពុទ្ធនិយមសុទ្ធសាធ
- ពុទ្ធនិយមក្លាយ
- ពុទ្ធនិយមក្លាយហួសហេតុ

### និយមន័យ

ពាក្យថា "ជាតក" ជាភាសាបាលី អានថា [ជា-តៈ-កៈ] អានតាមបែបខ្មែរ -ដក់], ខ្មែរបង្រួញឲ្យខ្លីមកទៀតដោយ បដិសេធសូរអក្សរ "ក" ទៅជា "ជាតក៍" អានថា [ជាត៍] ។

"ទសជាតក៍ គឺជាអតីតប្រវត្តិរបស់ព្រះសក្យមុនីគោតម បរមសម្ពុទ្ធក្នុង១០ពះជាតិមុនពះជាតិដែលបានត្រាស់ ។

រឿងជាតកគឺជារឿងរ៉ាវពីក្នុងជាតិមុនៗដែលលោកអ្នកបានលុះញាណវិសេសសម្រាប់ដឹងជាតិ លោកសម្ដែងប្រាប់យ៉ាងដូច ជាជាតកទាំង១០ មានគេមិយជាតកជាដើម ដែលព្រះសក្យមុនី សព្វញ្ញូពុទ្ធទ្រង់សម្ដែង ឈ្មោះអង្គនៃពុទ្ធសាសនាមួយយ៉ាងក្នុង អង្គទាំង៩ ។

រឿងរ៉ាវទាំងដប់ពន្យល់ពីការកសាងបារមីទាំង១០ ឬ ទសបារមីរបស់ព្រះះពោធិសត្វ គឺក្នុងមួយរឿងពន្យល់ពីបារមីមួយ ។

### ប្រភពរឿង

- "គម្ពីរទសជាតក" ប្រភពដើមជាភាសាបាលី មាននៅក្នុង គម្ពីរខុទ្ទកនិកាយ ជាតក បហានិបាត ផ្នែកសុត្តន្តបិដកនៃគម្ពីរព្រះ ត្រៃបិដក។

សរុបមករឿងអក្សរសិល្ប៍ពុទ្ធនិយម មានប្រភពមកពីគម្ពីរនានាជាច្រើន អ្នកនិបន្ធបានតាក់តែងឡើងរៀបរាប់ពីតួអង្គព្រះពោធិសត្វ ដែលបានកសាងបារមីដើម្បីកសាងមារមីត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធ និងដើម្បីជួយស្រោចស្រង់សត្វលោកគ្រប់បែបយ៉ាង។

# ជំពូក ៣ វិធីសាស្ត្រស្រាវជ្រាវ

## ៣.១. ប្រភេទនិង ប្រភពនៃការស្រាវជ្រាវ

ប្រភេទទិន្នន័យលើការសិក្សាស្រាវជ្រាវទៅលើនិក្ខេបបទប្រធានបទ ''តម្លៃអប់រំអក្សរសិល្ប៍ពុទ្ធនិមក្រោយសម័យអង្គរ''តាមរយៈរឿងពុទ្ធនិយមខ្មែរ នេះគឺអនុវត្តតាមវិធីសាស្ត្រស្រាវជ្រាវតាមបែបគុណវិស័យ Qualitative Research ដោយសារតែយើងត្រូវការធ្វើការប្រមូលនិងដកស្រង់ទិន្នយកពីអក្សរសិល្ប៍ពុទ្ធនិយមក្នុងគម្ពីរព្រះត្រៃបិតក សាស្ត្រាល្បែង សៀវភៅរឿងទសជតក៍ ឬ ពុទ្ធនិយមសុទ្ធ បញ្ញាសជតក៍ ឬពុទ្ធនិយមក្លាយ នានាជាតក៍ ឬពុទ្ធនិយមក្លាយហួសហេតុ ឯកសារចាស់ៗ និងសៀវភៅផ្សេងទៀតដែលមានទ្រឹស្តីពាក់ពន្ធទៅនិងប្រធានបទយកមកធ្វើការពិចារណានិងវិភាគវែកញែក មានលក្ខណៈសមស្រប សមហេតុផង និងមានលក្ខណៈវិទ្យាសាស្ត្រ យើងខ្ញុំបានរៀបចំទៅតាមដំណើរការដូចខាងក្រោមៈ

## ៣.២. វិធីសាស្ត្រស្រាវជ្រាវតាមបែបគុណវិស័យ

ចំពោះដំណើរការ ក្នុងការសិក្សាស្រាវជ្រាវទៅលើប្រធានបទបទ ''តម្លៃអប់រំអក្សរសិល្ប៍ពុទ្ធនិមក្រោយសម័យអង្គរ'' ¬មួយនេះ ស្ទេរបានធ្វើការអនុវត្តិតាមវិធីសាស្ត្រស្រាវជ្រាវបែបគុណវិស័យ។ ដោយយោងទៅតាមវិធីសាស្ត្រនេះគឺតម្រូវឱ្យស្ទេរសិក្សាស្រាវជ្រាវប្រមូលរាល់ឯកសារ ទ្រឹស្ត្រីដែលជាប់ពាក់ព័ន្ធនិង ទ្រឹស្តីក្នុងព្រះពុទ្ធសាសនា គម្ពីរព្រះត្រៃបិតក៍ សាស្ត្រល្បែងសៀវភៅទសជាតក៍ ឬ ពុទ្ធនិយមសុទ្ធ សៀវភៅបញ្ញាសជាតក៍ឬ ពុទ្ធនិយមក្លាយ នានាជាតក៍ ឬពុទ្ធនិយមក្លាយហួសហេតុ ផ្លូម និងទិន្នន័យដែលជាប់ទាក់ទងនិងអត្ថបទតាមរយៈឯកសារនានា តាមសៀវភៅផ្សេងៗដែលជាសាស្ត្រាចារ្យបណ្ឌិជំនាន់មុន និង សៀវភៅពុទ្ធប្រវត្តិទៀតផង។ ដើម្បីចងក្រងបញ្ជូលគ្នាជាទិន្នន័យមួយនេះឡើង ព្រមទាំងត្រិះរិះពិចារណាបានល្អិតល្អន់វែកញែកពីលក្ខណៈតម្លៃអប់រំនៃរឿងនីមយយៗ មកបកស្រាយបង្ហាញផ្សេងទៅតាមចំណុចនីៗមួយឱ្យកាន់តែច្បាស់លាស់ពំពីអក្សរសិល្ប៍ពុទ្ធនិយម។

ប្រធានបទខាងលើនេះ ស្ទេរមានគោលបំណងស្វែងយល់ពីតម្លៃអប់រំរបស់អក្សរសិល្ប៍ពុទ្ធនិយមរបស់អ្នកនិពន្ធ គឺស្ទេរបានប្រើវិធីសាស្ត្រការសិក្សាស្រាវជ្រាវតាមបែបគុណវិស័យ Qualitative research Method ជាប្រភេទស្រាវជ្រាវដេលទាក់ទងទៅនិងការប្រមូលនិង ការវិភាគទិន្នន័យ ដែលមានទម្រង់ជាអក្សរ និងលទិផលជាអត្ថបទរៀបរាប់ពិស្តារទៅតាមសាច់រឿងខ្លឹមសារ ឬប្រធានបទ។ ឯកសារយោង វចនានុក្រមសង្គប្បតាមការសិក្សាស្រាវជ្រាវបែបនេះមានលក្ខណៈចម្រុះមួយយនៅក្នុងការសិក្សាអន្តរកម្មសង្គមនិងការសិក្សាអំពីប្រភពនៃអត្ថន័យដែលបានទទួលពីបទពិសោធន៍ជាច្រើនរបស់បុគ្គលម្នាក់ៗ។ ការសិក្សាស្រាវជ្រាវតាមបែបគុណវិស័យ មួយនេះត្រូវបានផ្តោតលើការយកចិត្តទុកដាក់ ជាពិសេសលើធម្មជាតិ អត្ថន័យនសបទពិសោធន៍របស់មនុស្ស។ មនុស្សបានបង្កើតរបៀបរបបជីវភាពរស់នៅប្រចាំថ្ងៃពិតជាក់ស្តែងរបស់ពួកគេដោយសារមានការជឿឬ ជំនឿទនៀមទម្លាប់ពីបុរាណដោយការគោរពប្រត្តិបត្តិដែលដូនតាយើងបានបន្សល់ទុកឱ្យមកតៗគ្នា។

វិធីសាស្ត្រនេះតែងលើកជាសំណួរថា តើមនុស្សពន្យល់អំពីអត្ថន័យអំពីបទពិសោធន៍របស់ពួកគេយ៉ាងដូចម្តេច?

តើមនុស្សទទួលបានបទពិសោធន៍ គ្រប់គ្រងនិងចចារជាមួយស្ថានភាព សកម្មភាពកំពុងជួបប្រទះយ៉ាងដូចម្តេច ?

តើមនុស្សជជែកអំពីអ្វីដែលបានកើតឡើងចំពោះពួកគេ និងអ្នកដ៏ទៃ ?

វិធីសាស្ត្រស្រាវជ្រាវតាមបែបគុណវិស័យ គឺជាវិធីសាស្ត្រស្រាវជ្រាវមួយ ដែលស្ទេរត្រូវដកស្រង់ប្រមូលទិន្នន័យពីឯកសារចាស់ៗនិងសៀវភៅផ្សេងៗ ដែលពាក់ព័ន្ធទៅនឹងប្រធានបទ។ គួររំឮកដែរថាក្នុងការសិក្សាទៅលើប្រធានបទមួយនេះស្ទេរពុំបានប្រើប្រើវិធីសាស្ត្រស្រាវជ្រាវតាមបែបបរិមាណវិស័យទេ ដោយហេតុថា ប្រធានបទដែលយើងលើកមកសិក្សាស្រាវជ្រាវមួយនេះពុំមែនជាប់ទាក់ទងទៅនិងចំនួនឬ ស្ថិតិអ្វីសោះឡើយ។

លើសពីនេះទៅទៀត យើងក៏បានសិក្សាវិភាគវែកញែកសំដៅឆ្ពោះទៅរកឱ្យឃើញអំពី វាទកម្មនិងរូបនិមិត្តិកម្ម ដែលជាសញ្ញាណតំណាងសាសនានិងសម្ពន្ធភាពយ៉ាងជិតស្និតរវាង តម្លៃ

អប់រំ មនុស្សនិងសាសនាដែលបង្ហាញឱ្យឃើញតាមរយៈអក្សរសិល្ប៍។ ម្យ៉ាងវិញទៀតប្រការដែលសំខាន់ស្ទេរបានប្រមូលផ្តុំពហុឯកសារជាច្រើន។ ឯកសារដែលមានទ្រឹស្តីមានលក្ខណៈវិទ្យាសាស្ត្រ អាចយកជាគោលក្នុងការសិក្សាតែប៉ុណ្ណោះ ពោលគឺប្រភេទឯកសារទាំងឡាយណាដែលជាស្នាដៃរបស់បណ្ឌិត អ្នកប្រាជ្ញ សាស្ត្រាចារ្យ ខ្មែរនិងករីនិពន្ធល្បីៗដែលធ្លាប់មានបទពិសោធន៍កន្លងមក។ តាមរយៈឯកសារដែលយើងបានលើកមកគឺជាមូលដ្ឋានគ្រឹះសម្រាប់ធ្វើការលម្អិតទៅលើស្នាដៃនៃរឿងនីៗមួយដែលមាននៅក្នុងអក្សរសិល្ប៍រឿងពុទ្ធនិយមខ្មែរ។

## ៣.៣. វិធីសាស្ត្រនៃការប្រមូលទិន្នន័យ

បន្ទាប់ពីបានជ្រើសរើសប្រធានបទស្រាវជ្រាវរួចមកស្ទេរត្រូវបានប្រមូលទិន្នន័យ តាមបែបគុណវិស័យស្ទេរបានខិតខំប្រមូលឯកសារនៅតាមប្រពន្ធអិនធ័រនេត ឯកសារមានស្រាប់តាមបណ្ណាល័យ តាមបណ្ណាគារ ទិញសៀវភៅតាមប្រពន្ធអនឡាញ សម្ភាជ៍សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូតាមទូស័ព្ទ និងទិញតាមតូបសៀវភៅនានាជាច្រើនទៀត។ នូវឯកសារដែលបានជាប់ទាក់ទងនិងប្រធានបទដើម្បីជួយក្នុងការសិក្សាស្រាវជ្រាវប្រកបដោយ ប្រកបដោយភាពទទួលខុសត្រូវ ភាពជោគជ័យ មានប្រសិទ្ធិភាព ជាស្ថារពរ ទៅតាមគំរោងដែលបានកំណត់ទុកធ្វើជាមូលដ្ឋានទ្រឹស្តីក្នុងការសិក្សាវិភាគនូវសៀវភៅរឿងពុទ្ធនិយមដែលជាប់ទាក់ទងនិងប្រធានបទ។ នៅពេលឯកសារបានគ្រប់គ្រាន់ហើយទើបស្ទេរយើងខ្ញុំចាប់ផ្តើមអានពិនិត្យដោយយកចិត្តទិកដាក់ហើយដកស្រង់ទិន្នន័យដែលទាក់ទងនឹងវាទកម្ម រូបនិម្មត្តិតំណាងតម្លៃអប់រំអក្សរសិល្ប៍ពុទ្ធនិយម ព្រមទាំងទំនាក់ទំនងរវាងមនុស្សនិងតម្លៃអប់រំនៅក្នុងស្នាដៃនីមួយៗ។

បន្ទាប់ពីបានប្រមូលឯកសារគ្រាប់គ្រាន់ល្មមហើយយើងខ្ញុំបានធ្វើការថ្លឹងថ្លែងប៉ាន់ប្រមាណមើលពីទំហំកិច្ចការស្រាវជ្រាវជាមួយឯកសារដែលប្រមូលបានទៅវិនិច្ឆ័យហើយចាប់ផ្តើមពីការសរសេរតែម្តង។

## ៣.៤. វិធីសាស្ត្រវិភាគទន្ទន័យ

ចំពោះការវិភាគទិន្នន័យវិញឃើញថា គឺបានស្ទេរបានធ្វើការសិក្សាវិភាគវែកញែកយ៉ាងលម្អិតសំដៅឆ្ពោះទៅរកឱ្យឃើញអំពី តម្លៃអប់រំអក្សរសិល្ប៍ពុទ្ធនិយមក្រោយសម័យអង្គរ ដែលបានលាតត្រដាងតាមរយៈស្នាដៃអក្សរសិល្ប៍ពុទ្ធនិយមខ្មែរដែលមានដូចជា តម្លៃអប់រំចំពោះមនុស្សទាំងឡាយ តម្លៃអប់រំឱ្យយល់ពីទស្សនៈកម្មផល តម្លៃអប់រំក្នុងសង្គម តម្លៃអប់រំឱ្យស្គាល់ពីការគោរពទំនៀមទម្លាប់ប្រពៃណី ជាអត្តសញ្ញាណជាតិ ដែលមានទក់ទងជាមួយសង្គមមនុស្ស អប់រំឱ្យចេះប្រព្រឹត្តិអំពើល្អធ្វើបុណ្យដាក់ទាននិងមានធម៌កត្តញ្ញូចំពោះអ្នកមានគុណ។ មួយវិញទៀត ចំពោះប្រការដែលសំខាន់នោះ គឺស្ទេរបានឯកសារជាច្រើនសម្បូរបែប ដោយយកតែឯកសារទ្រឹស្តីណាដែលទាក់ទងប្រធានបទ សៀវភៅរឿងនានា ទសជាតក បញ្ញាសជាតក នានាជាតក និងឯកសារដែលមានលក្ខណៈវិទ្យាសាស្ត្រខ្លះ អាចយកជាគោលក្នុងការសិក្សាបានតែប៉ុណ្ណោះ ពោលគឺប្រភេទឯកសារទាំងឡាយណាដែលជាស្នាដៃរបស់ បណ្ឌិត សាស្ត្រាចារ្យអក្សរសាស្ត្រខ្មែរ និងករីនិពន្ធល្បីៗដែលធ្លាប់មានបទពិសោធន៍។ តាមរយៈឯកសារ ដែលយើងបានលើកមក គឺជាមូលដ្ឋានគ្រឹះសម្រាប់ធ្វើការសិក្សាលម្អិតទៅលើស្នាដៃរឿងនីមួយៗដែលមាននៅក្នុងអក្សរសិល្ប៍ពុទ្ធនិយម និងឯកសារនានាផ្សេងទៀត។

# ជំពូក ៤ ការវិភាគទិន្នន័យ លទ្ធផល

## ៤.១. ទិដ្ឋភាពទូទៅនៃអក្សរសិល្ប៍ពុទ្ធនិយម

មុននិងយើងបោះជំហានឈានចូលក្នុងការសិក្សាស្រាវជ្រាវតាំងពីសម័យបុរាណរហូតមក ប្រទេសខ្មែរយើងចាប់ផ្តើមមានភាសាសម្រាប់និយាយប្រាស្រ័យទាក់ទងគ្នា ក្រោយមកមនុស្សបានបង្កើតតួអក្សរ ដើម្បីសម្រាប់កត់ត្រាចារភាសាទាំងនោះសម្រាប់ប្រើប្រាស់ និងរហូតដល់ទំនើបជាដើម។

អក្សរសិល្ប៍ខ្មែរមានប្រវត្តិដ៏សម្បូរបែបដែលអាចបែងចែកជាសម័យសំខាន់ៗជាច្រើន ដែលនីមួយៗឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរវប្បធម៌ នយោបាយ និងសង្គមនៅកម្ពុជា។ នេះគឺជាការបែងចែកសំខាន់ៗមានៈ

### ក.សម័យបុរាណ (សតវត្សទី ៩ ដល់ទី ១៥):

- សម័យកាលនេះស្របគ្នានឹងកំពស់នៃអាណាចក្រខ្មែរ ជាពិសេសនៅក្រោមរជ្ជកាលរបស់ស្តេចដូចជាព្រះបាទជ័យវរ្ម័នទី២ និងសូរ្យវរ្ម័នទី២។
- អក្សរសិល្ប៍ក្នុងអំឡុងពេលនេះ បានទទួលឥទ្ធិពលយ៉ាងខ្លាំងពីសាសនាហិណ្ឌូ និងពុទ្ធសាសនា ដែលមានអត្ថបទជាច្រើនសរសេរជាភាសាសំស្ក្រឹត និងភាសាខ្មែរ។
- ស្នាដៃសំខាន់ៗរួមមាន សិលាចារឹក អត្ថបទសាសនា និងកំណាព្យ ជាញឹកញយ ប្រារព្ធពិធីរបស់ស្តេច និងទេវៈ។

### ខ.យុគសម័យមជ្ឈិមសម័យ សតវត្សទី១៥.១៩

- បន្ទាប់ពីការធ្លាក់ចុះនៃអាណាចក្រខ្មែរ អក្សរសិល្ប៍បានក្លាយជាមូលដ្ឋានីយកម្មកាន់តែច្រើន និងឆ្លុះ បញ្ចាំងពីទិដ្ឋភាពនយោបាយដែលផ្លាស់ប្តូរ។ យុគសម័យនេះបានឃើញការលេចចេញនូវរឿងនិទានប្រជាប្រិយ សុភាសិត និងទំនៀមទម្លាប់ផ្ទាល់មាត់ ក៏ដូចជាការកែប្រែទម្រង់អក្សរសាស្ត្រពីវប្បធម៌ជិតខាង។
- ឥទ្ធិពលនៃវប្បធម៌សៀម និងវៀតណាម បានចាប់ផ្តើមបង្កើតអក្សរសិល្ប៍ខ្មែរក្នុងអំឡុងពេលនេះ។

គ.សម័យអាណានិគម (សតវត្សទី ១៩ដល់ពាក់កណ្តាលសតវត្សទី ២០)

- ក្រោមការគ្រប់គ្រងរបស់អាណានិគមបារាំង មានការរស់ឡើងវិញនៃចំណាប់អារម្មណ៍លើអក្សរសាស្ត្រ និងវប្បធម៌ខ្មែរ។
- សម័យកាលនេះបានកត់សម្គាល់ពីការដាក់បញ្ចូលទម្រង់អក្សរសាស្ត្របស្ចិមប្រទេស រួមជាមួយនឹងការឱ្យតម្លៃជាថ្មីចំពោះអក្សរសិល្ប៍ខ្មែរបុរាណ។
- អ្នកនិពន្ធគួរឱ្យកត់សម្គាល់បានលេចឡើង ហើយសង្គមអក្សរសាស្ត្រត្រូវបានបង្កើតឡើងដើម្បីលើកកម្ពស់អក្សរសាស្ត្រខ្មែរ។

ឃ. សម័យក្រោយឯករាជ្យ (ពាក់កណ្តាលសតវត្សទី ២០ ដល់បច្ចុប្បន្ន)៖

បន្ទាប់ពីទទួលបានឯករាជ្យពីប្រទេសបារាំងនៅឆ្នាំ 1953 អក្សរសិល្ប៍ខ្មែរបានបន្តវិវឌ្ឍដោយឆ្លុះបញ្ចាំងពីបញ្ហា និងប្រធានបទសហសម័យ។

- របបខ្មែរក្រហម (១៩៧៥-១៩៧៩) បានជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរដល់អក្សរសិល្ប៍ ដោយមានអ្នកនិពន្ធជាច្រើនត្រូវបានបៀតបៀន ឬសម្លាប់។
- ក្នុងរយៈពេលប៉ុន្មានឆ្នាំក្រោយរបបដួលរលំ មានសកម្មភាពអក្សរសាស្ត្រកើតឡើងឡើងវិញ ដោយផ្តោតលើការកសាងឡើងវិញនូវអត្តសញ្ញាណវប្បធម៌ និងការស្វែងរកប្រធានបទនៃរបួស ភាពធន់ និងទំនើបកម្ម។

ការបែងចែកទាំងនេះបង្ហាញពីភាពស្វាហាប់នៃអក្សរសិល្ប៍ខ្មែរ និងសមត្ថភាពរបស់វាក្នុងការសម្របខ្លួនទៅនឹងកាលៈទេសៈដែលផ្លាស់ប្តូរ ខណៈពេលដែលរក្សាបាននូវបេតិកភណ្ឌវប្បធម៌តែមួយគត់របស់វា។

## ក. សម័យកាលទីមួយសម័យនគរភ្នំគ្រឹះសតវត្សទី ១ ដល់ទី ៦

ព្រះមហាក្សត្រសំខាន់ៗ

ក្នុងគ.ស៥០ព្រះបាទកៅណ្ឌិន្យ និងនាងសោមា.ឬ កោណ្ឌិន នាងសោមា.គឺព្រះនាងនាគី ជាមហាក្សត្រីទីក្រុងឈ្មោះ វ្យាធបុរៈ នៅបាភ្នំ

- មុនគ.សទី៣គឺព្រះបាទហ្វួន.ហ្វាន់ចូលទតង្កតព្រះជន្ម៩ឆ្នាំ
- តមកព្រះរាជបុត្រនាម ហ្វាន់.ហ្វាន់ សោយរាជបាន៣ឆ្នាំកាន់សិវសាសនាគោរពឥសូរជាធំ
- ព្រះបាទស្រីមារៈ ឬ ហ្វាន់ចេ.មីន
- ព្រះបាទធរណិន្ទ្រវរ្ម័នដែលបានឡើងសោយរាជ។

## ខ. សម័យកាលទី ២

- សម័យមុនអង្គរចាប់ពីគ្រិស្តសករាជ ៥០០ .៨១២

ព្រះមហាក្សត្រសំខាន់ៗក្នុងសម័យកាលនោះមាន

- ព្រះបាទភវវ្ម័នទី១ គ្រិស្តសករាជ ៥០០.៦00
- ព្រះបាទមហីន្ទ្រវរ័ន្ម ចិត្រាសែនគឺគ.ស៦០០.៦១៨
- ព្រះបាទឥសានវរ្ម័នទី ១ គ.ស៦១៥.៦៣៥
- ព្រះបាទភវវរ័នទី ២ គ.ស៦៣៩.៦៥៥
- ព្រះបាទជ័យវរ្ម័នទីមួយគ.ស៦៥៥.៦៨១ ។

## ៣. សម័យកាលទី៣

- សម័យអង្គរគ្រស្តសតវត្សទី ៩.១៤

### ក. ព្រះមហាក្សត្រសំខាន់ៗក្នុងសម័យកលនោះមាន

- ព្រះបាទជ័យវរ្ម័នទី២គ.ស ៨០២ .៨៥០ ដែលកសាងប្រាសាទដំបូងនៅក្នុងភ្នំគូលែន
- ព្រះបាទជ័យវរ្ម័នទី ៣ គ.ស ៨៥៤. ៨៧៧
- ព្រះបាទឥន្ទ្រវរ្ម័នទី ៨៧៧៨៨៩
- ព្រះបាទយសោវរ្ម័នទី១ ៨៨៩.៩០០
- ព្រះបាទហសវរ្ម័នទ្រវរ្ម័ន គ.ស ៩៤១.៩៤៤
- ប្រះបាទរាជេន្ទ្រទវរ្ម័ន គ.ស ៩៤៤.៩៦៨
- ព្រះបាទសវរ្ម័នទី ១ គ.ស.១០០២.១០៥០
- ព្រះបាទឧទិត្យាវរ័នទី ២គ.ស១០៥០.១០៦៦
- ព្រះបាទហសវរ្ម័នទី 3 គ.១០៦៦.១០៨០
- ព្រះបាទជ័យវរ្ម័នទី ៦ គ្រឹះស្តរាជ ១០៨២.១១០៧
- ព្រះបាទធរណិន្ទ្រវរ័នទី១គ.ស ១១០៧.១១១២
- ព្រះបាទសូរ្យវរ្ម័នទី ២ គ.ស ១១១៣.១១៥០

- ព្រះបាទជ៧យវរ័នទី ៧គ.ស១១៨១.១២០១

## ខ. សម័យកាលទី ៤

សម័យក្រោយអង្គរចុងក្រស្តសតវត្សទី១៤ដល់សព្វថ្ងៃចែកជា៣ផ្នែកសំៗបានជាបីផ្នែកសំខាន់ៗគឺ

- ផ្នែកទី១ សម័យលង្វែកគឺពីរចម្បាំងជាមួយសៀមមកទល់ការបាត់បងបន្ទាយលង្វែក គ.ស១៣៣៦.១៥៩៣ គឺចាប់ពីសម័យបាត់បង់អង្គរក្នុងរាជការព្រះបាទលំពង គ.ស.មកដលរាជកាលព្រះសត្ថា

- ផ្នែកតី២ សម៧យក្រុងឧត្តុងញ្ជ័យគ.ស១៦១៨ .១៨៥៩ ពីរាជការព្រះជ័យជេដ្ឋាកាលព្រះបាទអង្គឌួង គ.ស ១៨៤៥.១៨៥៩

ផ្នែកទី៣សម័តក្រុងភ្នំពេញចាប់ពីគ.ស១៨៥៩តមកដល់ស្វថ្ងៃ។

បុព្វបុរសខ្មែរក៏មានគំនិតច្នៃប្រឌិតដោយខ្ចីតួអក្សរព្រាហ្មី ពីឥណ្ឌាភាគខាងត្បូងយកមកប្រើ ។ កាលដែលមានភាសានិងតួអក្សររបស់ជាតិនីមួយៗនេះហើយបានបង្កើតបានជាអក្សរសាស្ត្រ អក្សរសិល្ប៍ឡើង។ ក្នុងសម័យនគរភ្នំ ហ្វូណន ជាភ័ព្វសំណាងដ៏ធំធេងមួយរបស់ប្រជាជនខ្មែរគឺ កេរ្តិ៍តំណែលវប្បធម៌ដ៏លើសលុបដែលបុព្វការី ជនរបស់ខ្លួនបានបន្សល់ទុកមិនគ្រាន់តែមាននៅកម្ពុជា ថៃ និងឡាវ (លាវ)នោះទេ គឺមានទាំង នៅវៀតណាមខាងត្បូងផងដែរ ។វិសាលភាព និងអធិរាជភាពនៃមរតកវប្បធ៌មបុរាណ ទាំងនោះ កាត់ថ្លៃពុំបានឡើយហើយ គឺសិល្បៈស្ថាបត្យកម្ម និងផ្ទាំងសិលាចារឹកយ៉ាងច្រើន ចំនួនមិនតិចជាង ២០០០ ផ្ទាំងនោះហើយ ដែលជាអត្តសញ្ញាណជាតិខ្មែរ និង ត្រូវបានគេ ចាត់ទុកថា ជាប្រភពមូលដ្ឋានគ្រឹះនៃប្រវត្តិសាស្ត្រខ្មែរបុព្វបុរសយើងលោកដែលបានបង្កើតជាតួអក្សរឡើង ។យើងឃើញសិលាចរិកក្នុងចំណោមអត្ថបទសិលាចារឹក(ចារលើថ្ម) នាសម័យបុរាណទាំងនោះ មាន សិលាចារឹកវ៉ូកាញ់ ជាសិលាចរិកសស្ត្រឹតបានរកឃើញនៅឆ្នាំ១៨៨៤នៅភូមិវាំងកាញប្រហែល៤ គីឡូម៉ែត្រពីទីក្រុងញ៉ាត្រាងប្រទេសវៀតណាមសិលាចរិចនេះមានទម្រង់ជាបង្គោលថ្មកំពស់២.៥ម៉ែត្រ ដែលមានជ្រុងមិនស្មើគ្នាបី ដែលមានចំណាស់ចាស់ជាងគេនៅដែនដីអាស៊ីភាគអាគ្នេយ៍ ព្រោះត្រូវបានចារឡើងជា ភាសាសំស្ក្រឹត នាចុងស.វទី២ ដើមស.វទី៣ នៃគ.ស ដ៏គួរឲ្យមោទនៈសិលាចរិកនេះថ្លែងពីព្រះបាទ ស្រីមារ ព្រះបាទហ្វាន់ចេម៉ានទ្រង់ជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ។

នេះសបញ្ជាក់ឱ្យឃើញថា អក្សរសាស្ត្រខ្មែរយើងបានចាប់បដិសន្ធិចាប់ពីពេលនោះកមរហូតដល់បច្ចុប្បន្នហើយក៏មានការប្រែប្រួលទៅតាមរបត់នៃសង្គមផងដែរ។ តួយ៉ាងនៅសម័យអង្គរខ្មែរយើងបានកាន់លទ្ធិទេវរាជក្រោយមកលទ្ធិទេវរាជក៏បានចុះអន់ថយបន្តិចម្តងៗ ក្រោយមកមានការហូរចូលនៃព្រះពុទ្ធសាសនា ហិនយាន ដែលនាំចូលមកពីប្រទេសឥណ្ឌាស្រីលង្កាទ្វិប។ ហើយព្រះពុទ្ធសាសនាបានជ្រោលជ្រាបចូលមកសង្គមខ្មែរយ៉ាងឆាប់រហ័សនៅក្នុងសតិអារម្មណ៍ប្រជាពលរដ្ឋខ្មែរបានជឿស៊ប់ទៅក្នុងព្រះពូទ្ធសាសនាស្របពេលដែលខ្មែរកំពុងជួបនិង វិបត្តិសង្គ្រាម នឹងទំនាស់ផ្សេងៗ ពួកគេធ្លាក់ទៅក្នុងការអស់សង្ឃឹមសាសនាបានជួយលោងលោម និងផ្តល់កម្លាំងចិត្តដល់ពួកគេបន្ទាប់មកមានបៀបជាងទៅលើព្រហ្មណ៍សាសនា និងព្រះពុទ្ធសាសនាមហាយានផងដែរ។ទន្ទឹមនឹងនោះ ខ្មែរយើងក៏បានទទួលអារម្មណ៍របស់ប្រជាពលរដ្ឋខ្មែរនាសម័យនោះ ភាសាមួយទៀត គឺភាសាបាលី ។ ជាបណ្តើរៗ ខ្មែរបានបោះបង់ចោលភាសាសំស្ក្រឹត ប៉ុន្តែខ្មែរមិនបោះបង់ភាសាខ្លួនចោល ទាំងស្រុងនោះទេហើយអ្វីដែលពិសេសនោះ គឺខ្មែរយើងរក្សា និងបង្កើតភាសាជាតិ ដោយបានកាឡៃពាក្យបាលីឱ្យ មានសូរសំឡេងជាភាសាខ្មែរថែមទៀត ។ឧទាហរណ៍ ៖ ជយ > ជ័យ អាចម> អាចម៍ ... ជាដើម។

អក្សរសិល្ប៍សម័យក្រោយអង្គរ ឬសម័យកណ្តាល គឺសំដៅចំពោះសំណុំ ចង្កោមអត្ថបទទាំងឡាយណា ដែលអ្នកនិពន្ធរចនាឡើងជាភាសាខ្មែរកណ្តាល គឺគិតចាប់ពីស.វ ទី១៥ ដល់ ស.វ ទី១៩ ដែលភាគច្រើនជាអត្ថបទ សាស្ត្រា ឬក្រាំង។ អក្សរសិល្ប៍សម័យនេះមាន សម័យលង្វែក (១៤៣១-១៦១៨) សម័យឧដុង្គ(១៦១៨-១៨៦៣) និងសម័យអាណានិគមបារាំង(១៨៦៣-១៩៥៣)

### ៤.១.១. ការបែងចែកប្រវត្តិអក្សរសាស្ត្រខ្មែរ

ការបែងចែកអក្សរសាស្ត្រខ្មែរ បង្កើតបានតួអក្ខរៈជាលក្ខណៈពិសេសរបស់ជាតិខ្លួន ប្រកបដោយគំនិតច្នៃប្រឌិតខ្ពស់ ការបង្កើតតួអក្សរដើម្បីកត់ត្រាសូរសម្លេង ឬរឿងរ៉ាវ ប្រវិត្តិសាស្ត្រ ព្រឹត្តិការផ្សេងៗ ក្នុងអត្ថបទស្នាដៃអ្នកនិពន្ធរបស់កវីបណ្ឌិតបានខិតខំព្យាយាមបង្កើតជាងក្សរឡើងហើយមានការវិវត្តគ្រប់សម័យកាលរហូតមកដល់សព្វថ្ងៃនេះ។

បើតាមលោក លាង ហាប់អានលោកបានបែងចែកសម័យកាលប្រវត្តិអក្សរសាស្ត្រខ្មែរជា៤ ផ្នែកធំៗគឺ៖

- សម័យនគរភ្នំ ស.វ.ទី១ ដល់ ស.វ.ទី៦
- សម័យមុនអង្គរ ស.វ.ទី៦ ដល់ស.វ.ទី៩
- សម័យអង្គរ ស.វទី៩លដ់ ស.វទី១៤
- សម័យក្រោយអង្គរ ចុងស.វ.ទី១៤ ដល់បច្ចុប្បន្ន ហើយនៅក្នុងផ្នែកទី៤នេះ លោកបា

ក. បែងចែកជាបីកតូចៗទៀតគឺ៖

- សម័យលង្វែក ១៥២៥-១៥៩៣
- សម័យឧដុង្គ ចាប់ពីរជ្ជកាលព្រះបាទជ័យជេដ្ឋា(១៦១៨-១៦២៨) ដល់រជ្ជកាលអង្គឌួង (១៨៤៥-១៨៥៩)
- សម័យក្រុងភ្នំពេញ គិតចាប់ពីឆ្នាំ១៨៥៩ រហូតដល់សព្វថ្ងៃ។

គេបានបែងចែកអក្សរសិល្ប៍ទៅតាមស័មកាលប្រវត្តិសាស្ត្រគឺ

- សម័យមុនអង្គរ ស.វ.ទី១ ដល់ស.វ.ទី៩
- សម័យអង្គរ ស.វ.ទី៩ ដល់ស.វ.ទី១៥
- សម័យក្រោយអង្គរ ស.វ.ទី១៥ ដល់ស.វ.ទី១៨
- សម័យបារាំង១៨៦៣-១៩៥៣
- សម័យបច្ចុប្បន្ន ឆ្នាំ១៩៥៣ ដល់បច្ចុប្បន្ន។

បើតាមការសិក្សាយើងអាចនិយាយបានថានៅចុងសម័យអង្គរប្រទេសខ្មែរយើងបានជួបនិងសង្គ្រាមរាំរៃវិបត្តិផ្ទៃក្នុងមានទំនាស់ គឺបញ្ហាបច្ចាមិត្ររុករានទន្ទ្រានប្រទេសខ្មែរធ្វើឱ្យប្រជាពលរដ្ឋខ្មែររងទុក្ខវេទនាគ្មានថ្ងៃស្រាក់ស្រានទាំងផ្លូវកាយផ្លូវចិត្ត។ ហើយបញ្ហាទាំងពីរនេះបានជះឥទ្ធិពលអាក្រក់ដល់វិស័យនានាក្នុងសង្គមខ្មែរក៏មានផលប៉ះពាល់ទៅលើអក្សរសាស្ត្រផងដែរ។ ទោះជាយ៉ាងណាក៏ដោយអក្សរសាស្ត្រខ្មែរត្រូវបានជនបរទេសបំផ្លេចបំផ្លាញដោយការវាយលុកចូលប្រទេសខ្មែរហើយពួកគេបានដុតនិងយកទៅប្រទេសរបស់ខ្លួនក្បួនច្បាប់មានគម្ពីរជាច្រើនស្ទើរអស់ពីប្រទេសកម្ពុជា។យ៉ាងណាក៏ដោយប្រជាពលរដ្ឋខ្មែរបានថែរក្សាទុកនៅទីវត្តអារាមក្រោមដំបូលព្រះវិហារ ទោះជាប្រទេសធ្លាក់ក្នុងសភាពច្របូកច្របលយ៉ាងណាក៏ដោយវប្បធម៌ជាតិផ្នែកអក្សរសាស្ត្រខ្មែរមានការថែរក្សាពីសំណាក់ព្រះសង្ឃក្នុងការផ្សព្វផ្សាយដល់កូនចៅជំនាន់ក្រោយក្នុងការសិក្សាស្វែងយល់អប់រំគ្រប់វិស័យទាំងនេះ ដោយបានសរសេរចារ លើវត្ថុស្រាលៗ ដូចជា ស្លឹករឹត ស្លឹកត្នោត និងក្រាំង។

យោងតាមលោកបណ្ឌិត ឃីង ហុកឌី បានលើកឡើងថា អក្សរសាស្ត្រសម័យកណ្ដាល គឺសំដៅចំពោះ សំណុំ ចង្កោម អត្ថបទទាំងឡាយដែលនិពន្ធរចនាឡើងនៅក្នុងភាសា “ខ្មែរកណ្ដាល” គឺគិតតាំងពីស.វ.ទី១៥ ដល់ដើមសតវត្សទី១៩ ។

ចូរបកស្រាយបញ្ជាក់ដោយសង្ខេប?

## ខ..អក្សរសិល្ប៍ខ្មែរសម័យបុរាណ

## ក.អក្សរសិល្ប៍ខ្មែរសម័យមុនអង្គរ

- សម័យនគរភ្នំ សតវត្សទី១-៦ នៅក្នុងសម័យកាលនេះចារនៅលើសិលាចារឹកដែលនិយាយអំពីព្រះមហាក្សត្រនិងសាសនាមានប្រើពាក្យពេចន៍នគីភាសាសំស្ក្រឹត ។

- សម័យចេនឡា ពីសតវត្សទី៦ ដល់សតវត្សទី៩ ស្នាដៃអក្សរសិល្ប៍មានច្រើន គឺច្រើនបង្ហាញពីជំនឿប្រពៃណី ទំនៀមទំលាប់ ហេតុការណ៍នៃការកសាងសមិទ្ធផលផ្សេងៗ។ ការសរសេរជាភាសាសំស្ក្រឹត ភាសាខ្មែរបុរាណ ។

ខ.អក្សរសិល្ប៍ខ្មែរសម័យអង្គរ សតវត្សទី៩ ដល់សតវត្សទី១៥ នៅក្នុងសម័យនេះជាដំណាក់កាលរីកលូតលាស់យ៉ាងខ្លាំង។ នៅក្នុងការតាក់តែងនិពន្ធ មានការកត់ត្រាហេតុការណ៍ប្រទេសជាតិនិងជំនឿរបស់ព្រះមហាក្សត្រ។ អត្ថបទភាគច្រើនជាពាក្យកាព្យ ភាសាសំស្ក្រឹត ក្រៅពីនោះក៏មានភាសាខ្មែរផងដែរ គឺខ្មែរបុរាណ ។ នៅចុងសម័យអង្គរក៏មានការសរសេរជាភាសាបាលីផងដែរ ការសរសេរអត្ថបទគឺសរសេរនៅលើសិលាចារឹកនិងនៅលើស្បែក។

## ២.អក្សរសិល្ប៍ខ្មែរសម័យក្រោយអង្គរ ឬហៅថាអក្សរសិល្ប៍ខ្មែរសម័យកណ្ដាល

### ក.អក្សរសិល្ប៍ខ្មែរសម័យលង្វែកពីសតវត្សរ៍ទី១៥ ដល់សតវត្សទី១៧

នៅក្នុងសម័យកាលនេះអក្សរសិល្ប៍ក៏ដូចជាអក្សរសាស្ត្របានចុះថមថយ។ ខ្លឹមសារអត្ថបទមានលក្ខណៈស្រមើលស្រមៃប្រឌិតតាមមនោគតិរបស់អ្នកនិពន្ធ ស្នាដៃអ្នកនិពន្ធមួយចំនួនត្រូវបរទេសប្លន់យកទៅនៅពេលខ្មែរមានសង្គ្រាមជាមួយបទេសបែកបាក់បន្ទាយលង្វែក។ ការសរសេរជាសិលាចារឹកស្ទើរតែបាត់បង់ ក្រោយមកក៏មានការជំនួសសរសេរជាក្រាំងនិងសាស្ត្រា។

### ខ.អក្សរសិល្ប៍ខ្មែរសម័យឧត្តុង្គ ពីសតវត្សរ៍ទី១៧ ដល់សតវត្សរ៍ទី១៩

- នៅក្នុងសម័យកាលឧដុងគឺមានសង្គ្រាមជ្រៀតជ្រែកពីបរទេស គឺយួននិងសៀម និងមានជម្លោះរឹបត្តិរាជបល្ល័ង្កជាហូរហែ ចំណែកអក្សរសាស្ត្រជាតិនៅតែខិតខំនិពន្ធនិងផ្សព្វផ្សាយវប្បធម៌ អរិយធម៌របស់ខ្លួន ដោយមានការចូលរួមពីព្រះសង្ឃ ដើម្បីចន្សល់ទុកមកដល់សព្វថ្ងៃនេះ ដែលជាមូលដ្ឋានគ្រឹះដ៏សំខាន់នៅក្នុងវិស័យអក្សរសាស្ត្រជាតិ។ នៅសម័យនេះផងដែរជាសម័យកាលយុគមាស ដោយសំបូរអ្នកនិពន្ធ កវី បណ្ឌិតជាច្រើន រួមទាំងព្រះមហាក្សត្រ ដែលព្រះអង្គស្រឡាញ់នូវវិស័យអក្សរសាស្ត្រជាតិ អត្ថបទអក្សរសាស្ត្រអក្សរសិល្ប៍គឺទំនោរទៅរកសាសនាដោយលើកយកបែបជាតក និទានជាតក បញ្ញាជាតក ដែលយកយកតាមគំនិតជំនឿនិងជីវភាពរបស់ខ្លួន ការសរសេរជាពាក្យកាព្យ មានជាសាស្ត្រាល្បែង ការសរសេរអត្ថបទជាពាក្យកាព្យបទភុជង្គលីលា បទកាកគតិ ពំនោល ព្រហ្មគីតិ និងបទពំនោល ។

## ៣. អក្សរសិល្ប៍ខ្មែរសម័យទំនើប ឆ្នាំ១៨៦៣ មកដល់បច្ចុប្បន្ន

### ក. អក្សរសិល្ប៍ខ្មែរសម័យអាណាព្យាបាលបារាំង

- អក្សរសិល្ប៍ខ្មែរនៅក្នុងសម័យបារាំងបានធ្លាក់ចុះមានសេសសល់រត់ទៅជ្រកពួននៅក្រោមវត្តអារាមដោយព្រះសង្ឃជាអ្នកថែរក្សា មិនត្រឹមតែប៉ុណ្ណោះបានបង្ខំកូនខ្មែររៀនភាសាបារាំងបារាំងរាំង។ ដោយឃើញសភាពបែបនេះកវីនិពន្ធខ្មែរបានខិតខំនិពន្ធស្នាដៃ ដើម្បីបណ្ដុះបណ្ដាលកូនខ្មែរ អោយស្រលាញ់វប្បធម៌ជាតិរបស់ខ្លួនឡើងវិញ។ ក្នុងនោះអក្សរសិល្ប៍ខ្មែរបានដាក់ពីសាសនាជីវភាពសង្គមពិតវិញម្ដង ឬបង្កប់ការរិះគន់មកលើពួកអាណានិគមបារាំង។ ការសរសេរអត្ថបទជាពាក្យកាព្យមកជាពាក្យរាយម្ដង ។

### ខ. អក្សរសិល្ប៍ខ្មែរសម័យសង្គមរាស្ត្រនិយម ពីឆ្នាំ១៩៥៣ ដល់ឆ្នាំ១៩៧0

- អក្សរសិល្ប៍ខ្មែររីកចម្រើនឡើងវិញគ្រប់ផ្នែកដូចជាប្រលោមលោក កំណាព្យ ល្ខោន សៀវភៅបច្ចេកទេស ទស្សនវិជ្ជា ដែលមានទំនោរទៅរកជាតិនិយម និងរិះគន់សង្គមចាស់។ ស្នាដៃប្រលោមលោក សរសេរជាពាក្យរាយ ដែលមានទម្រង់ច្រើនបែបដូចជា ប្រលោមលោកមនោសញ្ចេតនា ស៊ើបអង្កេតនិងចារកម្ម ផ្សងព្រេងនិងអាថ៌កំបាំង ប្រវត្តិសាស្ត្រ នយោបាយ និងសង្គម និងប្រលោមលោកបែបទស្សនវិជ្ជា។

## គ. អក្សរសិល្ប៍ខ្មែរសម័យសាធារណរដ្ឋខ្មែរឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥

- អក្សរសិល្ប៍ខ្មែរសម័យនេះនៅតែមានសន្ទុះរីកចម្រើនជានិច្ច អក្សរសិល្ប៍មួយចំនួនមាននិន្នាការទ្រទ្រង់នយោបាយថ្មីនិង របបសាធារណរដ្ឋខ្មែរ ក៏មានការរិះគន់សង្គមចាស់និងរិះគន់សង្គមថ្មីផងដែរ។

## ឃ. អក្សរសិល្ប៍ខ្មែរសម័យកម្ពុជាប្រជាធិប្បតេយ្យឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩

- ការតែងនិពន្ធស្ទើរតែបាត់បង់ទាំងស្រុង ព្រោះខ្មែរក្រហមបំបិទសិទ្ធិសេរីភាព សម្លាប់ចោលអ្នកចេះដឹង អ្នកនិពន្ធខ្លះបាននៅរស់ត្រូវលាក់ខ្លួនកុំឱ្យគេដឹងថាខ្លួនចេះអក្សរ ស្នាដៃអក្សរសិល្ប៍គឺបម្រើឲ្យនយោបាយ ក្នុងរបបនេះអ្នកនិពន្ធបានលួចលាក់ ការរិះគន់របស់សង្គមខ្មែរក្រហមដូចជា មានអ្នកនិពន្ធលោកជួន ម៉ែន មើលផែនដីខ្មែរជាដើម។

## ង. អក្សរសិល្ប៍ខ្មែរក្រោយ៧ មករា ចាប់ពីឆ្នាំ១៩៧៩ដល់បច្ចុប្បន្ន

- ស្នាដៃអក្សរសិល្ប៍ស្របទៅតាមបន្ទាត់នយោបាយថ្មី ហើយរិះគន់សម័យកាលខ្មែរក្រហម គឺសម័យរបបកម្ពុជាប្រជាធិបតេយ្យស្នាដៃខ្លះទៀតរៀបរាប់ពីទុក្ខសោកនៃរបបចាស់ៗនិងអំពើឃោរឃៅនៃរបបនេះដែលបានប្រព្រឹត្តមកលើប្រជាជនខ្មែរស្លូតត្រង់ ចាប់ពីឆ្នាំ១៩៨៣ មកអក្សរសិល្ប៍មានការដុះឡើងវិញការតែងនិពន្ធបានរីកដុះដាលជាលំដាប់។

## ច. លក្ខណៈនិងវិវត្តិអក្សរខ្មែរពីសម័យបុរាណមកដល់បច្ចុប្បន្ន

- លក្ខណៈទី១ អក្សរបែបសិលាចរិក ហាន់ជ័យ កើតក្នុងសតវត្សប្រមណជាទី៦នៃគ.ស
- លក្ខណៈទី២ ងក្សរបេបសិលាចរិក វាលកន្ទែល កើតក្នុងសតវត្សតិ៦ ឬដើមសតវត្សតី៧
- លក្ខណៈទី៣អក្សរបែបសិលាចរិក អង្គជំនីក.លោក សឺដែស ហៅថា .ក្តិអង្គ.ក្នុងឆ្នាំ គ.ស៦៦៧
- លក្ខណៈទី៤ អក្សរបេបសិលាចរិក ព្រះឥន្ទកោសីយក្នុងឆ្នាំ ៦៧០
- លក្ខណៈទី៥ អក្សរបែបសិលាចរិក ព្រះកែវ . លោក សឺដែស ហៅថា តាកែវ ក្នុង គ.ស១០០២
- លក្ខណៈទី៦ អក្សរបេបសិលាចរិក ព្រហនក ក្នុង គ.ស ១០៦៦
- លក្ខណៈទី៧ អក្សរបែបសិលាចរិក បន្ទាយឆ្មារ ក្នុងសតវត្សតី១២ ឬដើមសតវត្សទី១៣ នៃ គ.ស
- លក្ខណៈទី៨ អក្សរបែបសិលាចរិក អង្គរវត្ត ក្នុងសតវត្សទី១៣ នៃគ.ស
- លក្ខណៈទី៩ អក្សរបែបសិលាចរិក អង្គរ ក្នុងឆ្នាំ១០៧២ នៃគ.ស
- លក្ខណៈទី១០ អក្សរបែបបច្ចុប្បន្ននេះ។

សរុបសេចក្តីមកអក្សរសាស្រ្តខ្មែរបានជួយ អ្នកសិក្សាឱ្យមានចំណេះដឹង បានស្វែងយល់ពីការវិវត្តនៃអក្សរសាស្រ្តខ្មែរ និងការបែងចែកនិងទៅតាមដំណាក់កាលនីៗមួយផងដែរ។

## ១.អក្សរសិល្ប៍សាស្ត្រាស្លឹករឹត

មានការកកើតតាំងពីយូយារណាស់មកហើយមុនសម័យកណ្តាលទៅទៀត ហើយគេសង្កេតទៅលើឧបករណ៍ប្រើប្រាស់ មានការសរសេរតាំងពីរាប់រយឆ្នាំមុនគ.ស មកម្លេះ ការសរសេរមានលក្ខណះបុរាណ តាំងពីស.តវត្សទី៦មុនគ្រិស្តសករាជ សរសេរឬ ចារច្រើនធ្វើនៅលើស្លឹក នៅលើស្បែក នៅលើក្រដាស ហើយចារនៅលើថ្ម ...។ អក្សរដែលនៅសេសសលនៅសិលាចរិត រីឯស្បែកសត្វ និងស្លឹករឹតបានខូចអស់ទៅហើយ ពុំអាចរក្សាទុករហូតដល់បច្ចុប្បន្នបានឡើយ។ នៅពេលចុងក្រោយបំផុតគេចារលើក្រដាសផ្នត់ហៅថា ក្រាំង ឯកសារនេះប្រើមិនបានយូ។ វាតែងឱ្យគេចម្លងសាជាថ្មីមានរវាងពី៥០ ទៅ៨០ឆ្នាំម្តង។សាស្ត្រាបានសរសេរលាត្រដាងចង្ក្រាញ

ឱ្យយើងបានឃើញនូវ វប្បធម៌ អរិយធម៌ ការគោរពសាសនា ហើយបុព្វបុរសយើងរៀនចេះចាំអក្សរតាមសាស្ត្រ។ យើងអាចដឹងបានថាវត្ថុទាំងនោះត្រូវបានគេយកមកប្រើប្រាស់សម្រាប់សរសេរដោយសម្អាងលើឯកសារ ជីវតាក្ខាន់ លិខិតជម្មតា និងអត្ថបទទាំងអស់ ដូចជាឯកសារផ្លូវការ ជាដើម សុទ្ធតែសរសេរលើស្បែកសត្វប្រើស រមាំង ឬ ស្បែក ដទៃទៀត ដែលគេយកមកហាលស្ងួតលាបពណ៌ខ្មៅ ។ គេ កាត់ស្បែកនោះឲ្យមានទំហំធំ ឬតូច ទៅតាមសេចក្ដីត្រូវការ និងយកម្សៅម៉្យាងមកប្រើ មានសណ្ឋានដូចដីសនៅ ស្រុកចិន ដោយលុញឲ្យវែង ចិតចុងស្រួច គេហៅថា សោ ហើយគេសរសេរដោយដៃបានជាប់ជិតល្អណាស់មិនងាយ នឹងរលុបឡើយ ។ ជាមួយគ្នានេះនៅក្នុងសិលាចរិតខ្លះក៏បានឱ្យដឹងថា មានការធ្វើគម្ពីរ ស្លឹក មាស ប្រាក់ ដែលគម្ពីរនោះហៅថា Rikta ។ ហើយគេសន្និដ្ឋានថា គម្ពីរឬ Rikta សន្លឹកនេះគឺប្រហែលសាស្ត្រស្លឹករឹតបច្ចុប្បន្ន ។ បណ្ណាការចេនឡាស្លឹករឹត ក្រាំង

សាស្ត្រស្លឹករឹតត្រូវបានធ្វើពីស្លឹកទ្រាំង ឬ ចាស់បុរាណហៅថា ស្លឹកសម្លាញ ដែលប្រទះក្នុងសិលារឹត បុរាណផងដែរ ពេលខ្លះគេប្រើស្លកត្នោត ប៉ុតែពិបាកចារ ។ តាមវចនានុក្រមខ្មែរ សម្ដេចសង្ឃរាជ ជួន ណាត ទ្រាំងគឺជាឈ្មោះ ចកសារព្រឹកមួយ សណ្ឋានព្រៃ មានធាងវែង មានស្លឹកប្រើការច្រើនយ៉ាងចារសាស្ត្រហៅថាស្លឹករឹត.....ដុះពីគ្រាប់វាក្នុងព្រៃធំៗនៅក្នុងប្រទេសកម្ពុជា មាននៅខេត្រក្រចេះនិងកំពង់ធំ ។ វាជារុក្ខជាតិដែលមានអាយុវែងជាងអាយុមនុស្ស រុក្ខជាតិមានផ្កាផ្លែនៅចុងផ្កាផ្លែហើយដើមវាក៏ងាប់ដែរ....។ ដើមទ្រាំង អាចយកទៅច្នៃធ្វើជា រំពាត់ ដំបង ពន្លូមូល ដាម.....រីឯស្លឹកទ្រាំងធ្វើសំពៀត ស្បោង កន្ទេល ស្លឹកភ្នល់ ស្លឹករឹត....11។ទុកសរសេរសាស្ត្រល្បែងចូលតាមលោកគ្រូទឹមសុហួយ។

## ៤.២. ទិដ្ឋភាពទូទៅសម័យលង្វែក

បើយើងនិយាយពីសម័យលង្វែកប្រទេសយើងជួបវិបត្តិដ៏ធ្ងន់ធ្ងរគឺវិបត្តិទំនាស់ផ្ទៃក្នុង មានការរុករានទម្រានបានយកទ្រព្យសម្បត្តិ របស់មានតម្លស គម្ពីរក្បួនច្បាប់ អ្នកប្រាជ្ញកវីបណ្ឌិត ពូជពង្សរាជវង្ស និងប្រជារាស្ត្រខ្មែរជាច្រើន។ ធ្វើឱ្យប្រទេសខ្មែរបានជួបក្ដីទុក្ខលំបាកវេតនាគ្រប់បែបយ៉ាងបាត់ទេសជិតខាងមិនចេះយ៉ាងមិនចេះចប់មិនចេះហើយ សច្ចាឫអាមិត្តទន្រ្ទាមប្រទេសខ្មែរនាំឲ្យមានការបែកបាក់បន្ទាយលង្វែក ស្ដេចខ្មែរលើករាជធានីផ្លាស់ប្ដូរជាច្រើនកន្លែងសង្ឃឹមថាគេចផុតបីការយាយីពីសំណាក់ប្រទេសជិតខាង មានសៀម និងវៀតណាម ក្រោយមកព្រះអង្គមកតាំងរាជធានីនៅចតុមុខវិញតែនៅតែមិនទទួលបានសេចក្ដីសុខផ្សេងក្សាន្តបន្តដដែល កាន់តែជួបនិងវិបត្តិធ្ងន់ធ្ងរទៅទៀត ។ ឥទ្ធិពលទាំងនោះបានជះឥទ្ធិពលអាក្រក់គ្រប់បែបយ៉ាង ព្រមទាំងធ្វើឱ្យវិស័យអក្សរសាស្ត្រខ្មែរបានតទួលវិបត្តិធ្ងន់ធ្ងរស្ទើរផុតដង្ហើម ប៉ុន្ដែអក្សរសាស្ត្រខ្មែរបានរត់ទៅជ្រកកោននៅក្នុងទីវត្តអារាម ដែលមានព្រះសង្ឃជាអ្នកការពារ និងផ្សព្វផ្សាយដល់ប្រជាពលរដ្ឋខ្មែរ ។ វត្តអារាមជាសាលារៀន ជាកន្លែងផ្ទុកនូវចំនេះដឹង ប្រាជ្ញាពុទ្ធិ រួមទាំងផ្នែកស្មារតីផងដែរ។ ហើយសិក្ខាកាមនៅសាលាវត្តនេះហើយ ដែលជាអ្នកផលិតអក្សរសាស្រនៅសម័យកណ្ដាល ដោយមានការសរសេរទៅលើវត្ថុស្រាលៗដូចជាស្លឹករឹក ស្លឹកត្នោត និងក្រាំង។

នៅក្នុង គ.ស ១៣៣៦.១៥៩៣ ប្រមាណជា ៣ សតវត្សនេះប្រទេសជាតិមានការរាតត្បាតក្លាយទៅជាចម្បាំងរាងជល់ជាមួយពួកប្លន់ទឹកដីគឺសៀមនេះឯង ។ វិបត្តិកើតមានតាំងតែពីឆ្នាំ ១៣៥៣ រហូតដល់ឆ្នាំ ១៥៩៣ ជាឆ្នាំបាត់បង់ក្រុងលង្វែកក្នុងរយៈពេល ២៤០ ឆ្នាំ ប្រទេសរងទុកវេទនាប្រជារាស្ត្ររត់ទ័ពហើយព្រះមហាក្សត្រព្រះអង្គខិតខំទប់ទាល់សត្រូវដើម្បីរក្សាទឹកដីសបូរណភាពទឹកដី ឯករាជ្យជាតិគ្រប់ ពេលវេលា ។ព្រមទាំងវិស័យនានាត្រូវថបថយចុះ ដូចជា ការកសាងសម្និតផល បុរាណដ្ឋានព្រមទាំងវិស័យសេដ្ឋកិច្ច ជាដើម ដោយសារប្រទេសជួបវិបត្តិគ្រប់ពេលវេលាដូច្នេះការសិក្សាតែងនិពន្ធក្បួនខ្នាតឬការចងក្រងកត់ត្រានូវព្រឹត្តិការណ៍ផ្សេងៗ ក៏ថប់ថយមនុស្សត្រូវរស់នៅក្នុងសេចក្ដីទុក្ខភ័យជានិច្ចសេចក្ដីសង្ឃឹមគឺស្ថិតនៅលើជំនឿក្នុងត្រៃសាណគមន៍ជាគ្រឿងសំអាងជួយផ្ដល់នៅសេចក្ដីសុខចម្រើនសម្រាប់ជនថ្មីតាមអ្នកបរលោកពីព្រោះម្នាក់ៗ ពុំដឹងជាត្រូវស្លាប់ដោយចម្បាំងខ្មាំងសត្រូវវាយយាយីថ្ងៃណាមួយមិនប្រាកដ ។ មនុស្សសឹងតែទូទៅនាំគ្នាធ្វើបុណ្យរហូតដល់ព្រះមហាក្សត្រជាដើមដែលព្រះអង្គមានព្រះរាជហ ឬទ័យក្នុងការកសាងកុសល ឬការបន់ស្រន់លាបំណាំសូមប្រាថ្នាសេចក្ដីសុខក្សេមក្សាន្តសន្តិភាពចំពោះប្រទេសនិងប្រជារាស្ត្រភស្តុតាងនៅក្នុងសិលាចារឹករបស់លោក ជ័យ នន្ទ នៅអង្គរវត្តជាដើម។

បើយោងតាមប្រភពទំព័ររឿងបូរាណ គឺបន្ទាយលង្វែក (រូបគំនូរដែលជនជាតិបរទេសបានគូរក្រោយពេលបន្ទាយបានបែក) ។ សម័យលង្វែក (១៤៣១-១៦១៨) គឺជាសម័យក្រោយពីរជ្ជកាលព្រះបាទពញាយ៉ាត ដែលកាលនោះប្រទេសកម្ពុជាកើតមានចម្បាំងជាច្រើនលើកច្រើនសា។ រាជធានីត្រូវបានផ្លាស់ប្តូរជាច្រើនកន្លែងវិលចុះវិលឡើងពីក្រុងអង្គរ ទួលបាសាន្ត (កំពង់ចាម) ភ្នំពេញ (ចតុមុខ) រហូតមកដល់លង្វែក (កំពង់ឆ្នាំង)។ រាជធានីលង្វែកត្រូវបានកសាងឡើងរយៈពេល៣ឆ្នាំ គឺពីឆ្នាំ១៥២៧ ដល់ ១៥២៩ ក្នុងរាជព្រះបាទចន្ទរា នៅកណ្តាលរាជធានីលង្វែក បានសាងវត្តមួយឈ្មោះវត្តត្រឡែងកែង មាននៅសល់រហូតមកដល់សព្វថ្ងៃ កសាងវត្តអារាមជាច្រើននៅ ខេត្តពោធិ៍សាត់ បរិបូណ៍ ជួសជុលវត្តនៅឧដុង្គមានវត្តលើភ្នំរាជទ្រព្យជាដើម (ព្រះពុទ្ធរូបចូលព្រះនិព្វាន)។ទីតាំងភូមិសាស្ត្រ រាជធានីលង្វែក ជាទីតាំងប្រវិត្តសាស្ត្រខ្មែរមួយដែលសព្វថ្ងៃស្ថិតនៅក្នុងស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ជាកន្លែងយុទ្ធសាស្ត្រមានទន្លេ បឹង ជាពិសេសព្រែក។ ព្រះអង្គបញ្ជាឱ្យមន្ត្រីគ្រប់ជាន់ថ្នាក់កេណ្ឌប្រជានុរាស្ត្រកាប់ម្ការព្រៃ ជញ្ជូនដីដើម្បីបានកន្លែងក្នុងការកសា បន្ទាយ និងរាជវាំង មានកំពែងការពារ ៥ជាន់ ព្រមទាំងដាំរបង ឫស្សីយ៉ាងក្រាសដើម្បីការពារសត្រូវក្រោយកមក៏មានការការបែកបាក់បន្ទាយលង្វែកជួបនិងវិបត្តិរងទុកវេទនាថែមទៀតផង។

## ក.ស្ថានភាពនយោបាយ សម័យលង្វែក

នៅសម័យលង្វែកមានវិបត្តិរាជវង្សជាញឹកញាប់ ព្រះបាទសត្ថាទី១ ដាក់រាជ្យថ្វាយទៅបុត្រច្បងព្រះនាមជ័យជេដ្ឋាទី១ មានព្រះជន្ម ១១ ព្រះវស្សាព្រោះខ្លាចព្រះអនុជព្រះនាមស្រីសុរិយោពណ៍ដណ្តើមរាជសម្បត្តិ ដោយព្រះបាទស្រីសុរិយោពណ៍មានសមត្ថភាព និងប្រជាប្រិយភាព ការបាត់បន្ទាយលង្វែកធ្វើឲ្យខ្មែរអស់ឫទ្ធានុភាព អស់ក្បួនច្បាប់ សត្រូវប្រមូលទ្រព្យសម្បត្តិ និងរបស់មានតម្លៃយកទៅស្រុកសៀមអស់។

## ខ.ផ្នែកកសិកម្ម

ផ្នែកកសិកម្មមានសកម្មភាពខ្លាំង មានការយកព្រះទ័យទុកដាក់ពីព្រះរាជា ផ្តល់ដីធ្លីដល់ប្រជារាស្ត្រធ្វើស្រែចម្ការ បានជីកអូរ ព្រែក ប្រឡាយ សម្រាប់ផ្គត់ផ្គង់ទឹកក្នុងកាងារកសិកម្ម ថែមទាំងកាប់ឆ្ការព្រៃដើម្បី បានដីបន្ថែមនៅរដូវបង្កបង្កើនផល និងប្រមូលផលគេតែងតែបញ្ឈប់សង្គ្រាមដើម្បីជួយប្រជារាស្ត្រក្នុងការ

ប្រកបរបរកសិកម្ម។

## គ.ពាណិជ្ជកម្ម

បឹងទន្លេសាបជាកន្លែងផ្តល់ប្រយោជន៍ជាច្រើនមាន សម្បូរត្រី ដីនៅជុំវិញសម្បូរជីជាតិទន្លេមេគង្គជាផ្លូវទឹកដ៏សំខាន់សម្រាប់ដឹកនាំទំនិញទៅលក់ឯបរទេសបានជួយសម្រួលដល់ការដឹកទំនិញ វិស័យពាណិជ្ជកម្មមានការរីកចម្រើន ក្នុងរជ្ជកាលព្រះបាទពញាយ៉ាត ស្តេចកនចន្ទរាជា ... ប្រទេសកម្ពុជាសុទ្ធតែបាននាំទំនិញទៅលក់នៅបរទេស បានទិញមកវិញនូវគ្រឿងសាស្ត្រាវុធ ព្រះបាទបរមរាជាបានធ្វើទំនាក់ទំនងជាមួយពួកអឺរ៉ុប ជប៉ុន ចិន ជ្វា ឱ្យមករកធ្វើជំនួញស្រុកខ្មែរយ៉ាងច្រើនសន្ធឹកសន្ធាប់ ពួកគេបាននាំទំនិញចូលប្រទេសខ្មែរមានជាកំណាត់សំពត់ ឧបករណ៍ប្រើប្រាស់ផ្សេងៗ បាននាំចេញទៅវិញនូវគ្រឿងទេស ភ្លុកដំរី ស្នែង ជ័រ ស្បែក ។

## ឃ.សិប្បកម្ម

សិប្បកម្មនៅមានការអន់ថយនៅឡើយ។ សកម្មភាពសំខាន់ក្នុងសម័យនោះគឺការស្លដែក ដែលមានសន្ទុះខ្លាំងក្លាចាប់ពីរជ្ជកាលព្រះបាទចន្ទរាជា ព្រះអង្គបានយកព្រះទ័យទុកដាក់នឹងបញ្ហានេះណាស់។ ប៉ុន្តែការប្រើដែលជាវត្ថុធាតុដើម មានរបរដំដែកជាដើម មានសកម្មភាព តាំងពីក្នុងរជ្ជកាលព្រះបាទពញាយ៉ាតម្ល៉េះ។ពួកសៀមបានប្រមូលយកព្រះគោ ព្រះកែវ ទ្រព្យសម្បត្តិក្បួនខ្នាត និងឯកសារផ្សេងៗជាច្រើនយកទៅស្រុកសៀម។ព្រះបាទសត្ថាទី១ និងបុត្រព្រះនាមជ័យជេដ្ឋាទី១ ភៀសព្រះកាយទៅនៅដែនដីលាវ ហើយក៏សោយទិវង្គតនៅទីនោះទៅ ក្នុងឆ្នាំ ១៥៩៦។ ឯព្រះបាទស្រីសុរិយោពណ៍ ត្រូវសៀមចាប់បាននាំយកទៅស្រុកសៀម។

## ខ.ផលវិបាក

ក្រោយពីបែកបាក់បន្ទាយលង្វែកមកបន្ទាយលង្វែកមក ប្រទេសកម្ពុជាអស់ឫទ្ធានុភាព ហើយធ្លាក់ទៅជារដ្ឋទន់ខ្សោយមួយនៅតំបន់អាស៊ីអាគ្នេយ៍។ ខ្មែរបានបាត់បង់កេតនភណ្ឌជាតិ ក្បួនច្បាប់ អ្នកប្រាជ្ញ បណ្ឌិត ហើយវប្បធម៌ខ្មែរ ក៏ត្រូវសៀមឆក់ប្លន់យកទៅប្រទេសវាស្ទើរតែអស់រលីង។ ប្រទេសជាតិធ្លាក់ទៅក្នុងភាពអនាធិបតេយ្យ ហើយគ្រោះទុរភិក្សបានចូលមកយាយីប្រជារាស្ត្រខ្មែរពេញផ្ទៃប្រទេសប្រទេសកម្ពុជាបានបាត់បងអាណាខែត្រ ខាងលិច និងពាយព្យ ដូចជា ខែត្រចន្ទបុរី បស្ចិមបុរី នគររាជសីមា សៀមរាប ពោធិ៍សាត់ ។ ការរកឃើញសម្ភារថ្មីៗនៅតំបន់លង្វែក ឬក្នុងខេត្តកំពង់ឆ្នាំ ចំពោះលោក Polkinghorne ភ័ស្តុតាំងនៅលើដីរួមជាមួយនឹងអ្វីដែលកំពុងត្រូវបានជីក បង្ហាញថាលង្វែកជាកន្លែងល្បីមិនងាយបំភ្លេចបានដែលត្រូវធ្វើការស្រាវជ្រាវ។ការរកឃើញដ៏កម្រមួយធ្វើឲ្យអ្នកបុរាណវិទ្យាភ្ញាក់ផ្អើលគឺបំណែកកុលាលភាជន៍នៃក្រឡសតវត្សរ៍ទី ១៦ មកពីខេត្តហ្វ៊ូជាន (Fujian) ប្រទេសចិនដែលត្រូវបានរកឃើញកាលពីដើមឆ្នាំនេះនៅជិតសិប្បកម្មឡឥដ្ឋមួយនាពេលបច្ចុប្បន្ន។លោកស្រី Yuni Sato ដែលជាអ្នកជំនាញបុរាណវិទ្យាមកពីវិទ្យាស្ថានជាតិស្រាវជ្រាវដើម្បីទ្រព្យសម្បត្តិវប្បធម៌ (NARA) របស់ជប៉ុនបានថ្លែងថា ការរកឃើញវត្ថុបែបនេះដំបូងបំផុតគឺរកឃើញនៅវត្តសាកៃនៅតំបន់ឆ្នេរភាគខាងត្បូងនៃកោះ ហុងស្ស៊ូរបស់ប្រទេសជប៉ុន ។ ឈរនៅខាងក្រៅផ្ទះមួយដែលក្រុមអ្នកបុរាណវិទ្យានេះបានជួលនៅក្នុងឃុំលង្វែក លោកស្រី Sata បានបង្ហាញអំពីកែរពណ៌ខៀវ និងសនៅលើថាសប្លាស្ទិកដែលលោកស្រីថា ជារបស់សម័យត្រីមាសទី ២ នៃសតវត្សរ៍ទី ១៦ ហើយធ្វើជាចានគោមកុលាលភាជន៍មួយ ។ វត្តមាននៃកុលាលភាជន៍ទាំងអស់នេះបង្ហាញថា លង្វែកជាផ្នែកពាណិជ្ជកម្មដ៏សំខាន់ជាងការសន្មតកាលពីពេលមុនៗ ។ លោកស្រីបានថ្លែងថា «វាគឺពីសម័យដំបូងបំផុតនៃសម័យលង្វែក ដែលព្រះមហាក្សត្រអាចនាំចូលចានគោមពណ៌ខៀវ និងពណ៌សដែលមានគុណភាពល្អ [មានន័យថា នេះជាផ្នែកនៃភ័ស្តុតាងបង្ហាញអំពីអំណាចនៃព្រះមហាក្សត្រសម័យលង្វែក ។ ខណៈក្រុមនេះដើរតាមព្រៃគុម្ពោតនៅជិតវត្តសុភិរង្សីដែលវត្ថុសេសសល់ពីប្រាសាទសម័យអង្គរនៅអាចរកឃើញនៅឡើយ ដែលសម្ភារទៅដោយកុលាលភាជន៍រួមទាំងកែរទំហំប៉ុនក្រចកដៃដែលសមាជិកក្រុមរបស់លោក Polkinghorne បានកំណត់អត្តសញ្ញាណថា ទំនងជាមកពីប្រទេសចិន។ លោកបានថ្លែងថា បំណែកដែលសម្ភារទាំងនេះអាចរកឃើញនៅពេលព្យុះដីស្រែម្តងៗត្រូវបាននាំយកទៅធ្វើការវិភាគ។

១.លោកស្រី Sato បានថ្លែងថា៖ «ការនាំចូលចំនួនកុលាលភាជន៍ទាំងនេះបានមានន័យថាពួកគេមានអំណាចគ្រប់គ្រាន់ដើម្បីរក្សាទំហំនៃទីក្រុងនេះ និងអាចធ្វើពាណិជ្ជកម្មនៅបរទេស និងបានកសាងពង្រឹងមិត្តភាពជាមួយនឹងបរទេសរួចហើយ។

២.លោក Polkinghorne ថ្លែងថាកាលពីខែមុនក៏បានរកឃើញដាវដែកមួយផងដែរដែលធ្វើឱ្យមានសំណួរចោទឡើងថា តើវត្ថុបែបនេះចេញមកពីណា និងស្ថានភាពយោធារបស់កម្ពុជានៅសម័យនោះ ។ លោកបានបន្តថា ដែកគោលជាច្រើនគឺជាភ័ស្តុតាងនៃស្ថាបត្យកម្មឈើដ៏ស្មុគស្មាញបើទោះបីជាអតីតទីតាំងរាជវាំងរបស់ព្រះអង្គចន្ទត្រូវបានគេសន្មតថា ត្រូវបានសាងសង់នៅក្នុងទសវត្សរ៍ឆ្នាំ ១៥៥០ ក្តី ហើយកាន់តែធ្វើឲ្យក្រុមការងារខិតខំស្រាវជ្រាវបន្ត ។

៣. លោកបញ្ជាក់ថា៖ «យើងកំពុងមានភាពកក់ក្តៅរៀងរាល់ថ្ងៃ» ។ ខណៈដែលការធ្វើផែនទីគឺកំពុងធ្វើឡើងដោយប្រព័ន្ធឡាស៊ែរដើម្បីបង្ហាញគ្រឹះទីក្រុងឲ្យច្បាស់នោះ ជញ្ជាំងបាក់បែកមើលទៅមិនមានអ្វីច្រើនលើសពីការធ្វើពីដីនោះទេ ហើយជាទូទៅអ្នកដែលមិនបានសិក្សាស្វែងយល់គឺមិនសូវចាប់អារម្មណ៍ទេជួនកាលការធ្វើនគរូបនីយកម្មពីរាជធានីភ្នំពេញ អាចនឹងបង្កការខូចខាតចំពោះស្ថានីយបុរាណវិទ្យា ។ ចំពោះការគំរាមកំហែងនេះមិនមែនរដ្ឋាភិបាលមិនបានកត់សម្គាល់នោះទេ ។ ថ្លែងទៅកាន់អ្នកភូមិជិត ១០០ នាក់នៅវត្តត្រឡែងកែងកាលពីថ្ងៃទី ២៩ ខែមករាអគ្គនាយកនៃអគ្គនាយកដ្ឋានបេតិកភណ្ឌរូបីនៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ លោក ប្រាក់ ស៊ុនណារ៉ា បានថ្លែងថា វិធានការផ្លូវច្បាប់នឹងត្រូវធ្វើឡើងដើម្បីប្រឆាំងក្រុមហ៊ុន ឬបុគ្គលណាដែលបានរំលោភលើច្បាប់អភិរក្សនៅឯកន្លែងអភិរក្សដូចជា នៅលង្វែកនេះជាដើមជាកន្លែងដែលមានមួយករណីរួចហើយដែលក្រសួងបានដឹង និងកំពុងបន្តពិនិត្យតាមដាន។លោកបញ្ជាក់ថា៖ «យើងនឹងមានវិធានការប្រឆាំងនឹងអ្នកដែលបានប្រព្រឹត្តបទ ល្មើស ទាំងនោះ។ ទី ១ គឺចំពោះក្រុមហ៊ុនណាដែលបាន

រំលោភបំពានលើជញ្ជាំង ហើយទី ២ យើងមានវិធានការប្រឆាំងនឹងម្ចាស់ដីដែលបានលក់ដីទៅឱ្យក្រុមហ៊ុន។ យើងមិនបានហាមឃាត់ដល់ការអភិវឌ្ឍទេ ប៉ុន្តែមុនពេលអ្នកធ្វើអ្វីមួយ អ្នកត្រូវតែស្នើសុំការអនុញ្ញាតឲ្យស្របច្បាប់ ដូច្នេះហើយទើបយើងអាចសិក្សាអំពីផលប៉ះពាល់ជាមុនបាន។

៤.លោក Polkinghorne បានកត់សម្គាល់ថាការថ្លឹងថ្លែងអំពីការអភិវឌ្ឍទល់នឹងការអភិរក្សគឺជាតុល្យភាពមួយដ៏ពិបាក ហើយក្រុមការងាររបស់លោកត្រូវតែប្រុងប្រយ័ត្នខ្ពស់នៅពេលដែលពួកគេបំពេញការងារ។ បច្ចុប្បន្ននេះពួកគេកំពុងប្រើប្រាស់ម៉ាស៊ីនអេស្កាវ៉ាទ័រកាយលើជញ្ជាំងបាក់បែកមួយចំណែកដែលអាចនាំឱ្យអ្នកភូមិចោទសួរថា ហេតុអ្វីបានជាពួកគេមិនអាចប្រើប្រាស់ឧបករណ៍បែបនេះនៅលើទ្រព្យសម្បត្តិរបស់ពួកគេបាន។

៥.លោកថ្លែងថាៈ «វាពិបាកក្នុងការពន្យល់ថាឧបករណ៍បែបនេះត្រូវប្រើបានដោយផ្ចិតផ្ចង់ និងប្រុងប្រយ័ត្នខ្ពស់»។

លោកមានប្រសាសន៍ថា «លក្ខណៈខាងក្រៅនៃការរស់នៅ និងការប្រើប្រាស់ភាសាក្នុងតំបន់ឬរបៀបដែលមនុស្សសាងសង់ផ្ទះសំបែងរបស់ពួកគេនៅសម័យនោះគឺវាស្ទើរតែដូចគ្នាទៅនឹងសម័យបច្ចុប្បន្ននៅតាមតំបន់ផ្សេងៗទៀតនៅក្នុងប្រទេសកម្ពុជាដែរ ដូច្នេះហើយយើងពិបាកក្នុងការកំណត់ថា តើប្រពៃណីបែបណាជារបស់សម័យលង្វែកនោះទេ»។

## ក.ព្រះមហាក្សត្រសំខាន់ៗនៅសម័យលង្វែកមានៈ

នេះជាតំណព្រះរាជវង្សព្រះបាទត្រសក់ផ្អែមគ្រាព្រះបាទត្រសក់ផ្អែមឡើងសោយរាជ្យក្នុគ.ស១២៩០.ហើយទ្រង់ចូលទីវង្គលក្នុងរាជសម្បត្តិក៏ធ្លាក់ទៅឲ្យព្រះរាជបុត្រច្បងព្រះនាមព្រះការព្រះបាទនិទានបានរាំទីវង្គតក្នុងគ.ស ១៣០៧រាជសម្បត្តិធ្លាក់ទៅលើរាជបុត្រច្បង ព្រះនាបព្រអនិពានបាទ ក.ស ១៣៤០ ១៣៤៦។កាលព្រះបាទនិពានបានចូលទិវង្គតទៅព្រះអានុជព្រះនាម សិទ្ធន្តទទួលរាជសម្បត្តិបន្ត គ.ស ១៣៤៦ បានតែ៦ឆ្នាំក៏សុគតទៅទៀត។

- ព្រះស្រីលំពង់រាជា គ.ស ១៣៤៧ .១៣៥៣ រាជធានីអង្គរធំ
- ព្រះរាជាស្រីសុរិយោទ័យគ.ស ១៣៥៣
- ព្រះបាទស្រីសូរិយោវង្ស គ.ស ១៣៥៧ ១៣៦៦
- ព្រះបាទមរមេរាមា គ.ស ១៣៦៦ .១៣៧៣ រាជធានីអង្គរធំ
- ព្រះបាទធម្មាសោ គ.ស ១៣៧៣ ១៥៩៤
- ព្រះបាទស្រីសុរិយោវង្សទី ២ គ.ស ១៤០១ .១៤១៧
- ព្រះបាទមរមេសុខា គ.ស១៤១៧ .១៤២០
- ព្រះបាទសម្តេចព្រះពញាយ៉ាត គ.ស ១៤២១ ១៤៦៤ ទ្រង់គង់នៅនគរធំបាន ៥ ឆ្នាំក្នុង គ.ស ១៤២៦ ស្តេចមកគង់នៅទួលបាសន្ធរបានមួយឆ្នាំបានផ្លាសរាជធានី មកគង់នៅចតុមុខភ្នំពេញក្នុង គ.ស ១៤២៧
- ព្រះនារាណ៍រាមាធិបតី គ.ស ១៤២២ .១៤៦៧ រាជធានីចតុមុខ
- ព្រះធម្មរាជាទី១ គ.ស ១៤៧៤ .១៤៩៨
- ព្រះបាតសុគន្ធបទ ១៤៩៨ . ១៥០៥ រាជធានីនៅទួលបាសាន
- ព្រះបាទអង្គចន្ទទី១ គ . ស ១៥១៥ .១៥៥៥ ទ្រង់លើករាជធានីមកតាំងនៅលង្វែកក្នុងឆ្នាំ ១៥២៨
- ព្រះបាទសម្តេចព្រះបរមមិន្ទររាជា គ.ស ១៥៥៥.១៥៦៧រាជធានីលង្វែក
- ព្រះបរមហិន្ទរាជា ឬ ព្រះសត្ថាទី១ គ.ស ១៥៦៧ .១៥៧៤ រាជធានីលង្វេក
- ព្រះបាទជ័យជេត្ថាទី១ឬ ព្រះជ័យជេស្ថា គ.ស ១៨៧៥ .១៥៩៣ សៀមយកបន្ទាយលង្វែ។
- ជារួមនៅសម័យលង្វែក ប្រទេសខ្មែរបានជួបនិងវិបត្តគ្រប់បែបយ៉ាង ទំនាស់ផ្ទៃក្នុង បរទេសឈ្លានពាន ប្រជាជនខ្មែរជួបវិបត្តអស់សង្ឃឹម មិនដឹងថាខ្លួនស្លាប់ដោយសារស

គ្រានៅពេលណាទេ ពួកគេពឹងផ្អែកទៅលើសាសនា បានខិតខំធ្វើបុណ្យទាន សន្សំកុសល បន់ស្រន់ប្រថ្នាសុំសេចក្តីសុខ។

## ខ.ព្រឹត្តិការណ៍សំខាន់ខ្លះៗ

តាមប្រវត្តិសាស្ត្រក្នុងរយៈកាល២៥៧ប្រទេសកម្ពុជាយើងទទួលគ្រោះថ្នាក់មកពីសៀមដែលប្រមាថនិងលើកទ័ពមកច្រើនគ្រាណាស់។ឧទាហរណ៍

១.នៅចុងរាជព្រះបាទស្រីរំពងរាជាស្តេចសៀមឈ្មោះឧត្តុនលើកកងទ័ពមកវាយនគរធំប្រាថ្នានិងយកខ្មែរឲ្យចំណុះវាសង្គ្រាមនេះធំណាស់

២.ក្នុងរាជព្រះឧបរាជស្រីសុរិយោទ័យសៀមបន្តចម្បាំងហើយយកនគរខ្មែរបានគ.១៣៥៣។សៀមរំលាយទ្វាពីទិសខាងកើតរួចចូលលុកលុយប្លន់រាជសម្បត្តិចាប់ខ្មែរជាឈ្លើយជិតមួយម៉ឺនអ្នកនាំទៅស្រុកវាសៀមនេះតាំងនៅនគរធំរវាង៤ឆ្នាំពីគ .ស១៣៥៣.១៣៥៧ វាដាក់នាម៉ឺនសៀមឱ្យនៅត្រួតត្រាខេត្តខ្មែរខ្លះផង។

៣.ព្រះស្រីសុរិយោវង្សទី១ កេណ្ឌសេនារហូតដល់ស្រុកលាវ វាយកម្ចាតសៀមចេញពីនគរធំបាននៅគ.ស១៣៨៧។ពេលនោះព្រំដែនខ្មែរខាងកើតទល់ដូណៃខេត្តបារៀ កូសាំងស៊ីន ខាងលិចតាំងពីខេត្តនាងរងអង្គរាជអាគ្នេខេត្តអង្គរាជរហុតដល់ឈូងសមុទ្រសៀម ខាងជើងដល់ស្ទាមខ្សាច់គោកខណ្ឌ។

៤.នៅក្នុងរាជព្រះបាទធម្មសោកា គ.ស១៣៩៤សៀមព័ទ្ធបន្ទាយនគធំច្បាំង៧ខែស្លាប់សេនាសៀមជាច្រើន។មានមេទ័ពក្បត់ពីរនាក់ចុលគំនិតនិងសៀមពួកប្លន់នេហរមលាយទ្វាខាងលិចចូលនគរធំបាន ។ប្រហជម្មសោកាទ្រង់សុគតក្នុងសង្គ្រាមគ.ស ១៣៩៤សៀមតាំងនៅនគរធំម្តងទៀត។

### ៤.២.១.ប្រភេទអក្សរ

នៅក្នុងសម័យលង្វែកយើងសង្កេតឃើញថា មានប្រភេទអត្ថបទអក្សរសិល្ប៍ដែលសំខាន់ៗមានពីរប្រភេទគឺ សិលាចារឹក និងសាសស្រ្តាល្បែង។

### ៤.២.២. អំពីសិលាចារឹក

តាមការសិក្សាស្នាដៃរបស់ បណ្ឌិត ជ័យ នន្ទ តែមួយប៉ុណ្ណោះ គឺសិលាចារឹកនគរវត្តដែលចែកចេញជាបីផ្នែកគឺះ

ផ្នែកទី១ ចារលើព្រះពាន់ ត្រង់ថែវ ដែលមានព្រះពុទ្ធរូបច្រើនព្រះអង្គ ។

ផ្នែកទី២ សរសេរផ្នែកខាងត្បូងសូរ្យវ័ន្ន កសាងដែលតម្កល់រូបព្រះវិស្ណុដ៏ធំ ដើម្បីឧទ្ទិសដល់ព្រហ្មញ្ញាសាសនា ។ ក្នុងរាជព្រះបាទ ចន្ទរាជា (សម័យលង្វែក) ប្រហែលជាឆ្នាំ១៥៤០-៥៥ បានឱ្យគេជួសជុលប្រាសាទ និងកសាងរូបបដិមាព្រះពុទ្ធធំៗ ៤អង្គតម្កល់ជំនួសព្រះវិស្ណុវិញ។

ផ្នែកទី៣ សិលាចារឹកលេខ៣៨ នៅព្រះរបៀងថ្នាក់ក្រោម ពីខាងកើតត្រង់កន្លែងមានព្រះចេតិយថ្មបាយក្រៀមកសាងឡើងនៅសម័យក្រោយអង្គរ មានសិលាចារឹកមួយផ្ទាំងទៀតរបស់បណ្ឌិត ជ័យ នន្ទ (ផ្នែកទី៣ នៃសិលាចារឹកនគរវត្ត ដែលយើងអាចនិយាយបានថា ជាសិលាចារឹកចុង ក្រោយបង្អស់របស់ប្រទេសកម្ពុជា)។ កត់ត្រាអំពីគ្រឿងបូជាតង្វាយព្រះឬ ការកសាងព្រះពុទ្ធរូបនានាសម្រាប់គោរបូជា ដោះលែងទាសាទាសីខ្ញុំបម្រើប្រុសស្រី ដាក់ទោសអ្នកដែលបំផ្លាញសម្បត្តិព្រះ។

## គ.អ្នកនិពន្ធ

បណ្ឌិតជ័យនន្ទជាអ្នកនិពន្ធដ៏ល្បីក្នុងរាជកលព្រះករុណាព្រះបាទធម្មរាជាទី១សតវត្សទី១៥ នៃគ. ស ឆ្នាំ១៤៧៤ .១៤៩៨ ។លោកបានកត់ត្រារៀបរាប់នូវសិលាចារឹកជាច្រើននៅនាថែវអង្គរវត្តដែលជាអត្ថបទ។រៀបរាប់អំពីពាក្យស្លូតីការបួងសួងសុំនូវសេចក្តីប្រាថ្នាសុខចម្រើនសម្រេចមគ្គផលក្នុងការធ្វើកុសលផ្សេងៗ

### ខ.អត្ថន័យទូទៅ

នៅក្នុងសិលាចារឹកទូទៅយើងឃើញអ្នកនិពន្ធបញ្ជាក់កត់ត្រាអំពីគ្រឿងបូជាដង្វាយព្រះ ឬការកសាងព្រះពុទ្ធរូបនានាដើម្បីសន្សំកងកុសលផលបុណ្យក្នុងការធ្វើកុសលកម្មយើងឃើញមានការប្រោសប្រណីដោះលែងទាសា ទាសីឲ្យទៅជាអ្នកជា មានសេរីភាពហើយគេមិនញញើតនឹងដាក់ទោសចំពោះមនុស្សអាក្រក់ដូចជាលួចគរុភណ្ឌបំបាត់ប្រវាញ គេជាខាតិ គឺជាបញ្ហាបុណ្យបាបនតកសួគ៌មានរៀបរាប់ជាច្រើនជាប់ទៅនឹងជំនឿសង្ឃឹមអស់សង្ឃឹមរបស់ប្រជាពដ្ឋរតាំងពីវណ្ណៈទាបរហូតដល់អភិជន និងព្រះមហាក្សត្រ។

## ៤.៣. អក្សរសិល្ប៍សាស្ត្រល្បែង

តើសាស្ត្រាល្បែងគឺជាអ្វី ?

ដែលហៅថា សាស្ត្រាល្បែង គឺជារឿងរ៉ាវទាំងឡាយ ដែលសរសេរជាពាក្យកាព្យ មានច្រើនខ្សែ ហើយកវីច្រើន ផ្អែកលើការយល់សុបិ្ត លើមន្តអាគម ចេះហោះ ចេះហើរ ដើរលើអាកាស ជ្រែកទឹក ជ្រែកដី ដែលមនុស្សធម្មតាមិន អាចធ្វើបាន និងមិនសមហេតុផល ។ កវីទាំងនោះ លោកបង្កើតរឿងទាំងនេះឡើងគឺដើម្បីចង់សម្រាលទុក្ខប្រជារាស្ត្រ ដែលរងទុក្ខវេទនាដោយសារស្រុកទេសកើតសង្គ្រាម។ ក្រៅពីអត្ថបទខាងលើនេះ មានអត្ថបទទូន្មានជាច្រើនសម្រាប់ងប់រំដល់កូនចៅជំនាន់ក្រោយ ឱ្យចេះរស់នៅក្នុងសង្គម ច្បាប់ធម្មជាតិ និងច្បាប់មនុស្ស ផងដែរ។

ចំពោះសាស្ត្រាល្បែង គេយល់ថា ពាក្យល្បែងមានក្នុងភាសាខ្មែរយូមកហើយដំបូងនៅសិលាចរឹតK.254 នោសតវត្សទី១៩មានពាក្យ គរុលំបែង នេះឯង។ លោកសីដេសយល់ថា គរុដែលធ្វើពិធីផ្សេងៗទេ គឺមិនយក ប្រទីប ។ពាក្យល្បែងមានច្រើននៅក្នុងអក្សរសាស្ត្រសម័យកណ្តាល ១៣។ដាក់ស្តែងនៅក្នុងច្បាប់ត្រីនេតិ ក្នុងច្បាប់ផ្សេងៗទំព័រ ៩១លដ់៩៤ ៖វគ្គ៧៤" កុំលេងជាល្បែង រំពឹងយល់ឈ្នេង ពាក្យពុំពិរោះ ស្រដីឱ្យដាច់ ឱ្យស្រេចឱ្យស្មោះ កុំធ្វើឡេះឡោះ សសោះអន្ទង "។ រីឯច្បាប់ប្រុសក្នុងច្បាប់ផ្សេងៗទំព័រ១ដល់១០៖វគ្គ៥២"លោកថាហៅឆ្កួតបី មួយឆ្កួតស្រីមួយឆ្កួតស្រា មួយឆ្កួតល្បែងពាលា លេងបៀប៉ោងជួកំតាត់ "។

១. លោកអូ ឈៀង បានឱ្យនិយមន័យ ល្បែងមកពីពាក្យ"លេង" មានន័យថាល្បែងគឺជា អ្វីដែលជាទីកម្សាន្តសម្បាយ បំបាត់ភាពតាមតឹង សើចបំពេញអារម្មណ៍។

២. យោងតាមវចនានុក្រមខ្មែរ សម្តេចសង្ឃរាជ ជួន ណាត ពាក្យសាស្ត្រាល្បែង គឺជាប្រលោមលោកសម័យកណ្តាល ។ សម័យដើមសាស្ត្រល្បែងឬ រឿងល្បែង សម្រាយជាពាក្យកាព្យ ....ខាងបាលីតែងបកិណ្ណកៈឬ វេយាករណ៍បាឋពាក្យបាលីងាយៗមានរឿងជាបញ្ញាសជាតក៍ ជាដើម ពាក្យកាព្យសម្រាយក្តី បាលីក្តីហៅថា× សាស្ត្រល្បែង ឬរឿងល្បែង× ដូចគ្នា និងរឿងប្រលោកបច្ចុប្បន្ន១៥។

៣. បណ្ឌិត ជ សោ លោកយល់ថា អក្សរសិល្ប៍ពុទ្ធនិយម ក្លាយហួសហេតុ ស្នាដៃជាសាស្ត្រាល្បែងកើតនៅសតវត្សទី១៧.១៨.១៩ ១៤។

៤ បណ្ឌិតសភាចារ្យ ឃីង ហុកឌី រឿងល្បែងស្នាដៃអក្សរសាស្ត្រច្នៃប្រឌិតលោមលួងអារម្មណ៍កម្រងភាសាកំនាព្យ រឿងរ៉ាវប្រពៃណី តែងជាកំណាព្យ រវាងសតវត្សទី១៨.១៩.។ អក្សរសាស្ត្រមានទំហំវែង ចំនួនមធ្យមប្រហែល៨០០០ឃ្លា ១៩។

៥. សាស្ត្រល្បែងគឺជាសាស្ត្រាជាអត្ថបទរឿងរ៉ាវទាំងឡាយណាសម្រាប់អានកម្សាន្ត បំពេរអារម្មណ៍អោយរីករាយ។ ឧទាហរណ៍៖សាស្ត្ររឿងក្រុងសុភមិត្រ ហង្សយន្ត។ល។ សាស្ត្រាល្បែងទាំងនោះតែងជាពាក្យបទកំណាព្យ បទកាកគតិ ព្រហ្មគីតិ ភុជង្គលីលា ពំនោល...។Chenla Library ។

៦. បណ្ឌិតសភាចារ្យ សោម សុមុនី យល់ឃើញថា សាស្ត្រាល្បែងប្រលោមលោកពាក្យកាព្យទទួលឥទ្ធិពលព្រះបុទ្ធសាសនា មានលក្ខណៈឯកភាពបីគឺ ចារលើស្លឹក ឬក្រាំង មិនឆ្លាក់លើថ្មដូចសម័យមុនទៀតទេ ទី២សរសេរជាពាក្យកាព្យលើសាស្ត្រា អ្នកនិព្វមាននិនាការពុទ្ធនិយមទី៣គឺត្រូវសតវត្សទី១៧.១៨.១៩. ១៧។

៧. បណ្ឌិតសភាចារ្យ ស៊ុំ ឈុំ លោកបាននិយាយថា អំឡុងសតវត្សទី១៨.១៩ អ្នកនិព្វខ្មែរដកស្រង់រឿងក្នុងជាតក៍មួយចំនួនប្រែជាផាសាខ្មែរគាថាបាលីខ្លះៗបនដកស្រង់ដំណើររឿង

ក្នុងជាតក៍តែងតាមគំនិតរបស់ខ្លួនស្នាដៃទាំងនោះត្រូវបានចារលើសាស្ត្រាស្លឹករឹតហៅថាសាស្ត្រល្បែង។

ជារួមអក្សរសិល្ប៍សម័យការសរសេឯកសារផ្សេងៗដោយដោយសិលាចារិក និងសាស្ត្រ ប៉ុន្តែសាស្ត្រសរសេរទុកមិនបានយូត្រូវពុកផុយ ភ្លើងឆេះនៅក្នុងសង្គ្រាម ឬ ជនបរសេទដឹកយកទៅស្រុករបស់វាផងក៏មិនដឹង ហើយមានសេសសលនៅក្រោមដំបូលវត្តអារាមដែលប្រះសង្ឃជាអ្នកថេរក្សា ដែលដូនតាយើងបានបន្សល់ទុក ក្នុងនោះមានទាំងតម្លៃអប់រំដល់មនុស្ស និងតាមរយះស្នាដៃអក្សរសិល្បព្រះពុទ្ធនិយម។

ទ្រឹស្តីល្បែ""(អង់គ្លេស: Game theory) គឺជាផ្នែកមួយនៃគណិតវិទ្យាអនុវត្តដែលប្រើនៅក្នុងវិទ្យាសាស្ត្រសង្គម ដូចជាសេដ្ឋកិច្ច ក៏ដូចជាក្នុងជីវវិទ្យា វិស្វកម្ម វិទ្យាសាស្ត្រនយោបាយ ទំនាក់ទំនងអន្តរជាតិ និងជំនាញគ្រប់គ្រង។ ទ្រឹស្តីល្បែងទាញយកឥរិយាបថក្នុងស្ថានភាពយុទ្ធសាស្ត្រ ឬហៅថាល្បែង (ដែលជោគជ័យរបស់បុគ្គលម្នាក់ក្នុងការសម្រេចចិត្តបានមកពីការសម្រេចចិត្តរបស់បុគ្គលដទៃ) មកវិភាគតាមបែបគណិតវិទ្យា។ ទ្រឹស្តីនេះជាបឋមត្រូវបានប្រើដើម្បីវិភាគការប្រកួតប្រជែងដែលបុគ្គលម្នាក់ធ្វើបានប្រសើរជាងដោយសកម្មភាពនៃបុគ្គលផ្សេងមួយទៀត (zero sum ). ក្រោយមកទ្រឹស្តីនេះត្រូវបានពង្រីកយកទៅប្រើក្នុងការវិភាគផ្សេងៗស្មុគ្រស្មាញជាច្រើនដូចជារវាងអ្នកលេងមនុស្ស និងមិនមែនមនុស្ស (ដូចជាកំព្យូទ័រ សត្វ រុក្ខជាតិជាដើម)

ទ្រឹស្តីប្រពៃណីនៃល្បែងត្រូវបានប្រើដើម្បីស្វែងរកចំនុចសមតា ដែលក្នុងចំនុចនេះ អ្នកលេងនីមួយៗបានឯកភាពទៅលើយុទ្ធសាស្ត្រមួយដែលពួកគេនឹងមិនកែប្រែ។ គំនិតសមតា (equilibrium concepts) ជាច្រើនត្រូវបានបង្កើតឡើងដើម្បីស្វែងយល់ពីគំនិតនៃល្បែង។ គំនិតដែលល្បីល្បាញជាងគេគឺ សមតាណាស (Nash equilibrium)។

ទ្រឹស្តីល្បែងត្រូវបានបង្កើតឡើងជាដំបូងពីការស្រាវជ្រាវរបស់ Emile Borel នៅក្នុងឆ្នាំ ១៩៣៨ ក្នុងសៀវភៅរបស់គាត់ដែលមានចំណងជើងថា Applications aux Jeux de Hasard និងក្រោយមកនៅក្នុងសៀវភៅរបស់ John von Neumann និង Oskar Morgenstern ដែលមានចំណងជើងថា ទ្រឹស្តីល្បែងនិងឥរិយាបថសេដ្ឋកិច្ច (Theory of Games and Economic Behavior)។ ក្រោយមកទៀតនៅទសវត្សឆ្នាំ ១៩៥០ ក៏មានការស្រាវជ្រាវយ៉ាងច្រើនសន្ធឹកសន្ធាប់ផងដែរ។ ទ្រឹស្តីនេះត្រូវបានយកទៅប្រើយ៉ាងជាក់ច្បាស់ក្នុងជីវវិទ្យានៅទសវត្សឆ្នាំ ១៩៧០ ទោះជាការស្រាវជ្រាវជាច្រើនត្រូវបានធ្វើតាំងពីទសវត្សឆ្នាំ ១៩៣០ មកក៏ដោយ។ ទ្រឹស្តីនេះត្រូវបានគេទទួលស្គាល់យ៉ាងទូលំទូលាយថាមានសារសំខាន់សម្រាប់ជំនាញជាច្រើន។ ទ្រឹស្តីវិទូល្បែងចំនួន ៨ នាក់បានទទួលរង្វាន់ណូបែលនៅក្នុងវិទ្យាសាស្ត្រសេដ្ឋកិច្ច (Nobel Memorial Prize in Economic Science) ហើយលោក John Maynard Smith បានទទួលរង្វាន់សម្រាប់ការយកទ្រឹស្តីល្បែងទៅអនុវត្តក្នុងជីវវិទ្យា។

ជារួមអក្សរសិល្ប៍សម័យការសរសេឯកសារផ្សេងៗដោយដោយសិលាចារិក និងសាស្ត្រ ប៉ុន្តែសាស្ត្រសរសេរទុកមិនបានយូត្រូវពុកផុយ ភ្លើងឆេះនៅក្នុងសង្គ្រាម ឬ ជនបរសេទដឹកយកទៅស្រុករបស់វាផងក៏មិនដឹង ហើយមានសេសសលនៅក្រោមដំបូលវត្តអារាមដែលប្រះសង្ឃជាអ្នកថេរក្សា ដែលដូនតាយើងបានបន្សល់ទុក ក្នុងនោះមានទាំងតម្លៃអប់រំដល់មនុស្ស និងតាមរយះស្នាដៃអក្សរសិល្បព្រះពុទ្ធនិយម។

## ៤.៤.និដ្ឋភាពទូទៅនៅសម័យឧត្តុង

សម័យឧដុង្គជាសម័យមាសនៃប្រវត្តិអក្សរសាស្ត្រខ្មែរ ។ ដោយសារ ការយកព្រះ រាជហឫទ័យទុកដាក់ និង វិស័យវប្បធម៌អក្សរសាស្ត្រ របស់ព្រះបាទសម្តេចព្រះហរិរក្សរាមាព្រះអង្គ ឌួង ទើបក្បួន ខ្នាតរឿងរាវផ្សេង ៗ ព្រមទាំងអ្នកនិពន្ធ បណ្ឌិត រាជកវី កើតឡើងយាំងច្រើន ដូចជាផ្សិតត្រូវទឹកសន្សើ ហើយ គង់វង្ស មកដល់សព្វថ្ងៃ សំរាប់ការសិក្សាត្រិះរិះ អានកំសាន្តរបស់អនុជន ។ប្រវត្តិអក្សរសាស្ត្រខ្មែរ លាង ហាប់ អានទំព័រ២០ អត្ថបទអក្សរសិល្ប៍សឹងតែទួទៅ រឿងរាវផ្សេងៗក្នុងសម័យឧដុង មានលក្ខណ:ជារឿងប្រឌិតចងក្រង តាមបែបមនោសញ្ចេតនា ។ អ្នកនិពន្ធជ្រើសរើសយករឿង ក្នុងជាតកបែបបាលី (មានបញ្ញាសជាតក ឬជាតកក្នុងអដ្ឋកថានៃព្រះត្រៃបិតក ជាដើម) តែងតាមចិត្តគំនិតរបស់ខ្លួន ដើម្បីសម្រេចទៅ តាមជំនឿ បញ្ហាការរស់នៅ ជាសុខ ជាទុក្ខ សប្បាយ និង រឿងរៀបរៀងដោយ មាន អច្ឆរិយអស្ចារ្យ ហេតុផ្សេង ៗ ដូច ជាពួកអង្គទេវ ខ្មោច យក្ស អារក្ស អ្នកតា ឬមនុស្សចេះ មន្តអាគមហោះ

ហើរពួកែខ្លាងក្លាមកនិទាន ដើម្បីលើកទឹកចិត្តមនុស្សទូទៅបូរពេលពួកគេអស់សង្ឃលើជីវិតផ្ទាល់របស់ហើយជឿថា ការប្រព្រឹត្តិអំពើអាក្រក់ទទួលបានផលអាក្រក់ ធ្វើអំពើល្អទទួលបានផលល្អមានភាពអច្ឆរិយៈមកជួយពួកគេបាន ។

ការកើតមាននូវបញ្ញកម្មផលជាមូលហេតុ ក្នុងរឿងនៃ អក្សរសាស្ត្របែបនេះ មានបុព្វហេតុមកពីសេចក្តីភិតភ័យលំបាករងទុក្ខទោសយ៉ាងទារុណកម្មរបស់ប្រជាជនខ្មែរយើង ដោយសារតែមានការថ្វើសង្គ្រាមពីសំណាក់ជនបរទេសឈ្លានពានទឹកដី កវិអ្នកនិពន្ធបានរិះរកមធ្យោបាយជួយផ្តល់កម្លាំងចិត្តតាមរយៈស្នាដៃអក្សរសិល្ប៍របស់ខ្លួន តែងឱ្យមានអច្ឆរិយៈអស្ចារ្យ តាមមកជួយសង្គ្រោះអ្នកដែលបានប្រព្រឹត្តអំពើល្អ ដើម្បីមកជួយព្យាបាលជំងឺផ្លូវចិត្ត ដោយលើកយកស្នាដៃអក្សរសិល្ប៍រឿងព្រះវេសន្តរ សបញ្ជាក់ឱ្យឃើញនូវទស្សនៈកម្មផល បាបបុណ្យ ល្អ អាក្រក់។ឧទាហណ៍ អ្នកធ្វើអំពើល្អបានកើតនៅឋានសួគ៌ អ្នកធ្វើអំពើអាក្រក់ទៅកើតនៅឋាននរកជាដើម។

## ក.ព្រះមហាក្សត្រសំខាន់

ព្រះមហាក្សត្រ ដេលមានប្រះមរមក្តិយសសព្វល្បីល្បាញក្នុងវិស័យឧបត្ថមរម្បថម៍ អក្សរសាស្ត្រនៅសម័យឧត្តុងមានដុចតទៅៈ

១.ព្រះបាទជ័យជេដ្ឋាទី២ គ.ស១៦១៨

២.ព្រះបាទធម្មរាជារាជសម្ភារ .ព្រះពញាតូ.គ.ស១៦១៨.១៦២០

៣.ព្រះបាទសម្តេចព្រះហរិរក្សរាមាប្រះអង្គឌួង គ.ស១៦៤១.១៨៦០

៤.ព្រះបាទជ័យជេដ្ឋាទី២ គ.ស១៦១៨.១៦២៨

៥.ព្រះបាទរាមាធិបតិចន្ទគ.ស១៦៤២.១៦៥៨

៦.ព្រះបាទជ័យជេដ្ឋាទី៤ គ.ស១៦៧៥.១៧០៦

៧.ព្រះបាទកេវហ្វា អង្គអឹម រាជ្យទី២ គ.ស១៧១០។១៧២២

៨.ព្រះបាទសត្ថាទី២ .ព្រះអង្គជ័យ.គ.ស១៧២២.១៧៣៦

៩.ព្រះបាទឧត័យអង្គតន់.ព្រះឧទ័យទី២ គ.ស១៧៥៨.១៧៧៥

១០.ព្រះបាទអង្គអេងគ.ស១៧៧៩.១៧៩៦

១១.ព្រះបាទអង្គចន្ទទី២ព្រះឧទ័យរាជាគ.ស១៨០៦.១៨៣៤

១២.ក្សត្រីអង្គម៉ីគ.ស១៨៣៥.១៨៤១

## ៤.៤.១.អក្សរសាស្ត្រសម័យឧត្តុង

### ទី១សន្ទស្សន្អក្សរសិល្ប៍

នេះយើងអាចលើកយកព្រះរាជាសម្ភារបញ្ជាក់ពីលក្ខណៈស្នាព្រះហស្តព្រះហស្តព្រះអង្គដូចតទៅៈ

## ក. ជីវប្រវត្តិព្រះរាជសម្ភារ

កវីរាជសម្ភារក្នុងសតវត្ស៍ទី១៧ គ.ស១៦២៩.១៦៣០ ជបុត្រច្បងរបស់ព្រះបាទជ័យចេត្ថា និងអ្នកម្នាងសុខទ្រង់បានទទួលរាជាពិសេកក្នុងគ.ស១៦២៩មានមរមនាមថាព្រះបាទសម្តេចស្តេចព្រះរាជអង្គាព្រះស្រីធម្មោករាជារាមាធិបតី។ពង្សសារតាកំណត់ព្រះនាមតែត្រឹមព្រះស្រីធម្មោរាជាឬព្រះរាជសម្ភារទ្រង់ធម៌ជាបណ្ឌិតរាជដោយសារមានវិបត្តិក្នុងរឿងព្រះបាទឧទ័យព្រះអង្គភៀសទៅភិរ័ត្នទៅខេត្តកញ្ជះខេត្តក្រចេះសព្វថ្ងៃ។ហើយក៏ត្រូវទាទ័ពបរទេសដេញទាន់ហើយបានធ្វើគត់ទាំងពីរអង្គដោយគ្រាប់កាំភ្លើងទៅ។មុននឹងត្រូវបារាំង.ព័រទុយកាគោ្គល .បាញ់ប្រហារព្រះអង្គ ស្តេចរាព្រះហស្តមានព្រះតម្រាលថា បារាំងអាប់លក្ខណ៍ ដដេញបាញ់អ្នកព្រះរាជសម្ភារ ឡើងលើចុងត្នោត ពុំកោតចេស្តា អ្នកលើកដងត្លា រារាំងយត់ទុក។

## ខ.ស្នាមព្រះហស្តទាំងឡាយដូចខាងក្រោម

មានឯកសារត្រឹមត្រូវតាមរាជពង្សាវតាកំណត់នូវវិទ្យាស្ថានពុទ្ធសាសនបណ្ឌិតព្រមទាំងចុះក្នុងទស្សនាវដ្ដីកម្ពុជាសុរិយាគឺ៖

១.ច្បាប់រាជគិតិ

២.ព្រះរាជសម្ភារ

៣.លិខិតផ្ញើទៅថ្វាយព្រះនាងយូរវត្តី

៤.ពាក្យកាព្យប្រារព្ធកំពូលត្នោតមុនពេលសុគតដោយទាហានបារាំងបាញ់

៥.កំណាព្យសរសើរហោមមាស

៦. កំណាព្យកន្លង់មាសមង្គលថ្លៃ

៧.កំណាព្យព្រលឹងមាសអើយ

៨.ច្បាប់ក្រុម

៩.ច្បាប់សហៃសាធុជនឬច្បាប់ត្រីនេត

គ.លក្ខណៈស្នាដៃក្នុងប្រភេទសារកថា

ស្នាដៃទាំងឡាយគឺលិខិតផ្ញើទៅថ្វាយព្រះម៉ែយូរវតី ពាក់កាប ប្រារព្ធកំពូលត្នោតមានមាស កំណាព្យកន្លង់មាសមង្គលថ្លៃ កំណាព្យព្រលឹងមាសអើយ រាប់បានជាសារលិខិតថ្លែងនៅមនោសញ្ចេតនា ស្នេហានឹករលឹក និងពាក់សន្យាដែលព្រះរាជសម្ភារទ្រាំផ្ញើទៅនាងម៉ែយូរវត្តីជាគូសង្សារ។

### ១.លិខិតផ្ញើទៅថ្វាយព្រះម៉ែយូរវត្តី

ក.មិត្តស្នេហ៍ស្នង គូសាងនិងប កាលអវិជ្ជា តែងត្រាច់រង្គាត់ ក្នុងវត្តភពកា ឆ្លាសឆ្លងប្រវាស គម្ពីរជលស័យ ។

### ខ.តួសេចក្ដី

ព្រះករអ្វី រាជរៀបរាប់នៅអស់អនុស្សាវរីយ៍ តាំងពីកុមារភាព និងការរំលឹកនៅបណ្ដាំផ្សេងៗរវាងព្រះនាងម៉ែយូរះវត្តីដោយសេចក្ដីនឹកដោយសេចក្ដីសោកស្ដាយអាឡោះអាល័យគ្នាយ៉ាងខ្លាំង។

### គ.សេចក្ដីបញ្ចប់

បើបានដូចចិត្ត បំណងគំនិត មូលមួយហ ឬទ័យ ទាំងនេះហៅបុណ្យ ពីមុនក្រាស់ក្រៃទើបបានមូលមៃ ត្រឹមត្រូវអភិបាល។

### ២.ពាក្យកាព្យចារលើកំពូលត្នោតមុនពេលសុគត

សាធុសម្មាយ កុំបីរាយមាយ និងក្ដីកាមា តែងឱ្យវង្វេង ក្នុងវាលវដ្តសង្សា ស្លាប់ទៅកាលណា មានសោយតែទុក្ខ។ ហេតុតេក្បត្រី នាំឱ្យអប្រិយ ដូចត្រីក្នុងភក បើបុរសណា ចង់ឆ្លងនរក កុំធ្វើវិរក់ ដូចអញច្នោះណា ។ពីព្រោះកម្មបេ ឧឡូវទាល់តែ ក្សិនក្សៃមរណា សូវស្លាប់ទៅគាប់ ឱ្យជាប់ធម្មា សូមអសទេវតា ជួយជាទិព្វញ្ញាណ ។ឱ្យអ្នកទាំងពួង ជាទាមានហ្វូង នាំយកតៅថ្វាយព្រះបិតុច្ឆា ទ្រង់ជ្រាបអប្បាយ កុំទ្រង់រាយមាយ និងក្ដីកាបេ។

### ២.អត្ថន័យនៃអត្ថបទ

អត្ថបទនេះមិនគ្រាន់តែមានប្រយោជន៍សរាប់បំលុបលាងនៅទោសកំហុសរបស់ទ្រង់ក្នុងការរំលោបបំពានបំពានធម៌កាមេប៉ុណ្ណោះទេតែជាការប្រៀបប្រដៅព្រះបាទឧទ័យជាព្រះមិតុ

ឆាដែលប្រព្រឹត្តអំពើមិនគប្បីពុំគោរពពាក្យសន្យាផ្តាំផ្ញើរបស់ព្រះបាទជ័យជេដ្ឋាដែលផ្សងផ្គុំជាស្រេចនឹងព្រះនាងអង្គរតីកាលព្រះ កុមារម្លេះ។

## ៣.កំណាព្យសរសើរហេមន្តមាស

ព្រះនិពន្ធរាជទ្រង់ បានប្រារព្ធនៅស្នាមព្រហស្មនេះ ក្នុងគោលបំណងថ្លែងនៅទុក្ខផ្សារខាងផ្លូវចិត្តចំពោះការព្រាត់ប្រាស់ព្រះនាងម៉ែយូរវតី កំណាព្យនេះតែងជាបទព្រហ្មគិត។

### ក.អត្ថបទ

តំណែងដំណើរនា សរសើរគ្រាហេមន្តមាស ត្រសៀកឯការភាស សែនសាយល្ហេទេរទៅ។ស្រណោះបក្សាគរ ឯអម្ពរផ្សៀលឆ្វាតស្លៅ សំកុកសំកាងនៅ សងសូរសាទ័ន្តវាយ៉ំ។ស្រណោះនៅនៃបនិត្យ ត្រេកត្រូវចិត្តស្នេហ៍ស្នោះស បិតឋាននពនេចរ តបឋប្បទ័យ សោកស្នេហ៍ស្មាល។

### ខ.អត្ថន័យនៃអត្ថបទ

ព្រះករីរាជរាប់ធម្មជាតិ ទេសភាពតាមឧបមានវិធី និងការពិតទៅតាមកាលវេលា តាមរដូវ ដែលផ្តល់នូវអនុស្សាវរីយ៍ពោរពេញទៅដោយក្តីស្រណោះ អាលោះអាល័យ និងទឹកចិត្តជាប់ជំពាក់ស្នេហាយ៉ាងរំភើប។ឆព្រោះការអ្វីរាជកំពុងស្លុងអារម្មណ៍ទៅលើទេវីជាគូកំណាន់ចិត្ត។

## ៤. កំណាព្យ កន្លង់មាសមង្គលថ្លៃ

កំណាព្យនេះបិតនៅក្នុងព្រះរាជសម្ភារតែងផ្ញើទៅបន្ទូលចិត្តរបស់ព្រះអង្គ។ កំណាព្យនេះមានតែងជាបទភុជង្គលីលា។

### ក. អត្ថបទ

"កន្លង់ មាសមង្គលថ្លៃ" គៀសឆ្វាត់វិលវៃ ទ្រហឹងខ្វាត់ខ្វែរ។ កន្លង់គ្រាច់ត្រង់ឬស្សីដូចបង និងស្រី រួមរស់ស្នេហា"។

### ខ. អត្ថន័យនៃអត្ថបទ

ព្រះករីរាជប្រៀបធៀប រូបទ្រង់ទៅនឹងកន្លងដែលជាណកសត្វចូលចិត្តនូវសនៃបុប្ផានានា។ ទោះបីបិតនៅក្នុង អារាមដ្ឋានណាក៏ដោយ ឬ ទោះបីមានម្ចាស់ការពារ " ជា កម្មសិទ្ធិរបស់ជនបែបណាក្តី បុប្ផាជាចំណីគាប់ប្រសើររបស់ កន្លង់ ដូច្នេះកុមារីមិន ដែលចេះនឿយណាយឬបំភ្លេចចោលបានឡើយនូវបុប្ផាដែលខ្លួនធ្លាប់ស្គាល់ ធ្លាប់ត្រឹម ធ្លាប់ក្រេបរឡើយ។

៥.កំណាព្យ ព្រលឹងមាសអើយ

### ក.អត្ថបទ

ព្រលឹងមាអើយ ថ្ងៃចឹសព្រហើយ បន្ទាបសុរិយា ស្រនោះសម្ងសត្វ ផ្សៀងឆ្វាត់វេហាស៍ ចុះចាប់ព្រឹក្សា សសិតស្លបយ៉ំ..។ មាសអើយផ្ទៃបឹង ព្រលឹគឈរសឹង លាស់លូតមានផ្កា លួន់ស្ទះគ្រាចៀក សិកសៀតស្លាបទា ស្លោមស្លាមច្រវា កំពឹងពួយពាស ។ មាសអើយអណ្តែតសារាយកញ្ជែត សារាយអណ្តែត យាប្លងឆ្លូតន្លាស់។

### ខ.អត្ថន័យនៃអត្ថបទ

កំណាព្យនេះបង្កើតនៅមនោរូបារម្មណ៍ ដែលព្រះករីរាជសម្ភារផ្តោតចិត្តទាំងស្រុងទៅលើអតីតគូសង្សារដែលព្រះអង្គទើបនឹងបានជួបវិញការពើបពះខណៈនេះធ្វើឲ្យព្រះករណីរាជវិកតណែនចុកដើមទ្រូងព្រួយបារម្ភគិតសុំចែកយកគំនិតគតភិតភ័យផងអរផងព្រោះវិបត្តិខាងផ្លូវកាយនិងផ្លូវចិត្តម្តងនេះ។បំពានលើចម្រោងចម្រាស់ឧបសគ្គធំណាស់។

## ទី ២. ប្រលោមអក្សរសិល្ប៍

ក្នុងសម័យឧត្តុង អ្នកអក្សរសិល្ប៍អ្នកអាចទុកប្រភេទអក្សរសិល្ប៍ប្រភេទនេះអាចឱ្យរកឃើញនូវ៖

វីរកថាជាស្នាដៃយ៉ាងច្រើនរៀបរាប់ឡើងថា ពាក្យកាព្យនិយាយអំពីសកម្មភាពផ្សងព្រេង ដ៏ស្វិតស្វាញក្លាហាននៃវីរៈជនមានតួអង្គពោធិសត្វ ឬតួអង្គក្សត្រដ៏ខ្លាំងពូកែក្នុងការផ្ចាញ់យក្សមារ ដើម្បីរំដោះទុក្ខសោករបស់មនុស្សជាតិ រំដោះគូសង្សារជាដើម។ រឿងបែបនេះ អ្នកខ្លះមានឈ្មោះអ្នកនិពន្ធច្បាស់តែគួរឱ្យស្តាយព្រោះអ្នកនិពន្ធទាំងនោះរកជីវប្រវត្តិច្បាស់ប្រាកដពុំឃើញ ហើយរឿងខ្លះទៀតគ្មានឈ្មោះអ្នកនិពន្ធទេ ព្រមទាំងការបរិច្ឆេទពិតប្រាកដគ្មានផងទៀត។ តទៅនេះយើងលើកយកអត្ថបទមានការបរិច្ឆេទត្រឹមត្រូវឬមាននាមអ្នកនិពន្ធមកបញ្ជាក់៖

### ក. ព្រះបាទសម្តេចព្រះអង្គឌួងត្រូវធ្វើ

### ព្រះរាជជីវប្រវត្តិសង្ខេប ព្រះបាទសម្តេចព្រះអង្គឌួង

ព្រះអង្គជាព្រះរាជបុត្រពៅនៃព្រះបាទសម្តេចព្រះអង្គគ.ស. ១៧៧៩ ដល់ ១៧៦ * ទ្រង់គ្រងរាជ្យនៅរាជធានីឧដុង្គមានជ័យ ពីគ.ស.១៨៤១ដល់ ១៨៦។ ព្រះអង្គឌួង ទ្រង់ប្រកបដោយព្រះប្រាជ្ញាឈ្លាសវៃណាស់ ។ សៀបសំផ្កាច់យកខត្តម្កព ខណៈពៅ និងឯទៀតៗ ព្រះអង្គមានព្រះតម្រាស់ ខ្ញុំមិនឲ្យអ្វីទៅសបទាំងអស់" ។ សៀបរាំងពួក ទ្រង់ឲ្យសៀមយក!ខណា ដែលសៀមយកបានពីមុនយកសិនចុះ ។ ព្រះមហាក្សត្រអង្គនេះ ទ្រង់ប្រកបដោយទសពិធរាជធម៌។

### ខ. ព្រះរាជជីវប្រវត្តិសង្ខេប

ព្រះអង្គជាព្រះរាជបុត្រព្រះបាទអង្គអេងគ.ស១៧៧៩គស១៧៩៦។ ទ្រង់គ្រងរាជ្យនៅរាជធានីឧដុង្គមានជ័យពីគស១៨៤១ ដល់ ១៨៦០ ។ ព្រះអង្គឌួងទ្រង់ប្រកបដោយប្រាជ្ញាឈ្លាសវៃណាស់។សៀមផ្តាំផ្តាច់យកខេត្តម្លូព្រៃទន្លេពៅនៅខេត្តឯទៀត។ ព្រះអង្គមានព្រះតម្រះថាខ្ញុំមិនឲ្យអ្វីទៅសៀមទាំងអស់។ សៀមខ្លាំងពូកែទ្រាំឲ្យសៀមយក ដែលសៀមយកបានពីមុនសិនចុះ។ ព្រះមហាក្សត្រ ព្រះអង្គនេះទ្រង់ប្រកបដោយទសពិតរាជធម៌ បានប្រារព្ធសង្គ្រោមប្រទេសបាក់បែកដោយសង្រាម ព្រះអង្គបានកសាងសមិទ្ធិផលសំខាន់ៗសម្រាប់ប្រទេសជាតិគឺមួយព្រះអង្គបានកសាងព្រះវិហារនូវឧត្តុង បានចាត់អាចារ្យឱ្យបង្រៀនព្រះបរិយត្តិធម៌គឺព្រះត្រៃបិដក។ ទ្រង់បានកសាងសាលាទានឲ្យអ្នកប្រាជ្ញបណ្ឌិតផ្ទៀងកែព្រមទាំងតែងច្បាប់តាមសម័យនិយម។ ទ្រង់ជ្រើសនាម៉ឺនយកសុទ្ធតែបានចំណេះជ្រៅជ្រះ។ ទ្រង់បានបញ្ជាឱ្យកុមារទៅរៀននៅវត្ត។ ទ្រង់បញ្ញត្តិដាក់ទណ្ឌកម្មដល់នាម៉ឺនទុច្ចរិត ស៊ីសំណូក និងដែលប្រព្រឹត្តអបាយមុខ បានជក់អាភៀនជាដើម។ ទ្រង់បញ្ញត្តិមិនឲ្យយកពន្ធលើសលុប ខ្ញុំនិងចងការប្រាក់យកការខ្ពស់ពីប្រជាពលឡើយ។ ទ្រង់ឱ្យធ្វើពុម្ពបោះប្រាក់ចាយ។ ទ្រង់សាងផ្លូវមួយពីឧដុង្គទៅកំពត ហើយនិងសំពៅជំនួញមួយ។ ទ្រង់ចំណាយព្រះរាជទ្រព្យចាត់ឲ្យយុវជន ទៅរៀនភាសាបរទេសនៅសិង្ហបូរី ។ក្នុងរាជ្យព្រះបាទសម្តេចព្រះអង្គ ឌួង បានសុខក្សេមក្សាន្តរហូតដល់ ១៨៥៩ ។ ទ្រង់ចូលទីវង្គតនៅ ឧដុង្គមានជ័យគ.ស. ១៨៦0។ ព្រះអង្គមានព្រះរាជបុត្របីព្រះអង្គព្រះមាតាទីទៃពីគ្នាគឺ៖

ទី១ ព្រះអង្គរាជាវតី (ព្រះបាទនរោត្តម)

ទី២ ព្រះអង្គស្រីសុវត្ថិ (ព្រះបាទស៊ីសុវត្ថិ)

ទី៣ ព្រះអង្គជ័យវឡា ( ព្រះអង្គ ឬ ព្រះស៊ីវតា)

### គ. ស្នាព្រះហស្ថ

ពិតមែនតែទ្រង់មានព្រះភារកិច្ចយ៉ាងច្រើនចំពោះប្រទេសជាតិ គឺព្រះបាទសម្តេចព្រះហរិរក្សរាមាឥស្សរាអិបតី ព្រះអង្គរឌួង ទ្រង់បានប្រារព្ធនិពន្ធអត្ថបទរឿងពីច្បាប់ក្បួនសម្រាប់ទុកជា ព្រះកេរ្តិ៍ដំណែលអក្សរហស្ថជាតិដែរ ព្រះហស្ថដែលបានឃើញសព្វថ្ងៃនេះមាន

១. រឿងចម្ប៉ាថោង (ទ្រង់និពន្ធក្នុង គ.ស. ១៨១០ កាលនៅសិក្សាពុំខានឡើងគ្រងរាជ្យនៅឡើយ) ។

២.រឿងកាកី (គ.ស. ១៨១៥) (ទ្រង់និពន្ធគ្រាដែល ទ្រង់បានព្រះជន្ម ១៩វស្សា ។

៣.ច្បាប់ស្រី (ទ្រង់និពន្ធក្នុងគ.ស១៧៥៩ច.ស.១១៩៩.ព.ស២៣៨០.គ.ស១៨៣៧ក្នុងវេលាទ្រង់មានព្រះជន្ម៤១ព្រះវស្សា។

## ១. រឿងផ្នែកប្រលោមអក្សរសិល្ប៍ សាស្ត្រាល្បើកកាកី

ព្រះរាជកវីទ្រង់តែងរឿងនេះ ពីថ្ងៃពុធ ១១ កើត ខែពិសាខ ឆ្នាំសប្តស័ក ព.ស២៣៥៨ ប.ស. ១១៧៧ គ.ស.១៨១៥ ។

ជាអត្ថបទពាក្យកាព្យ (មានបទកាកគតិ ពំនោល ប្រហ្មគិត និងភុជង្គលិលា) ។ ប្រភពរឿងចេញមកពី៥០០ ជាតក។ ឯកសារសាស្ត្រាស្លឹករិត ១ ខ្សែចប់ដុំជាតក៏រក្សាទុកនៅពុទ្ធ-សាសនបណ្ឌិត្យ ចុះលេខសាស្ត្រ ៦៨១ ដែលបានមកពីវត្ត សិរីបទុម ខេត្តកំពង់ចាម ។

## ២.អត្ថបទមានលំនាំតែងដូចនេះ

ក. សេចក្តីផ្តើម ជាបទកាកគតិ “អង្គអញត្រកូល ជាតិជាកំពូល កម្លោធជានី នុជនាថ ចូឡជា បុត្រាជាតិ ក្នុងរាជសុខី សុខុមខត្តិយា។ ធរចាកបុរី បុរាណវេណី ទៅបិតនៅនាក្រុងទេពនគរ កុលករចិន្តា តែងតាមបទបាឡីលោកសំដែង។ ក្នុងប្រាំរយជាតក ចងជាបទបាទ កិច្ចកាព្យថាយថែង តុកជាតំណ តែងតអង្វែង ឱ្យអស់គម្លែង ជនជាតិដងដាន។ ខ. សេចក្តីបញ្ចប់ថា ប្រភេទបទកាកគតិ

ស្ត្រីស្រីណាគាប់ កុំត្រងត្រាប់កែវកាកី គំនិតផិតក្បត់ប្តី ចោលស្វាមីសពសាហាយ

កំពុងពេញស្នេហា ចិត្តពេស្យានឹកនិរណាយ ផិតក្បត់ប្តីទាំងឡាយ ព្រោះចិត្តចោរចងសម្ពន្ធ។ ដំណើរនាងកាកី ប្រែសេចក្តីសៀមភាសា ជាពាក្យខ្មែរកាព្យា សូវចេះរឿងអម្លេះហោង

## គ. សាស្ត្រារឿងចម្ប៉ាថោង

រឿងនេះព្រះរាជកវីទ្រង់ពុំបានបញ្ជាក់ ថ្ងៃ ខែ ឆ្នាំទេនិពន្ធ។ ពុទសាសនបណ្ឌិត្យមានឯកសារនេះដោយសារលោក ឧកញ៉ាសាទេព និងអ្នកស្រី ប៉ិលសាងទុក ក្នុង ព.ស. ២៤៥២, គ.ស ១៩០៦។ ជាអត្ថបទពាក្យ មានបទកាកគតិ ព្រហ្មគិត ពំនោល និងបទភុជង្គលិលា។

តាមដំណើររឿង ហាក់ដូចជា ការនិយាយពីជីវិតរបស់ ពោធិសត្វដែលមានប្រភពចេញមកអំពីគម្ពីរជាតកមួយមាន បញ្ញាសជាតកឬ៥០០ជាតកជាដើម។

ឯកសារដើមជាស្លឹករិតមាន ៨ ខ្សែចប់ជុំជាតក៍។ លេខសាស្ត្រា១៦២៩ រក្សាទុកនៅពុទ្ធសាសនបណ្ឌិត្យ។ចុះលេខ ១៨១ រក្សាទុកនៅពុទ្ធសាសនបណ្ឌិត្យ ។

## ៣.លក្ខណៈតែងមានដូចនេះជា

## ក.សេចក្តីផ្តើម បទកាកគតិ

យើងខ្ញុំបង្គំ កិតតួញពុទ្ធបាទ គ្រួញក្រាបវន្ទា ទាំងទសធូលី តាំងភ្ជីបុណ្យថារ បង្គំភគវា --សារពេ្វជជិនស្រី ។ ទោះទាំងព្រះធម៌ ប្រសើរអស់អាថ៌ បើកបទបាលី ប៉ែនម៉ឺនសែនពាន់ បានព្រះគម្ពីរ សោស្ងួនទ្បវន្តី ជួញជង្គលីយោ បង្គំព្រះសង្ឃ ប្រសើរសឹងទ្រង់ សីលសិទ្ធសរង្គា ឱនអស់កង្កា ហត្ថរសរា ក្រយញក្រាបវន្ទ ទុកលើសិរសា ។ ខ្ញុំនិងថែង និតនថ្លាថ្លែង ជុំជាតិមាត្តិកាកាលព្រះពោធិ៍ កំបាំងសោតកាលណោះ ពីមុនមិញនេះ ពហុជាតា ។

## ខ.សេចក្តីបញ្ចប់

ថាភិក្ខុវេរ ភិក្ខុកើយគម្ពីរ ក្រពើរយុងឃ្នង ទ្រីស្តិទ្រុស្តប្របាត់ ឃោរឃាតមានហ្មងឥឡូវនេះហាង ចេះវឹលវឹងជា ។ ទេវទតោ គឺនាមគោ ទេវទតថេរោ ឥតិបាបំ នាមំសូរិសា

ចឹងបារីកា ទេវទតកិរិយំ ។

ក្នុងព្រះបាលី សម្តេចព្រះស្រី សារពេជ្ញទេសនា សម្ពាធានី សឹងជាតិកា គតិអរា តិង្គិកាចែងចប់ ។

សរុបសេចក្តីមកម័យឧដុង្គ ជាពេលវេលាដែលកវីមានការរីកចម្រើនខ្លាំងខាងតែងនិពន្ធ នូវរឿងសាស្ត្រជាច្រើន ទុកឱ្យកុនចៅជំនាន់ក្រោយបានសិក្សា ដេលយើងប្រើហូតមកដល់សព្វថ្ងៃនេះ ។

## ១.អត្ថន័យនៃអត្ថបទ

សម្តេចព្រះបាទ អង្គឌួងបានតែងជាអត្ថបទជាការងប់រំ តាមរយៈស្នាដៃរឿងកាកីដល់ស្ត្រីកុំឱ្យមានចិត្តផិតក្បត់ស្វាមី គោរពប្រពៃណីជាស្ត្រីខ្មែរ បានតែងកំណាព្យជាច្បាប់ស្រីផងដេរ។ មិនតែប៉ុណ្ណោះមានការអប់រំដល់មនុស្សទូទៅ មិនថាជាមន្ត្រី ឬរាស្ត្រ ព្រះអង្គមានក្តីមេត្តាគ្រប់ជាន់ថ្នាក់។

## ២.អំពីអត្ថរូបនៃអត្ថបទ

ចំណែកវិធីតែងគេប្រើពាក្យកាព្យ កំណាព្យ មានបទផ្សេង ៗ គ្នា គឺ បទកាកគតិ ព្រហ្មគិត ភុជង្គលីលា បន្ទោលកាក ឬ ពំនោលជាដើម ដើម្បីជួយជាមធ្យោបាយសម្របសម្រួលតាមឧត្តមគតិនៃសាច់រឿងតាំងមូលដែលបានបំពេញអារម្មណ៍ បន្លួបន្លយក្តីទុក្ខសង្រេងឱ្យបានធូរស្បើយ។

### ក.សេចក្តីផ្តើម

ការរឿង ជាបទនមស្ការ ព្រះរតនត្រ័យ រំលឹកគុណព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ រំលឹកគុណព្រះមហាក្សត្រ មាតា បិតា គ្រូបាធ្យាយជាដើម ។ ឯកសារខ្លះមានបញ្ជាក់កាលបរិច្ឆេទនៃការតាក់តែងរបស់អ្នកនិពន្ធ ។ ឆ្នាំដែលគេ ប្រើ ច្រើនជាពុទ្ធសករាជ មហាសករាជ មានបញ្ជាក់ពីប្រភពរឿង ដែលអ្នកនិពន្ធបានដកស្រង់យកមកតាក់តែងរចនា។ហើយមានប្រាប់ឈ្មោះងារស័ក្តិលំនៅដ្ឋានរបស់អ្នកនិពន្ធ។ ស្នាដៃខ្មែរទៀត ប៉ុន្តែរឿងមួយភាគធំ បែរជាពុំមាន ឬបាត់នូវកាលបរិច្ឆេទ និងឈ្មោះអ្នកនិពន្ធជាដើម ។

### ខ.តួសេចក្តី

តួសេចក្តីអ្នកនិពន្ធច្រើនប្រើភាសាបាលី ឬសំស្ក្រឹត ទៅតាមចំណេះដឹងរបស់អ្នកនិពន្ធក្នុងការតាក់តែងរៀបរៀងរឿង។ ដំណើររឿងជឿលើបញ្ហាកម្មផល ធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់។

### គ. បញ្ចប់សេចក្តី

បញ្ចប់សេចក្តី អ្នកនិពន្ធបញ្ចប់រឿង ដោយធ្វើការឧទ្ទិសប្រាថ្នាកុសលបែបអធិដ្ឋាន ឬការសរជាតិ (ដំណើរ រឿងមានប្រភពពីព្រះពុទ្ធសាសនា)។

## ៣. អត្ថរសអត្ថបទ

ដោយដំណើររឿង ជារឿងសម្រាលទុក្ខប្រជាពលរដ្ឋ ដូច្នេះរឿងត្រូវមានភាពអស្ចារ្យ អច្ឆរិយៈ (អច្ឆរិយរស) ធម្មតា(សាមញ្ញរស) កំសត់(ទារុណរស) កំប្លែង (ហាសរស)ដែលជាលក្ខណៈត្រទ្រង់នៃអត្ថរសទូទៅរបស់អត្ថបទ។ ជារួមអក្សរសិល្ប៍សម័យឧដុង បានរីកចម្រើនខ្លាំងជាសម័យយុគមាសនៃអក្សរសិល្ប៍ ដោយសារបានការយកព្រទ័យទុកដាក់របស់ព្រះមហាក្សត្រ នាម៉ឺនមុខមន្ត្រី គ្រប់ជាន់ថ្នាក់ ដោយមានការប្រកួតប្រជែងតាក់តែងជាកំនាព្យ រឿងអក្សរសិល្ប៍ផ្សេងៗ ដើម្បីឱ្យបណ្ឌិតកវី ប្រកួតប្រជែងគ្នា យកស្នាដៃក្នុងការនិពន្ធរបស់ខ្លួន ។ អ្នកនិពន្ធតែងជារឿងអណ្តែតអណ្តូងនិយមក៏ដោយវាមានតម្លៃអប់រំពិតៗ តាមរយៈព្រះពុទ្ធសាសនា និងបានជួយអក្សរសាស្ត្រជាតិឱ្យនៅស្ថិតស្ថេររហុតដល់សព្វថ្ងៃ។គ្រប់អក្សរសិល្ប៍តាំងអស់នៅម័យឧដុង បានផ្តល់តម្លៃងប់រំយ៉ាងធំធេងសម្រាប់ប្រជាពលរដ្ឋមានការប្រព្រឹត្តិអំពើ

ល្អ ជួយលើកទឹកចិត្តនូវពេលពួកគេអស់សង្ឃឹមក្នុងឆាកជីវិត ឱ្យចេះខ្លាចរអាចំពោះអំពើបាបទាំងនោះ ។

## ៤.៥. ព្រះពុទ្ធសាសនា

ព្រះពុទ្ធសាសនា ជាភាសាសនាមួយដែលមានអ្នកគោរពកាន់រហូតដល់ទៅរាប់រយលាននាក់ ។ ហើយបានរីកផ្សាយភាយស្ទើរពាក់ពេញពិភពលោក អ្នកប្រាជ្ញជាច្រើនបានអះអាងថាព្រះពុទ្ធសាសនាជាសាសនាមួយមានត្រឹមត្រូវបំផុតចំពោះឱវាទ ឬពាក់ព្រៀងប្រដៅរបស់ព្រះពុទ្ធមានលក្ខណៈជារបស់មនុស្សសុទ្ធសាធ កម្ពុជាកំណត់យកព្រះពុទ្ធសាសនាគឺជាសាសនារបស់រដ្ឋ ។ ហើយទ្រឹស្តីលិទ្ធិព្រះពុទ្ធតែងតែអប់រំទូន្មានឲ្យមនុស្សប្រព្រឹត្តអំពើល្អ អំពើជាកុសលដោយជៀសវាងការប្រព្រឹត្តអំពើបាបជាអកុសលកម្មគ្រប់បយ៉ាងហើយមានគោលបំណងរក្សាសេចក្តីសុខសាន្តសន្តិភាពការមិនបៀតបៀនគ្នាទៅវិញទៅមក ។ ការអប់រំនេះ គឺឲ្យមនុស្សមានតែគ្នាប្រាសចាកកិលេសតណ្ហា ជាសាសនានៃបញ្ញា មានករុណានិងណែនាំឲ្យមនុស្សគ្មានការរើសអើង ជួយគ្នានឹងគ្នាមិនបែងចែកវណ្ណៈក្នុងរឿងភេទស្រីប្រុសឡើយ។ ហើយក៏បានសាបព្រោះនូវការចេះរក្សាសិលទាន មានគញ្ញណធម៌ សីលធម៌ឲ្យដុសដាលក្នុងក្នុងខ្លួនមនុស្សគ្រប់គ្នាផង ។

សរុបមកព្រះពុទ្ធសាសនាបានចុលរួមចំណែកក្នុងការអប់រំដល់មនុស្សគ្រាប់រូប ឱ្យចេះប្រព្រឹត្តអំពើល្អជាកុសលគ្រប់បែបយ៉ាងហើយយើងគ្រាប់រូបគោរពមកដល់សព្វថ្ងៃនេះ ។

### ៤.៥.១. ព្រះពុទ្ធសាសនាក្នុងសង្គមខ្មែរ

នៅក្នុងដែនដីសុវណ្ណភូមិព្រះពុទ្ធសាសនាបានឈានជើងចូលប្រទេសខ្មែរយើងនៅ ស.វទី៣ ក្នុងរាជកាលព្រះបាទអសោកមហារាជ២១៨ មុន គ.ស ១៤ ។ យើងបានឃើញនៅក្នុងគម្ពីរមហាវង្ស ពង្សាវតាលង្កាទ្វិបក្នុងសៀវភៅពុទ្ធសាសនាសង្ខេបបានសរសេររៀបរាប់ថា កាលព្រះសោណត្ថេរ និងឧត្តមត្ថេរនិមន្តទៅដែនដីសុវណ្ណភូមិ មានន័យថាកោះមាស តាមសេចក្តីខាងលើបានឱ្យដឹងថា ព្រះពុទ្ធសាសនាបានហូរចូលតាំងពីមុន គ. សមកហើយ ។ នៅសម័យនគរភ្នំប្រទេសខ្មែរយើងនិយមកាន់ព្រះពុទ្ធសាសនានិកាយមហាយាន បន្ទាន់មកគឺព្រាហ្មណ៍សាសនា ។ នៅសម័យចេន្ឡា សាសនាព្រាហ្មណ៍មានការរីកចម្រើនខ្លាំងជាងនៅសម័យហ្វូណន ចំណែកពុទ្ធសាសនាមានការចុះអន់ថយ ពុំសូវទទួលបានការរាប់អានពីព្រះមហាក្សត្រទេ ។ គេបានរកឃើញព្រះពុទ្ធរូប៤០អង្គរនៅតំបន់ភាគាគខាងក្រោមនៃទន្លេមេកង្គមាននៅតំបន់ដ៏ទៃ
ទៀត ប្រទេសថៃ មានទំនាក់ទំនាក់ទំនងជាមួយអណាចក្រភ្នំ២៥ ។ គេបានរកឃើញព្រះពុទ្ធរូបនៅស្រុកព្រៃកប្បាសខេត្តតាកែវដែលបានកសាងឡើងនៅ ស.វទី៧ ។ នៅក្នុងរាជព្រះបាទជ័យវរ័នទី១ មានសិលាចរិចនៅវត្តព្រៃរៀងស្រុកកំពង់ត្របែក ខេត្តព្រៃវែងបានសរសេរថា × មានភិក្ខុពីរអង្គជាបងប្អូនបង្កើតនិងគ្នាជាមហាក្សត្រ ចេញសាងព្រះផ្នូសគង់នៅវត្តព្រៃរៀងព្រះនមថា ×ភិក្ខុរតនភាណុ និងភិក្ខុរតនសិង្គ២៦។ នៅសម័យអង្គរព្រះបាទជ័យវរ្ម័នទី៧សាសនិតដ៏ឆ្នើមបានកាន់ព្រះពុទ្ធសាសនានិកាយមហាយាន គោរពប្រះពោធិសត្វអវលោកិស្វៈនិងព្រះប្រាជ្ញាបារតា២៨ ធ្វើឱ្យប្រទេសជាតិមានការរីកចម្រើនគ្រប់វិស័យ ហើយប្រទេសខ្មែរយើងបានក្លាយជាប្រទេសដ៏ខ្លាំងហើយល្បីរន្ទឺពេញសកលលោក ។ ក្រោយព្រះបាទជ័យវរ្ម័នទី៧ទៅមានទំនាស់វិបត្តិសាសនាកើតមានរ៉ាំរៃរហូតដល់រាជព្រះបាទត្រសក់ផ្អែ ឬអង្គជ័យ ព្រះអង្គព្រះអង្គបានដោះស្រាយវិបត្តិសាសនាបានដោយទទួលយកកាន់សាសនាព្រះពុទ្ធបែបនិកាយហិនយានដែលប្រជាជនខ្មែរទូទៅគោរពប្រត្តិបត្តរហូតមកដល់សព្វថ្ងៃយើងនេះ។

នៅក្រោយអង្គរឬសម័យកណ្តាល ប្រះពុទ្ធសាសនាហិនយានបានជ្រៅជ្រាបសុសសាយចាក់ ឫសយ៉ាងមាំនៅក្នុងសង្គមខ្មែរ មានទាំងគ្រប់ស្រទាប់វណ្ណៈព្រះពុទ្ធសាសនាមានការអប់រំដល់មនុស្សទូទៅ គ្រប់ទីកន្លែងយើងក៏បានឃើញការកសាងវត្តអារាមជាច្រើននៅបច្ចុប្បន្ននេះផងដែរ។ត្រឹង ងា ប្រវត្តិសាស្ត្រខ្មែរភាគ១.២ បោះពុម្ពឆ្នាំ១៩៧៣។

### ៤.៥.២ ឥទ្ធិពលព្រះពុទ្ធសាសនាសម័យក្រោយអង្គរ

ព្រះពុទ្ធសាសនាសម័យក្រោយអង្គ រឬសម័យកណ្តាល បានផ្តល់តម្លៃអប់រំយ៉ាងសំខាន់នៅក្នុងសង្គមខ្មែរ ចូលខ្លួនមកជំនួសឱ្យព្រហ្មនិយមល្បីល្បាញ់នៅក្នុងសម័យអង្គរ ។ ចំណែកព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ និងជាសាសនាផ្លូវការរបស់ប្រទេសកម្ពុជាផងដែរមាន

រហូតមកដល់សព្វថ្ងៃនេះ។ នៅពេលដែលប្រទេសបានជួបនិង សង្គ្រាមរ៉ាំរ៉ៃគ្រប់បែបយ៉ាង ទាំងសង្រ្គាមជាមួយរាជវង្សង្សាវង្ស ទំនាស់វិបត្តិផ្ទៃក្នុងម្នាក់ៗ គិតថាខ្លួនមានសិទ្ធឡើងគ្រង់រាជដូចៗ គ្នា និងសង្គ្រាមជាមួយប្រទេសជិតខាងជាពិសេសនោះគឺប្រទេសសៀម ។

នៅពេលព្រះពុទ្ធសាសនាបានចូលខ្លួនមកក្នុងសង្គមខ្មែរស្របពេលដែលប្រទេសខ្មែរកំពុងជួបប្រទះនិង ធ្លាក់ខ្លួនចូលក្នុងភ្លើងសង្រ្គាម ធ្វើឱ្យបាត់បងនូវអ្វីៗ គ្រប់យ៉ាង មានគម្ពីរក្បួនច្បាប់ធម៌វិន័យដោយជនបរទេសបំផ្លិចបំផ្លាញបាត់អស់ស្ទើគ្មានសល់ ។ នូវពេលនោះហើយដែលព្រះពុទ្ធសាសនាបានជួយលោងលោមអារម្មណ៍ផ្លូវចិត្ត ឱ្យមានកម្លាំងចិត្តឡើងវិញ ហើយផ្តេកផ្តួលទៅលើព្រះពុទ្ធសាសនា តាមទស្សនៈព្រះពុទ្ធសាសនា ទស្សនៈកម្មផលមានបុណ្យបាន អរិយសច្ចៈ បានជួយឱ្យប្រជាពលរដ្ឋខ្មែរមានកម្លាំងចិត្ត បំបាត់នូវទុកកង្វល់ទាំងពួងធ្វើឱ្យពួកគាត់មានទឹកចិត្តតស៊ូឡើងវិញ ។

អក្សរសិល្ប៍ក្រោយសម័យអង្គរ ឬសម័យកណ្ដាល យើងបានដឹងតាមឯកសារនានាមានរឿងល្បែង បានចងក្រងឡើងមានគម្ពីរព្រះត្រៃបិដកព្រះពុទ្ធសាសនា គម្ពីរបញ្ញាសជាតក៍ ទាក់ទងនិង ព្រះពុទ្ធសាសនា បញ្ហាកម្មផល សជាតិ ចំណែកទីកន្លែងគឺមានឋានសួគ៍ ឋាននរក ឋានកណ្ដាល នគរពារាសី ស្ថានបាតាស ព្រៃហេមនិពាន្ធ មានបច្ចុប្បន្នជាតិ អនាគតជាតិ អតីតជាតិ ធ្វើឱ្យមនុស្សគិតថា ធ្វើអំពើល្អបានកើតនៅឋានសួគ៍និពាន្ធ និងធ្វើអំពើអាក្រក់ធ្លាក់ទៅក្នុងឋាននរកធ្វើឱ្យពួកគេខ្លាចរអារស្អប់ខ្ពើមអំពើជាអកុសលទាំងឡាយផងដែរ ។

បច្ចុប្បន្ន ព្រះពុទ្ធសាសនាបានបន្តវិវឌ្ឍន៍ និងមានឥទ្ធិពលយ៉ាងសំខាន់លើទិដ្ឋភាពផ្សេងៗ នៃវប្បធម៌ សង្គម និងនយោបាយនៅអាស៊ីអាគ្នេយ៍ ។ ខាងក្រោមនេះជាឥទ្ធិពលសំខាន់ៗមួយចំនួននៃព្រះពុទ្ធសាសនាបន្ទាប់ពីសម័យអង្គរ។

ឥទ្ធិពលវប្បធម៌ និងសិល្បៈ ការធ្លាក់ចុះនៃអាណាចក្រអង្គរ បានឃើញការផ្លាស់ប្ដូរពីសាសនាហិណ្ឌូ មកព្រះពុទ្ធសាសនា ជាសាសនាលេចធ្លោនៅកម្ពុជា ។ ការផ្លាស់ប្ដូរនេះមានឥទ្ធិពលលើសិល្បៈ ស្ថាបត្យកម្ម និងអក្សរសិល្ប៍។ ប្រាសាទដូចជាវត្តភ្នំ និងវត្តប្រាក់ក្នុងទីក្រុងភ្នំពេញ ឆ្លុះបញ្ចាំងពីរចនាបថស្ថាបត្យកម្មព្រះពុទ្ធសាសនា និងរូបតំណាង។ ប្រធានបទព្រះពុទ្ធសាសនាបានលេចធ្លោក្នុងសិល្បៈចម្លាក់ គំនូរ និងវាយនភ័ណ្ឌ។

ឥទ្ធិពលនយោបាយ៖ ព្រះពុទ្ធសាសនាបានដើរតួនាទីយ៉ាងសំខាន់ក្នុងការធ្វើឱ្យអំណាចនយោបាយស្របច្បាប់។ អ្នកគ្រប់គ្រងតែងតែយកព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ ដើម្បីបង្រួបបង្រួមមុខវិជ្ជារបស់ពួកគេ និងទទួលបានសិទ្ធិអំណាចខាងសីលធម៌។ រជ្ជកាលព្រះបាទនរោត្តមក្នុងសតវត្សទី ១៩ បានឃើញការរស់ឡើងវិញនៃព្រះពុទ្ធសាសនាថេរវាទដែលត្រូវបានប្រើដើម្បីពង្រឹងរាជាធិបតេយ្យនិងលើកកម្ពស់អត្តសញ្ញាណជាតិ។

រចនាសម្ព័ន្ធសង្គម និងជីវិតសហគមន៍៖ វត្តអារាមបានក្លាយជាមជ្ឈមណ្ឌលនៃការអប់រំ និងជីវិតសហគមន៍។ ពួកគេបានផ្ដល់សេវាសង្គម ដូចជាការថែទាំសុខភាព និងការគាំទ្រដល់ជនក្រីក្រ ហើយបម្រើជាកន្លែងសម្រាប់ការជួបជុំវប្បធម៌។ ព្រះសង្ឃ (សហគមន៍ព្រះសង្ឃ) បានដើរតួនាទីយ៉ាងសំខាន់ក្នុងការថែរក្សាសណ្ដាប់ធ្នាប់សង្គម និងការណែនាំសីលធម៌។

ការធ្វើសមកាលកម្មសាសនា៖ នៅក្នុងតំបន់ជាច្រើននៃអាស៊ីអាគ្នេយ៍ រួមទាំងប្រទេសកម្ពុជាផងដែរ ព្រះពុទ្ធសាសនាតែងតែរួមរស់ជាមួយជំនឿ និងការប្រតិបត្តិក្នុងស្រុក ដែលនាំឱ្យមានទិដ្ឋភាពសាសនាដែលស៊ីសង្វាក់គ្នា។ ធាតុនៃសាសនានិកាយ និងព្រហ្មញ្ញសាសនាត្រូវបានបញ្ចូលទៅក្នុងការអនុវត្តព្រះពុទ្ធសាសនា ដែលបណ្ដាលឱ្យមានទម្រង់ព្រះពុទ្ធសាសនាក្នុងស្រុកតែមួយគត់។

ឥទ្ធិពលលើប្រទេសជិតខាង៖ ការរស់ឡើងវិញនៃព្រះពុទ្ធសាសនាថេរវាទនៅកម្ពុជាបានជះឥទ្ធិពលយ៉ាងខ្លាំងនៅក្នុងប្រទេសជិតខាងដូចជាប្រទេសថៃ និងឡាវ។ ការផ្លាស់ប្ដូរគំនិតអត្ថបទ និងការប្រតិបត្តិសាសនាបានរួមចំណែកដល់បេតិកភណ្ឌវប្បធម៌ និងសាសនាក្នុងតំបន់។

ការអភិវឌ្ឍន៍សម័យទំនើប៖ នៅសតវត្សទី ២០ ព្រះពុទ្ធសាសនាបានប្រឈមមុខនឹងបញ្ហាដោយសារអាណានិគមនិយម សង្គ្រាម និងទំនើបកម្ម។ ទោះជាយ៉ាងណាក៏ដោយ វាក៏បានជួបប្រទះការរស់ឡើងវិញផងដែរ ជាមួយនឹងចលនាដែលសំដៅទៅរកយុត្តិធម៌សង្គម និងកំណែទម្រង់កំពុងលេចឡើង។ សព្វថ្ងៃនេះ ព្រះពុទ្ធសាសនានៅតែជាផ្នែកសំខាន់នៃអត្តសញ្ញាណ

របស់ខ្មែរ ហើយនៅតែបន្តមានឥទ្ធិពលលើបញ្ហាសហសម័យ ដូចជាការអប់រំ នយោបាយ និងសុខុមាលភាពសង្គម។

សកលភាវូបនីយកម្ម និងនិរន្តរភាព៖ ក្នុងប៉ុន្មានទសវត្សរ៍ថ្មីៗនេះ ព្រះពុទ្ធសាសនាកម្ពុជាត្រូវបានជះឥទ្ធិពលដោយសកលភាវូបនីយកម្ម និងនិរទេសកម្ពុជា។ នៅពេលដែលប្រជាជនកម្ពុជាបានធ្វើចំណាកស្រុកទៅកាន់ប្រទេសផ្សេងៗ ពួកគេបាននាំយកប្រពៃណីព្រះពុទ្ធសាសនាមកជាមួយ ដែលនាំទៅដល់ការបង្កើតវត្តអារាម និងសហគមន៍នៅបរទេស ដែលរក្សានូវទំនៀមទម្លាប់វប្បធម៌ ស្របពេលដែលសម្របខ្លួនទៅនឹងបរិបទថ្មី។

មួយវិញទៀតឥទ្ធិពលព្រះពុទ្ធសាសនាក៏បានគ្រប់គ្រង់ទៅលើអក្សរសិល្ប៍ពុទ្ធនិយមផងដែរ ហើយបានផ្សព្វផ្សាយជាច្រើនតាមរយៈស្នាដៃនៃរឿងអក្សរសិល្ប៍អក្សរសិល្ប៍ពុទ្ធនិយម គឺមានគោលគំនិតចម្បងក្នុងការអប់រំមនុស្សឱ្យជឿទៅលើសាសនា ទ្រឹស្តីពុទ្ធសាសនា នៅពេលអ្នកនិពន្ធខ្មែរ លោកបានតាក់តែងនូវរឿងនោះ លោកក៏បានបញ្ចូលនូវ លក្ខណៈជាតិរបស់ខ្មែររួមជាមួយផងដែរ ។

## ៤.៦. ទស្សនៈកម្មផល

ចំពោះ អក្សរសិល្ប៍ពុទ្ធនិយរ៉ាក៏បានបង្ហាញពីទស្សនៈកម្មផលគឺជាទស្សនៈដែលសំខាន់បំផុតនៅក្នុងលិទ្ធិព្រះពុទ្ធសាសនា ហើយបានពន្យល់ប្រាប់ផងដែរថា កម្ម ឬអំពើរបស់មនុស្សសត្វ បានប្រព្រឹត្តិហើយ ពុំអាចនរណាម្នាក់អាចទទួលជំនួសបានទេ អ្នកប្រព្រឹត្តិនិងទទួលដោយខ្លួនឯង អ្នកធ្វើកម្មល្អនិង ទទួលបានល្អ អ្នកធ្វើកម្មអាក្រក់និងទួលបានអាក្រក់ មនុស្ស សត្វគ្រប់រូបដែលកើតមកហើយរមែងជួបនូវសេចក្តីទុក្ខ សោកជរាព្យាធិ មរណៈ វិលកើត វិលស្លាប់ វាវដ្តសង្សាដែលបុគ្គលម្នាក់ៗ ពុំអាចជៀសផុតបាន ។ ចំណែកអ្នកបានកសាងនូវអំពើល្អ បានទៅកើតនៅឋានសួគ៌ ទេវលោកសោយសុខសម្បត្តិទេព្វគ្រប់បែបយ៉ាង អ្នកប្រព្រឹត្តអំពើអាក្រក់អកុសលកម្មពេលស្លាប់ទៅកាន់ឋាននរកសោយសុខនូវទុកវេទនាគ្រប់បែបយ៉ាង។ កម្មខ្លះឱ្យផលនៅបច្ចុប្បន្នជាតិ កម្មខ្លះឱ្យផលនៅអនាគតជាតិ ជាលំដាប់ៗមិនអាចឱ្យបុគ្គលនាអាចជៀសផុតបានឡើយ។

តាមរយៈទស្សនៈកម្មផលក៏បានបង្ហាញតាមរយៈស្នាដៃអក្សរសិល្ប៍ពុទ្ធនិយមរួមមានដូចខាងក្រោម៖

មាននៅក្នុងរឿងសព្វសិទ្ធ ក្នុងស្នាដៃអ្នកនិពន្ធ ហ៊ីនភក្តីអក្សរគន់ លោកបានបង្ហាញពីបញ្ហាកម្មផង ចាបចៀបកប្បាសកាលជាតិកើតនៅជាមនុស្សបានប្រព្រឹត្តិអំពើបាបដោយបានសម្លាប់សត្វស្លាបដោយដុតក្នុងភ្លើងឱ្យស្លាប់ នៅពេលពួកគេកើតមួយជាតិទៀតជាសត្វជៀបកប្បាសបានទទួលរងនូវបាបកម្មពៀររបស់ខ្លួនដែលបានកសាងទុក ដែលបានដុតសម្លាប់សត្វស្លាប ហើយកម្មពៀរនោះបានមកវិញធ្វើឱ្យកើតហេតុមានភ្លើងឆេះព្រៃដែលនាំឱ្យភ្លើងបានឆេះទីលំនៅជាលំនៅរបស់ពួកគេរួមទាំងកូននៅក្នុងសំបុកទាំងពីរកូននៅក្នុងសំបុកស្លាប់ទាំងអស់ឯចាបញីវិញ បានយល់ខុសចំពោះចាបឈ្មោលថា មានស្រីភ្លេចប្រពន្ធកូនមិនឃើញមករកផ្ទះវិញដោយចោទប្រកាន់ចាបឈ្មោល ទោះបីចាមឈ្មួលខំពន្យល់យ៉ាងណាក៏មិនស្តាប់។ដែលនោះមុននិងលោគទម្លាក់ខ្លួនស្លាប់ក្នុងភ្លើងចាបញីបាននិយាយថា កើតជាតិណាៗ កុំឱ្យនាងនិយាយស្ដីជាមួយមនុស្សប្រុស និយាយរួចក៏លោកចូលភ្លើងស្លាប់បាត់ទៅ។ ចំណែកចាបឈ្មួលវិញដោយចាមញីមិនព្រមស្តាប់ហេតុផលរបស់ខ្លួនបែបនោះមុន និងលោគចូលក្នុងភ្លើងចាបឈ្មោលបាននិយាយថាផ្សងជួបចាបញីគ្រប់ៗជាតិក៏លោគទំលាក់ខ្លួនចូលភ្លើងតាមចាបញីដែរ ហើយពួកគេបានទទួលកម្មពៀរនេះបន្តរហូតដល់ទៅប្រាំរយជាតិ។

ទាំងនេះហើយដែលធ្វើឱ្យចាបជៀបកប្បាសទាំងពីរទទួលកម្មពៀរវេរាដែលខ្លួនបានសាងពីអតីតជាតិហើយហុចផលមកដល់បច្ចុប្បន្នជាតិ ។ នៅក្នុងកំណើតជាតិជាសព្វសិទ្ធ អ្នកទាំងពីរមានការប្រច័ណ្ឌគ្នា មិនទុកចិត្តគ្នាទៅវិញទៅមកកម្មពៀរបានឆ្លងទៅអនាគតជាតិនេះឯង។ ហើយយើងឃើញមាននៅក្នុងទ្រឹស្តីកម្មផលកម្មនេះបានឱ្យផលជាបន្តបន្ទាប់គេរហៅថា អបរាបរវេទនីយកម្ម។

១. រឿងរឿង ចៅស្រទាប់ចេក វិញយើងឃើញថា ចៅស្រទាប់ចេកបានកសាងបាបកម្មពីអតីតជាតិដោយវាយសម្រាតស្បង់ជីពររបស់ព្រះសង្ឃធ្វើឱ្យព្រះសង្ឃអក្រាតរគខ្មាស់គេ។ ចំណែកកម្មពៀរនោះធ្វើឱ្យចៅស្រទាប់ចេកបានទទួលកម្មដែលខ្លួនបានកសាងពីអតីអជាតិបានទទួលនៅជាតិបន្តធ្វើឱ្យបាត់បងក្រុមគ្រួសារ នៅពេលម្តាយស្លាប់គ្មានអ្វីទ្រប់បឈូសចៅ

ស្រទាប់ចេកបានដោះសម្លៀកបំពាក់ទ្រប់ជំនួស ថ្វើឱ្យចៅស្រទាប់ចេកគ្មានសម្លៀកបំពាក់ស្លៀកដណ្តប់រាងកាយ ក៏បានយកស្រទាប់ចេកស្លៀកបិតបាំងកេរខ្មាស់ទៅ ផលនោះបានទទួលនូវបច្ចុប្បន្នជាតិ។ នៅក្នុងទ្រឹស្តីកម្មផលហើយផលឱ្យជាបន្តបន្ទាប់គេហៅថា អបរាបរវេទនាយកម្ម។

២.ចំណែកនៅក្នុងរឿង ពុទ្ធសែននាងកង្រី ជារឿងសាស្ត្រាល្បែងវិញបានបង្ហាញឱ្យយើងបានដឹងជារឿងដែលមានប្រជាប្រិយភាពនៅក្នុងសង្គមខ្មែរ និងមានភ្នំមួយឈ្មោះភ្នំនាងកង្រីតំណាងឱ្យនាងកង្រី។ រឿងនេះបានបង្ហាញពីបាបកម្មដែលនាងទាំងដប់ពីរបានកសាងនៅបច្ចុប្បន្នជាតិ នៅពេលពួកនាងត្រូវម្តាយបានយកទៅបំបរបង់ចោលនៅក្នុងព្រៃដោយគ្មានលទ្ធិភាពចិញ្ចឹមបីបាចថែរក្សាពួកគេ ពេលនោះពួកនាងរកផ្លូវមកផ្ទះវិញពុំឃើញវង្វេងផ្លូវដើរពេញព្រៃទាំងអត់អាហារដើរៗ ទៅបានប្រទះស្ទឹងមួយចុះចាប់ត្រីក្នុងស្ទឹងមួយ បានត្រីចង្វាម្នាស់មួយនាងបងៗទាំងដប់មួយបានដោតភ្នែកត្រីទាំងសងខាង ចំណែកនាងពៅបានដោតភ្នែកត្រីតែម្ខាង ។

ទាំងនេះហើយនាងទាំងដប់មួយបានទទួលកម្មផលមកវិញដោយយក្សសម្ងាចាប់ខ្វេសភ្នែកបងៗទាំងសងខាងចំណែកនាងពៅខ្វេសភ្នែកតែម្ខាង កម្មពៀរនេះទទួលនៅបច្ចុប្បន្នជាតិ ហៅថា ទិដ្ឋធម្មវេទនិយកម្ម។

៣. ចំពោះរឿង ទុលកបណ្ឌិត នៅបច្ចុប្បន្នជាតិព្រាហ្មណ៍បរោហិតដែលមានចិត្តអាក្រក់ចង់បៀតបៀនជីវិតអ្នកដ៏ទៃគឺភិក្ខុសង្ឃទាំងដប់បីអង្គ ដោយខ្លាចព្រះមហាក្សត្រសព្វព្រះហឫទ័យនិងភិក្ខុសង្ឃទាំងនោះខ្លួននឹងបាត់បងប្រយោជន៍ ព្រាហ្មណ៍បាននិយាយយាយញុសញ៉ង់ព្រះមហាក្សត្រថា មានចោរបន្លំខ្លួនធ្វើជាភិក្ខុ មករស់នៅលាយឡំជាមួយអ្នកស្រុក អ្នកភូមិស្តេចក៏ជឿតាមពាក្យព្រាហ្មណ៍ក៏បញ្ជាសេនាចាប់ខ្លួនភិក្ខុសង្ឃមកដាក់ទោសតាមសម្តីព្រាហ្មណ៍។

ដូចច្នោះព្រាហ្មណ៍បុរោហិត បានទទួលផលកម្មបច្ចុប្បន្នជាតិដែលខ្លួនបានប្រព្រឹត្តិដោយការចង់សម្លាប់ជីវិតភិក្ខុសង្ឃទាំងដប់បីរូបចុងក្រោយបរោហិតបានត្រូវព្រះរាជាបំបរបង់បណ្តេញចេញដែនដីរបស់ទ្រង់។កម្មពៀរនេះទទួលនៅបច្ចុប្បន្នជាតិ ហៅថា ទិដ្ឋធម្មវេទនិយកម្ម។

៤. រឿង ព្រះសុវណ្ណកច្ឆបៈ ក៏បានបង្ហាញពី អាមាត្រជាមនុស្សមានចិត្តរមើលគុណអ្នកបានជួយជីវិតខ្លួនគឺតាយាយទាំងពី ។ នៅពេលដែលប្រទេសបានជួបគ្រោះទឹកជំនន់ឡើងលិចទាំងនគរធ្វើឱ្យមនុស្ស សត្វស្លាប់ជាច្រើន ចំណែកអាមាត្របានយាយតាជួយសង្គ្រោះរួចផុតពីសេចក្តីស្លាប់ ។ ពេលថ្ងៃក្រោយមកបានមករកយាយតាម្តងទៀតយាយតាបានយកបាយទឹកមកឱ្យអាបាត្រហូប។ ហូបឆ្អែតហើយមិនគ្រាន់តែមិនដឹងគុណយាយតាដែលធ្លាប់ជួយជីវិតខ្លួននោះទេ បាននិយាយមូលបង្កាចពួកគាត់ថា តាយាយបានលួចសព៌រចាត្ររបស់ស្តេចថែមទៀត ។ អាមាត្រចង់ឱ្យពួកគាត់ទទួលគ្រោះថ្នាក់ក៏និយាយប្រាប់ស្តេចចំណែកស្តេចក៏ធ្វើតាមពាក្យអុចអាលរបស់អាមត្រ ។ ពេលស្តេចបាននិយាយសួរតាយាយៗ បាននិយាយប្រាប់ កាលទូលបង្គំទាំងពីរនាក់នៅពេលទឹកជំនន់បានកើតឡើង ។ ទូលព្រះបង្គំបានជួយសង្គ្រោះបានជួយសត្វខ្លាធំមួយ ស្វាមួយ ពស់មួយ និងអាមាត្រនេះផងដែរ មិនត្រឹមតែមិនដឹងគុណទូលព្រះបង្គំទាំងពីរថែមទាំងចោទប្រកាន់និងចង់សម្លាប់ទៀត ស្តេចបានដឹងការពិតបានដាក់ទោសអាមាត្រឱ្យក្លាយជាអ្នកបម្រើយាយតាអស់មួយជីវិត ។ កម្មពៀរនេះទទួលនៅបច្ចុប្បន្នជាតិ ហៅថា ទិដ្ឋធម្មវេទនិយកម្ម។

៥. រឿង កាកី នាងកាកីជាព្រះមហេសីព្រះបាទព្រហ្មទត្ត មានរូបឆោមលោមពណ៌ស្រស់ស្អាតសោភាគ្មានស្រីណាបៀបផ្ទឹមបាន ដែលកើតពីផ្កាកនិកាបើបុរសណាបានឃើញនាងកាកីតែងលង់ស្នេហ៍នាងពុំអាចគេចផុតឡើយ ។ ចំណែកស្តេចគ្រុឌដែលជាតួអង្គព្រះពោធិសត្វបានឃើញនាង កាកី ហើយលង់ស្រឡាញ់ នាងកាកី ចំណែកនាងកាកិវិញ ក៏មានចិត្តស្រឡាញ់មកវិញផងដែរ រហូតបានប្រព្រឹត្តិខុសច្បាប់ស្រីដែលបានទៅរួមរស់ជាមួយស្តេចគ្រុឌ ក្រោយមកបានរួមមេត្រីជាមួយគជន្ទ ស្តេចគ្រុឌបានដឹងរឿងនេះប្រគល់នាងឱ្យព្រះបាទព្រហ្មទត្តវិញ ព្រះបាទព្រហ្មទត្តក៏ដាក់ទោសនាងបណ្តែតពោងពាយនៅកណ្តាលមហាសាគររហូតបានក្ស័យព្រះជន្មទៅ។

ដូច្នោះកម្មពៀរដែលនាងកាកីបានប្រព្រឹត្តនៅបច្ចុប្បន្នកម្មពៀរនេះទទួលនៅបច្ចុប្បន្នជាតិ ហៅថា ទិដ្ឋធម្មវេទ។

៦.រឿង ចន្ទកុមារ នៅពេលព្រះបាទឯករាជបានយល់សុបិននិម្មិតឃើញខ្លួនបានទៅឋានត្រៃត្រឹងទើបព្រះអង្គចង់ទៅកើតនៅឋានសួគ៌ ទើបសួរទៅកាន់កណ្ឌហាលព្រាហ្មណ៍ថា "តើយើងត្រូវធ្វើបុណ្យដូចម្ដេច ទើបទៅ នៅឋានត្រៃត្រឹង្ស? ចូរអ្នកប្រាប់ខ្ញុំឲ្យធ្វើឲ្យខានតែបានទៅកើតដូចក្ដីប្រាថ្នា " កណ្ឌហាលព្រាហ្មណ៍ទូលថា "សូមទ្រង់ព្រះមេត្តាប្រោស ជនទាំងឡាយឲ្យទានដ៏ក្រៃលែងសម្លាប់នូវបុគ្គលដែលមិន សម្លាប់ ទើបបានទៅកើតឯឋានសួគ៌ ព្រះអង្គគប្បីបូជាយញ្ញ ដោយបុត្រទាំងឡាយ ៤ ព្រះអគ្គមហេសីទាំងឡាយ ៤ សេដ្ឋីទាំង ឡាយ៤ គោឧសភរាជទាំងឡាយ៤ សេះអាជានេយ្យទាំងឡាយ៤ ហើយនិងសត្វទាំងឡាយមួយមុខៗសុទ្ធត៤ៗ ទើបបានទៅកើត ឋានសួគ៌" ។ ព្រះអង្គបានធ្វើតាម អ្នកដែលត្រូវបូជាយញ្ញសម្រែកអ្នកត្រូវបូជាយញ្ញយំស្រែកនិងការបួងសួងបានក្ដៅដល់ប្រះឥន្ទ្រាធិរាជ ព្រះឥន្ទ្រាធិរាជក្រវីដែកស្រែកគម្រាម ព្រះបាទឯករាជថា "ម្នាល ស្ដេចកាឡកណ្ណីអប្រិយលាមក អញនឹងសំពងក្បាលឥឡូវ ឯងមាន ដែលឃើញពីអង្កាល់អ្នកដែលសម្លាប់បុត្រ មហេសី សេដ្ឋី គហបតី ព្រោះប្រាថ្នាឋានសួគ៌នោះ"។ រំពេចនោះព្រះរាជា និងកណ្ឌហាលព្រាហ្មណ៍បានស្ទុះទៅស្រាយចំណងជនទាំងនោះទាំងអស់គ្នា ។ ប្រជារាស្ត្រទាំងអស់យកដុំដីចោលកណ្ឌហាលព្រាហ្មណ៍រហូតដល់ស្លាប់ទៅ រីឯព្រះបាទឯករាជអ្នកស្រុកបណ្ដេញចេញពីព្រះនគរ។

កម្មដូច្នោះកម្មពៀរដែលព្រះបាទឯករាជ និងកណ្ឌហាលព្រាហ្មណ៍បានប្រប្រត្តឹនៅ បច្ចុបន្នជាតិកម្មពៀរនេះទទួលនៅបច្ចុប្បន្នជាតិ ហៅថា ទិដ្ឋធម្មវេទ។

៦. ចំណែករឿង នាងចដាចារ ស្នាដៃសាស្ត្រល្បែង បានបង្ហាញទស្សនៈកម្មផល នៅពេលដែលនាងបដាចារបានស្រឡាញ់គ្នាជាមួយថៅបាណពដែលជាអ្នកបម្រើនៅផ្ទះរបស់នាងតាំងតែពីក្មេងពីព្រោះ ថៅមាណពជាក្មេងកំព្រាឪពុក ម្ដាយ ។ ហើយបានស្រឡាញ់កូនក្រមុំសេដ្ឋីពួកគេទាំងពីរមានចិត្តឱ្យគ្នាទៅវិញទៅមក ក៏បានប្រព្រឹត្តជ្រុលជ្រុះខុសប្រពៃណីទុំមុនស្រគាល ពេលនោះបានដឹងដល់លោកសេដ្ឋី សេដ្ឋីខឹងយ៉ាងខ្លាំង ។ អ្នកទាំងពីរស្រឡាញ់គ្នាស្នាក់ស្នោះក៏ពង្រតគ្នាទៅរស់នៅទីឆ្ងាយពីស្រុកភូមិ ។ ក្រោយមកនាងបដាចារមានផ្ទៃពោះនៅពេលសម្រាលថៅមាណពទៅរកកាប់អុស ស្រាបតែពស់ពិសចឹកស្លាប់តែម្ដង។ ពេលនាងបដាចារឃើញប្ដីស្លាប់ នាងបាននាំកូនទាំងពីរទៅស្រុកកំណើតវិញដោយតាមផ្លូវធ្វើដំណើរត្រូវឆ្លងស្ទឹង ពេលទៅដល់ស្ទឹងនាងបានចម្លងកូនប្អូនទៅមុន កូនប្រុសបងនៅត្រើយម្ខាងទៀត។ ពេលដាក់កូនប្អូនត្រើយម្ខាងហើយមានខ្លែងឆាបយកកូនប្អូនទៅបាត់ ម្ដាយក៏ស្រែកកុំឱ្យខ្លែងយកទៅ កូនបងស្មានតែម្ដាយហៅក៏ចុះលង់ទឹកស្លាប់ទៅ ។ ពេលនាងមកដល់ភូមឪពុកនិងម្ដាយ ស្លាប់ទាំងពីរ បងប្រុសក៏ស្លាប់ដោយសារភ្លើងឆេះផ្ទះ ក៏ធ្វើឱ្យនាងរន្ធត់ចិត្តជាខ្លាំងក្លាយជាមនុស្សបាត់ចងនូវសតិស្មារតី វិកលចរិចមួយរំពេច ។

កម្មពៀរដែលនាងបដាចារបានកសាងព្រោះ តែមិនស្ដាប់បង្គាប់លោកអ្នកមានគុណធ្វើឱ្យនាងទទួលទុក្ខទោសគ្រាប់បែបយ៉ាងនៅពេលបច្ចុប្បន្នជាតិហៅថា ទិដ្ឋធម្មវេទ។

៧. មួយវិញទៀតរឿង តេមិរាជ បានបង្ហាញឱ្យយើងឃើញពីលក្ខណៈកម្មផលនៅពេលព្រះតេមិរាជកុមារបានទៅជាមួយ មាតលិទេវបុត្រ ទៅទតនៅឋាននរកពេលនោះព្រះអង្គបានទតឃើញសត្វនរកមួយចំនួនត្រូវយកមកដោតដោយលំពែង ផឹកទឹកក្រុត ត្រូវត្មាតចឹក ត្រូវរងនៅការសំពងដោយដំបងដែកមាត់ស្រួច ស៊ីខ្ទុះឈាមភ្លើងឆេះក្បាលកាត់ព្រលះបោះក្នុងទឹកក្ដៅ ។ ពួកវាជាមនុស្សមានទ្រឹស្ដីខុសផ្ទុយពីការពិតព្រះមោហៈគឺមានសេចក្ដីយល់ថាការឲ្យទានមិនមានផលផលនៃអំពើល្អនិងអំពើអាក្រក់មិនមានមាតាបិតាមិនមានគុណសមណព្រាហ្មណ៍ប្រព្រឹត្តិប្រតិបត្តិឥតប្រយោជន៍ ។ ស្លាប់ទៅចាប់ជាតិកំណើតជាថ្មីទៀតមិនមានលោកដ៏ទៃមិនមានយល់ខុសដូច្នេះហើយ ថែមទាំងបបួលនាក់ដ៏ទៃឲ្យយល់ខុសចាកគន្លងធម៌តាមទ្រឹស្ដីរបស់ខ្លួនឯង។

ដូចនេះអំពើបានបានដល់ពួកនរកបានកសាងទុកនោះពេលស្លាប់ទៅត្រូវទទួលនូវកម្មដែលខ្លួនបានប្រព្រឹត្តិនូវអំពើបាបកម្មទាំងឡាយនោះហើយយើងឃើញមាននៅក្នុងទ្រឹស្ដិកម្មផលកម្មនេះបានឱ្យផលជាបន្តបន្ទាប់គេរហៅថា អបរាបវេទនីយកម្ម។

នៅក្នុងរឿង វិបុលកិត្តិ ពេលដែលព្រះនាង សិរិរតនាភា បានធ្វើដំណើរទៅរកបេះផ្លែផ្លូនៅក្នុងព្រៃពេលនោះព្រះនាងបានចូលសម្រាកក្រោមម្លប់ដើមជ្រៃដ៏ធំមួយ ។ នៅទីនោះមានយក្សនៅរក្សាដើមជ្រៃនោះក៏បានចាប់ឃាត់ព្រះនាងទុកមិនឲ្យព្រះនាងមកលំនៅឋានរបស់ព្រះនាងវិញទេ ។ ព្រះរាជកុមារបាត់មាតាយូរពេក មិនឃើញត្រឡប់មកផ្ទះវិញដូចសព្វដងក៏ចេញទៅតាមរកព្រះមាតា ហើយស្រែកប្រកាសហៅនៅពេលទៅដល់ជិតដើមជ្រៃធំមួយ

នោះ ព្រះពោធិសត្វបានឮសំឡេងព្រះមាតាឆ្លើយតបមករកខ្លួន។ហើយទៅដល់ក៏បានឃើញយក្សនៅទីនោះ បម្រុងនឹងសម្លាប់ព្រះមាតា ។ ព្រះអង្គបានឃាត់យក្សដោយនិយាយថាបើអ្នកចង់បរិភោគបរិភោគខ្លួនខ្ញុំទៅ ទុកជីវិតឲ្យព្រះមាតារបស់ខ្ញុំ ។ យក្សក៏បាននិយាយថាបើអ្នកអាចពុះទ្រូងរូងយកបេះដូងមកឲ្យយើងបាន យើងនឹងលែងម្ដាយអ្នកភ្លាម ។ នៅពេលនោះព្រះពោធិសត្វបានអធិដ្ឋានថា សូមឲ្យមានអាវុធធ្លាក់មកពីលើហើយអាវុធក៏ធ្លាក់មកមែន ។ ព្រះអង្គក៏ពុះទ្រូងរូងយកបេះដូងប្រគល់ជូនដល់ដៃយក្ស ហើយក៏ដួលសន្លប់បាត់ទៅ ។ ព្រះឥន្ទ្រាធិរាជបានទត់ឃើញដូច្នោះក៏បានគំរាមកំហែងនិងសម្លាប់ជីវិតយក្សនេះព្រោះ តែនាងបានសម្លាប់ជីវិតរាជបុត្រដែលជាតួអង្គព្រះពោធិសត្វធ្វើឲ្យយក្សបានភិតភ័យជាខ្លាំងព្រោះតែអំពើបាបរបស់ខ្លួនធ្វើឲ្យខ្លួនជិតបាត់បងជីវិតដោយសារព្រះឥន្ទ្រាធិរាជដាក់ទោស ។ បន្ទាប់មកក៏បានរកថ្នាំទេព្វមកព្យាបាលឲ្យរាជកុមារជាសះស្បើយបានដូចដើមវិញ។

នេះបញ្ជាក់ទស្សនៈកម្មផលត្រង់យក្សមានបំណងបៀតបៀនជីវិតអ្នកដ៏ទៃបន្ទាប់មកអ្នកក៏បានទទួលបាបកម្មតបស្នងភ្លាមៗ។ ដោយព្រះឥន្ទ្រាធិរាជបានគម្រាមកំហែងនិងយកជីវិតនៅពេលបច្ចុប្បន្នជាតិហៅថា ទិដ្ឋធម្មវេទ។

៨. រឿង ទឹករាំផ្ការាំ ជារឿងនិទានល្បីមួយសម្រាប់យកមកនិទានកែអផ្សុកកសាន្តកម្លែងសម្បាយ និងនិយាយឱ្យក្មេងៗស្ដាប់ដែលជារឿងមានប្រជាប្រិយភាពមួយផងដែរ ។ រឿងបានបង្ហាញប្រាប់ពីទស្សនៈកម្មផល នៅពេលព្រះនាងបទុមាបានប្រសូតបុត្របុត្របីអង្គប្រុសពីរនិងបុត្រីជាកូនពៅ ។ ព្រះនាងចន្ទា យាយម៉ប តាហោ នៅពេលព្រះនាងប្រសូតបុត្រមកអ្នកទាំងបីបានកុហកថា កូននាងកើតមកជាឈើ ចំណែកបុត្រពិតប្រាកដយាយម៉បបានយកកំណាត់មានតម្លៃរុំ បន្ទាប់មកយកដាក់នៅក្នុងហិបយកឱ្យតាហោយទៅបណ្ដែតទឹកចោល ។ ព្រះបាទព្រហ្មទត្តយកព្រះនាងបុទមាទៅកប់ត្រឹមករ ។ ក្រោយមកព្រះបាទព្រហ្មទត្តបានដឹងការពិតពីរឿងចោទប្រកាន់ព្រះនាងបុទមាថាមានសាហាយ កូនកើតមកជាឈើ។ នៅពេលក្រោយមក ដោយសារបុត្រទាំងបីរបស់ព្រះអង្គប្រាប់ហើយពួកគេបានជួបជុំក្រុមគ្រួសារលើងវិញ។ ព្រះបាទព្រហ្មទត្តបានដាក់ទោសអ្នកដែលប្រព្រឹត្តិខុសយកទៅដាក់ទោសមានយាយម៉ប តាហោនិង ព្រះនាងចន្ទា យកទៅប្រហារជីវិតទាំងងស់។

ដូចនេះហើយទស្សនៈកម្មផលអ្នកដែលប្រព្រឹត្តិនូវអំពើបាបកម្មទាំងប៉ន្មាននិងត្រូវទទួលដោយខ្លួនឯង គ្មានអ្នកណាអាចជួយបានឡើយ ដូចយាយម៉ប តាហោ ព្រះនាងចន្ទាបានធ្វើបាបព្រះនាងបទុមាចុងក្រោយត្រូវទទួលទោសប្រហារជីវិតនៅពេលបច្ចុប្បន្នជាតិហៅថា ទិដ្ឋធម្មវេទ។

៩. រឿង ចំប៉ាថោង នៅពេលព្រះនាងចំប៉ាសុវណ្ណ បានយកពង់ក្រពើកមចិញ្ចឹម នាងសុវណ្ណាជាសត្វឆ្មាបាននិយាយប្រាប់ថា កុំឱ្យយកពងក្រពើមកចិញ្ចឹមនិងនាំទុក្ខមកថ្ងៃក្រោយឱ្យព្រះនាងយកទៅចោល តែព្រះនាងមិនជឿឡើយ។ ព្រះនាងជាអ្នកធ្វើបុណ្យទានរក្សាសិលព្រះនាងបានឱ្យគេកសាងល្អាងដាក់ក្រពើធ្វើអំពីមាសជេជ្រ និងក្បូង ។ ក្រពើនោះធំលឿនខុសប្លែកពីក្រពើធម្មតា ហើយមានរឹទ្ធិអំណាចខ្លាំងក្លា ក្រពើបានគិតរកឧបាយកលថា ព្រះនាងចំប៉ាសុវណ្ណធ្វើបាបវា ៗបាននិយាយប្រាប់យាយមើលថែក្រពើថា វាចង់ស៊ីសាច់ព្រះនាងចំប៉ាសុវណ្ណ ។ ក្រោយយាយបានដឹងនិយាយប្រាប់ព្រះនាង បន្ទាប់មកយាយបាននិយាយប្រាប់ព្រះរាជា ព្រះនាម សនុរាជា និងមហេសីនាម កែវសុទ្ធិ ។ ព្រះអង្គបានបញ្ជាឱ្យសម្លាប់ក្រពើតែសេនាមិនធ្វើតាមព្រះអង្គ បានយកទៅលែងនៅក្នុងស្ទឹងមួយតាមបញ្ជាព្រះនាងចំប៉ាសុវណ្ណ ។ លុះក្រោយមកទៀតក្រពើបានស៊ីអ្នកចុះទៅនេសាទក្នុងស្ទឹងនោះ ហើយត្របាក់ខាំទាំងសំពៅទៀយផង។ ក្រពើប្រាប់សេនាថា យកនាងចំប៉ាឱ្យវាស៊ី បើពុំនោះទេវានិង ស៊ីអ្នកនគរនេះទាំងអស់ ។ គ្មានវិធីដោះស្រាយ ព្រះនាងចំប៉ាក៏យល់ព្រមឱ្យក្រពើស៊ីឆ្នាសុំទៅជាមួយដែរ ។ ពេលក្រពើឃើញព្រះនាងឱ្យព្រះនាងចុះមកក្នុងទឹកឱ្យវាស៊ី ព្រះនាងថាដើរទៅដល់មុខសិនដើរៗទៅផុតចុងនៃស្ទឹង ព្រះនាងបួងសួងអធិដ្ឋាន ។

សូមឱ្យវត្ថុស័ក្តិសិទ្ធិ ទេវតានិងព្រះឥន្ទ្រាជួយ ពេលនោះក្ដៅដល់ព្រះឥន្ទ្រា ព្រះឥន្ទ្រាបានជួយព្រះនាងនិមិត្តជាផ្កាឈូកដ៏ធំមួយ ព្រះនាងនិងឆ្មាគង់នៅលើផ្កាឈូកនោះក្រពើក៏លោតត្របាក់ព្រះនាង ដោយរិទ្ធបារមីព្រះឥន្ទ្រាមានឈើមកខ្ទាស់មាត់ក្រពើ ក្រពើបានប្រកាច់លើច្រាងដាច់ខ្យល់ស្លាប់មួយរំពិច។

កម្មពៀរដែលសត្វក្រពើជាសត្វរមើលគុណអ្នកដែលបានធ្វើគុណមកលើខ្លួន វាសម្លាប់មនុស្សនិងចង់សម្លាប់ព្រះនាងចំប៉ាដែលបានរក្សាចិញ្ចឹមវាទៀត ដោយបាបកម្មនេះវាបានស្លាប់ភ្លាមៗ នៅបច្ចុប្បន្នជាតិ ហៅថា ទិដ្ឋធម្មវេទ។

សរុបមកតាមរយៈស្នាដៃអក្សរសិល្ប៍លើកឡើងខាងលើនេះសបញ្ជាក់ឱ្យឃើញថា ការគោរពប្រតិ្តបត្តសាសនាមានឥទ្ធិពលទស្សនៈកម្មផលខ្លាំងមកលើសង្គមខ្មែរ វាបានដក់ជាប់ក្នុងផ្នត់គំនិតរបស់ខ្មែរ តាមរយៈអក្សរសល្ប៍សាស្ត្រាល្បែង ។ ជាតាំងតឹងនៃអក្សរសិល្ប៍ពុទ្ធនិយមក្រោយសម័យអង្គរ បានចូលរួមអប់រំដល់មនុស្សឱ្យចេះខ្លាចអំពើបានបើប្រព្រឹត្តអំពើបាបនិង ធ្លាក់ទៅក្នុងនរកឬ ប្រេតជាដើម។ ឥទ្ធិពលអក្សរសិល្បពុទ្ធនិយមជារនាងការពារមនុស្សឱ្យប្រព្រឹត្តតែអំពើល្អសុចរិចត្រឹមត្រូវ ជាមនុស្សល្អរស់នៅក្នុងសង្គមទៀតផង។

## ក.សង្ខេបរឿង មហាជន

ក្នុងកាលកន្លងទៅហើយ ព្រះរាជាព្រះនាមមហាជនកសោយរាជ្យក្នុងនគរមិថិលាដែនវិទេហរាស្ត្រ ទ្រង់មានព្រះរាជ បុត្រាពីរព្រះអង្គព្រះនាម អរិដ្ឋជនក ជាឧបរាជ និង បោលជនកមានឋានៈជាសេនាបតី។ ចំណេរកាលមកខាងក្រោយទៀតព្រះបាទ ជនក ទ្រង់សោយទីវង្គតទៅ ព្រះអរិដ្ឋជនកក៏បានឡើងសោយរាជ្យហើយព្រះរាជទានឋានៈជាឧបរាជដល់បោលជនក។ ក្រោយមក ដោយមានការញុះញង់ពីអាមាត្យម្នាក់ ទ្រង់បានចាប់ព្រះបោល ជនកដាក់ច្រវាក់ឃុំទុក ព្រះបោលជនកបានដោះច្រវាក់ ហើយ ចេញទៅនៅឯស្រុកបច្ចន្តគ្រាម ហើយប្រជុំជាកងទ័ពឡោមព័ទ្ធ ចាប់ព្រះបាទអរិដ្ឋជនកធ្វើគុត ហើយបានឡើងសោយរាជ្យតមក ។

គ្រាចម្បាំង ព្រះទេវីរបស់ព្រះបាទ អរិដ្ឋជនក ទ្រង់គភ៌គ្រប់ខែជ្រាបថាព្រះស្វាមីសុគតក៏យកមាសប្រាក់ដាក់ក្នុងបាតកញ្ជើរ ហើយក្លែងព្រះអង្គជាស្រីកម្សត់រត់ទៅតាមទ្វារខាងជើង បានជួប នឹងព្រះឥន្ទដែលនិម្មិតជាព្រាហ្មណ៍ចាស់បររទេះបញ្ជូនាំទៅដល់ នគរកាលចម្បាកទៅនៅអាស្រ័យជាមួយអាចារ្យទិសាបាមោក្ខនាម ឧទិច្ចព្រាហ្មណ៍ ។ មិនយូរប៉ុន្មានព្រះនាងក៏ប្រសូតព្រះរាជបុត្រ ព្រះនាម មហាជនក (ឈ្មោះដូចព្រះអយ្យកោ) ។

ព្រះមហាជនកបរមពោធិសត្វចម្រើនវ័យធំឡើងជាមនុស្ស ថ្មើងចាងក្អេងក្អាង ឥតខ្លាចក្មេងណាដោយសារកើតក្នុងត្រកូល ខត្តិយ ។ ក្មេងឯទៀតស្អប់ គេជេរថា “កូនឥតឪពុក” ក៏រំអុកជាទុក្ខ ទទូចសួរមាតាលុះត្រាណាបានជ្រាបនូវប្រវត្តិដើមរបស់ខ្លួន ហើយ ព្រះអង្គខំផ្ចង់ស្មារតីដើម្បីគោរពប្រតិបត្តិមាតា ព្រមទាំងលោកគ្រូ អាចារ្យខំសិក្សារហូតចេះចប់ត្រៃវេទក្នុងព្រះជន្ម១៦វស្សា ទើបក្រាបបង្គំទូលព្រះមាតាបម្រុងទៅយករាជសម្បត្តិឯនគរមិថិលា មហាជនក សុំវត្ថុមានខ្លឹមសារគឺៈ កែវមណី១ កែវមុក្តា១ កែវវជីរ១ ព្រះអង្គបានលាព្រះមាតានិងគ្រូអាចារ្យចុះសំពៅទៅជាមួយពាណិជ្ជ ចំនួន៧០០នាក់ ធ្វើជំនួញបានប្រាក់យកមកថ្វាយមាតា និងជូនគ្រូ រួចថ្វាយបង្គំលាព្រះមាតា និងគ្រូអាចារ្យត្រឡប់ទៅប្រទេសសុវណ្ណ ភូមិវិញតាមផ្លូវសមុទ្រ ។ ព្រះអង្គធ្វើដំណើរបាន៧ថ្ងៃក៏បានជួបនឹង ព្យុះលិចសំពៅក្នុងមហាសមុទ្រ ។ មហាជនទាំងឡាយភិតភ័យយ៉ាង ខ្លាំង យំស្រែកកងរំពង ហើយក៏ក្លាយជាចំណីសត្វទឹកទាំងអស់ ។ ចំណែកខាងព្រះពោធិសត្វមិនដូចគេទេ ព្រះអង្គឈរលើចុងក្ដារ ឆ្ពោះព្រះភក្ត្រទៅនគរមិថិលា រួចលោតផ្លោតរំលងពួកត្រី និងសត្វ ទឹកសាហាវៗ ខំហែលឆ្លងសមុទ្រអស់រយៈពេល៧ថ្ងៃ ដោយអធិដ្ឋាន សីលឧបោសថ ។ គ្រានោះនាងទេពធីតារក្សាសមុទ្រឈ្មោះ មណី មេខលា បានជួយយកអាសាព្រះអង្គទៅកាន់នគរមិថិលា។

ថ្លែងពីព្រះបាទ បោលជនក ឥតព្រះរាជបុត្រាសោយរាជ្យ ត្រឹមតែព្រះរាជបុត្រីមួយព្រះអង្គព្រះនាម សីវលីទេវី ។ ព្រះបាទ បោលជនកបានផ្ដាំផ្ញើនិងនាម៉ឺនសព្វមុខមន្ត្រីឲ្យស្វែងរកអ្នកមាន បុណ្យបារមីអាចស្វែងរកកំណប់១៦យ៉ាងរបស់ព្រះអង្គឃើញ ត្រូវ ជ្រើសតាំងអភិសេកឲ្យឡើងគ្រងរាជ្យសម្បត្តិជំនួសព្រះអង្គ និង រៀបអភិសេកជាមួយព្រះនាងសីវលី។ កំណប់ទាំង១៦នោះគឺ

១.ត្រង់ទីដែលព្រះអាទិត្យរះ

២. ត្រង់ទីដែលព្រះអាទិត្យលិច

៣. ខាងក្នុង

៤. ខាងក

៥. មិនមែនខាងក្នុង មិនមែនខាងក

៦. ត្រង់ទីសម្រាប់ចុះ

៧. ត្រង់សាលព្រឹក្សទាំងបួន

៨. ត្រង់ទីមួយយោជន៍ជុំវិញ

៩. នៅចុងភ្លុកដំរី

១០. នៅចុងកន្ទុយដំរី

១១. ក្នុងទឹក

១២. លើចុងឈើ

១៣. នរណាគាស់បានសហស្សថាមធ្ន ១៤. នរណាអាចលើករួច

១៥. បល្ល័ង្កបួនជ្រុង នរណាអាចដឹងបាន តើក្បាលដំណេកនៅខាងណា

១៦. នរណាអាចធ្វើឲ្យព្រះនាងសិវលីរាជទេវីត្រេកអរបានជ្រើសឱ្យសោយរាជនិង រៀបអភិសេកជាមួយព្រះនាង។

អាមាត្យទាំងឡាយបានចាត់ការជ្រើសរើសព្រះមហាក្សត្រតាមព្រះរាជបណ្តាំនេះពុំបាន ទើបព្រមព្រៀងតាមបុរោហិតចាត់ការផ្សងបុស្សរថដែលទឹមដោយសេះពីរគូ មានកម្រាល និង ផ្កា រចនាដ៏វិចិត្រដាក់គ្រឿងរាជកកុធភ័ណ្ឌគ្រប់គ្រាន់ទាំង៥ប្រការមានពួកចតុរង្គសេនា ចោមរោមត្រៀបត្រា បួងសួងសុំឲ្យបានអ្នកមាន វាសនាគួរទទួលរាជ្យសម្បត្តិ បុស្សរថដែលគេ ផ្សងហើយលងទៅក៏សំដៅទៅត្រង់ទីមង្គលសិលាប័ត្រដែលព្រះពោធិសត្វផ្ទំ ។ បុរោហិតបាន ឃើញលក្ខណៈព្រះអង្គហើយបាននិយាយប្រាប់គ្នាថា បុរសនេះមានសមត្ថភាពអាចសោយរាជ្យ ក្នុងមហាទ្វីបទាំង បួនបាន ទើបព្រមព្រៀងគ្នាអារាធនាព្រះអង្គ សូមទ្រង់ទទួលរាជ្យ សម្បត្តិ បានដង្ហែទៅជួបនឹងព្រះនាងសិវលីទេវីកញ្ញា បន្ទាប់មក ព្រះមហាជនកទ្រង់បានលើកធ្នូ ដោះប្រស្នា និងយកកំណប់ទ្រព្យ ទាំង១៦បានមក ព្រះអង្គត្រូវបានឡើងគ្រងរាជ្យសម្បត្តិ និង រៀប អភិសេកជាមួយនឹងព្រះនាងសិវលីទេវីនៅនគរមិថិលា រស់នៅយ៉ាងសុខក្សេមក្សាន្ត ។ ថ្ងៃ មួយពេលទ្រង់យាងទៅកាន់ឧទ្យានបានឃើញស្វាយ មួយដើមរេចស្លឹកបាក់មែកព្រោះតែមាន ផ្លែស្វាយមួយដើមទៀត មានស្លឹកលាស់ខ្ចី សាខាគឈឹងត្រឈៃព្រោះឥតផ្លែ ទើបទ្រង់ព្រះ ចិន្តាថា ស្វាយដែលរេចស្លឹកបាក់មែកព្រោះតែផ្លែដូចអាត្មាអញជា ស្តេចសោយរាជ្យធ្វើប្រយោជន៍ឲ្យ កើតឡើងសម្រាប់តែអ្នកត្រូវការ ត្រង់ខ្លួនអាត្មាចេះតែរេចទៅៗ ។ ក្រោយពីពិចារណាបាន សព្វគ្រប់ព្រះបហាជនកក៏បានសម្រេចព្រះទ័យក្នុងភេទជាបព្វជ្ជា។ ព្រះអង្គ ប្រាថ្នានឹងនិមន្ត ចេញពីព្រះបរមរាជវាំងឆ្ពោះទៅកាន់ពហមពាន្ត តែព្រះអង្គត្រូវនាងសិវលីទេវីប្រើឧបាយកល រារាំងព្រះរាជដំណើរ ដោយដុតស្លឹកឈើក្រៀមៗឲ្យនេះផ្សែងហុយទ្រលោមក្នុងបំណង បញ្ឆោត ព្រះអង្គថា នគរមិថិលាឆ្លើងឆេះហើយ ព្រះនាងសិវលីទេវី បានពិសោធន៍ច្រើនលើកច្រើនសារ តែព្រះអង្គមិនភ្ញាក់ផ្អើលអ្វីទាំងអស់ ។ ថ្ងៃមួយ នារទតាបស បានមានពុទ្ធដីកាទូលព្រះ ពោធិសត្វថា សេចក្តីអន្តរាយតាំងឡើងពីប្រភពច្រើនប្រការគឺពីការដេកលក់ ពីសេចក្តីខ្ជិល ពីការបីតពត់ ពីសេចក្តីអផ្សុក ពីការពុលអាហារ។ តាបសមានពុទ្ធដីកាអួតពីសេចក្តីត្រេកអរ ក្នុងបព្វជ្ជា និងព្រហ្មវិហារធម៌ ចូរកើតដល់ព្រះអង្គ ការខ្វះខាតសីល និងឈាន សូមព្រះអង្គ បំពេញ សូមព្រះអង្គរំលាយចោលនូវសេចក្តីមើលងាយ និងសេចក្តី ក្រអើតក្រអោង ។ សូមព្រះ អង្គគោរពនូវកុសលកម្មបថ និងវិជ្ជាគឺ អភិញ្ញា៥ សមាបត្តិ៨ និងសមណធម៌។

ចំណេរកាលក្រោយមកព្រះនាងសិវលីទេវី និងរាជបរិពារ បានចាត់ឲ្យជាងសាងសង់ព្រះ ចេតីយ៍អនុស្សាវរីយ៍ទុកសម្រាប់ធ្វើសក្ការបូជា ។ ឯព្រះពោធិសត្វក៏និមន្តទៅគង់ក្នុងព្រៃហេម ពាន្តដ៏រាប ដល់ជីវិតបរិយោសានទៅឧប្បត្តិកក្នុងព្រហ្មលោកនាយហោង។ ព្រះនាងសិវលិបាន ប្រារព្ធចាត់ការរៀបចំពិធីអភិសេក ទីឃាវុកុមារ ឱ្យសោរាជ្យអំពីព្រះស្វាមីនាង ទើបទ្រង់ផ្នួសជា ឥសី គង់នៅក្នុងព្រៃអម្ពវ័ន រាជឧទ្យានដ៏រាបដល់ជីវិតតាសាន បានទៅកើតក្នុងព្រហ្មលោក ដូចព្រះបរមពោធិសត្វដែរ។

## ក.អត្ថន័យខ្លឹមសារ

អត្ថន័យអត្ថ .ប្រយោជន៍.អត្ថន័យ .ការណែនាំអត្ថាធិប្បាយសេចក្តីពន្យល់.អត្ថន័យជា គំនិតសំខាន់ៗរបស់អ្នកនិពន្ធដែលលាតត្រដាងនៅក្នុងដំណើររឿង ហើយគេអាចហៅវាថាជា ជម្រៅនៃរឿង។

ក្នុងផ្នែកអត្ថន័យមាន ប្រធានរឿង មូលបញ្ហារឿងនិងឧត្តមគតិរឿង។

## ខ. ប្រធានរឿងឬមូលន័យ

ប្រធានរឿងឬមូលន័យ គឺជាគំនិតសំខាន់ៗរបស់រឿងប្រតិឬជាបញ្ហារួមរបស់រឿង ។ តែ អ្នកនិពន្ធចង់បង្ហាញដល់អ្នកអានប្រធានរឿងជាបញ្ហារួបផ្តុំបំផុតដែលអ្នកនិពន្ធលើកយក មកសរសេរឬជ្រើសរើសជាប្រធានបទហើយដែលមានមូលបញ្ហារឿងស្ថិតតនៅក្នុងនោះ។

ប្រធានរឿងបង្ហាញនៅចំហររបស់អ្នកនិពន្ធវាជាមូលដ្ឋានដើមរបស់អ្នកនិពន្ធក្នុងការចាប់ផ្ដើមសរសេរឡើង ។ មុនពេលចាប់ផ្ដើមសរសេរឡើង អ្នកនិពន្ធត្រូវកំណត់ថា តើគាត់ត្រូវសរសេរអំពីអ្វី ។ អំពីជីវិតសង្គម សង្គ្រាម ស្នេហា រឿងជំនឿ ទំនៀមទម្លាប់ប្រពៃណីចម្លើយរបស់សំណួរនេះហើយជាប្រធានរឿង។រឿងខ្លះប្រធានរឿងស្ថិតនៅលើចំណងជើងរបស់រឿង។

នៅក្នុងរឿងមហាជនកជាតកអ្នកនិពន្ធក៏បានបង្ហាញពីការតស៊ូ អំណត់ព្យាយាម។

## ឃ.មូលបញ្ហារឿង

មូលបញ្ហារឿងគឺជាភាពចំណែកនៃប្រធានរឿងជាទិដ្ឋភាពផ្សេងៗរបស់យើងវាជាការចូលជ្រៅទៅក្នុងប្រធានរឿង។

## ទី១ បញ្ហាទំនាស់ក្នុងរាជវង្ស

រឿងមហាជនក នៅពេលដែលព្រះបិតាបានតែងតាំងព្រះរាជបុត្រ ច្បងអរិដ្ឋជនក ឱ្យធ្វើជាឧបរាជ្ជ ចំណែកបុត្រប្អូន បោជនក ឱ្យធ្វើជាសេនាបតី ។ ពេលនោះព្រះរាជាចូលទិវង្គ ព្រះរាជបុត្រច្បង អរិជនកឡើងសោយរាជ ព្រះរាជបុត្រប្អូនជាឧបរាជ្ជ ។ ពេលព្រះអង្គសោយរាជមិនទាន់បានសេចក្ដីសុខប៉ុន្មានផង បានជឿតាមពាក្យញួសញង់របស់អាមាត្របានចាប់ព្រះបាទ បោជនក យកទៅដាក់ច្រវ៉ាក់ឃុំទុកនៅខ្ទមឆ្ងាយពីវាំង ព្រះអង្គបានដោះច្រវ៉ាក់បានរតទៅបចិន្ត្រាមនៅតល់ដែន ពេលនោះមានមនុស្សមកចុះចូលមានមនុស្សជាច្រើន ។ ពេលនោះជាឱកាសល្អសម្រាប់ព្រះបាទ បោជនក ជាមួយបង ពួកគេបានធ្វើសង្គ្រាមជាមួយបងប្អូនឯងបង្កើត ប្អូនបានសម្លាប់បងទៅ ។ នេះបានបង្ហាញពីទំនាស់នៅក្នុងរាជវង្ស មកពីជឿតាមពាក្យអ្នកដទៃមុននិងធ្វើអ្វីមួយយើងត្រូវចេះគិតគូឱ្យបានវែងឆ្ងាយជាមុនសិនបើពុំនោះទេវាធ្វើឱ្យអន្តរាយជាមិនខាន ។ ចំណែកមហេសីទេវី ពេលដឹងថាព្រះស្វាមីស្លាប់បាត់ហើយព្រះនាងទេវីបានតែងខ្លួនធ្វើជាស្រីកំសត់ទូលកញ្ជើលួចរត់ទៅទាំងពោះធំជិតគ្រប់ខែផងបានជួបព្រះឥន្ទតំណែងខ្លួនជាតាចាស់អ្នកបរទេស ហើយព្រះឥន្ទនាំទៅរស់នៅជាមួយអាចារ្យទិសាបាមោក្ខ រហូតប្រសូតបុត្រ ។ ព្រះនាងបានដាក់ឈ្មោះបុត្រថា មហាជនកកុមារ ព្រះរាជបុត្របានទៅលេងជាមួយក្មេងដទៃ ក្មេងទាំងនោះបានជេរព្រះអង្គថា កូនអត់ឪព្រះអង្គឆ្ងល់សួរព្រះមាតាពីប្រវត្តិរបស់ខ្លួន ។ ក្រោយមកព្រះកុមារខំសិក្សារៀនសូត្រសិល្បសាស្ត្រចប់សព្វគ្រប់។

សរុបមកការមិនចេះយោគយល់គ្នាធ្វើឱ្យមានទំនាស់ ការមិនចេះរិះគិតពិចារណាបានត្រឹមត្រូវនាំឱ្យបាត់បង់ប្រយោជន៍ បានបង្ហាញនៅក្នុងរឿងខាងលើស្រាប់ យើងគម្បីចេះយោគយល់គ្នាចេះស្រឡាញ់បងប្អូនក្រុមគ្រួសារសាច់ញាត្តិរបស់ខ្លួននិង ចេះស្រឡាញ់អ្នកនៅជុំវិញខ្លួនផងដែរ។

## ទី២ បញ្ហាព្រះបាទមហាជនកកុមារចង់ទៅនគររបស់ខ្លួន

ព្រះមហា ជនកកុមារ បានខិតខំបម្រើអាចារ្យទេសាបាបោកនិង ព្រះមាតា ព្រះអង្គបានចង់ចេញទៅធ្វើជំនួញ ហើយសួរមាតាជាមានទ្រព្យសម្បត្តិអ្វីខ្លះដែលមានតម្លៃ មាតាប្រាប់ថា មានរបស់បីមុខ កែវមណីមួយ កែវមុខក្ដាមួយ និងកែវវីរៈជីវមួយ ។ ព្រះរាជកុមារបានយកតែពាក់កណ្ដាលទេ ដើម្បីទៅជំនួញ បានចំនេញយកប្រាក់មកឱ្យព្រះមាតា និងអាចារ្យទេសាបាបោក ។ ហើយព្រះអ្គទៅធ្វើជំនួញទៀតែសំពៅនោះបានធ្វើដំណើរប្រាំពីរថ្ងៃក៏មានខ្យល់ព្យុះបោកបកផ្ទុះធ្លាយសំពៅទៅ ។ ចំណែកមនុស្សនៅក្នុងសំពៅនាំគ្នាយំស្រែក បួងសួងវតាជួយ និយាយពីព្រះពោធិសត្វវិញបានលាយស្ករជាមួយទឹកដោះគោបរិភោគទឹកដោះគោឱ្យមានកម្លាំង រួចលាបប្រេងលើខ្លួនដើម្បកុំឱ្យសត្វមកក្បែរនៅពេលសំពៅជិតលិចព្រះអង្គបានឡើងទៅចុងក្ដោងសំពៅលោតឱ្យផុតដើម្បីកុំឱ្យត្រីស៊ីបាន អ្នកនៅក្នុងសំពៅទាំងអស់ត្រូវសត្វនៅក្នុងសមុទ្រស៊ីអស់ទៅ ។ ចំណែកព្រះរាជកុមារបានហែលទឹករួចដល់ថ្ងៃពេញបារមីព្រះអង្គបានខ្ពុលព្រះឱដ្ឋក៏តាំងឧបោសពសិល ។ ក្រោយមកព្រះនាងមណីមេខលា បានឃើញព្រះពោធិសត្វហើយបាននិយាយថា អ្នកណានេះបានហែលទឹកដោយមើលអត់ឃើញត្រើយសោះចេះតែហែលដែរ ឃើញប្រយោជន៍ដូចម្ដេចបានជាព្យាយាមងេលដល់ម្លឹង ។ ព្រហពោធិសត្វឆ្លើយថាម្នាលទេវតាវតរបស់សត្វត្រូវតែធ្វើការដោយអនិសង្សនៃសេចក្ដីព្យាយាមត្រូវតែផុតទុក្ខទោះមើលមិនឃើញត្រើយក៏ដោយក៏ខំព្យាយាមហែលដែរ។ ព្រះនាងមណីមេខលាបានស្រង់

ព្រះពោធិសត្វយកទៅដាក់នៅនគរមិថិលាព្រះអង្គបានសោយរាជ្យនៅទីនោះទៅ។ ប្រការនេះសបញ្ជាក់ថា សេចក្តីព្យាយាមយ៉ាងខ្លាំងក្លារបស់ព្រះពោធិសត្វបានធ្វើឱ្យមនុស្សយកតម្រាបតាម ក្នុងជីវិតរស់នៅប្រចាំថ្ងៃ ។ ជីវិតមនុស្សតែងបានជួបឧសគ្គគ្រប់បែបយ៉ាង ឱ្យចេះដោះស្រាយព្យាយាម គ្រប់មធ្យាបាយ លក្ខណៈនៃការតស៊ូព្យាយាមអ្វីក៏ដោយអាចទទួលបានលទ្ធផលល្អដែរ ក៏ដោយសារតែការប្រឹងប្រែងតែមួយគត។ មួយវិញទៀតមិនមែននៅពេលជួបរឿងអ្វីមួយមិនហានប្រឈមមុខនោះទេ។

សរុបមកសេចក្តីព្យាយាមនាំមនុស្សឱ្យសម្រេចនូវអ្វីដែលខ្លួនប្រថ្នាចង់បាន ដោយមានភាពស្មោះត្រង់ កតញ្ញូចំពោះអ្នកមានគុណ មិនបំភ្លេចគុណអ្នកដទៃដែលបានជួយខ្លួន ចេះជួយអ្នកដទៃដែលបានជួបការលំបាក អំពោះទាំងនេះមិនសាបសូននោះឡើយ និងជួយបុគ្គលគ្រប់រូបបានសេចក្តីសុខគ្រប់យ៉ាង។

## ទី៣ បញ្ហាភាយាងចេញទៅសាងផ្នួសរបស់ព្រះមហាជនក

បន្ទាប់ពីព្រះពោធិសត្វបាននៅក្នុងព្រះរាជវាំងមានការអផ្សុកបានចេញទៅក្រសាលនៅក្នុងសួនឧស្សាន បានទតឃើញដើមស្វាយពីរដើម ដើមមួយមានស្លឹកច្រើនលាស់ត្រឈឹងត្រឈៃប៉ុន្តែអត់មានផ្លែ ចំណែក ។ ឯដើមស្វាមួយទៀតមាន បាក់មែករបេចស្លឹកមែក ។ បន្ទាប់ពីពិចារណាទៅលើដើមស្វាយទាំងពីរដើមនេះមក ព្រះមហាជនកបានចាក់ចេញពីរាជបល្ល័ង្កហើយទ្រង់ព្រះផ្នួសរួចផុតខ្លួនពីវដ្តសង្សា ។ ពេលនោះព្រះនាងសីវលីខំឃត់និងប្រជារាស្ត្រឃាត់យ៉ាងណាក៏ព្រះអង្គពុំស្តាប់ដែរ ។ ព្រះព្រោះអង្គគិតថា រំដោះខ្លួនចេញផុត ពីលោកិយសច្ចៈ ដើម្បីស្វែងរកផ្លូវបរមសុខ ការចាកផុតទុក្ខ ។ នេះបានសបញ្ជាក់ឱ្យឃើថា ព្រះអង្គបានលះបង់អ្វីៗគ្រប់យ៉ាងសាងព្រផ្នួសសុខចិត្ត បេះបង់ចោលរាជសម្បត្តិ មហេសី បុត្រនិងប្រជារាស្ត្រ ការលោះបងបែបនេះពុំមានបុគ្គលណាអាចធ្វើបាននោះទេ ។ ដោយហេតុថា បុគ្គលគ្រប់រូបតែងតែឈ្លួសវង្វេងនិងទ្រព្យសម្បត្តិ បុណ្យសក្កិនិង ស្រី ស្រាជាដើម អ្វីៗ គ្រប់យ៉ាងគេមិនងាយបោះបង់ចោលនោះទេ មានតែព្រះមហាជនកទេដែលបានលះបង់បានដោយឥតមានស្តាយស្រណោះនិងមានការតស៊ូព្យាយាមខិតខំបំពេញការសាងព្រះផ្នួសនេះឯង។

សរុបមកការការចេះរក្សាសិលធ្វើឱ្យមនុស្សយើងបានរួចចាកទុក្ខ ធ្វើឱ្យមនុស្សមានសេចក្តីព្យាយាម មិនមានចិត្តលោបលន់ ចេះអធ្យាស្រ័យគ្នាទៅវិញទៅមកនិងដើម្បីផលប្រយោជន៍រួម។

## ឃ. ឧត្តមគតិតម្លៃអប់រំ

ឧត្តមគតិរឿងគឺជាឧត្តមគតិរបស់អ្នកនិពន្ធ។ឧត្តមគតិរឿងគឺយកកត្តាប្រធានវិស័យដែលបញ្ហាដែលបញ្ជាក់ពីគោលជំហរសតិអារម្មណ៍របស់អ្នកនិពន្ធដែលស្តែងឡើងតាមរយៈសកម្មភាពរបស់តួអង្គ។

នៅក្នុងរឿងមហាជនកជាតកនេះក៏និយាយពីការខិតខំប្រឹងប្រែងតស៊ូព្យាយាមរបស់តួអង្គ ព្រះពោធិសត្វពិសេសគឺបានបង្កប់នូវការអប់រំជាច្រើនដល់បុគ្គលគ្រប់រូប ក្នុងការធ្វើអ្វីមួយដើម្បីកុំឱ្យឆាប់ចុះចាញ់ភ្លាមៗពេកព្រោះការចុះចាញ់នេះ វារមែងតែទទួលបាននូវផលអវិជ្ជមានជាមិនខាន។

- អប់រំឱ្យយើងចេះមាន ជំនឿជាក់លើសមត្ថភាពរបស់ខ្លួន មានភាពអង់អាច កំណត់មិនតក់ស្លុតភិតភ័យមានភក្តីភាពចំពោះការងារដែលខ្លួន ធ្វើមិនរាថយ ឬរុញរានៅពេលដែលជួបបញ្ហានៅចំពោះមុខនោះឡើយ
- អប់រំឱ្យមនុស្សកុំឱ្យមានចិត្តលោបលន់
- អប់រំឱ្យមនុស្សមានប្រាជ្ញា
- អប់រំមនុស្សឱ្យចេះខិតខំរកស៊ីជួញប្រែដើម្បីចិញ្ចឹមជីវិតរស់នៅប្រចាំថ្ងៃ
- អប់រំធ្វើឱ្យមនុស្សខិតខំប្រឹងប្រែងរៀនសូត្រ
- អប់រំធ្វើឱ្យមនុស្សជឿលើអំពើល្អ
- អប់រំមនុស្សជឿលើបុណ្យបាប។

## ខ.វិភាគតម្លៃអប់រំនៃរឿង

តាមរយៈសាច់រឿងទាំងមូលអ្នកនិពន្ធបានបង្ហាញពីគោលគំនិត កំនិតអប់រំ សំខាន់ៗ ដូចតទៅៈ

នៅពេលដែលព្រះបាទ អរិដ្ឋជនក បានឡើយសោយរាជហើយបានជឿតាមពាក្យអាមាត្រចាប់ព្រះបោជនក ដាក់ច្រវាក់នៅក្រៅរាជវាំង បានរួចខ្លួនបានកេណ្ឌទ័ពទៅច្បាំងជាមួយអរិជនកជាបង ហើយសម្លាប់បងបាត់ទៅ។ នេះបង្ហាញតម្លៃអប់រំឱ្យបុគ្គលគ្រប់រូបមុនជឿទៅលើរឿងអ្វីមួយឱ្យចេះគិតឱ្យបានវែងឆ្ងាយ ។ កុំមានចិត្តឆាប់ជឿជាក់ទៅលើពាក្យសម្តីអ្នកដ៏ទៃហើយបានធ្វើបាបបងប្អូនរបស់ខ្លួន ត្រូវចេះស្រឡាញ់គ្នាទៅវិញទៅមក អធ្យាស្រ័យគ្នា កុំដូចព្រះបាទបោជនក។ មួយវិញទៀតបានអប់រំឱ្យមានសេចក្តីព្យាយាម នៅពេលមានបញ្ហាត្រូវព្យាយាមតស៊ូជំនះរាល់ឧបសគ្គតហូតបានសម្រេចបំណងដូចព្រះមហាជនក ។ បន្ទាប់មកបានអប់រំឱ្យមានធម៌កតញ្ញូចំពោះ អ្នកមានគុណ និងអ្នកបានជួយខ្លួនដោយតបស្នងសងគុណតាមលទ្ធិភាពដូចព្រះមហាជនកជាគំរូល្អសម្រាប់ឱ្យបុគ្គលគ្រប់រូបយកជាគំរូ។

សរុបជារួមមករឿងនេះបានបង្ហាញពីការចេញសាងផ្នួស ដើម្បីបំពេញារមី ការមិនមានចិត្តចង់បានទ្រព្យសម្បត្តិ បុណ្យស័ក្តិឋានៈ ដើម្បីបំពេញបារមី បានត្រាស់ដឹងនិង ជួយដល់សត្វលោក។

សង្ខេបរឿង សុវណ្ណសាម

ក្នុងកាលកន្លងទៅហើយ មានស្រុកពួកអ្នកនេសាទពីរ មួយ នៅត្រើយខាងអាយនស្ទឹង ឯមួយទៀតនៅខាងត្រើយខាងនាយ ស្ទឹងជិតនគរពារាណសី ។ នាយនេសាទទាំងពីរជាសម្លាញ់នឹងគ្នាហើយសន្យាថានឹងធ្វើជាដន្លងគ្នានៅពេលមានកូនប្រុសសី ។

តមក នាយនេសាទនៅស្រុកត្រើយខាងអាយបានកូនប្រុស ម្នាក់ឈ្មោះ ទុកូល ។ ឯនាយនេសាទ ស្រុកត្រើយខាងនាយបាន កូនស្រីម្នាក់ឈ្មោះថា បារិកា។ ទោះបីជនទាំងពីរកើតក្នុងត្រកូល អ្នកនេសាទក៏ដោយក៏តតធ្វើបាណាតិបាតសោះ ។ ដល់វ័យកំលោក្រមុំ មាតាបិតាបង្ខំឱ្យរៀបការ ហើយក៏ទ្រាំរស់នៅជាមួយគ្នាតែ មិនព្រមឆ្លងសមុទ្រកិលេស (រួមរ័ក) សោះ ។

ចំណេរកាលក្រោយមក ទុកូល និងបារិកា លាមាតាបិតា ទៅបួសជាឥសីរស់នៅក្នុងអាសមនិម្មិតក្បែរស្ទឹងមិគសម្មតា ។ ថ្ងៃ មួយព្រះឥន្ទ្រប្រមើលមើលឃើញនូវសេចក្តីអន្តរាយនតាបសទាំង ពីរថាមុខជាខ្វាក់ព្រះនេត ទើបទ្រង់ទូលប្រាប់ទុកូលនូវសេចក្តី អន្តរាយគ្រប់ប្រការ ហើយអង្វរឱ្យព្រមរួមរ័ក ដើម្បីបានកូនមួយ គ្រាន់បម្រើ តែតាបសពុំព្រមធ្វើសោ ។ ព្រះឥន្ទក៏ឲ្យពរពិសេសថា គ្រាន់តែស្ទាបឧទរនាងបារិកាក៏បានដែរ ។ តាបសព្រមស្ទាបតាម ការអង្វររបស់ព្រះឥន្ទ ។ គ្រានោះព្រះពោធិសត្វច្យុតចាកទេវលោក មកចាប់បដិសន្ធិក្នុងផ្ទៃនាងបារិកា លុះកន្លងបាន១០ខែទៅក៏ ប្រសូតបានបុត្រមួយមានសម្បុរដូចមាស ទើបដាក់ឈ្មោះថា សុវណ្ណសាម ។ ពួកកិន្នរី និងម្រឹគទាំងឡាយចោមរោមជាបរិវារ មើលថែរក្សាសុវណ្ណសាមមិនឱ្យមានសៅហ្មងឡើយ ។

ពេលពោធិសត្វមានព្រះជន្ម១៦វស្សាក៏បានបួសជាឥសី ។ មាតាបិតាបានទៅព្រៃដើម្បីស្វែងរកផលានុផល ។ លុះត្រឡប់មក ដល់ជិតអាស្រម ជួនជាមេឃបង្អុរភ្លៀងដ៏ធំ ឥសីទាំងពីរចូលទៅ ជ្រកក្រោមដើមឈើលើដំបូកមួយមានពស់វែកមួយបានព្រួសពិស ចូលព្រះនេត្រខ្វាក់ទាំងពីរអង្គរកផ្លូវមកអាស្រមពុំឃើញក៏នៅជា ទុក្ខខ្សឹកខ្សួលក្នុងទីនោះ ។ គ្រានោះពោធិសត្វ កាលបើបាត់មាតា បិតាយូរក៏យាត្រាតាមទៅរក ស្រែកបង្អែកពាសពេញព្រៃ ។ តាបស ឮសម្តីកូនក៏ឆ្លើយ ។ កាលបើកូនចូលជិតដល់ហើយក៏ប្រាប់ថាទីនេះ មានមហន្តរាយ ។ ពោធិសត្វក៏ហុចឈើច្រត់វែងឱ្យមាតាបិតាតោងចុះពីដំបូករួចក៏យំសោកសងដោយក្តីអាណិតមាតាបិតា ហើយបែរជាសើចវិញ ដោយគិតថានឹងបានបម្រើមាតាបិតាជាប់លាប់មិនដាច់ ចាប់ពីពេលនោះមក សុវណ្ណសាមទុកមាតាបិតាក្នុង អាស្រម ទៅសន្សំផលានុផលក្នុងព្រៃជាប្រក្រតី ។ ព្រឹកៗ សុវណ្ណសាម បោសសម្អាតលំនៅស្ថាន ហើយកណ្តៀតក្អមទៅកាន់ស្ទឹង មិគសម្មតា ដងទឹកសម្រាប់មាតាបិតាឆាន់ និងប្រគេនចំណីអាហារ ដល់មាតាបិតានាន់ស្កប់ស្កល់ ទើបយកសំណល់មកឆាន់ខ្លួនឯង ។ សម័យនោះ ព្រះបាទបិលយក្ខ ក្សត្រដែនកាសី(ពារាណ-សី) សព្វព្រះទ័យសាច់ម្រឹគ ទ្រង់បានធ្វើដំណើរទៅព្រៃហេមពាន្ត ដល់ស្ទឹងមិគសម្មតា ។ ទ្រង់

ទតឃើញសុវណ្ណសាមមានពួកម្រឹគ ដើរតាម ទើបទ្រង់នឹកឆ្ងល់ថាគាត់នេះជាអ្វីៈ ទើបទ្រង់បាញ់សំដៅ ទៅត្រូវសុវណ្ណសាមត្រង់ចំហៀងខាងស្តាំធ្លាយទៅខាងឆ្វេង ពួក ម្រឹគភ័យផ្អើលបោលទៅកាន់ទីផ្សេងៗ។ ពោធិសត្វខំផ្ចង់ស្មារតី ស្រែកសួរថាៈ លោកណាអើយ! បាញ់ខ្ញុំកំពុងដងទឹកខ សាច់ខ្ញុំនៈ មិនជារបស់គួរស៊ីទ ទាំងស្បែករបស់ខ្ញុំក៏មិនជារបស់ដែលគេត្រូវ ការដែរ។ តើលោកសម្គាល់ខ្ញុំដូចម្តេចបានជាបាញ់ហើយពួន? ព្រះបាទបិលយក្ខទ្រង់សណ្តាប់ហើយទ្រង់ព្រះ បុរសនេះអញ បាញ់ហើយនៅមិនជេរអញ ថ្នមចិត្ត អញ និយាយពាក្យគួរជាទី ស្រឡាញ់ ។ ទ្រង់ចូលទៅហើយមានព្រះរាជឱង្ការថា ខ្ញុំជាព្រះរាជារបស់អ្នកដែនកាសី ឈ្មោះបិលយក្ខ ចុះអ្នកជាអ្វី ជាបុត នរណា? ព្រះពោធិសត្វ ទូលព្រះបង្គំឈ្មោះសុវណ្ណសាម ជាបុត្រ របស់តាបសឥសីដែលរស់នៅក្នុងព្រៃនេះ ។ ព្រះពោធិសត្វបានទូល ប្រាប់នូវដំណើររឿងពិតជាក់ស្តែងរបស់ខ្លួនដល់ព្រះរាជាសណ្តាប់ ។ បិលយក្ខបានយល់ពីទុក្ខវេទនារបស់សុវណ្ណសាមពីការចិញ្ចឹមមាតាបិតាពិការភ្នែកទាំងពីរព្រះអង្គ ។ ខណៈនោះ ទេវធីតាវសុន្ទរី បានពន្យល់បិលយក្ខពីអំពើបាបដែលខ្លួនបានសាង មិនចិញ្ចឹមឥសីពិការភ្នែកទាំងពីរទេនោះ ទ្រង់នឹងចុះនរក មិនបានទៅកាន់សុគតិភពឡើយ ។ បិលយក្ខក្សត្រក៏ព្រមទទួលមើល ជួយថែរក្សា មាតាបិតារបស់សុវណ្ណសាមដូចឪពុកម្តាយបង្កើត។

ព្រះបាទបិលយកសម្រេចព្រះទ័យយាងទៅកាន់អាស្រមតាបសជាមាតាបិតាសុវណ្ណសាម ។ ទុកូលតាបសឮសន្ធឹកជើងក៏សួរថា សូរជើងនរណាហ្នឹង ពិតជាមិនមនសូរជើងសាមទ ដ្បិតសាម តែងដើរថ្នមៗ ស្រាលៗ នៃអ្នកឯងជាអ្វីហ្នឹង? ព្រះបាទបិលយក្ខ តបថា ជាព្រះរាជារបស់ពួកអ្នកដែនកាសី ឈ្មោះបិលយក្ខ ទុកូលតាបសស្តាប់ស្គាល់ជាក់ក៏ធ្វើកិរិយារាក់ទាក់ដោយវាចាស្វាគមន៍ចំពោះការយាងរបស់ព្រះរាជាអង្គនេះយ៉ាងកក់ក្តៅ ។ បន្ទាប់ មក ព្រះរាជាក៏បានរៀបរាប់ប្រាប់ពីការសម្លាប់សុវណ្ណសាមដល់ ទុកូលតាបស ធ្វើឲ្យឥសីទាំងពីរក្តុកក្តួលក្នុងចិត្តយ៉ាងខ្លាំង បិលយក្ខក៏បានជូនអ្នកទាំងពីរទៅដល់កន្លែងដែលសុវណ្ណសាមដេកដួល លើដីខ្សាច់ដូចជាព្រះចន្ទធ្លាក់មកលើផែនដី តាបសឥសីស្ទាបឱប បុត្រញ័ររន្ធត់សព្វសង្គកាយ ងនាងបារិកាបានបន្លឺនូវសច្ចវាចាថា ក្នុងកាលមុន សាមនេះជាអ្នកប្រតិបត្តិធម៌ ជាអ្នកប្រព្រឹត្តិព្រហ្មចារ្យ ជាអ្នកពោលពាក្យសត្យ ជាអ្នកបម្រើមាតាបិតា ជាអ្នកកោត ក្រែងនូវត្រកូលរៀមច្បង ជាទីស្រឡាញ់របស់ខ្ញុំជាងជីវិត ដោយពាក្យពិតនោះសូមឱ្យថ្នាំពិសសាបរលាបទៅ ទុកូលតាបសក៏ ប្រកាសនូវពាក្យសច្ចៈដូចគ្នានេះដែរលុះចប់សច្ចកិរិយានជនទាំងឡាយនោះ សុវណ្ណសាមក៏ក្រោកឡើងភ្លាម បាត់ឈាម បាត់ ស្នាមពីរាងកាយ ហើយភ្នែកទាំងគូរបស់មាតាបិតាក៏ភ្លឺឡើងវិញ។ សុវណ្ណសាមមានសចក្តីស្រស់ស្រាយរីករាយរកជនទាំងនោះថា សេចក្តីចម្រើនចូរមានដល់លោកអ្នកទាំងឡាយ ខ្ញុំក្រោកឡើងដោយ សួស្តីហើយ សូមលោកទាំងឡាយកុំខ្សឹកខ្សួលឡើយ ព្រះពោធិសត្វបានសម្តែងនូវការទូន្មានដល់ព្រះបាទបិលយក្ខឱ្យប្រកាន់នូវធម្មចរិយាចំពោះមាតាបិតា ប្រពន្ធ កូន ជនក្រោមឱវាទ ប្រជារាស្ត្រ ហើយថែមទាំងឱ្យបិលយក្ខប្រកាន់នូវសីលប្រាំជាប់ជានិច្ចតរៀងទៅ។ ចំណែកព្រះពោធិសត្វតែងគោរពប្រតិបត្តិមាតាបិតា ចម្រើន មេត្តាភាវនា លុះសម្រេចនូវអភិញ្ញា និងសមាបត្តិជាមួយគ្នានឹង មាតាបិតាស្ថិតដល់អស់ព្រះជន្មាយុសង្ខារ ក៏បានទៅកើតក្នុងព្រហ្ម លោកជាមួយគ្នាទាំង៣ព្រះអង្គហោង។

## ក.សិក្សាអត្ថរូប

## ខ.ផ្តើមរឿង

អ្នកនិពន្ធធ្វើបទនមស្ការដោយប្រារព្ធនូវប្រភពរឿង ដោយ ផ្តើមថាៈ “ព្រះពុទ្ធជាបរមសាស្តាកាលគង់ក្នុងវត្តជេតពន ទ្រង់ ប្រារព្ធនូវភិក្ខុមួយរូបជាអ្នកចិញ្ចឹមមាតាបិតា ទ្រង់សម្តែងព្រះធម៌ ទេសនាថា កោ នុ មំ ឧសុនា វិជ្ឈ ដូច្នេះជាដើម ។

សេចក្តីថាៈ កូនប្រុសសេដ្ឋីម្នាក់ក្នុងនគរសាវត្ថីបានឃើញ មហាជនប្រុសស្រីទៅវត្តជេតពនដើម្បីស្តាប់ធម៌ទេសនា ក៏ ទៅស្តាប់នឹងគេ ឃើញទោសក្នុងកាម ឃើញអានិសង្សក្នុងភេទបព្វជ្ជា ក៏ចូលទៅសូមផ្នួសក្នុងសំណាក់ព្រះសាស្តា។ ព្រះអង្គមានពុទ្ធដីកាថាៈ ព្រះតថាគតទាំងឡាយមិនដែល

បំបួសកូនដែលមាតាបិតាមិនទាន់អនុញ្ញាតទេ។ កុលបុតនោះឮដូច្នេះក៏ថ្វាយបង្គំលាទៅកាន់ផ្ទះនៃអាត្មា ថ្វាយបង្គំមាតាបិតាសូមលាទៅបួស។ គ្រានោះ មាតាបិតាបានឮសម្តី កូននោះ ក៏ហាក់ដូចជានឹងបែកទ្រូងព្រោះកូនមានតែមួយ ប៉ុណ្ណោះ មិនព្រមអនុញ្ញាតសោះ។ កូន

នោះក៏ជាទុក្ខតូចចិត្ត ឱនក្បាលផ្ទប់សុបសៅតគអាហារអស់៧ថ្ងៃ។ មាតាបិតាភិត ភ័យក៏យល់ព្រមឱ្យទៅបួស...។ ទើបព្រះល្អះមារទ្រង់នាំមក នូវអតីតនិទាននេះថា... ។ "

### គ. តួរឿង

តួរឿងចាប់ផ្តើមជាភាសាបាលីដើម្បីផ្តើមដំណើររឿងដោយសង្កត់ធ្ងន់ទៅលើប្រធានរឿង គឺការបំពេញមេត្តាបារមីរបស់តួអង្គ ពោធិសត្វ។ ការចាប់ផ្តើមដោយពាក្យថាៈ

អតីត ភិក្ខុ ម្នាលភិក្ខុទាំងឡាយក្នុងកាលកន្លង ទៅហើយមានស្រុកពួកអ្នកនេសាទមួយនាត្រើយខាងអាយ នៃស្ទឹងជិតនគរពារាណសី ។ មានស្រុកពួកអ្នកនេសាទមួយទៀត នាត្រើយខាងនាយនៃស្ទឹង អ្នកនិពន្ធបានបង្ហាញពីដំណើររឿងនៃការសាងបារមី មត្តបារមីរបស់ព្រះពោធិសត្វ គឺចាប់ពីពេលចាប់កំណើតរហូតដល់ ការបំពេញនូវមេត្តាបារមីបានសម្រេច ។ សាច់រឿងជាបែបទសនា (លក្ខណៈនិទាន) អ្នកនិពន្ធប្រើប្រាស់នូវសិល្បវិធីនិពន្ធលាយចម្រុះ គ្នា ដោយប្រើពាក្យពេចន៍យ៉ាងពីរោះរណ្តំ មានពណ៍នាវិធី សំវាទ វិធី ឯកវាទវិធី វឌ្ឍមានវិធីជាដើម។

### ឃ. បញ្ចប់រឿង

អ្នកនិពន្ធបានបង្ហាញពីការសរជាតិនៃតួអង្គៈ

អង្គសម្តេចវិជិតមារទ្រង់នាំព្រះធម៌ទេសនានេះមកសម្តែង ហើយទ្រង់មានព្រះពុទ្ធដីកាថា "ម្នាលភិក្ខុទាំងឡាយ ការចិញ្ចឹម មាតាបិតាជាវង្សប្រពៃណីនៃអ្នកប្រាជ្ញទាំងឡាយ ហើយទ្រង់ប្រជុំ

ជាតកថាៈ

- ព្រះរាជាបិលយក្ខ គឺភិក្ខុអានន្ទ
- ទេវធីតាវសុន្ទរី គឺភិក្ខុនីឧប្បលវណ្ណាថេរី
- ព្រះឥន្ទ គឺភិក្ខុអនុរុទ្ធត្ថេរ
- បិតា (ទុកូល) គឺមហាកស្សប មាតា
- (បារិកា) គឺភិក្ខុនីភទ្ទកាបិលានី
- សុវណ្ណសាមបណ្ឌិត គឺអង្គអញតថាគតជាសម្ម- សម្ពុទ្ធហ្នឹងឯងហោង ។

### ក. សិក្សាអត្ថរស

តម្លៃរឿងជាមូលដ្ឋានបិតលើមនុស្សរសគឺការរស់នៅចិញ្ចឹម ជីវិតដោយការនេសាទបេះផ្លែឈើ ចិញ្ចឹមមាតាបិតាជាដើម។ អ្នកនិពន្ធក៏បានបង្ហាញពីវិសិដ្ឋរស គឺវិសេសរកគ្មានក្នុងសកម្មភាព ដ៏អស្ចារ្យរបស់តួអង្គសុវណ្ណសាមពោធិសត្វ ដែលមនុស្សធម្មតាពុំ អាចធ្វើបាន ពោធិសត្វបានបម្រើមាតាបិតាសព្វគ្រប់ ពុំមានទូចខ្នោះ ហើយជាពិសេសទៅទៀតនោះគឺ ពុំចេះខឹងក្រោធ ព្រម ទាំងមានចិត្តមេត្តាចំពោះមនុស្សសត្វទូទៅ ជាក់ស្តែងនៅពេល ត្រូវព្រួញរបស់បិលយក្ខហើយ សុវណ្ណសាមមិនបានខឹងក្រោធទ

បែរជានិយាយសម្តីផ្អែមល្ហមចិត្តចំពោះអ្នកដែលបាញ់ខ្លួនទៀត រីឯ ចិត្តវិញនៅតែនឹករឭកព្រួយបារម្ភចំពោះមាតាបិតាជានិច្ច - សាច់ រឿងបានបង្ហាញពីលក្ខណៈអស្ចារ្យហួសពីលក្ខណៈដែលមនុស្សអាចធ្វើបាន ដែលគេហៅថាអច្ឆរិយរស។ "ទុកូលគ្រាន់តែយកដៃទៅស្ទាបឧទរ (ពោះ) នាងបារិកាក៏អាចមានកូនបានដែរ។" ជាង នេះទៅទៀត ខណៈសុវណ្ណសាមត្រូវព្រួញយក្សស្លាប់ ក្រោយពីការបន់ស្រន់របស់មាតាបិតា

និងរំឭកនូវកុសលកម្មដែលធ្លាប់ប្រព្រឹត្តវិញ។

ចំពោះមាតាបិតានិងអ្នកដទៃកន្លងមកក៏បានរស់រានមានជីវិតឡើងកុសលរស តាមរយៈរឿងនេះគឺៈ

- ឱ្យចេះដឹងគុណចំពោះមាតាបិតា មានចិត្តកតញ្ញូ និងកតវេទីចំពោះមាតាបិតា

- ឱ្យមនុស្សប្រព្រឹត្តអំពើល្អ មានសេចក្ដីមេត្តា ប្រកាន់ខ្ជាប់នូវចរិយាធម៌ និងនីច្ចសីល។ អំពីបាប ជាប្រភពនៃទុក្ខដែលនាំទៅកាន់ភាពលំបាកវេទនា និងធាក់នរក។សិក្សាអក្សរសិល្ប៍ពុទ្ធនិយមទសជាតក

- ឱ្យមនុស្សចេះរស់នៅជាមួយគ្នាប្រកបដោយសន្តិភាពមានការអធ្យាស្រ័យឱ្យគ្នាទៅវិញទៅ មក និងចេះជួយគ្នាក្នុងគមានអាសន្ន។

គោលគំនិតអប់រំរបស់អក្សរសិល្ប៍ពុទ្ធនិយ អក្សរសិល្ប៍ពុទ្ធនិយម បានបង្កប់នូវតម្លៃអប់រំយ៉ាងជ្រាលជ្រៅក្នុងការដុសខាត់ចិត្តគំនិតមនុស្សសង្គមខ្មែរ ប្រព្រឹត្តនូវអំពើល្អស្រឡាញ់នូវគុណធម៌ ស្រឡាញ់សុខសន្តិភាព គ្មានការប្រកាន់វណ្ណៈ មិនមានការលោភលន់ ពិសេស រួមចំណែកក្នុងការអភិវឌ្ឍសង្គមជាតិគ្រប់វិស័យទាំងអស់។ ខាងក្រោមនេះ យើងសូមលើកយកទស្សនៈអប់រំ សំខាន់ៗ ក្នុងអក្សរសិល្ប៍ពុទ្ធនិយមដូចតទៅ។

## ខ. ប្រធានរឿង

រឿងសុវណ្ណសាមជាតក ប្រធានរឿងនិយាយអំពី ការកសាងមេត្តាបារីរបស់តួអង្គព្រះពោធិសត្វ (សុវណ្ណសាម)ក្នុងការបំពេញមេត្តាបារមីដើម្បីត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធនៅអនាគតជាតិ។

- មេត្តាចំពោះមាតបិតា

សុវណ្ណសាមជាកូនប្រកបដោយក្ដិមេត្តាចំពោះមាតា បិតា ជាទង្វើប្រកបដោយគុណធម៌ កតញ្ញូ កតវេទី របស់បុត្រធីតា ជាក់ស្តែងនៅពេល មាតា បិតា សុវណ្ណសាមបានជួបគ្រោះថ្នាក់ដោយសារតែពស់អសិរពិសវាបានព្រួសពិសដាក់ភ្នែកអ្នកទាំងពីរធ្វើឱ្យពិការ សុវណ្ណសាមបានមើលថែរក្សាអ្នកទាំងពីរគ្រប់បែបយ៉ាង ទាំងចំណីអាហារ ផ្លែឈើគ្រប់មុខ បម្រើ ទាំងថ្ងៃទាំងយប់គ្រប់ពេលវេលា ។

- មានមេត្តាចំសត្វ(ម្រឹក .ចតុបាទ)

សុវណ្ណសាមតែងមានសេចក្ដីមេត្តាចំពោះ សព្វសត្វទាំងឡាយនៅពេលទៅណាមកណាសត្វបានដើរតាមអមគ្រប់ពេលវេលា ការមិនសម្លាប់ជីវិតសត្វជាអំពើដ៏ប្រសើរជាអំពើល្អ ជាកុសលកម្ម ដេលព្រះពោធិសត្វបានប្រព្រឹត្តគ្រប់អង្គ។

- មេត្តាចមពោះស្ដេចកបិយក្ស

នៅពេលកបិលយក្សបានបាញ់ព្រួញត្រូវ សុវណ្ណសាម មិនខឹងក្រោធមានខន្តី ហើយពោលពាក្យសម្ដីពិរោះពិសារទៅកាន់កបិលយក្ស នោបេលសុវន្ណសាមកំបុង ដងទឹក"ផ្ទង់ស្មារតី » ស្រែកសួរថា៖ លោកណាអើយ! បាញ់ខ្ញុំកំពុងដងទឹក សាច់ខ្ញុំ មិនជារបស់គួរស៊ីទេ ទាំងស្បែករបស់ខ្ញុំក៏មិនជារបស់ដែលគេត្រូវ ការដែរ។ តើលោកសម្គាល់ដូចម្ដេចបានជាបាញ់ហើយពូន។

## គ.មូលបញ្ហារឿង

ការចេញទៅសាងផ្នួសជាឥសី ទុកុលនិង បាសិកា

រឿងនេះបានស្ដេងឱ្យឃើញពីការមិនសម្លាប់សត្វរបស់អ្នកទាងពីរ (បាណាតិបាតា) មិនតែប៉ុណ្ណោះអ្នកទាំងពីរនូវកិលេសតណ្ហា ធ្វើឱ្យពួកគាត់ពុំមានបុត្រមើលថែរក្សានោពេលចាស់ចំណែកព្រះឥន្ទ្រាធិរាជបានប្រមើលមើលបានដឹងអនាគត់អ្នកទាំងពីរនិងពិកាភ្នែក ព្រះឥន្ទ្រឱ្យទុកូល យកដៃស្ទាបពោះ បាសិកាហេតុនេះទើបមានពោធិសត្វចុះពីស្ថានទេវលោកមកចាប់បដិសន្ធិអ្នកទាំងពីរ។

## ខ.ស្ដេចកបិលយក្សនៅដែនកាសីចូលចិត្តការបរបាញ់សត្វ

ការកសាងបារមីរបស់ពោធិសត្វតែងមានឧបសគ្គ ដូចសុវណ្ណសាមបានត្រូវព្រួញកបិលយក្សពេលបាញ់ត្រូយមិនមានតបតដោយទោសៈ ទៅវិញឡើយ។

## ឃ.ឧត្តមគតិ តម្លៃអប់រំនៃរឿងសុវណ្ណសាម

តាមរយៈសាច់រឿងទាំងមូលអ្នកនិព្វបានបង្ហាញពីគោលគំនិតអប់រំសំខាន់ៗដូចជា៖

ការដឹងគុណចំពោះមាតាបិតាកូនត្រូវមានចិត្តកតញ្ញូ និងមានកាតព្វកិច្ចតបគុណចំពោះមាតាបិតា ព្រោះលោកជាអ្នកចិញ្ចឹមបីបាច់ថែរក្សា កូនតាំងពីតូចដល់ធំ និងផ្តល់នូវអ្វីៗគ្រប់បែបយ៉ាងដល់កូន។ ឪពុកម្តាយជាអ្នកមានគុណដ៏លើសលប់ និងជាបុគ្គ ដែលជាទីសក្ការបូជាចំពោះកូនលោកតែងមានព្រហ្មវិហារធម៌ចំពោះកូន ការពារកូន ណែនាំកូនឱ្យដើរផ្លូវល្អ។ ឪពុម្តាយ ត្រូវបានគេចាត់ទុកថាជាព្រះកន្លោង នៅក្នុងផ្ទះ លោកជាបុព្វទេវតា ថែរក្សាកូនមុនគេបង្អស់ និង ជាបុព្វការី គឺជាគ្រូ បង្រៀននូវអ្វីៗដល់កូន មុនគ្រូដទៃណាណា ទាំងអស់។ ដូចនេះ កូនត្រូវតែមានចិត្តកតញ្ញូ និងកតវេទី ចំពោះលោកដូចបានបង្ហាញតាមរយៈរឿងខាងលើ សុវណ្ណសាមបានចញ្ចឹមមាតា បិតាដោយកតញ្ញូព្រហ្មវិហារធម៌តបសងគុណលោកវិញ ទោះលោកពិការភ្នែកទាំងសងខាងក៏សុវណ្ណសាមមិនបោះបង់ចោល ហើយខិតខំបម្រើទ្វេដងទាំងថ្ងៃទាំងយប់ សុវណ្ណសាមមានមេត្តាចំពោះសព្វសត្វទាំងឡាយ ធ្វើឱ្យសត្វទាំងឡាយមានការគោរពស្រឡាញ់ជាខ្លាំងពេលសុវណ្ណសាមទៅណាតែងមានសត្វតាមហែរហមជានិច្ច ។

ឱ្យមនុស្សប្រព្រឹត្តអំពើល្អ មានសេចក្តីមេត្តា ប្រកាន់នូវចរិយាធម៌ និងសីលប្រាំអំពើបាប ជាប្រភពនៃទុក្ខ ដែលនាំទៅកាន់ភាពលំបាកវេទនា និងនរក។ ដូចនេះ សេចក្តីមេត្តាការមិនចងគំនុំ និងការរក្សានូវសីលប្រាំ គឺ ៖

- ១. បាណាតិបាតា គឺ ការមិនសម្លាប់សត្វ
- ២.អទិន្នា គឺ ការមិនឆក់ប្លន់ លួចទ្រព្យសម្បត្តិអ្នកដទ
- ៣.កាមេសុមច្ឆាគឺការមិនប្រព្រឹត្តខុសក្នុងផ្លូវកាម (ប្រព្រឹត្តខុសលើ ប្រពន្ធ កូនអ្នកដទៃ)
- ៤. មុសា គឺការមិនពោលពាក្យកុហក
- ៥. សុរា គឺការមិនសេពនូវគ្រឿងស្រវឹងផ្សេងៗ (សុរា និង មរាយ)។

យើងក៏បានឃើញតាមរយៈតួអង្គនោក្នុងសាច់រឿងជាច្រើនដែលបានដង្ហាញពីការមិនសម្លាប់សត្វ ដូចសុវណ្ណសាមបានទូន្មានដល់កបិយក្សថា “បពិត្រព្រះរាជាលុះទ្រង់ប្រព្រឹត្តធម៌ចរិយានេះហើយទៅកើតក្នុងស្ថានសួគ៌អំពើដែលខ្លួនប្រព្រឹត្តល្អនេះឯង។

អប់រំឱ្យមនុស្សចេះរស់នៅជាមួយគ្នាប្រកបដោយសន្តិភាព ការអធ្យាស្រ័យឱ្យគ្នាទៅវិញទៅមក និងចេះជួយគ្នាក្នុងគ្រាមានអាសន្ននាំមកនូវសន្តិភាព។ មនុស្សមិនអាច រស់នៅតែម្នាក់ឯងបានឡើយ គឺតែងមានការពឹងពាក់គ្នាទៅវិញទៅមក ជួយយកអាសារគ្នាពេលជួបបញ្ហាអ្វីមួយ ដោយយថាហេតុ ។ ជាក់ស្តែងដូច ទេវធីតាវសុន្ទរី បានណែនាំកបិលយក្ខ ឱ្យមានការភ្ញាក់រលឹក និងទំនួលខុសត្រូវ ហើយថែមទាំងជួយយកអាសារដល់សុវណ្ណសាម ពេលជួបនឹងគ្រោះថ្នាក់ទៀតផង ។ ជាពិសេសទៅទៀត ការដោះស្រាយបញ្ហាប្រកបដោយសន្តិវិធីជៀសវាងការប្រើកម្លាំងបាយ កំហឹងទល់នឹង កំហុស គំនុំចំពោះទង្វើខ្លួនមនុស្សគំនុំគួន សងសឹកគ្នាទៅវិញទៅមកដែលនាំឱ្យចំណងកាន់ជ្រៅដោះស្រាយមិនបានដូចនេះតាមរយៈរឿងនេះបានបង្ហាញឱ្យឃើញពេលសុវណ្ណសាមបានត្រូវព្រួញកបិយក្ស។

ជារួមរឿងសុវណ្ណសាមបានផ្តល់តម្លៃអប់រំដល់ បុគ្គលគ្រប់រូបឱ្យចេះមានធម៌កតញ្ញូដឹងគុណចំពោះ មាតា បិតា គ្រូបាចារ្យ អ្នកដែលបានធ្វើអមពើល្អមកលើខ្លួន ឱ្យចេះអធយាស្រ័យគ្នាទៅវិញទៅមកមានក្តិមេត្តការជួយយកអាសារគ្នាពេលមានអាសន្ន ការវៀចាកក្នុងផ្លូវកាមទាំងឡាយ និងការកាន់ធម៌ចរិយាសិល្បប្រាំជាដើម។

## សង្ខេបរឿង តេមិយ

កាលកន្លងទៅហើយមានព្រះមហាក្សត្រមួយអង្គព្រះនាម កាសិករាជ សោយរាជ្យក្រុងពារាណសី មានព្រះអគ្គមហសីព្រះនាម ចន្ទាទេវីទ្រង់ពុំមានព្រះរាជបុត្រ ឬព្រះរាជធីតាសោះ ។ អ្នកនគរភ័យខ្លាចផុតព្រះរាជវង្ស ទើបទ្រង់ឱ្យស្រីស្នំទាំង មួយម៉ឺនប្រាំមួយពាន់នាក់បួងសួងសុំបុត្រ ។ ដោយអំណាចតេជ សីលឧបោសថ ទើបព្រះឥន្រ្ទាធិរាជអារាធនាព្រះពោធិសត្វជាទេវបុត្រនៅឋានតត្រឹង្ស ឱ្យមកចាប់បដិសន្ធិក្នុងផ្ទៃព្រះនាងចន្ទទេវី ។ ថ្ងៃដែលព្រះពោធិសត្វប្រសូតមកមានភ្លៀងបង្អុរជោគជាំពេញដែនកាសី ព្រះរាជាដាក់នាមព្រះរាជបុត្រថា តេមិយកុមារ ។

កាលតេមិយកុមារ ព្រះជន្មបានមួយ ពួកស្នំនាំទៅគាល់ ព្រះរាជានៅទីនាំងវិនិច្ឆ័យទោសចោរ ។ ព្រះរាជាទ្រង់វិនិច្ឆ័យទោស ចោរ៤នាក់ ដោយចោរខ្លះត្រូវធ្វើទារុណកម្ម ហើយចោរខ្លះឱ្យយក ទៅសម្លាប់ ។ ព្រះរាជកុមារទតឃើញព្រះវរបិតាវិនិច្ឆ័យទោសចោរ ទាំងបួននាក់ក៏មានសេចក្តីតក់ស្លុតព្រោះព្រះអង្គធ្លាប់ទទួលរងបាប កម្មដោយអំពើប្រហារចោរនេះកាលពីជាតិមុន ហើយទៅរងទុក្ខដូច្នេះ ស្រាប់តែទេវតារក្សាស្វេតច្ឆ័ត្រដែលធ្លាប់ជាមាតាពីជាតិមុន ទោសទណ្ឌកម្មក្នុងឧស្សទនរកអស់ប្រាំបីម៉ឺនឆ្នាំ ។ កំពុងភ័យព្រួយ បានបញ្ចេញនូវកិច្ចកលថ្វាយព្រះពោធិសត្វ ដោយឱ្យធ្វើពុតជាគ .ថ្លង់ ខ្វិនខ្វង់ ដើម្បីគេចផុតពីការសោយរាជ្យ ព្រះតេមិយ ធ្វើពុតជា គថ្លង់ លែងនិយាយស្តី ព្រះរាជាទ្រង់ជ្រាបថាបុត្រមិនមាន និយាយ។

តាំងពីពេលនោះមក ព្រះតេមិយកុមារធ្វើខ្លួនជាមនុស្សខ្វិន ) ចលនា ទើបហៅព្រាហ្មណ៍ទាំងឡាយមកប្រជុំ ប៉ុន្តែព្រាហ្មណ៍ទាំង នោះយល់ថា ជើងមិនខ្វិន ចង្កមនុស្សគក៏មិនមែនត្រចៀកមនុស្ស ថ្លង់ក៏មិនមែន ឃើញដូចនេះទើបព្រះអង្គពិសោធដោយវិធី១៦ បការអស់រយៈកាល១៦ឆ្នាំ គឺទី១ ពិសោធដោយចំណី, ទី២ ពិសោធ ដោយផលានុផល, ទី៣ ពិសោធដោយគ្រឿងកីឡា, ទី៤ ពិសោធ ដោយភោជន, ទី៥ ពិសោធដោយភ្លើង, ទី៦ ពិសោធដោយដំរីច្រែះប្រេង, ទី៧ ពិសោធដោយពស់, ទី៨ ពិសោធដោយមហោស្រប, ៩ ពិសោធដោយគ្រឿងអាវុធ ទី១០ ពិសោធដោយសូរសព្ទគ ស័ង្ខ, ទី១១ ពិសោធដោយសូរសព្ទស្គរ,ទី១២ ពិសោធដោយពន្លឺភ្លើង ប្រទីប, ទី១៣. ពិសោធដោយរុយ, ទី១៤ ពិសោធដោយគ្រឿង សម្លុយ, ទី១៥ ពិសោធដោយដុតភ្លើងឆ្អើរ,និងទី១៦ ពិសោធដោយ មាតុគ្រាម ។ ក្រោយពីការពិសោធទាំង១៦អស់ចំណេះទាល់គំនិត ហើយ ព្រះមហាក្សត្រក៏ប្រជុំព្រាហ្មណ៍ទាំងអស់ ហើយស្តីបន្ទោស. ដោយប្រការផ្សេងៗ។ ពួកព្រាហ្មណ៍ទាំងអស់នោះមានការអាក់ ឱ ! អន់ចិត្តទើបទាយថា ព្រះរាជកុមារជាកុមារកាឡកណ្ណី, កាលបើទុក ក្នុងនគរនឹងនាំឱ្យមានក្តីអន្តរាយ ត្រូវតែយកទៅកប់ចោលក្នុងព។ ប៉ុន្តែដោយការអង្វរករបស់ព្រះនាងចន្ទាទេវី ទ្រង់ក៏យល់ព្រមផ្ទេរ រាជសម្បត្តិឱ្យព្រះរាជបុត្រសោយរាជ្យបាន៧ថ្ងៃសិនមុននឹងយកទៅប្រហារជីវិត។

បន្ទាប់មក ព្រះបាទកាសិករាជទ្រង់បានបញ្ជាឱ្យនាយសារថីទឹមរទេះអពមង្គលដឹកនាំព្រះតេមិយទៅទិសខាងលិច ប៉ុន្តែដោយ អំណាចបារមីនៃព្រះពោធិសត្វ ទេវតាបានប្រែក្លាយជារទេះទឹម ដោយរថមង្គល ហើយធ្វើដំណើរទៅទិសខាងកើតវិញ។

ខណៈពេលដែលនាយសារថីកំពុងតែជីករណ្តៅ ព្រះពោធិ- សត្វបានក្រោកច្របាច់ព្រះហស្តឆ្វេងស្តាំ និងព្រះបាទា ហើយស្រដី ទៅកាន់នាយសារថីថា ព្រះអង្គមិនមែនខ្វិន មិនគមិនថ្លង់ឡើយ ។ នាយសារថីមានការតកអរ ហើយសុំយាងព្រះកុមារទៅនគរវិញ តែត្រូវព្រះពោធិសត្វបដិសេធ ដោយសុខចិត្តរស់នៅក្នុងព សន្សំ កុសលផលបុណ្យ ជាអ្នកមានព្រហ្មចរិយធម៌ និងចាកផុតពីភាពភិត ភ័យដោយអំពើនរក និងរាជសម្បត្តិ។ ដោយការស្តាប់បន្ទូលយ៉ាង ក្បោះក្បាយ នាយសារថីក៏បានសុំបួសក្នុងព្រះរាជដំណាក់ព្រះអង្គតែព្រះអង្គមានបន្ទូលឱ្យនាយសារថីប្រគល់រថ ហើយធ្វើខ្លួនឱ្យអស់សម្រេចបុគ្គលមិនមានបំណុល ជាកម្មដែលពួកឥសិសរសើរ ។ ចំណុលសិតទើបអាចសម្រេចបាននូវបុព្វជា ព្រោះបព្វជាបង។

នាយសារថីបាននាំដំណឹងទៅទូលព្រះរាជានិងព្រមហសី ដល់ពមពោធិសត្វធ្វើបដិសណ្ឋារកិច្ចំពោះព្រះវរមាតាបិតា ទើបរអង្គយាងមកជិតព្រះរាជបុត្រដោយផ្ទាល់ លុះមកហើយឱ្យគ្រូវមាតាបិតាគង់លើស្លឹកឈើ ដោយឱ្យសោយព្រះនាងឧនកដែលឡោះដោយស្លឹកឈើមិនមានរសជាតិ ។ ប៉ុន្តជាមិនសោយ ហើយនិយាយលួងលោមឱ្យព្រះរាជបុត គ្រឡប់ទៅសោយរាជ្យវិញ ព្រះពោធិសត្វក៏ទូន្មានដោយប្រការផ្សេងៗដល់ព្រះមាតាបិតាអំពីការប្រព្រឹត្តនូវព្រហ្មចរិយធម៌ដើម្បីបានសេចក្តីសុខ ។

កាលនោះព្រះបាទកាសិករាជ និងព្រះនាងចន្ទាទេវី ព្រ ទាំងស្នំ១ម៉ឺន ៦ពាន់ រួមទាំងបរិវារសព្វព្រះទ័យនឹងសាងព្រះផ្នួស ទើបទ្រង់ឱ្យចំហទ្វាររងទាំងអស់ និងទ្វារផ្សារ ហើយទៅកសាង បុណ្យកុសលនៅពេញអាស្រមដែលព្រះឥន្ទ្រនិម្មិតថ្វាយចម្ងាយ មួយជ្រុងៗបីយោជន៍ បានសម្រេចនូវសហបត្តិ៨ និងអភិញ្ញា៥ទាំង អស់គ្នា ។ ចំណែកពួកសាបន្តរាជទាំងឡាយដែលបកប្រដែងយក រាជសម្បត្តិនៅក្នុងនគរពារាណសីក៏ប្រែព្រះទ័យសាងព្រះផ្នួសទាំង អស់ ហើយបានសម្រេចនូវសមាបត្តិដូចៗគ្នា ពួកដំរី ពួកគេះក្លាយជាដំរីព : សេនព្រៃអស់ ដោយមានសោមនស្សនឹងម្ចាស់ខ្លួនសាងព្រះផ្នួសលុះស្លាប់ទៅបានទៅកើតជាទេវតានៅឆកាមាវចរ មានព្រះពោធិសត្វជាបធានស្ថិតនៅស្ថេក៏ ។ ឯតាបស និងតាបសិនីដល់អស់អាយុជីវិតទៅបានទៅកើតក្នុងព្រហ្មលោកគ្រប់ៗអង្គ ។

## ក.អត្ថន័យខ្លឹមសារ

អត្ថន័យអត្ថ .ប្រយោជន៍.អត្ថន័យ .ការណែនាំអត្ថាធិប្បាយសេចក្ដីពន្យល់.អត្ថន័យជាគំនិតសំខាន់ៗរបស់អ្នកនិពន្ធដែលលាតត្រដាងនៅក្នុងដំណើររឿង ហើយគេអាចហៅវាថាជាជម្រៅនៃរឿង។

ក្នុងផ្នែកអត្ថន័យមាន ប្រធានរឿង មូលបញ្ហារឿងនិងឧត្តមគតិរឿង។

## ខ.ប្រធានរឿងមូលន័យ.

ប្រធានរឿងឬមូលន័យ គឺជាគំនិតសំខាន់ៗរបស់រឿង។ប្រតិឬជាបញ្ហារួមរបស់រឿង។តែអ្នកនិពន្ធចង់បង្ហាញដល់អ្នកអានប្រធានរឿងជាបញ្ហារួបផ្ដុំបំផុតដែលអ្នកនិពន្ធលើកយកមកសរសេរឬជ្រើសរើសជាប្រធានបទហើយដែលមានមូលបញ្ហារឿងឋិតនៅក្នុងនោះ។

ប្រធានរឿងបង្ហាញនៅចំហររបស់អ្នកនិពន្ធវាជាមូលដ្ឋានដើមរបស់អ្នកនិពន្ធក្នុងការចាប់ផ្ដើមសរសេរឡើង។មុនពេលចាប់ផ្ដើមសរសេរឡើង។អ្នកនិពន្ធត្រូវកំណត់ថា តើគាត់ត្រូវសរសេរអំពីអ្វី ។ អំពីជីវិតសង្គមសង្គ្រាមស្នេហារឿងជំងឺទំនេនទម្លាប់ប្រពៃណីចម្លើយរបស់សំណួរនេះហើយជាប្រធានរឿង។រឿងខ្លះប្រធានរឿងស្ថិតនៅលើចំណងជើងរបស់រឿង។

ប្រធានរឿងតេមិយ គឺការបំពេញនេក្ខកម្មបារមី របស់ព្រះពោធិសត្វ ។

## គ.មូលបញ្ហារឿង

មូលបញ្ហារឿងគឺជាភាពចំណែកនៃប្រធានរឿងជាទិដ្ឋភាពផ្សេងៗរបស់យើង។វាជាការចូលជ្រៅទៅក្នុងប្រធានរឿង។

ជុំវិញប្រធានរឿងនេះយើងអាចកំណត់នូវបញ្ហាជាច្រើន ជាមែកធាង ដែលស្ថិតនៅជុំវិញការអធិដ្ឋានបារមីរបស់ព្រះពោធិសត្វក្នុងការចេញកសាងផ្នួស។

## ទី១ បញ្ហាការកាត់ទោសចោរ

ព្រះមហាក្សត្រកាត់ទោសចោរព្រះព្រះតេមិយកុមារបានទតឃើញការកាត់ទោស ចោរទាំង៤ ព្រះអង្គមានការភិតភ័យក្រៃលែង ។ រឿងចោរទាំង៤ ព្រះមហាក្សត្របានដាក់ទោសចោរមួយត្រូវវាយដោយរមពាត់ ១ពាន់ខ្នាត់ ចោរម្នាក់ចងដោយច្រវាក់ដាក់ក្នុងពន្ធនាគារ ចោរម្នាក់ត្រូវចាក់សម្លាប់ និងចោរមួយទៀតត្រូវដោតឆ្កាងអណ្ដោតដោយដែកស្រួច ។ ព្រះពោធិសត្វឃើញហេតុការណ៍បែបនោះខ្លាចនូវអំពើបាបបានស្លុងស្មារតីព្រួយបារម្ភណ៍គឧបមាគិតថា បើខ្លួននៅសោយរាជនិងប្រព្រឹត្តដូចព្រះបិតា ហើយត្រង់ពិចារណាថា អាត្មាអញមកពីណាមកនៅក្រោមស្វេតច្ឆត្រនេះ គឺមកពីឋានតាវតឹង្សមកនៅទីនេះ មកពីនរកទៅកាន់ឋានតាវតឹង្ស ទៅពីកន្លែងនេះទៅរក ព្រោះធ្លាប់ជាស្ដេចសោយរាជ្យនៅនគរនេះ អស់ម្ភៃឆ្នាំដោយសារទោសនៃការសោរាជ្យ បានជានៅរងទុក្ខឧស្សូទនរកប្រាំបីម៉ឺនឆ្នាំ។ នៅពេលព្រះពោធិសត្វបានពិចារណត្រឹមត្រូវហើយបើដាក់ទោសចោរភ័ន្តច្រឡំ ត្រូវជាខុសល្អជាអាក្រក់ដោយអំពើទាំងនេះហើយធ្វើឱ្យព្រអង្គខ្លាចចំពោះខ្លួនឯង ។ ពេលនោះទើបមាតារក្សាឆ្ទេសឆត្រជាមាតាជាតិមុនផ្ដល់ឧបាយកលថា ធ្វើគ ធ្វើថ្លង់ ធ្វើខ្វិនខ្វង់និង លែងនិយាយស្ដី ។

បន្ទាប់មកព្រះមាតា បិតា បានខំធ្វើវិធាច្រើនឱ្យព្រះអង្គភ័យខ្លាចមាន១៦ប្រការក៏ប្រែះអង្គពុំមានសកម្មភាពអ្វីទាំងងស់។

សរុបសេចក្តីមក ការកាត់ទោសបុគ្គលណាម្នាក់ត្រូវប្រកាន់ភ្ជាប់នូវ សច្ចធម៌សុចរិចត្រឹមត្រូវនិង ក្នុងនាមជាអ្នកមានអំណាចម្នាក់។

### ទី២ បញ្ហាការបំពេញនេក្ខម្មបារមី

ព្រះរាជកុមារបានគិតថា មានតែការបួសទេទើបបានរួចជាក្សត្រ ជៀសផុតកាន់អំណាចជាអ្នកកាត់ទោសគេ ចៀសផុតពីទ្រព្យសម្បត្តិ ចំណែកព្រះបាទឯករាជបានកាត់ទោសចោរនិងដោយការដាក់ទណ្ឌកម្មការពិសោធន៍មកលើបុត្រដែលនាំឱ្យខ្លួនឯងបានប្រព្រឹត្តអំពើបាបដោយមិនដឹងខ្លួន។ ការដាក់ទោសចោរទាំងបួន បានធ្វើឱ្យព្រះរាជបុត្រមានការតក់ស្លុតជាខ្លាំង បន្ទាប់មកការពិសោធន៍ចំពោះព្រះពោធិសត្វ ដោយការបំបាក់ស្មារតីមានដប់ប្រាំមួយប្រការ ។ លុះថ្ងៃក្រោយមកទៀតបានបញ្ជាឱ្យនាយសុនន្ទសារថីឱ្យចាប់ព្រះរាជកុមារទៅសម្លាប់ចោលដោយកប់ទាំងរស់ ។ អំពើនេះបានធ្វើឱ្យព្រះរាជកុមាររតគេចពីការស្នងរាជសម្បត្តិ មានតែការបួសមួយទេដែលជួយឱ្យព្រះរាជកុមាររួចផុតភាពជាគ្រងហស្ថ បានឃ្លាតចាកទុក្ខទាំងពួងបាន។

សរុបសេចក្តីមកការសម្រេចចិត្តមុននិង ធ្វើនូវរឿងមួយត្រូវគិតឱ្យបានច្បាសលាស់ជាមុនសិន ទើបរឿងនោះមិនមានកំទៅថ្ងៃក្រោយនិងមិនប្រព្រឹត្តនូវអំពើជាអកុសទៀត។

### ឃ.ឧត្តមគតិរឿងគំនិតដឹកនាំរឿងតម្លៃអប់រំ

ឧត្តមគតិរឿងគឺជាឧត្តមគតិរបស់អ្នកនិពន្ធ។ឧត្តមគតិរឿងគឺយកកត្តាប្រធានវិស័យដែលបញ្ហាដែលបញ្ជាក់ពីគោលជំហរសតិអារម្មណ៍របស់អ្នកនិពន្ធដែលស្តែងឡើងតាមរយៈសកម្មភាពរបស់ព្រះអង្គ ។

- អប់រំមនុស្សកមឱ្យមានចិត្តលោបលន់និងទ្រព្យសម្បត្តិ
- អប់រំឱ្យមនុស្សជឿលើកម្មផល
- អប់រំមនុស្សឱ្យចេះដោះស្រាយសុចរិចយុត្តិធម៌
- អរំមនុស្សមានផាពស្មោះត្រង់
- ងប់រំមនុស្សឱ្យចះជួយគ្នា
- អប់រំឱ្យមនុស្សមានសេចក្តីស្រឡាញ់ចំពោអ្នលកមានកុណ
- អប់រំឱ្យបាតាណបិតាមានធម៌ចន្ទីចំពោះកូន ប្រស ស្រី
- អប់រំមនុស្សឱ្យស្អប់ខ្ពើមនូវការបៀតបៀនជិវិតអ្នកដ៏ទៃ។

## ខ.ជំនឿសាសនានិងការដឹកនាំក្នុងសង្គម

ព្រះតេមិយកុមារនាបសម្រេចចិត្តចេញសាងផ្នួស ពីព្រោះមិនចង់សោយរាជ្យ ការធ្វើជាស្តេចបានធ្វើឱ្យព្រះអង្គរងទុក្ខក្នុងឋាននរកអស់ជាច្រើនឆ្នាំ។ ពេលឃើញព្រះរាជាជាបិតាកាត់ទោសចោរមានការភ័យខ្លាច ដោយគិតថា បិតាធ្វើនេះនាំទៅកាន់ឋាននរក ពេលឃើញបែបនោះព្រះអង្គគេចធ្វើម៉េចឱ្យផុតពីការឡើងសោយរាជ្យ។ ត្រង់នេះបានបង្ហាញកុំឱ្យយើងស្រឡាញ់នូវអំណាច បុណ្យស័ក្តិ កេរ្តិ៍ឈ្មោះ ចេះខ្លាចនូវអំពើបាប ។ ដូច្នេះបើយើងប្រព្រឹត្តនូវអំពើអ្វីមួយ យើងទទួលវាដូចនោះដែរ កម្មនោះមិនអាចឱ្យអ្នកប្រព្រឹត្តិរួចខ្លួនទេ ។ ទោះជាស្តេចតុលាការ និងចៅក្រមទោះខ្លួនបានធ្វើត្រូវច្បាប់សង្គមក៏ដោយ នៅពេលស្លាប់ទៅក៏ត្រូវទទួលទោសនោះវិញឯង ។ លើសពីនេះទៅទៀត មិនឱ្យមានចិត្តលោបលន់ និងបុណ្យស័ក្តិឋានៈយើងមិនប្រព្រឹត្តិនូវអំពើអ្វីដែលនាំខ្លួនឱ្យវិនាសនោះទេ។ ការចេះលះបង់ហើយដោយការរក្សាសិល លះបង់កម្មកិលេស តណ្ហា ដូចព្រះតេមិយកុមារ ការមានចិត្តមិនចង់បាននិងនាំឱ្យយើងរស់នៅប្រកបដោយសេចក្តីសុខគ្រប់យ៉ាង។

សរុបជារួមមករឿងនេហបានបង្ហាឱ្យឃើញ ពីការលាសបង់ឋានៈជាព្រហមហាក្សត្រ បានចេញទៅសាងព្រះផ្នូសនៅក្នុងព្រះនិងអាចេជៀសផុតបីអំពើបាប។

# សង្ខេបរឿង មហោសថ

ក្នុងកាលកន្លងទៅព្រះបាទវិទេហរាជ សោយរាជ្យក្នុង នគរមិថិលាដែនវិទេហរាស្ត្រ ព្រះរាជាអង្គនោះមានអ្នកប្រាជ្ញ បួននាក់ឈ្មោះ សេនក បុក្កុសកាមិន្ទ ទេវិន្ទ ។ គ្រានោះព្រះរាជាទ្រង់យល់សុបិននិម្មិតជិតភ្លឺថា "មានគំនរភ្លើង៤ភ្នក់ ត្រង់ជ្រុង ទាំងបួននៃព្រះរាជវាំងឆេះសន្ធោសន្ធៅឡើងស្មើនឹងកំពស់ភ្នំ ត្រង់ កណ្តាលភ្នក់ភ្លើងទាំង៤នោះមានភ្លើងមួយប៉ុនអំពិលអំពែកភ្លើងឡើងភ្លឺជាងភ្នក់ភ្លើងទាំង៤ធំៗ ភ្លឺឡើងៗទៅលើទល់នឹង អកនិដ្ឋព្រហ្មជុំវិញពេញសកលចក្រវាឡ។

ព្រឹកឡើងទ្រង់ក៏សួរអ្នកប្រាជ្ញទាំង៤នាក់ បណ្ឌិតទាំងបួនបាន ប្រាប់ថាមានអ្នកប្រាជ្ញម្នាក់ទៀតគម្រប់ជាទីប្រាំកើតមកហើយ ។

កាលនោះមានសេដ្ឋីម្នាក់ឈ្មោះសិរីវឌ្ឍក មានភរិយានាម សុមនាទេវី នៅស្រុកបាចិនយវមជ្ឈគ្រាម ខាងកើតក្រុងផ្ទៃនាងសុមនាទេវី ក្នុងវេលាដែលព្រះរាជាទ្រង់និម្មិតនោះឯងហើយទេវបុត្រទាំងមួយពាន់អង្គផ្សេងទៀត ក៏ច្យុតព្រមគ្នាមកចាប់ បដិសន្ធិក្នុងត្រកូលនៃអនុសេដ្ឋីទាំងឡាយក្នុងស្រុកនោះដែរ ។ នាងសុមនា ទេវីទ្រង់គភ៌គ្រប់ទសមាសក៏ប្រសូតបុត្រល្អដូចមាស ឯ ត្រកូលរវនុសេដ្ឋីទាំងមួយពាន់នាក់សុទ្ធតែបានកូនប្រុសក្នុងថ្ងៃជាមួយនោះដែរ ។

ក្នុងកាលដែលព្រះពោធិសត្វប្រសូតនោះព្រះឥន្ទបានយកថ្នាំ ទិព្វមកដាក់ក្នុងបាតព្រះហស្តរបស់ព្រះពោធិសត្វដើម្បីព្យាបាលរោគ ព្រះបិតាដែលមានជំងឺប្រាំពីរឆ្នាំមកហើយធ្វើឲ្យរោគនោះបានជា ភ្លាមមួយរំពេចទើប បិតា សន្មតនាមបុត្ររបស់ខ្លួនថា មហោសថ ។ លុះចម្រើនព្រះជន្មបាន៧ឆ្នាំ កុមារទាំងមួយពាន់នាក់ចូលមកជា បរិវារ ថ្ងៃមួយព្រះពោធិសត្វបង្គាប់កុមារទាំងអស់ឲ្យយកប្រាក់ មកចូលហ៊ុនគ្នាមួយកហាបណៈម្នាក់ៗ ដើម្បីធ្វើសាលាប្រាំខ្នង គឺ សាលានៅមណ្ឌលកីឡាសម្រាប់ប្រជុំលេងកីឡាមួយខ្នង សាលា សម្ភពគឺមន្ទីរពេទ្យសម្រាប់សម្រាលកូនចំពោះជនអានាថាមួយខ្នង សាលាសម្រាប់សាមណៈ និងព្រាហ្មណ៍អាគន្តុកៈមួយខ្នង សាលា សម្រាប់មនុស្សអាគន្តុកៈមួយខ្នង និងសាលាសម្រាប់ពួកអ្នកជំនួញ មួយខ្នង ក្នុងសាលានីមួយៗ ព្រះពោធិសត្វឲ្យគូរក្បាច់រចនាល្អ អស្ចារ្យ ហើយឲ្យជីកស្រះបោក្ខរណីមួយ ឲ្យជាងរៀបគន្លងជាផ្លូវត់រំពត់មួយពាន់ មានបំពង់មួយរយ ឲ្យដាំផ្កា និងដាំដើម ឈើដែលមានផ្លែផ្កា ជាទីមានម្លប់ត្រឈឹងត្រឈៃ។ ចំណែកព្រះ បាទវិទេហរាជ ទ្រង់នឹកភ្នកដល់ទំនាយបណ្ឌិតទាំងបួនទាយ ក៏ចាត់ ឲ្យអាមាត្យទៅស៊ើបរកអ្នកប្រាជ្ញ។ អាមាត្យចេញទៅទិសខាងកើត ឃើញសាលាទាំងប្រាំ និងស្រះទឹក ទើបពិចារណាគិតទៅឃើញថា ឥឡូវនេះប្រាំពីរឆ្នាំគត់ទើបទូលមហាក្សត្រតាមដំណើរ ។ ព្រះរាជា បញ្ជាឲ្យហៅមហោសថមកដើម្បីតែងតាំងជាអ្នកប្រាជ្ញ ប៉ុន្តែអាចារ្យសនកៈមានចិត្តច្រណែន ដោយខ្លាចបាត់លាភសក្ការៈ ក៏ទូល ថាមិនទាន់ល្មមក្លាយជាអ្នកប្រាជ្ញបានទេ។

ព្រះរាជាត្រាស់បង្គាប់ឲ្យព្រះរាជទូតរបស់ព្រះអង្គទៅល្បង ពិសោធនឹងព្រះមហោសថឲ្យដោះប្រស្នាទាំង១៩រឿង ទី១. មំសំ (សាច់), ទី២ គោណោ (គោ), ទី៣ កណ្ឋិ (សង្វារ), ទី៤ សុត្តំ (អំបោះ), ទី៥ បុត្ត (កូន), ទី៦ គោជា (បុរសឈ្មោះគោឡកាឡ), ទី៧ រថោ (រទេះ), ទី៨ ទណ្ឌ (កំណាត់ឈើ), ទី៩ សីសំ (ក្បាល), ទី១០ អហិ (ពស់), ទី១១ កុក្កដា (មាន់), ទី១២ មណិ (កវមណី), ទី១៣ វិជាន (ការប្រសូត), ទី១៤ ឱទនំ (បាយ), ទី១៥ វាលុកា (ដីខ្សាច់), ទី១៦ តឡាកំ (ស្រះ), ទី១៧ ឧស្សានំ (សួនឧទ្យាន), ទី១៨ គទគោ (សត្វលា), និងទី១៩ មណិ (កែវមណី)។ ប្រស្នានីមួយៗដែលសួរដល់ព្រះមហោសថៗឆ្លើយដោះស្រាយរួចទាំងអស់ឥតមានទាស់ត្រង់ណាឡើយ ។ ក្រោយពេលដឹងថាព្រះមហោសថមាន ប្រាជ្ញា ស្តេចវិទេហរាជក៏មានបំណងតែងតាំងព្រះមហោសថជា អ្នកប្រាជ្ញ ប៉ុន្តែត្រូវបានជំទាស់ពីអាចារ្យទាំងបួននាក់។

ថ្ងៃមួយមានសត្វពពែមួយត្រូវបានគេវាយបាក់ខ្នង និងឆ្កែ មួយគេវាយបាក់ជើង សត្វទាំងពីរជាមិត្តនឹងគ្នា ព្រះរាជាក៏ដាក់ ប្រស្នាដល់អ្នកប្រាជ្ញទាំងបួន តែអាចារ្យទាំងបួនរកមិនឃើញ ក៏នាំ គ្នាទៅសួរព្រះមហោសថ ទើបអាចដោះប្រស្នានោះបាន ប៉ុន្តដោយអាចារ្យសនកៈនៅតច្រណែនព្រមហោសថ ក៏បានដាក់ ប្រស្នាបន្តបន្ទាប់ឲ្យព្រះមហោសថ (សិរិមណ្ឌកប្បញ្ហា, ដំរី, គោ សេះ, កែវមណី, សិរីអ្នកប្រាជ្ញ និងអ្នកធំ) ធ្វើឲ្យព្រះរាជាពេញព្រះ ទ័យតែងតាំងព្រះមហោសថជាអគ្គមហាសេនាបតីបូជាគោឧសភតែព្រះហើយសុំលាទៅស្វែងរក១ពាន់ ដំរី និងអាជានេយ្យ១ម៉ឺន និងស្រុកសួយ១៦ថែមទៀត។ លុះមកដល់អាយុ១៦ឆ្នាំ ព្រះនាង ឧទុម្ពរទេវីមហេសី ព្រះរាជាបានគិតថានឹងដណ្តឹងភរិយាឲ្យព្រះមហោសថ មហោសថបានសុំពេលពីរបីថ្ងៃ

សិន ភរិយាដោយខ្លួនឯង ពេលចេញដំណើរទៅក៏បានជួបនឹងនាង អមរាផីតា កំពុងទូលបបរទៅជូនឪពុកភ្ជួរស្រែ។ ព្រះមហោសថ ក៏សួរប្រស្នាទៅនាង ទើបដឹងថានាងជាស្រីប្រកបដោយបញ្ចពិធ កល្យាណីមែន ហើយមានប្រាជ្ញាទៀត ទើបទៅស្ដីដណ្ដឹងនាងធ្វើជាភរិយា ។ ចំណែកខាងបុរាណបណ្ឌិតរបស់ព្រះរាជាទាំងបួនក៏បានសាបសូន្យដូចជាពន្លឺអំពិលអំពែកនៅពេលថ្ងៃ ជាហេតុនាំឲ្យពួក នោះចេះតែរកវិធីរកទោសមហោសថ គឺអាចារ្យសនកៈលួចយក ស្លូតព្រះដាក់ក្នុងក្អមទឹកដោះខាប់ អាចារ្យបុក្កុសលួចខ្សែក មាស អាចារ្យកាមិន្ទលួចព្រះភូសាកម្ពុលដាក់ក្នុងកញ្ច្រែងបន្លែ អាចារ្យទេវិន្ទលួចស្បែកជើងមាស រួចហើយឲ្យទាសីរៀងៗ ខ្លួនយក ទៅលក់នៅផ្ទះមហោសថ ។ ឯនាងអបរាពិភាល់នឹងភរិយាអ្នកលក់ ទាំងនេះណាស់ ទើបហៅមកបញ្ជាក់ម្ដងទៀតរហូតបានដឹងពី គម្រោងការរបស់អាចារ្យទាំងបួន ក៏យកក្រដាសបកកត់ថ្ងៃខែទាំងបួននាក់ ដោយបញ្ជាក់ថាពិតជាបានទទួលបប្រើពីចៅហ្វាយខ្លួនឲ្យ របស់ទាំងនេះមកប្រាកដមែន ។ ព្រះមហោសថក៏ភៀសខ្លួនលាក់ អាត្មា ។ លុះរំជួលអស់ទេវតាៗ ក៏ចោទប្រស្នាព្រះរាជា ទើបទ្រង់ ភ័យតក់ស្លុតហើយបង្គាប់ឲ្យរកព្រះពោធិសត្វ ដើម្បីដោះស្រាយ ទេវទណ្ឌ ។ ក្រោយពេលព្រះមហោសថគេចបាត់ទៅ អាចារ្យទាំង បួននាក់ចេះតទៅចែចង់នាងអមរា តែត្រូវជាន់គន្លឹយន្តភ្លាត់ធ្លាក់ ចុះរណ្ដៅលាមក នាងក៏ឲ្យគេទាក់កទាញចេញមក រួចយកដុំឥដ្ឋរូស ក្បាលទំពែកឲ្យលាបទឹកបបរ ភ្ជាប់សំឡីស្រហមពេញទាំងខ្លួនទើបនាំទៅថ្វាយព្រះរាជា ។ ប៉ុន្ដែត្រូវព្រះមហោសថសុំដោះលែងឲ្យរួចទោសទាំងអស់គ្នា។

លុះថ្ងៃក្រោយមកទៀត អាចារ្យទាំងបួននាក់គិតចង់ចោទ សួរប្រស្នាស្ទាត់កំបាំង ហើយញុះញង់ព្រះរាជាថាព្រះមហោសថ ចង់ដណ្ដើមរាជបល្ល័ង្គ តែរឿងទាំងអស់នេះត្រូវត្រឡប់ទោសមក អាចារ្យទាំងបួនវិញ ។ ព្រះមហោសថក៏សុំលើកលែងទោស ចាប់ពីពេលនោះមក ព្រះមហោសថ និងភរិយាក៏រស់នៅបាន សេចក្ដីសុខសួស្ដីរៀងទៅ។

ព្រះមហោសថមានសេចក្ដីព្យាយាមរៀបចំពះនគរឲ្យថ្កុំថ្កើងរុងរឿងបរិបូណ៌ដោយភោគសម្បត្តិ ព្រមទាំងចាត់ការការពារ ធ្វើបន្ទាយរាយទ័ពប្រដាប់ដោយកំពែងប្រាំពីរជាន់ គូទឹកប្រាំពីរជាន់មានចិញ្ចឹមក្រពើ មានទ្វារតូចធំគ្រប់ៗមុំមានសស្ត្រាវុធគ្រប់ប្រការ។ ទ្រង់ចិញ្ចឹមសេកសោមបណ្ឌិតឈ្មោះ មាធុរៈដើម្បីឲ្យស៊ើបការណ៍ ស្ដេចទាំង១០១នគរ ក៏បានដឹងថាស្ដេចចុល្លនីព្រហ្មទត្ត នានគរ ឧត្តរបញ្ចាលជាមនុស្សអាក្រក់។

សម័យមួយ ព្រះបាទចុល្លនី និងអាមាត្យកែវដ្ឋព្រាហ្មណ៍ ព្រមទាំងទាហានដប់នាក់នាំគ្នាលើកទ័ពដណ្ដើមនគរតូចៗមក ជាចំណុះ រួចលើកទ័ពមកនគរធំៗទៀត។

ក្រោយពីដឹងដំណឹងនេះ មាធុរសេកក៏មកប្រាប់ព្រះមហោសថ ដើម្បីត្រៀមពលឲ្យចាំការពារ និងបង្កើនគ្រឿងសស្ត្រាវុធ។

លំដាប់ក្រោយមក អាចារ្យកេវដ្ដព្រាហ្មណ៍ និងព្រះបាទ ចុល្លនីដណ្ដើមបាននគរ១០១ជាចំណុះ ហើយលើកទ័ពមកដណ្ដើម យកនគរមិថិលា តែដោយមិនបានសម្រេច បែរជាផ្ញើសារសុំជួប ព្រះហោសថដើម្បីធ្វើធម្មយុទ្ធ ។ តែល្បិចនេះត្រូវបានព្រះមហោ សថដឹងមុន ធ្វើឲ្យពួកសត្រូវបាក់ទ័ពរត់ទៅប្រទេសវាំវិញអស់ ។ ក្រោយពីភ័យក៏រត់ទៅរកអាចារ្យករ ហើយអាចារ្យបានញុះញង់ឲ្យលើកទ័ពមកម្ដងទៀតក៏ត្រូវបរាជ័យទៀត។

មួយឆ្នាំកន្លងផុតទៅអាចារ្យកេវដ្ដព្រាហ្មណ៍ចង់សម្លាប់ព្រះមហោសថ និងព្រះបាទវិទេហរាជ ដោយបញ្ជូននាង បញ្ចូលចន្ទី ថ្វាយចំពោះព្រះរាជា ។ ព្រះមហោសថក៏ជ្រាបរឿងនហើយបញ្ជាឲ្យគេជីកដីឧម្មង្គអស់រយៈពេលបួនខែទើបសម្រេច) ហើយក៏ បាននាំព្រះបាទវិទេហរាជមករៀបអភិសេកថ្វាយព្រះនាងបញ្ចូល ចន្ទី ដោយនាំចុះកាន់នាវា៣០០គ្រឿងចម្លងទៅកាន់ត្រើយម្ខាង ប្រគល់ឲ្យសេនាហែហមបន្ដទៅកាន់នគរមិថិលា។ ព្រះបាទចុល្លនី បានឡោមព័ទ្ធបុរីថ្មីអស់រាត្រីទាំងមូល តែមិនទទួលជោគជ័យ ទើបសុំចុះចាញ់ព្រះមហោសថ ហើយស្បថថាលែងបៀតបៀន ខ្មាតទៅទៀត ។ ស្ដេចចុល្លនីបានថ្វាយរាជសម្បត្តិរបស់ខ្លួនទាំងអស់ ដល់ព្រះមហោសថ ដោយឃាត់មិនឲ្យទៅនគរមិថិលាវិញ ព្រះមហោសថពុំព្រមទទួល ហើយក៏ជូនមកនគរមិថិលាវិញ ។ ភពលោកទាំងមូលបានសន្តិភាព ដោយបញ្ញាបារមីនៃព្រះមហោសថក្នុងកាលនោះឯង ។

ព្រះនាងបញ្ចូលចន្ទីនៅរួមបវេណីជាមួយព្រះបាទវិទេហ ជាបានពីរឆ្នាំ ទ្រង់ប្រសូតបានរាជបុត្រមួយអង្គព្រះរាជបុត្រមានព្រះជន្ម ព្រះបាទវិទេហរាជក៏សោយទិវង្គតទៅ ព្រះមហោសថក៏បាអភិសេកព្រះរាជបុត្រនោះជាព្រះមហាក្សត្ររស់ក្នុងនគរមិលា ហើយព្រះមហោសថតាំងជា

ស្តេចព្រះបរម បិតា ។ ព្រះមហោសថបានលាទៅគង់នៅនគរឧត្តរបញ្ចាល ព្រះ បានចុល្លនី គឺចាត់លំនៅដីសមគួរដល់ព្រមហោសថ

ខណៈពេលគោនាង បរិព្វាជិកា ដែលជាទីរាប់អាននៃព្រះបាទចុល្លនី បានដួជាព្រះមហោសថនាមុខព្រះលាន ។ បន្ទាប់ពីបានចោទសួរ បណ្តះដោយកាយវិការរួចមក ជនទាំងពីរក៏ស្គាល់គ្នាទៅវិញទៅមក ជាតិជាមានប្រាជ្ញាវាងវៃមែន ហើយក៏លាគ្នាទៅ ។ ពួកស្រីស្នំ IIនាក់ដែលនាងននួទេវីតម្រូវឲ្យចាំរំពៃរកទោសព្រះមហោសថក៏មានគំនុំបានទៅទូលព្រះរាជាដើម្បីយកទោស ព្រះមហោសថ ទទួលបរាជ័យ ថែមទាំងបានព្រះរាជាព្រះរាជទានឋានៈ ជាអគ្គមហាសេនាបតី ព្រមទាំងគ្រឿងឥស្សរិយយស និងទ្រព្យជា ច្រើនគណនាដល់ព្រះមហោសថទៀតផង ។ ព្រះមហោសថគិតថា ធម្មតាស្តេចតងតមានឧបាយកលដូច្នេះដើម្បីដឹងថាស្តេចមានភាពស្មោះត្រង់ ឬមិនមានភាពស្មោះ៖ ត្រង់នោះ មហោសថក៏បានទៅជួបនាងភេរី ដោយឲ្យនាងទៅពិសោធដល់ស្តេចចុល្លនី ។ ក្រោយពេលពិសោធចប់ ទើបដឹងថា ស្តេចចុល្លនីនេះមានភាពស្មោះត្រង់ចំពោះមហោសថពិតមែន ។ នាងភេរីបរិព្វាជិកា បានញុំាងកិត្តិសព្ទនៃគុណសម្បត្តិព្រះពោធិសត្វឲ្យខ្ទរខ្ទាឡើងដោយប្រការយ៉ាងនេះ។

### ក.អត្ថន័យខ្លឹមសារ

អត្ថន័យអត្ថ ប្រយោជន៍ អត្ថន័យ ការណែនាំអត្ថាធិប្បាយសេចក្តីពន្យល់ អត្ថន័យជាគំនិតសំខាន់ៗរបស់អ្នកនិពន្ធដែលលាតត្រដាងនៅក្នុងដំណើររឿង ហើយគេអាចហៅវាថាជាជម្រៅនៃរឿង។

ក្នុងផ្នែកអត្ថន័យមាន ប្រធានរឿង មូលបញ្ហារឿងនិងឧត្តមគតិរឿង។

### ខ.ប្រធានរឿង.មូលន័យ.

ប្រធានរឿងឬមូលន័យ គឺជាគំនិតសំខាន់ៗរបស់រឿង។ប្រតិបត្តិ ឬជាបញ្ហារួមរបស់រឿង។តែអ្នកនិពន្ធចង់បង្ហាញដល់អ្នកអានប្រធានរឿងជាបញ្ហារូបផ្តុំបំផុតដែលអ្នកនិពន្ធលើកយកមកសរសេរឬជ្រើសរើសជាប្រធានបទហើយដែលមានមូលបញ្ហារឿងឋិតនៅក្នុងនោះ។

ប្រធានរឿងបង្ហាញនៅចំហររបស់អ្នកនិពន្ធវាជាមូលដ្ឋានដើមរបស់អ្នកនិពន្ធក្នុងការចាប់ផ្តើមសរសេរឡើង។មុនពេលចាប់ផ្តើមសរសេរឡើង ។ អ្នកនេះពាន់គ្រប់ត្រូវកំណត់ថាតើគាត់ត្រូវសរសេរអំពីអ្វី។អំពីជីវិតសង្គមសង្គ្រាមស្នេហារឿងជំងឺទំនេនទម្លាប់ប្រពៃណីចម្លើយរបស់សំណួរនេះហើយជាប្រធានរឿង។រឿងខ្លះប្រធានរឿងស្ថិតនៅលើចំណងជើងរបស់រឿង។

ប្រធានរឿងមហោសថ គឺការកសាងនូវបញ្ញាបារមី របស់ព្រះពោធិសត្វ។

### គ.មូលបញ្ហារឿង

មូលបញ្ហារឿងគឺជាភាពចំណែកនៃប្រធានរឿងជាទិដ្ឋភាពផ្សេងៗ របស់យើង។ វាជាការចូលជ្រៅទៅក្នុងប្រធានរឿង។

ជុំវិញប្រធានរឿងនេះ យើងបានកំណត់បញ្ហាជាច្រើន ដែលនៅជុំវិញការកសាងសិលបារមីរបស់ព្រះពោធិសត្វ បញ្ហាទាំងនោះរួមមាន៖

## បញ្ហាទី១ ការដោះស្រាយលើបញ្ហាទាំង១៩ ដែលមានរូបភាពផ្សេងៗគ្នាដូចខាងក្រោម៖

- ទី១ មំសំ(សាច់)មានសត្វខ្លែងមួយបានឆាបឆក់យកសាច់មួយដុំពីជ្រញអ្នកលក់ហើរផ្លោះ ទៅកាន់អាកាស ហើយក្មេងឃើញក៏រត់ដេញ ខ្លះដួល តែសត្វនោះមិនព្រមទម្លាក់ ព្រះមហោសថ ក៏ឃាត់ក្មេងទាំងនោះ ពេលនោះ មហោសថបានស្ទុះមួយទំហឹងទៅជាន់ស្រមោលសត្វខ្លែងហើយ ស្រែកខ្លាំងៗ ធ្វើឱ្យលកសំឡេងនោះ, ទៅប៉ះនឹង សត្វខ្លែង ហើយធ្វើឱ្យសត្វខ្លែងភ័យក៏ទម្លាក់ដុំសាច់នោះមក។
- ទី២ គោណោ (សត្វគោ) ការដោះស្រាយបញ្ហារវាងបុរសម្ចាស់គោ និងចោរ។ ការប្តឹង គ្នារវាងម្ចាស់គោ និង រ ធ្វើឱ្យព្រះមហោសថចេញមុខដោះស្រាយប្រកបដោយ យុត្តិធម៌ ។

- ទី៣ កណ្ឌិ (សង្វារ) ដោះស្រាយបញ្ហាដោយឱ្យស្ត្រីម្ចាស់សង្វារឈ្នះលើស្ត្រីជាចោរ ។

- ទី៤ សុត្តំ(អំបោះ) មានស្ត្រីម្នាក់រវៃអំបោះដាក់ផ្លែទម្លាប់ខាងក្នុងធ្វើជាហុងអំបោះ ពេលធ្វើដំណើរទៅដល់ ឯស្រះបោក្ខណ៍មួយ ក៏ទុកហុងអំបោះនៅលើសំពត់ ហើយក៏ចុះទៅងូតទឹក ពេលនោះមានស្ត្រីចោរម្នាក់មកលួច ហើយ ម្ចាស់មកទាន់ទាយកវិញ ស្រីចោរមិនព្រមឱ្យរឿងនេះបានដឹងដល់ព្រះមហោសថ ហើយមហោសថបានហៅអ្នក ទាំងពីរមកសួរ តាមដំណើររឿង ពេលដឹងរឿងហើយក៏បានកាត់ក្ដីស្រីជាម្ចាស់ហុងអំបោះឈ្នះ ។

- ទី៥ បុត្ត (កូន) ការដោះស្រាយទៅលើបញ្ហាមានស្រីម្នាក់មានកូនមួយទុកចោល នៅមាត់ស្រះ ហើយចុះ យ ទៅងូតទឹកក្នុងស្រះបោក្ខណ៍ ពេលនោះមានយក្ខមួយប្រែក្រឡា យកកូននោះបំរុងហែកស៊ី ម្ដាយមកទាន់ក៏ដណ្ដើម យក្ខនោះមិនព្រមហើយប្រកែកឮដល់ មហោសថ ហើយមហោសថក៏បានគូសរង្វង់ដាក់កូននោះនៅចំកណ្ដាលឱ្យ ស្រីទាំង២នាក់ នោះដណ្ដើមគ្នា ម្ខាងចាប់ដៃ ម្ខាងចាប់ជើង ម្ដាយពិតជាមានចិត្តអាណិតអាសូរកូនក៏បានលែងទៅ ពេលនោះមហោសថក៏បានដឹង ហើយបង្ហាញនូវស្រីជាយក្ខនោះ ។

- ទី៦ គោជា (បុរសឈ្មោះគោឆកាឡ) មានបុរស និងស្ត្រីជាប្ដីប្រពន្ធនឹងគ្នាបានធ្វើដំណើរទៅលេងស្រុក កំណើតខាងប្ដីទៅដល់មាត់ស្ទឹងមួយមិនហ៊ានឆ្លងពេលនោះមានបុរសម្នាក់មកជួយចម្លង តែការចម្លងនោះយក

ប្រពន្ធទៅមុនហើយក៏បង្ហួសទៅបុរសជាប្ដីខឹងយ៉ាងខ្លាំង ហើយឆ្លងទៅទាន់ក៏ប្រកែកគ្នាដំណឹងនេះ ឮដល់មហោសថ មហោសថក៏បានដោះស្រាយបញ្ហានេះប្រកបដោយយុត្តិធម៌ ។

- ទី៧ រថោ (រទេះ) ការដោះស្រាយទៅលើបញ្ហាការក្រឡាខ្លួនរបស់ព្រះឥន្ទ ទៅលួចរទេះបុរសម្នាក់ ដើម្បី សាកល្បងប្រាជ្ញាព្រះមហោសថ ។ ព្រះមហោសថបានដោះស្រាយ ប្រកបដោយភាពវាងវៃ និងត្រឹមត្រូវ ។

- ទី៨ ទន្ទេ (កំណាត់ឈើ) ព្រះរាជាបានល្បងប្រាជ្ញាមហោសថដោយយកកំណាត់ ឈើឈ្លូសយ៉ាងស្អាត ទៅឱ្យអ្នកស្រុកបាបីនគ្រាមទាយថាខាងណាចុងខាងណាគល់ អ្នកស្រុកពុំដឹង ក៏ទៅពិគ្រោះជាមួយសេដ្ឋី សេដ្ឋីក៏ បានហៅមហោសថមកសួរ ហើយមហោសថ ក៏បានពន្យល់មនុស្សគ្រប់គ្នាឲ្យយល់ ដោយឲ្យយកសូត្រមកចងត្រង់ កណ្ដាលកំណាត់ឈើ នោះទម្លាក់ទឹក ហើយមហោសថប្រាប់ថា “ខាងដែលលិចទឹកមុនជាគល់ ខាងដែលលិចទឹក ក្រោយជាចុង ។

- ទី៩ សីសំ (ក្បាល) ព្រះរាជាពិសោធបញ្ហាមហោសថ ដោយឱ្យយកក្បាល់ខ្មោចប្រុស មួយស្រីមួយឱ្យអ្នក ស្រុកបាចិនគ្រាមទាយអ្នកស្រុកមិនដឹងក៏ទៅសួរមហោសថ ពេលនោះមហោសថ បានបកស្រាយថា លលាដ៍ក្បាល ដែលមានថ្មេរត្រង់ៗ ជាលលាដ៍ក្បាលមនុស្សប្រុស ឯលលាដ៍ ក្បាល មានលក្ខណៈវៀចវិល ជាលលាដ៍ក្បាលមនុស្សស្រី ។

- ទី១០ អហិ ពស់ព្រះរាជាបានបញ្ជូនពស់ឈ្មោលមួយគូទៅឲ្យអ្នកស្រុកបានបាចីនគ្រាមទស្សន៍ទាយអ្នកស្រុកបាចីនគ្រាមមិនស្គាល់ថាណាមួយញីណាមួយឈ្មោលក៏ទៅពគ្រោះជាមួយ មហាសថក៏បានប្រាប់ថាពស់ឈ្មោលក្បាលក្រាស់រាងក្រមឹកភ្នែកធំៗ សង្វារឆ្នូត អន្លាយៗ ឯពស់ញីក្បាលស្ដើងរាង ភ្នឹងភែកតូចសង្វារឆ្នូតៗ។

- ទី១១ កុកដោត មាន់ ព្រះបាទវិទេហរាជបានឲ្យអ្នកស្រុកបើបាចិនគ្រាមបញ្ជូនឧសភមានសម្បុរសសុទ្ធមានស្នែងជើងមានបូរលើក្បាលស្រែករោទ៍មួយថ្ងៃ ៣ដង ឲ្យជាប្រញាប់អ្នកស្រុកមិនស្គាល់ក៏ទៅពីព្រោះជាមួយមហោសថព្រះមហោសថបានប្រាប់ថាឲ្យយកមាន់សឈ្មោលដែលមានដុះផ្ទាក់នាជើង ដុះសិរលើក្បាលរងាវពាដងក្នុងមួយព្រឹកទៅថ្វាយ។

- ទី ១២ មណិ កែវមណី មានកែវមណីមួយដោតសូត្រចូលទៅហើយដាច់យកមិនបាន ព្រះរាជាបានបញ្ជូនទៅឱ្យអ្នកស្រុកបាចិនគ្រាមហូតចេញ ហើយបញ្ជូលសូត្រថ្មី អ្នកស្រុកគ្មានវិធីដោះស្រយបានទៅសួរព្រះមហោសថ បានប្រាប់ឱ្យយកកែវមណី លាបតឹកឃ្មុំលាបទឹកឃ្មុំ ត្រង់រន្ធសងខាងហើយត្របាញ់សូត្រថ្មីលាបទឹកឃ្មុំទៅដាក់បញ្ជូល បន្តិចទៅក្នុងរន្ធ តើបឱ្យតកទៅដាក់ត្រង់រន្ធស្រមោចធុំក្លិនក៏ចូលមកហើយបានខាំទាញសូត្រចេញសូតថ្មីក៏ចេញបាន។

- ទី១៣ វិដានន់ គោឈ្មោលឱ្យបង្កើតកូនមក មហោសថបានដោះស្រាយដោយឱ្យង្អកស្រុកទោយំឱ្យព្រះរាជាជួយព្រះជារាជជួយរឿងអីឪពុកតូលបង្គុំសម្រាលកូនប្រាពីរថ្ងៃហើយតែសម្រាលមិនកើតសោះ ព្រះរាជាថា មិនដែលមនុស្សប្រុងណាដែលមានកូននោះទេ បុរសនោះ

ឆ្លើយថា នើមនុស្សប្រុសអត់មានកូនទេគោឧសភក៏អត់មានកូនដែរប្រះរាជាទល់គំនិតក៏ចាញ់ព្រះបហោសថទៅ។

- ទី១៤ ឱទនំ. បាយ .ស្ដេចបានប្រាប់អ្នកស្រុកបាចីនគ្រាម ចំអិនបាយប្រកបដោយអង្គប្រាំបី ដោយវៀរចាកអង្ករ ទឹក ឆ្នាំង ចង្ក្រាន ភ្លើង អុស មនុស្សប្រុសស្រី ហើយកុំដើរយកតៅតាមផ្លូវ អ្នកស្រុកទៅពិគ្រោះជាមួយមហោសថ ព្រះមហោសថប្រាប់ឱ្យយកចុងអង្ករ ទឹកសន្សើម ភាជន៍ដីថ្មីមិនមែនជាឆ្នាំង ឱ្យចោះគល់ឈើតម្កល់ភាជន៍នោះ ។

- ទី១៥.វាលុកា.ដីខ្សាច់.ស្ដេចបង្គាប់អ្នកស្រុកបាចីនគ្រាម វិញខ្សែរពួរដីខ្សាច់មួយ បញ្ជូនទៅជាវាំង អ្នកស្រុកបានទៅពិគ្រោះជាមួយមហោសថ ព្រះអង្គបានឱ្យរកបុរសពីរនាក់ចេះសម្ដីហើយបង្គាប់ថា អ្នកស្រុកបានតៅក្រាបទូលព្រះរាជាថា សូមទ្រង់មេត្តាប្រោសពួកអ្នកស្រុកពុំដឹងពីទំហំខ្សែរពួរនោះតូចឬធំទេ សូមព្រហអង្គកាត់ខ្សេរពួចាស់ប្រវែងមួយចំអាម យកធ្វើជាគម្រូ ស្ដេចតបថា មិនធ្លាប់មានខ្សែរពួដែលវេញបីដីខ្សាច់ពីកាលណាទេ បើគ្មានម៉េចក៏ព្រះអង្គឱ្យអ្នកស្រុកធ្វើដុចម្ដេចកើត។

- ទី១៦ តឡាកំស្រះ ព្រះរាជាបានបង្គាប់ឱ្យអ្នកស្រុកបាចីនគ្រាមបញ្ជូនស្រះបោក្ខណិ ទៅរាជវាំងដើម្បីក្រសាល អ្នកស្រុកគ្មានមធ្យោបាយទៅសួរមហោសថហៅមនុស្សពីរបីនាក់ដែលមានថ្វីមាត់ កាន់ដំបងនិងខ្សែរពួរចុះទៅមុជទឹកស្រះលេង ឱ្យភ្នែកក្រហមនិងប្រលាក់ភពហើយឡើងទៅទូលស្ដេចថាទូលបង្គំយកទៅធ្វើផ្ដាក់ ទាក់ស្រះនោះមកវិញបាន ស្ដេចមិនធ្លាប់មានស្រះមកពីព្រៃទេ បើមិនមានម្ដេចព្រះអង្គឱ្យអ្នកស្រុកបញ្ជូនស្រះបោក្ខណិថ្វាយម្ដេចកើតទៅ។

- ទី១៧ ឧឡានំ សយនឧទ្យាន ព្រះរាជាបានបង្គាប់ឱ្យបញ្ជូនឧទ្យាថ្មីមានដើមឈើលាស់ខ្ចីទៅរាជវាំង អ្នកស្រុកទៅសួរមហោសថ ព្រះអង្គបានឱ្យរកមនុស្សពីរបីនាក់ឱ្យយកខ្សែរពួរនុងដំបងយកទៅរាវាំងទូលព្រះរាជាថា ខ្ញុំនាំឧទ្យានដ៏ធំមកថ្វាយ ប៉ុន្តែឧទ្យាននោះធ្លាប់តែនៅក្នុងព្រៃ បានឃើញបុរីក៏ផ្អើលដាច់បោលទៅចូលក្នុងព្រៃវិញទៅសូមព្រៃអង្គប្រទានឧទ្យានចាស់ឱ្យទូលបង្គំដើម្បីយកទៅផ្សាំងជាភ្នក់ព្រះរាជាថា មិនធ្លាប់មានទេ អ្នកស្រុកថា បើគ្មានព្រះអង្គឱ្យអ្នកស្រុកយកមកពីណាបាន។

- ទី១៨ កទ្រភោ សគ្វលា អស្សតរព្រះរាជាបាក់ជើង ហើយបង្គប់ឱ្យមហោសថយកអសរតដែលប្រសើរដូចអស្សតរស្ដេចឬប្រសើរជាងទៅថ្វាយ បន្ទាបមកព្រះមហាសថយកសគ្វលាទៅថ្វាយដោយទូលថាអសរតដែរប្រសើរ គឺកើតចេញពីមេសេះអាជានេយ្យនិងបាជា សគ្វលាដូច្នោះសូមព្រះអង្គទុលយកសគ្វលានេះចុះព្រះរាជាក៏យល់ព្រមថែមទាំងយកមហោសថជារាជបុត្ររបស់ព្រះអង្គ។

- ទី១៩ មណិ កែវមណិ មានកែវមណិមួយនៅក្នុងសំបុកក្អែកលើដើមត្នោតក្បែរស្រះបោក្ខណិថាំងរស្មីនៅក្នុងទឹកស្រះព្រះរាជាបានឱ្យអាចារ្យសនកៈយកចេញឱ្យបានតែអាចារ្យកមិនបានព្រះរាជាសួរមហោសថថា យកកែវមណីនោះបានទេព្រះមហោសថទូលថា អាចយកបានបានបង្ហាញដោយឱ្យយកភោជន៍ទឹកមកដាក់នៅក្បែរដើមត្នោតមានពន្លឺចាំងមកក្នុងភោជន៍នោះព្រះមហោសថទូលព្រះរាជាថាកែវមណីនៅលើចុងត្នោតឯនោះ។

សរុបមកការចេះប្រើប្រាស់ប្រាជ្ញ នាំឱ្យបុគ្គលគ្រប់រូបតែងដោះស្រាយរាល់ឧសគ្គនៅចំពោះមុខទទួលបានជោគជ័យ មិនថានៅទីណានោះទេក៏គ្រប់ទីកន្លែងជុបតែភាពជោគជ័យគ្រប់យ៉ាង។

## ទី២បញ្ហាការធ្វើសង្គ្រាមជាមួយប្រទេសជិតខាង

នៅក្នុងការធ្វើសង្គ្រាមជាមួយព្រះរាជាចុល្លនី នៅនគរឧត្តរបញ្ចាល ព្រះមហោសថបានប្រើប្រាជ្ញនៅពេលធ្វើសឹកសង្គ្រាមដែលមានប្រើយុទ្ធវិធីគ្រប់បែបយ៉ាងដើម្បីយកឈ្នះសទៅលើគូរសត្រូវ ។ ព្រះមហោសថបានប្រើឱ្យកសាងកំពែង ជីកស្រះ ជុំវិញចិញ្ចឹមសត្វក្រពើ កសាងមានទ្វាតូចទ្វាធំប្រកបដោយអារុតយុភ័ណ្ឌ ពិសេសបានបញ្ជូនសេកសោមបណ្ឌិតទៅជួយសើបការណ៍ព្រះអង្គបន្ទាប់មកទៀតព្រះមហោសថបានយកឈ្នះលើសត្រូវថែមទៀត។

សរុបមក ការបៀតបៀនអ្នកដ៏ទៃនាំឱ្យខ្លួនវិនាសគ្រប់យ៉ាងហេតុនេះបុគ្គលគ្រប់រូប ត្រូវប្រព្រឹត្តនូវអំពើល្អគ្រប់យ៉ាង ពេលនោះនិងទទួលបានសេចក្ដីសុខក្រៃបៀយ៉ាង។

## ឃ.ឧត្តមគតិរឿងគំនិតដឹកនាំរឿងតម្លៃអប់រំ

ឧត្តមគតិរឿងគឺជាឧត្តមគតិរបស់អ្នកនិពន្ធ។ឧត្តមគតិរឿងគឺយកកត្តាប្រធានវិស័យដែលបញ្ហាដែលបញ្ជាក់ពីគោលជំហរសតិអារម្មណ៍របស់អ្នកនិពន្ធដែលស្តែងឡើងតាមរយៈសកម្មភាពរបស់តួអង្គ។

យើងឃើញថា តាមរយៈសាច់រឿងតាំងមូលបានបង្ហាញកំនិតការចេះប្រើប្រាស់ប្រាជ្ញាជាច្រើនដែលស្តែងមានជាហូហែរមានៈ

- តម្លៃអប់រំ ជួយឱ្យមនុស្សមានសមត្ថិភាពក្នុងការក្នុងការដោះស្រាយបញ្ហាដោយការប្រើប្រាស់ប្រាជ្ញា
- អប់រំធ្វើឱ្យមនុស្សត្រិះរិសគិតបានវែងឆ្ងាយមុននិងធ្វើមួយ
- អប់រំមនុស្សមិនឱ្យមានចរិច្ចរអើតក្រទម
- អប់រំមនុស្សឱ្យចេះគោរពគ្នាទៅវិញទៅមក
- អប់រមមនុស្សឱ្យចេះការពារខ្លួនពីសត្រូវ
- អប់រំមនុស្សឱ្យចេះស្រឡាញ់ប្រទេសជាតិរបស់ខ្លួយន
- អប់រំមនុស្សកុំឱ្យឆាប់ជឿពាក្យអុចអាលរបស់អ្នកដ៏ទៃ
- អប់រំមនុស្សឱ្យចេះសាមគ្គីគ្នា
- អប់រំចំពោះអ្នកដឹកនាំឱ្យចេះស្រឡាញ់សន្តិភាព
- អប់រំមនុស្សមិនឱ្យមានចិត្តលោបលន់
- អប់រំមនុស្សឱ្យប្រកាន់ភ្ជាប់សុចរិចយុត្តិធម៍គ្រប់ស្រទាប់វណ្ណ។

## ខ.តម្លៃអប់រំនៃរឿងមហោសថ

តាមរយៈសាច់រឿងទាំងមូលអ្នកនិពន្ធបានបង្ហាញពីគោលគំនិត កំនិតអប់រំ សំខាន់ៗ ដូចតទៅៈ

នៅពេលព្រះមហោសថនៅក្មេងបានកសាងសាលាឆទានប្រាំខ្នងសម្រាប់ប្រើប្រាស់ដល់ជនទូទៅ អត់មានការរើសអើងបុគ្គលណាមួយឡើយ។ ដូច្នោះចង់បង្ហាញឱ្យមនុស្សនៅក្នុងសង្គមសព្វថ្ងៃ យើងក៍ឃើញមានការកសាងសម្មិតផលជាច្រើននៅក្នុងប្រទេសទាំងឡាយដើម្បីបានជាប្រយោជន៍ ដល់គ្រួសារ សង្គមជាតិ សហគមន៍ ទាំងមូល។ បានបណ្តុះប្រាជ្ញា ឱ្យចេះដោះស្រាយបញ្ហានៅចំពោះមុខ ដោយភាពស្មោះត្រង់ យុត្តិធម៌ចំពោះអ្នកធ្វើល្អ ចំណែកអ្នកធ្វើអំពើអាក្រក់ និងត្រូវតទទួលផលនោះវិញ។ លើសពីនេះកុំឱ្យមានចិត្តបៀតបៀនអ្នកដ៏ទៃនាំឱ្យវិនាសដល់ខ្លួន ដូចដុចព្រាហ្មណ៍ទាំង៤ ។ បន្ទាប់មកពេលបុគ្គលមួយណាបានប្រព្រឹត្តិខុស ត្រូវចេះភ្ញាក់រឭក ទទួលស្គាល់កំហុសខ្លួនដូចនាងយក្សខនីជាដើម។

តាមរយៈសាច់រឿងទាំងមូលអ្នកនិពន្ធបានពីគោលគំនិត តម្លៃអប់រំសំខាន់ៗ ដូចតទៅៈ

សរុបជារួមមក រឿងនេះបានបង្ហាញពី ការប្រើប្រាស់ប្រជ្ញាក្នុងការដោះស្រាយបញ្ហាក្នុងការធ្វើចម្បាំង និងប្រកាន់ភ្ជាប់ភាពស្មោះត្រងត្រឹមត្រូវ។

# សង្ខេបរឿង ភូរិទត្ត

## កច្ឆបកណ្ឌ និងនគរកណ្ឌ

គ្រាកន្លងទៅហើយមានព្រះមហាក្សត្រមួយព្រះអង្គព្រះនាម ព្រហ្មទត្ត សោយរាជ្យនៅនគរពារាណសី មានព្រះរាជបុត្រ មួយអង្គនាម ព្រះចៅព្រហ្មទត្តកុមារ ។ ព្រះរាជបុត្រអង្គនេះចេញទៅ បួសជាតាបសឥសីនៅទៀបស្ទឹងយមុនាក្បែរមាត់សមុទ្រ ។ ព្រះ រាជឥសីនេះបានដាក់ផ្នួស ហើយរួមសង្វាសជាមួយ នាងនាថាមាណវិកា បានបុត្រាមួយនាង សាគព្រហ្មទត្ត និងបុត្រីមួយពនាងសមុទ្ទជា។

លុះព្រះបាទព្រហ្មទត្តចូលទិវង្គតទៅព្រះចៅព្រហ្មទត្តកុមារ ក៏ឡើងគ្រងរាជ្យបន្ត មានឈ្មោះថា កាសិករាជ ហើយទ្រង់យក តែព្រះរាជបុត្រទាំងពីរចូលនគរ ចំណែកនាងនាគមាណវិកាត្រឡប់ ទៅឋានភុជង្គនាគវិញ។ព្រះនាងសមុទ្ទជាបានជាមហេសីនៃព្រះបាទធតរដ្ឋនាគរាជ នាឋានភុជង្គនាគ ដោយហេតុអណ្ដើកសង្កុលដែលលង់ខ្លួនក្នុងឋាន ភុជង្គនាគ កុហកដោះសារថាខ្លួនជារាជទូតព្រះបាទកាសិករាជមក ទូលសុំព្រះបាទធតរដ្ឋទៅនាំយកនាងសមុទ្ទជាបកជាអគ្គមហេសី។ ព្រះបាទកាសិករាជតូចចិត្តក្នុងរឿងនេះ ទ្រង់ក៏ដាក់រាជ្យ ហើយចេញសាងផ្នួស ព្រះអង្គម្ចាស់សាគរព្រហ្មទត្តឡើងសោយរាជ្យបន្ត ។

ព្រះបាទធតរដ្ឋ កាលទ្រង់នាំនាងសមុទ្ទជាមកកាន់នគរនាគទ្រង់ឱ្យពួកនាគទាំងអស់និម្មិតរាងកាយជាមនុស្សអស់កាលជានិច្ច បើនាគណាឱ្យនាងសមុទ្ទជាឃើញរាងកាយខ្លួនជានាគនោះនឹងត្រូវមានរាជទណ្ឌ។

## ឧបោសថកណ្ឌ

ក្រោយមកទៀត ព្រះនាងសមុទ្ទជាបានរួមរស់ជាមួយព្រះ បាទធតរដ្ឋនាគរាជរហូតមានព្រះរាជបុត្របួនព្រះអង្គគឺ សុទស្សន៍ សុភោគ រិដ្ឋ និង ឧត្ត។ ទត្តនាគរាជកុមារជាពុទ្ធង្កូរបណ្ដូលពោធិសត្វមានប្រាជ្ញាអាចដោះស្រាយប្រស្នាដែលគេដោះស្រាយពុំរួច ក្នុងនាគពិភព។ ដោយសារលក្ខណៈបែបនេះហើយព្រះបាទធតរដ្ឋជាបិតាសព្វព្រះទ័យយ៉ាងខ្លាំងចំពោះខេត្តកុមារ កាលស្ដេចទៅ គាល់ព្រះបាទវិរូបក្ខទេវរាជ ទ្រង់យកទត្តកុមារទៅផង។ ទត្តកុមារ បានជួយដោះស្រាយអាថ៌ប្រស្នាថ្វាយស្ដេចទេវតានោះទៀត។ ព្រះបាទវិរូបក្ខជ្រះថ្លាក៏សុំយកទៅគាល់ព្រះឥន្ទ្រាធិរាជ។ ទត្តកុមារ បានជួយដោះស្រាយអាថ៌បស្នាក្នុងឋានតាវតឹង្សទៀត។ ព្រះឥន្ទ្រ ជ៖ថាធ្វើសក្ការបូជាថ្វាយព្រះនាមថែមទៀតថា ភូរិទត្ត ។

ព្រះភូរិទត្តបានឃើញជ័យយន្តប្រាសាទដ៏ដេរដាសដោយ ស្រីទេពអប្សរជាទីមនោរម្យដោយសិរីសម្បត្តិរបស់សម្ដេចព្រះ សហស្សន័យ ក៏ជាប់ព្រះទ័យថាគួរតែកសាងឱ្យបានមកកើតក្នុង ឋានទេវលោក ។ តមកព្រះអង្គបានលាព្រះមាតាបិតាចេញ ទៅរក្សាឧបោសថសីលនាឋានមនុស្សលោក នៅនាដំបូកក្រោម ដើមជ្រៃជិតស្ទឹងយមុនា។ ព្រះអង្គតាំងអធិដ្ឋានបារមីផ្ដោតព្រះទ័យចំពោះឧបោសថសីល ប្រកបដោយអង្គបួនប្រការ គឺតាំងព្រះ ទ័យថា នរណាចង់បានតែស្បែកក្ដី សរសៃក្ដី ឈាមក្ដី ឆ្អឹងក្ដីរបស់ អញ អ្នកនោះចូលមកយកចុះ ឯត្រង់ឧបោសថសីលរបស់អញៗ មិន ព្រមលះបង់នោះទេ។ ទ្រង់អនុញ្ញាតឱ្យភរិយាទាំងឡាយរបស់ព្រះអង្គនាំនាងនាគមាណវិកាជាស្រីរបាំដប់ៗនាក់មកដាក់វេនៗឱ្យយក គ្រឿងតូរ្យតន្ត្រីទៅកាន់សំណាក់ព្រះអង្គធ្វើសក្ការៈចំពោះព្រះអង្គ ដោយផ្កា និងគ្រឿងក្រអូបផ្សេងៗ លេងភ្លេងបូជាហើយនាំពអង្គមកកាន់ភោគពិភពវិញរាល់ៗព្រឹក។ ព្រះអង្គរក្សាសីលតាមទំនង នេះក្នុងទីនោះអស់កាលដ៏យូរអង្វែង ។

## នេសាទកណ្ឌ

គ្រានោះមានព្រាហ្មណ៍នេសាទម្នាក់នៅនគរពារាណសី និងកូនប្រុសម្នាក់ឈ្មោះ សោបទ នាំគ្នាទៅបាញ់សត្វក្នុងព្រៃដើម្បី លក់ចិញ្ចឹមជីវិត។ ពួកគេនាំគ្នាតាមប្រកិតនូវសត្វម្រឹតមួយដែលខ្លួន បាញ់ត្រូវ ហើយបោលទៅទាំងកូនសរ។ ម្រឹគនោះបោលទៅដួលស្លាប់ក្នុងវេលាព្រលប់ក្បែរកន្លែងដែលពោធិសត្វរក្សាសីល ។នាយនេសាទតាមទៅទាន់ឃើញម្រឹតក្បែយក៏ស៊ូនៅក្នុងព្រៃអាស្រ័យដំណេកលើប្រគាបឈើអស់មួយយប់។ ព្រឹកឡើងស្រាប់តែឃើញ ពួកនាងនាគមាណវិកាកាន់ភ្ញីផ្កានិងគ្រឿងតូរ្យតន្ត្រីមកក្នុងទីនោះ ។ ព្រានសម្លួតចុះទៅជិតស្រាប់តបាត់

នាងនាគទាំងអស់នោះទៅ។ ព្រានដើរបន្តិចទៅបានឃើញព្រះពោធិសត្វលើដំបូក។ ព្រះពោធិសត្វកាលបានជ្រាបថា ព្រានឃើញព្រះអង្គហើយ ក៏នឹកថា សេចក្តីអន្តរាយនឹងមាន បើដូច្នេះគួរតែអាត្មាអញនាំពន នេះទៅបំប៉នដោយគ្រឿងសក្ការៈ និងសេចក្តីរាប់អានឯឋានភុជង្គ នាគ ។ គហើយក៏លួងលោមទាំងឪពុកទាំងកូនរហូតដល់ព្រម ទៅ។ ព្រះអង្គឱ្យទៅនៅក្នុងពិមានមួយម្នាក់ ឱ្យស្រីស្នំចាំបមើ ឱ្យ ប្រដាប់ដោយរតន៍ផ្សេងៗជាច្រើន។ដោយបុណ្យព្រេងវាសនារបស់ព្រាហ្មណ៍នេសាទមានតិច តួចបណ្តាលឲ្យចិត្តរបស់គេនឹកឃើញរឿងរ៉ាវអតីតកាលធ្លាប់ដើរបរបាញ់សត្វក្នុងព្រៃ ពេលនោះព្រាហ្មណ៍នេសាទបានចូលទៅ សុំព្រះពោធិសត្វលាមកឋានមនុស្សលោកវិញ ដោយកុហកព្រះះពោធិសត្វថាមកបួស ដោយហេតុព្វថាព្រាហ្មណ៍ចង់បួស ព្រះ អង្គក៏មិនហ៊ានជំទាស់ដែរ ហើយក៏ប្រគល់នូវកែវមណី និងមាស ប្រាក់រតនវត្ថុផ្សេងៗហើយឱ្យជូនត្រឡប់មកវិញ ។ លុះធ្វើដំណើរ ត្រឡប់មកឋានមនុស្សលោកវិញដល់ពាក់កណ្តាលព្រៃក្បែរបឹងមួយបាបកម្មរបស់ព្រាហ្មណ៍នេសាទតាមមកដល់ធ្វើឲ្យគេក្តៅអន្ទះអន្ទែងចង់ងូតទឹកទាំងឪពុកទាំងកូន ក៏ដាក់បង្វេចមាសប្រាក់ និងកែវមណីមាត់ត្រពាំងរួចក៏ចុះទៅងូតទឹក។ ឡើងមកវិញរកវត្ថុទាំងនោះពុំឃើញៗ សំពត់បំណាស កញ្ចាស់ និងផ្នូសរជាសម្បត្តិដើមរបស់ខ្លួនវិញ។ ឪពុកកូនធ្វើដំណើរមកដល់ផ្ទះវិញ កូនរៀបរាប់ ប្រាប់ម្តាយអំពីការបាត់មួយរយៈនេះព្រោះទៅស្ថានភុជង្គនាគ។ ម្តាយសោមទត្តកុមារសួរថា តើកូនបានករមណីទេ? ពេលនោះ កូនប្រាប់ថាពុកមិនយកទេ ព្រោះគាត់ប្រាប់ព្រះពោធិសត្វថាទៅ បួស បានខ្លះមកដែរតែតឡូវជ្រុះបាត់អស់ហើយ។ ប្រពន្ធព្រាហ្មណ៍ នេសាទ កាលបានឮសូរកូននិយាយដូចនោះខឹងប្តីខ្លាំងណាស់ក៏ទៅ សំពងប្តីកំពុងតែដេកលក់ ។ នាយព្រាហ្មណ៍នេសាទ និងកូនត្រូវរត់ ចាកចេញពីផ្ទះទាំងពីរនាក់។

## សោមទត្តកណ្ឌ

កាលនោះមានព្រាហ្មណ៍កម្សត់ម្នាក់ជំពាក់បំណុលគេត្រូវគ ទារខ្លាំងក៏រត់ទៅពួនក្នុងពបានទៅបម្រើមហាឫសីផ្តាប់ផ្គុនដរាបដល់តែលោកប្រទានមន្តអាលម្ពាយ និងទិព្វឱសថដែលស្តេចគ្រុឌប្រទានឱ្យលោក ។

ព្រាហ្មណ៍អាលម្ពាយរើសបានគ្រឿងករមណីពីពួកនាងនាគមាណវិកាឡើងមកលេងឋាន មនុស្សលោក និយាយអំពីនាយព្រាហ្មណ៍នេសាទ និងកូនកាលបានឃើញនាយព្រាហ្មណ៍អាលម្ពាយកាន់កែវមណីនៅជាប់នឹងដៃដូច្នោះ គិតថាកែវមណីជារបស់ ខ្លួន កាលជ្រុះបាត់ពេលចុះមុជទឹកត្រពាំងនោះ។ ដោយហេតុនេះ ហើយទើបនាយព្រាហ្មណ៍នេសាទដេញតាមសុំកែវមណីអំពីព្រាហ្មណ៍អាលម្ពាយ ប៉ុន្តែត្រូវបានអាលម្ពាយមិនឲ្យដូចបំណង នោះទេ ដោយសារតែព្រាហ្មណ៍នេសាទដេញសុំដូចនោះ ក៏ ពោលថាមិនខ្វះទេគ្រឿងកែវមណី ឲ្យតែឯងរកនាគឲ្យយើងបាន មួយគ្រាន់តែឮសូរបែបនោះ ព្រាហ្មណ៍នេសាទអរណាស់ ហើយប្រាប់ទៅកូនសោមទត្តថា ឪពុកនឹងបានកែវមណីមកវិញ ហើយ តែសោមទត្តជាកូនសួរថា តើពុកឯងទៅរកនាគឯណាបានទៅ ឪពុកថា គឺឪនឹងនាំគេទៅជួបព្រះពោធិសត្វ។ ដោយគ្រាន់ត ឮឪពុកនិយាយអំពីព្រះពោធិសត្វ សោមទត្តប្រឆាំងជាមួយឪពុក អំពីរឿងនេះ។ សោមទត្តពន្យល់ប្រាប់អំពីបញ្ហានេះថា ព្រះពោធិសត្វមានបំណងល្អ ធ្វើគុណមកលើយើងច្រើនណាស់ មិនគួរឪពុក ធ្វើបែបនេះឡើយ ។ ម្យ៉ាងវិញទៀតការធ្វើអំពើបែបនេះជាអំពើបច្រើនណាស់សម្រាប់ទៅអនាគតជាតិ ឪពុកតបទៅវិញថា កូនឯងនៅក្មេងណាស់ មិនសូវដឹងរឿងសង្គមច្រើនទេ ។ ទោះជា យ៉ាងណាក៏ដោយ សោមទត្តពុំព្រមយល់ស្របតាមឪពុកវាឡើយ ហើយព្រមទាំងបានសុំបកផ្លូវគ្នាដើរ ។ សោមទត្តកុមារបានលា ឪពុកចេញទៅបួសជាឥសីនៅព្រៃហេមពាន្ត បានសមថឈាន អភិញ្ញា និងសមាបត្តិ បានទៅកើតនៅឋានព្រហ្មលោក។

## សីលកណ្ឌ

ចំណែកព្រាហ្មណ៍នេសាទបាននាំអាលម្ពាយទៅជួបព្រះពោធិសត្វ។ ពេលនោះព្រាហ្មណ៍នេសាទចង្អុលប្រាប់ថា នោះភូមិ ភូទត្តនាគរាជ ចូរអ្នកឯងទៅយកចុះ ថ្កែវមណីមកយើង ព្រះពោធិសត្មើកព្រះនេតជ្រាបច្បាស់អំពីនាយព្រាហ្មណ៍នេសាទនិងអាលម្ពាយនោះ ព្រះពោធិសត្វមិនហ៊ាននឹងបើកព្រះនេតចំ អ្នកទាំងពីរនេះឡើយ ព្រោះអាចបណ្តាលឲ្យឆេះខ្ទេច ព្រោះព្រះអង្គខ្លាចដាច់សីល ហើយបើព្រះអង្គគេច អ្នកទាំងពីរនាក់នេះខឹង នឹងព្រះអង្គ កើតប្រទូស្តរ៉ាយនឹងគ្នា បើដូចនេះគួរអញយកជីវិតដូរ នឹងសីល ទោះបីជាអាលម្ពាយកាត់ខ្លួនអញក្តី ចំអិន

សាច់អញក្តី ឬសម្លាប់អញដោយប្រការណាក្តី ចាក់អញដោយដែកស្រួចឲ្យលំបាក យ៉ាងណាក្តី ក៏អញមិនត្រូវខឹងដែរ។

## អាលម្ពាយកណ្ឌ

នាយព្រាហ្មណ៍អាលម្ពាយ ចូលទៅសកមន្តគាថា ចូលចាប់ កន្ទុយនាគពោធិសត្វគ្រវីក្រវាត់បោកផ្ទប់នឹងផែនដី ហើយដាក់ចូល កន្ទុកយកទៅឃោសនាឱ្យអ្នកស្រុកយកថ្លៃឈ្នួលមកជួលមើល នាគរាំ។ វាបញ្ជាពោធិសត្វឲ្យសម្តែងសិល្បៈសព្វបែបយ៉ាង ឲ្យខ្លួន ធំ ឲ្យតូច ឲ្យបត់ឲ្យលា ឲ្យបើកពពារមួយ ពពារពីរ។ ល ។ តាមការ នឹកឃើញ អាលម្ពាយនាំយកពោធិសត្វយកទៅសម្តែងគ្រប់ស្រុក គ្រប់តំបន់ ដើម្បីលក់សំបុត្រយកប្រាក់បានយ៉ាងច្រើនអស់រយៈ ពេលមួយខែ ។

ចំណែកព្រះចៅក្រុងពារាណសីក៏សព្វព្រះរាជហឫទ័យចង់ ទស្សនានាគរាំក៏អនុញ្ញាតឲ្យអាលម្ពាយនាំពោធិសត្វចូលក្នុងព្រះបរមរាជវាំង ។

## ចិលាបកណ្ឌ

ថ្លែងអំពីព្រះនាងសមុទ្ទជាដែលជាព្រះមាតាភូរិទត្តទ្រង់សុបិននិម្មិតថា មានបុរសសម្បុរខ្មៅ ភ្នែកក្រហម កាត់ព្រះហស្ត ព្រះនាងខាងស្តាំយកទៅបាត់។ ព្រះនាងតើនចាកសយនាសន្និដ្ឋាន ថា ព្រះពោធិសត្វប្រាកដជាមានអន្តរាយជាមិនខាន ។ ដោយពុំ ឃើញព្រះពោធិសត្វត្រឡប់មកពិភពនាគវិញ អ្នកនៅភុជង្គនាគយ៍ បោកខ្លួនសងោកសង្រេងគ្រប់ៗគ្នា។ ព្រះនាងឲ្យព្រះរាជបុត្រច្បងសុទស្សន៍ចាត់ចែងបងប្អូនដើរ ដររកព្រះពោធិសត្វ ។ សុទស្សន៍នាគរាជចាត់ឲ្យអរិដ្ឋនាគរាជទៅ រូបលោក សុភោគទៅព្រៃហេមពាន្ត ឯខ្លួនឯងទៅកាន់ឋានមនុស្សលោកដើម្បីស្វែងរកព្រះភូរិទត្ត។ នាងនាគកញ្ញា អន្ទំបុរី ជា ប្អូនស្រីពោធិសត្វ មានមាតាផ្សេងគ្នាសុំជួយយកអាសារ ទទួចទៅ ជាមួយនឹងសុទស្សន៍ សុទស្សន៍នាគរាជក្លែងភេទជាតសិ នាង អច្ចិមុន្នីក្លែងខ្លួនជាកង្កែបតូច បង្កប់ខ្លួនពួនក្នុងជដានតាបសជាបង ចេញទៅចប្រប់រកក្នុងជ្រោះជ្រុង ដងព្រៃភ្នំ រហូតដល់ស្រុកតូចធំ នានា រហូតដល់ទ្វារនៃក្រុងពារាណសី។

## នាគគវសនកណ្ឌ

ថ្លែងអំពីនាយព្រាហ្មណ៍អាលម្ពាយបាននាំយកនាគពោធិសត្វមកក្នុងរាជវាំងដើម្បីសម្តែងសិល្បៈថ្វាយព្រះមហាក្សត្រទ្រង់ទត ។ ស្តេចសព្វព្រះរាជហឫទ័យយ៉ាងខ្លាំងចំពោះព្រះពោធិសត្វ ។ គ នោះសុទស្សន៍នាគរាជដែលក្លែងភេទជាតសិក៏ចូលទៅក្នុងទីនោះដែរ ហើយរំដោះ៖ភូរិទត្តពីកណ្តាប់ដៃអាលម្ពាយ ឯព្រាហ្មណ៍នោះ៖ ក៏ត្រូវភ្លើងឆេះក្លាយជារោគឃ្លង់សពព្រុះ ។

នាគទាំងបីក៏និម្មិតជាមនុស្ស ហើយថ្វាយការពិតដល់ព្រះ៖ បាទកាសិករាជជាព្រះបិតុលា និងកំណត់ថ្ងៃណាត់ជួបព្រះអយ្យកោ ព្រហ្មទត្តកុមារ) និងព្រះមាតា(សមុទ្ទជា) រួចថ្វាយបង្គំលាទៅពោធិសត្វដល់ពិភពនាគវិញ។

## សុភោគកណ្ឌ

ព្រះពោធិសត្វដល់បិភពនាគវិញមានរាងកាយ ទុរន់ក៏ចូលកាន់គិលានសេល្យា ។ អរិត្រឡប់មកពីឋានទេវលោក វិញបានទទួលឱ្យទៅយាម គិលានដ្ឋាន។ សុភោគទៅព្រះហេមនិពាន្តក៏មិនឃើញដើរដល់ស្ទឹងមិនា។

ថ្លែងពីនាយនេសាទ កាលឃើញអាលម្ពាយកើតឃ្លង់ក៏ខ្លាច ទើបទៅកាន់កំពង់ទឹកជាទីលាងបាបនាស្ទឹងមានភ័យដល់ខ្លួនយមុនា។ សុភោគវណ្ឌជើងអ្នកនេសាទនោះដោយកន្ទុយពន្លិចទៅ ក្នុងទឹក ទោះបីអ្នកនេសាទអង្វរយ៉ាងណាក៏ពុំលែង ដរាបដល់អ្នក នេសាទអួតអាងដល់ជាតិខ្លួនថាជាបុត្ររបស់ព្រព្រហ្ម។ សុភោគ ក៏នាំព្រាហ្មណ៍នោះទៅពិភពនាគដើម្បីជួបព្រះភូរិទត្តជម្រុះក្តីសង្ស័យនេះ ។

## យញ្ញវាទវណ្ណនា និងយញ្ញភេទកណ្ឌ

សុភោគបាននាំព្រាហ្មណ៍ដល់ពិភពនាគ កាណារិដ្ឋ(អរិដ្ឋនាគ) ក៏ហាមសុភោគមិនឲ្យបៀតបៀនព្រាហ្មណ៍ទេ ព្រោះខ្លាចអន្តរាយដល់ពិភពនាគ រួចកាណារិដ្ឋនាគក៏ពិពណ៌នាអំពីមហិទ្ធិឫទ្ធិរបស់ព្រ

ព្រហ្មនិងការបូជាយញ្ញប្រាប់ដល់សុភោគ។ លំដាប់នោះព្រះភូរិទត្ត ពោធិសត្វឮហើយ ព្រះអង្គក៏ចេញមកបដិសេធនឹងការពណ៌នានូវរូវខុសរបស់អរិទ្ឋ ទើបពោលតបពន្យល់អំពីបាបអកុសលនពិធី ឡូយញ្ញ និងបហិច្ចតារបស់ពួកព្រាហ្មណ៍។ ពួកនាគស្ដាប់ហើយ កើតសេចក្ដីជ្រះថ្លា។ មហាសត្តឲ្យនាំព្រាហ្មណ៍នេសាទចេញអំពី ពួកពិភព ឥតបានធ្វើបាបសូម្បីត្រឹមតែការជេរប្រទេចក៏គ្មានដែរ ។

ថ្លែងពីព្រះបាទសាគរព្រហ្មទត្ត លុះដល់ថ្ងៃសន្នតក៏ស្ដេច ទ្រង់ទៅលំនៅនៃមហាឥសីជាព្រះរាជបិតា។ ភូរិទត្តក៏នាំព្រះមាតា ទៅគាល់ព្រះអយ្យកោ និងព្រះបិតុលា។ ក្សត្រទាំងអស់បានជួបជុំគ្នា។

ព្រះនាងសមុទ្ទជាថ្វាយបង្គំព្រះឥសីជាបិតា និងព្រះរាជា ជាព្រះជេដ្ឋាទ្រង់ព្រះកន្សែងសោក ហើយទៅកាន់ពិភពនាគវិញ។ ងព្រះបាទព្រហ្មទត្តសាគរគង់នៅក្នុងទីនោះអស់វេលាពីរបីថ្ងៃទើបទ្រង់និវត្តទៅកាន់នគរពារាណសីវិញ។

ព្រះពោធិសត្វទ្រង់រក្សាសីលដរាបដល់អស់ជីវិតបានទៅកើតក្នុងឋានសួគ៌ជាមួយនាគបរិស័ទដែលប្រតិបត្តិតាម។

## ក.អត្ថន័យខ្លឹមសារ

អត្ថន័យអត្ថ ប្រយោជន៍ អត្ថន័យ ការណែនាំអត្ថាធិប្បាយសេចក្ដីពន្យល់.អត្ថន័យជាគំនិតសំខាន់ៗរបស់អ្នកនិពន្ធដែលលាតត្រដាងនៅក្នុងដំណើររឿង ហើយគេអាចហៅវាថាជាជម្រៅនៃរឿង។

ក្នុងផ្នែកអត្ថន័យមាន ប្រធានរឿង មូលបញ្ហារឿងនិងឧត្តមគតិរឿង។

## ខ.ប្រធានរឿង.មូលន័យ.

ប្រធានរឿងឬមូលន័យ គឺជាគំនិតសំខាន់ៗរបស់រឿង។ប្រតិឬជាបញ្ហារួមរបស់រឿង។តែអ្នកនិពន្ធចង់បង្ហាញដល់អ្នកអានប្រធានរឿងជាបញ្ហារូបផ្តុំបំផុតដែលអ្នកនិពន្ធលើកយកមកសរសេរឬជ្រើសរើសជាប្រធានបទហើយដែលមានមូលបញ្ហារឿងឋិតនៅក្នុងនោះ។

ប្រធានរឿងបង្ហាញនៅចំហររបស់អ្នកនិពន្ធវាជាមូលដ្ឋានដើមរបស់អ្នកនិពន្ធក្នុងការចាប់ផ្តើមសរសេរឡើង។មុនពេលចាប់ផ្តើមសរសេរឡើង។ អ្នកនេះពាន់គ្រប់ត្រូវកំណត់ថាតើគាត់ត្រូវសរសេរអំពីអ្វី។អំពីជីវិតសង្គមសង្គ្រាមស្នេហារឿងជំងឺទំនេនទម្លាប់ប្រពៃណីចម្លើយរបស់សំណួរនេះហើយជាប្រធានរឿង។រឿងខ្លះប្រធានរឿងស្ថិតនៅលើចំណងជើងរបស់រឿង។

ប្រធានរឿងភូរិទត និយាយអំពីការបំពេញសីលបារមីរបស់ប្រះពោធិសត្វ .ភូរិទត. ដើម្បីត្រាសដឹងជាព្រះសម្មាសម្ពុ។

## គ.មូលបញ្ហារឿង

មូលបញ្ហារឿងគឺជាភាពចំណែកនៃប្រធានរឿងជាទិដ្ឋភាពផ្សេងៗរបស់យើង។ វាជាការចូលជ្រៅទៅក្នុងប្រធានរឿង។

## មូលបញ្ហារឿង ភូរិតត

ជុំវិញប្រធានរឿងនេះ យើងបានកំណត់បញ្ហាជាច្រើន ដែលនៅជុំវិញការកសាងសីលបារមីរបស់ព្រះពោធិសត្វ បញ្ហាទាំងនោះរួមមាន៖

- ការបំពេញទានបារមីរបស់ព្រះពោធិសត្វ
- បញ្ហាទ្រឹស្ដីកម្មផល

- ការបំពេញបារមីរបស់ព្រះពោធិសត្វ

### បញ្ហាទី១ ការបំពេញទានបារមីរបស់ព្រះពោធិសត្វ

តាមការវិភាគស្នាដៃរឿងនេះមក យើងឃើញថាបញ្ហាដែលកើតមានដំបូងគឺការបំពេញសីលបារមីព្រះអង្គបានបំពេញបានយ៉ាងខ្ជាប់ខ្ជួន ហើយព្រះអង្គជាអ្នកមាន សមត្ថភាពខ្ពស់ ប្រាជ្ញឈ្លាសវៃលើសគេពុំមានបុគ្គលណាបៀបនិងព្រះអង្គបានឡើយ។ នៅពេលឋាននាគគ្មានអ្នកណាដោះប្រដ្ឋាបាន ព្រះអង្គដោះបាន រហូតទៅដោះប្រដ្ឋាឋានព្រះឥន្ទ្រ ព្រះឥន្ទ្រជ្រះថ្លាបានធ្វើសក្ការៈបូជាហើយថ្វាយព្រះនាមថា ភូរិទត ។ ព្រះភូទតបានមករក្សាសីលនៅឋានមនុស្សនៅក្រោមដំបូកក្រោមដើមជ្រៃជិតស្ទឹងយមុនា ព្រះអង្គផោតព្រះទ័យចំពោះឧបោសថសីល។

សរុបមកបញ្ហាការបំពេញសីលបារមីបានបង្ករឱ្យប្រហពោធិសត្វបានជុបបញ្ហាជាច្រើន សម្រាប់តែបានប្រយោជន៍ដល់ខ្លួននិងមនុស្សជាតិ។

### បញ្ហាទី២ បញ្ហាទ្រឹស្តីកម្មផល

ព្រះពោធិសត្វកាលបានដឹងថា ព្រានពីរនាក់ឪកូនឃើញព្រះអង្គហើយក៏នឹកថាសេចក្តីវិនអន្តាយនិងមានដល់ព្រះអង្គ បើដូច្នោះគួរអាត្មាអញយកព្រាននេះទៅបំប៉នដោយគឿងសក្ការៈ និងសេចក្តីរាប់អាននៅឋានភុជង្គនាគយើយព្រានបានសុំព្រះភូទតថា ឡើងទៅបួសនៅឋានមនុស្សវិញ ហើយព្រះអង្គបានជូនកែវមណី មាសប្រាក់ វត្ថុផ្សេងៗជាច្រើន។ បន្ទាប់មកសោនមទត្តជាកុននិងឪពុកបានចុះងូតទឹកទុកក្បូងនិងមាសប្រាក់នៅលើគោកពេលត្រឡប់មកវិញសល់តែខោអាវរបស់ខ្លួន ដោយហេតុថាបុណ្យគ្មាន។ នៅពេលឪបុកកូនបានឃើញអាលម្ពាយន៍មានកែវមណីចង់បានមកវិញ បាននិយាយនិងកុនថា យើងត្រូវបង្ហាញផ្លូវផៅរទតដល់អាម្ពាយន៍នេហណា ..ទេឪ ! ខុសមនុស្សធម៌ឆ្ងាយណាស់។..កុនតបថាគិតតែខាងបានប៉ុណ្ណោះមិនល្អទេឪ! ព្រោះភូរិទតបានធ្វើសក្ការៈបូជាដល់ឪ ឱ្យទៅនៅសំណាក់ងស្រ័យយ៉ាងនេះហៅថា កល្យាណមិត្តប្រពៃ ..។ នោពេលកូននិយាយប្រាប់ឪពុកថ្វើអំពើអាក្រក់មកលើភូរទតឪពុំយល់ព្រមកូនសុំបេកផ្លូវពីពេលនោះទៅ។

ដូចនេហយើងឃើញថា អក្សរសិល្ប៍ថាបញ្ហាមនុស្សនៅក្នុងសង្គម ហើយថ្វើឱ្យយើងចេះស្វែងរកសេបគប់មិត្តដេលជាកល្យាណមិត្តទើបនាំខ្លួនឱ្យចម្រើន។

### បញ្ហាទី៣ ការបំពេញទានបារមីរបស់ប្រះពោធិសត្វ

នៅក្នុងស្នាដៃអក្សរសិល្ប៍ពុទ្ធនិយម តែងតែលើកយករឿងដែលទាក់ទងនិងសាសនាទាក់ទងនិងជីវភាពរស់នៅរបស់មនុស្សនៅក្នុងសង្គម ។ ហើយព្រះភូរទតបានបំពេញសីលបារមីទោះជួបការលំបាកក៏ព្រះអង្គស៊ូទ្រាំ គ្រប់បែបយ៉ាង។ នាយព្រាហ្មនេសាទជាមនុស្សមានចិត្តលោបលន់ចង់បានអ្វីដែលមិនមែនជារបស់ខ្លួនដើម្បីមកបំពេញដល់ការរស់នៅប្រចាំថ្ងៃធ្វើធ្វើអំពើអាក្រក់មកព្រះអង្គដោយ ការប្រាប់ដល់អាលម្ពាយឱ្យមកធ្វើបាបព្រះអង្គដោយប្រាសចាកគុនធម៌ បំភ្លេចគុណដែលព្រះអង្គជួយខ្លួនទោះដឹងថាព្រាហ្មនេសាទបាននាំអ្នកអាក្រក់មកធ្វើបាបមិនមានការខឹងនោះឡើយ។ព្រាហ្មនេសាទនិង ព្រាហ្មអាម្ពាយបានជួបគ្នាបាននាំទៅជួបព្រះពោធិសត្វ រយចព្រាង្ហបានបរិមន្តចាប់ព្រះអង្គព្រះអង្គមិនតបតនៅពេលគេធ្វើបាបចាប់ព្រះអង្គបោកចេញឈាម យកទៅសម្តែងឱ្យរាំឱ្យង្នកស្រុកមើលយកថ្លៃឈ្នួលពីអ្នកមើល តាំងពីខោអាវហែករហូតមានដល់មានតាំងគឿងអលង្ការ ព្រះមហាក្សត្រចង់មើលនាគរាំបានហៅព្រហ្មយកនាគទៅរាំនៅក្នុងរាជវាំង ទោះព្រហ្មបានធ្វើបែបណាព្រះពោធិសត្វអត់ធ្មតនិងធ្វើតាម។

សរុបមករឿងនេះបានបង្ហាញឱ្យឃើញពីជីវិតរស់នៅរបស់មនុស្ស ធម៌ខន្តីរបស់ព្រះពោធិសត្វក្នុងការរក្សាសីលបារមី មយយវិញទៀតលក្ខណៈរបស់មនុស្សក្នុងសង្គមផងដែរ។

### ឃ.ឧត្តមគតិរឿងគំនិតដឹកនាំរឿងតម្លៃអប់រំ

ឧត្តមគតិរឿងគឺជាឧត្តមគតិរបស់អ្នកនិពន្ធ។ ឧត្តមគតិរឿងគឺយកកត្តាប្រធានវិស័យដែលបញ្ហាដែលបញ្ជាក់ពីគោលជំហរសតិអារម្មណ៍របស់អ្នកនិពន្ធដែលស្តែងឡើងតាមរយៈសកម្មភាពរបស់តួអង្គ។

រឿងភូរិតត្តជាតកអក្សរសិល្ប៍ពុទ្ធនិយមជារឿងបុរាណ បង្ហាញពីរឿងផ្សេងៗរបស់ព្រះពោធិសត្វដើម្បីបំពេញសីលបារមីរបស់ព្រះអង្គ។ឆ្លងតាមរយៈការសិក្សារឿងនេះមកបានបង្ហាញឧត្តមគតិអប់រំដូចជា ៖

- តម្លៃអប់រំមនុស្សមិនឱ្យមានចិត្តលោភលន់រិះកិតឱ្យបានវែងឆ្ងាយ
- តម្លៃអប់រំចេះតស៊ូព្យាយាមគ្រប់កាលៈទេសៈ
- តម្លៃអប់រំតម្លៃអប់រំមនុស្សឱ្យចេះជួយគ្នានៅពេលមានអសន្ន
- តម្លៃអប់រំមនុស្សចេះអធ្យាស្រ័យដល់គ្នា
- តម្លៃអប់រំមនុស្សរស់នៅដោយមិនប្រកាន់វណ្ណៈរើសអើងគ្នា
- តម្លៃអប់រំមនុស្សឱ្យជឿលកកម្មផល
- តម្លៃអប់រំមនុស្សចេះរស់នៅស្មើរភាពគ្នាដោយមិនបៀតបៀនគ្នា
- តម្លៃអប់រំមនុស្សចេះមិនប្រើអំពើហឹង្សា
- តម្លៃអប់រំមនុស្សធ្វើអំពើល្អទាំងកាយ វិចាចិត្ត
- តម្លៃអប់រំមនុស្សមិនភ្លេចគុណអ្នកដែលបានធ្វើអំពើល្អមកលើខ្លួន។

## ខ.វិភាគតម្លៃអប់រំនៃរឿង

តាមរយៈសាច់រឿងទាំងមូលអ្នកនិពន្ធបានបង្ហាញពីគោលគំនិត កំនិតអប់រំ សំខាន់ៗ ដូចតទៅៈ

នៅពេលព្រះភូរិទត្តបានកាន់សិល នៅឋានមនុស្សបានទទួលរងនូវក្តីលំបាកគ្រប់យ៉ាងដោយព្រាហ្មណ៍បានធ្វើបាប ការវាយដុំ ការឱ្យសម្តែងការរាំការប្រើឱ្យធ្វើអ្វីៗ គ្រប់យ៉ាងតាមចិត្តព្រាហ្មណ៍។ នៅត្រង់ចំនុចនេះបានបង្ហាញថា មនុស្សគ្រប់រូបត្រូវចេះរក្សាធម៌ខន្តីក្នុងការរស់នៅ ចេះយោគយល់អធ្យាស្រ័យគ្នា ។ នៅពេលដែលមានអ្នកដទៃបានប្រព្រឹត្តិអំពើមិនល្អមកលើខ្លួន ឱ្យចេះយកធម៌ខន្តីខំតស៊ូអត់ធ្មត់ព្យាយាមងធ្យាស្រ័យឱ្យគ្នាដោយមិនបានការតបតពៀររងាប់ដោយការមិនដងពារ ដូចព្រះភូរិទត្ត ។ មួយវិញទៀតបានអប់រំឱ្យចេះជួយគ្នាទៅវិញទៅមកដូច។ រីឯនៅក្នុងសង្គមសព្វថ្ងៃវិញ យើងក៏បានឃើញមានការចេះជួគ្នានៅពេលបុគ្គលណាមួយបានជួបទុក្ខលំបាក តែងមានការជួយគ្នាទៅវិញទៅនូវវត្ថុគ្រប់យ៉ាង។

សរុបជារួមមក យើងឃើញថា រឿងអក្សរសិល្ប៍ខ្មែរភូរិទត្តបានឆ្លុះបញ្ចាំងឱ្យឃើញពីការអត់ធ្មតព្យាយាម ពីចំណេះដឹង សមត្ថភាពទេពកោសលរបស់អ្នកប្រជ្ញ គ្រប់ជំនាន់ បង្កប់ទស្សនៈវិស័យ ចក្ខុវិស័យ ល្អថ្លៃថ្លាសម្រាប់សង្គមជាតិ។

# សង្ខេបរឿង ចន្ទកុមារ

កាលកន្លងទៅមានព្រះរាជបុត្រព្រះបាទ វសវត្តី ព្រះ នាមព្រះបាទ ឯករាជ្យសោយរាជ្យនានគរបុប្ផវតី មានរាជបុត ព្រះនាម ចន្ទកុមារ ជាឧបរាជ។ កណ្ឌហាលព្រាហ្មណ៍ ជាអ្នក បង្រៀនប្រដៅអត្ថ និងធម៌ កណ្ឌហាលព្រាហ្មណ៍កាន់តំណែង ខាងវិនិច្ឆ័យតែងស៊ីសំណូកហើយកាត់ក្ដីដោយអយុត្តិធម៌ ។ ថ្ងៃមួយ មានអ្នកចាញ់ក្ដីទៅទូលរឿងរបស់ខ្លួនដល់ព្រះចន្ទកុមារៗបានយក សំណុំរឿងមកពិនិត្យ ហើយកាត់សេចក្ដីតាមគតិយុត្តិធម៌ ព្រះរាជាទ្រង់ជ្រាបរឿងនេះ ព្រះអង្គបានដកហូតតំណែងកណ្ឌហាព្រាហ្មណ៍ ហើយតែងតាំងព្រះចន្ទកុមារជាអ្នកវិនិច្ឆ័យវិញ។ រឿង នេះធ្វើឲ្យកណ្ឌហាលមានការគុំគួន គិតផ្ដន្ទាជាមួយព្រះចន្ទកុមារជានិច្ច។

ថ្ងៃមួយព្រះបាទឯករាជទ្រង់សុបិននិមិ្មតឃើញបានទៅស្ថាន ត្រៃត្រឹង្ស ហើយចង់ទៅកើតនៅឋានសួគ៍នោះ ទើបសួរទៅកាន់កណ្ឌហាលព្រាហ្មណ៍ថា “តើខ្ញុំត្រូវធ្វើបុណ្យដូចម្ដេចទើបទៅកើត នៅឋានត្រៃត្រឹង្ស ចូរអ្នកប្រាប់ខ្ញុំឲ្យធ្វើឲ្យខាងតែបានទៅកើតដូចប្រាថ្នា” ។

កណ្ឌហាលព្រាហ្មណ៍ទូលថា “សូមទ្រង់ព្រះមេត្តាប្រោស ជនទាំងឡាយឲ្យទានដ៏ក្រៃលែងសម្លាប់នូវបុគ្គលដែលមិនគួរ សម្លាប់ ទើបបានទៅកើតឯស្ថានសួគ៌ ព្រះអង្គគប្បីបូជាយញ្ញ “ដោយបុត្រទាំងឡាយ ៤ ព្រះអគ្គមហេសីទាំងឡាយ៤ សេដ្ឋីទាំង ថា ឡាយ៤ គោឧសភរាជទាំងឡាយ៤សេះអាជានេយ្យទាំងឡាយ៤ ថ ហើយនិងសត្វទាំងឡាយមួយមុខៗសុទ្ធតែ៤ៗទើបបានទៅកើតឯ

ឋានសួគ៌” ។

បន្ទាប់មកព្រះរាជាទ្រង់បានចេញរាជបញ្ជាឲ្យទៅចាប់រាជ កុមារទាំងឡាយមាន ចន្ទកុមារ សុរិយកុមារ ភទ្ទសេនកុមារ សុរកុមារ និង រាមគោត្តកុមារ កុមារីទាំងឡាយមាន នាងឧប- សេនា នាងកោកិលា នាងមុទិតា និង នាងនន្ទ មហេសីទាំង ឡាយមាន នាងវិជយានាងឯរាវតី នាងកេសិនី និង នាង សុនន្ទ គហបតីទាំងឡាយមាន បុណ្ណមុខ ភទ្ទិយ លិង្គលនិង វឌ្ឍ ព្រមទាំងសត្វដែលមានឈ្មោះល្បីក្នុងព្រះនគរផង ដើម្បីជា ប្រយោជន៍ដល់ការបូជាយញ្ញ សូរសម្រែកដ៏គួរឲ្យខ្លោចផ្សានៃមនុស្សប្រុសស្រី ចាប់ផ្ដើមឮឡើងពេញរាជបូរី។

មាតា និងព្រះបិតាព្រះបាទឯករាជទ្រង់ឃាត់ថា “ម្នាលកូនអើយ អ្នកកុំជឿកណ្ឌហាលព្រាហ្មណ៍ថាសុគតិបានដល់ការបូជាបុត្តភរិយាជាដើមយ៉ាងនេះឡើយ ផ្លូវហ្នឹងជាផ្លូវទៅកាន់នរក ចូរ អ្នកឲ្យទានដល់សមណៈជីព្រាហ្មណ៍វិញ ទើបជាផ្លូវនៃសុគតិភព”។

ព្រះចន្ទកុមារអង្វរថា “បពិត្រព្រះបិតា សូមទ្រង់កុំសម្លាប់ ទូលព្រះបង្គំជាខ្ញុំទាំងឡាយឡើយ សូមព្រះអង្គព្រះរាជទានទូល បង្គំជាខ្ញុំទាំងឡាយឲ្យជាទាសកនៃកណ្ឌហាលព្រាហ្មណ៍ ឬក៏បំបរ បង់ចាកព្រះនគរក៏បាន” ។

ព្រះបាទឯករាជទ្រង់តបថា “អ្នកទាំងឡាយបង្កើតទុក្ខដល់ យើង យំស្រែកព្រោះចង់បានជីវិត ចូរអ្នកលែងកុមារទាំងឡាយ ទៅ ការបូជាយញ្ញដោយកូនល្មមលើកលែង” ។ ប៉ុន្តែកណ្ឌហាល ព្រាហ្មណ៍ទូលថា “ការបូជាយញ្ញជាអំពើធ្វើបានដោយកម្ម ជន ទាំងឡាយណាបូជាដោយខ្លួនឯងក្ដី ឲ្យគេបូជាក្ដី ឬគ្រាន់តែអនុមោទនាតាមការបូជាមហាយក្ដី ក៏រមែងទៅកាន់សុគតិភពដែរ” ។

ព្រះចន្ទកុមារបានតវ៉ាដោយលើកយករឿងពីកុមាររហូតដល់ពេញកំលោះថា ឥតមានទោសកំហុសសោះ និងជាមនុស្ស ពាក់គ្រឿងក្រោះ ជិះសេះ ជិះដំរី ទៅច្បាំងជាមួយបច្ចាមិត្រ ពុំមែនសម្រាប់បូជាយញ្ញទេ ។

ព្រះរាជាទ្រង់លើកលែងការបូជាយញ្ញ ប៉ុន្តែកណ្ឌហាលរាហ្មណ៍នៅតែទទូចទាមទារដដែលៗ ហើយព្រះចន្ទកុមារបានកើតនៅឋានទេវលោកបណ្ឌហាលព្រាហ្មណ៍គប្បីបូជាកូន គាត់មុនចុះ សឹមបូជាខ្ញុំជាក្រោយ” ពេលនោះកណ្ឌហាល ព្រាហ្មណ៍ហាក់ដូចជាតាំងមួយស្របក់ ។ វសុលរាជកុមារ និងសលា រាជកុមារីបម្រះនទៀល និងទូលអង្វរទៅព្រះរាជាជាអយ្យកោថា”សូមព្រះអង្គកុំសម្លាប់ព្រះបិតាខ្ញុំព្រះអង្គឡើយព្រោះខ្ញុំព្រះអង្គ នៅក្មេង” ព្រះរាជាក៏ឲ្យលើកលែងការបូជាយញ្ញទៀត ប៉ុន្ត កណ្ឌហាលទូលឲ្យព្រះរាជាយាងចេញទៅ ទុកខ្លួនជាអ្នកទទួលខុស ត្រូវចំពោះពិធីនេះ ដោយឲ្យព្រះរាជាចារិករាយនៅស្ថានសួគ៌ចុះ ហើយឲ្យយកចន្ទកុមារ និងសុរិយកុមារនៅកាន់កន្លែងបូជាយញ្ញមុនគេ ។

ព្រះនាងគោត្តមីទេវី ជាព្រះមាតាព្រះចន្ទកុមារបានបម ននៀលទៀបបាទាព្រះរាជាទូល ថា “ខ្ញុំម្ចាស់ជាស្ត្រីឆ្កួត សាបសូន្យ ចាកសេចក្ដីចម្រើន ប្រឡាក់ប្រឡូសដោយធូលីដី ឬបែក ធ្លាយនូវ ជីវិតឥន្ទ្រីយ៍ បើគេសម្លាប់ចន្ទកុមារ និងសុរិយកុមារ ហើយក៏ ដួលសន្លប់បាត់ស្មារតី។ ព្រះចន្ទកុមារស្ទុះមកឱបមាតាសោយសោក ថា “បពិត្រព្រះមាតា ព្រះអង្គបានបង្កើតបុត មានទុក្ខព្រួយច្រើន ព្រោះតែការចិញ្ចឹមខ្ញុំជាកូន ខ្ញុំសូមលាព្រះមាតាទៅកាន់ទីស្លាប់ដើម្បីព្រះ បិតាទៅកាន់ស្ថានសួគ៌ ហើយសូមព្រះមាតាអនុញ្ញាតឲ្យ ខ្ញុំថ្វាយបង្គំព្រះមាតាទៅកាន់ទីព្រាត់ ប្រាស”។ ព្រះនាងចន្ទាទេវីជា មហេសីចន្ទកុមារបានប្រហារខ្លួនឯងដោយបាតដៃទាំងពីរ ហើយផឹកថ្នាំពិសឲ្យស្លាប់ ។ ក្នុងគ្រាដែលព្រះចន្ទកុមារ និងសុរិយកុមារ រៀបត្រូវប្រហារដើម្បី បូជាយញ្ញ ព្រះនាងចន្ទាបញ្ចូលរាជធីតាបាន ស្ទុះចូលតាមចន្លោះពួកបរិស័ទ ហើយស្រែក ប្រកាសថា “កណ្ឌហាលព្រាហ្មណ៍ជាមនុស្សអាក្រក់យល់ខុសធ្វើបាបកម្ម ខ្ញុំសូមស្លាប់ជាមួយព្រះ ស្វាមី និងសូមឲ្យពួកអមនុស្សជួយធ្វើសេចក្ដីខ្វល់ខ្វាយចំពោះមនុស្សដែលត្រូវពួកបច្ចាមិត្រ ផ្ចាញ់” ។ ព្រះឥន្ទ្រាធិរាជទ្រង់សណ្ដាប់ហើយក៏គ្រវីដែកស្រែកគម្រាមព្រះបាទឯករាជថា““ម្នាល ស្ដេចកាឡកណ្ណិអប្រិយលាមក អញនឹងសំពងក្បាលឥឡូវ ឯងមាន ដែលឃើញពីអង្កាល់អ្នក ដែលសម្លាប់បុត្រ មហេសី សេដ្ឋី គហ- បតី ព្រោះប្រាថ្នាឋានសួគ៌នោះ”។ រំពេចនោះព្រះរាជា និង កណ្ឌ- ហាលព្រាហ្មណ៍បានស្ទុះទៅស្រាយចំណងជនទាំងនោះ ។ ជនទាំង នោះរួចពីចំណងហើយ ក៏នាំគ្នាយកដុំដីគប់កណ្ឌហាលព្រាហ្មណ៍ រហូតដល់ស្លាប់ ទៅកើតនៅឋាននរកទៅ។

កពួករាជបុរស រាជសនាបតី នាម៉ឺនសព្វមុខមន្ត្រី សី ស្នំស្រីង្គារ រាជកញ្ញាបានចាត់ការ ធ្វើពិធីរាជាភិសេក លើកស្វេតច្ឆ័ត្រថ្វាយព្រះចន្ទកុមារ។ ព្រះចន្ទកុមារសោយរាជ្យប្រកបដោយ ធម៌ ទ្រង់ត្រេកអរតែក្នុងការបរិច្ចាគទានដរាបដល់អវសាននជីវិតទៅកើតក្នុងស្ថានសួគ៌ទេវ លោកហោង។

## ក.អត្ថន័យខ្លឹមសារ

អត្ថន័យអត្ថ .ប្រយោជន៍.អត្ថន័យ .ការណែនាំអត្ថាធិប្បាយសេចក្ដីពន្យល់.អត្ថន័យជា គំនិតសំខាន់ៗរបស់អ្នកនិពន្ធដែលលាតត្រដាងនៅក្នុងដំណើររឿង ហើយគេអាចហៅវាថាជា ជម្រៅនៃរឿង។

ក្នុងផ្នែកអត្ថន័យមាន ប្រធានរឿង មូលបញ្ហារឿងនិងឧត្ដមគតិរឿង។

## ខ. ប្រធានរឿង

ប្រធានរឿងឬមូលន័យ គឺជាគំនិតសំខាន់ៗរបស់រឿង។ប្រតិឬជាបញ្ហារួមរបស់រឿង។តែ អ្នកនិពន្ធចង់បង្ហាញដល់អ្នកអានប្រធានរឿងជាបញ្ហារួបផ្តុំបំផុតដែលអ្នកនិពន្ធលើកយក មកសរសេរឬជ្រើសរើសជាប្រធានបទហើយដែលមានមូលបញ្ហារឿងឋិតនៅក្នុងនោះ។

ប្រធានរឿងបង្ហាញនៅចំហររបស់អ្នកនិពន្ធវាជាមូលដ្ឋានដើមរបស់អ្នកនិពន្ធក្នុង ការចាប់ផ្តើមសរសេរឡើង។មុនពេលចាប់ផ្តើមសរសេរឡើង។អ្នកនេះពាន់គ្រប់ត្រូវកំណត់ថា តើគាត់ត្រូវសរសេរអំពីអ្វី។អំពីជីវិតសង្គមសង្គ្រាមស្នេហារឿងជំងឺទំនេនទម្លាប់ប្រពៃណី ចម្លើយរបស់សំណួរនេះហើយជាប្រធានរឿង។រឿងខ្លះប្រធានរឿងស្ថិតនៅលើចំណងជើងរបស់ រឿង។

ក្នុងរឿងចន្ទកុមារនេះគឺ”ការបំពេញបារមី(ខន្តីបារមី)របស់ព្រះពោធិសត្វ”។

## គ. មូលបញ្ហារឿង

មូលបញ្ហារឿងគឺជាភាពចំណែកនៃប្រធានរឿងជាទិដ្ឋភាពផ្សេងៗរបស់យើង។វាជាការ ចូលជ្រៅទៅក្នុងប្រធានរឿង។

មូលបញ្ហាក្នុងរឿងនេះ និយាយពីទំនាស់ដែលកើតចេញពីការគុំគួន តាមព្យាបាទព្រះ ចន្ទកុមាររបស់ កណ្ឌហាលព្រាហ្មណ៍ តាមព្យាបាទព្រះចន្ទកុមារ ។នៅក្នុងដំណើររឿងនេះ បាន រៀបរាប់ពីការចង់បានរបស់ព្រះបាទឯករាជាព្រះបិតារបស់ចន្ទកុមារដែល ទៅកើតនៅស្ថាន សួគ៌ទើបប្រឹក្សាជាមួយកណ្ឌហាលព្រាហ្មណ៍។ ព្រះចន្ទកុមារ តាមទាន់ការកាត់ក្ដីដោយអយុត្តិធ ម៌កណ្ឌហាលបានស៊ីសំណូកទ្រង់ក៏សើរើកាត់ក្តីជាថ្មី យុត្តិធម៌ ព្រះរាជាទ្រង់ជ្រាបរឿងនេះ ក៏ដក សេចក្ដីទុកចិត្តពីកណ្ឌហាលព្រាហ្មណ៍ ដែលធ្វើឱ្យព្រាហ្មណ៍ ការខាតបង់លាភសក្ការៈ។

## បញ្ហាទី១ ការចងគំនុំរបស់កណ្ឌហាលព្រាហ្មណ៍ចំពោះព្រះចន្ទកុមារ

ទំនាស់ផ្ដើមចេញដំបូងគឺដោយសារតែកណ្ឌហាលព្រាហ្មណ៍ជាបុគ្គលមានចិត្តលោភ ប្រព្រឹត្តិទុក្ខ ស៊ីសំណូករួចវិនិច្ឆ័យដោយអយុត្តិធម៍។ ដោយមូលហេតុនេះ ធ្វើឲ្យអ្នកចាញ់ក្ដីមានសេចក្ដីក្ដៅក្រហាយ បានទូលរឿងរ៉ាវដល់ព្រះចន្ទកុមារ ទ្រង់ក៏វិនិច្ឆ័យរឿងក្ដីសារជាថ្មី។ កណ្ឌហាល ត្រូវបាត់បង់មុខតំណែង និង លាភសក្ការៈ ក៏ចេះតែមានចិត្តគុំគួនគួចចង់សងសឹកនឹងព្រះចន្ទកុមារជានិច្ច។

ឧទាហរណ៍៖ “កណ្ឌហាលព្រាហ្មណ៍នោះកាន់តំណែងខាងការវិនិច្ឆ័យផង គាត់តែងស៊ីសំណូកធ្វើម្ចាស់ ឱ្យ មិនមែនជាម្ចាស់វិញលអាក្រក់របស់កណ្ឌហាលព្រាហ្មណ៍ក៏ដាច់រលត់ទៅ បានជាព្រាហ្មណ៍កើតក្ដីមួម៉ៅគេ ផ្ដន្ទាព្រះចន្ទកុមារ”។

## បញ្ហាទី២ ការសុបិនរបស់ព្រះបាទឯករាជ

ព្រះបាទឯករាជទ្រង់សុបិននិមិត្តឃើញឋានត្រៃត្រឹង្ស ក៏មានព្រះទ័យចង់ទៅកើតសោយសុខនាស្ថាននោះ។ ព្រះអង្គទ្រង់ទៅពិភាក្សាជាមួយកណ្ឌហាលព្រាហ្មណ៍ ពីរឿងថា តើត្រូវធ្វើយ៉ាងណាដើម្បីបានទៅកើតនៅស្ថានសួគ៍ កណ្ឌហាលព្រាហ្មណ៍ទូលថា “សូមទ្រង់ព្រះមេត្តាប្រោស ជនទាំងឡាយឲ្យទានដ៏ក្រៃលែង សម្លាប់នូវបុគ្គលដែលមិនគួរ សម្លាប់ ទើបបានទៅកើតឯស្ថានសួគ៍។ ព្រះអង្គគប្បីបូជាយញ្ញ ដោយបុត្រទាំងឡាយ ៤ ព្រះអគ្គមហេសីទាំងឡាយ៤. សេដ្ឋីទាំង ឡាយ៤ គោឧសភរាជទាំងឡាយ៤ សេះអាជានេយ្យទាំងឡាយ៤ ហើយនិងសត្វទាំងឡាយមួយមុខៗសុទ្ធត៤ៗ ទើបបានទៅកើតឯឋានសួគ៍”ហើយព្រះបាទឯករាជក៏ធ្វើតាមដោយមិនបានគិតពិតពិចារណាអ្វីទាំងអស់។

សរុបមកការជឿដោយគមានការគិតពិចារណា បានទ្វើឱ្យខ្លួនមានកំហុស និងនាំឱ្យខ្លួនជូបទយកទោសមុននិងជឿទៅលើរឿងអ្វីមួយចេះគិតឱ្យបានវែងឆ្ងាយ។

## ទី៣ បញ្ហា ការបូជាយញ្ញរបស់ព្រះបាទឯករាជ

ព្រះបាទឯករាជជាមនុស្សខ្វះការរិះគិតពិចារណាមុនពេលសម្រេចចិត្តធ្វើអ្វីមួយដោយការចង់ទៅកើតនៅឋានសួរគ៌របស់ព្រះអង្គ បានជឿតាមកំនិតអាក្រក់ហួសហេតុ ពាក្យញួសញ៉ង បំបែកបំបាក់គ្រួសារក៏ព្រះអង្គធ្វើតាមព្រហ្មទាំងអស់ ។ ទោះព្រហ្មបង្គាប់ឱ្យធ្វើអ្វីព្រះបាឯករាជតាមដើម្បីបានទៅកើតនៅឋានត្រៃត្រឹង ។ នៅពេលនោះដែរព្រះអង្គបានចញ្ជាក់ឱ្យគេចាប់យកបុត្រ មហេសី សេដ្ឋី គោឧសភរាជ សេះអាជាអានេយ្យ ដំរីរាជ គឺចំណួន៤ៗក្នុងមួយមុខ។ ព្រះចន្ទកុមារត្រូវគេយកទៅបូជាយញ្ញ ជាមួយមនុស្ស និងសត្វជាច្រើន។ព្រះរាជកុមារបានទូលសុំអង្វរព្រះបិតា សុខចិត្តធ្វើជាទាសៈព្រហ្ម នារទេសចេញពីនគរ និងដើរសុំទានគេក៏ព្រះរាជកុមារសុខចិត្ត។ បេលនោះការង្វរកររបស់ព្រចន្ទកុមារបានធ្វើឱ្យព្រះបាទឯករាជទន់ចិត្តអាណិតអាសូរព្រមក៨បញ្ជាឱ្យឈប់ហើយ ក៏កហាលព្រហ្មណ៍ នៅតែតវ៉ាទទូចសុំព្រះបាទឯករាជនៅតែធ្វើតាមព្រហ្មណ៍ទៀត។ ព្រះចន្ទកុមារបាននិយាយពន្យល់ព្រះបិតា គ្រប់បែបយ៉ាងថា ការធ្វើទង្វើទាំងអស់នេះមិនមែននាំព្រះបិតាទៅកាន់ឋានសួគ៍ទេអំពើនេះជាអំពើអាក្រក់អកុសលកម្ម ដេលនិងនាំព្រះបិតាទៅកាន់ឋាននរកទៅវិញទេ។ ប៉ុន្តែកកណ្ឌហាលព្រហ្មណ៍ នៅតែតវ៉ាដ៏ដែល ។ ពេលនោះទំនាស់កាន់តែកើតមានឡើងកាន់តែខ្លាំង។ ចំណែកព្រះនាងចន្ទទេវីសម្រេចចិត្តសម្លាប់ខ្លួនតាមព្រះស្វាមី និងបួងសួងឱ្យពួកអមនុស្សទេវតា ជួយតាមថែរក្សាព្រះនាងនិងប្រះស្វាមីផង។ បន្ថែមពីនេះ ព្រះមាតានៃព្រះបាទឯករាជនិងប្រះបាទវសវតីជាព្រះបិតាទ្រង់យត់ថា ម្នាលកូន ! អ្នកកុំជឿកហាលព្រហ្មណ៍ ...ផ្លូវនិងនាំកុនទៅកាន់នរកទេកុន។ ព្រះចន្ទកុមារក៏បានទូលអង្វរទៅកាន់ប្រះបិតាម្ដងទៀតដែលថា ... បណិត្រព្រះមិតាសូមព្រះអង្គកុំសម្លាប់ទូលព្រះបង្គំជាខ្ញុំឡើយ សូមព្រះអង្គរាជទានទូលបង្គំខ្ញុំទាំងឡាយជាទាសៈនៃកហាលពក្រម្មណ៍ចុះ ...ទូលបង្គំជាខ្ញុំទាំងឡាយសុខចិត្តដើរសុំទានគេចិញ្ចឹមជីវិតផលដែរ។ ការ ការស្រែកសុំជំនួយមានសម្រែស្រែកយំរបស់មនុស្សទាំងឡាយនិងការបួងសួងរបស់ព្រះនាងចន្ទាទេវីបានធ្វើឱ្យក្ដៅក្រហាយដល់ព្រះឥន្ទ្រាធិរាជ សកទេវរាជបានក្រវីដំបងដែកហើយស្រែកគម្រាមព្រះបាទឯករាជ កមឱ្យសម្លាប់ព្រះបាទចន្ទកុមារដែលជាមនុស្សប្រកបដោយសច្ចៈធម៍និងគុណធម៍យ៉ាងវិសេសវិសាលឱ្យសោះ។ ខណៈនោះបានធ្វើឱ្យព្រះបាទឯករាជនិងកហាលព្រហ្មណ៍មានការភិតភ័យជាខ្លាំង ហើយទ្រង់បានបញ្ជាឱ្យគេដោះលែងព្រះចន្ទកុមារ មនុស្ស និងសត្វផលដែរ។ចុងបញ្ចប់កហាលព្រហ្មណ៍បានត្រូវមនុស្សជា

ច្រើននៅទីនោះកប់ដុំដីស្លាប់មរណាទៅ សោយទុក្ខទោសនៅក្នុងឋាននរក។ចមណែកព្រះបាទឯករាជត្រូវបានបណ្ដេញចេញពីព្រះនគរ។

សរុបមករឿងនេះអប់រំឱ្យមនុស្សគ្រប់រូបចេះដោះស្រាយបញ្ហានៅចំពោះមុខដោយសន្តិវិធី ចេះអត់ធ្មត់ដោយប្រើធម៌ខន្តី ចេះខ្លាចនូវអំពើបាបដែលនាំឱ្យខ្លួនវិនាសនិងចេហកសាងនូវអំពើល្អដែលនាំឱ្យខ្លួនរស់នៅបានសេចក្ដីសុខ។

## ឃ. ឧត្តមគតិតម្លៃអប់រំរឿងចន្ទកុមារ

ឧត្ដមគតិរឿងគឺជាឧត្ដមគតិរបស់អ្នកនិពន្ធ។ឧត្ដមគតិរឿងគឺយកកត្តាប្រធានវិស័យដែលបញ្ហាដែលបញ្ជាក់ពីគោលជំហរសតិអារម្មណ៍របស់អ្នកនិពន្ធដែលស្តែងឡើងតាមរយៈសកម្មភាពរបស់តួអង្គ។

រឿង”ចន្ទកុមារ”ស្ថិតក្នុងចលនាពុទ្ធនិយម ដែលចង់បង្ហាញនូវការអប់រំដ៏ជ្រាលជ្រៅដល់អនុស្ស មនុស្សឱ្យចេះប្រើធម៌ខន្តីក្នុងការដោះស្រាយបញ្ហាដើម្បីសម្រេចបានជោគជ័យ។ មួយវិញទៀត រឿងនេះបានចូលរួមបង្ហាញទស្សនះកម្មពៀរដែលជាទ្រឹស្តីសំខាន់របស់ព្រះពុទ្ធសាសនាគឺដំបូងថាបុគ្គលណាបានប្រព្រឹត្តអ្វីតែងតែបានទទួលផលចំពោះទង្វើរបស់ខ្លួន ដាក់ស្តែងកណ្ឌហាលព្រាហ្មណ៍ដែលជាមនុស្សដែល” ចិត្តបាបមានគំនិតប្រទូស្តជាមួយមនុស្សល្អមានគុណធម៌យ៉ាងប្រសើរ ចុងបញ្ចប់ត្រូវគេកប់នឹងដុំដីរហូតដល់ស្លាប់ ហើយថែមទាំងទៅសោយទុក្ខនៅនរកទៀត។ ចំណុចនេះធ្វើឲ្យមនុស្សមានទឹកចិត្តប្រព្រឹត្តអ្វីដែលវៀរចាកអកុសល្យ ពោលគឺធ្វើតែអំពើល្អជាកុសលដែលជាកត្តានាំមកនូវសន្តិភាព មួយវិញទៀតឱ្យមានការចេះជួយគ្នាពេលជួបគ្រោះអសន្ទ នៅពេលមនុស្សត្រូវបូជាយញ្ញព្រះគន្ទបានជួយសង្គ្រោះពួកគេឱ្យរួចពីមរណៈភ័យ និងងប់រំឱ្យមនុស្សកែប្រែចិត្តដូចជាព្រះបាទឯករាជជាដើម។

- មនុស្សចេះមានចិត្តសន្តោសប្រណីជំពោះគ្នា
- ធ្វើឱ្យមនុស្សកុំឱ្យមានចិត្តចងគំនុំជាមួយគ្នា
- អប់រំមនុស្សប្រកាន់ភ្ជាប់សុចរិយុត្តិធម៌
- អប់រំមនុស្សចេះគោរពសិទ្ធគ្នា
- អប់រំមនុស្សចេះស្រឡាញ់បងប្អូន
- អប់រំមនុស្សឱ្យមានធម៌ខន្តី
- ងប់រំមនុស្សឱ្យចេអតស៊ូអត់ធ្មត់។

តាមរយ:សាច់រឿងទាំងមូលអ្នកនិពន្ធបានចង្ហាញពីគោលគំនិត តម្លៃអប់រំ សំខាន់ៗ ដូចតទៅៈ

នៅពេលព្រះបាទឯករាជសោយរាជ បានយល់សុបិនឃើញខ្លួនទៅកើតនៅឋានសួគ៍ បានសួរព្រាហ្មណ៍ តើធ្វើបុណ្យអ្វីបានទៅកើតនៅឋានសួគ៌។ បានបង្ហាញឱ្យឃើញកុំឱ្យមានចិត្តលោបលន់ដោយមានចិត្តចងគុំនំទៅលើអ្នកបានធ្វើលើខ្លួននោះ។ នៅពេលកណ្ឌាលព្រាហ្មណ៍បានញួសញ៉ុងព្រះបាទឯករាជជឿតាម កន្លែងនេះបានបង្ហាញមកក្នុងសង្គម ពេលខ្លះមានពត៌មានមិនល្អ ៈុកខ្លះគ្រាន់តែ ឮឃើញពត៌មានមិនល្អនោះបានជឿដោយមិបានគិតពិចារណាពេលដឹងការពិតថា មិនពិតមានការស្ដាយក្រោយតែបានប្រព្រឹត្តទៅហើយដូចព្រះចាទឯករាជ។

ជារួមរឿងចន្ទកុមារបានអប់រំឱ្យមនុស្សគ្រប់រូបកុំចងគំនុំគ្នាមានធម៌ខន្តី ពីព្រោះការចងគំនុំគ្នានាំឱ្យអន្រាយមកដល់ខ្លួនដូចព្រម្មណ៍កណ្ឌហាលដែរសរបញ្ជក់នៅក្នុងសាច់រឿងនេះឯង។

# សង្ខេបរឿង ព្រះវេស្សន្តរ

## ទី១ កណ្ឌទសពរ

ព្រះបាទ សិរិមហារាជ សោយរាជ្យនៅនគរជេតុត្តរសិរីវដ្ឋ ទ្រង់មានព្រះរាជបុត្រមួយអង្គព្រះនាម ស្រីសញ្ជ័យ។ ព្រះរាជាទ្រង់អភិសេកព្រះសញ្ជ័យជាមួយព្រះនាងសុបារសុប្បតី(ផុសតី) ជារាជបុតនៃព្រះបាទ មទ្ទរាជ ននគរមទ្ទរដ្ឋ។

បុព្វប្រវត្តិនៃនាងផុស្សតីនោះគឺថានៅចុងកប្បទី៩១ នាងនេះជារាជបុត្រីនៃព្រះបាទពន្ធុមរាជ នគរពន្ធុមតី នាងបាន បូជាលម្អិតខ្លឹមចន្ទន៍ចំពោះព្រះពុទ្ធ វិបស្សី ។ ដោយផលានិសង្ស នេះធ្វើឱ្យនាងមានក្លិនក្រអូប។ ទីបំផុតនាងបានទៅជាអគ្គមហេសី នៃព្រះឥន្ទ្រាធិរាជ។ កាលដល់កំណត់ជន្មាយុ ព្រះឥន្ទ្រជ្រាបថានាង នឹងច្យុតចាកទេវលោក ព្រះអង្គក៏ប្រទានពរ១០ប្រការ (ទសពរ) ចំពោះនាងតាមសេចក្តីប្រាថ្នាគឺ៖

១. ឱ្យបានជាអគ្គមហេសីនៃព្រះបាទស្រីសញ្ជ័យនានគរ

២.ឱ្យមានភ្នែកល្អ មានភូមោកោងទទេស ទទួយដូចចង្កួយកៅទណ្ឌ

៣. ឱ្យមានឈ្មោះថាផុស្សតីដដែល

៤. ឱ្យមានកូនប្រុសមួយមានកិត្តិនាមល្បីល្បាញ

៥. ពេលមានគភ៌សូមឱ្យមានផ្ទៃពោះរាបស្មើល្អដូចរូប

៦. កុំឱ្យមានដោះសណ្តាយ ៧- កុំឱ្យមានសក់ស្កូវ

៨.ត្រូវមានសាច់សម្បុរស្បែកម៉ដ្ឋខល្អដូច សាច់ពពិល

៩. ឱ្យមានអំណាចដោះទុក្ខទោសរបស់មនុស្ស សត្វទាំង

១០. ឱ្យមានបក្សី គឺហង្ស ក្រៀល ក្ងាន បន្លឺនូវសព្ទលង់ ល្វើយនាព្រះរាជមន្ទីរ។

## ទី២ កណ្ឌហេមពាន្ត

ព្រះនាងផុស្សតីច្យុតចាកទេវលោកមកកើតក្នុងផ្ទៃនៃអគ្គមហេសីរបស់ព្រះបាទមទ្ទរាជ នាងមានក្លិនកាយកអូបដូច ខ្លឹមចន្ទន៍ ទើបគេថ្វាយព្រះនាមថា ផុស្សតី ព្រះបាទសិរិមហា រាជទ្រង់ប្រោសអភិសេកនាងឱ្យជាអគ្គមហេសីនៃព្រះបាទសីសញ្ជ័យរាជបុត្ររបស់ព្រះអង្គ កាលនោះព្រះពោធិសត្វយាងចុះ ពីឋានត្រៃត្រឹង្សមកចាប់បដិសន្ធិក្នុងផ្ទៃនាងផុស្សតី។ តាំងពីមានគភ៌ កាលណាព្រះនាងផុស្សតីចំណាយព្រះរាជទ្រព្យ៦ម៉ឺនកហាបណៈ រាល់ថ្ងៃដើម្បីព្រះរាជទានក្នុងសាលាទានទាំងបី នៅពេលគប់ទសមាស ព្រះនាងយាងប្រទក្សិណនគរ ក៏ស្រាប់តែប្រសូតព្រះ៖ ពោធិសត្វនៅចន្លោះផ្លូវនៃពួកឈ្មួញ ទើបគេថ្វាយនាមព្រះរាជ ទារកថាព្រះវេសន្តរ ក្នុងថ្ងៃព្រះពោធិសត្វប្រសូតមកមានម ដំរីមួយបាននាំកូនដំរីសសុទ្ធមកទុកថ្វាយក្នុងកន្លែងដំរីមង្គល ។ ទ្រង់ដាក់នាមដំរីនោះថា បច្ច័យនាគេន្ទ្រ។ នៅពេលព្រះជន្មបាន៥ឆ្នាំព្រះពោធិសត្វប្រទាននូវប្រដាប់ប្រដារកុមារមានតម្លៃមួយសន កហាបណៈដល់មេនំគម្រប់៩ដង ។ កាលព្រះជន្មបាន៨ឆ្នាំ ទ្រង់ ប្រាថ្នាឱ្យបេះដូង ភ្នែក សាច់ ឈាមជាទាន ហៅថាអជ្ឈត្តិកទាន ។ ព្រះជន្មបាន១៦វស្សា ព្រះបិតាទ្រង់ផ្សំផ្គុំនាង មទ្រី ជាមាតុលធីតា អំពីមទ្ទរដ្ឋឱ្យជាអគ្គមហេសី ហើយទ្រង់ដាក់រាជ្យថ្វាយឱ្យគ្រប់គ្រង នគរតរៀងមក ។ ចំណេរកាលមកនាងមទ្រីប្រសូតបានព្រះរាជ បុត្រមួយដាក់នាមថា ជាលី រួចប្រសូតបានបុត្រីមួយដាក់នាមថា កណ្ហាជិនា (ក្រឹស្នា) ។គ្រាមួយ ដែនកលិង្គរាស្ត្រកើតទុរភិក្ស រាំងភ្លៀង អត់បាយ។ អ្នកនគរចាត់ឱ្យព្រាហ្មណ៍៨នាក់ទៅសុំដំរីមង្គលពីព្រះវេស្សន្តរ។ ព្រះពោធិសត្វក៏សព្វព្រះទ័យប្រោសប្រទានដំរី ព្រមទាំងគ្រឿងប- ដាប់ទៅស្លូម ។ ពេលនោះ៖អ្នកស្រុកស្រីពិរាស្ត្រនាំគ្នាខឹងសម្បា សុំព្រះរាជាឱ្យបំបរបង់ព្រះវេស្សន្តរចេញពីនគរ។ ព្រះបាទស្រីសញ្ជ័យ ពុំយល់ព្រមតាម តែអ្នកស្រុកពុំសុខចិត្ត ទីបំផុត ព្រះវេស្សន្តរសម្រេចព្រះទ័យថានឹងចេញពីនគរទៅបួសនៅក្នុងព្រៃភ្នំគិរីវង្គត។ព្រះអង្គហៅនាងមទ្រីមក ប៉ុន្តែព្រះនាងទទូចសុំទៅតាមបម្រើព្រះស្វាមីតែមួយមុខ ។

## ទី៣ ទានកណ្ឌ

ព្រះនាងផុស្សតីអាឡោះអាល័យបុត្រ។ នាងយាងទៅអង្វរ សុំទោសព្រះស្វាមីឱ្យព្រះរាជទានលើកលែងទោសឱ្យព្រះវេស្សន្តរ តែពុំបានសម្រេច។ តមកព្រះវេស្សន្តរប្រារព្ធធ្វើសត្តសតកមហាទាន គឺទានមានចំនួន៧រយៗគម្រប់៧មុខ។ព្រះនាងផុស្សតីសុំឃាត់នាងមទ្រីជារាជសុណិសាឱ្យនៅក្នុងនគរ។ នាងមទ្រីមិនព្រម ដោយបានរៀបរាប់អំពីធម្មជាតិអាក្រាត បីមុខថ្វាយព្រះមាតាស្តាប់គឺៈ

- ទន្លេគ្មានទឹក ហៅថា ទន្លេអាក្រាត
- ដនគ្មានស្តេច ហៅថា ដែនអាក្រាត
- ស្ត្រីមេម៉ាយ ហៅថា ស្រីអាក្រាត

តមកព្រះវេស្សន្តរមួយអន្លើ និងនាងមទ្រីបុត្រទាំងពីរថ្វាយ បង្គំលាមាតាបិតាយាងចេញពីនគរ។ នៅតាមផ្លូវព្រះពោធិសត្វ ទ្រង់បានប្រទានសេះទាំង៤ទៅព្រាហ្មណ៍៤នាក់ និងរាជរថទៅឱ្យ ព្រាហ្មណ៍ម្នាក់ទៀត ទីបញ្ចប់ទ្រង់ពបាជាលី ឯនាងមទ្រីពថៅ គ្រីស្នាយាងព្រះបាទបន្តផ្លូវទៅមុខទៀត។

## ទី៤ កណ្ឌវនប្បវេសន៍

ព្រះវេស្សន្តរ មហេសី និងបុត្រយាងដល់មាតុលនគរ។ ពួក អ្នកចេតរាស្ត្រចេញមកទទួល ហើយព្រមព្រៀងថ្វាយរាជសម្បត្តិ ចំពោះព្រះវេស្សន្តរ ប៉ុន្តែព្រះអង្គពុំទទួល។ ស្តេចចេតរាស្ត្រនាំគ្នា រៀបជូនដំណើរព្រះពោធិសត្វទៅដល់ទ្វារភ្នំគិរីវង្គត ហើយរើស កូនប្រុសអ្នកស្រុកម្នាក់ឈ្មោះ ចេតបុត្រ ឱ្យចាំនាច្រកភ្នំដើម្បី ការពារសេចក្តីសុខចំពោះព្រះវេស្សន្តរ។ ក្សត្រទាំង៤អង្គយាងដល់ឆ្នេរស្រះបោក្ខរណីបានឃើញអាស្រមបទដែលសក្កទេវរាជនិម្មិត ថ្វាយ ក៏នាំគ្នាចូលគង់នៅជាមួយគសីក្នុងទីនោះទៅ។

## ទី៥ កណ្ឌជូជក

និយាយពីព្រាហ្មណ៍ម្នាក់ឈ្មោះ ជូជក នៅស្រុកទុន្នវិដ្ឋគ្រាម សន្សំប្រាក់បាន១០០កហាបណៈយកទៅផ្ញើនឹងត្រកូលព្រាហ្មណ៍ មួយ។ ត្រកូលព្រាហ្មណ៍នោះចាយប្រាក់ជូជកអស់ ក៏សុខចិត្តលើក កូនស្រីឈ្មោះនាង អមិត្តតាបនា ឱ្យធ្វើជាប្រពន្ធជូជក។

ថ្ងៃមួយពួកព្រាហ្មណ៍ក្មេងៗបានចោមរោមវាយនាងអមិត្ត- តាបនាដោយក្តីចណន នាងនេះបានលេសក៏លែងបម្រើប្តីចាស់ហើយបង្ខំតាជូជកឱ្យទៅសុំកូនព្រះវេស្សន្តរមកបម្រើនាង។ ជូជក

ធ្វើដំណើរទៅកាន់ភ្នំគិរីវង្គត។ ចេតបុត្រឃើញព្រាហ្មណ៍ចាស់ត្រូវ ឆ្កែដេញខាំរត់ឡើងចុងឈើ ក៏ទាញព្រួញបម្រុងនឹងបាញ់ប្រហារ។

## ទី៦ កណ្ឌចូឡពន

ជូជកកុហកថាខ្លួនជារាជទូតព្រះបាទស្រីសញ្ជ័យ ចេត- បុត្រជឿ ក៏អញ្ជើញជូជកចុះមកជប់លៀង។ ក្រោយការជប់លៀង ចេតបុត្ររៀបរាប់ដំណើរទៅកាន់ភ្នំគិរីវង្គតឱ្យជូជកស្តាប់ ... តមក ជូជកលាចេតបុត្រធ្វើដំណើរទៅដល់អាស្រម អច្ចុតមហាឫសី ។

## ទី៧ កណ្ឌមហាពន

អច្ចុតមហាឫសីទទួលជូជករួចក៏រៀបរាប់ប្រាប់អំពីផ្លូវទៅកាន់អាស្រមព្រះវេស្សន្តរ ។ ជូជកទៅដល់អាសមនៅពេលរសៀល។ គាដ៏នៅសំណាក់ ដើងភ្នំមួយយប់រង់ចាំព្រឹកស្អែកនឹងចូលទៅសុំបុត្រទាំងពីរអំពីព្រះវេស្សន្តរ។

## ទី៨ កណ្ឌកុមារបព្វ

រាត្រីនោះនាងមទ្រីយល់សុបិននិមិ្មតឃើញបុរសម្នាក់ទាបខ្មៅស្លៀក ពាក់សំពត់អម្ពាត់ ត្រឹមជង្គង់ សៀតផ្កាចារនៅត្រចៀក កាន់អាវុធមុតថ្លាចូលមកចាប់ផ្តួលនាងឆ្មៀលយកភ្នែក

ទាំងពីរ កាត់ យកព្រះអង្សាទាំងសងខាង ពុះទ្រូងរូងយកថ្លើមបេះដូងទៅ ។ ព្រះនាងតើន ឡើងភិតភ័យតក្កមា ទើបព្រះនាងយាងយាត្រាចូល ទៅរកព្រះស្វាមីគោះទ្វារអាស្រមបរមកុដិ ទាំងរាត្រី។ ព្រះវេស្សន្តរ កាត់សុបិននោះថាជាការល្អទេ។

ព្រឹកឡើងនាងមទ្រីនាំបុត្រទាំងពីរទៅផ្ញើនឹងស្វាមី រួចចេញទៅបេះផ្លែផលាទាំង អារម្មណ៍ពិភាល់យ៉ាងខ្លាំងអំពីសុបិននិម្មិត។ ជូជកចូលមកសុំចៅក្រឹស្នា និងជាលី។ រាជ កុមារទាំងពីរភិតភ័យ នាំគ្នារត់ទៅពួនឯស្រះឈូក ជូជកចាប់កុមារទាំងពីរទៅចងវាយ វាត់ នៅចំពោះព្រះភក្ត្រព្រះវេស្សន្តរ ព្រះពោធិសត្វទប់ព្រះទ័យ ពុំទាន់ ទ្រង់ចាប់ធ្នូសរបម្រុងនឹង ប្រហារព្រាហ្មណ៍ចោល តែទ្រង់ ទប់បានវិញ។ ជូជកនាំកុមារចេញទៅ ។

# ទី៩ កណ្ឌមទីបព្វ

និយាយពីនាងមទ្រីចេញទៅបេះផ្លែឈើពុំបានសោះ ។ នាងជួបប្រទះនូវខ្យល់ព្យុះ ភ្លៀងផ្គរ ហើយចេះតែមានហេតុភេទ ចម្លែកៗដូចជារកាំភ្នែកឆ្វេង កម្រើកភ្នែកស្តាំ ធ្លាក់សង្រែកពីស្មា ធ្លាក់ទំពក់ពីដៃ នាងពុំអាចវិលមកអាស្រមបានព្រោះទេវបុត្ត ច្បូតនិម្មិតកាយជារាជសីហ៍១ ខ្លាធំ១ ខ្លាដំបង១ រាំងផ្លូវនាង។ លុះ ព្រលប់ទើបទេវបុត្តកាឡាខ្លួនចេញទៅអស់ នាងក៏វិលមក កាន់ អាស្រមវិញ។ នាងមទ្រីពុំឃើញបុត្ររត់មកទទួលដូចប្រក្រតី ធ្វើ ឱ្យនាងភិតភ័យណាស់ ខំស្រែកហៅបុត្រទាំងទ្វេ ក៏នៅតែពុំឃើញ។ នាងសួរព្រះស្វាមីក៏ព្រះអង្គពុំឆ្លើយតប នាងមទ្រី សោយសោកលុះ ដួលសន្លប់បាត់ស្មារតី។ ព្រះវេស្សន្តរស្ទុះមកត្រកងបី យកទឹកសព ព្រះភក្ត្រឱ្យ នាងដឹងខ្លួនវិញ ទើបទ្រង់លួងលោមប្រាប់ថាព្រះអង្គបានប្រទានបុត្រទៅជូជកហើយ។ នាង មទ្រីក៏អនុមោទនាបុត្តមានក្នុងខណៈនោះ ។

# ទី១០ កណ្ឌសក្កបព្វ

និយាយពីព្រះឥន្ទ្រាធិរាជទ្រង់ចុះមកកាឡាខ្លួនជាព្រាហ្មណ៍ ម្នាក់ដើរចូលមកអាស្រមព្រះ វេស្សន្តរដើម្បីបំពេញភរិយាទានដល់ពោធិសត្វ ព្រះនាងមទ្រីយល់អធ្យាស្រ័យស្វាមីក៏យល់ព្រម ឱ្យព្រះ វេស្សន្តរដាក់ទាននាងទៅឥន្ទ្រព្រាហ្មណ៍ ព្រះឥន្ទ្រទ្រង់សរសើរ ព្រះទ័យសប្បុរសរបស់ព្រះ ពោធិសត្វ ហើយទ្រង់បានប្រគល់នាងមទ្រីថ្វាយទៅព្រះវេស្សន្តរវិញ។

ខណៈនោះព្រះវេស្សន្តរបានសុំពរពីព្រះឥន្ទ្រ៨ប្រការគឺៈ

១. សូមឱ្យព្រះវររាជបិតាស្តេចមកនាំពួកយើងខ្ញុំគឡប់ទៅ នគរវិញ
២. សូមឱ្យមានអំណាចអាចដោះទុក្ខទោសរបស់សត្វទាំងឡាយឱ្យផុតពីក្តីស្លាប់
៣. សូមឱ្យបានជួយសង្គ្រោះដល់ជនកម្សត់ទុក៌តផុតពីក្តីក លំបាក
៤. សូមកុំឱ្យមានចិត្តត្រេកត្រអាលខាងផ្លូវកាមគុណជាអកុសល
៥. សូមឱ្យចៅជាលី និងនាងកណ្ហាជិនាបានគ្រប់គងបុរីពិជ័យជេតុត្តរ
៦. សូមឱ្យមានអាហារទិព្វកើតឡើងរៀងរាល់ថ្ងៃ
៧. សូមឱ្យការបរិច្ចាគទានកុំបីមានខ្វះខាត
៨. សូមឱ្យរំលងខន្ធទៅ បានទៅកើតនៅឋានតុសិតទ- លោកកុំបីខានឡើយ ។

# ទី១១ កណ្ឌមហារាជបព្វ

ជូជកបានដើរអស់១៥ថ្ងៃ ហើយទីបំផុតគឺវង្វេងផ្លូវទៅកាន់ ក្រុងជេតុត្តរ ។ ព្រះបាទស្រី សញ្ជ័យទតឃើញព្រាហ្មណ៍ចាស់បណ្ដើរ ក្មេងតូចៗ ទ្រង់បញ្ជាឱ្យហៅមកគាល់។ ពួកអាមាត្យមុខ មន្ត្រីបាន ស្តាប់ជូជកថ្លែងរឿងប្រាប់ ក៏ចោទប្រកាន់ថ្កោលទោសព្រះវេស្សន្តរ ថាមិនគួរលើក កូនឱ្យជាទានសោះ។ ជាលី-ក្រឹស្នាបានដោះសារការ ពារព្រះបិតា។ ព្រះបាទស្រីសញ្ជ័យត្រាស់ឱ្យ លោះព្រះរាជអនត្ត អនត្តាអំពីជូជក ហើយទ្រង់ឱ្យរៀបពិធីទទួលព្រលឹងទៅ ជាលី បានក្រាប ទូលអំពីទុក្ខលំបាករបស់បិតាមាតានៅក្នុងព។ ព្រះ ស្រីសញ្ជ័យសម្រេចនាំរេហ៍ពលទៅតាមរាជ បុត្រវិលមកនគរវិញ។ ចំណែកជូជកក្រោយដែលបានទទួលព្រះរាជទានរង្វាន់ហើយ ដោយសារ គាត់អត់ឃ្លានមកយូរថ្ងៃ គាត់ក៏បរិភោគអាហារ ច្រើនហួសប្រមាណ។ ភ្លើងធាតុមិនអាច រំលាយឱ្យរលួយបានគាត់ ក៏រលត់សង្ខារក្នុងគ្រានោះហោង។

## ទី១២ កណ្ឌឆក្សត

ព្រះបាទស្រីសញ្ជ័យ នាងផុស្សតី រាជវង្សានុវង្ស និងអស់ លោកអាមាត្យមន្ត្រី ព្រមទាំងកុមារទាំងពីរបានចេញដំណើរទៅ កាន់ភ្នំគិរីវង្កត ក្សត្រទាំង៦អង្គក៏បានជួបជុំគ្នាដូចប្រាថ្នាហើយ សំណេះសំណាល យំសោកគ្រាគសន្លប់អស់ ។ ខណៈនោះមហា មេឃបង្អុរភ្លៀងបោក្ខរពស៌មកធ្វើឱ្យក្សត្រទាំង៦ និងសេនាអាមាត្យ មុខមន្ត្រីដឹងស្មារតីវិញ អស់មុខមន្ត្រីក្រាបថ្វាយបង្គំព្រះវេស្សន្តរ និងនាងមទ្រី សូមឱ្យស្តេចត្រឡប់ព្រះនគរឋាន សោយរាជសម្បត្តិវិញ ។

## ទី១៣ នគរកណ្ឌ

ក្រោយនោះ ព្រះវេស្សន្ត និងនាងមទ្រីក៏លាព្រះផ្នួស។ ព្រះបាទស្រីសញ្ជ័យបានសុំទោសបុត ហើយទ្រង់លួងលោមបុត ដោយប្រការផ្សេងៗ។ មុខចតុរង្គសេនាក៏ដង្ហែព្រះពោធិសត្វ រាជ-វង្សានុវង្សចូលនគរវិញដោយសុវត្ថិភាព ។

ព្រះវេស្សន្តរសោយរាជ្យជាសុខរហូតដល់សោយទីវង្គតបានទៅកើតនៅឋានតុសិតមាននាមថា សន្តុសិតទេវបុត្រ ។

ព្រះរាជវង្សានុវង្ស និងនាម៉ឺនសព្វមុខមន្ត្រីបានចាត់ការធ្វើពិធីរាជាភិសេកព្រះជាលី និងកណ្ហាជិនាជាព្រះមហាក្សត្រតរៀងមក។

### ក.អត្ថន័យខ្លឹមសារ

អត្ថន័យអត្ថ .ប្រយោជន៍.អត្ថន័យ .ការណែនាំអត្ថាធិប្បាយសេចក្តីពន្យល់.អត្ថន័យជាគំនិតសំខាន់ៗរបស់អ្នកនិពន្ធដែលលាតត្រដាងនៅក្នុងដំណើររឿង ហើយគេអាចហៅវាថាជាជម្រៅនៃរឿង។

ក្នុងផ្នែកអត្ថន័យមាន ប្រធានរឿង មូលបញ្ហារឿងនិងឧត្តមគតិរឿង។

### ខ. ប្រធានរឿង

ប្រធានរឿងឬមូលន័យ គឺជាគំនិតសំខាន់ៗរបស់រឿង។ប្រតិឬជាបញ្ហារួមរបស់រឿង។ តែអ្នកនិពន្ធចង់បង្ហាញដល់អ្នកអានប្រធានរឿងជាបញ្ហារូបផ្តុំបំផុតដែលអ្នកនិពន្ធលើកយកមកសរសេរឬជ្រើសរើសជាប្រធានបទហើយដែលមានមូលបញ្ហារឿងឋិតនៅក្នុងនោះ។

ប្រធានរឿងបង្ហាញនៅចំហររបស់អ្នកនិពន្ធវាជាមូលដ្ឋានដើមរបស់អ្នកនិពន្ធក្នុងការចាប់ផ្តើមសរសេរឡើង។មុនពេលចាប់ផ្តើមសរសេរឡើង។អ្នកនេះពាន់គ្រប់ត្រូវកំណត់ថាតើគាត់ត្រូវសរសេរអំពីអ្វី។អំពីជីវិតសង្គមសង្គ្រាមស្នេហារឿងជំងឺទំនេនទម្លាប់ប្រពៃណីចម្លើយរបស់សំណួរនេះហើយជាប្រធានរឿង។រឿងខ្លះប្រធានរឿងស្ថិតនៅលើចំណងជើងរបស់រឿង។

ព្រះវេស្សន្តរជាជាតិកំណើតពោធិសត្វចុងក្រោយបង្អស់របស់ព្រះពុទ្ធ។ ក្នុងរឿងនេះ ព្រះពោធិសត្វមាននាម ថា “វេស្សន្តរ” ។ ឯដំណើររឿងទាំងមូលបានលាតត្រដាងពីដំណើរជីវិតព្រះអង្គដែលផ្សារភ្ជាប់តែ “ការដាក់ទាន” តែ ប៉ុណ្ណោះ ។ ដូចនេះប្រធានរឿងគឺ “ការបំពេញទានបារមីរបស់ព្រះពោធិសត្វព្រះនាមវេស្សន្តរ”។ ការបំពេញទានបារមី នេះ គឺការបំពេញមហាបរិច្ចាគ៥គឺ ធនបរិច្ចាគបុត្តបរិច្ចាគ ភរិយាបរិច្ចាគ អង្គបរិច្ចាគ និងជីវិតបរិច្ចាគដែលបុគ្គលធម្មតាមិនអាចធ្វើបាន ។

### គ. មូលបញ្ហារឿង

មូលបញ្ហារឿងគឺជាភាពចំណែកនៃប្រធានរឿងជាទិដ្ឋភាពផ្សេងៗរបស់យើង។វាជាការចូលជ្រៅទៅក្នុងប្រធានរឿង។

តាមរយៈសាច់រឿងព្រះវេស្សន្តរឃើញថា ការបរិច្ចាគទានទាំង៥នេះ មនុស្សធម្មតាមិនអាចធ្វើបានទេ ហើយដំណើររឿងយើងឃើញថាថ្វីត្បិតតែព្រះវេស្សន្តរជាទេវបុត្រដែលច្យុតមកលើផែនដីដើម្បីបំពេញទាន

បារមីក៏ដោយ ក៏ការបំពេញទាននោះវាមិនមែនជាការងារធម្មតាចំពោះព្រះអង្គឡើយ ព្រោះពេលដែលបំពេញទាន ព្រះអង្គជាមនុស្ស "មនុស្ស" ពោលមិនទាន់ក្លាយជាព្រះនៅឡើយទេ ។ តាមរយៈការបំពេញទានបារមីនេះគេអាចឃើញនូវបញ្ហាចោទសំខាន់ៗមួយចំនួនដូចខាងក្រោម។

### ទី១ បញ្ហាបុគ្គលនិង កម្លាំងប្រជាធិតេយ្យ

បើនិយាយដល់សម័យកាលនេះ ការចំណាយទ្រព្យធនរបស់ព្រះអាចបាត ដល់ផលប្រយោជន៍ប្រជាជនឡើយ។ ប៉ុន្តែតាមដំណើររឿង ដំរីបច្ច័យនាគេន្ទ្រានកម្មសិទ្ធរបស់ព្រះអង្គ អំណោយរបស់មេដំរីស្ទូគ៏ដែលហោះមកថ្វាយ ។ ដូចនេះហើយទើបព្រះអង្គមិននឹកនាដល់ការបោះបោរប្រឆាំងតវ៉ាពីសំណាក់ប្រជាពលរដ្ឋអ្នកស្រុកដែលរស់នៅក្នុងនគរស្រីពិរាស្រ្ត។ មុនពេលត្រូវគេបណ្តេញទើបព្រះអង្គយល់ពីបញ្ហានេះ ហើយសុខចិត្តចាកចោលនគរដោយគ្មានប្រកែកហើយទើបនាំឱ្យព្រះវេស្សន្តរតែងតែស្ទាបស្ទង់ ឬអង្វរអ្នកដែលទាក់ទងដល់ផលប្រយោជន៍ក្នុងការដាក់ទានរបស់ព្រះអង្គជានិច្ច ។ពេលធ្វើបុត្តបរិច្ចាគ ព្រះអង្គបានអង្វរបុត្រយ៉ាងច្រើន ទាល់តែបុត្រយល់ព្រមដោយខ្លួនឯង ។ ហើយពេលដាក់ទានភរិយាទៅឱ្យឥន្ទ្រព្រាហ្មណ៍ក៏ព្រះអង្គចោលកន្ទុយភ្នែកស្ទាបស្ទង់ចិត្តព្រះនាងមទ្រីទាល់តែព្រះនាងឆ្លើយថាយល់ព្រម ទើបទ្រង់ធ្វើ "ភរិយាបរិច្ចាគ " ។និយាយរួមការបរិច្ចាគតាមបែបរឿងព្រះវេស្សន្ត គឺជាការបរិច្ចាគដ៏តឹងតែងជាទីបំផុតដែលមនុស្សសាមញ្ញប្រាកដជាមិនអាចធ្វើបាន មានតែព្រះវេស្សន្តរទើបអាចសម្រេច ។ នៅត្រង់ចំណុចនេះបានសរបញ្ជាក់ឱ្យយើងឃើញពី កម្លាំងប្រជាធិប្បតេយ្យប្រជាជនអ្នកស្រុកស្រីពិរាស្រ្ត

### ទី២ បញ្ហាក្នុងការដាក់ទានបំពេញបារមីដើម្បីត្រាស់ដឹងជាព្រះពុទ្ធ

ចំពោះមហាបរិច្ចាគទានរបស់ព្រះវេស្សន្តរនេះ អ្នកនិពន្ធមានគំនិតមួយអប់រំមនុស្សឱ្យហ៊ានលះបង់អ្វីៗទាំង អស់ដើម្បីឱ្យមនុស្សជាតិទូទៅពិសេសគឺ ការដាក់ទានចំពោះជនអ្នកក្រីក្រគោកយ៉ាក ព្រះវេស្សន្តរតែងព្យាយាម បំពេញទានបារមីនោះ គឺដើម្បីបានត្រាស់ជាព្រះពុទ្ធនិងបានជួយប្រោសសត្វលោកឱ្យផុតចាកពីអវិជ្ជា។ យើងឃើញតួអង្គសំខាន់ៗដទៃទៀតក៏ឯកភាពក្នុងឧត្តមគតិនេះដែរ ដូចជាកុមារជាលីនិងក្រស្នា ទោះបីត្រូវទទួលទណ្ឌកម្មខ្លាំងយ៉ាងខ្លោចផ្សាពីតាជូជក ក៏គេនៅតែជួយការពារឧត្តមគតិឪពុករបស់ខ្លួន។ ឯនាងមទ្រីដោយបាត់កូន នាងយំសោកស្វែងរករហូតសន្លប់បាត់ស្មារតី តែនៅពេលដឹងថាព្រះស្វាមីឱ្យកូនជាទានដល់ព្រាហ្មណ៍នោះ, ព្រះនាងក៏ស្ងប់ចិត្តដែរ ព្រះឥន្ទ្រដែលប្រែជាភេទព្រាហ្មណ៍ដើម្បីសុំយកនាងមេទ្រីជួយបំពេញបារមីរបស់ព្រះវេស្សន្តហើយព្រះវេស្សន្តយល់ព្រមឱ្យរីឯព្រះនាងមេទ្រីក៏យល់ព្រមតាមព្រះវេស្សន្តដែរ ។ ដូចនេះសូម្បីតែទេវតា ព្រះឥន្ទ ក៏ជួយជ្រោមជ្រែងឱ្យព្រះវេស្សន្តរសម្រេចឧត្តមគតិនេះដែរ។

### ទី៣ បញ្ហាព្រហ្មវិហារធម៌របស់បុគ្គលគ្រប់រូប

ព្រះវេស្សន្តរបានធ្វើការបរិច្ចាគទានដោយគ្មានរួញរា សូម្បីពេលដែលត្រូវគេបណ្តេញចេញពីព្រះនគរពុំមានខឹងហើយក៏នៅតែហ៊ានលះបង់របស់គ្រប់យ៉ាងឱ្យគ្មានស្តាយស្រណោះ ដូចជាតាមផ្លូវទៅភ្នំគិរីវង្កតព្រះអង្គបានដាក់ទានអាជានេយ្យ៤ព្រមទាំងរាជរថទៅពួកព្រាហ្មណ៍ ហើយចែកកូនគ្នាពធ្វើដំណើរដោយជើងចេញរហុតទៅដល់ព្រៃហេនិពាន្តនោពេលទៅដល់ព្រៃព្រៃព្រឹក្សាទាំងឡាយគោរព បញ្ចេញផ្កាផ្លែ បក្សាបក្សីស្រែកចៀងលន់ខ្ទៀវខ្ទាចាំទទួលព្រះអង្គ។ ប៉ុន្តែប្រការមួយដែលមនុស្សធម្មតារហូតដល់ព្រះពោធិសត្វពិតជាពុំអាចចៀសផុតបាន

គឺមនោសញ្ចេតនាជាព្រហ្មវិហារធម៌របស់ឪពុកចំពោះកូន។ព្រះអង្គអាចដាក់ទានវត្ថុគ្មានវិញ្ញាណដោយគ្មានបង្ខំចិត្តតែព្រះអង្គត្រូវតែខ្លោចចិត្តអាណិតបុត្រពេលដែលដាក់ទាន ឱ្យទៅព្រាហ្មណ៍ឬស្សាដោយពួសម្រែវាចាត្អូញត្អែរ យំស្រែកពីការឈឺចាប់របស់បុត្រ ព្រះអង្គលើកផ្តួបំរុងនិងបាំតាជជូកហើយតែព្រះអង្គកដាក់វិញកន្លែងនេះហើយបង្ហាញឱ្យឃើញបីព្រហ្មវិហារធម៌របស់ទ្រង់។

### ក. តម្លៃអប់រំរឿងព្រះវេស្សន្ត

ឧត្តមគតិរឿងគឺជាឧត្តមគតិរបស់អ្នកនិពន្ធ។ឧត្តមគតិរឿងគឺយកកត្តាប្រធានវិស័យដែលបញ្ហាដែលបញ្ជាក់ពីគោលជំហរសតិអារម្មណ៍របស់អ្នកនិពន្ធដែលស្តែងឡើងតាមរយៈសកម្មភាពរបស់តួអង្គ។

- ការចេះធ្វើអំពើសប្បុរសធម៌ជួយគ្នាទៅវិញទៅមករបស់បុគ្គលគ្រប់រូប រឿងព្រះវេសន្តជាតកជាប្រភេទអក្សរសិល្ប៍បុរាណបែបពុទ្ធនិយម ដែលបង្ហាញអំពីរឿងរ៉ាវផ្សេងៗទាក់តងនិងការចេះឱ្យទានជួយសង្គ្រោះគ្នាទៅវិញទៅមក សបញ្ជាក់ឱ្យយើងឃើញតាមរយៈតួអង្គព្រះវេស្សន្តរ វាជាតម្លៃអប់រំមួយដែលមិនអាចខ្វះបានក្នុងកការរស់នៅក្នុងជីវិតប្រចាំថ្ងៃ។ មិនត្រឹមតែប៉ុណ្ណោះការរស់នៅរបស់មនុស្សយើងសព្វថ្ងៃក៏មានការចេះជួយគ្នាទៅវិញទៅកមក្នុងសង្គមផងដែរ។ ជាក់ស្តែងនៅពេលមានគ្រោះធម្មជាតិកើតឡើងដល់ប្រជាពលរដ្ឋ រាជរដ្ឋាបាលកម្ពុជាតែងតែជួយគ្រប់ពេលវេលា។

- តាជជូក ដែលជារដើកភ្លើងធំបំផុតទ្រទ្រង់ចំនងឱ្យចង់បានហួសហេតុធ្វើឱ្យអ្នកដ៏ទៃរងទុក្ខទោស ខ្លោចផ្សារទាងរូបរាងកាយតាងផ្លូវចិត្ត បានមកសុំបុត្រទាំងពីររបស់ព្រះវេស្សន្តរបានហើយ ថែមទាំងមិនដឹងគុណ ក៏បានវាយធ្វើបាបកុមារទាំងពីរយ៉ាងឈឺចាប់ខ្លោចផ្សារស្រែកទ្រហូយំគួរឱ្យឧនិច្ចា ។ មួយវិញទៀតនៅពេលដែលតាជូជកបានធ្វើដំណើរអស់ដប់ប្រាំថ្ងៃទៅដល់នគរ ក្រុងជេតុត្តរ ព្រះបាទស្រីសញ្ជ័យទតឃើញព្រាហ្មណ៍ចាស់បណ្តើរក្មេងតូចៗ ទ្រង់បញ្ជាឱ្យហៅមកគាល់បានឃើញជាលី-ក្រឹស្នា ព្រះបាទស្រីសញ្ជ័យត្រាស់ឱ្យលោះព្រះរាជអនត្តអនត្តារពីជូជកហើយទ្រង់ឱ្យរៀបពិធីទទួលព្រលឹងទៅ។ ចំណែកជូជកក្រោយដែលបានទទួលព្រះរាជទានរង្វាន់ហើយ ដោយសារគាត់អត់ឃ្លានមកយូរថ្ងៃ គាត់ក៏បរិភោគអាហារច្រើនហួសប្រមាណ។ ភ្លើងធាតុមិនអាចរំលាយឱ្យរលួយបានគាត់ ក៏រលត់សង្ខារក្នុងគ្រានេះ ជាផលកម្មនៃការលោបលន់របស់គាត់ស្លាប់ហើយបានទទួលរងទុក្ខវេទនានៅក្នុងស្ថាននរកត្រងើនេះបានងប់រំដល់មនុស្សគ្រប់រុបឱ្យប្រព្រឹត្តតែអំពើល្អជាកុសលដើម្បីបានផលបុណ្យទៅកើតនៅឋានសួក៍នេះឯង។

- មៅក្នុងសាច់រឿងនេះដ៏ដែល បានអប់រមដល់មនុស្សគ្រប់រូបឱ្យចេះគោរពសិត្តគ្នាទៅវិញទៅមក ដូចតួអង្គព្រះវេស្សន្តរគោរពមតិភាគច្រើនជាធំចាកចេញបិនគរដោយមិនមានខឹងក្រោតអ្វីឡើយ។ នៅពេលព្របាទស្រីសញ្ជ័យបានលោះកុមារតាំងពីរពីតាជូជក ប្រះអង្គបានឱ្យតម្លៃថានរង្វន់ដល់តាជួជកគ្រប់បែបយ៉ាងឱ្យតែគាត់ចង់បាន។

- អប់រំឱ្យមនុស្សចេះធ្វើទាន
- អប់រំមនុស្សឱ្យចេះដោះស្រាយបញ្ហានៅចំពោះមុខ
- អប់រំមនុស្សចេះគោរពលិទ្ធិប្រជាបិតេយ្យដើម្បីប្រយោជន៍រួម
- អប់រំមនុស្សចេហដឹងគុណមាតាបិតា
- អប់រំមនុស្សចេះយោលចិត្តគ្នា
- មានអធ្យាស្រ័យល្អជាមួយគ្នាទៅវិញទៅមក។

សរុបជារួមមក រឿងអក្សរសិល្ប៍បុទ្ធនិយមទសជាតកបានផ្តល់តម្លៃងប់រំដល់មនុស្សទូទៅ ឱ្យចេះចែកទានរំលែកដល់អ្នកដែលត្រូវការ ការគោរពសិទ្ធឱ្យតម្លៃគ្នា ការមិនប្រកាន់វណ្ណៈ ការអត់ធ្មត់ខន្តីរស់នៅជាមួយគ្នាប្រកបដោយសុខសន្តិភាព ធ្វើឱ្យសង្គមឫសង្គមជាតិទាំងមុលមានការរីកបម្រើន។

## ៤.៧ អក្សរសិល្ប៍ពុទ្ធនិយមក្លាយ

តាមរយៈស្នាដៃអក្សរសិល្ប៍រឿងបញ្ញាសជាតក អ្នកនិពន្ធខិតខំបង្កើតស្នាដៃនេះឡើងដោយ ពឹងផ្អែកលើគោលទស្សនៈទ្រឹស្តីនៃលទ្ធិពុទ្ធសាសនាផងនិងបញ្ចូល បន្ថែមគោលនិយមនៃសាសនា ព្រាហ្មណ៍ខ្លះ។ តាមការស្រាវជ្រាវរឿងបញ្ញាសជាតក ... បានចារឡើងនៅក្នុងអំឡុង ព.ស. ២២០០ គឺរវាង គ.ស.១៤៥៧-១៦៥៨ ដោយភិក្ខុសង្ឃខ្មែរ ថៃ ឡាវ ភូមា ដែលបានចេញទៅសិក្សា ធម្ម វិន័យនៅលង្កាទ្វីប លុះចេះដឹងស្ទាត់ហើយក៏ត្រឡប់មកស្រុកវិញ ចាប់និពន្ធរឿងរ៉ាវតាមទំនាក់ទំនងនិទានជាតកដើម្បីជួយអប់រំដល់ប្រជាពលរដ្ឋចេះគោរពនៃព្រះពុទ្ធសាសនានិង ជួយសម្រាលទុក្ខពួកគាត់បានខ្លះៗផង។

រឿងបញ្ញាសជាតក ដំបូងសរសេរជាពាក្យបាលីរហូតមក សតវត្សរ៍ទី១៨និង១៩ ទើបត្រូវបាន ប្រជាពលរដ្ឋខ្មែរនិយមកវីបណ្ឌិតយើង ប្រែសម្រាយជាពាក្យកាព្យស្លោក ឬជាបទល្ខោនក៏មានការរាប់អានមើលកំសាន្តក្នុងពេលលំហពីការងារ ឬចូលចិត្តយករឿងរ៉ាវនេះទៅនិទានកំណាលដល់កូនចៅតៗគ

អត្ថបទបែបពុទ្ធនិយមក្លាយនេះ សំដៅយករឿងទាំង៥០ក្នុងគម្ពីរបញ្ញាសជាតក ដូចមាន

រាយឈ្មោះក្នុងតារាងខាងក្រោមនេះ

១. ព្រះសមុទ្ទឃោសៈ
២. ព្រះសុធនកុមារ
៣. ព្រះសុធនុកុមារ
៤. រតនប្បជ្ជោត
៥. សិរីវិបុលកិត្តិ
៦. វិបុលរាជ បំពេញទានបារមី
៧. សិរិច្ចូឌាមណី បំពេញជីវិតបារមី
៨. ចន្ទរាជ
៩. សុភមិត
១០. សិរីធរ បំពេញទានបារមី
១១. ទុលកបណ្ឌិត
១២. អាទិត្តរាជ បំពេញទានបារមី
១៣ ទុក្កម្មានិកៈ
១៤ មហាសុរសេន បំពេញទានបារមី
១៥ សុវណ្ណកុមារ
១៦ ភនកវណ្ណរាជ
១៧ វិរិយបណ្ឌិត
១៨ ធម្មសោណ្ឌក
១៩ សុទស្សនមហារាជ
២០ វត្តង្គុលីរាជ
២១ បោរាណកបិលរាជ
២២ ធម្មិកបណ្ឌិតរាជ
២៣ ចាគទានបំពេញទានបារមី
២៤ ធម្មរាជ
២៥ នរជីវៈ គួរអង្គបំពេញសកម្មភាព លះបង់ជីវិតជូនមាតា
២៦ សុរូប
២៧ មហាបទុម
២៨ ភណ្ឌាគារ បំពេញបញ្ញាបារមី
២៩ ពហុលគាវី បំពេញសច្ចៈបារមី
៣០ សេតបណ្ឌិត បំពេញបញ្ចសិល

៣១ បុប្ផរាជ

៣២ ពារាណសិរាជ និទានពីរឿងហង្សមាស មានក្បាលពីរ

៣៣ ព្រហ្មឃោសរាជ

៣៤ ទេវរុក្ខកុមារ

៣៥ សលភៈ

១ រឿងក្អែកនិងដង្កូវ ការស្រោយប្រាថ្នា៤ខ

២ រឿងកន្លប និងក្រុខដង្កូវ ការស្រាយប្រាថ្នា៤ខ

៣៦ ព្រះសោនន្ទ

៣៧ ទេវន្ត

៣៨ នរជីវកឋិន គួអង្គបំពេញសកម្មភាព ដោយការធ្វើកឋិនទានថ្វាយចំពោះព្រះពុទ្ធ

៣៩ រថសេន

៤០ វរនេត្តវរនុជ

៤១ បទុមត្ថរៈ។ បំពេញកត្តញ្ញូចំពោះមាតា

៤១ សង្ខបត្ត

៤២ សព្វសិទ្ធិ

៤៣ សិទ្ធិសារ "ព្រះសិទ្ធិសារនិងបុញ្ញសារ ជាសម្លាញ់និងគ្នា។

៤៤ ព្រះសិសោររាជ

៤៥ សុបិនកុមារ

៤៦ សុវណ្ណកច្ឆប (ទី១) លះបង់ជីវិតជាទាន ដល់ពួកនាយពាណិជ ដែលកំពុងអត់អាហារ។

៤៧ សុវណ្ណកច្ឆប (ទី២) ជួយយកអាសារតាយាយ ជាឪពុកម្តាយធម៌កាល គ្រាមានទឹកជំនន់។

៥៨ សុវណ្ណវង្ស

៤៩ សូរ្យវង្សវរវង្ស

៥០ អតិទេវរាជ

បញ្ញាសជាតក គឺជាប្រភពដ៏ចម្បងមួយដែលអក្សរសិល្ប៍ខ្មែរ ជាពិសេសរឿងល្បែង ដែលអ្នកនិពន្ធខ្មែរនាសតវត្សទី១៩នោះបានស្រង់យកមករៀបរៀងជាថ្មី។ អត្ថបទបញ្ញាសជាតក ឬ៥០ ជាតកនេះ គឺជាគម្ពីរមួយដែលជនជាតិខ្មែរ និងជនជាតិនៅអាស៊ីភាគអាគ្នេយ៍ស្គាល់ច្បាស់ជាងគេ។ ជាតកប្រភេទនេះគេឃើញមានតែនៅបណ្តាលប្រទេសមួយចំនួនក្នុងតំបន់អាស៊ីអាគ្នេយ៍ យើងនេះ គឺមាននៅប្រទេសកម្ពុជា ថៃ ឡាវ និងភូមា តែប៉ុណ្ណោះ។ តាមអ្នកពិនិត្យស្រាវជ្រាវខ្លះថារឿងនេះគ ចាប់ផ្តើមនិពន្ធឡើងក្នុងកំឡុងពុទ្ធសករាជ ២០០០-២២០០ (រវាង គ.ស.១៤៥៧-១៦៥៧)។ កាល បរិច្ឆេទនេះ ប្រហែលគេយោងសំដៅទៅរកប្រវត្តិសាស្ត្រដែលថែងថា ក្នុងកំឡុងចិរវេលានេះមាន ព្រះភិក្ខុសង្ឃខ្លះ (ខ្មែរ ថៃ លាវ ភូមា) ចេញពីប្រទេសឥណ្ឌូចិន ទៅលង្កាទ្វីបដើម្បីសិក្សាធម្មវិន័យ ដែលជាភាសាបាលី។ លុះចេះដឹងស្ទាត់ជំនាញហើយ បានវិលត្រឡប់មកស្រុកទេសរបស់ខ្លួនវិញ ក៏បានចាប់ផ្តើមនិពន្ធរឿងរ៉ាវផ្សេងៗ តាមទំនងនិទានជាតក ដូចយ៉ាងពួកអ្នកប្រាជ្ញលង្កាទ្វីបធ្លាប់ធ្វើមកហើយ។

ជាតកទាំង៥០រឿង នេះជាប្រភពដ៏ចម្បងមួយសម្រាប់អ្នកប្រាជ្ញ កវី និពន្ធខ្មែរនៅសតវត្សទី ១៩ តែងបានស្រង់លើកយកមករចនាថែមថយនូវសំនួនភាសារបស់លោកជាថ្មីទៀត

បង្កើតបាន ជារូបភាពថ្មី មួយដែលអ្នកសិក្សាផ្នែកអក្សរសាស្ត្រខ្មែរ លោកឲ្យឈ្មោះថា “សាស្ត្រាល្បែង” ឬ “រឿង ល្បែង”។

រឿងអក្សរសិល្ប៍ពុទ្ធនិយមក្លាយ

បង្កើតបាន ជារូបភាពថ្មី មួយដែលអ្នកសិក្សាផ្នែកអក្សរសាស្ត្រខ្មែរ លោកឲ្យឈ្មោះថា “សាស្ត្រាល្បែង” ឬ “រឿង ល្បែង”។

# សង្ខេបរឿង ព្រះសុធនកុមារ

អតីតេ ក្នុងកាលកន្លងមកយូរលង្វងហើយ មានរឿង ដំណាលថាមានព្រះមហាក្សត្រមួយអង្គព្រះនាមព្រះបាទអាទិច្ចវង្សមានអគ្គមហេសីព្រះនាមចន្ទាទេវី គ្រងរាជ្យក្នុងនគរបញ្ញូល។ ទ្រង់មានព្រះរាជបុតមួយអង្គព្រះនាមសុធនកុមារ។ បានសិក្សា សិល្បសាស្ត្រចេះចប់សព្វគ្រាប់ទ្រង់មានចរិយាសម្បត្តិជារីសត្វ ព្រះហឫទ័យនៃព្រះមាតាបិតានឹងព្រះញាតិវង្ស។

នៅទិសខាងលិចក្នុង ឧត្តរបញ្ញូលមានស្រះមួយធំទឹកថ្លាឈ្វេងមានផលជាតិផ្សេង ៗ ដុះស្រាងៗក្នុងស្រះនោះជាទី លំនៅនៃជម្ពូចិត្តនាគរាជ ។ អ្នកស្រុកតែងនាំគ្នាទៅធ្វើពាក់លីការបន់ ស្រន់សុំទឹកភ្លៀងរៀងរាល់ឆ្នាំ ។ ហេតុនេះហើយបានជាអ្នកស្រុក ឧត្តបញ្ញូលធ្វើស្រែបានផលស្រូវបរិបូណ៌មិនដែលអត់ឃ្លានក្នុងឆ្នាំណាមួយឡើយ។

នៅខាងកើត នគរឧត្តបញ្ចាល មានស្រុកមួយឈ្មោះមហាបញ្ចូលកើតទុរ្ភិក្សអត់បាយខ្លាំងណាស់អ្នកស្រុករតចេញទៅនៅនគរដ៏ទៃអស់ច្រើន។ ព្រះរាជាទ្រង់ជ្រាបសភាពដូច្នោះទ្រង់មានបំណងចង់ពិឃាតជម្ពូចិត្តនាគរាជនោះទើបទ្រង់ ប្រជុំពួក ព្រាហ្មណ៍៥០០នាក់ ។ មានព្រាហ្មណ៍ចេះបន្តវិជ្ជាសក្តិសិទ្ធិទទួលយកអាសារទៅពិឃាត នាគរាជនោះចេញ។ បើព្រាហ្មណ៍ទៅធ្វើការ បានសម្រេច ទ្រង់នឹង ប្រទាន រង្វាន់យ៉ាងថ្លៃថ្នូរ។ ឯព្រាហ្មណ៍នោះ ដោយក្តីលោភយសដោយអាងវិទ្ធវេទមន្តរបស់ខ្លួនគឺទទួលយកអាសាទៅធ្វើកាពិឃាតដល់ចិត្តនាគរាជ។ ព្រាហ្មណ៍ស្លៀកស ពានាស ដៃឆ្វេងកាន់ផ្កាសិរមាន់ដៃស្តាំលាត្រង់ឈររាយមន្តលើមាត់ស្រះនោះ ដោយតេជះមន្តទឹកក្នុងស្រះនោះ ក៏ពុះពោរហុយជាផ្សែងទ្រលោមឡើង។...ព្រាហ្មណ៍ឈប់ដេក សម្រាក់នៅឆ្នេរស្រះនោះអស់មួយរាត្រី ព្រឹកឡើងចូលទៅក្នុងព្រៃស្វែងរកថ្នាំ ។ ឯនាគរាជ ក្រឡាខ្លួនជាព្រាហ្មណ៍ម្នាក់ ដេកនៅក្បែរ មាត់ស្រះនោះដែរ ជួនជាខណៈនោះ មានព្រានព្រៃម្នាក់ឈ្មោះបុណ្ឌរិកស្វែងរកបរបាញ់សត្វព្រៃបានចូលមកដល់ទីនោះដែរ។ទើបព្រានកាឡាសួរព្រានព្រៃនោះថា អ្នកជាអ្នកកស្រុកឧត្តបញ្ចូល ឬអ្នកៗ ស្រុកដ៏ទៃ ខ្ញុំជាអ្នកស្រុកនេះឯង តើអ្នកស្រុកអ្នកសម្បូរសប្បាយទេ? សម្បូរសប្បាយទេ តើអ្នកស្រុកអ្នកសម្បូរសប្បាយដោយសារអ្វី? ដោយសារអនុភាពជម្ពូចិត្តអ្នករាជដែលអាស្រ័យនៅក្នុងស្រហនេងឯង បើមានចនណាមានបំនងចង់ពិឃាតជម្ពូចិត្តនាករាជ តើអ្នកគិតយ៉ាងណា? ខ្ញុំនិងប្រហារវាមិនបង្អង់ឡើយ ខ្ញុំនេះហើយជាជម្ពូចិត្តនាគរាជវានិងមករាយមន្តនៅស្រះនេះឯងអ្នកនិងប្រហារវាចេញដោយធ្នូរបស់ហើយអ្នករាជក៏បាត់ខ្លួនទៅ ។បន្តិចក្រោយមក ព្រានព្រៃក៏នាំព្រាព្រៃទៅឋាននាគធ្វើសក្ការះបូជាអស់ប្រាំពីរថ្ងៃក៏នាំព្រានព្រៃនោះមកឋានមនុស្សលោកវិញ។ប្រានព្រៃបានទៅរកបរបាញ់សត្វនៅព្រៃហេនិពានមានរាងសង្ហានបួនជ្រុងមានទុបជាតិដុះហូរហែរតាមមាត់ស្រះនោះ ហើយនៅពេលនោះ មាននាងកីនរីប្រាំពីររូបជាធីតានសព្រះបាទទុម្ភរាជនៅឋានកីលាសនាំបរិវាមកកសាន្តនៅស្រះនោះ ។ ក្រោយពីបានទៅសុំអ្នកបាលពីនាគរាជបានហើយក៏លបពួននៅក្បែរនោះឯនាងកីនរីទាំងប្រាំពីររូបតែងនាំបរិវាមកលេងកសាន្តស្រហស្រង់នោះដូចសព្វដងប្រានប្រែបោះចំណងនាគបាលទៅលើនាងកីនរីទាំងនោះក៏ទៅជាប់ធីតានាងមនោរាធីតាច្បង។ ពួកនាងកិន្នរីដ៏ទៃទៀតគិតភ័យតក្កមាក៏ហោះហើរទៅលើអាកាសយំសោកសង្រេងសង្រៃមាំគ្នាទូលដំណឹងនោះដល់ព្រះវរបិតា។ឯព្រានព្រៃក៏ នាំនាងកិន្នរីមនោរាទៅថ្វាយដល់ព្រះសុធមកុមា ទ្រង់សព្វព្រះហទ័យណាស់ បានប្រទានមាសមួយពាន់ ដប្លឹងជរង្វាន់ដល់បុណ្ឌនិកព្រានព្រៃនោះ ។

សម័យថ្ងៃមួយ ស្រុកបច្ចន្តគ្រាមជាចំណុះនគរឧត្តរបញ្ចាល កើតចលាចលបះបោរឡើង ។ ព្រះបាទអាទិច្ចវង្ស ស្តេចលើកទ័ពទៅបង្ក្រាបខ្លាំង ក៏មិនបានរាបទាបសោះ។ ទើបស្តេចទ្រង់ពិគ្រោះសួរព្រាហ្មណ៍បុរោហិតរបស់ព្រះអង្គបុរោហិតក្រាបទូលថា សូមទ្រង់ត្រាស់ប្រើព្រសុធនកុមារឱ្យចេញទៅច្បាំងវិញទើប សម្រេច។ ទ្រង់ត្រាស់ថាព្រះរាជបុត្រនៅក្មេងពេកក្រែងមិនទាន់ស្ទាត់ជំនាញក្នុងយុទ្ធវិធី។ព្រាហ្មណ៍ក្រាបទូលថា ពិតមែនតែរាជកុមារនៅក្មេងតែទ្រង់ស្ទាត់ជំនាញក្នុងយុត្ថវិធី ហើយមុខជាមានជ័យជំនះពួកលើពួកខ្មាំងមិនខាន។ ក្រោយពីបានទទួលព្រះរាជបញ្ជាហើយព្រះសុធនកុមារក៏លើកទ័ពចេញទៅបង្រាបសត្រូវនៅបច្ចន្តគ្រាមនោះ។

ក្នុងរាត្រីមួយព្រះបាទអាតិត្យវង្សទ្រង់ព្រះសុបិនអស្ចារ្យចម្លែកណាស់គឺទ្រង់ទតឃើញពោះវៀនធំធ្លាយចេញអំពីព្រះឧទរព័ទ្ធរុំជម្ពូទ្វិបដល់ទៅបីជុំរួចឡប់ចូលមកក្នុងព្រះឧទរវិញ។ ត្រង់តើនឡើងទ្រង់តក់ស្លុតរន្ធត់ព្រះទ័យជាខ្លាំងទើបទ្រង់ត្រាស់ហៅបុរោហិត ទ្រង់ត្រាស់

ប្រាប់ពីសុបិននិមិត្តនោះហើយទ្រង់ត្រាស់សួរថាបើបានឃើញដូច្នេះតើនិងមានហេតុភេទដូចម្តេចខ្លះ?

ព្រានបុរោហិតធ្លាប់បានចងគុំនុំព្រះសុធនកុមារពីថ្ងៃមុនហើយគ្រាន់តែទ្រង់មានព្រះបន្ទូលលេងនិងព្រាហ្មណ៍កំល្លោះម្នាក់មានចំណេះចេះស្ទាត់ជំនាញក្នុងគម្ពីរវេទ ហើយធ្លាប់ចេញចូលគាល់ព្រះកុមារហើយតាំងអ្នកឯងឱ្យធ្វើបុរោហិតរបស់ខ្ញុំ។ ហេតុនេះហើយបានជាបុរោហិតរបស់ព្រះអាតិងវង្សចងគំនុំទ្រង់ហើយរកឧបាយកំចាត់ទ្រង់ចេញពីរាជសម្បត្តិ។ ដែលព្រាហ្មណ៍ទូលព្រះវរបិតាទ្រង់ឱ្យបញ្ជូនទ្រង់ទៅបង្រាបសត្រូវនៅបន្ទន្តគ្រាម ក៏ជាឧបាយរបស់ព្រាហ្មណ៍ដែរ។ ហេតុនេះបានជាព្រហ្មណ៍ក្រាបទូលទាយនិមិត្តថ្វាយស្តេអាក្រក់ណាស់ និងមានអន្តរាយដល់រាជសម្បត្តិនគរឬព្រះរាជបុត្រណាមួយមិនខានលុះតែទ្រង់ធ្វើពិធីបូជាយញ្ញដោយជីវិតគ្រាប់ប្រភេទទើបអាចរួចរំដោះអំពីគ្រោះថ្នាក់នេះចេញបាន។ ក្រោយដែលបានតៀមសត្វគ្រប់សព្វ ព្រមទាំងមនុស្សប្រុសស្រីហើយ ព្រាហ្មបានក្រាបទូលថា នៅខ្វះនាងកិន្នរីមួយរូបទៀត។ទ្រង់ប្រាប់ថា រកមិនបានទេ។ ព្រាហ្មក្រាបទូលថា ចុះនាងមនោរា។ត្រង់ត្រាស់ថា ជីវិតកូនប្រសាយើង ក៏ដូចជីវិតកូនយើងព្រាហ្មទូលពន្យល់ដោយន័យផ្សេងៗនៅទីបំផុតទ្រង់គង់នៅស្ងៀម។

ព្រាហ្មណ៍អន្តេរថី ក៏ឆ្កាប់រាជបុរសឱ្យទៅចាប់ព្រះនាងមនោរាទីពីរនៃព្រះសុធនកុមារព្រះនាងភិតភ័យតកមារទើបព្រះនាងបានឡើងទៅគល់ព្រះវមាតាខ្មេកឱ្យជួយសង្រោះរួចពីមរណះភ័យតែមិនសម្រេចក៏ព្រះនាងសុំឱ្យព្រះមាតាទៅសុំបិតាខ្មេកចាំព្រះស្វាមីត្រឡប់មកវិញសិនដើម្បីទូលលាព្រះភស្សស្តារលាទៅបូជាយញ្ញាញតាមប្រះរាជអង្ការ។ ព្រះបាទអាតិវង្សទ្រង់មិនព្រមឱ្យអគ្គមហេសីចូលគល់ព្រះអង្គឡើយ។លុះមរណះភ័យកាន់តែជិតមកខ្លាងហើយទើបព្រះមាតាខ្មេកប្រាប់កន្លែងដែលគេយកស្លាបព្រហនាងកែវមនោរាលាក់ទុកនោះ។ប្រហនាងបានស្លាបហើយក៏ហោះហើរទៅព្រះហេនិពានសំដៅទៅអាស្រមកសិបតសីបានបណ៌នារឿងផ្សេងៗ ព្រះនាងបានប្រគល់សំពតកំពលនិងព្រះទំរងមយយវង្សទុកនិងតសីទុកថ្វាយព្រះស្វាមី។ ព្រហនាងទូលផ្តាំ តាមស រួចហើយ បានចូលពុទ្ធដីកា តទៅទៀតថា ប្រសិនបើព្រះស្វាមីមកតាមព្រះនាងដល់ទីនេះ សូមកុំឱ្យទ្រង់បន្តដំណើរតទៅទៀត។ ព្រោះផ្លូវកម្រហើយឆ្ងាយណាស់ផង។ ប្រសិនបើព្រះស្វាមីមិនព្រមត្រឡប់ទេសូមឱ្យយកឱសថនេះផ្សំនឹងមន្តសូន្យជា កុលិការួចដើរសំដៅទៅទិសខាងជើង និងដល់ព្រៃថ្នាំពិស សូមឱ្យយកកូនស្វាទៅជាមួយផង សុមឱ្យត្រង់សោយតែផ្លែឈើណាដែលកូនស្វាបះស៊ីរហូសពីនោះទៅដល់ទៅព្រៃផ្តៅព្រែក ឱ្យកយសំពត់រុំខ្លួនប្រះផ្តុំទៅ និងមានសត្វហត្ថិលិង្គយកទៅដាក់ដល់ត្រើយខាងនាយនៃសមុទ្រ ។ តពីរនោះទៅនឹងឃើញនាគពីរបាំងគ្នា សូមឱ្យព្រះសាមី សេកបន្តសោយថ្នាំគុលិកា រួចដើរទៅតាមចន្លោះជើងនាគ ហើយទ្រង់នឹងទតឃើញភ្នំពីរទង្គិចគ្នា ។ សេតបន្តហើយដើរកាត់នោះទៅ នឹងបានដល់ទៅលំនៅបេយក្សអារក្សទឹក រួចដល់ព្រៃស្បូវភ្លាំង-ស្បូវណ្តាស - ព្រៃឫស្សី ព្រៃបបុស ព្រៃបន្លា ព្រៃស្បាក ភ្នំ ផង ព្រៃតំ មានយក្សធំកំពស់ប្រាំពីរដើមត្នោត សូមឱ្យព្រះស្វាមីយកថ្នាំគុលិកាលាបសររួចបាញ់ដើមទ្រូងយក្សនោះៗស្លាប់ហើយសឹមធ្វើដំដើរតទៅទៀត និងបានដល់ទៅស្ទឹងទឹកក្រុត សូមឱ្យព្រះស្វាមីយកថ្នាំគុលិកាលាបផ្ទៃព្រះបាទសិមដើរទៅឡៀត និងដល់ទៅព្រៃផ្តៅធំមួយ នៅត្រង់កណ្តាលព្រៃនេះ មានដើមឈើ ធំសំបើមមួយដើម ជាលំនៅសត្វឥន្ទ្រី សូមឱ្យព្រះស្វាមីចូល ជ្រកពួនក្នុងចន្លោះស្លាបឥន្ទ្រី ៗ ឥន្ទ្រីនឹងនាំទ្រង់រហូតដល់កំពូលភ្នំជាលំនៅកៃលាសជាលំនៅនៃព្រះនាង។

ឯព្រះឯព្រះសុធនកុមារក្រោយដែលទ្រង់បានបង្ក្រាបការចលាចលត្រឡប់មកចូលក្នុងបច្ចន្តគ្រាមរាបទាបហើយទើបទ្រង់លើកទ័ពព្រះនគរវិញ ហើយទ្រង់បានជ្រាបរឿងរ៉ាវព្រះនាងមនោហរាសព្វទ្រងសោកសង្រេងក្រៃលេងលុះត្រាតេសម្លប់បាត់ស្មារតីលុះទ្រង់មានព្រះស្មារតីឡើងហើយទ្រង់ទូលលាព្រះមាតាទៅតាមនាងមនោរាទ្រង់បានតាំងព្រានព្រៃឈ្មោះបងាកតិកជាអ្នកឧទេសនាំផ្លូវដើរសំដៅទៅកាន់អាស្រមព្រះសបតសី តសីបានទូលទ្រង់ពីបណ្តាំនាងមនោរាសព្វគ្រប់ទ្រង់បានសេបមន្តផ្សំជាឱសថផ្សំជាលិកាស្តេចមស្តាលាតសីឱ្យព្រាហ្មត្រឡប់ទៅស្រុកវិញ។ទ្រង់បេរព្រះភគ្រ័ទៅទិសខាងជើងវិញតែមួយព្រហអង្គឯងដោយក្តីស្នេហាទៅដល់កំពូលភ្នំកីលាដូចក្តីប្រាថ្នា។កាលនោហមាននាងកីនរីកាន់ខ្អមទឹកទោដងទឹកស្រះដូចក្តីប្រាថ្នា ដើម្បីយកទៅស្រងស្រង់ព្រះកាយព្រហនាងកែវមនោរា។ ព្រះសុធនបានទតឃើញនាងទាំងនោះដែរក្រោយទតឃើញព្រហអង្គអធិស្ថានសូមកុំឱ្យនាងទីប្រាំពីរលើកខ្អមទឹករួចហើយទ្រង់យាងទៅជួយលើក ហើយទ្រង់ក៏បានពត៌មានទ្រង់លបដាក់ព្រហទំរ័ត្មនៅបាតខ្អមមិនៀនាងកីនរីនោះបានឃើញលើយដើម្បីឱ្យជ្រាបដំណឹងដល់នាងកែវមនោរាក្រោយពីបានដល់ខ្អមចុងក្រោយព្រហនាងបានដឹងប្រហស្វាមីមកព្រះនាងឱ្យនាងកីនរីយកសំពត់ទិព្វទៅ

ថ្វាយព្រះស្វាមីព្រះនាងនាំព្រះស្វាមីជួបព្រះមាតាបិតាព្រះអង្គប្រឡងសិល្បសាស្ត្រព្រះអង្គអភិសេកអ្នកទាំងពីរសោយរាជ្យក្រោយមកក្រោយមកប្រះនាងនិងគ្រួសារបរិវារមកឋានមនុស្សព្រះអង្គអាទិវង្សបានរៀបអភិសេកព្រះសុធននិងនាងកែវមនោរា។

## ក.អត្ថន័យខ្លឹមសារ

អត្ថន័យអត្ថ ប្រយោជន៍ អត្ថន័យ ការណែនាំអត្ថាធិប្បាយសេចក្តីពន្យល់ អត្ថន័យជាគំនិតសំខាន់ៗរបស់អ្នកនិពន្ធដែលលាតត្រដាងនៅក្នុងដំណើររឿង ហើយគេអាចហៅវាថាជាជម្រៅនៃរឿង។

ក្នុងផ្នែកអត្ថន័យមាន ប្រធានរឿង មូលបញ្ហារឿងនិងឧត្តមគតិរឿង។

## ខ.ប្រធានរឿងមូលន័យ

ប្រធានរឿងឬមូលន័យ គឺជាគំនិតសំខាន់ៗរបស់រឿង។ ប្រតិឬជាបញ្ហារួមរបស់រឿង។ តែអ្នកនិពន្ធចង់បង្ហាញដល់អ្នកអានប្រធានរឿងជាបញ្ហារួបផ្តុំបំផុតដែលអ្នកនិពន្ធលើកយកមកសរសេរឬជ្រើសរើសជាប្រធានបទហើយដែលមានមូលបញ្ហារឿងឋិតនៅក្នុងនោះ។

ប្រធានរឿងបង្ហាញនៅចំហររបស់អ្នកនិពន្ធវាជាមូលដ្ឋានដើមរបស់អ្នកនិពន្ធក្នុងការចាប់ផ្តើមសរសេរឡើង។មុនពេលចាប់ផ្តើមសរសេរឡើង។ អ្នកនិពន្ធគ្រប់រូបត្រូវកំណត់ថាតើគាត់ត្រូវសរសេរអំពីអ្វី។ អំពីជីវិតសង្គមសង្គ្រាមស្នេហារឿងជំនឿទនៀមទម្លាប់ប្រពៃណីចម្លើយរបស់សំណួរនេះហើយជាប្រធានរឿង។

តាមរយៈការសិក្សារឿងនេះ បានបង្ហាញអ្នកសិក្សាស្វែងយល់អំពីប្រធាមរឿង ភក្តីភាពព្រះសុធននិងព្រះនាងកែវមនោរា ។

## គ.មូលបញ្ហារឿង

មូលបញ្ហារឿងគឺជាភាពចំណែកនៃប្រធានរឿងជាទិដ្ឋភាពផ្សេងៗរបស់យើង។វាជាការចូលជ្រៅទៅក្នុងប្រធានរឿង។

ជុំវិញប្រធានរឿងនេះ យើងបានកំណត់បញ្ហាជាច្រើន ដែលនៅជុំវិញការកសាងសីលបារមីរបស់ព្រះពោធិសត្វ បញ្ហាទាំងនោះរួមមានៈ

## ទី១ បញ្ហាការយោសុបិណ្ឌ

ការយល់សុបិនរបស់ព្រះបាតអាតិត្យបានយល់សុបិនឃើញពោះវៀនធំធ្លាយចេញពីព្រះឧទរវ៉ុទ្ធិបដល់ទៅបីជុំរយចត្រូឡប់ចូលមកព្រះឧទរវិញហើយសួរទៅព្រាហ្មណ៍ថា បើឃើញហេតុភេទដូចនោះតើមានបញ្ហាអ្វីខ្លះ ព្រាហ្មណ៍ទូលថា ព្រះសុបិននោះអាក្រក់ណាស់និងមានអន្តរាយដល់រាចសម្បត្តិឬដល់ប្រះរាជទីពីឬរាជបុត្រមួយណាមិនខាន ព្រហ្មបានបង្គប់ឱ្យព្រះអង្គធ្វើពិធីបូជាយញ្ញនិងជីវិគ្រប់ប្រភេទទើអាចរួចរំដោះពីគ្រោះថ្នាក់នេះបាន ព្រះអង្គក៏ធ្វើតាមបានតៀមសត្វនិងជីវិតមនុស្សប្រុស្រីហើយ ។ ពេលនោះព្រាហ្មបាននិយាយថា ខ្វះនាងគីនរីមួយទៀត។ បន្ទាប់បកព្រះអង្គប្រាប់ថារកមិនបានទេ ព្រហ្មបន្តថាឱ្យយកនាងកែវមនោរាព្រះអង្គបានប្រកែ ពរាហ្មក៏ឱ្យគរទៅចាប់ព្រះនាងកែវមនោរា។ពេលនោះព្រះនាងភិតភ័យយ៉ាងខ្លាំងបានទៅរកឱ្យព្រះមាតាជួយតែព្រះមាតាជួយបមបានសេចក្តីស្លាប់គៀជិតមកដល់ហើយព្រះមាតាអាណិតបុត្រក៏ប្រាប់កន្លែងលាក់ស្លាបព្រះនាងកែវមនោរាព្រះនាងបានស្លាបដោះទៅកន្លែងព្រះនាងទៅ។

សរុបមកមុននិងជឿលើរឿងអ្វីមួយឱ្យចេះរិះកិតពិចារណាឱ្យបានត្រឹមត្រូវជាមុនសិនដើម្បីកុំឱ្យមានកំហុសស្តាយក្រោយ។

## ទី២ បញ្ហាការស្វែងរកព្រះនាងកែវមនោរា

ព្រះសុធនកុមារដឹងថា ព្រះនាងកេវមនោរាបានជុបរឿងជាច្រើននៅក្នុងនគររបស់ទ្រង់រហូតបានចាកចេញពីនគរព្រះអង្គបានយំសោកអាឡិតព្រះនាងរហូតដល់សន្លប់។ ក្រោយមកព្រះអង្គបានទៅតាមរកព្រះនាងបាននាំព្រាហ្មព្រៃទៅជាមួយធ្វើដំណើរទៅបានជួបនិងក

សប៉តសីបានពណ៌នារៀបរាប់ពីបណ្តាំព្រះនាងប្រាប់ព្រះសុធនកុមាតថា  សូមយកឱសថផ្សំមន្តស្លូន្យជាគុលិកា ដើរសំដៅទៅទិសខាងជើង ដល់ព្រៃថ្នាំពិស យកកុនស្វាទៅជាមួយសោយផ្លែឈើណាដែលកូនស្វាបេះស៊ីបានហើយ ដល់ព្រៃផ្តៅក្រែក ឱ្យយកសំពត់រុំខ្លួន ប្រះផ្ទុំទៅមានសត្វហត្ថិលិង្គឆាបយកព្រះអង្គដាល់នៅត្រើយខាងនាយនៃសមុទ្រ។ បន្ទាប់មកឃើញយក្សពីរច្បាំងគ្នាសូមសេបមន្តជាថ្នាំគោលិកាដើរតាមថន្លោះជើងនាគ  ឃើញភ្នំពីរទង្គិចគ្នាសេកមន្តដើរកាត់ផ្ទំនោះ ទៅលំនៅនៃយក្សអារ័ក្សទឹក ដល់ស្ទួរភ្លាំង ស្ទួរវណ្ណាស ព្រៃឬស្សី ព្រៃបបុស ព្រៃស្បាត ភ្នំ ដងព្រៃធំ មានយក្សធំកំពស់៧ដើមត្នោត យកថ្នាំគុលិកាលាបសររួចបាញ់ដើមទ្រូងយក្សនោះនិងស្លាប់ហើយ  ធ្វើដំណើរទៅទៀតដល់ស្ទឹងតឹកត្រុតយកថ្នាំគុលិកាលាបផ្ទៃព្រះបាទនៅខាងមុខដល់ព្រៃផ្តៅធំមួយនៅត្រង់កណ្តាលព្រៃនោះមានដើមឈើសំបើមមួយដើមជាលំនៅរបស់សត្វឥន្ទ្រីៗ និងនាំទ្រង់រហូតដល់ទៅកំពូលភ្នំកៃលាសជាលំនៅនៃព្រះនាង។ពេលស្តប់ចប់ហើយព្រះអង្គបានធ្វើតាមបណ្តាំព្រះនាងកែរមនោរាគ្រប់យ៉ាងរហូតបានដល់កន្លែងព្រះនាងរស់នៅ ។ ពេលនោះព្រះសុធនបានឃើញនាងកិន្នរីកាន់ខ្អមទឹកទៅដងទឹកកក់ស្រង់ព្រះនាងកែរមនោរា។ព្រះអង្គសូមកុំឱ្យនាងទី៧លើកខ្អមទឹករួចព្រះអង្គទៅជួយលើកបានលូចដាក់ព្រះទំរងក្នុងបាតខ្អមនោះ។ ក្សត្រទាំងពីរបានជួបគ្នាបាននាំព្រះសុធនកុមារទៅជួបព្រះមាតាបិតាព្រះអង្គមិនខឹងនិងបុត្រឡើយ។

សរុបមកសេចក្តីព្យាយាមបានជួយ  ឱ្យយើងបានសម្រេចនូវគោលបំណងគ្រប់យ៉ាងរបស់ខ្លួនបានជោគជ័យ ។

## ឃ.ឧត្តមគតិរឿងគំនិតដឹកនាំរឿងតម្លៃអប់រំ

ឧត្តមគតិរឿងគឺជាឧត្តមគតិរបស់អ្នកនិពន្ធ។ឧត្តមគតិរឿងគឺយកកត្តាប្រធានវិស័យដែលបញ្ញាដែលបញ្ជាក់ពីគោលជំហរសតិអារម្មណ៍របស់អ្នកនិពន្ធដែលស្តែងឡើងតាមរយៈសកម្មភាពរបស់តួអង្គ។

- អប់រំឱ្យមនុស្សមានសេចក្តីព្យាយាមជំនះរាល់ឧសក្ក
- អប់រំមនុស្សឱ្យមានសេចក្តីស្រឡាញ់ស្មោះត្រង់ចំពោះគ្នា
- អប់រំធ្វើឱ្យមនុស្សចេះជួយគ្នាទៅវិញទៅមក
- អប់រមមនុស្សមិនឱ្យបំភ្លេចគុណអ្នកដ៏ទៃដែលបានធ្វើអំពើល្អមកលើខ្លួន
- អប់រំមនុស្សកុំឱ្យមានសេចក្តីក្រោធនៅក្នុងចិត្ត។

សរុបជារួមមករៀងព្រះសុធនកុមារ  បានបង្ហាញពីការតស៊ូអំណត់ព្យាយាមរបស់ ព្រះសុធនកុមារដើមបានជួបមនុស្សជាទីស្រឡាញ់ទោះឧសគ្គយ៉ាងណាព្រះអង្គរកបានជួប  និងឱ្យយើងចេះអត់ធ្មតតស៊ូ ក្នុងការរស់នៅប្របករបររកស៊ីប្រចាំថ្ងៃ និងចេះជួយគ្នាទៅវិញទៅមកផងដែរ។

# សង្ខេបរឿង ទុលកបណ្ឌិត

មានសេចក្តីដំណាលថា ក្នុងសម័យកន្លងយូរអង្វែងហើយនោះមានព្រះ រាជាមួយ ព្រះអង្គព្រះនាមចិនៈ គ្រងរាជ្យក្នុងដែនចិនរដ្ឋ មានព្រាហ្មណ៍បុរោហិត ម្នាក់ជាទីប្រឹក្សា ។ សម័យមួយបុរោហិតបានគយគន់ឃើញភិក្ខុ ៣៣ រូប កំពុង ដើរបិណ្ឌបាតតាមដងវិថី ក៏គិតក្នុងចិត្តអាត្មាថា “សមណៈទាំងនេះមានឥរិយាបថ រម្យទមគួរជាទីជ្រះថ្លា ។ ថ្ងៃណាមួយ ព្រះរាជាគង់នឹងសព្វព្រះទ័យចំពោះភិក្ខុ ទាំងនោះ ហើយលាភសក្ការៈរបស់អាត្មាអញ នឹងរៀររោយសាបសូន្យទៅវិញពុំ ខាន ដូច្នេះគួរអាត្មាអញរកមធ្យោបាយទូលព្រះរាជាឱ្យកំចាត់ចេញ” ។ ព្រាហ្មណ៍គិតដូច្នេះហើយក៏ឡើងក្រាបទូលព្រះបាទចិនរដ្ឋថា សូមទ្រង់ព្រះមេត្តាប្រោស ឥឡូវនេះពួកចោរព្រៃរួមខ្លួនជាភិក្ខុ ចូលមកនៅច្របូកច្របល់នឹងអ្នកស្រុក សូម ទ្រង់មានព្រះរាជបញ្ជាចាប់ខ្លួនចោរទាំងនោះយកទៅពិឃាតចោលចេញ” ។

ព្រះរាជាទ្រង់មានព្រះបញ្ជាដល់ពួកពេជ្ឈឃាតឱ្យទៅចាប់ចងព្រះសង្ឃទាំង ៣៣ អង្គ ឱ្យយកទៅពិឃាតចោលនៅព្រៃស្មសាន។ ដំណឹងនេះបានដឹងដល់ ទៅកូនសេដ្ឋីម្នាក់ឈ្មោះ ទុលកបណ្ឌិត១ បានចូលទៅរកព្រះនាគទីបកត្ថេរ ហើយ សួរអំពីទោសកំហុសរបស់លោក១ មានពុទ្ធដីកាថា “ក្នុងបច្ចុប្បន្ននេះអាត្មាភាព រាល់គ្នា មិនមានកំហុសអ្វីឡើយ ចំណែកខាងអតីតជាតិអាត្មាភាពរាល់គ្នាមិន អាចដឹងបានទទួលកបណ្ឌិតបានដោះគ្រឿងអលង្ការរបស់ខ្លួនឱ្យទៅពួកពេជ្ឈឃាតប្រាប់ថា សូមទ្រង់ព្រះមេត្តាប្រោសទូលបង្គំសូមថ្វាយមាស ឬ ប្រាក់តាមសព្វព្រះហឫទ័យ ដើម្បីទិញជីវិតភិក្ខុទាង៣៣រូបនេះ ដើម្បីឱ្យលោកម្ចាស់មានជីវិតរស់រានទៅទៀត។ ព្រះរាជាក៏អនុញ្ញាត្តិតាមសុំ។ អ្នកប្រញាប់ប្រញាល់ទៅសុំមាសពីម្តាយអ្នក

មកគរទុកឱ្យអាមាត្រយកជញ្ជីងមកថ្លឹង មាសឱ្យស្មើរភាពទម្ងន់ភិក្ខុមួយរូបៗត្រាតែអស់មាសទាំងគំនរនោះទៅនៅសល់ភិក្ខុ៣រូបទៀត ។ ពួកអាមាត្រក៏ដោះលែងភិក្ខុទាំង៣០រូបនោះទៅ ។ អ្នកទូលស្តេចសូមឱ្យបង្អង់បន្តិចសិន ហើយអ្នកទៅផ្ទះប្រាប់ប្រពន្ធកូនថា អ្នកនិងលក់ខ្លួនដើម្បីលោះភិក្ខុ៣អង្គទៀតអ្នកផ្ទះស្នាក់ចិត្តគ្រប់ៗគ្នាយកខ្លួនពួកគេទៅលក់វិញចុះ។ ចំនួនមាសនោះលាស់បានចំនួនភិក្ខុ២រូបនៅសល់សាមណេរតូចមួយរូបទៀត។ សាមណេរភ័យក្តីស្លាប់មហិមារយំសោកបោកខ្លួនប្រាណមុខគួរឱ្យអាណិតអាសូរពន់ពេក។

ទុលកបណ្ឌិតឃើញដូច្នោះហើយចូលទូលព្រះរាជាថា សូមទ្រង់ព្រះមរតត្តាប្រោសតូលព្រះបង្គំសូមយកជីវិតមកជំនួសសាមណេរអង្គនេះ សូមព្រះករុណាជាម្ចាស់ដោះលែងលោកចុះ។ព្រះរាជាក៏យល់ព្រមតាមសុំ ។ទុលកបណ្ឌិតបានប្រកាសដល់ពួកទេវតាថាៈ

បពិតទេវតាក ក្នុងឆកាមាវចរសួគ៌ សូមអញ្ជើញស្តាប់ពាក្យខ្ញុំ ក្បិតខ្ញុំបានលះបង់ជីវិតនេះ ព្រោះហេតុចង់បានពោធិញ្ញាណតែមួយមុខប៉ុណ្ណោះ។ ទេវតាដែលឋិតនៅលើអាកាសក្តីនៅលើផែនដីក្តី នាគទាំងឡាយក្តី អារក្សទេវតា ក្តី សូមអនុមោទនាបុណ្យដែលកើតពីការបរិច្ចាគជីវិតនេះ ខ្ញុំសូមឱ្យបានត្រាស់ ព្រះពុទ្ធ ចម្លងទេវតាមនុស្សនឹងសត្វទាំងឡាយទៅកាន់ត្រើយនៃព្រះនិព្វាន ។ កាលបើខ្ញុំនៅអន្ទោលក្នុងវដ្តសង្សារ សូមកុំឱ្យជួបប្រទះនឹងទុជ៌នទាំងឡាយ សូម ឱ្យបានជួបសមាគម តែនឹងលោកសប្បុរសដរាបដល់ព្រះនិព្វាន កុំបីឃ្លៀងឃាត ឡើយ” ។

បន្ទាប់មក ពួកពេជ្ឈឃាតក៏ចាប់ចងខ្លួនទុលកបណ្ឌិតដោយចំណង ប្រការរួចនាំខ្លួនទៅព្រៃស្មសាន ។ ថ្ងៃនោះ មានដំណឹងដឹងដល់ម្តាយអ្នក ១ រលះ៖ រលាំងយំសោកបោកខ្លួនប្រាណចំពោះមុខអ្នក ហើយនិយាយអង្វរអ្នកឱ្យត្រឡប់ ទៅគេហដ្ឋានវិញ តែមិនសម្រេច ។ ជួនជាក្នុងថ្ងៃនោះសុជាតព្រាហ្មណ៍ ត្រឡប់ មកពីក្រុងបាតលិបុត្ត ដល់មកចិននគរ ក៏បានដំណឹងពីបុត្រអាត្មាភ្លាម ក៏រលះ៖ រលាំងចូលទៅក្នុងវាំង ក្រាបទូលស្តេចសូមលោះយកបុត្រអាត្មាទៅវិញដោយផ្ទូរជា មាសប៉ុនខ្លួនទុលកបណ្ឌិត ។

ចំណែកខាងព្រះថេរានុត្ថេរ ៣៣ អង្គ មានព្រះមហាថេរជាប្រធានបាន ព្រមានដល់ភិក្ខុទាំងឡាយ យើងរាល់គ្នាបានរស់រួចជីវិតដោយសារទុលកបណ្ឌិត ហេតុនេះត្រូវយើងព្យាយាមចំរើនកម្មដ្ឋាន ឧទ្ទិសកុសលដល់គាត់ ដើម្បីតបគុណ គាត់ទើបគួរ ។ ព្រះថេរទាំង ៣៣ អង្គកំខំព្យាយាមចំរើនកម្មដ្ឋាន ត្រាតែបាន សម្រេចអរហត្តគ្រប់រូប ហើយនាំគ្នាហោះឡើងទៅកាន់អាកាសវេហាស៍ សំដែង ឥទ្ធិឫទ្ធិដ៏អស្ចារ្យជាអនេកប្រការ ។ ព្រះរាជាបានទតឃើញដូច្នោះ មានព្រះទ័យ តក់ស្លុតភិតភ័យតក្កមា ទើបទ្រង់ពិគ្រោះសួរអាមាត្យ១ បានទូលថា សូមព្រះអង្គឱ្យហៅចូលកបណ្ឌិតបកសួរ លុលកបណ្ឌិតបានចូលដល់ទ្រង់ត្រាស់ថ ម្នាលចូលកបណ្ឌិត ពួរចោរ

៣៣ រូប ដែលអ្នកឯងបានដោះលែង ឥឡូវ នេះហោះមកតាមអាកាស ប្រុងមកសម្លាប់យើង សូមអ្នកជួយដោះទុក្ខយើង ផង” ។ ទុលកបណ្ឌិតបានស្តាប់ព្រះឱង្ការនេះហើយ អ្នកមានចិត្ត អំណរត្រេកអរ ណាស់ ទើបក្រាបទូលព្រះរាជាវិញថា “សូមទ្រង់កុំបីព្រួយបារម្ភឡើយ ទូលព្រះបង្គំនឹងនិមន្តលោកទាំងនោះ ឱ្យចុះមកក្នុងកាលឥឡូវនេះឯង” ។ លុះពងលោម ព្រះរាជាដូច្នោះហើយ អ្នកក៏បានពោលពាក្យថា “បពិត្រលោកម្ចាស់ទាំងឡាយ ខ្ញុំករុណាឈ្មោះទុលកបណ្ឌិត សូមនិមន្តលោកម្ចាស់” ។

បុព្វជិតទាំង ៣៣ រូប បានព្រះរទើបករត្តេរជាប្រភេទ ក៏បានចុះពី អាកាសមកគង់លើអាសនៈ ដែលគេបានក្រាលបំរុងទុកក្នុងព្រះរាជវាំង ។ ព្រះ បាទចិនរាបាននមស្ការថ្វាយបង្គំដោយគោរព ហើយទ្រង់បានធ្វើសក្ការបូជាផ្សេងៗ ។ ព្រះនាគទីបករត្តេរបានសំដែងធម៌ថ្វាយព្រះរាជាថាៈ

បពិត្រមហារាជ! ការសេពគប់នឹងសប្បុរសតែមួយគ្រា អាចរក្សាការពារ អ្នកសេពគប់បាន ការសេពគប់នឹងអរសប្បុរស បើទុកជាច្រើនដង ក៏មិនអាចរក្សា ការពារអ្វីបានឡើយ ។

ដូច្នេះបុគ្គលគប្បីសេពគប់ នឹងពួកសប្បុរស គប្បីស្និទ្ធស្នាលជាមួយនឹង សប្បុរស បុគ្គលដែលបានដឹង ធម៌របស់សប្បុរសជាក់ច្បាស់ហើយ រមែងទៅជា អ្នកវិសេសថ្លៃថ្លា មិនថោកទាបឡើយ ។

អ្នករង្វេងសាកសួរអ្នករង្វេងដូចគ្នា នឹងនាំឱ្យកាន់តែរង្វេងខ្លាំងឡើងនោះនឹងមានសេចក្តីក្តៅក្រហាយស្តាយក្រោយជាប្រក្រតីការសេពគប់នឹងជនពាល៏មានទំនងដូច្នោះដែរ ។

ស្លឹកឈើដែលគេខ្ចប់ប្រហុក ស្លឹកនោះក៏ផ្សាយក្លិនស្អុយចេញមក ការសេព គប់នឹងពាលក៏មានទំនងដូច្នោះដែរ ។

ស្លឹកឈើដែលគេខ្ចប់គ្រឹស្នានឹងខ្លឹមច័ន្ទន៍ ស្លឹកនោះ ក៏ផ្សាយក្លិនក្រអូបចេញ

មក ការសេពគប់នឹងបណ្ឌិត ក៏មានឧបមាដូច្នោះដែរ” ។

លុះចប់ឱវាទដំបូន្មាននេះហើយ ព្រះរាជាមានព្រះទ័យរីករាយជ្រះថ្លា ទើប ទ្រង់ប្រគល់ថ្វាយខ្លួនចំពោះព្រះរតនត្រៃ តាំងអំពីថ្ងៃនោះរៀងមក ទ្រង់បាន ឱ្យប្រកាសទូងស្គរ ប្រាប់មហាជនក្នុងព្រះនគរ កុំមានសេចក្តីប្រមាទ ព្រះរតនៈ ក្រោយពេលដែលព្រះថេរៈទាំងនោះត្រឡប់ទៅកាន់អារាមវិញហើយព្រះរាជាទ្រង់បានចាត់តាំងទុលកបណ្ឌិតក្នុងតំណែងសេនាបតី ហើយ ទ្រង់ឱ្យបំបរ បង់ព្រាហ្មណ៍បុរោហិតនោះ ចេញចាកខេត្តដែលរបស់ព្រះអង្គ ។

ព្រះរាជានឹងទុលកបណ្ឌិត បានខំប្រឹងប្រែងប្រព្រឹត្តតែអំពើសុចរិតធម៌នឹង ការកុសលផ្សេងៗ មានទានសីលជាដើម ដរាបដល់អស់ព្រះជន្មាយុ ។

## ក.អត្ថន័យខ្លឹមសារ

អត្ថន័យអត្ថ ប្រយោជន៍ អត្ថន័យ ការណែនាំអត្ថាធិប្បាយសេចក្តីពន្យល់.អត្ថន័យជាគំនិតសំខាន់ៗរបស់អ្នកនិពន្ធដែលលាតត្រដាងនៅក្នុងដំណើររឿង ហើយគេអាចហៅវាថាជាជម្រៅនៃរឿង។

ក្នុងផ្នែកអត្ថន័យមាន ប្រធានរឿង មូលបញ្ហារឿងនិងឧត្តមគតិរឿង។

## ខ.ប្រធានរឿងមូលន័យ

ប្រធានរឿងឬមូលន័យ គឺជាគំនិតសំខាន់ៗរបស់រឿង។ប្រតិឬជាបញ្ហារួមរបស់រឿង។ តែអ្នកនិពន្ធចង់បង្ហាញដល់អ្នកអានប្រធានរឿងជាបញ្ហារួបផ្តុំបំផុតដែលអ្នកនិពន្ធលើកយកមកសរសេរ ឬជ្រើសរើសជាប្រធានបទហើយដែលមានមូលបញ្ហារឿងឋិតនៅក្នុងនោះ។

ប្រធានរឿងបង្ហាញនៅចំហររបស់អ្នកនិពន្ធវាជាមូលដ្ឋានដើមរបស់អ្នកនិពន្ធក្នុងការចាប់ផ្តើមសរសេរឡើង។មុនពេលចាប់ផ្តើមសរសេរឡើង។អ្នកនិពន្ធគ្រប់រូបត្រូវកំណត់ថាតើគាត់ត្រូវសរសេរអំពីអ្វី។អំពីជីវិតសង្គមសង្គ្រាមស្នេហារឿងជំនឿទនៀមទម្លាប់ប្រពៃណី ចម្លើយរបស់សំណួរនេះហើយជាប្រធានរឿង។

តាមរយៈការសិក្សារឿងនេះ បានបង្ហាញអ្នកសិក្សាអំពីការបំពេញបារមីរបស់ព្រះពោធិសត្វ ពោលគឺមេត្តាបារមី ព្រះពោធិសត្វ ឬ ទុលកបណ្ឌិត។

## គ.មូលបញ្ហារឿង

មូលបញ្ហារឿងគឺជាភាពចំណែកនៃប្រធានរឿងជាទិដ្ឋភាពផ្សេងៗរបស់យើង។វាជាការចូលជ្រៅទៅក្នុងប្រធានរឿង។

ជុំវិញប្រធានរឿងនេះ យើងបានកំណត់បញ្ហាជាច្រើន ដែលនៅជុំវិញការកសាងសីលបារមីរបស់ព្រះពោធិសត្វ បញ្ហាទាំងនោះរួមមានៈ

### ទី១ បញ្ហាការចាប់ភិក្ខុសង្ឃទាំង៣៣រូប

ព្រះបាទចិនៈបានជឿតាមពាក្យញុសញង់របស់ព្រាហ្មដោយប្របាននិយាយថា ចោរមកបន្លំខ្លួនជាភិក្ខុហើយរស់នៅលាយឡំជាមួយអ្នកស្រុកពេលព្រះរាជាបានស្តាប់ហើយជឿតាមបានបញ្ជាឱ្យពេជឃាតឱ្យទៅចាប់ចងភិក្ខុសង្ឃទាំង៣៣អង្គយកទៅពិឃាដចោលនៅព្រះស្មោសាន្ត។ ក្រោយមកដំណឹងនេះបានដឹងដល់កូនសេដ្ឋីឈ្មោះ ទុលកចណ្ឌិត ទុលកបណ្ឌិតបានចូលទៅរកព្រះនាគទីបគ្មោះ ហើយទូលសួរអំពីទោសរបស់លោក អាត្មាភាពរាល់គ្នាមិនមានទោសកំហុសអ្វីឡើយ ចំណែកខាងអតីតជាតិ អាត្មាភាពរាល់គ្នាមិនអាចដឹងបានទេ ។ ពេលនោះបានដោះគ្រឿងអលង្កាឱ្យទៅពួកពេជ្ឈឃាតសូមបង្អង់ចាំបន្តិចចាំខ្ញុំទៅក្រាបទូលព្រះករុណាសិន ហើយអ្នកឡើងទៅក្រាបទូលព្រះរាជាថា សូមទ្រង់ព្រះមេត្តាប្រោសទុលបង្គំសូមថ្វាយមាសប្រាក់ដើម្បីលោះជីវិតផិក្ខុទាំង៣៣អង្គនេះ ព្រះករុណាបានយល់ព្រម ។ រួចព្រះរាជាឱ្យទុលកបណ្ឌិតទៅដឹកមាស ឬ ប្រាក់មកគរទុក។ នៅពេលដឹកមាស និងប្រាក់មកអស់ហើយ ព្រះរាជាបញ្ជាឱ្យរាជអមាត្រយកជញ្ជីងមកថ្លឹងមាសតាមតម្ងន់ភិក្ខុមួយៗរូប។ មាសប្រក់មួយគំនរនោះមិនគ្រាន់នៅសល់ភិក្ខុ៣រូបទៀត។ បន្ទាប់មកទុលកបណ្ឌិតប្រាប់ព្រះរាជាថាខ្លួនលោះភិក្ខុ៣អង្គទៀត ពេលទោដល់ផ្ទះប្រាប់អ្នកផ្ទះអ្នកផ្ទះបសនយាត់សុំខ្លួនទៅជំនួស មាសបានគ្រប់តែភិក្ខុ២រូបនៅខ្វះមួយរូបទៀត ។ រួចទុលកបណ្ឌិតទូលព្រះរាជាថា ទូលបង្គំសូមលះបង់ជីវិតជំនួសសាមមណេរអង្គនេះ។ទុលកបណ្ឌិតបានប្រកាសដល់ពួកទេវតាថា

បពិតទេវតា ក្នុងឆកមាវចរសួគ៌ សូមអញ្ជើញស្តាប់ពាក្យខ្ញុំ ក្បិតខ្ញុំបានលះបង់ជីវិតនេះ ព្រោះហេតុចង់បានពោធិញ្ញាណមួយមុខប៉ុណ្ណេះដើម្បីស្រាស់ជសព្រះពុទ្ធ ចម្លងទេវតា មនុស្ស និងសត្វទាំងឡាយតៅកាន់ត្រើយនៃព្រះនិព្វាន។

សរុបសេចក្តីមក សេចក្តីមេត្តាចំពោះអ្នកដទៃបានធ្វើឱ្យបុគ្គលគ្រប់រូបបានសេចក្តីសុខគ្រប់គ្នានិងចេះជួយសង្គ្រោះគ្នាទៅវិញទៅមកថែមទៀតផង។

### ទី២ បញ្ហាការព្យាយាមចំរើនកម្មដ្ឋានរបស់ភិក្ខុ៣៣រូប

ភិក្ខុទាំង៣៣រូបមានព្រះមហាថេរជាប្រធានបានដឹងថាទុលកបណ្ឌិតត្រូវស្តេចយកទៅសម្លាប់ដោយសារតែជួយខ្លួនបានដឹងគុណទុលកបណ្ឌិត បានព្យាយាមចរើនកម្មដ្ឋានឧទ្ទិសកុសលដល់គាត់ តបគុណគាត់បានគូរ ។ លុះថាហើយភិក្ខុសង្ឃបានខំព្យាយាម ប្រត្តិបត្តយ៉ាងខ្ជាប់ខ្ជួនលុះគ្រាបានសម្រេចអរហត្តគ្រប់រូប ហើយនាគ្នាហោះឡើងទៅកាន់អាកាសវេហាស៍ សម្តែងឥទ្ធិឫទ្ធិដ៏អស្ចារ្យជាអនេកប្រការ។ព្រះរាជាទតឃើញដូចនោះមានការភិតទ័យជាខ្លាំងទើបទ្រង់ពិគ្រោះសួរអាមាត្រ អាមាត្រទូលប្រាប់ឱ្យហៅទុលកបណ្ឌិតមកសួរ ។ដ្ឋេចបានភិតភ័យនិយាយប្រាប់ទុលកបណ្ឌិតថា ភិក្ខុសង្ឃទាំង៣៣រូបនោះប្រុងមកសម្លាប់យើង សូមអ្នកជួយដោះទុក្ខយើងផង។ អ្នកស្តាប់ហើយមានចិត្តត្រេកអរណាស់ និមន្តភិក្ខុទាំង៣៣រូបមកចុះក្នុងកាលឥឡូវនេះឯង។ អ្នកក៏បានពោលពាក្យថា បពិតលោកម្ចាស់ទាំងឡាយ ខ្ញុំករុណាឈ្មោះទិលកបណ្ឌិតសូមនិមន្តលោកម្ចាស់ ។ ភិក្ខុទាំង៣៣អង្គបានចុះពីលើអាកាសមកគង់លើអាសនៈ ដែលគេបានក្រាលបំរុងទុកក្នុងរាជវាំង ។ បន្ទាប់មកទៀតព្រះនាគទីបករត្តេះបានសម្តែងធម៌ថ្វាយព្រះរាជាថា បពិត្រមហារាជ! ការសេបគប់និងសប្បុរស តែមួយគ្រាអាចរក្សាការពារអ្នកសេបគប់បាន ។

សរុបសេចក្តីមក មេត្តាធម៌ដែលបានកើតឡើងអំពោះយើងហើយរមែងជួយជួយថែរក្សាមិនឱ្យលិចលង់នោះឡើយ។

### ទិ៣ការញូជញួងអុចអាល

ព្រះរាជាបានជឿតាមសម្តីអាមាត្រ បានធ្វើបាបភិក្ខុសង្ឃទាំង៣៣រូបយកប្រហារជីវិត ដោយភិក្ខុទាំងនោះពុំមានទោសកំហុសអ្វីឡើយ ។ មួយវិញទៀតភិក្ខុទាំង៣៣រូបបានទុលកបណ្ឌិតជួយសង្គ្រោះរួចផុតពីក្តីមរណៈ ។ ចំណែកទុលកបណ្ឌិតវិញសុកចិត្តស្លាប់ជំនួសសាមមនេរតូច ។ក្រោយមកព្រះរាជាបានដឹងការពិត បាដាក់ទោសអាមាត្រនោះបណ្តេញចេញពីព្រះនគរ ផលកម្មនេះបណ្តាលមកពីអាមាត្រប៉ងសម្លាប់ជីវិតអ្នកដ៏ទៃនិងត្រូវវិនាសដល់ខ្លួនឯងវិញ។

សរុបមកយើមិនត្រូវមានការចងគំនុំគំគួនគ្នានោះឡើយ អំពើទាំងនេះនាំឱ្យយើងជួបតែសេចក្តីកក្តីក្រហាយជាក់ជាមិនខាន មុននិងជឿទៅលើអ្នកណាម្នាក់មុននិងប្រព្រឹត្តធ្វើអ្វីមួយយើងត្រូវគិតឱ្យបានវែឆ្ងាយ។

## ឃ.ឧត្តមគតិរឿងគំនិតដឹកនាំរឿងតម្លៃអប់រំ

ឧត្តមគតិរឿងគឺជាឧត្តមគតិរបស់អ្នកនិពន្ធ។ឧត្តមគតិរឿងគឺយកកក្តាប្រធានវិស័យដែលបញ្ហាដែលបញ្ជាក់ពីគោលជំហរសតិអារម្មណ៍របស់អ្នកនិពន្ធដែលស្តែងឡើងតាមរយៈសកម្មភាពរបស់តួអង្គ។

- អប់រំមនុស្សឱ្យជៀលើបុនក្យបាប
- អប់រំមនុស្សឱ្យចេះកែប្រែចិត្ត
- អប់រំមនុស្សឱ្យមានចិត្តមេត្តាចំពោះគ្នាទៅវិញទៅមក
- អប់រំមនុស្សចេហគិតផលប្រយោជន៍រួមជាធំ
- អប់រំមនុស្សឱ្យអ្នកដេកនាំចេះប្រកាន់ភ្ជាប់ភាពស្មោះត្រង់សុចរិចត្រឹមត្រូវ។

សរុបជារយមមករឿងនេះបានបង្ហាញ ឱ្យយើងចេះមានចិត្តប្រកាន់ភ្ជាប់នុវសេចក្តីល្អមិនមានចិត្តច្រណែនអ្នកដ៏ទៃនិងមានការជួយសង្រោះ។

# សង្ខេបរឿង ទុកម្មានិកៈ

ក្នុងកាលកន្លងមកយូរអង្វែងហើយនោះ មានកុដុម្ពីក៍ម្នាក់នៅទីជនបទ ន ខេត្តដែលក្រុងពារាណសី មានបុត្រម្នាក់ឈ្មោះទុក្កម្មានិកៈ ។ តមកបុរសជាបិតា មានរ៉ូឈឺជាទម្ងន់ មុនស្លាប់បានហៅទុក្ខម្មាទីកមាណពជាបុត្រមកផ្តាំថា "ហ កូនមាសឪពុកឯង់កុំយកសីមេមាយបីដងជាប្រពន្ធ, កុំយកបុរសបួសបីដង សឹក បីឯងជាសម្លាញ់. កុំសេពគប់ព្រះរាជាដែលឥតពិចារណាពោលផ្តាំពាក្យបីម៉ាត់នេះហើយកុដុម្ពីក៍ជាបិតាបានក៏អនិច្ចកម្មទៅ ។

ថ្ងៃមួយ មានស្រីមេម៉ាយបីដងម្នាក់ ( មកសំដែងអាការស្និទ្ធស្នាលគួរឱ្យចាប់ ចិត្តស្នេហា ។ មាណពបាននឹកឃើញបណ្តាំរបស់បិតាដែរ តែចង់សាកល្បងមើល តើ ជាមានផលពិតមែនឬមិនមែនទេ ។ ដើម្បីឱ្យយល់ការណ៍ជាក់ស្តែង អ្នកក៏ទទួល យកស្រីមេម៉ាយបីដងនោះធ្វើជាភរិយា។ តមកទៀតមានបុរសបួសបីដង ចូល មករកអ្នក១ ក៏ទទួលយកជាមិត្រសំឡាញ់ដើម្បីពិសោធពាក្យបណ្តាំ របស់បិតា ។

សម័យមួយ សុវណ្ណហង្សរបស់ព្រះរាជា កំពុងត្រាច់ដើរក្បែរមាត់ស្ទឹង ។ មាណពក៏ចាប់យកសុវណ្ណហង្ស ហើយតាំងជីករណ្តៅមួយ ហើយដាក់ហង្សក្នុង រណ្តៅនោះ យកជាលគ្របបំពោកភក់ ទុកប្រហោងតូច១ . សម្រាប់ឱ្យហង្សដក ដង្ហើមបានស្រួល ហើយអ្នកវិលមកផ្ទះសម្លាប់ហង្ស ១ ផ្សេងទៀត ចិញ្ច្រាំស្ងួជា សច នៅពេលដែលនាងមេម៉ាយបីដងទៅផ្សារ ។ បន្តិចលេចភរិយាមកពីផ្សារ អ្នកក៏និយាយ ប្រាប់ថា "បងចាប់សុវណ្ណហង្សរបស់ព្រះរាជា ចិស្លស្រេចទៅហើយ។.. ភរិយាតាំងស្តីបន្ទោសប្តីថា " អ្នកមិនដឹងទេ ឬអំពើនេះមានទោសធ្ងន់ ណាស់" ។

តបកបន្តិច ក៏មានការជ្រួលច្របល់កើតឡើង ដោយហេតុបាត់សុវណ្ណហង្ស របស់ស្តេច ត្រាស់ឱ្យាសនាផ្សាយដំណឹងថា "អ្នកណាមួយអាចដឹងថាសុវណ្ណហង្សបាត់រូបទៅដោយហេតុដូចម្តេចទ្រង់នឹងប្រទាមាសមួយពាន់ដំឡឹង ឯភរិយាទុក្កម្មាធិកបុរស កំពុងតែចង់បានប្តីថ្មីទៀតផង ក៏ឆ្លើយតប រាមាត្យអ្នកឃោសនាថា "ខ្ញុំដឹងហេតុដែលបាត់សុវណ្ណហង្សរបស់ស្តេច ហើយ និយាយប្រាប់អាមាត្យនោះ ដោយសព្វគ្រប់ ។ អាមាត្យក៏ចាប់ចងបុរសប្តី ដោយចំណង ៥ ប្រការ ហើយនាំទៅថ្វាយស្តេច១ ត្រាស់បង្គាប់ឱ្យនាំខ្លួនទៅសម្លាប់ក្នុង ថ្ងៃនោះឯង ។ ឯបុរសបួសបីដង សឹកបីដង ជាសំឡាញ់ឥតបានជួយឈឺឆ្អលអ្វី សោះ ត្រឡប់បែរជានិយាយសុំសំពត់ស្លៀក ពីទុក្កម្មាធិកបុរសវិញថា "សំឡាញ់អើ សំពត់យើងរហែករយើ សំឡាញ់ជាប់ទោសត្រូវសម្លាប់ សំឡាញ់ឱ្យសំពត់ស្លៀក នោះមកយើងវិញទៅ ថាហើយក៏ភើមយកសំពត់ស្លៀកសំពត់ដណ្តប់អ្នក ទៅ នៅគ្រាដែលពួកពេជ្ឈឃាតកំពុងបណ្តើរអ្នកយកទៅសម្លាប់នោះ អ្នកទន្ទេញថា "បើហង្សស្លាប់ ខ្ញុំក៏ស្លាប់ បើខ្ញុំមិស្លាប់ ហង្សក៏មិនស្លាប់ដែរ " ។

ពួកពេជ្ឈឃាតក៏និយាយគម្រាមថា " ហង្សរបស់ស្តេច ព្រះស្តែងកាប់ស្លុសុំ អស់ទៅហើយ មានហង្សពីណារស់ឡើងវិញ ហើយនាំខ្លួនអ្នកទោសចេញទៅ សំដៅទ្វារទិសខាងកើត ។ ជួនជាថ្ងៃនោះ ពួកឆ្មាំទ្វារបិទទ្វារព្រះនគរក្នុងពេលថ្ងៃ រសៀល ។ ពេជ្ឈបរាតសុំឱ្យបើកទ្វារ។ ឆ្មាំទ្វារឆ្លើយថា "បើព្រះរាជាមិនទាន់ជំនុំ ជំរះទោសទេ យើងនឹងបិទទ្វារអស់កំណត់បីថ្ងៃ ព្រោះក្រែងព្រះរាជាឱ្យសម្លាប់មនុស្សមិន មែនជាចោរកំណាច នឹងនាំឱ្យបានក្តីក្តៅក្រហាយស្តាយក្រោយមហិមា ដូចបុរសប្តីប្រពន្ធសម្លាប់ស្ការ ។ ពេជ្ឈឃាតសុំឱ្យឆ្មាំទ្វារដំណាលរឿងនោះ ។ ឆ្មាំទ្វារក៏ដំណាលរឿងនោះថា៖

"កាលណោះមានស្វាមីភរិយាពីរនាក់ នឹងកូនប្រុសតូចមួយ អ្នកទាំងពីរ ចិញ្ចឹមសត្វស្ការមួយឱ្យនៅចាំផ្ទះ ខ្លួនឯងទាំងពីរចេញទៅធ្វើការឯស ថ្ងៃ មួយ ពស់មួយលូនចូលមកចឹកទារកនោះស្លាប់ទៅ ឯស្ការក្រឡេកឃើញពស់ ក៏ ស្ទុះចូលទៅប្រយុទ្ធនឹងពស់នោះ ហើយបានខាំពស់ដាច់ចេញជាកំណាត់ៗ ពស់ក៏ ស្លាប់ ទារកក៏ស្លាប់ ។ ស្ការរត់ទៅឱ្យដំណឹងដល់ម្ចាស់វាងស .. ប្តីប្រពន្ធមិន យល់សេចក្តី ដោយបានឃើញខ្លួនស្ការប្រឡាក់ឈាមក៏ស្មានថា ស្ការខាំកូនរបស់ ខ្លួនក៏ចាប់ដងរនាស់សំពងស្ការនោះគ្រាតែស្លាប់ទៅ ប្តីប្រពន្ធក៏នាំគ្នារត់មក មើលងផ្ទះ៖ បានឃើញខ្មោចពស់ជាកំណាត់ នៅកៀនជញ្ជាំងទើបដឹងថា កូនខ្លួន ត្រូវពស់ចឹកស្លាប់ ក៏នាំគ្នាយំសាកស្តាយកូនស្តានស្ការ ដែលខ្លួនបានសម្លាប់ដោយ ឥតពិចារណា" ។ ហេតុនេះហើយ បានជាយើងមិនយល់ព្រមបើកទ្វារឱ្យ ។

ពេជ្ឈឃាត ក៏នាំអ្នកទោសទៅទ្វារនគរខាងត្បូង ។ ពួកឆ្មាំទ្វារនគរទិស ខាងត្បូងក៏បាននិយាយដូចឆ្មាំទ្វាខាងកើតដែរហើយថាអំពើដែលមិនបានពិចារណាជាមុន ច្រើនតែ

បានក្ដីក្ដៅក្រហាយស្ដាយក្រោយ ដូចរឿងព្រានប្រមាញ់ សម្លាប់ខ្លែង ។ ពេជ្ឈឃាតក៏សុំឱ្យដំណាលរឿងនោះ ឆ្មាំទ្វារក៏ដំណាលថា៖

មានព្រានប្រមាញ់ម្នាក់ បានចិញ្ចឹមសត្វខ្លែងមួយ កាលណាព្រានចេញ ទៅបរបាញ់សត្វបក្សី ខ្លែងក៏ទៅជាមួយដែរ ។ ថ្ងៃមួយ បុរសព្រានស្រេកទឹកខ្លាំង ក៏ចុះទៅផឹកទឹកក្នុងស្ទឹងមួយ នៅទីនោះមានពស់មានពិសមួយ ប្រុងលោតមកបុរសឈ្លោកផឹកទឹកម្ដងទៀតចឹកទាយព្រាន១ ឥតបានឃើញសោះ ឯសត្វខ្លែងបានក្រឡេកឃើញអាការដូច្នោះ ក៏ទទះស្លាបកញ្ជ្រោកទឹកកុំឱ្យម្ចាស់វាចុះទៅផឹកទឹក ។ ឯបុរសស្រុកខ្លាំង ប្រឹង តែមមុលចុះទៅផឹកទឹក បានឃើញខ្លែងមកក្លែងធ្វើមិនឱ្យផឹកទឹកកើត ក៏ខឹងខ្លាំង ហើយ ប្រហារក្បាលខ្លែងដោយដងផ្ទួស្លាប់ទៅ ។ ពស់ក៏ហក់ភ្លែតទឹកចំភ្នែកម្ខាងខ្វាក់ទៅ ។ ព្រានប្រមាញ់ក៏ស្រែកទ្រហោយំស្ដាយ សត្វខ្លែង ដែលមានស្វាមីភក្ដិ ថែមទាំងខូចភ្នែកម្ខាងទៀតផង ។

ពេជ្ឈឃាតក៏នាំអ្នកទេសទៅទ្វារទិសខាងលិច ។ ពួកឆ្មាំទ្វារក៏បាននិយាយ សាសព្ទប្រាប់ហេតុដែលខ្លួនមិនព្រមបើកទ្វារដូចអ្នកមុនៗ នេះដែរ  រឿង ដំណាលមានដូចតទៅនេះ៖

កាលណោះ មានព្រះរាជាមួយព្រះអង្គ ព្រះនាមព្រះបាទព្រហ្មទត្ត គ្រង រាជសម្បត្តិ ក្នុងនគរពារាណសី មានព្រះរាជធីតាមួយព្រះអង្គ ព្រះនាមសុន្ទរា ។ ព្រះនាងតែងទៅកកំស្រង់ក្នុងស្រះបោក្ខរណី មានឆ្កែចិញ្ចឹមមួយតែងតែដើរទៅ តាមព្រះនាងជានិច្ច មានបុរសជាសត្រូវម្នាក់បានចងគំនុំព្យាបាទព្រះរាជាជា ព្រះវរបិតាព្រះនាង បានលបលួចបង្កប់ចរោងក្បែរមាត់ស្រះបោក្ខរណី ដើម្បីឱ្យ ជង់រាជបុរី ងឆ្កែបានឃើញហេតុភេទដូច្នោះ ក៏រត់ទៅស្ទាក់ផ្លូវព្រះរាជធីតា ដែលកំពុងយាត្រា តែព្រះរាជធីតាចេះតែទ្រង់ចចេសទៅមុខទៀតដល់មាត់ស្រះ ត្រូវនឹងចម្រូងសោយទិវង្គតទៅ ។ ឯឆ្កែក៏ស្ទុះទៅពយកគ្រឿងអលង្ការទៅដាក់ ក្បែរព្រះរាជា ដើម្បីជាដំណឹង ។ ឯព្រះបាទព្រហ្មទត្តបានទ្រង់ទឃើញប្រដាប់ ប្រដាព្រះរាទី ទ្រង់គិតស្មានថា ឆ្កែនេះខាំសម្លាប់កូនអញ ហើយពាំយក ប្រដាប់ប្រដាមក ទើបទ្រង់ឱ្យគេសម្លាប់ឆ្កែនោះភ្លាមទៅ ។ តមកបន្តិចទ្រង់បានាបច្បាស់ថា ព្រះរាជបុត្រីសុគតដោយហេតុដទៃទេ ក៏ទ្រង់កន្ទ្បេងវិយោគសោកស្ដាយមហិមា ព្រោះតែមិនបានពិនិត្យពិចារណាជាមុន។ ពេជ្ឈឃាតក៏បាននាំអ្នកទោសទៅទ្វារទិសខាងជើង ។ ពួកឆ្មាំទ្វារមិនព្រម បើកទ្វារឱ្យ ដោយអាងហេតុផលដូចអ្នកមុន១នោះដែរ ហើយបាននិទានរឿងពី សំឡាញ់ពីនាក់ ។

ពេជ្ឈឃាតក៏បាននាំអ្នកទោសទៅទ្វារទិសខាងជើង ។ ពួកឆ្មាំទ្វារមិនព្រម បើកទ្វារឱ្យដោយរងហេតុផលដូចអ្នកមុនៗនោះដែរ ហើយបាននិយាយរឿង ពីសំឡាញ់ពីរនាក់ ។

មានសេចក្ដីដំណាលថា មានបុរសជាសំឡាញ់គ្នាពីរនាក់ហើយស្រឡាញ់គ្នា ណាស់ ម្នាក់នៅស្រុកខាងលិច ម្នាក់ទៀតនៅស្រុកខាងកើត សំឡាញ់ស្រុក ខាងកើតនោះ បានចិញ្ចឹមឆ្កែមួយជាទីពេញចិត្តណាស់ ប៉ុន្តែទីទ័លក្ររករនឹងឱ្យ សំឡាញ់គ្មាន ក៏បានលើកឆ្កែនោះឱ្យទៅសំឡាញ់ស្រុកខាងលិច ក៏បបោស អង្អែលឆ្កែ ថ្លែងសេចក្ដីអរគុណហើយនាំទៅគេហដ្ឋានរបស់ខ្លួន ។

ចំណេរតមក បុរសនោះចងខ្សែយាំងល្អនឹងកម្លេ ហើយបញ្ជូនទៅម្ចាសំ ដើមវិញ ដើម្បីឱ្យដំណឹងសុខទុក្ខរបស់ខ្លួន។ ឆ្កែកំរត់ទៅរកម្ចាស់ដើម ១ បាន ឃើញខ្សែល្អពាក់នៅកន្លែ ក៏គិតស្មានថាឆ្កែនេះលួចទ្រព្យសំឡាញ់ខ្លួនរត់មក ក៏ ប្រហារឆ្កែនោះ ត្រាតែស្លាប់ទៅ ។ ឯសំឡាញ់នៅស្រុកខាងកើត មិនឃើញឆ្កែ ត្រឡប់មកវិញក៏នឹកសង្ស័យក៏សួរដំណឹងឆ្កែនោះ ។ លុះបានដំណឹងថាឆ្កែនោះ ស្លាប់ទៅហើយ ដោយអំពើមិនសមហេតុផល ។ បុរសទាំងពីរនាក់ ក៏កើតទុក្ខ ក្ដៅក្រហាយស្ដាយក្រោយយាំងខ្លាំង ។

កាលពេជ្ឈឃាតនឹងឆ្មាំទ្វារនិយាយឆ្លើយឆ្លងគ្នា ដូចបានពណ៌នាមកនេះជានិងនាងឡើង ។ ដោយក៏នាំអ្នកទោសត្រឡប់ទៅក្រាបទូលព្រះរាជា បងសារនានាទីយបង្គំទូលតាមដំណើរសព្វគ្រប់ ព្រះរាជាក៏ត្រាស់ ច្រៀងដល់ទ្រង់ស្ដិបន្ទោសថា “អញឱ្យយកវាទៅសម្លាប់ ម្ដេចក៏ដាំវាត្រឡប់ស្មានិងគ្នានិងបុរស។រឺនប្រវែងឯងខានរឿងចង់ដូចម្ដេចខ្លះ?កត្តញ្ញនិតបុរសន៍បបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស ការដែលទូ មានសិទ្ធិ បានធ្វើមកាល ប្រយោជន៍ចង់សាកល្បងពាក្យបណ្ដាំបិតារបស់ទូលព្រះបង្គំ មិនបានសម្លាញ់ ចូលព្រះបង្គំលាក់ទុកនៅត្រង់ណា សូមទ្រង់ជ្រាប ដូចទូលថាព្រះស្ដេងមិនបានសំលាប់ហង្សយើងទេ ចូរចៅនាំយកមកឱ្យនិងក្នុងកាលជាផ្លូវនោះចុះ បុរសក៏នាំយហង្សនោះមកថ្វាយព្រះរាជាក្នុងខណៈនោះឯង។ ព្រះរាជាទ្រង់សួរអ្នកអំពីប្រស្នារបស់បិតាអ្នកមុនអនិច្ចកម្ម អ្នករបស់ប្រើមេម៉ាយប្ដីជី ដែលបានមកជាប្រពន្ធអ្នក ឱ្យបានទ្រង់ជ្រាបសព្វគ្រប់ ... ព្រះរាជាមាន និយាយសាទរណាស់ ទ្រង់បានឱ្យដំណែងដល់អ្នក ប៉ុន្ដែដោយ មិនយកទេបានពោលទុកថា “នគរណាដែលមានស្ដេចគ្រង

រាជ្យគតគពិចារណាមិនឱ្យនៅក្នុងនគរនោះឡើយ ហើយអ្នកក្រាបបង្គំទូលលា ។ នៅនគរនោះ អ្នកបានបកដោយជោគជ័យសិទ្ធស្ថិតនៅក្តីសុខ សុភមង្គលខ្ពង់ខ្ពស់ជានិច្ចតរៀងទៅ ។

## ក.អត្ថន័យខ្លឹមសារ

អត្ថន័យអត្ថ .ប្រយោជន៍.អត្ថន័យ .ការណែនាំអត្ថាធិប្បាយសេចក្តីពន្យល់.អត្ថន័យជាគំនិតសំខាន់ៗរបស់អ្នកនិពន្ធដែលលាតត្រដាងនៅក្នុងដំណើររឿង ហើយគេអាចហៅវាថាជាជម្រៅនៃរឿង។

ក្នុងផ្នែកអត្ថន័យមាន ប្រធានរឿង មូលបញ្ហារឿងនិងឧត្តមគតិរឿង។

## ខ.ប្រធានរឿងមូលន័យ

ប្រធានរឿង ឬមូលន័យ គឺជាគំនិតសំខាន់ៗរបស់រឿង។ប្រតិប្ឋជាបញ្ហារួមរបស់រឿង។ តែអ្នកនិពន្ធចង់បង្ហាញដល់អ្នកអានប្រធានរឿងជាបញ្ហារួបផ្តុំបំផុតដែលអ្នកនិពន្ធលើកយកមកសរសេរ ឬជ្រើសរើសជាប្រធានបទហើយដែលមានមូលបញ្ហារឿងឋិតនៅក្នុងនោះ។

ប្រធានរឿងបង្ហាញនៅចំហររបស់អ្នកនិពន្ធវាជាមូលដ្ឋានដើមរបស់អ្នកនិពន្ធក្នុងការចាប់ផ្តើមសរសេរឡើង។ មុនពេលចាប់ផ្តើមសរសេរឡើង។អ្នកនិពន្ធគ្រប់រូបត្រូវកំណត់ថាតើគាត់ត្រូវសរសេរអំពីអ្វី។អំពីជីវិតសង្គមសង្គ្រាមស្នេហារឿងជំនឿទនៀមទម្លាប់ប្រពៃណីចម្លើយរបស់សំណួរនេះហើយជាប្រធានរឿង។

តាមរយៈ រឿងទុម្ពាក្ក្មាទិកៈបានបង្ហាញពីខ្សែរជីវិតទុក្កម្ទានិកៈ។

## គ.មូលបញ្ហារឿង

មូលបញ្ហារឿងគឺជាភាពចំណែកនៃប្រធានរឿងជាទិដ្ឋភាពផ្សេងៗ របស់យើង។វាជាការចូលជ្រៅទៅក្នុងប្រធានរឿង។

ជុំវិញប្រធានរឿងនេះ យើងបានកំណត់បញ្ហាជាច្រើន ដែលនៅជុំវិញការកសាងសីលបារមីរបស់ព្រះពោធិសត្វ បញ្ហាទាំងនោះរួមមានៈ

### ទី១ បញ្ហាបណ្តាំកុដុម្ពីរ

កុដុម្ពីរមានកូនប្រុសម្នាក់ឈ្មោហទុកម្ទានិកៈ មុនស្លាប់បានហៅទុកម្មនិកៈមានពជាបុត្រមកផ្តាំថា .ហៃ ឯងកុំយកស្រីមេមាយបីដងជាប្រពន្ធ. កុំយកបុរសបួសបីដងសឹកបីដងជាសម្លាញ់ .កុំសេបគប់ព្រះរាជាឥតពិចារណា កុដុម្ពីរជាបិតាបានផ្តាំពាក្យបៅម៉ាតនេះហើយក៏ទទួលអនិកម្មទៅ។ ក្រោយមកមានស្រីមេម៉ាយបីដងម្នាក់មកស្និតស្នាលស្នេហាជាមួយមាណព។ មានពបានយកនាងនោះជាភតិយាចង់ពិសោធន៍ចណ្តាំបិតា ។ ក្រោយមកមានបុរសបួសបីដងចូលមករកមាណពក៏ទទួលទៀតដោយចង់សាកល្បងបណ្តាំបិតា សម័យមួយសុវណ៌ហង្សរបស់ព្រះរាជាកំពុងត្រាចដើរក្បែរមាត់ស្ទឹង។ ពេលមាណបបានឃើញចាប់យក ហើយជិករណ្តៅមួយទៅទុកក្នុងរណ្តៅ យកជាលគ្រប់បំពោគភក់ទិកប្រហោងតូចៗ ដើម្បីឱ្យហង្សដកដង្ហើមបានស្រួល។ មាណពចាប់ហង្សផ្សេងសម្លាប់ស្ល ។ ពេលនាងមេម៉ាយបីដងមកពីផ្សារវិញមាណពប្រាប់ប្របន្ធថា បងចាប់សុវណ្ណហង្សព្រះរាជាចិញ្ច្រាស្លទៅហើយ ។ក្រោយមកស្តេចឱ្យគេបានប្រកាសឃោសនាថា អ្នកណាមួយបានដឹងថាសុវណ្ណហង្សរបស់ស្តេចបាត់តៅដោយរបៀណាស្តេចនិងប្រទានមាស១ពាន់ដំឡឹង នាងមេម៉ាយបីដងដោយចង់បានប្តីថ្មីផងបានប្រាប់អាមាត្រថា ខ្ញុំដឹងហេតុបាត់សុវន្ណហង្សរបស់ស្តេចនោះ ដោយនិយាយប្រាប់អាមាត្រសព្វគ្រប់។ អាមាត្រចាប់ចងបុរសប្តីដោយចំណងប្រាំប្រការ ។ រួចនាំទៅថ្វាយស្តេច ៗបង្គាប់ឱ្យនាំទៅសម្លាប់ក្នុងថ្ងៃនោះឯង។ ឯបុរសបួសបីដង សឹកបីដងមិនបានជួយទុកម្ទានិកៈសោះពែរជាសុំសំពាត់ស្លៀកទៅវិញ ។

សរុបមកមុននិងសេបគប់នរណាម្នាក់ត្រូវចេះ ថ្លឹងថ្លែងពីអាកប្បកិរិយារបស់ពួកគេ បើយើងសេបគប់មិត្តពាលនិងនាំឱ្យយើងវិនាស យើងត្រូវសេបគប់បុគ្គលជាបណ្ឌិតនិងនាំឱ្យយើងចម្រើនបានសេចក្តីសិខផងដែរ។

### ទី២ បញ្ហាឆ្នាំទ្វា

ពេជ្ឈឃាតបណ្ដើរមាណពដល់ទ្វារទិសខាងកើតពេលនោះជួនជាឆ្មាំទ្វារបិតគ្នានៅពេលរសៀលពេជ្ឈឃាតសុំឱ្យបើកទ្វារ ។ បើព្រះរាជាមិនទាន់ជំនុំជំរះទោសទេយើងនិងបិតទ្វារអស់កំណត់បីថ្ងៃ ក្រែងប្រះរាជាឱ្យសម្លាប់ជាមនុស្សមិនមែនជាចោរកំណាច នាំឱ្យព្រះរាជាស្ដាយក្រោយដូចបុរសប្ដីប្រពន្ធសម្លាប់ស្ការ។ពេជ្ឈឃាតបានឱ្យឆ្មាំទ្វារដំណាលប្រាប់រឿងនោះ។ ឆ្មាំទ្វារក៏តំណាលរឿងនោះថា៖

កាលនោហមានប្ដីប្រពន្ធពីរនាក់និង កូនប្រុសតូចមួយ ។ បុរសប្ដីប្រពន្ធបានចេញទៅធ្វើការនៅឯស្រែ ឱ្យស្ការនៅចាំផ្ទះ ថ្ងៃមួយពស់លូនមកចឹកទារកនោះស្លាប់ទៅ ។ ស្ការបានទៅប្រាប់ម្ចាស់នៅឯស្រែ ប្ដីប្រពន្ធពេលឃើញសត្វស្ការប្រលាកឈាមនឹកស្មានថាស្ការនោះសម្លាប់កូនខ្លួន ក៏ចាប់ដងរនាសសំពងស្ការនោះគ្រាតែស្លាប់ទៅ។ ក្រោយមកដល់ផ្ទះបានឃើញពស់ដាច់ជាកំណាតៗក៏យំស្ដាយស្ការ។

ពេជ្ឈឃាតនាំអ្នកទោសទៅកាន់ទ្វានគរខាងត្បូង ។ ឆ្មាំទ្វារទិសខាងត្បូងបាននិយាយដូចឆ្មាំទ្វារទិសខាងកើតដែរអំពើដែលមិនបានពិចារណាជាមុននាំឱ្យក្ដៅក្រហាយស្ដាយក្រោយដូចរឿងព្រានប្រមាញសម្លាប់ខ្លែង។ ពេជ្ឈឃាតសុំឱ្យតំណាលរឿងនេះ។ ឆ្មាំទ្វារបានតំនាលប្រាប់ថា៖

មានព្រានព្រៃម្នាក់បានចិញ្ចឹមសត្វខ្លែងមួយ ។ ថ្ងៃមួយបុរសព្រានស្រេករីកជាខ្លាំងបានចុះទៅផឹកទឹក នៅទីនោះមានពស់មានពិសមួយ ប្រុងលោតមកចឹកនាយព្រាន ៗ មិនបានឃើញសោះក្អែកបានឃើញខំទទញស្លាបកញ្ជ្រោកទឹកកុំឱ្យម្ចាស់វាចុះទៅផឹកបទឹក។ ពេលបុរសឃើញក្លែងមកក្លែងធ្វើមិនឱ្យផឹកតឹកកើត ខឹងខ្លាំងបានប្រហារក្បាលខ្លែងនិងដងផ្លូស្លាប់ទៅ។ ពស់ក៏ចឹកភ្នែកព្រានខ្វាក់មួយម្ខាងទៅ។ ព្រានប្រមាញស្រែកទ្រហោយំស្ដាយសត្វខ្លែង។

ពេជ្ឈឃាតបាននាំមណពទៅទ្វារទិសខាងលិចឆ្មាំទ្វារមិនព្រមបើកឱ្យដូចអ្នកមុនៗបានតំណាលរឿងប្រាប់ដូចអ្នកមុនៗ

កាលនោហមានប្រះរាជាមួយព្រះអង្គព្រះនាមព្រហ្មទតសោយរាជនៅនគរពារាសី មានបុត្រីមួយអង្គព្រះនាមសុន្ទរា ។ព្រះនាងតែងទៅកក់ស្រង់នៅស្រះបោក្ខណី តែងមានឆ្កែមួយដើរតាមព្រះនាងជានិច្ច ។ បុរសដែលចងគំនុំជាមួយព្រះរាជាបានដាក់ចំរូងនៅមាត់ស្រះនោះឆ្កែបានខំឃាត់ផ្លូវព្រះនាងតែព្រះនាងនៅតែចចេសទៅ ក៏ត្រូវចំរោងនោះស្លាប់ទៅ ។ឆ្កែឃើញបែបនោះក៏ពាំយកគ្រឿងអលង្ការ នោះទៅថ្វាយព្រះរាជាគិតស្មានថា ឆ្កែនោះសម្លាប់កុនអញ្ញទ្រងក៏បញ្ជាឱ្យគេសម្លាប់ឆ្កែនោះស្លាប់ទៅ។ ពេលទៅដល់កំពង់ទឹកឃើញរាជធីតាសុគតដោយហេតុដ៏ទៃទេ ត្រងសោកវិយោគមិនបានគិតពិចារណាជាមុន។

ពេជ្ឈនាំអ្នកទោសទៅទ្វារទិសខាងជើងឆ្មាំទ្វារបានឃាត់ដូចអ្នកក៏និយាយប្រាប់ដូចងអ្នកមុនទៀត។ឆ្មាំទ្វារបាននិយាយរឿងសម្លាពីរនាក់។

សេចក្ដីតំណាលថា មានមានបុរសពីរនាក់ស្រឡាញ់គ្នាណាស់ម្នាក់ទៀតនៅស្រុកខាងលិចម្នាក់ទៀតនៅស្រុកខាងកើត បានចិញ្ចឹមឆ្កែមួយជាទីពេញចិត្តណាស់តែទីទល់ក្រគ្មានអ្វីឱ្យសំឡាញឱ្យឆ្កែទៅសម្លាញស្រុកខាងលិច។ សំឡាញខាងលិចត្រេកអរណាស់នាំទៅផ្ទះខ្លួន។

ចំណេរក្រោយមទៀតបុរសចងខ្សែរយ៉ាងល្អនៅនិងករឆ្កែ បានបញ្ជូនតៅឱ្យម្ចាស់ដើមវិញដឹងសុខទុករបស់ខ្លួន ម្ចាស់ដើមបានឃើញឆ្កែមានពាក់ខ្សែរកល្អបានកិតថាឆ្កែបានលួចខ្សែរកមិត្តខ្លួនក៏ប្រហារឆ្កែនោះគ្រាតែស្លាប់ទៅ។

សរុបសេចក្ដីមក ការស្លាប់របស់សត្វក្នុងរឿងខាងលើបានបានបំផុសគំនិតអប់រំ ដល់មនុស្សគ្រប់រូបការធ្វើអំពើអ្វីមួយទៅលើ អ្នកស្មោះត្រង់និងកើតមានកំហុសស្ដាយក្រោយជាមិនខានយើងគួរជៀសវាងអំពើទាំងនេះដើម្បីជាប្រយោជន៍រួមទាំងអស់គ្នា។

## ឃ.ឧត្តមគតិរឿងគំនិតដឹកនាំរឿងតម្លៃអប់រំ

ឧត្តមគតិរឿងគឺជាឧត្តមគតិរបស់អ្នកនិពន្ធ។ឧត្តមគតិរឿងគឺយកកត្តាប្រធានវិស័យដែលបញ្ញាដែលបញ្ជាក់ពីគោលជំហរសតិអារម្មណ៍របស់អ្នកនិពន្ធដែលស្ដែងឡើងតាមរយៈសកម្មភាពរបស់តួអង្គ។

- អប់រំមនុស្សកុំឱ្យពោលពាក្យកុហកមុសា

- អប់រំមនុស្សកុំឱ្យជឿនរណាម្នាក់ដោយអត់ហេតុផល
- អប់រំមនុស្សឱ្យក្លាយជាចៅក្រមកាត់ក្តីដោយត្រឹមត្រូវ
- អប់រំមនុស្សកុំឱ្យនិយាយលេងពាក្យអត់ប្រយោជន៍
- អប់រំមនុស្សមុននិងដាក់ទោសនរណាម្នាក់ត្រូវមានភ័សតាំង
- អប់រំមនុស្សឱ្យចេះស្តាប់ពាក្យទូន្មាន។

សរុបជារួមមក រឿងនេះបានធ្វើឱ្យយើងត្រូវចេះស្តាប់ដំបូន្មាន គ្រូបាចារ្យដែលបានអប់រំឱ្យទទួលបាន ជីវិតរស់នៅប្រកបដោយសេចក្តីសុខនិងសុភមង្គល។

# សង្ខេបរឿង សុវណ្ណកុមារ

អតីត ក្នុងកាលកំបាំងបាត់ស្ងាត់យូរអង្វែងមកហើយនោះ មានព្រះ ព្រះនាមមហាក្សត្រគ្រងរាជសម្បត្តិក្នុងនគរពារាណសី មានព្រះអគ្គមហេសីព្រះនាមចន្ទាទេវី ជាស្ត្រីប្រកបដោយកល្យាណធម៌ប្រពៃថ្លៃ ថ្នូរ ជាទីសព្វព្រះទ័យ នៃព្រះរាជស្វាមីក្រៃលែង ។ ទ្រង់មានព្រះរាជបុត្រមួយ ព្រះ អង្គនាមសុវណ្ណកុមារ មានវ័យចំរើនឡើង បានសិក្សាសិល្បៈ សាស្ត្រផ្សេងៗ សព្វគ្រប់ ជាពិសេស ទ្រង់ចេះស្ទាត់ជំនាញខាងសិល្បធ្នូ ក្នុងព្រះជន្មគំរប់ ១៦ វស្សា ។

. សម័យថ្ងៃមួយ ព្រះបាទមហាភក្តស្តេច “លើកចតុរង្គសេនាព្រមទាំង ភ្លេងតូរ្យតន្ត្រីគ្រប់ប្រភេទ ទៅប្រពាតកំសាន្តឆ្នេរមហាសមុទ្រ ។ ព្រះសុវណ្ណ កុមារក៏ស្តេចយាងទៅជាមួយនឹងព្រះវរមាតា បិតាដែរ ហើយទ្រង់មានបំណងចង់ ស្តេចយាងទៅប្រពាតកណ្តាលមហាសមុទ្រ ដោយតេជៈបារមីនៃព្រះកុមារ ពួកទេពតារក្សាសមុទ្របាននាំដំរីសសុទ្ធមួយមកថ្វាយទ្រង់ៗ ព្រមដោយសេនា យោធា ស្តេចឡើងគង់លើព្រះទីនាំងគជេន្ទ្រយាងចុះទៅក្នុងសមុទ្រ ។ ឯគជសារមានមុខឆ្ពោះទៅត្រង់កន្លែងណា ទឹកសមុទ្រក៏បែកខ្ញែកជាពីរចំណែកដូចជា ជញ្ជាំងផ្ទះ ។ ឯនាងសមុទ្ទកញ្ញាទាំងឡាយ ក៏រាយរាយលំអិតគន្ធពិដោរ យក កម្រងផ្កាមាសបញ្ចពណ៌ ព្យួរនៅសងខាងនៃជញ្ជាំងទឹកសមុទ្រ ។ ឯស្តេចនាគនាំបញ្ញាសជាតកនាងនាគីបរិវារមកហែហមរបអង្គព្រះរាជកុមារ។ ពេលសោយទ្រង់សោយគ ភោជនាហារ ដែលពួកនាងសមុទ្ទកញ្ញានឹងកម្លោះជាគឺរៀបចំថ្វាយ ទ្រង់បាន ក្រសាលសប្បាយក្សេបក្សាន្តក្នុងមហាសមុទ្ររស់កំណត់ ៣ថ្ងៃ ។

ព្រះបាទមហាភក្តនឹងព្រះនាងទេវីលុះព្រះរាជបុត្របាត់យូរថ្ងៃពេកទើប ទ្រង់ចាត់បំរើឱ្យតាមព្រះរាជបុត្រទ្រង់មានបន្ទូលជាពួកសមុទ្ទទេវតានឹងនាគរាជហើយ ស្តេចព្រមដោយរាជបរិវារត្រឡប់មកថ្វាយបង្គំព្រះវររាជមាតាបិតា ឯឆ្នេរសមុទ្រ ហើយថ្វាយពេជ្រនីលចិត្តសព្វពិធរ័ត្នផង ដែលសមុទ្ទទេវតានឹង នាគរាជបានថ្វាយទាំងប៉ុន្មានដល់ ព្រះជនក ជននីរបស់ ទ្រង់ រួចស្តេចលើកទ័ព ត្រឡប់មកព្រះរាជធានីវិញ ដោយសិរីសួស្តី ។

ចំណេរកាលមក មានឈ្មួញសំពៅ ៥០០ បើក្តោងចេញទៅសីហឡទ្វីប ដើម្បីធ្វើជំនួញហើយនិយាយសរសើរមងសារសសុទ្ធរបស់ព្រះសុវណ្ណកុមារន ក្រុងពារាណសី ។ ដំណឹងនេះបានជ្រួតជ្រាបដល់ព្រះបាទភជសុរាជនៃសីហឡទ្វីប ហើយត្រាស់ហៅយោធាទាំង ៤ នាក់ ដែលក្លៀវក្លាអាចសម្រេចកិច្ចសព្វគ្រប់ ប្រការមកបង្គាប់ថា “ ចូរអ្នកទាំងឡាយ ចេញទៅនគរពារាណសីជាមួយនឹងពួក ឈ្មួញសំពៅ ហើយ ក្រាបទូលស្តេចមហាភក្តរាជថា៖ ព្រះបាទភជសុរាជនៅ សីហឡទ្វីប មានអានុភាពច្រើន មានតេជៈច្រើន មានពលច្រើន ឥតមានស្តេច ណាប្រៀបផ្ទឹមស្មើឡើយ ឥឡូវនេះទ្រង់បញ្ជាថា សូមឱ្យព្រះអង្គនាំដំរីសសុទ្ធ ប្រកបដោយលក្ខណៈគ្រប់ប្រការទៅថ្វាយព្រះរាជាជាម្ចាស់នៃយើង បើមិនដូច្នេះទេ ទ្រង់នឹងធ្វើឱ្យនគរពារាណសីនេះវិនាសខ្ទេចខ្ទីពុំខាន” ។ យោធាទាំងបួនក៏ ចេញទៅនគរពារាណសីឡើងគាល់ព្រះបាទមហាភក្តរាជ ហើយក្រាបទូលថ្លៃង្រះឱង្ការសព្វសេចក្តី ។ ព្រះចៅក្រុងពារាណសីទ្រង់មានសេចក្តីព្រួយបារម្ភក្រៃលែង ទើបត្រាស់ហៅប្រជុំសេនាបតី ឧបរាជ . បុរោហិត នឹងព្រះរាជបុត្រ ទ្រង់ បានថ្លែងប្រាប់ពីព្រះឱង្ការនៃព្រះបាទសីហឡទ្វីបសព្វគ្រប់ ។ ពួកសេវកាមាត្យទាំងនោះបានឮដូច្នោះ ក៏ភិតភ័យភាំងស្មារតីនៅតែស្ងៀមរៀងខ្លួន ។

គ្រានោះ ព្រះសុវណ្ណកុមារ ទ្រង់បានជ្រាបហេតុភេទដូច្នោះហើយ ក៏ក្រាបបង្គំទូលព្រះវររាជបិតាថា “សូមទ្រង់មេត្តាប្រោសថ “ សូមព្រះវរបិតា កុំព្រួយបារម្ភ ឡើយ សូមទ្រង់គង់ជាសុខសប្បាយចុះ ទូលព្រះបង្គំសូមទទួលធានានឹងទៅនាំ យកស្តេចភជេសុរាជ ព្រមទាំងពួកពលយោធាមកក្រាបថ្វាយបង្គំព្រះបាទាព្រះ អង្គឱ្យទាល់តែបាន” ។ ឯពួកអាមាត្យមុខមន្ត្រីបានស្តាប់ព្រះបន្ទូលនេះហើយ ក៏ មានសេចក្តីតកអរសោមនស្សទាំងអស់គ្នា នាំគ្នាថ្វាសព្ទសាធុការពរដល់ព្រះរាជកុមារ ព្រះវររាជបិតាមានព្រះទ័យត្រេកអរណាស់ ទ្រង់ឱ្យចាត់ចែងធ្វើពិធី រាជាភិសេកព្សុវណ្ណកុមារឱ្យឡើងគ្រងរាជសម្បត្តិជាដំណាងព្រះអង្គតទៅ ។ ព្រះសុវណ្ណកុមារលុះបានរាជាភិសេកហើយ មានចតុរងនាចោមរោមដង្ហែព្រះ អង្គចេញទៅ នៅពេលប្រកបដោយជោគជ័យល្អ ក្បួនទ័ពព្រះរាជាព្រមដោយ ស្វេតច្ឆ័ត្រក្ពស់ក្លំអភិរម្យ ទង់ជ័យព្រមទាំងអាវុធយុទ្ធភ័ណ្ឌភ្លឺផ្លេកព្រោងព្រាត ហាក់ដូចពពួកផ្កាយលើផ្ទៃស្មេហាស៍ ។

ព្រះបាទសុវណ្ណកុមារ មុនទ្រង់លើកទ័ពចេញទៅ ទ្រង់បានត្រិះរិះថា សម្បត្តិសុខ សុភមង្គលនឹងឫទ្ធិតេជៈទាំងឡាយកើតឡើងដោយអានុភាពន បុណ្យ ដូច្នេះគួរឱ្យពួកពលសេនាធ្វើបុណ្យសិន ព្រោះបុណ្យតែងរក្សាការពារអ្នក ធ្វើបុណ្យ ឱ្យផុតពីក្តីអន្តរាយ ” ហើយទ្រង់បាន

ចាត់ចែងធ្វើចង្ហាន់បិណ្ឌបាតប្រគេនដល់ ព្រះសង្ឃ ប្រគេនទេយ្យទានផ្សេងៗ ដល់ព្រះសង្ឃ ឱ្យសាងវាលុកចេតិយ ហើយទ្រង់រៀបគ្រឿងភ្លឺផ្កាបូជា ទ្រង់បានសមាទានសីល ស្ដាប់ធម៌ទេសនា ទ្រង់ បានព្រះរាជទានអាហារចំណីនឹងសំពត់អាវសារស្បៃជាដើម ដល់សូមយាចកទាំង ឡាយ ហើយទ្រង់បានជ្រួចទឹកឧទ្ទិសផលដល់សត្វលោកទូទៅ ។

ព្រះបាទសុវណ្ណកុមារទ្រង់បានលើកទ័ពចេញទៅ ដរាបដល់ត្រើយសមុទ នៅពេលអជ្រាត្ររាត្រី ទើបព្រះនរបតីទ្រង់ព្រះចិន្ដាថា “ស្ដេចភជសុររាជ - មាន ឫទ្ធីអានុភាពដូចម្ដេចអេះ?” ។ កំពុងទ្រង់ព្រះចិន្ដាដូច្នេះ ស្រាប់តែព្រះឥន្ទ្រាធិរាជ ទ្រង់នាំមកនូ១ មានសរ ៥ មកថ្វាយទ្រង់ ដែលជាអាវុធទិព្វវិសេសក្រៃលែង ។ សរមួយនោះបាញ់ទៅបានចម្ងាយមួយយោជន៍ មានឫទ្ធិអាចកាត់ក្បាលមនុស្ស នឹងទេពតាបានដូចបំណង ។ សរមួយទៀត បាញ់ចេញទៅកើតជាយានជំនិះ ។ សរមួយទៀត បាញ់ចេញទៅកើតជាវិមានអណ្ដែតលើអាកាស សរមួយទៀត បាញ់ទៅកើតជាភ្នក់ភ្លើងយ៉ាងសាហាវ សរមួយទៀ បាញ់ ត្រូវបុកសាច់ ឈាមហើយ លុះដល់កំណត់ប្រាំពីរថ្ងៃទើបស្លាប់ ، ព្រះឥន្ទ្រាធិរាជទ្រង់បាន ប្រទានធ្នូសរទិព្វនោះហើយ ទើបទ្រង់ថ្វាយស័ព្ទសាធុការពរ ទ្រង់បានប្រសិទ្ធី ជោគជ័យថ្វាយ ហើយស្ដេចលាត្រឡប់ទៅឋានវិមានរបស់ព្រះអង្គវិញ ។

គ្រានោះ ព្រះមហាក្សទ្រង់ត្រួតត្រាពួកពលទាំងឡាយ ទ្រង់ទតឃើញមាន របៀបរៀបរយល្អហើយ....ទើបទ្រង់នាំទ័ពចុះសំពៅនៅពេលមាននក្ខត្តឫក្សល្អបើកក្ដោងលឿនស្លូសំដៅកោសីហទ្បទ្វីប ដល់ហើយទ្រង់បានបញ្ជូលរាជទូត ឱ្យទៅទូលព្រះបាទភជសុររាជថា “ព្រះបាទសុវណ្ណកុមារជាម្ចាស់យើង ទ្រង់មាន ភូមិអំណាចអាចញាំញី ពួកសត្រូវប់ទិសត្រឹមតែដោយកូនសរមួយរបស់ព្រះអង្គ ឥឡូវស្ដេចមកដល់ហើយ សូមព្រះអង្គម្ចីម្នាចេញទៅថ្វាយបង្គំសូមអាយុជីវិត ឬមួយបើព្រះអង្គអាងមហិទ្ធិឫទ្ធិ ក៏សូមព្រះអង្គទ្រង់គិតរៀបចំគ្រឿងទ ចេញតតាំងច្បាំងចុះ” ។ ក្នុងខណៈនោះ ព្រះបាទសុវណ្ណកុមារ ទ្រង់បានថ្លែងសរ ជាអាវុធទូតមួយទៀត ទ្រង់បានផ្ដាំសរថា “នែសរដ៏ចំរើន ចូរឯងទៅបិតជិតគុម្ព ត្រចៀកស្ដេចរាជសុររាជ ហើយគម្រាមថា នៃស្ដេចកំណាច បើប្រស្ដែងមិន រវៀសរវៃទៅថ្វាយបង្គំព្រះបាទាព្រះរាជាជាម្ចាស់យើងទេ យើងនឹងកាត់ក្បាលទៅ ថ្វាយទ្រង់ឥឡូវនេះឯង” ។ សរនោះ ក៏ធ្វើតាមព្រះរាជបញ្ជា ព្រះមហាក្សត្រ។ ព្រះបាទភជសុរា ទ្រង់មានសេចក្ដីភិតភ័យក្រៃពេក ប៉ុន្ដែទ្រង់ខំធ្វើកិរិយាកីឡា ខាងក្រៅឱ្យមើឃើញថា ទ្រង់មិនខ្លាចមិនតក់ស្លុត ហើយទ្រង់ហៅប្រជុំសេនា យោធាដែលក្លាហានទាំងប៉ុន្មានដើម្បីទប់ទល់ ។ ព្រះបាសុវណ្ណកុមារ ក៏បានថ្លែងសរ មួយទៀតទៅកាត់សក់មនុស្សទាំងអស់ក្នុងនគរ ធ្វើឱ្យព្រាងិលត្រងោលទាំងអស់គ្នា ហើយ ត្រឡប់មកចូលបំពង់វិញ ។ មហាជនផងក៏ភិតភ័យតក្កមារាល់គ្នា ព្រះមហាក្សត្របានថ្លែងសរមួយទៀត កើតដោយានមានរាជរថទឹមសេះសឹងសសុទ្ធថ្មី មាន « ភ្លេងរបាំតូរ្យតន្ត្រី មានស្រីអប្សររាំច្រៀងក្នុងរាជរថ ហោះប្រទក្សិណខាងកនគរបីជុំ ទ្រង់បានថ្លែងសរមួយទៀតបង្កើតជាអណ្ដាតភ្លើងឆេះឡើងសន្ធោរសន្ធៅ ក្រឡឹងខាងក្រៅនគរ ៣ ជុំហើយត្រឡប់មកចូលបំពងវិញ ។ អាណាប្រជានុរាស្ត្រក៏ ភ្ញាក់ផ្អើលចូលច្របល់ពកូនជញ្ជូនចៅពួនដោយខ្លាចអគ្គិភ័យ។ ឯព្រះបាទភជសុររាជ ដែលង្កាទ្វីបនៅតែមិនទាន់ព្រមចុះចាញ់ព្រះបាទសុវណ្ណកុមា ទ្រង់បានជ្រាបដោយប្រាជ្ញាញាណរបស់ព្រះអង្គថា សេនាបតីជាច្បងពីរនាក់របស់សីហទ្បទ្វីប នឹង ក្ស័យព្រះជន្មក្នុងរវាង៧ថ្ងៃទៀត ទើបទ្រង់ចាត់រាជទូត ឱ្យទៅទូលស្ដេចភជសុររាជថា ៧ ថ្ងៃទៀតទ្រង់នឹងថ្លែងសរសម្លាប់អគ្គសេនាបតីទាំងពីរនាក់ ” ។ ក្នុងថ្ងៃគំរប់ ៧ សេនាបតីជាច្បងទាំងពីរនាក់ ក៏អនិច្ចកម្មមែននៅក្នុងព្រះរាជមន្ទីរ ដែលគេការ ចាត់ចែងការពារយ៉ាងម៉ឺងម៉ាត់ ។

ឯព្រះបាទភជសុររាជទ្រង់បានឃើញភេទចម្លែកអស្ចារ្យដូច្នោះ ទ្រង់ព្រួយ បារម្ភភិតភ័យតក្កមាយាំងក្រៃលែង ទើបទ្រង់ជំនុំជាមួយនឹងអរហត្យមុខបងឡាយថា “បើយើងនៅតែចចេសរឹងរូសតទៅទៀតមុខជារាណាប្រជានុរាស្ត្រយើង នឹងខ្លួនយើងទាំងអស់គ្នានឹងស្លាប់អសារបង់ ដូច្នេះគួរយើងសុខចិត្តចុះចាញ់ ស្ងប មានជីវិតរស់នៅតទៅទៀត... ទើបស្ដេចព្រមទាំងអាមាត្យមុខមន្ត្រីលើកភស្ដុភារ បណ្ណាការចេញទៅ ក្រាបទូលថ្វាយព្រះបាទសុវណ្ណកុមារជាសញ្ញានៃការចុះចាញ់ ។

ព្រះបាទសុវណ្ណកុមារទ្រង់ត្រាស់ថា “បពិត្រមហារាជ សូមទ្រង់កុំភ័យ កុំព្រួយ បារម្ភឱ្យសោះ ខ្ញុំគ្មានក្ដីក្រោធខឹងនឹងទ្រង់ទេ ខ្ញុំមិនមែនមកដណ្ដើមយករាជសម្បត្តិ នឹងដែនដីរបស់ទ្រង់ទេ គ្រាន់តែមកសូមយកដួងហឫទ័យរបស់ទ្រង់ប៉ុណ្ណោះ” ។

ព្រះបាទភជេសុររាជ បានទ្រង់ព្រះសណ្ដាប់ដូច្នោះ ក៏រឹងរឹតតែភិតភ័យញាប់ ញ័ររន្ធត់ត្រាតែព្រះសេទោហូរចេញសស្រាក់ ព្រះមហាសត្វទ្រង់បានទតឃើញដូច្នោះ ក៏មានព្រះហឫទ័យ

ករុណាពន់ពេក ទើបត្រាស់លួងលោមថា “ បពិត មហារាជ ខ្ញុំមិនមែនមកសុំយកសាច់បេះដូងរបស់ទ្រង់ទេ គឺគ្រាន់តែសូមឱ្យព្រះអង្គ មានព្រះទ័យស្រឡាញ់រាប់អានដ៏ស្មោះស្ម័គ្រចំពោះខ្ញុំ ហើយសូមឱ្យខ្ញុំមានមេត្រីរាប់ អានចំពោះទ្រង់តែប៉ុណ្ណោះទេតើ សូមទ្រង់ជ្រាប” ។ តអំពីនេះទៅ ព្រះមហាក្សត្រ ក្រុងពារាណសី ទ្រង់បានប្រទានឱវាទផ្សេងៗ ទៀត ជាអនេកប្រការ សុទ្ធតែផ្អែក ទៅលើកល្យាណធម៌សប្បុរសទាំងអស់ ។ ព្រះបាទរាជេសរាជនៃសីហឡទ្វីប ទ្រង់សាធុ ! សាធុ! ពិរោះណាស់ ព្រះឱង្ការរបស់ព្រះអង្គ សុទ្ធតែជាពាក្យសុភាសិតខ្ពង់ មានព្រះទ័យរីករាយក្សេមក្សាន្តពន់ពេក ទើបស្តេចទូលតបថា “បពិត្រមហារាជ ! ខ្ពស់ក្រៃលែង, ខ្ញុំសូមថ្វាយជីវិត ដួងហឫទ័យនឹងសេចក្តីស្រឡាញ់ស្នេហា ព្រមទាំង រាជសម្បត្តិក្នុងដែនទាំងមូលចំពោះព្រះអង្គ សូមទ្រង់ទទួលយកតាមសព្វព្រះរាជហឫទ័យចុះ ” ។

បើដូច្នេះ សូមឱ្យទ្រង់ស្តេចយាងទៅនគរពារាណសីជាមួយនឹងខ្ញុំ ដើម្បីថ្វាយ បង្គំ ព្រះវររាបិតា- មាតាខ្ញុំ ក្នុងកាលឥឡូវនេះចុះ” ។

បពិត្រព្រះភូមិន្ទ សូមទ្រង់មេត្តារង់ចាំ ទំរាំខ្ញុំចាត់ចែងដំណើររួចស្រេចសិន” ។ ព្រះមហាសត្វ ក៏ទ្រង់យល់ព្រម ។

ព្រះបាទភជសុរាជទ្រង់បានបង្គាប់អាមាត្យជាធំរបស់ទ្រង់ថា “ ម្នាលអាមាត្យ ចូរអ្នករៀបកងទ័ពមានអង្គបួន ឱ្យបានគ្រប់គ្រាន់ឱ្យពួកយោធាទាំងនោះ តែងកាយតាមថ្នាក់តាមជាន់ តាមពួកក្រុងផ្សេង ឱ្យស្លៀកពាក់ប្រដាប់ថ្មី

អាវុធថ្មី គ្រប់គ្នារួចហើយនាំគ្នាចូលទៅហែហមព្រះបាទសុវណ្ណកុមារ ជាមួយនឹង យើង ព្រះបាទសុវណ្ណកុមារឡើងគង់ដំរីរ័ត្នមង្គល ស្តេចបរពលដរាបដល់ទៅ មហាសមុទ្រ ដោយរីករាយក្សេមក្សាន្តទ្រង់ឱ្យបោះកងទ័ពសំចតនៅឆ្នេរសមុទ្រអស់ កម្លាំង៧ថ្ងៃ បើកដៃឱ្យពួកពលសកលយោធាលេងល្បែងមហោស្រពផ្សេងៗ តាមចំណង់ ។

លុះបានឫក្សពារពេលល្អ ព្រះរាជាទ្រង់នាំពួកពលសេនាយោធាចុះកាន់រាជ នាវាដ៏រុងរឿង ព្រះបាទសីហឡទ្វីបនឹងពួកយោធាទាំងពួង ក៏នាំគ្នាស្រែកថ្វាយពរ ជ័យបីដង ហើយនាំគ្នាត្រសងចុះកាន់នាវាតែរៀងៗ ខ្លួន ។ ពួកសមុទ្រទេវតានឹងស្តេចាគទាំងឡាយ ក៏នាំគ្នានិម្មិតប្រាសាទរ័ត្នថ្វាយព្រះមហាក្សត្រ នៅលើសុវណ្ណនាវា ហើយបានចាត់ការថែរក្សាមហានាវាទាំងអស់ពុំឱ្យមានក្តីអន្តរាយ ....ទេវតា ទាំងឡាយ ក៏បញ្ចេញវាយោបក់រំភើយៗ រហើយ ស្រួលសព្វកាយា បក់សំពៅភេត ឱ្យលឿនលយដោយស្រួលលើ ផ្ទៃមហាសមុទ្រ ។ សមុទ្ទទេវតានាំយកភោជនាហារ មានឱជារស ថ្ងៃថ្លាមកថ្វាយព្រះមហាសត្វ ព្រមទាំងពួកពល ពួកនាងសមុទ្ទកញ្ញានាំគ្នាតែងកាយាយាំងស្រស់ ដែកាន់ទិព្វមាលាបុណ្យបូជាព្រះនរបតីរាល់ទិវារាត្រី . ជនទាំងអស់ក្នុងនាវាទាំងឡាយ តែងខ្លួនយ៉ាងស្អាតច្រៀងរាំសើចសប្បាយ ទះដៃលេងយ៉ាងខ្ញៀវខ្ញារគគ្រឹកគគ្រេងរាល់ថ្ងៃ ត្រាតែដល់ទៅឆ្នេរសមុទ្រនៃនគរពារាណសី ។

ឯព្រះវររាជមាតា បិតាទ្រង់បានចាត់ចែងមាគ៌ ពីក្រុងពារាណសីដរាបដល់ ឆ្នេរសមុទ្រ ទើបស្តេចព្រមដោយអាមាត្យមុខមន្ត្រីនឹងរាជបរិវារផង ស្តេចចេញទៅ ទទួលព្រះរាជបុត្រដង្ហែចូលមកក្រុងពារាណសី ។ ព្រះបាទសុវណ្ណកុមារបានថ្វាយ ភស្តុភារបណ្ណាការដ៏មានតម្លៃផ្សេងៗព្រមទាំងស្តេចរាជសុរាជនឹងពួកពលយោធា។ ព្រះវរមាតា-បិតាទ្រង់អបអរសាទរនឹងព្រះរាជបុត្រណាស់ ទ្រង់បានប្រទានស័ព្ទសាធុការពរផ្សេងៗ ។ តមកព្រះបាទសុវណ្ណកុមារទ្រង់អនុញ្ញាត ឱ្យស្តេចភជសុរាជ ព្រមទាំងពួកពលត្រឡប់ទៅគ្រងរាជ្យនៅនគររបស់ទ្រង់វិញ ព្រះមហាសត្វទ្រង់ ត្រឡប់គ្រប់គ្រងរាជ្យដោយធម៌ រាស្ត្រប្រជាប្រកបដោយក្តីក្សេមក្សាន្ត ។ ព្រះនរបតី ទ្រង់បានបំពេញកុសលផ្សេងៗ មានទានសីលជាដើមដរាបដល់អស់ព្រះជន្មាយុ ។

## ក.អត្ថន័យខ្លឹមសារ

អត្ថន័យអត្ថ .ប្រយោជន៍.អត្ថន័យ .ការណែនាំអត្ថាធិប្បាយសេចក្តីពន្យល់.អត្ថន័យជាគំនិតសំខាន់ៗរបស់អ្នកនិពន្ធដែលលាតត្រដាងនៅក្នុងដំណើររឿង ហើយគេអាចហៅវាថាជាជម្រៅនៃរឿង។

ក្នុងផ្នែកអត្ថន័យមាន ប្រធានរឿង មូលបញ្ហារឿងនិងឧត្តមគតិរឿង។

## ខ.ប្រធានរឿងមូលន័យ

ប្រធានរឿងឬមូលន័យ គឺជាគំនិតសំខាន់ៗរបស់រឿង។ប្រតិឬជាបញ្ហារួមរបស់រឿង។តែអ្នកនិពន្ធចង់បង្ហាញដល់អ្នកអានប្រធានរឿងជាបញ្ហារូបផ្តុំបំផុតដែលអ្នកនិពន្ធលើកយកមកសរសេរឬជ្រើសរើសជាប្រធានបទហើយដែលមានមូលបញ្ហារឿងឋិតនៅក្នុងនោះ។

ប្រធានរឿងបង្ហាញនៅចំហររបស់អ្នកនិពន្ធវាជាមូលដ្ឋានដើមរបស់អ្នកនិពន្ធក្នុងការចាប់ផ្តើមសរសេរឡើង។មុនពេលចាប់ផ្តើមសរសេរឡើង។អ្នកនិពន្ធគ្រប់រូបត្រូវកំណត់ថាតើគាត់ត្រូវសរសេរអំពីអ្វី។អំពីជីវិតសង្គមសង្គ្រាមស្នេហារឿងជំនឿទនៀមទម្លាប់ប្រពៃណីចម្លើយរបស់សំណួរនេះហើយជាប្រធានរឿង។

តាមរយះ រឿងព្រះសុវណ្ណកុមារ បានបង្ហាញពីប្រធានរឿង ការប្រើប្រាស់ប្រាជ្ញាព្រះសុវណ្ណកុមារ។

## គ.មូលបញ្ហារឿង

មូលបញ្ហារឿងគឺជាភាពចំណែកនៃប្រធានរឿងជាទិដ្ឋភាពផ្សេងៗរបស់យើង។វាជាការចូលជ្រៅទៅក្នុងប្រធានរឿង។

ជុំវិញប្រធានរឿងនេះ យើងបានកំណត់បញ្ហាជាច្រើន ដែលនៅជុំវិញការកសាងសីលបារមីរបស់ព្រះពោធិសត្វ បញ្ហាទាំងនោះរួមមាន៖

### ទី១ បញ្ហាស្តេចយាងទៅកំសាន្តនៅឆ្នេរសមុទ្រ

ព្រះមហាក្សត្រព្រះបាទមហាភទ រួមទាំងមហេសីនិងបុត្របានទៅកសាន្តនៅឆ្នេរសបុទ្រ ។ ព្រះសុវណ្ណកុមារចង់តៅទតនៅកណ្តាលសមុទ្រ ។ ដោយតេជៈបារមីពួកទេវតារក្សារសមុត្របាននាំដំរីសរសុទ្ធមកថ្វាយ ទ្រង់ក៏ឡើងគង់លើព្រះទីនាងគជេន្ទ្រយាងចុះទៅក្នុងសមុទ្រ ឯគជសារមានមុខឆ្ពោះទៅកន្លែងណាទឹកសមុទ្របែកខ្ញែកជាពីរដូចជញ្ជាំងផ្ទះ។នាងកញ្ញាក៏រោយរាយលំអិតគន្ធពិដោរយកកម្រងផ្កាមានពណ៌ព្បូរនៅសងខាងនៃជញ្ជាំងទឹកសមុទ្រ ។ ស្តេចនាគនាំបរិវាមកហែហមទទួលព្រះរាជកុមារ ព្រះរាជកុមារបានក្សេមក្សាន្តក្នុងឋានសមុទ្រអស់រតៈពេល៣ថ្ងៃ ពេលព្រះមាតាបិតាបាននទឹកព្រះរាជកុមារក៏បានសុំលាស្តេចនាគ ស្តេចនាគបានថ្វាយ ទាំងប៉ុន្មានដល់ប្រះជនក .ជននីយាងមកជាធានីវិញ។ ចំណេរកាលមកឈ្មួញសំពៅ៥០០ បោកក្តោងទៅសីងឡទ្វីបដើម្បីធ្វើជំនួញ បាននិយាយសរសើរគជសារសរសុទ្ធរបស់ព្រះសុវណ្ណកុមារ នៃក្រុងពារាសី។

សរុបមកព្រះសុវន្នកុមារមានតេជៈបរមីនាងពេទធីតានិងស្តេចនាគបានទូលព្រះរាកុមារដោយកក់ក្តៅ នេះបង្ហាញក្នុងការប្រព្រឹត្តអំពើល្អបានទទួលលផលល្អ។

### ទី២ បញ្ហាវិធីក្នុងការធ្វើសឹកសង្គ្រាម

នៅពេលដែលព្រះភជេររាជនៃសីហឡទ្វិប បានជ្រាបពីសម្តីពួកនាយសំពៅសសើរពីគជសារសរសុទ្ធរបស់ព្រសុវណ្ណកុមារនៃក្រុងពារាសី ព្រះអង្គបានបង្គាប់ឱ្យយោធាទាំង៤នាក់ដែលក្លៀវក្លាសម្រេចកិច្ចការគ្រប់សព្វ មកហើយបង្គាប់ថា ព្រះបាទភជេសុររាជនៅ សីហឡទ្វីប មានអុភាពច្រើន មានតេជៈច្រើន មានពលច្រើន ឥតមានស្តេចណាបៀបផ្ទឹមស្មើរឡើយឥឡូវនេះទ្រង់បញ្ជាថា សូមព្រះអង្គយកដំរីសរសុទ្ធទៅថ្វាយព្រះរាជានៃម្ចាស់នៃយើង បើបុំដូចច្នេះទេ ទ្រង់និងធ្វើឱ្យនគរពារានសីខ្ទីចខ្ទីជាមិនខាន។ យោធាទាំង៤ក៏ធ្វើតាម ទៅគល់ព្រះមហាភត្តរាជ ថ្លែងព្រះឱង្ការសព្វសេចក្តី។ ព្រះអង្គពារាសីមានការភិតភ័យក្រៃលែង បានប្រជុំឧបរាជ បុរោហិត និងព្រះរាជបុត្រថ្លែងប្រាប់ពីអង្គារស្តេចសីហទ្វិប សព្វគ្រប់។ សូមទ្រង់ព្រះមរត្តាប្រោស សូមព្រះបិតាកុំព្រួយបារម្ភណ៍ឡើយ ព្រះសុវណ្ណកុមារទូលថា យកស្តេចសីងឡទ្វិប និងពួកយោធាមកក្រាបថ្វាយបង្គំព្រះបិតាឱ្យបាន។ ព្រះរាជបុត្រ សុវណ្ណកុមារ បានចេញពីព្រះរាយវាំងមកធ្វើសង្គ្រាម ពេលនោះព្រះឥន្ទបានប្រទានធ្នូ១មានសរប្រាំមកថ្វាយទ្រង់ដែលជាអារុតទិព្វពិសេសក្រៃលែង។ សរមួយនោះបាញ់តៅបានចម្ងាយ១០០យោជន៍អាចកាត់ក្បាលមនុស្សទេវតាបានដូចបំណង ។ សរមួយទៀតបាញ់ទៅកើតជាយានជំនិះ ។ សរមួយទៀតបាញ់ទៅកើតកើជាវិមានអណ្តែតលើអាកាស ។ សរមួទៀតបាញ់ទៅកើតជាភ្នកភ្លើងយ៉ាងសាហាវ ។ សរមួយទៀតបាញ់ទៅមុតសាចឈាមហើម លុះដល់កំណត់៧ថ្ងៃនិងស្លាប់។ ព្រះសុវន្នកុមារបានធ្វើដំណើរដល់កោះសីហឡទ្វិប បានបញ្ជារាជទូតទូលស្តេចសីហទ្វិប ថាអាចសម្លាប់ព្រះអង្គតែកូនធ្នូសរតូចមួយ ស្តេចបានមកដល់ហើយសូមព្រះអង្គចេញទៅថ្វាយង្គំទ្រង់ៗនឹងទុកជីវិតឱ្យ។ បើ

ព្រះអង្គមានរិទ្ធចេញទៅច្បាំងចុះ។ ព្រសុវណ្ណកុមារថ្លែងសរមួយគំរាមកាត់ក្បាលស្តេចសីហឡទ្វិបព្រះអង្គមានការភិតភ័យតែធ្វើដូចជាមិនភ័យ។ ព្រះសុវណ្ណកុមារថ្លែងសរមួយទៀត កាត់សក់មនុស្សទាំងអស់ក្នុងនគរត្រងោល។ថ្លែងសរមួយទៀតកើតជាយានជំនិសមានតន្ត្រីក្រឡឹងប្រះនគរបើជុំ។ទ្រង់បានបង្កើតសរមួយទៀតកើជារដើកភ្លើងចូលក្នុងវាំងព្រះបាទសីហឡទ្វិប។ព្រះអង្គចាត់រាជទូតសេនាជាច្បងតាងពីរ៧ថ្ងៃទៀតនិងស្លាប់ពួកគេក៏បានស្លាប់មែន។ ព្រះសីហឡទ្វីបបានសុំចុះចាញ់ព្រះសុវណ្ណកុមារទៅ។

សរុបមកដើម្បីសម្រេចគោលបំណងអ្វីមួយ យើងត្រូវតស៊ូប្រើប្រាជ្ញាដែលមាន មួយវិញទៀតត្រូវភាពស្មោះត្រង់ផងដែរ។

## ឃ.ឧត្តមគតិរឿងគំនិតដឹកនាំរឿងតម្លៃអប់រំ

ឧត្តមគតិរឿងគឺជាឧត្តមគតិរបស់អ្នកនិពន្ធ។ ឧត្តមគតិរឿងគឺយកកត្តាប្រធានវិស័យដែលបញ្ហាដែលបញ្ជាក់ពីគោលជំហរសតិអារម្មណ៍របស់អ្នកនិពន្ធដែលស្តែងឡើងតាមរយៈសកម្មភាពរបស់តួអង្គ។

- អប់រំមនុស្សកុំឱ្យមានចិត្តលោភលន់
- អប់រំមនុស្សកុំឱ្យមានចិត្តឈ្នាសនីសអ្នកដទៃ
- អប់រំមនុស្សឱ្យចេះស្គាលនុវកំហុសខ្លួនឯង
- អប់រំឱមនុស្សជឿថា អំណើល្អតែងយកឈ្នះអំពើអាក្រក់
- អប់រំមនុស្សឱ្យចេះប្រើប្រាស់យុវិធីដើម្បីផ្តួលដៃគូរសត្រូវរបស់ខ្លួនដោយសន្តតវិធី
- អប់រំឱ្យចេះដឹងគុណមាតាពបិតា អ្នកមានគុណដែលបានជួយខ្លួន
- អប់រំឱ្យចេះអំណត់តស៊ូព្យាយាមគ្រប់ឧសគ្គ។

សរុបជារួមមក រឿងនេះបានបង្ហាញពីការចេហប្រើប្រាស់ប្រាជ្ញា យុទ្ធវិធីក្នុងការធ្វើសង្គ្រាម មានទាំងសេចក្តីព្យាយាម និងឱ្យយើងមានក្តីមេត្តាផងដែរ។

# សង្ខេបរឿង វត្តង្គុលីរាជ

ក្នុងកាលកន្លងមកយូរអង្វែងហើយនោះ មានពាណិជម្នាក់ឈ្មោះកុលភទ្ទកុមារ នៅក្នុងនគរអមរវតី ។ ថ្ងៃមួយ កុលភទ្ទកុមារពាណិជ បានបររទេះទៅកាន់នគរ ផ្សេងទៀត ដើម្បីជួញជាមួយពាណិជរទេះដូចគ្នា ប្រមាណមួយពាន់នាក់ កំពុងគ បររទេះតាមផ្លូវ ស្រាប់តែអ្នកប្រទះឃើញព្រះពុទ្ធបដិមាមួយអង្គដែលគេបាន សាងពីដីស្អិត ក្នុងទីអារាមមួយដែលគេតាំងនៅក្នុងព្រៃក្បែរផ្លូវរទេះ ព្រះពុទ្ធបដិមានោះ បាក់ម្រាមព្រះហស្ដមួយ ទើបព្រះពោធិសត្វបានច្របាច់ដីស្អិត លាយនឹងប្រេងល្ង តម្រាមព្រះហស្ដព្រះពុទ្ធបដិមានោះ ឱ្យបានពេញលេញដូចដើមវិញ ហើយអ្នកបានបូជាដោយទៀនធូបនឹងកម្រងផ្កាជាដើម ចំណាយ ទ្រព្យ ប្រាំបីកហាបណៈ ប្រគល់ឱ្យទាសីម្នាក់ថែរក្សា ជាតម្លៃគ្រឿងសក្ការបូជាផ្សេងៗ អ្នកតាំងសេចក្ដីប្រាថ្នា សូមកុំឱ្យសត្រូវទាំងឡាយមានមកចំពោះមុខខ្ញុំបានឡើយ ដោយអានិសង្សនៃការកសាងម្រាមព្រះហស្ដនេះ” នៅជាតិជាទីបំផុត ខ្ញុំ សូមឱ្យបានត្រាស់ជាព្រះពុទ្ធអង្គស្រោចស្រង់សត្វលោក” ។

ព្រះពោធិសត្វប្រកបជីវភាពរបស់ខ្លួន ប្រកបដោយក្ដីសុខក្សេមក្សាន្តដរាប ដល់អស់អាយុ បានទៅកើតក្នុងឋានសួគ៌ទេវលោក លុះអស់អាយុបានមកចាប់ បដិសន្ធិក្នុងឧទរនៃអគ្គមហេសីនៃព្រះបាទក្រុងពារាណសី ព្រះនាងទ្រង់គភ៌គ្រប់ ទសមាសហើយ ប្រសូត ព្រះរាជបុត្រប្រកបដោយលក្ខណៈប្រសើរ លុះព្រះកុមារចំរើនវ័យឡើង ទ្រង់មានអានុភាពជាអស្ចារ្យចម្លែកទោះបីសេះក្ដី ដំរីក្ដី ដែលកាចសាហាវ គេពុំអាចទូន្មានបាន ព្រះរាជកុមារគ្រាន់តែយកម្រាមព្រះហស្ដ មួយចង្អុលប៉ុណ្ណោះ ក៏ទ្រោមចុះឥតមានពុតកំណាចអ្វីឡើយ ហេតុនេះហើយទើបព្រះរាជវង្សថ្វាយព្រះនាមថា “ វត្តង្គុលីរាជកុមារ ។ ជាតំណតមក ទ្រង់ប្រកបដោយទសពិធរាជធម៌ទ្រង់បានគ្រប់គ្រងរក្សាអាណា។

លុះអំណេះពីព្រះវររាជបិតាទៅវត្តង្គុលិកុមារបានឡើងគ្រងរាជសម្បត្តិប្រជានុរាស្ត្រដោយសង្គហវត្ថុ ៤ យ៉ាំងពុំបាច់ប្រើអាជ្ញាឡើយទ្រង់ជាធម្មិករាជ ទ្រង់បានសង់សាលាទាន . . ចំណាយព្រះរាជទ្រព្យជាទានដល់ស្មូមយាចកទាំង ឡាយរាល់១ ប្រជាជនក៏មានសេចក្ដីសប្បាយរីករាយស្រុកទេសមាន សន្តិសុខទូទៅ ។ ការសម្បូណ៍សប្បាយនឹងសេចក្ដីសប្បុរសមនុស្សធម៌នេះ ក៏បាន ជ្រួតជ្រាបដល់ស្ដេចទាំង ១០១ ក្នុងជម្ពូទ្វីប ។ ស្ដេចទាំងនោះជំនុំប្រឹក្សាគ្នា លើក ទ័ពចំនួនយោធា ១៨. អក្ខោភិនីមកប្រុងប្រយុទ្ធដណ្ដើមយកក្រុងពារាណសីន ព្រះបាទវត្តង្គុលីរាជ ហើយបានបញ្ជូនរាជទូតឱ្យនាំរាជសារទៅក្រុងពារាណសីថា សុខចិត្តប្រគល់រាជសម្បត្តិឱ្យយើង ឬចេញច្បាំងតទល់គ្នាយកចាញ់ឈ្នះ ។

ព្រះបាទវត្តង្គុលីរាជ ទ្រង់បានជ្រាបហើយ ឥតមានព្រះទ័យតក់ស្លុតសោះ ហើយទ្រង់ត្រឡប់ជាមានព្រះហឫទ័យអង់អាចក្លាហានដូចរាជសីហ៍ ហើយ ត្រាស់សួររាជទូតនោះថា “ស្ដេចទាំងនោះ មានពួកពលសេនាទាហានចំនួន ប៉ុន្មាន ដែលមានបំណងមកធ្វើសង្គ្រាមជាមួយនឹងយើងនេះ ? ” រាជទូតក្រាបទូលថា មានចំនួនពលទាំងអស់ ១៨ អក្ខោភិនី បានប្រុងត្រៀមចាំជាស្រេច ។ គ្រានោះ ពួកសហជាតអាមាត្យបានក្រាបទូលព្រះអង្គថា សូមទ្រង់ព្រះឡើឃ្លាប្រោស ! យើងខ្ញុំទូលព្រះបង្គំទាំងអស់គ្នា សុទ្ធតែជាអ្នកមានកម្លាំងស្ទាត់ជំនាញ ក្នុងសង្គ្រាម ក្លាហានអង់អាច សូមទទួយកអសាព្រះអង្គ ចេញចាប់ស្ដេចទាំង ១០១ នឹងពូកពលសេនាទាហានទាំងអស់ សូមព្រះរាជទានព្រះរាជានុញ្ញាត ។

ព្រះបាទវត្តង្គុលីរាជ មានព្រះរាជឱង្ការថា “យើងសូមអរគុណអ្នកទាំង អស់គ្នា ប៉ុន្តែណ្ហើយចុះ អ្នកទាំងឡាយកុំច្បាំងឡើយ តែច្បាំងទៅហើយមុខជា ស្ដេចទាំង ១០១នឹងពួកពលសេនានឹងវិនាសអន្តរាយពុំខាន ខ្ញុំគ្រាន់តែសុំឱ្យអ្នក ទាំងឡាយតាមហខ្ញុំតាមដំណើរប្រក្រតីខ្ញុំនឹងជិះដំរីទៅដេញបង្អើលកងទ័ពទាំង នោះឱ្យខ្ចាត់ខ្ចាយអស់ទៅ ដោយគ្រាន់តែប្រើចង្អុលម្រាមមួយប៉ុណ្ណោះ អ្នកទាំង ឡាយកុំព្រួយបារម្ភឡើយ” ។

លុះបានឫក្សពារពេលាល្អ ព្រះរាជាឡើងគង់លើខ្នងដំរីសឹកមានអាមាត្យ សហជាតតាមហែហមព្រះអង្គ តាមដំណើរជាប្រក្រតីធម្មតា ព្រមទាំងភ្លេងតូរ្យ - តន្ត្រីផ្សេង១ ព្រះចក្រីយាងចេញតាមទ្វារទិសខាងកើត បានទតឃើញចតុរង្គ សេនារបស់ខ្មាំងច្រើនណាស់ ណែនណាន់តាន់តាប់ ច្រើនស្រទាប់ជាប់ ១ បន្តគ្នា មានឧបមាដូចរលកទឹកមហាសុទ្ររកទីបំផុតគ្មាន ។ ព្រះពោធិសត្វគ្រាន់តែលើក ម្រាមព្រះហស្ដ ១ ចង្អុលទៅចំពួកខ្មាំងទាំងនោះ ។ កាលណោះការណ៍អស្ចារ្យ ក៏កើតឡើងជាក់ស្ដែង ស្រាប់តែពួកពលដំរី ធ្លាក់ពីលើខ្នងដំរី ពលសេះធ្លាក់ពីខ្នង សេះ ពលរងធ្លាក់ពីលើរថ ពលថ្មើជើងដាក់មេផាយនាំគ្នារត់ខ្ចាត់ខ្ចាយអស់ទៅ ។ ព្រះរាជាទ្រង់ទតឃើញដូច្នោះ ក៏មានព្រះហឫទ័យអាណិត អាសូរណាស់ ទ្រង់, ត្រាស់ខ្លាំងៗ ថា “ ចូរអ្នក

ទាំងឡាយនាំគ្នាក្រោកឡើងចុះ កុំបីភិតភ័យព្រួយបារម្ភ អីឡើយ ។ ស្តេចទាំងនោះ ក៏នាំគ្នាក្រោកឡើង លើកដៃប្រណម្យសូមទោសសូមជីវិត សូមថ្វាយរាជសម្បត្តិដល់ព្រះអង្គ ។ ព្រះបាទវត្តង្គលិរាជទ្រង់បាន ទូន្មានប្រដៅស្តេចទាំងនោះ ឱ្យឋិតនៅក្នុងសន្តិភាពដោយ ប្រពៃហើយ ទើបទ្រង់

បញ្ជូនក្សត្រទាំងនោះ ឱ្យត្រឡប់ទៅកាន់រាជធានីរៀងៗ ខ្លួន ។

ព្រះនរបតី ស្តេចត្រឡប់ចូលព្រះរាជនិវេសន៍ ដោយសិរីសួស្តីនឹងជោគជ័យដ៏ខ្ពង់ខ្ពស់ ឯក្សត្រទាំង ១០១មកថ្វាយ ព្រះបាទវត្តង្គលិរាជ ដោយក្តីស្វាមីភក្តិ ។ ព្រះចក្រីតែងទ្រង់ព្រះរាជទាន អង្គបាននាំគ្នាយកគ្រឿងរាជបណ្ណាការផ្សេងៗ ព្រះរាជទ្រព្យផ្សេង ១ ដល់ស្មូមយាចកទាំងឡាយ ទ្រង់ប្រកបដោយទសពិធរាជ ធម៌តាមរាជប្រពៃណីនៃព្រះមហាក្សត្រអំពីបុរាណទ្រង់ជារាជាធិរាជក្នុងសកល ជម្ពូទ្វីប ទ្រង់មានចេស្តាបារមីល្បីល្បាញទូទៅ ។ ស្តេចក្នុងសកលជម្ពូទ្វីប ក៏ឋិត នៅក្នុងឱវាទរបស់ព្រះអង្គដោយគោរពស្មោះត្រង់ទូទៅ ។

អ្នកនិពន្ធបានបញ្ជាក់ថា ម្រាមដ៏មានឫទ្ធិយ៉ាងអស្ចារ្យរបស់ព្រះបាទវត្តង្គលិរាជនោះកើតឡើងដោយ អានិសង្សនៃការកសាងម្រាមព្រះហស្តនៃព្រះពុទ្ធ បដិមាពីបុព្វជាតិរបស់ព្រះអង្គ ។

## ក.អត្ថន័យខ្លឹមសារ

អត្ថន័យអត្ថ .ប្រយោជន៍.អត្ថន័យ .ការណែនាំអត្ថាធិប្បាយសេចក្តីពន្យល់.អត្ថន័យជាគំនិតសំខាន់ៗរបស់អ្នកនិពន្ធដែលលាតត្រដាងនៅក្នុងដំណើររឿង ហើយគេអាចហៅវាថាជាជម្រៅនៃរឿង។

ក្នុងផ្នែកអត្ថន័យមាន ប្រធានរឿង មូលបញ្ហារឿងនិងឧត្តមគតិរឿង។

## ខ.ប្រធានរឿង មូលន័យ

ប្រធានរឿងឬមូលន័យ គឺជាគំនិតសំខាន់ៗរបស់រឿង។ប្រតិឬជាបញ្ហារួមរបស់រឿង។តែអ្នកនិពន្ធចង់បង្ហាញដល់អ្នកអានប្រធានរឿងជាបញ្ហារួបផ្តុំបំផុតដែលអ្នកនិពន្ធលើកយកមកសរសេរឬជ្រើសរើសជាប្រធានបទហើយដែលមានមូលបញ្ហារឿងឋិតនៅក្នុងនោះ។

ប្រធានរឿងបង្ហាញនៅចំហររបស់អ្នកនិពន្ធវាជាមូលដ្ឋានដើមរបស់អ្នកនិពន្ធក្នុងការចាប់ផ្តើមសរសេរឡើង។មុនពេលចាប់ផ្តើមសរសេរឡើង។អ្នកនិពន្ធគ្រប់រូបត្រូវកំណត់ថាតើគាត់ត្រូវសរសេរអំពីអ្វី។អំពីជីវិតសង្គមសង្គ្រាមស្នេហារឿងជំនឿទំនៀមទម្លាប់ប្រពៃណីចម្លើយរបស់សំណួរនេះហើយជាប្រធានរឿង។

តាមរយៈ រឿងវត្តង្គលិរាជបានបង្ហាញពី ការបំពេញមេត្តបារមី ព្រះពោធិសត្វ វត្តង្គលិរាជ។

## គ.មូលបញ្ហារឿង

មូលបញ្ហារឿងគឺជាភាពចំណែកនៃប្រធានរឿងជាទិដ្ឋភាពផ្សេងៗរបស់យើង។វាជាការចូលជ្រៅទៅក្នុងប្រធានរឿង។

ជុំវិញប្រធានរឿងនេះ យើងបានកំណត់បញ្ហាជាច្រើន ដែលនៅជុំវិញការកសាងសីលបារមីរបស់ព្រះពោធិសត្វ បញ្ហាទាំងនោះរួមមាន៖

### ទី១ បញ្ហាការកសាងម្រាមព្រះហស្តព្រះពុទ្ធបដិមារ

កុលភទ្ទកុមារពាណិជ បានបររទេសទៅធ្វើជំនួញ នៅនគរផ្សេងស្រាប់តែធ្វើដំណើរទៅតាមផ្លូវបានឃើញ រូបបដិមារនៅក្នុងទីអារាមបាក់ម្រាមព្រះហស្តមួយ ។ ពេលនោះព្រះអង្គបានឃើញបាក់ម្រាមមួយ បានយកដ៏ស្អិតលាយនិងប្រេងល្ង តម្រាមព្រះងស្តព្រះពុទ្ធបដិមារនោះឱ្យបានដូចដើមវិញ ព្រះអង្គបូជា ទៀនធូបនិងកម្រងផ្កាជាដើម។ចំនាយព្រទ្យប្រាំបីគហបណៈប្រគល់ឱ្យទាសីថែរក្សា ព្រះអង្គបានប្រាថ្នាថា .សូមកុំឱ្យសត្រូវទាំងឡាយមានមកចំពោះមុខខ្ញុំបានឡើយ ។

សរុបសេចក្ដីអំពើល្អតែងជួយការពារមិន ឱ្យអំពើអាក្រក់គ្រប់យ៉ាងមិនអាចបៀតបៀនបានឡើយ។

### ទី២ អំណាចនៃម្រាមព្រះហស្ដ

នៅពេលព្រះរាជកុមារបានចាប់បដិសន្ធិក្នុងផ្ទៃព្រះមហេសី នៃព្រះបាទក្រុងពារាសី ពេលប្រសូតមកព្រះអង្គមានលក្ខណៈប្រសើរកុមារចំរើនវ័យឡើង ទ្រង់មានអនុភាពអស្ចារ្យ ទោះ បីសេះក្ដី ដំរីក្ដី ដេលកាចសាហាវ គេមិនអាចទូន្មានបាន ទ្រង់លើកតែម្រាមព្រះហស្ដមួយ ចង្អុលប៉ុណ្ណោះ ក៏ទ្រោមចុះអត់មានពុតកំណាចអ្វីឡើយ ព្រះរាជវង្សថ្វាយព្រះនាមថា .វត្តង្គុលិរាជ.។ ព្រះកុមារបានឡើងសោយរាជបន្តពីព្រះបិតា ទ្រង់ប្រកបដោយទសពិតរាជធម៌ គ្រង់អាណាប្រជានុរាស្ត្រដោយសង្គហវត្ថុ៤យ៉ាងពុំបាច់ប្រើអជ្ញាឡើយ ទ្រង់ជាធម្មិករាជ ទ្រង់បានសាងសាលាទាន៦ចំនាយទ្រព្យដល់ស្មូមយាចរាល់ថ្ងៃ។ ស្ដេចទាំង១០១ក្នុងជំពូទ្វីបបានជ្រាបដំណឹងនេះ បានជំនុំព្រឹក្សាគ្នាលើកទ័ពចំនួនយោធា១៨ អក្ខោនភិនីមកប្រយុទ្ធដណ្ដើមក្រុងពារាសី នៃព្រះបាទវត្តង្គុលិរាជ ។ បន្ទាប់មកមានទូតនាំសារតៅក្រុងពារាជសីថា .សុកចិត្តប្រគល់រាជសម្បត្តិឱ្យយើង ឬ ចេញច្បាំងតទល់គ្នាយកឈ្នះ។ ព្រះអង្គបានជ្រាបហើយពុំមានភ័យខ្លាចឡើយ បែជាមានព្រះទ័យអង់អាចក្លាហានដូចរាជសីទៅវិញ។ ព្រះអង្គសួរថា តើស្ដេចទាំងនោះមានពលសេនាទាហានចំនួនប៉ុន្មាន .ដែលមានបំណងមកធ្វើសង្គ្រាមជាមួយនិងយើងនេះ .។ រាជទូតឆ្លើយទូលថា មានចំនួនពលទាំងអស់១៨ អក្ខោនភិនី បានត្រៀបចាំជាស្រេច។ ពួកសហអាមាត្រទូលព្រះថា.ពួកយើងខ្ញុំសុទ្ធជាអ្នកមានកម្លាំងស្ទាត់ជំនាញក្នុងសង្គ្រាម អង់អាចក្លាហានជួយដល់ប្រះអង្គ..។ ខ្ញុំគ្រាន់ឱ្យអ្នកទាំងឡាយតាមហែ ខ្ញុំនិងជិះដំរីដេញបង្អើលកងទ័ពទាំងនោះឱ្យរតខ្ចាត់ខ្ចាយអស់ទៅ ដផយគ្រាន់តែប្រើអង្គុលម្រាមមួយប៉ុណ្ណោះ អ្នកទាំងឡាយកុំព្រួយបារម្ភឡើយ .។ ព្រះអង្គបានធ្វើដំណើរតាមទ្វាខាងកើតទតឃើញចតុរង្គសេនារបស់ខ្មាំងច្រើនណាស់។ ព្រះពោធិសត្វគ្រាន់តែលើកម្រាមព្រះហស្ដមួយចង្អុលទៅចំពួកខ្មាំងទាំងនោះ។ កាលនោះកាលអស្ចារ្យក៏កើតឡើងជាក់ស្ដែងស្រាប់តែពួកពលដំរីធ្លាក់ពីលើខ្នងដំរី ពលសេះធ្លាក់ពីលើខ្នង់សេះ ពលរងធ្លាក់ពីលើរង្ហ ពលថ្មើរជើងដាក់មេផាយនាំគ្នារតខ្ចាតខ្ចាយអស់ទៅ។ ពួកស្ដេចក្នុងនគរទាំងនោះក៏សុំចុះចាញ់លើដៃប្រណមសុំទោស សូមជីវិត សូមថ្វាយរាជសម្បត្តិដល់ព្រះអង្គ ព្រះរាជាទូន្មានស្ដេចទាំងនោះឱ្យស្ថិតនៅក្នុងសន្ដិភាពដោយប្រពៃ។

សរុបសេចក្ដីមកការធ្វើបុណ្យទានជាកុសលដែលមិនចេះសាបសូន្យ បានឱ្យផលមកយើងគ្រាប់ៗជាតិ។

### ឃ.ឧត្តមគតិរឿងគំនិតដឹកនាំរឿងតម្លៃអប់រំ

ឧត្តមគតិរឿងគឺជាឧត្តមគតិរបស់អ្នកនិពន្ធ។ឧត្តមគតិរឿងគឺយកកត្តាប្រធានវិស័យដែលបញ្ហាដែលបញ្ជាក់ពីគោលជំហរសតិអារម្មណ៍របស់អ្នកនិពន្ធដែលស្ដែងឡើងតាមរយៈសកម្មភាពរបស់តួអង្គ។

- អប់រំមនុស្សឱ្យចេះធ្វើបុណ្យធ្វើទាន
- អប់រំមនុស្សឱ្យចេះស្រឡាញ់កាពារសម្បត្តិសាធារណៈ
- អប់រំមនុស្សឱ្យចេះឱ្យមានមេត្តាកតញ្ញូនិងខន្ដី
- អប់រំមនុស្សឱ្យចេះយោគយល់អធ្យាស្រ័យគ្នា
- អប់រំមនុស្សឱ្យចេះទទួលស្គាល់នូវកំហុសរបស់ខ្លួន
- អប់រំមនុស្សឱ្យជឿលើកម្មផល
- អប់រំមនុស្សឱ្យចេះស្រឡាញ់សន្ដិភាព។

សរុបជារួមមករឿងនេះបានចង្អាញពីការចេះធ្វើទានបុន្យទាន កសាងនដិមារករ និងឱ្យយើងចេះអធ្យាស្រ័យគ្នាទៅវិញទៅមកទៀតផង។

# សង្ខេបរឿង សេតបណ្ឌិត

កាលណោះ មានព្រាហ្មណ៍ម្នាក់ឈ្មោះ សុធម្មបាល នៅក្នុងនគរពារាណសី បានចិញ្ចឹមកណ្ដុរសសុទ្ធ មានសម្បុរដូចខ្យងស័ង្ខ។ ព្រាហ្មណ៍នេះដើមឡើងជាខ្ញុំ នៃសេដ្ឋីម្នាក់ នៅនគរពារាណសីដែរ ប៉ុន្តែដោយព្រាហ្មណ៍បានចិញ្ចឹមកណ្ដុរពោធិ- សត្វនោះ ទើបបណ្ដាលឱ្យមានទ្រព្យសម្បត្តិស្តុកស្តម្ភ ព្រមទាំងខ្ញុំប្រុសស្រី ។ ឯ មហាសេដ្ឋីតែងទៅគាល់ព្រះមហាក្សត្ររៀងរាល់ថ្ងៃ ដល់ត្រឡប់មកវិញ, តែង ប្រឡែងលេងនឹងកណ្ដុរសជានិច្ច ។

ថ្ងៃមួយ កណ្ដុរស បាននិយាយនឹងមហាសេដ្ឋីថា “ខ្ញុំរក្សាបញ្ចសីល សូម លោកមហាសេដ្ឋីក្ដី ព្រាហ្មណ៍ក្ដី កុំប្រឡែងលេងនឹងខ្ញុំទៀត ។ បើអ្នកប្រឡែង លេងនឹងអ្នករក្សាសីល នឹងមានបាបច្រើន បើអ្នកឱ្យសុខស្រួលដល់អ្នកមានសីល អ្នកនឹងបានបុណ្យច្រើន” ។ ឯព្រាហ្មណ៍បានឮសំដីកណ្ដុរនិយាយដូច្នោះក៏ខឹងណាស់ បង្គាប់ខ្ញុំកំដរឱ្យចាប់កណ្ដុរយកទៅប្រហារចោលទៅ ។

គ្រានោះ មហាសេដ្ឋី បានឮសំដីព្រាហ្មណ៍ដូច្នោះ ក៏គិតថា “ កណ្ដុរសនេះ ជាសត្វវិសេសមិនគួរសម្លាប់ចោលទេ” នឹកឃើញដូច្នោះហើយ មហាសេដ្ឋី ក៏ស្ទុះ ទៅចាប់កណ្ដុរមុនកម្មកររបស់ព្រាហ្មណ៍ ហើយបីឱបកណ្ដុរចុះពីផ្ទះព្រាហ្មណ៍ទៅ លែងចោលក្នុងព្រៃមួយ - កណ្ដុរក៏រត់ចូលព្រៃបាត់ទៅ ។ ចាប់តាំងពីថ្ងៃដែល -១០រសចេញពីផ្ទះព្រាហ្មណ៍ទៅ ព្រាហ្មណ៍នោះក៏ចេះតែចាយវាយ ទ្រព្យសម្បត្តិបញ្ញោសរៀតកអស់ទៅ លក់ខ្ញុំប្រុស-ស្រី លក់កូនប្រពន្ធ លក់ផ្ទះសំបែង នៅទីបំផុតព្រាហ្មណ៍ តាងរើលំនៅ កាន់អំបែងដើរសុំទានអ្នកស្រុក ដេកតាមសន្យាបផ្ទះអ្នកដទៃឬក្រោមដើមឈើ ចិញ្ចឹមជីវិតដោយលំបាកវេទនាណាស់ ទោះបីដូច្នេះក៏ដោយ ព្រាហ្មណ៍នៅតែខំរក្សាសីល ៥ ជាប់ជានិច្ច ។

លុះកាលកន្លងមកមួយឆ្នាំ កណ្ដុរសពោធិសត្វនឹករលឹកដល់ព្រាហ្មណ៍ជាចៅ របស់ខ្លួនពីមុន ក៏ចេញពីព្រៃហេមពាន្តទៅកាន់លំនៅរបស់ព្រាហ្មណ៍ ក៏មិន បានឃើញទីលំនៅ ព្រមទាំងគ្រួសាររបស់ព្រាហ្មណ៍ ទើបកណ្ដុររុករកទៅដល់ផ្ទះ មួយ ដែលគេបោះបង់ចោល ហើយបានឃើញព្រាហ្មណ៍នោះ ដេកក្រោមរទេះ ចាស់មួយ ប្រកបដោយទុក្ខតភាពពន់ពេក មុខគួរឱ្យអាណោចអាណិតណាស់ ។ កណ្ដុរចូលទៅថើបបាទជើងទាំងទឹកភ្នែកហូរល្វែង ។ ព្រាហ្មណ៍ភ្ញាក់ឡើងសួរថា នរណានុ៎ះ ? ។ កណ្ដុរឆ្លើយថា ខ្ញុំសេតបាលកៈ ។ ព្រាហ្មណ៍ក្រឡេកឃើញកណ្ដុរ ស ដ៏មានសិរីមានក្បាលហាក់ដូចពាក់មកុដនៃស្ដេចចក្កពត្រាធិរាជ ហើយរលឹក នឹកឃើញដល់ទ្រព្យសម្បត្តិដែលវិនាសអន្តរាយអស់ទៅ ក៏ទ្រហោយំឡើង ។ កណ្ដុរស ក៏និយាយលួងលោមព្រាហ្មណ៍ សន្យាថា នឹងធ្វើព្រាហ្មណ៍ឱ្យមានសម្បត្តិ មានកិត្តយសដូចដើមឡើងវិញ ហើយប្រាប់ព្រាហ្មណ៍ថា សុំឱ្យនាំខ្លួនយកទៅលក់ ក្នុងព្រះរាជដ្ឋាន ។

ឯព្រាហ្មណ៍ ងូតទឹកជំរះកាយស្អាតហើយ កណ្ដុរសទៅរកមហាសេដ្ឋី១ មានសេចក្ដីពេញចិត្តណាស់ ទើបនិយាយសុំទិញកណ្ដុរ ប៉ុន្តែព្រាហ្មណ៍មិនព្រមលក់ សោះ ហើយនិយាយសរសើរគុណសម្បត្តិរបស់កណ្ដុរស ដោយ ប្រការផ្សេងៗ ។ នៅទីបំផុត សេដ្ឋីនិយាយសុំរោមកណ្ដុរសពីរបីសរសៃជាទីរលឹក ហើយបូជាកណ្ដុរសដោយសំពត់សពីរ ។ ព្រាហ្មណ៍ក៏យល់ព្រមហើយយកសំពត់សម្លៀកមួយដណ្ដប់មួយ លាសេដ្ឋីចូលទៅកាន់ព្រះរាជវាំង ។

ព្រះរាជាទ្រង់ទតឃើញកណ្ដុរសនោះហើយ ទ្រង់សព្វព្រះហឫទ័យណាស់ ទ្រង់ត្រាស់សុំទិញពីព្រាហ្មណ៍១ កាត់ថ្លៃជាវត្ថុផ្សេងៗ មួយមុខមួយរយ ១ គឺ គោ ១០០ ដំរី ១០០ ទាសី ១០០ ទាសា ១០០ នាងកញ្ញា ១០០ ផ្ទះ ១០០ ខ្នង សេះ ១០០ រថ ១០០ ។

ឯកណ្ដុរស ក៏បានសំដែងធម៌ទូន្មានព្រះមហាក្សត្រ ព្រមទាំងប្រជាជនឱ្យឋិត នៅក្នុងធម៌សុចរិត នឹងការកុសលមានទានសីលជាដើម ហេតុនេះហើយបានជា តាំងពីកាលណោះមក គេតាំងនាមកណ្ដុរសនោះថា “ ធម្មសេតបណ្ឌិត”។

ធម្មសេតបណ្ឌិត ឋិតនៅក្នុងរាជសំណាក់អស់កាលយូរអង្វែង ។ ឯព្រះមហាក្សត្រនឹងអាមាត្យមន្ត្រីព្រមទាំងប្រជាជន បាននាំគ្នាបំពេញសុចរិតធម៌ នឹង ការកុសលផ្សេងៗ មានទានសីលជាដើម ។ តមក ធម្មសេតបណ្ឌិត បានក្រាប ចូលលាព្រះរាជាចេញទៅនៅក្នុងព្រៃហេមពាន្ត ។ ថ្ងៃនោះជាថ្ងៃពេញបូណ៌មីព្រះ ពោធិសត្វជំរះរាងកាឱ្យស្អាត តាំងចិត្តអធិដ្ឋានរក្សាសីល ១០ មិនបរិភោគ អាហារតាំងពីព្រឹកដល់ល្ងាច ។

គ្រានោះ សក្កទេវរាជនិម្មិតជាព្រាហ្មណ៍ ចូលមកឈរជិតព្រះពោធិសត្វ សួរថា “លោកព្រាហ្មណ៍ចូលមកដល់ព្រៃធំនេះ តើមានបើប្រាថ្នាអ្វី ? ។

ព្រះឥន្ទ្រាធិរាជ ត្រាស់តបថា ក្នុងថ្ងៃពេញបូណ៌មី អ្នកមិនទាន់បាន បរិភោគអាហារទេ ឬ ? ឯខ្ញុំក៏អត់អាហារតាំងពីព្រឹកមកដែរ ដូច្នេះ ខ្ញុំចូលមករក អ្នក ដើម្បីសុំសាច់អ្នក ” ។

ធម្មសេតបណ្ឌិត បានសុំឱ្យព្រាហ្មណ៍បង្កាត់ភ្លើង ឱ្យមានរងើកល្អហើយ អ្នកដឹងឱ្យទានសាច់របស់អ្នកដល់ព្រាហ្មណ៍ស្ងួម ក៏បណ្ដាលឱ្យកើតរណ្ដៅរងើក ភ្លើងឡើងក្នុងពេលនោះឯង កណ្ដុរសបានពោលនឹងព្រាហ្មណ៍ថា “បពិត្រ ព្រាហ្មណ៍ដ៏ចំរើន យើងមិនបានប្រាថ្នាសម្បត្តិមនុស្ស ទេវតា ព្រហ្មទេ ប៉ុន្តែ យើងតាំងចិត្តឱ្យបានសម្រេចព្រះសព្វញ្ញុតញ្ញាណតែប៉ុណ្ណោះហើយក៏សំដែងដល់លោតចូលទៅក្នុងរណ្ដៅរងើកភ្លើង ស្រាប់តែមានផ្កាឈូកមាសមួយធំផុសឡើង ទ្រព្រះពោធិសត្វ មិនឱ្យឆេះភ្លើង ឬ រលាក ឬ ក្ដៅសោះឡើយ ហើយសម្ដេច ព្រះអមរិន្ទនាំអ្នកឡើងទៅកាន់ឋានត្រៃត្រឹង្សក្នុងខណៈនោះឯង ទេពតាទាំងឡាយទ្រង់អញ្ជើញឱ្យធម្មសេតបណ្ឌិតឋិតលើអាសនៈ ទ្រង់អារាធនា ឱ្យសំដែងធម៌ជាទីសណ្ដាប់ដល់ពពួកទេពតា ក្រោយពេកចប់ធម្មទេសនាពួក ទេពតាបានធ្វើសក្ការបូជាជាយាំងធំ ព្រមទាំងជូនពរស័ព្ទសាធុការផ្សេងៗ ។

ព្រះឥន្ទ្រាធិរាជ ទ្រង់នាំធម្មសេតបណ្ឌិតចុះមកកាន់ព្រៃហេមពាន្តកន្លែង ដើមវិញ ហើយទ្រង់និម្មិតទីឋាននោះ ជាទីរមណីយដ្ឋានគួរជាទីមនោរម្យផ្សេងៗ ហើយ ទ្រង់លាត្រឡប់ទៅទៅទេវលោកវិញ ។

## ក.អត្ថន័យខ្លឹមសារ

អត្ថន័យអត្ថ .ប្រយោជន៍.អត្ថន័យ .ការណែនាំអត្ថាធិប្បាយសេចក្ដីពន្យល់.អត្ថន័យជាគំនិតសំខាន់ៗរបស់អ្នកនិពន្ធដែលលាតត្រដាងនៅក្នុងដំណើររឿង ហើយគេអាចហៅវាថាជាជម្រៅនៃរឿង។

ក្នុងផ្នែកអត្ថន័យមាន ប្រធានរឿង មូលបញ្ហារឿងនិងឧត្ដមគតិរឿង។

## ខ.ប្រធានរឿង មូលន័យ

ប្រធានរឿង ឬមូលន័យ គឺជាគំនិតសំខាន់ៗ របស់រឿង។ ប្រតិឬជាបញ្ហារួមរបស់រឿង។ តែអ្នកនិពន្ធចង់បង្ហាញដល់អ្នកអានប្រធានរឿងជាបញ្ហារួបផ្ដុំបំផុតដែលអ្នកនីពន្ធលើកយកមកសរសេរឬជ្រើសរើសជាប្រធានបទហើយដែលមានមូលបញ្ហារឿងឋិតនៅក្នុងនោះ។

ប្រធានរឿងបង្ហាញនៅចំហររបស់អ្នកនិពន្ធវាជាមូលដ្ឋានដើមរបស់អ្នកនិពន្ធក្នុងការចាប់ផ្ដើមសរសេរឡើង។ មុនពេលចាប់ផ្ដើមសរសេរឡើង។ អ្នកនិពន្ធគ្រប់រូបត្រូវកំណត់ថាតើគាត់ត្រូវសរសេរអំពីអ្វី។អំពីជីវិតសង្គមសង្គ្រាមស្នេហារឿងជំនឿទនៀមទម្លាប់ប្រពៃណីចម្លើយរបស់សំណួរនេះហើយជាប្រធានរឿង។

តាមរយះ រឿងសេតបណ្ឌិត បានបង្ហាញពី ការបំពេញមេត្តបារមី ព្រះពោធិសត្វ សេតបណ្ឌិត។

## គ.មូលបញ្ហារឿង

មូលបញ្ហារឿងគឺជាភាពចំណែកនៃប្រធានរឿងជាទិដ្ឋភាពផ្សេងៗរបស់យើង។វាជាការចូលជ្រៅទៅក្នុងប្រធានរឿង។

ជុំវិញប្រធានរឿងនេះ យើងបានកំណត់បញ្ហាជាច្រើន ដែលនៅជុំវិញការកសាងសីលបារមីរបស់ព្រះពោធិសត្វ បញ្ហាទាំងនោះរួមមានៈ

### ទី១ បញ្ហាព្រាហ្មណ៍ចង់សម្លាប់កណ្ដុសរ

នៅពេលដែលព្រាហ្មណ៍និងមហាសេដ្ឋីមកពីរាជវាំងវិញបាននាំគ្នាមកលេងកណ្ដុសរព្រះពោធិសត្វ បាននិយាយ សេដ្ឋី និងព្រាហ្មថា ខ្ញុំរក្សាបច្ចសិលសូមមហាសេដ្ឋីក្ដី ព្រាហ្មណ៍ក្ដីកុំប្រឡែងលេងនិងអ្នកមានសីល និងមានបាបច្រើន បើអ្នកឱ្យសុខស្រួលនិងអ្នករក្សាសីលនិងបានបុណ្យច្រើន។ ព្រាហ្មបានស្ដាប់ហើយខឹងណាស់បង្គាប់ខ្ញុំកំណរឱ្យចាប់យកតៅប្ដហារចោលទៅ។ មហាសេដ្ឋីបានស្ដាប់ហើយគិតថា កណ្ដុសរនេះជាសត្វពិសេសមិនគួរសម្លាប់ចោលទេក៏ចាប់យកទៅលែងក្នុងព្រៃទៅ។ ក្រោយមកសេដ្ឋីបានធ្លាក់ខ្លួនក្របានលក់ប្រពន្ធកូន ខ្ញុំប្រុសស្រី ផ្ទះសម្បែងហើយដើរសុំទានគេ ។

សរុបសេចក្តីមកមនុស្សម្នាក់ៗ គម្បីយល់ពីការរក្សាទានសិលបានជួយឱ្យយើងបានសេចក្តីសុខ និងមិនត្រូវមានចិត្តបៀតបៀនចំពោះអ្នកដែលរក្សាសិលនោះឡើយ។

### ទី២ បញ្ហាកតញ្ញូរបស់កណ្តុសរ

ក្នុងរយៈពេល១ឆ្នាំកន្លងផុតទៅ កណ្តុសរពោធិសត្វបានទឹកដល់ម្ចាស់ក៏ចេញពីព្រៃហេនិពន្ធ មករកព្រាហ្មណ៍កន្លែងព្រាហ្មណ៍នៅផ្ទះព្រាហ្មណ៍ តែមិនឃើញសោះក៏ដើររក បានឃើញព្រាហ្មណ៍ដេកនៅផ្ទះគេចោលក្រោមរទេះចាស់មួយ ប្រកបដោយទុក្ខតភាពកណ្តុសរបានទៅថើបបាតជើងម្ចាស់អាណិតម្ចាស់ទាំងទឹកភិនែកហូររហែងជាខ្លាំង។ ពេលព្រាហ្មន៍ភ្ញាក់ឡើងឃើញក៏និយាយថា អ្នកណានោះ ខ្ញុំសេតបនិកៈ ព្រាហ្មណ៍ក្រឡេកឃើញកណ្តុសរហាក់ដូចពាក់ម្កុដនៃស្តេចចក្កបត្រាធិរាជ ហើយរកឹកឃើញដល់ទ្រព្យសម្បត្តិដែលវិនាសបាត់ទៅក៏ទ្រហោយំឡើង កណ្តុសរនិយាយលួងលោមប្រហ្មណ៍ដោយនិយាយសន្យាថា ជួយឱ្យព្រាហ្មណ៍មានទ្រព្យសម្បត្តិ មានកិត្តិយសឡើងវិញ ឯព្រាហ្មណ៍ងូតទឹកជំរះកាយហើយបិកណ្តុរសរទៅផ្ទះសេដ្ឋី សេដ្ឋីឃើញកណ្តុរសរហើយកើតចិត្តជ្រះថ្លាសុំទិញកណ្តុរសរនោះពីព្រាហ្មណ៍ក្នុងតម្លៃថ្លៃតែព្រាហ្មមិនព្រមលក់ ដេដ្ឋីក៏សុំរោមកណ្តុរសរនោះទុកជាសក្ការៈបូជាដោយបូជាសំពត់សរពីរ ព្រាហ្មណ៍ក៏យកព្រម ។ ហើយព្រាហ្មណ៍យកសំពត់សរស្លៀកមួយដណ្តប់មួយដើរទៅក្នុងរាជវាំង។ ព្រះរាជាឃើញកណ្តុរសរហើយសព្វព្រះទ័យជាខ្លាំងសុំទិញកណ្តុរសរនោះ ព្រាហ្មណ៍ក៏យល់ព្រម ដោយយកថ្លៃជាវត្ថុផ្សេងៗមួយមុខ១០០ៗ គឺគោ១០០ ដំរី១០០ ទាសី១០០ ទាសា១០០នាងកញ្ញា១០០ផ្ទះ១០០ខ្ទង់សេះ១០០និងរដ្ឋ១០០។ កណ្តុរសរថ្លែងធម៌ទូន្មានព្រះមហាក្សត្រព្រមទាំងប្រជាជនឱ្យស្ថិតនៅក្នុងធម៌សុចរិច។

សរុបមក ភាពកញ្ញូកតវេទីចំពោះអ្នកដែលបានជួយ សង្គ្រោះខ្លួនជាអំពើដ៏ល្អមិនចេះសាបសូនដែលបុគ្គគ្រប់រូបគួរតែធ្វើ។

### ឃ.ឧត្តមគតិរឿងគំនិតដឹកនាំរឿងតម្លៃអប់រំ

ឧត្តមគតិរឿងគឺជាឧត្តមគតិរបស់អ្នកនិពន្ធ។ឧត្តមគតិរឿងគឺយកកក្តាប្រធានវិស័យដែលបញ្ហាដែលបញ្ជាក់ពីគោលជំហរសតិអារម្មណ៍របស់អ្នកនិពន្ធដែលស្តែងឡើងតាមរយៈសកម្មភាពរបស់តួអង្គ។

- អប់រំមនុស្សឱ្យចេះតបគុណអ្នកដែលជួយសង្គ្រោះខ្លួន
- អបរំមនុស្សឱ្យចេះគិតឱ្យបានវែងឆ្ងាយមុននិងធ្វើអ្វីមួយ
- អប់រំមនុស្សឱ្យមានការភ្ញាក់រលឹកឡើងវិញ
- អប់រំមនុស្សមិនឱ្យមាបការរើសអើង
- អប់រំមនុស្សឱ្យចេះជួយសង្គ្រោះគ្នាទៅវិញទៅមក
- អប់រំមនុស្សឱ្យចេះធ្វើបុណ្យដាក់ទាន។

សរុបជារួមមករឿងនេះ បានបង្ហាញពីផាពកតញ្ញូចំពោះអ្នកដែលបានជួយសង្គ្រោះខ្លួននៅពេលដែលបានជួបបញ្ហា ហើយមិនភ្លេចគុណ នឹងឱ្យយើងចេះរក្សាភាពស្មោះត្រង់ចំពោះគ្នាទៅវិញទៅមក។

# សង្ខេបរឿង វិបុលកិត្តិ

មានព្រះមហាក្សត្រមួយអង្គព្រះនាមយសកិត្តិរាជគ្រងរាជ្យក្នុង ចម្បកនគរ មហេសីព្រះនាម សិរិមតីទេវី ។ រាត្រីមួយព្រះរាជទេវី ទ្រង់ព្រះសុបិន ឃើញតាបសមួយរូបដៃកាន់កែវមណី មានពន្លឺរស្មីចិញ្ចែង ហោះចេញពីភ្នំវិបុលបពិត ហើយបានប្រគល់កែវដួងនោះដល់ព្រះនាង តាំងពីកាលណោះព្រះ នាងក៏ទ្រង់គភ៌ ។

មានស្តេចជិតខាងមួយអង្គ បានជ្រាបថា ព្រះបាទយសកិត្តិរាជជាស្តេចទ្រង់ ធម៌ ទ្រង់រក្សានិច្ចសីលពុំដែលដាច់ខានសោះឡើយ ។ ស្តេចក៏លើកទ័ពទៅព័ទ្ធឡោម ក្រុងចម្បកនគរ ពួកសេនាយោធារបស់ព្រះអង្គស្រុះចិត្តគ្នា ចេញច្បាំងតទល់នឹង បច្ចាមិត្រ ប៉ុន្តែទ្រង់ពុំយល់ព្រមសោះ ហើយស្តេចលបដោះខ្លួនរត់ចេញពីព្រះរាជវាំង ជាមួយនឹងអគ្គមហេសីដែលទ្រង់កគ៌ ហើយទ្រង់ភេទជាឥសី នៅក្នុងព្រៃជិតជើងភ្នំ វិបុលកិត្តិ ។ ឯស្តេចបច្ចាមិត្របានប្រកាលឱ្យរកចាប់ស្តេចយសកិត្តិដោយឱ្យរង្វាន់ ដល់អ្នកចាប់បានជាមាស ១០០០ តម្លឹង ។

មានព្រានព្រៃម្នាក់ ដោយក្តីលោភចង់បានរង្វាន់នោះ ក៏ចូលទៅរកបរបាញ់ ម្រឹគ ដើម្បីរុករកទីកន្លែងដែលស្តេចយសកិត្តិ លាក់ខ្លួនពួនអាត្មា ។ លុះចូលទៅក្នុង ព្រៃជ្រៅទៅ ក៏វង្វេងវិលវល់នៅក្នុងព្រៃរកផ្លូវត្រឡប់មកផ្ទះវិញពុំឃើញសោះ អស់ កំឡុង ៧ ថ្ងៃ ហើយជួនបានប្រទះអាស្រមបទរបស់ស្តេចយសកិត្តិ១ ទ្រង់បានទទួល រាក់ទាក់ឱ្យព្រានព្រៃស្នាក់នៅនឹងព្រះអង្គ ៧ថ្ងៃ ហើយទើបទ្រង់នាំផ្លូវវាឱ្យចេញព្រៃ ទ្រង់បានផ្តាំផ្តាច់ថា កុំឱ្យនិយាយប្រាប់នរណាអំពីទីកន្លែងដែលទ្រង់គង់នៅតំបន់នោះឱ្យសោះ ។

ឯព្រានព្រៃអកតញ្ញូ ក្រោយដែលបាន ឮប្រកាសរបស់ស្តេចបច្ចាមិត្រម្តងទៀតក៏មានក្តីលោភទ្រព្យកើតឡើងទើបក្រាបទូលដំណឹងនោះដល់ស្តេចដណ្តើមរាជ្យ១ ក៏តាំងព្រានព្រៃជាមគ្គុទ្ទេសក៍ ឱ្យនាំសេនាទាហានទៅតាមចាប់ស្តេចយសកិត្តិនោះ ។

ព្រះរាជឫសី ទ្រង់បានឮសូរហ៊ោកងរំពងទាំងព្រៃក៏ទ្រង់ជ្រាបថា ព្រានពចិត្ត អាក្រក់នាំទ័ពមកតាមចាប់ព្រះអង្គមានបន្ទូលនឹងមហេសីដែលទ្រង់គភ៌ជិតគ្រប់ ខែហើយថា ទ្រង់នឹងចេញទទួលកងទ័ពខ្លាំងពីចម្ងាយ ដើម្បីកុំឱ្យវាដឹងទីតាំងអាស្រម របស់ទ្រង់ ទ្រង់បានចេញទៅរកកងទ័ពដោយអង់អាចឥតតក់ស្លុតឡើយ ពួក សេនាខ្លាំងក៏ចាប់ចងព្រះអង្គដោយចំណង ៥ ប្រការ នាំបណ្តើរទ្រង់ទៅដាក់គុកក្នុង ក្រុងចម្បកនគរនោះឯង ។

ព្រះនាងសិរិមតីទេវីទ្រង់សោយសោកអាណិតព្រះស្វាមីលើសលន់ពន់ប្រមាណ ដល់ពេលរាត្រីអាធ្រាត្រ ព្រះនាងឈឺផ្ទៃប្រសូតព្រះរាជបុត្រ ដ៏មានសិរី វិលាសឱភាសក្រៃលែង ។ ព្រះនាមផ្សំនាមមាតាបិតានឹងឈ្មោះភ្នំបញ្ចូលគ្នា ជានាម ព្រះរាជបុត្រថា សិរីវិបុលកិត្តិកុមារ១ ក៏បានធាត់ធំចំរើនឡើងជាលំដាប់ ។ ថ្ងៃមួយ ព្រះកុមារទូលលាព្រះវរមាតាអ្នកទៅរកព្រះវរបិតាឯចម្បកនគរ ព្រះវរមាតាពុំ យល់ព្រមឱ្យអ្នកទៅទេ តែទូលអង្វរគ្រាតែយល់ព្រម ហើយព្រះមាតាបានប្រទាន សំពត់កម្ពល ១ ព្រះទម្រង់ ១ ដល់ព្រះកុមារកាន់ភេទជាឥសីក្មេងទៅស៊ើបសួររក ព្រះវរបិតាឯចម្បកនគរ ។

នៅទីបំផុត អ្នកបានជួបនឹងព្រះវរបិតា មិនទទួលស្គាល់អ្នកទើបបង្ហាញសំពត់កម្ពលិនឹងព្រះទម្រង់ៗ ព្រមទាំងចូលរឿងរ៉ាវឱ្យជ្រាប ទើបទ្រង់ជឿថា ឥសី ក្មេងនេះជារាជបុត្ររបស់ទ្រង់ពិតមែន ។ អ្នកបានឡើងទៅក្រាបទូលស្តេចបច្ចាមិត ថា “ ទ្រង់បានចាប់ឃុំស្តេចយសកិត្តិមកយូរហើយ ឥឡូវសូមទ្រង់ព្រះមេត្តាដោះលែង ចេញ ប្រសិនបើទ្រង់ចង់ពិឃាតឱ្យក្សិណក្ស័យ ទូលបង្គំសូមថ្វាយជីវិតជាជំនួសវិញ” ស្តេចអធម៌ក៏យល់ព្រម ទើបទ្រង់បញ្ជាឱ្យចាប់ចងអ្នកដោយចំណង ៥ ប្រការ ហើយ នាំខ្លួនយកទៅពិឃាត ។ លោកថា ដោយអានុភាពនៃធម៌កតញ្ញូកតវេទី រក្សាការពារ ព្រះកុមារ ដាវលំពែងរបស់ពេជ្ឈឃាតក៏បាក់បែកវិនាសអន្តរាយ ។ ស្តេចអធម៌នោះ ឱ្យយកដំរីសឹកទៅពេចសម្លាប់ទៀត ដំរីក៏ពុំហ៊ានប៉ះពាល់ដល់រាង់កាយ ព្រះរាជកុមារ ឡើយ ។ ទ្រង់បញ្ជាឱ្យចាប់អ្នកបោះទម្លាក់ក្នុងរណ្តៅរងើកភ្លើង ក៏ពុំមានអន្តរាយ ទៀត ទើបទ្រង់បង្គាប់ឱ្យចាប់អ្នកទម្លាក់ទៅក្នុងជ្រោះជ្រៅមួយ ដោយអំពើអធម្មកម្ម នៃស្តេចទ្រុស្តមិត្តនេះ ព្រះធរណីហាក់ដូចជាទ្រង់ខ្ញាល់ នឹងអំពើលាមកសាហាវឃោរឃៅរបស់ស្តេចអធម៌ ទើបស្រូបទម្លាក់ស្តេចនោះទៅ ក្នុងរណ្តៅមហានរកទៅ។ ចំណែកឯព្រះកុមារក្រោយដែលបានធ្លាក់ទៅក្នុងជ្រោះជ្រៅនោះ ចួនជាស្តេចភុជង្គបានទទួលទ្រព្រះកុមារពុំឱ្យអន្តរាយដល់ជីវិតហើយនាំអ្នកទៅឋានភុជង្គនាគ រួចដង្ហែអ្នកមកចម្បកនគរ ហើយស្តេច

នាគបានធ្វើពិធីរាជាភិសេកព្រះកុមារឱ្យអ្នក ឡើងគ្រងរាជ្យ នៅចម្បកនគរ ទើបលាត្រឡប់ទៅឋានភុជង្គនាគវិញ ។

កាលព្រះមហាក្សត្រ ទ្រង់បានឡើងគ្រងរាជ្យហើយ ទ្រង់បាននឹករលឹកដល់ ព្រះវរមាតាខ្លាំងណាស់ ទើបស្តេចព្រមដោយព្រះវរបិតា ..លើកសេនាយោធាចេញ ទៅព្រៃ ដើម្បីទទួលព្រះមាតាវិលថ្កានព្រះនគរ ។ ឯព្រះនាងសិរិមតីទេវី ក្រោយព្រះបុត្រា ជាបណ្តូលចិត្តលាចេញទៅស្វែងរកព្រះវរបិតាផុតទៅ ព្រះនាងកើតទុក្ខធ្ងន់ក្រៃលែង ដោយក្តីព្រាត់ប្រាសព្រះរាជស្វាមីនឹងព្រះរាជបុត្រសំឡាញ់ ព្រះនាងមានរាងកាយ ញាប់ញ័ររន្ធត់ជានិច្ច ហើយចេះតែស្គាំងស្គមថមថយខ្សោយ ព្រះកាយពលដរាបដល់ ក្ស័យ ព្រះជន្មក្នុងបណ្ណសាលានោះឯង ។

លុះព្រះមហាក្សត្រយាងចូលទៅក្នុងបណ្ណសាលាស្រាប់តែទតឃើញព្រះវរមាតាសោយទិវង្គតផុតទៅហើយ ទ្រង់ព្រះកន្សែងសោក អាឡោះអាល័យមហិមា រួច ទ្រង់បញ្ជាឱ្យអាមាត្យមុខមន្រ្តីរៀបក្បួនដង្ហែព្រះសពទៅចម្បកនគរវិញ ។ ព្រះបាទសិរីវិបុលកិត្តិរាជ ទ្រង់មានបំណងនឹងបរិច្ចាគជីវិតទ្រង់ដើម្បីតបស្នង សងគុណព្រះវរមាតា ទើបទ្រង់ក្រាបទូលលាព្រះវរបិតា ទុកជាបានហាមឃាត់ទ្រង់ យ៉ាងណា ក៏ទ្រង់ពុំយល់ព្រមសោះ ព្រោះមានព្រះទ័យអាឡោះអាល័យសោកស្តាយ ព្រះវរមាតាលើសលន់ផង ដោយទ្រង់មានកតញ្ញូកតវេទី ចំពោះព្រះ មាយាំងក លែងផង ក្រោយថ្វាយបង្គំលាព្រះវរបិតាហើយ ទ្រង់បានចូលទៅផ្ទុំក្រោមព្រះ មឈូសមាស ទ្រង់លើកក្តារមឈូសដាក់លើឱរាហើយ ទ្រង់ឱបក្តារមឈូសជាប់ ហើយទ្រង់បង្គាប់ឱ្យថ្វាយព្រះភ្លើងព្រះសពព្រះវរមាតា ។

គួរឱ្យអស្ចារ្យ ព្រះអគ្គីហាក់ដូចជាមានសេចក្តីគោរពព្រះចេស្តាបារមី មិនហ៊ានបញ្ចេញចំហាយក្តៅឱ្យឆាបឆេះ ឬ ក្តៅដល់ព្រះអង្គឡើយ ។ ឯព្រះសពព្រះ វរមាតា ព្រះអគ្គីឆេះរំលាយត្រាតែសុសអស់ទៅ ។ ឯព្រះកាយព្រះមហាសត្វ ត្រឡប់មានវិថ្មីរុងរឿងហាក់ដូចសុវណ្ណបដិមាករនៅក្នុងរងើកភ្លើង។ ទាំងនេះលោក ថាកើតឡើដោយធម៌កតញ្ញូកតវេទីដ៏វិសេសក្រៃលែងនៃព្រះមហាសត្វ ទ្រង់បានគ្រប់គ្រងរាជសម្បត្តិ ប្រកបដោយក្តីសុខក្សេមក្សាន្ត នឹងសន្តិភាពរៀងដរាបតទៅ ។

## ក.អត្ថន័យខ្លឹមសារ

អត្ថន័យអត្ថ .ប្រយោជន៍.អត្ថន័យ .ការណែនាំអត្ថាធិប្បាយសេចក្តីពន្យល់.អត្ថន័យជាគំនិតសំខាន់ៗរបស់អ្នកនិពន្ធដែលលាតត្រដាងនៅក្នុងដំណើររឿង ហើយគេអាចហៅវាថាជាជម្រៅនៃរឿង។

ក្នុងផ្នែកអត្ថន័យមាន ប្រធានរឿង មូលបញ្ហារឿងនិងឧត្តមគតិរឿង។

## ខ. ប្រធានរឿងវិបុលកិត្តិ

នៅក្នុងស្នាដៃរឿងបញ្ញាសជាតកតាមរយៈការអានរឿងនេះជាច្រើនលើកច្រើនសារ យើងខ្ញុំរកឃើញនិងសំរេចជ្រើសរើសយក ប្រធាន រឿងដែលក្តោបសាច់រឿងទាំងមូលនោះការបំពេញធម៌កតញ្ញូនិងខន្តី ព្រោះយើងឃើញថារឿងនេះ មិនមែនត្រឹមតែអប់រំតាមបែបពុទ្ធសាសនាប៉ុណ្ណោះ ទេ ពោលគឺទស្សនៈកម្មផល បានន័យថាកម្មបែបណាផលបែបនោះ ។

គ.មូលបញ្ហារឿងការដណ្តើមរាជ្យសម្បត្តិរបស់ស្តេចអធម៌

នៅក្នុងស្នាដៃរឿងវិបុលកិត្តិបានបង្ហាញពីចិត្តលោបលន់របស់ស្តេចអធម៌ ដែលមានចិត្តចង់បានក្លាយខ្លួនជាស្តេចផែនដី បានប្រព្រឹត្តិអំពើបាបកម្មលើកទ័ពបោះបោរដណ្តើមរាជ្យ និងធ្វើឱ្យស្តេចយុសកិត្តចេញពីនគរទាំងក្រុមគ្រួសារ។

ការរក្សានិច្ចសីលព្រះបាទយុសកិត្ត តាមរយៈការកាន់និច្ចសីលរបស់ស្តេចយុសិកិត្តិបានធ្វើឱ្យព្រះអង្គចាកចេញពីនគរ តៅរស់នៅក្នុងព្រៃដោយចិត្តខន្តីចំពោះស្តេចអធម៌ ព្រះអង្គសុកចិត្តរងទុក្ខរស់នៅក្នុងព្រៃ ដើម្បីសុខសន្តិភាពនៅក្បួងនគរ។

ឃ.ឧត្តមគតិរឿងគំនិតដឹកនាំរឿងតម្លៃអប់រំ

ឧត្តមគតិរឿងគឺជាឧត្តមគតិរបស់អ្នកនិពន្ធ។ឧត្តមគតិរឿងគឺយកកត្តាប្រធានវិស័យដែលបញ្ហាដែលបញ្ជាក់ពីគោលជំហរសតិអារម្មណ៍របស់អ្នកនិពន្ធដែលស្តែងឡើងតាមរយៈសកម្មភាពរបស់តួអង្គ។

- អប់រំឱ្យមនុស្សចេះខន្តីចំពោះអ្នកដែលបានធ្វើអំពើបាបកម្មមកលើខ្លួន ដូចបាន បង្ហាញចំពោះតួអង្គស្តេចវិបុលកិត្តិ

- អប់រំដល់មនុស្សកុំឱ្យមានចិត្តលោបលន់ចង់បាននូវអ្វីដែលមិនមែនជារបស់ខ្លួនធ្វើ ឱ្យអ្នកដទៃរងទុកទោសដូចតួអង្គស្តេចយុសកិត្តិ

- អប់រំដល់មនុស្សឱ្យចេះបំពេញព្រហ្មវិហារធម៌ចំពោះអ្នកមានគុណ និងតបស្នងសង គុណលោកវិញដូចតួអង្គ ព្រះរាជកុមារសិរីវិបុលកិត្តិរាជ មានធម៌កតញ្ញូចំពោះ មាតា បិតា សុកចិត្តលះបង់អាយុជីវិតដើម្បីអ្នកកទាំងពីរបានបង្ហាញនៅពេលប្រះបិតាត្រូវស្តេចអធម៌ចាប់ព្រះបិតា ទៅឃុំឃាំងនៅក្នុងនគរ ព្រះរាជកុមារបានទទួលទោសជំនួស និងមួយទៀតពេលព្រះ មាតាសុគតព្រះកុមារបានបូជាជីវិតចូលទៅក្នុងភ្លើងជាមួយសពមាតាដោយធម៌កតញ្ញូព្រះ អគ្គិមិនហានធ្វើឱ្យព្រះអគ្គីគោរពមិនហានប៉ះពាល់ដល់ព្រះអង្គឡើយរាងកាយព្រះអង្គប្រែជា ដូចមាសតៅវិញ

- ការអប់រំឱ្យយើងចេហខ្លាចនូវការប្រព្រឹត្តិអំពើបាបកម្មធ្វើឱ្យយើងអន្រាយ ដូចស្តេច អធម៌បានធ្វើបាបកម្មតៅលើព្រះរជកុមារត្រូវព្រះធរណីស្រូបទៅភ្លាមៗបានគទយលបាបកម្ម នៅបច្ចុប្បជាតិទស្សនៈកម្មផលក្នុងរឿងដក្សរសិល្បពុទ្ធនិយម។

សរុបជារួមកមយើងថា រឿងវិបុលកិត្តិបានអប់រំដល់បុគ្គលគ្រប់រូបឱ្យមានខន្តីចេះ ដោះស្រាយបញ្ហាដោយសន្តិវិធីដូចស្តេចយសកិត្តិ មានធម៌កតញ្ញូចំពោះអ្នកមានគុណអ្នក ដែលមានធម៌កតញ្ញូទោះជាទៅដល់ទីណាចូបគ្រោះមហន្តរាយក៏មិនងន្រាយមកដល់ខ្លួយន ដែរសបញ្ជាក់ឱ្យឃើញតាមរយៈតួងង្គសិរីវិបុលកិត្តិរាជ នៅពេលស្តេចអធម៌ឱ្យពេជខាត សម្លាប់ដៅលំបេងរបស់ពេពឃាតក៏វិនាសបាក់បេកងស់ក៏យកទៅបោះចុលណ្តៅបានស្តេចភ ជុង្គនាកទ្រប្រះអង្គហើយចុងក្រោយព្រះរាជកុមារក៏បានសេចេក្តីសុខក្សេមសាន្តរហុតទៅ។

## ក. លក្ខណៈសំគាល់នអក្សរសិល្ប៍ពុទ្ធនិយមក្លាយហួសហេតុផ្នែកអត្ថបទ

### ខ. អត្ថន័យ

. អត្ថន័យ ទាក់ទងទៅនឹងការកសាងបារមីរបស់តួអង្គព្រះពោធិសត្វ ជំនឿ កម្ម ផល។

បញ្ហាចោទ និងដំណោះស្រាយ

បញ្ហាចោទនិងដំណោះស្រាយ នៅលើទំនាស់វិបត្តិរវាងព្រះពោធិសត្វ និងទ្រព្យ សម្បត្តិ រវាង ទ្រព្យសម្បត្តិនិងបិតា ភរិយាដើម្បីលោភៈ ទោសៈ មោហៈ និងស្នេហារវាងទ្រព្យ សម្បត្តិ និងពលរដ្ឋ។

ដំណោះស្រាយបញ្ហានៅក្នុងរឿងគឺ តាមបែបសន្តិវិធី ឬអហិង្សា។ បង្ហាញពីស្នេហាស្មោះ ត្រង់ រវាងតួអង្គព្រះពោធិសត្វនិងនាងកន្សែសារពេជ្ញ។ នៅទីបញ្ចប់ពោធិសត្វទទួលជ័យជំនះ បានជួបជុំ

គ្រួសារ ឡើងសោយរាជ្យត្រូវបានមហាជនគោរព និងសរសើរចំពោះបារមីព្រះអង្គ។

### គ. ផ្នែកអត្ថរូប មានលក្ខណៈឯកភាពគ្នាដូចតទៅ

### ឃ. ផ្តើមរឿង

អ្នកនិពន្ធច្រើនផ្តើមរឿងដោយ ធ្វើបទនមស្សការគោរពព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ និងការនឹក គុណដល់មាតាបិតា និងគ្រូបាធ្យាយ។

### ខ. ផ្នែករឿង (ដំណើររឿង)

ជាការបរិយាយប្រៀបធៀប បាននឹងធម៌ទេសនារបស់ព្រះពុទ្ធអង្គចំពោះភិក្ខុសង្ឃ ពុទ្ធបរិស័ទ ទាំងឡាយដើម្បីមើលឃើញពីការកសាងបារមីរបស់ព្រះពោធិ សត្វដ៏ស្ថិតស្វាញក្នុង អនេកជាតិ។ ច្រើន បំពេរចិត្តគំនិតពុទ្ធសាសនិកជនឲ្យជឿបុណ្យបាបខ្លាចអំពើអាក្រក់។ បរិយាយលាយឡំរវាងពុទ្ធចកនិងអាណាចក្រ។

តួអង្គក្នុងអក្សរសិល្ប៍ពុទ្ធនិយបក្លាយហួសហេតុតួឯកប្រុសជាពោធិសត្វ តួឯកស្រីជានាកន្សៃស្សារពេជ្ជ ដែលជាគូរបស់ព្រះពោធិសត្វ។

កាលអាកាសច្រើនប្រព្រឹត្តទៅក្នុងនគរពារាណសី សាវត្ថី ស្រុកស្រីពិរាស្ត្រ កលិង្គរាស្ត្រ លង្កា ពាហេមពាន្តពោលគឺនៅប្រទេសឥណ្ឌា។

## ខ. បញ្ចប់រឿង

បញ្ចប់ដោយការសរជាតិឲ្យតួអង្គពោធិសត្វសម្រេចជោគជ័យក្នុងសកម្មភាពអ្វីមួយ ដោយការលើកសរសើរប្រសិទ្ធពរ ចំពោះការបំពេញកុសលកម្ម រក្សាសីលរហូតអស់ជន្មាយុរួចទៅកើតក្នុងឋាន តុសិតទេលោកសោយរាជ្យ សម្បត្តិទិព្វសុខក្សេមក្សាន្ត។

គោលគំនិតអប់រំអក្សរសិល្ប៍ពុទ្ធនិយមក្លាយហួសហេតុ អប់រំឲ្យមានជំនឿលើកម្មផល អប់រំកាយវាចាចិត្ត អប់រំឲ្យស្រឡាញ់សន្តិភាព ឲ្យបានចិត្តមេត្តាករុណានិងចេះធ្វើទានដល់អ្នកក្រ កុំឲ្យលោភលន់ហួសហេតុប្រកាន់ភ្ជាប់នូវសេចក្តីព្យាយាម ឲ្យប្រើប្រាស់បញ្ញាដើម្បីដោះស្រាយបញ្ហា។

## ក.ឥទ្ធិពលនៃរឿងបញ្ញាសជាតកខ្លះ

រឿងជាតកទាំងឡាយ ដែលមានសេចក្តីផ្តើមបញ្ជាក់អំពីរឿងរ៉ាវខ្លី ក្នុង សម័យពុទ្ធកាលក្តី នៅពេលបញ្ចប់រឿងថ្លែងបញ្ជាក់ពីការត្រឡប់ជាតិ ឬការសជាតិក្តី អត្ថន័យទាំងពីរអន្លើនេះ បញ្ជាក់ឱ្យយើងយល់ថារឿងជាតកនោះ ឡើងដោយឥទ្ធិពលនៃអក្សរសាស្ត្រខាងពុទ្ធសាសនា ។ ប៉ុន្តែប្រសិនបើគេពិនិត្យរែក ញែកមើលចំពោះអត្ថន័យនឹងអត្ថរសនៃផ្ទៃរឿងជាតកនោះៗ នឹងឃើញថា មិន មន សុទ្ធតែសមប្រកបទៅតាមទំនងនេះគ្រប់ រឿងជាតកទេ ព្រោះរឿងជាតកខ្លះថ្លែង អំពីរឿងរ៉ាវប្រកបដោយក្តីស្នេហាកាមគុណ-តណ្ហា-រាគៈ-លំអនៃរូបឆោមនារី ដែល នាំឱ្យកើតសេចក្តីស្នេហាខាងផ្លូវកាមគុណ សេចក្តី ស្រើបស្រាលដោយកាមកិលេស មានកាមគុណជាទីមនោរម្យ ដែលសមជារឿងលោកិយនិយម ដូចរឿងប្រលោមលោកជាដើម ដែលផ្ទុយនឹងទ្រឹស្តីនៃពុទ្ធនិយម ។ ឧទាហរណ៍ ដូចរឿងកាកីរឿង នាងកង្រីនឹងរថសេន, រឿងព្រះសុធន នឹងនាងមនោហ៍រាជាដើម ។

រឿងខ្លះចេញមកពីឥទ្ធិពល ព្រាហ្មណ៍និយម ហោរានិយម ជាមួយនឹងពុទ្ធនិយម ខ្លះក៏មាន ។ ឧទាហរណ៍ ដូចរឿងព្រះបាទស៊ីសៅរ៍, រឿងវរវង្សសូរវង្ស ជាដើម ។

រឿងខ្លះចេញមកពីឥទ្ធិពល នៃលទ្ធិពុទ្ធនិយមក៏មាន។ ឧទាហរណ៍ ដូចរឿង វិបុលរាជជាតក.រឿងភោគកុលកុមរ,កនករណ្ណរាជជាតក,វិរិយបណ្ឌិតជាតកជាដើម ។

ខ.សកម្មភាពចិនរឿងបញ្ញាសជាតកខ្លះ

រឿងជាតកខ្លះ ថ្លែងអំពីសកម្មភាពនៃការសាងផ្នួសក្នុងព្រះពុទ្ធសាសនា ដូច រឿងសុបិនកុមារជាដើម ។

រឿងជាតកខ្លះ ថ្លែងអំពីសកម្មភាពខាងការធ្វើទាន ហើយបានទទួលលទ្ធផល ក្នុងបច្ចុប្បន្នជាតិក៏មាន ដូចរឿងកនករណ្ណរាជជាតកជាដើម ។

រឿងខ្លះ ថ្លែងអំពីសកម្មភាពនៃការតស៊ូចំពោះកម្មផលដោយផ្អែកទៅលើ ជំនឿបុព្វកម្មនឹងពៀរវេរាពីព្រេងនាយ ដូចរឿងក្រុងអសុភមិត្រជាដើម ។

រឿងខ្លះ ថ្លែងអំពីសកម្មភាពនៃការជួយសង្គ្រោះអ្នកដទៃ រហូតដល់ទៅសុខ ចិត្តលះបង់ជីវិតខ្លួន ដើម្បីជួយស្រោចស្រង់ជីវិតជនដទៃក៏មាន ដូចរឿងទុលកបណ្ឌិត ជាដើម ។ល ។

### ៤.៨.១.អក្សរសិល្ប៍ពុទ្ធិនិយមក្លាយហួសហេតុហួសហេតុ

អក្សរសិល្ប៍ពុទ្ធនិយមមួយបែប ដែលពុំមែនជាទសជាតក ឬបញ្ញាសជាតក ជាស្នាដៃអក្សរ សិល្ប៍ខ្មែរកើតនៅសម័យកណ្តាលដែលទទួលឥទ្ធិពលតិច ឬច្រើន ពីពុទ្ធសាសនាដែរ។ ដែលអ្នកនិពន្ធ ច្រើនលើកយកទស្សនៈកម្មផលមកផ្សំជាមួយ ជីវិតលោកិយសច្ចៈ គួបផ្សំភាព

អច្ឆរិយ ការហោះហើរដើរ លើអាកាស ប្រើមន្តអាគម នៃលទ្ធិព្រាហ្មណ៍។ កើតឡើងនៅសតវត្សរ៍ទី១៨ ឬ១៩ ដែលមានឈ្មោះអ្នកនិពន្ធច្បាស់លាស់។

ស្នាដៃអក្សរសិល្ប៍ពុទ្ធនិយមក្លាយហួសហេតុឬ ផ្លូម ដែលមានឈ្មោះអ្នកនិពន្ធ និងកាលបរិច្ឆេទមានដូចខាងក្រោមៈ

| ល.រ. ចំណងជើងរឿង | អ្នកនិពន្ធ | ឆ្នាំនិពន្ធ | ប្រភព |
|---|---|---|---|
| ១.រឿងហង្សយន្ត | ចៅឃមបុណ្យភក្តិ ឧក | ១៦៦៨ | នានាជាតក |
| ២. រឿងខ្យងសង្ខ | ឧកញ៉ាសុភាធិបតី អ៊ុក | ១៦៩៣ | នានាជាតក |
| ៣. រឿងជយទត្ត | បណ្ឌិត កោ | ១៧៥៥ | ហារយជាតិតិ |
| ៤.រឿងលោកនយបករណ៍ | ឧកញ៉ាព្រះឃ្លាំង និង | ១៧៩៤ | នានាជាតក |
| ៥. រឿងបុញ្ញសារសិរិសា | ឧកញ៉ាព្រះឃ្លាំង និង | ១៧៩៧ | បញ្ញាសជាតក |
| ៦. រឿងក្រុងសុភមិត | ឧកញ៉ាកោសាធិបតី កៅ | ១៧ ៩៨ | បញ្ញាសជាតក |
| ៧. រឿងភោគកុលកុមារ | ឧកញ៉ាព្រះឃ្លាំង និង | ១៨០៤ | នានាជាតក |
| ៨. រឿងវរនេត្រវរនុជ | ឧកញ៉ាព្រះឃ្លាំង នង | ១៨០៦ | បញ្ញាសជាតក |
| ៩. រឿងព្រះសមុទ្ទ | ឧកញ៉ាព្រះឃ្លាំង នង | ១៨០៨ | នានាជាតក) |
| ១០. រឿងចម្ប៉ាថោង | ព្រះអង្គដួង | ១៨១០ | ហារយជាតក |
| ១១. រឿងកាកី | ព្រះអង្គដួង | ១៨១៥ | ហារយជាតក |
| ១២. រឿងសមុទ្ទឃោសៈ | ឧកញ៉ាំបញ្ញាធិបតី កែវ | ១៨១៨ | បញ្ញាសជាតក |
| ១៣.រឿងព្រះចន្ទគោរពឬនាងមុច្ចលិន | បណ្ឌិត ស្អាត ឬសម្អាត | ១៨៣៣ | នានាជាតក |
| ១៤ .រឿងដាវរឿង | ព្រះអរិយកាមុនី ហ៊ីង | ១៨៥៦ | រឿងជាតក១ |
| ១៦. រឿងចៅពេជ្ជតាឬចៅពេច | ព្រះធម្មបញ្ញា ម៉ែន | ១៨៥៨ | នានាជាតក |
| ១៧. រឿងចន្ទឃាត | ព្រះស្រីអញ្ជិត | ១៨៥៨ | បញ្ញាសជាតក |
| ១៨. រឿងទេវន្ទ | ឧកញ៉ាំសន្ធរវោហារ ម៉ុក | ១៨៥៩ | បញ្ញាសជាតក |
| ១៩. រឿងរថសេនឬពុទ្ធសែន | ឧកញ៉ាំសន្ធរវោហារ ម៉ុក | ១៨៦១ | បញ្ញាសជាតក |

| | | | |
|---|---|---|---|
| ២០. រឿងសិង្ហនាទ | ឧកញ៉ាំសន្ធរវោហារ ម៉ុក | ១៨៦៣ | បញ្ញាសជាតក |
| ២១. រឿងវិមានច័ន្ទ | ឧកញ៉ាបញ្ញាធិបតី ឃឹម | ១៨៧៧ | បញ្ញាសជាតក |
| ២២. រឿងមរណមាតា | ព្រះធម្មបញ្ញា អ៊ុក | ១៨៧៧ | គម្ពីរចេតនាពុទ្ធ |
| ២៣. រឿងពោធិវង្ស | បវរកក្តី ព្រហ្ម | ១៨៨២ | នានាជាតក |
| ២៤. រឿងដង្កូវក្អក | ភិក្ខុ វង្ស | ១៨៨៣ | បញ្ញាសជាតក |
| ២៥. រឿងសុគន្ធថោង | បវរកក្តី ព្រហ | ១៨៨៣ | បញ្ញាសជាតក |
| ២៦. រឿងស័ង្ខសិល្ប៍ជ័យ | ឧកញ៉ាំវង្សាធិបតី អ៊ុក | ១៨៨៧ | គម្ពីរនិបាទឈ្មោះពាហុរី* |
| ២៧. រឿងចៅស្រទបចេក | កវី ស៊ិន | ១៨៨៩ | គម្ពីរទុកនិបា |
| ២៨. រឿងសព្វសិទ្ធិ | ម៉ឺនកក្តីអក្សរ  គន់ | ១៨៩៩ | បញ្ញាសជាតក |
| ២៩. រឿងរតនាវង្ស | កវី ប៉ាត | ព.ស.២៤៣០ | នានាជាតក |
| ៣០. រឿងសុនន្ទរាជឬអំបែក | ឧកញ៉ាំសុត្តន្តប្រីជា គន្ធ | ១៩០១ | បញ្ញាសជាតក |
| ៣១. រឿងចន្ទលីវង្ស | ភិក្ខុបណ្ឌិត ខៀវ | | បញ្ញាសជាតក |
| ៣២. រឿងព្រះលក្ខិណវង្ស | ឧកញ៉ាំប្រាថ្នាធិបតី អៀម | | នានាជាតក |
| ៣៣.រឿងភិនសុវណ្ណ | កវីចន្ទ | | បញ្ញាសជាតក |
| ៣៤. រឿងព្រះសូក៏ត | បណ្ឌិត កោរ | | បញ្ញាសជាតក |
| ៣៥. រឿងសុភោគ | ចៅពញាភក្តីសង្គ្រាមបាល | | បញ្ញាសជាតក |

ស្នាដៃអក្សរសិល្ប៍ពុទ្ធនិយមក្លាយហួសហេតុឬ ផ្លូម ដែលពុំមានឈ្មោះអ្នកនិពន្ធនិងកាលបរិ មានដូចជា៖

| ល.រ. ចំណងជើងរឿង | អ្នកនិពន្ធ | ឆ្នាំនិពន្ធ | ប្រភព |
|---|---|---|---|
| ១. រឿងពុទ្ធិសែន | | | បញ្ញាសជាតក |
| ២. រឿងព្រះសុធន | | | បញ្ញាសជាតក |
| ៣. រឿងទិព្វសង្វារ | | | |
| ៤. រឿងរាជកុល | | | |

៥. រឿងសុវណ្ណខ្យងស័ង្ខ

៦.រឿងវរវង្សសូរវង្ស បញ្ញាសជាតក

៧. រឿងព្រះសមនគោតម បញ្ញាសជាតកលាវ

៨. រឿងព្រះសរូប បញ្ញាសជាតក

៩. រឿងព្រះចក្រវង

១០. រឿងជាលីភិសេក រឿងជាតក៍

១១. រឿងសុបិនកុមារ

១២. រឿងទឹករាំផ្កាវាំ

១៣. រឿងភ្នួងមាំល័យ

១៤. រឿងសុវណ្ណវង្ស

១៥.រឿងសុវព្ណ បញ្ញាសជាតក

១៦. រឿងនាងបដាចារ រឿងជាតក៍

១៧. រឿងទុក្កម្មមានព ឬទុក្កម្មានិក បញ្ញាសជាតក

១៨. រឿងព្រះសិទ្ធផ្ទូឬសុធនុ បញ្ញាសជាតក

១៩. រឿងពុទ្ធិសែន បញ្ញាសជាតក

២០. រឿងចន្ទកុមារ បញ្ញាសជាតកលាវ

# អក្សរសិល្ប៍ពុទ្ធនិយមក្លាយហួសហេតុ

## សង្ខេបរឿង ហង្សយន្ត

អតីតកាលដ៏យូរលង់មានមហាក្សត្រមួយអង្គព្រះនាម អាទិត្យវង្សា សោយរាជ្យនៅនគរទេពបុរី បហាក្សត្រអង្គនោះជាស្តេចមានខ្លី ចេស្តា មាននគរចំណុះ១០១ និងមានស្រីស្នំ៦០០០នាក់ ទ្រង់មានបហេសីព្រះ នាបព្រះនាង ពិម្ពា។ តែជាអកុសលគឺទ្រង់ពុំមានព្រះរាជបុត្រមួយអង្គសោះ សម្រាប់ស្នងរាជ្យ ធ្វើឲ្យទ្រង់មានក្តីកង្វល់ជាពន់ពេក។ សម័យថ្ងៃមួយទ្រង់បានពិគ្រោះដោះស្រាយជាមួយនាម៉ឺនសព្វមុខមន្ត្រីអំពីបញ្ហានេះទើបលោកបន្ទ្រី មួយរូបលើកយោបល់ថា គួរមានពិធីបន់ស្រន់ថ្វាយទេព្តាសុំបុត្រា ដោយឲ្យព្រះ បហេសី និងស្រីស្នំទាំងអស់ចាំសីលភាវនា។

ស្នំទាំងអស់ ពិសេសព្រះនាងពិម្ពា បានប្រតិបត្តិការបួងសួងយ៉ាងយក ចិត្តទុកដាក់រហូតធ្វើឲ្យកក្រើកដល់ឋានទេ ពេលនោះព្រះឥន្ទ្រកោសីយក៏បានទៅអាជនាទេវបុត្រឲ្យមកចុះចាប់បដិសន្ធិក្នុងគភ៌ព្រះនាងពិម្ពាជាបុត្រារបស់ ព្រះអាទិត្យវង្សា លុះព្រះរាជបុត្រគ្រប់ទសមាស ទ្រង់ប្រសូតមកមានព្រះ កាយភ្លឺដូចមាស ទើបព្រាហ្មណ៍បុរោហិតទាំងឡាយដាក់ព្រះនាមថា សុវណ្ណកុមារ។

ព្រះសុវណ្ណកុមារទ្រង់ចម្រើនវ័យវឌ្ឍការក្រោមការបីបាច់ដ៏ល្អឥតខ្ចោះ។ នៅពេលព្រះសុវណ្ណកុមារពេញវ័យព្រះបាទអាទិត្យវង្សា ទ្រង់មានបំណងជ្រើស មហេសីថ្វាយបុត ក៏បង្គាប់ក្សត្រចំណុះទាំង១០១នគរ ឲ្យនាំបុត្រមកឲ្យព្រះ សុវណ្ណកុមារជ្រើសរើស។ ប៉ុន្តែពុំមានក្សត្រីអង្គណាជាទីពេញព្រះទ័យនៃព្រះ សុវណ្ណកុមារឡើយ មានតែទទួលក្តីអាម៉ាស់ដោយការតិះដៀលពីព្រះសុវណ្ណកុមារទៅវិញ ដែលធ្វើឲ្យព្រះបាទអាទិត្យវង្សាមានការពិរោធនឹងទ្រង់ជាខ្លាំង។ចំណេរកាលតមកមិនយូរប៉ុន្មាន ក្នុងរាជវាំងមានជាងទងពីរនាក់មាន ជំនាញរៀងៗខ្លួនក្នុងការសាងជាវត្ថុសិល្បៈផ្សេងៗមានទំនាស់គ្នារវាងចំណេះរៀងៗ ខ្លួនដែលនាំឲ្យឮដល់ព្រះមហាក្សត្រទ្រង់ក៏ចាត់ចែងឲ្យជាងទាំងពីរ ប្រឡងសាកល្បងគ្នា ដោយទ្រង់ប្រទានសម្ភារៈតាមតម្រូវការ។ ជាងម្នាក់បាន សាងសង់ជាពិមានដែលរំលេចដោយក្បូរក្បាច់រចនាល្អគ្មានពីរស្រោបដោយមាសនិងត្បូងទទឹមភ្លឺរន្ទាលឆ្អិនឆ្អៅហាក់បីដូចជាទិព្វពិមានរបស់សក្កទេវរាជ។ ចំណែកជាងមួយរូបទៀតសាងរូបបក្សីធ្វើអំពីមាសរំលេចដោយត្បូងចរណ ហើយបក្សីទាំងនោះអាចហោះហើរលើអាកាសាបានសព្វទិសបានតាមចិត្តប្រាថ្នា មានចលនាដូចជាសត្វពិត មានឫទ្ធិបីដូចជាសត្វទេព។ ព្រះមហាក្សត្រ ទ្រង់មានព្រះអំណរក ហើយទ្រង់បានឲ្យជាងទាំងពីរសហការណ៍គ្នាសាងជា រូបហង្សយន្តដែលអាចឲ្យមនុស្សជិះបានថ្វាយទ្រង់ ។ ឯជាងទាំងពីរក៏បានសាង ជាបក្សីយន្តតាមព្រះរាជបំណង។ ហង្សយន្តអំពីមាសដែលរំលេចទៅដោយក្បូរ ក្បាច់យ៉ាងវិចិត្រគ្មានពីរភ្លឺរន្ទាល អាចឲ្យមនុស្សអាស្រ័យហោះហើរទៅគ្រប់ទី ស្ថានបានតាមចិត្តប្រាថ្នា ។ ឯរាជបុត្រកាលឃើញយានទិព្វក៏ទូលសុំព្រះបិតា បំណងយកយានហង្សយន្តនេះទៅស្វែងរករៀនសិល្ប៍វិជ្ជាការ ចំណេះវិជ្ជាផ្សេងៗ និងរកទេពីជាទីពេញព្រះទ័យ ព្រះមាតាបិតាក៏ព្រះរាជទានតាមបំណង។

ក្រោយពីបានហង្សយន្ត ព្រះសុវណ្ណកុមារទ្រង់ធ្វើដំណើរយ៉ាងរីករាយ ទតធម្មជាតិ ! ហើយរៀបរាប់សរសើរជាហូរហែ។ លុះបន្ទាប់មកទៀត ទ្រង់ ក៏បានដល់បញ្ចាល៍នគរដែលជាទីព្រះបាទបណ្តាល៍គ្រប់គ្រង។ ទង់បានទៅសំណាក់ជាមួយព្រាហ្មណ៍មួយរូប ក្រោយមកក៏ក្លាយជាឪពុកធម៌របស់ទ្រង់។ ដោយទ្រង់ជាបុគ្គលមានភាពឧស្សាហ៍ព្យាយាមក្នុងកាសិក្សា ហើយមានប្រាជ្ញលើសពីមនុស្សទាំងពួងផង ទ្រង់ក៏បានរៀនចេះចាំស្ទាត់ជំនាញអំពីវិជ្ជាការទាំង ប៉ុន្មានឥតចន្លោះ ហើយត្រូវឪពុកធម៌របស់ទ្រង់នាំទៅថ្វាយព្រះបាទបញ្ចាល័ឯព្រះបាទបញ្ចាល៍ទៀតដើម្បីឲ្យព្រះសុវណ្ណកុមារកាន់តួនាទីជំនួសលោក។ សោតក៏សឹងពេញចិត្តតាំងពីសមត្ថភាព រូបសម្បត្តិ និងអត្តចរិតរបស់ព្រះ សុវណ្ណកុមារជាពន់ពេក តែទ្រង់ពុំជ្រាបថាសុវណ្ណកុមារជាអម្បូរក្សត្រ នាំឲ្យទ្រង់ស្តាយដែលពុំអាចឲ្យព្រះសុវណ្ណកុមារធ្វើជារាជសុណិសាបាន។

ថ្លែងពីព្រះបាទ បញ្ចាល័ ទ្រង់មានព្រះរាជបុត្រីមួយព្រះអង្គប្រកប ដោយរូបសម្ផស្សល្អលើសទេពធីតានាឋានសួគ៌ទៅទៀតមានព្រះនាមថាបទុមកេសរ ។ នៅពេលដែលព្រះសុវណ្ណកុមារចូលដល់រាជវាំងព្រះនាង មានការចាប់ព្រះទ័យយ៉ាងចម្លែកទាំងរូបសម្បត្តិ ទាំងចរិយាសម្បត្តិ ឫកពាដែលធ្វើឲ្យព្រះនាងយល់ថាព្រះសុវណ្ណកុមារប្រាកដជាចេញមកអំពីត្រកូល រជាក្សត្រណាមួយជាក់ជាមិនខាន ។

ដោយទំហំនៃសេចក្តីស្រឡាញ់ចេះតែកើនឡើងពីមួយថ្ងៃទៅមួយថ្ងៃ ធ្វើឱ្យព្រះនាងស្រពាប់ស្រពោននាងភីលៀង កាលបើឃើញម្ចាស់សី មានទុក្ខក៏ធ្វើជាអ្នកនាំពាក្យពីព្រះនាងបុទមកេសរទៅព្រះសុវណ្ណកុមារ ដោយ ប្រការផ្សេងៗ ព្រះសុវណ្ណកុមារក៏បានមកជួប ហើយលួងលោមផិតាក្នុង ផ្លូវកាមគុណ។ ព្រះនាងចេះតែរកហេតុផលមកពន្យល់ តែព្រះសុវណ្ណកុមារធ្វើជានឹងទើបព្រះនាងព្រម ។

ព្រះសុវណ្ណកុមារតែងតែមកជួបផិតាតាមហង្សយន្តជារៀងរាល់រាត្រី រហូតព្រះនាងមានគភ៌ជិតគ្រប់ខែទើបបានជ្រាបដល់ព្រះចៅបញ្ចាល៍ទ្រង់ ពិរោធយ៉ាងខ្លាំង ក៏ប្រើល្បិចចាប់ព្រះសុវណ្ណកុមារ ហើយឲ្យពេជ្ឈឃាដនាំខ្លួន ទៅសម្លាប់ ។

ព្រះសុវណ្ណកុមារទ្រង់មានវិប្បដិសារីជាពន់ពេក ម្យ៉ាងនឹកដល់មាតា បិតាឯនាយ . ម្យ៉ាងស្តាយភរិយា ឯព្រះនាងបុទមកសរក៏ទួញសោកបោកខ្លួន ស្តាយសុវណ្ណកុមារដែរ។ ឯមាតាព្រះនាងបទុមកេសរក៏ជួយអង្វរសុំការលើក លែងទោស តែព្រះបាទបញ្ចាល៍ពុំព្រមលើកលែងទោសឡើយ។

ថ្លែងពីពេជ្ឈឃាដ ពេលនាំសុវណ្ណកុមារទៅសម្លាប់ត្រូវសុវណ្ណកុមារ បោកបញ្ឆោត ហើយឡើងជិះហង្សយន្តទៅយកព្រះនាងបទុមកេសរ រួចហោះ ប្រទក្សិណបីជុំប្រាសាទព្រះបណ្តាលដោយសុវណ្ណកុមារដៀលផ្តាសា និង គំរាមដោយប្រការផ្សេងៗ ធ្វើឲ្យព្រះបាទបញ្ចាល័ភិតភ័យតក្កមា ឯសុវណ្ណកុមារ ក៏នាំព្រះនាងបទុមកេសរហោះទៅកាន់នគរទេពបុរីរបស់ទ្រង់ លុះធ្វើដំណើរបាន៧ថ្ងៃ នាងបច្ចុបកេសរក៏ឈឺពោះឆ្លងទន្លេ។ សុវណ្ណកុមារក៏ឈប់សំចតក្នុង ខេត្តខណ្ឌហេពាន្តក្រោមដើមជ្រៃក្នុងព្រៃក្រឹស្នាខាងឆ្នេរព្រះគង្គាគឺស្រះបោក្ខរណី។ ដោយឃើញបទុបកេសរ និងបុត្រាមានភាពរងារញ័រញាក់ សុវណ្ណកុមារ បានអាស្រ័យដោយហង្សយន្តទៅយកភ្លើងពីនាយសំពៅកណ្តាលបហាសាគរ តែជាកម្មរកុសល ព្រះអគ្គីបានឆាបឆេះខ្សែបញ្ជាហង្សយន្ត ធ្វើឲ្យព្រះសុវណ្ណ កុមារ និងហង្សយន្តធ្លាក់ទៅក្នុងទឹកហូរទៅកាន់កន្លែងទីទៃពីគ្នា។ ព្រះសុវណ្ណ កុមារត្រូវបាននាយ សមុទ្រគោចរ ជួយសង្គ្រោះ ហើយហង្សយន្តត្រូវ នាយពាណិជ្ជ ស្រង់បាន តែពុំបានដឹងពីគុណប្រយោជន៍ឡើយ ។

នាងបទុមកសរកាលចាំស្វាមីបាត់ពុំឃើញត្រឡប់មកវិញក៏ទួញ សោយសោក ហើយដើររកស្វាមីដោយទុកកូនស្រោបដើមក្រឹស្នានាព្រៃនោះ។

ថ្លែងពីព្រះចៅ ព្រហ្មទត្ត ស្តេចនៃនគរពារាណសី ក្នុងពេលទ្រង់ យាងក្រសាលក្នុងដងព្រៃនោះក៏ឃើញបុត្ររបស់បទុមកេសរ ទ្រង់ក៏បានរើស ទារកនោះយកមកចិញ្ចឹម ហើយដាក់ព្រះនាមថា ចៅក្រឹស្នាកុមារ។ ទ្រង់ ស្រឡាញ់បុត្រក្រៃពេក ព្រោះទារកនោះមានរូបសម្បត្តិល្អល្អះសម្បុរដូចមាស ម្យ៉ាងទ្រង់ពុំមានបុត្រផង។ លុះនាងបទុមកេសរមកវិញរកកូនមិនឃើញសន្លប់បាត់ស្មារតី។ ពេលដែលនាងភ្ញាក់រលឹកឡើងក៏ដើរតាមស្នាមដានជើង រហូតមកដល់នគរពារាណសី ហើយស្នាក់នៅជាមួយ យាយមាលា ជាអ្នក ក្រងផ្កាថ្វាយស្តេច ដើម្បីរង់ចាំឱកាសជួបជាមួយនឹងចៅក្រឹស្នាកុមារ។

ក្នុងពេលនៅជាមួយយាយមាលា នាងក្រងផ្កាថ្វាយស្តេចជំនួសយាយមាលាយ៉ាងប៉ិនប្រសប់ជាហេតុនាំឲ្យស្តេចចង់ជួបនាងតែត្រូវយាយមាលាកុហកថានាងជាស្ត្រីមេម៉ាយ ហើយមានរូបអាក្រក់ក្រៃ ព្រោះពុំមែនជាឱភាស ល្អ។ នាងនៅជាមួយយាយមាលាអស់រយៈពេល១៦ឆ្នាំ ពេលនោះចៅក្រឹស្ន កុមារក៏ចម្រើនវ័យគ្រប់ការ ទើបព្រះបាទព្រហ្មទត្តទ្រង់ត្រាស់ឱ្យស្តេចនៃនគរ ចំណុះទាំង១០១ នាំបុត្រីដែលពេញវ័យគ្រប់ការមកថ្វាយ តែពុំមានសូម្បីមួយ អង្គដែលធ្វើឱ្យចៅក្រឹស្នាកុមារពេញចិត្តសោះឡើយ ទើបព្រះបាទព្រហ្មទត្តបញ្ជ ឲ្យរាជអាមាត្យដើររើសរកសិល្អក្នុងនគរមកថ្វាយ ។ ឯរាជអាមាត្យក្រាបថ្វាយ ទូលមហាក្សត្រថាក្នុងនគរពារាណសីនេះពុំមាននារីឯណាដែលមានសម្រស់ ស្រស់ស្អាតស្មើនឹងនាងបទុមកេសរជាចៅយាយមាលាសោះឡើយតែទ្រង់ពុំជឿ លុះអាមាត្យនាំនាងមក ទើបទ្រង់ជឿ។ ចៅក្រឹស្នាកុមារក៏សឹងពេញចិត្តគ្មានប្រកែកហើយព្រះបាទព្រហ្មទត្តទ្រង់ត្មះដៀលជេរយាយមាណជាច្រើនដែលហ៊ានភូតកុហកទ្រង់។ ក្រោយពីបានរៀបចំរាជអភិសេកចៅក្រឹស្នាកុមារ និងនាងបុទមកេសរព្រះបាទព្រហ្មទត្តក៏បានប្រគល់រាជសម្បត្តិថ្វាយចៅក្រឹស្នាកុមារផងឲ្យគ្រប់គ្រងនគរពារាណសី។

ក្នុងវេលារាត្រីផ្សំដំណេកខណៈដែលចៅក្រឹស្នាកុមារសំដៅទៅប្រាសាទ នាងបទុមកេសរក៏ស្រាប់តែមានទេវតាមកនិម្មិតទេពហេតុបីប្រការជាប្រស្នា ដល់ចៅក្រឹស្នាកុមារជាហេតុនាំឲ្យទ្រង់និងនាងបទុមកេសរបានស្គាល់គ្នាជាម្តាយនឹងកូន។ ក្រោយមកនាងបទុមកេសរ និង

ចៅក្រឹស្នាកុមារបានសាងសង់ជា សាលាឆទាន ដោយមានឆ្លាក់ជាសាច់រឿងនៃឆាកជីវិតរបស់នាង និងស្វាមីក្នុង គោលបំណងឲ្យសុវណ្ណកុមារបានឃើញ ហើយឲ្យយាយមាលាជាអ្នកគ្រប់គ្រងសាលានោះ។

ថ្លែងពីនាយសាគរពាណិជ្ជ ដែលរើសបានហង្សយន្តបានយកទៅ ថ្វាយស្ដេចព្រហ្មទត្ត ហើយទ្រង់បានឲ្យចៅក្រឹស្នាកុមារជាអ្នកថែរក្សា។ ឯនាយ សមុទ្រគោចរក៏បានចូលសំពៅមកដល់នគរពារាណសីដើម្បីសួរទំនិញ ដែល នាំឲ្យសុវណ្ណកុមារបានឃើញផ្ទួររឿងរ៉ាវដែលឆ្លាក់ជាប់សាលាឆទានហើយត្រូវយាយមាលានាំទៅជួបនាងបទុមកេសរ និងចៅក្រឹស្នកុមារ។ ដោយក្ដីនឹករលឹក គ្នាក្សត្រទាំងបីអង្គបានសោយសោករហូតដល់សន្លប់ទាំងបីអង្គ តែត្រូវព្រះតន្ត្រធិរាជប្រោសឲ្យរស់វិញទាំងអស់ឯព្រះបាទព្រហ្មទត្តទ្រង់បានឲ្យអាមាត្យមកសាកសួរ តែចៅក្រឹស្នាកុមារទូលថាជាបងរបស់នាងបទុមកេសរ។

ចៅក្រឹស្នាកុមារបានយកហង្សយន្តមកថ្វាយសុវណ្ណកុមារជួសជុលនាងបទុមរៀបចំស្បៀងអាហារក្នុងពេលធ្វើដំណើរ ហើយនាងបានឲ្យរង្វាន់ ដល់នាយសំពៅទាំងពីរ និងយាយមាលាជាច្រើន។ ចំណែកចៅក្រឹស្នាកុមារបាន សរសេរសំបុត្របិទជាប់ទ្វារប្រាសាទថ្វាយព្រះបាទព្រហ្មទត្ត ហើយទាំងបីអង្គ អាស្រ័ដោយហង្សយន្តហោះសំដៅទិសឧត្តរទៅទេពបុរីអស់មួយរយៈពេល។ ព្រះបាទព្រហ្មទត្តទ្រង់ទួញអាល័យបុត្រក្រៃពេក ។

ដល់ទេពបុរី ក្សត្រទាំង៥អង្គបានព្រះកន្សែងលុះសន្ទប់ស្មារតីទាំងអស់គ្នា ក្រោយធ្វើពិធីជញ្ជាត់ព្រលឹង ព្រះអាទិត្យវង្សាបានផ្ទេររាជបល្ល័ង្កថ្វាយ សុវណ្ណកុមារ និងចៅក្រឹស្នាកុមារជាឧបរាជ បានសេចក្ដីសុខសាន្តលុះមរណា រៀងៗខ្លួនក៏យោនយកកំណើតតាមផលកម្មគឺព្រះអាទិត្យវង្សាជាព្រះបាទសុទ្ធោទន៏ នាងពិម្ពាជាមហាមាយា ព្រហ្មទត្តជាអានន្ទ ព្រះឥន្ទជាអនុរុទ្ធ នាងបទុមជាយសោធារា ចៅក្រឹស្នាកុមារជារាហុលកុមារ ព្រះបាទបញ្ចាល៍ជា ទេវទត្តអញ្ជតិត្ថិយ ឯសុវណ្ណកុមារជាព្រះសាមណគោតមនេះឯង ។

## ក.អត្ថន័យខ្លឹមសារ

អត្ថន័យអត្ថ .ប្រយោជន៍.អត្ថន័យ .ការណែនាំអត្ថាធិប្បាយសេចក្ដីពន្យល់.អត្ថន័យជាគំនិតសំខាន់ៗរបស់អ្នកនិពន្ធដែលលាតត្រដាងនៅក្នុងដំណើររឿង ហើយគេអាចហៅវាថាជាជម្រៅនៃរឿង។

ក្នុងផ្នែកអត្ថន័យមាន ប្រធានរឿង មូលបញ្ហារឿងនិងឧត្តមគតិរឿង។

## ខ.ប្រធានរឿង មូលន័យ

ប្រធានរឿងឬមូលន័យ គឺជាគំនិតសំខាន់ៗរបស់រឿង។ប្រតិឬជាបញ្ហារួមរបស់រឿង។តែអ្នកនិពន្ធចង់បង្ហាញដល់អ្នកអានប្រធានរឿងជាបញ្ហារួបផ្តុំបំផុតដែលអ្នកនិពន្ធលើកយកមកសរសេរឬជ្រើសរើសជាប្រធានបទហើយដែលមានមូលបញ្ហារឿងឋិតនៅក្នុងនោះ។

ប្រធានរឿងបង្ហាញនៅចំហររបស់អ្នកនិពន្ធវាជាមូលដ្ឋានដើមរបស់អ្នកនិពន្ធក្នុងការចាប់ផ្ដើមសរសេរឡើង។មុនពេលចាប់ផ្ដើមសរសេរឡើង។អ្នកនិពន្ធគ្រប់រូបត្រូវកំណត់ថាតើគាត់ត្រូវសរសេរអំពីអ្វី។អំពីជីវិតសង្គមសង្គ្រាមស្នេហារឿងជំនឿទនៀមទម្លាប់ប្រពៃណីចម្លើយរបស់សំណួរនេះហើយជាប្រធានរឿង។ តាមរយៈរឿង ហង្សយន្ត និយាយរៀបរាប់ពីដំណើរជីវិតរបស់សុវណ្ណកុមារ ផ្សាភ្ជាប់និងហង្សយន្ត។

## គ.មូលបញ្ហារឿង

មូលបញ្ហារឿងគឺជាភាពចំណែកនៃប្រធានរឿងជាទិដ្ឋភាពផ្សេងៗ របស់យើង។វាជាការចូលជ្រៅទៅក្នុងប្រធានរឿង។

ជុំវិញប្រធានរឿងនេះ យើងបានកំណត់បញ្ហាជាច្រើន ដែលនៅជុំវិញការកសាងសីលបារមីរបស់ព្រះពោធិសត្វ បញ្ហាទាំងនោះរួមមាន៖

### ទី១ បញ្ហាមានហង្សយន្ត

នៅពេលដែលព្រះបាទអាទិត្យវង្សាបាន ឮជាងទងទាំងពីរឈ្លោះប្រកែគ្នាព្រះអង្គបានឱ្យពួកគេប្រគួតគ្នា ឯជាងទងមួយកសាងប្រាសាទដ៏ល្អឥតខ្ចោះ និង ជាងមួយទៀតធ្វើជារូបបក្សីធ្វើអំពីមាសក្បួង ហើយបក្សីនោះអាចហោះហើរលើអាកាសបាន មានចលនាដូចសត្វពិតមានរិទ្ធីដូចជាសត្វទេព ក្រោយមកព្រះមហាក្សត្របានបង្គាប់អោយជាងទងទាំងពីរធ្វើជាបក្សីហង្សយន្តជាងទាំងពីរបានធ្វើតាមព្រះរាជបំណង ហើយហង្សយន្តរំលេចដោយក្បូរក្បាចរចនាយ៉ាងវិចិត អាចហោះហើរតាមចិត្តប្រាថ្នា ។ ឯព្រះសុវណ្ណកុមារបានឃើញហើយយានទេពចង់បាន ទូលសុំព្រះបិតាជិះហោះហើរទៅរករៀនសិល្បិវិជ្ជាការចំណេះវិជ្ជាផ្សេងៗនិងតាមរករាជទេពី ហើយព្រះបិតាបំពេញតាមបំណង ។ ក្រោយពីបានហង្សយន្តប្រះរាជកុមារសប្បាយចិត្តរីករាយទតជម្ងជាតិ ។ ក្រោយមកបានដល់នគរបញ្ចាលហើយទៅសំណាក់នៅជាមួយព្រាហ្មណ៍ហើយបានរៀនចេះវិជ្ជាការយ៉ាងឈាប់រហ័ស ។ បន្ទាប់មកនាំសុវណ្ណកុមារទៅឱ្យព្រះបាទនគរបញ្ចាលធ្វើតួនាទីជំនួសលោក។ ព្រះបាទបញ្ចាលពេញចិត្តនិងរូបសម្បត្តិ ព្រះកុមារ ប៉ុន្តែសុវណ្ណកុមារមិនមេនជាអំបូរស្តេចនាំឱ្យព្រះអង្គស្តាយ។ ព្រះបាទនគរបញ្ចាលមានព្រះរាជបុត្រីព្រះនាមបុតមកេសរ ។ ព្រះមានងបានឃើញសុវណ្ណកុមារមានចិត្តស្រឡាញ់សុវណ្ណកុមារ ភីលៀងបាននាំដំណឹងនេះទៅប្រាប់សុវណ្ណកុមារ ហើយបានមកជុបព្រះនាងលោងលោមព្រះនាងក្នុងផ្លូវកាមកុណ ព្រះនាងក៏ព្រម។ ដុវណ្ណកុមារមករកនាងរាល់រាត្រី រហូតដល់ព្រះនាងមានគក៏។ ពេលមានគក៏ជិតគ្រប់ខែទើបព្រះបាទនគបញ្ចាលដឹងរឿងនេះ ទ្រង់ពិរោធយ៉ាងខ្លាំងក៏ឱ្យពេជ្ឈឃាតនាំទៅសម្លាប់ ។ សុវណ្ណកុមារមានវិប្បដិសារីយ៉ាងខ្លាំងនឹកស្តាយមាតា និងស្តាយភរិយា ។ ចំណែកព្រះនាងបុទកេសរទ្ទូញយំសោក និងទៅឱ្យព្រះមាតាសុំការលើកលែងទោសតែព្រះបាទបញ្ចាលមិនយល់ព្រម។ ព្រះសុវណ្ណកុមារ បានប្រើឧបាយកលបញ្ឆោតពេជ្ឈហើយបានឡើងជិះហង្សយន្តទៅយកព្រះនាងបុទមកេសរ។ រួចជិះក្រឡឹងព្រះរាជវាំងបីជុំ និងជេរព្រះបាទនគរចញ្ចោលជាច្រើន។នៅពេលព្រះនាងប្រសូត្របុត្រព្រះសុវណ្ណកុមារបានជិះហង្សយន្តទៅសុំភ្លើងពីនាយសំពៅដល់ពាក់កណ្តាលផ្លូវភ្លើងឆេះខ្សែរក៏ធ្លាក់ហង្សយន្តធ្លាកកណ្តាលសបុទ្រទៅ។

សរុបមក យើងមុននិងធ្វើនូវរឿងអ្វីមួយ ត្រូវគិតឱ្យបានវែងឆ្ងាយទើមពុំមានកំហុសស្តាយក្រោយ ត្រូវគោរពតាមប្រពៃណី និងស្តាប់តាមអ្នកមានគុណ។

### ទី២ បញ្ហារៀបការ

នៅពេលដែលចៅក្រឹស្នារើសមហេសីពុំពេញចិត្តបុត្រីស្តេចអង្គណាមួយឡើយ ។ ក្រោយមកក្រោយមកព្រះបាទព្រហ្មទតបានឱ្យចៅយាយមាលាមក ដែលជាព្រះនាង បុទមកេសរជាមាតាចៅក្រឹស្នា។រចៅក្រឹស្នាបានពេញចិត្ត ជាមួយនិង ព្រះនាងបុទមកេសរ ។ បន្ទាប់មកទៀតព្រះបាទព្រហ្មបានរៀបអភិសេកឱ្យអ្នកទាំងពីរ។ នៅពេលយប់ផ្សំដំណេកចៅក្រឹស្នាសំដៅទៅប្រាសាទនាងបុទមកេសរ ទើបមានទេវតាមកហេតុនិម្មិតទេពហេតុបិប្រការជាប្រស្នាដល់ចៅក្រឹស្នាកុមារ ដែលជាហេតុនាំឱ្យទ្រង់និងនាងកេសរបានស្គាលគ្នាជាម្តាយនិងកូន។ ព្រះនាងបុទមកេសរបានឱ្យ ចៅក្រឹស្នាកសាងសាលាឆទាន និងបានគូរគំនូររៀបរាប់ពីប្រវត្តិប្រះនាងបានបែកពីសុវណ្ណកុមារ ។ ក្រោយមកនាយសាគរពាណិជ្ជបានរើសបានហង្សយន្ត បានយកទៅថ្វាយព្រះបាទព្រហ្មទត ទ្រង់ឱ្យចៅក្រឹស្នាកុមារជាអ្នកថែរក្សា ។ ឯនាយសបុទ្រគោចរបានមកចូលសំពៅមកដល់នគរពាណរាសីដើម្បីជួញដូរទំនិញ ព្រះសុវណ្ណកុមារបានឃើញរូបគំនូរធ្លាក់ជាប់សាលាឆទាន បានត្រូវយាយមាលានាំទៅជួបព្រះនាងបទុមកេសរ និងចៅក្រឹស្នាកុមារ។

សរុបមក ការតស៊ូព្យាយាមនាំឱ្យយើងទទួលបានជោកជ័យគ្រប់យ៉ាង និងធ្វើឱ្យជីវិតប្រកបដោយសុជមង្គល។

## ឃ.ឧត្តមគតិរឿងគំនិតដឹកនាំរឿងតម្លៃអប់រំ

ឧត្តមគតិរឿងគឺជាឧត្តមគតិរបស់អ្នកនិពន្ធ។ ឧត្តមគតិរឿងគឺយកកត្តាប្រធានវិស័យដែលបញ្ហាដែលបញ្ជាក់ពីគោលជំហរសតិអារម្មណ៍របស់អ្នកនិពន្ធដែលស្តែងឡើងតាមរយៈសកម្មភាពរបស់តួអង្គ។

- អប់រំឱ្យយើងឱ្យចេះមានគំនិតវិទ្យាសាស្ត្រច្នៃប្រឌិតក្នុងការធ្វើអ្វីមួយ ដូចជាងដែលចេះធ្វើហង្សយន្តចេះច្នៃវត្ថុធ្វើជាហង្សយន្តអាចហោះហើរលើអាកាសបាន វាមានប្រយោជន៍ធ្វើឱ្យមនុស្សចេះចង្កើតរបស់ថ្មីៗជាច្រើនដូចយើងឃើញស្រាប់សព្វថ្ងៃមានយន្តហោះជាដើម

- អប់រំឱ្យយើងចេះស្តាប់ដំបូងន្មានអ្នកមានគុណ ឪពុក ម្តាយបើយើមិនស្តាប់ពួកគាត់ លទ្ធិផលទទួលបានដូចសុវណ្ណកុមារចឹង ដោយសារមិនធ្វើតាមព្រះបិតាក្នុងការជ្រើសរើសគូរស្រករ ធ្វើឱ្យជួបបញ្ហាជាច្រើនចេញពីនគរ

- អប់រំឱ្យយើងខិតខំប្រឹងប្រែងរៀនសូត្រដូច សុវណ្ណកុមារបានរៀនសិល្បសាស្ត្រចប់

- អប់រំឱ្យមាតា បិតា គ្រប់រូបចេះរៀបចំអនាគតឱ្យកូនចៅ

- អប់រំឱ្យយើងគោរពទនៀបទម្លាប់ប្រពៃណី កុំដូចនាង បទុមកេសរ បានប្រព្រឹត្តិខុសនិងប្រណីណីទុំមុនស្រគាល នាំឱ្យខ្លួនជួបនិងវិបត្តិជាច្រើនរហូតចាកចេញពីនគររបស់ខ្លួន។

សរុបជារួមមករឿងហង្សយន្តបានអប់រំ ដល់មនុស្សទូទៅឱ្យចេះមានគំនិតវិទ្យាច្នៃប្រឌិតក្នុងការក្នុងការកសាងរបស់អ្វីមួយ ដើម្បីជួយឱ្យប្រទេសជាតិមួយមានការរីកចម្រើនជឿនលឿន ឱ្យយើងចេះគោរពប្រពៃណី និងចេះស្តាប់បង្គាប់អ្នកមានគុណផងដែរ។

# សង្ខេបរឿង ខ្យងស័ង្ខ

នាសម័យព្រះសម្មាសម្ពុទ្ធទ្រង់យោនយកកំណើតជាពោធិសត្វ មានស្តេចមួយអង្គព្រះនាមវិមលរាជ សោយរាជ្យនៅសោឡសមហានគរ មានមហេសីពីរអង្គ។ មហេសីទីមួយព្រះនាមចន្ទទេវី មហេសីទីពីរព្រះនាមឆន្ទា។ ព្រះបាទវិមលរាជទ្រង់សព្វព្រះរាជហឫទ័យព្រះមហេសីទាំងពីរក្រៃលែង។ ថ្ងៃមួយដោយទ្រង់ឈ្វេងយល់ថា ព្រះអង្គនៅពុំទាន់មានបុត្រសម្រាប់ស្នងរាជ្យនៅឡើយ ព្រះបាទយសវិមលរាជទ្រង់ក៏បញ្ញាគេឲ្យទៅយាងមហេសីទាំងពីររបស់ព្រះអង្គថា បើចំណោមមហេសីទាំងពីរអាចមានបុត្រានោះព្រះអង្គនឹងតែងតាំងជាព្រះអគ្គមហេសី។ ក្រោយពីនេះមក មហេសីទាំងពីររបស់ព្រះអង្គក៏យាងទៅរៀបចំពិធីសុំបុត្រ។ ព្រះនាងចន្ទទេវី ក៏បានតាំងពិធីបួងសួងសុំបុត្រដោយការរក្សាសិលភាវនាយ៉ាងខ្ជាប់ខ្ជួន ដែលនៅពេលនោះមានអំណាចនៃផល្លានិសង្សរបស់ព្រះនាង បានធ្វើឲ្យក្តៅក្រហាយទៅដល់ឋានព្រះឥន្ទ្រៗ ក៏សុំយាងព្រះពោធិសត្វយោនយកកំណើតក្នុងផ្ទៃព្រះនាងច័ន្ទទេវី។ ចំណែកឯព្រះនាងឆន្ទាទ្រង់មិនបានតាំងសីលដូចព្រះនាងចន្ទទេវីទេ គឺនាងទៅធ្វើការបូជាដើមព្រះជ្រៃដើម្បីអធិដ្ឋានប្រាថ្នាសុំបុត្រ នៅពេលនោះដែរទេពធីតារក្សាដើមជ្រៃបានមកចាប់បដិសន្ធិនៅក្នុងផ្ទៃព្រះនាងឆន្ទា។ ក្រោយពេលពិធីសុំបុត្រចប់ ព្រះមហេសីទាំងពីរតែងតែនាំគ្នាចូលគាល់ព្រះមហាក្សត្រជាប្រក្រតី។ ថ្ងៃមួយព្រះបាទយសវិមលរាជ្យទ្រង់យល់ថា ទឹកមុខរបស់មហេសីទាំងពីររបស់ព្រះអង្គមានទឹកមុខខុសប្លែកពីសព្វមួយដង ព្រះអង្គក៏ទ្រង់សួរទៅមហេសីចន្ទទេវីអំពីការរៀបចំពិធីសុំបុត្រ។ នៅពេលនោះព្រះនាងចន្ទទេវីបានមានព្រះបន្ទូលថា ព្រះនាងយល់សុបិន្តឃើញរាហ៊ូពាំព្រះចន្ទ្រមកថ្វាយដល់ព្រះនាង ព្រះនាងក៏បានទទួលយកព្រះចន្ទ្រដោយក្តីត្រេកអរមហិមាតែរំពេចនោះព្រះចន្ទ្រដែលមានពន្លឺភ្លឺត្រចះត្រចង់ប្រែក្លាយទៅជាពណ៌ខ្មៅងងឹតសូន្យសុង ពេលនោះព្រះចន្ទ្រក៏បានព្រាត់ចេញពីដៃរបស់ព្រះនាង។ ព្រះនាងក៏ដួលសន្លប់ដល់ក្ស័យជន្មា។ ក្រោយមករាហ៊ូក៏បាននាំយកព្រះចន្ទ្រយកមកឲ្យនាងវិញ ហើយព្រះនាងក៏មានព្រះជន្មឡើងវិញ។ ដោយក្តីអាណិតចំពោះមហេសី ព្រះបាទយសវិមលរាជក៏បានបញ្ញាឲ្យហោរាទស្សន៍ទាយអំពីការយល់សប្តិរបស់ព្រះនាង។ ហោរាបាននិយាយថា ព្រះនាងចន្ទទេវីគឺមានរាជបុត្រាដែលជាទេវតាបានមកចាប់បដិសន្ធិក្នុងផ្ទៃព្រះនាង ហើយនៅពេលអនាគតព្រះរាជបុត្រអង្គនេះនឹងឡើងសោយរាជ្យជំនួសព្រះអង្គ។ ក្រោយពីលឺទំនាយបែបនេះ ជាហេតុបណ្តាលឲ្យព្រះនាងឆន្ទាផ្ទំពុំលក់ពេញមួយរាត្រី ព្រោះព្រះនាងគិតថាកូនខ្លួនអាចជាកូនស្រី ក្រែងគ្មានបានរាសនាអាចស្នងរាជ្យដូចបុត្រព្រះនាងចន្ទទេវី។ ដោយគិតសព្វគ្រប់ទៅព្រះនាងក៏បានឲ្យគេចេញទៅរកគ្រូស្នេហ៍ម្នាក់ឈ្មោះយាយស្មេជា ព្រះនាងឆន្ទាក៏បានឲ្យយាយស្មេជាធ្វើស្នេហ៍ដាក់ព្រះបាទយសវិមលរាជ ក្រោយពីត្រូវស្នេហ៍របស់ព្រះនាងឆន្ទា ព្រះអង្គក៏បានបណ្តេញព្រះនាងចន្ទទេវីតាមរយៈការញុះញង់របស់ព្រះនាងឆន្ទាទោះបីជាព្រះអង្គដឹងថាព្រះនាងចន្ទទេវីមានផ្ទៃពោះក៏ដោយ។ ក្រោយពីព្រះស្វាមីបានបណ្តេញចេញពីព្រះនគរ ព្រះនាងក៏ធ្វើដំណើរដោយគ្មានមាសប្រាក់សូម្បីតែបន្តិច ព្រោះទ្រព្យសម្បត្តិទាំងប៉ុន្មានដែលនៅលើខ្លួនរបស់ព្រះនាង ត្រូវនាងឆន្ទារឹបអូសគ្មានសល់។ នៅពេលដែលព្រះនាងកំពុងតែធ្វើដំណើរទៅដល់ព្រៃជ្រៅ ព្រះនាងបានជួបនឹងដូនចាស់ម្នាក់ ព្រះនាងក៏បានសុំដូនចាស់នោះស្នាក់នៅជាមួយ ហើយព្រះនាងតែងតែប្រកបរបរកាប់ឧសលក់។ ដោយយល់ឃើញថា រៀងរាល់ថ្ងៃព្រះមាតាតែងតែប្រកបការងារដោយលំបាក ព្រះអង្គក៏តាំងអធិដ្ឋានថា ប្រសិនបើព្រះអង្គជាតួអង្គពោធិសត្វ សូមឲ្យនៅពេលដែលព្រះអង្គប្រសូតមកឲ្យមានខ្យងស្រោបមកជាមួយ។ លុះដល់ខែកំណត់នៃការប្រសូតព្រះនាងទ្រង់ប្រសូតនូវព្រះរាជបុត្រមួយព្រះអង្គដែលរុំស្រោបដោយសម្បកខ្យង ដែលមានពន្លឺភ្លឺរលោង ព្រះនាងបានយកខ្យងនោះមកឱបថើប។ ដំណើរជីវិតរបស់ព្រះនាង និងបុត្របានប្រព្រឹត្តទៅរយៈពេលបីឆ្នាំ។ ថ្ងៃមួយព្រះនាងបានទៅកាប់អូសនៅក្នុងព្រៃដូចសព្វដង តែថ្ងៃនោះព្រះនាងបានទុកដាក់អង្ករប្រហែស។ ខ្យងស័ង្ខដោយឃើញពីទុក្ខវេទនារបស់មាតាចំពោះការខិតខំរកស៊ីទ្រង់ក៏ចេញពីស្រោមចុះមកដេញមាន់នឹងរៀបចំផ្ទះ។ ចំណែកឯព្រះនាងចន្ទទេវី ក្រោយពេលទៅដល់ព្រៃកាប់ឧសមួយសន្ទុះព្រះនាងក៏នឹកឃើញថាថ្ងៃនេះពេលចេញមកព្រះនាងមិនបានទុកដាក់របស់របរបានល្អ។ ព្រះនាងទ្រង់យាងត្រឡប់មកកាន់ខ្ទមរបស់ខ្លួន។ ព្រះនាងទ្រង់មើលពីចម្ងាយឃើញហាក់បីដូចជាមានមនុស្សនៅក្នុងខ្ទម។ ពេលមកដល់ទ្រង់មិនឃើញ ព្រះនាងក៏សញ្ជឹងគិតថានៅក្នុងខ្ទមនេះមានតែទ្រង់និងបុត្រ វាមិនអាចមានមនុស្សណាផ្សេងឡើយ។ នៅថ្ងៃស្អែកឡើងព្រះនាងក៏យាងធ្វើជាទៅកាប់ឧសដូចរាល់សព្វមួយដង ប៉ុន្តែព្រះនាងធ្វើជាភ្លេចគ្របទុកដាក់អង្ករឲ្យបានជិត។ ខ្យងស័ង្ខដោយគិតថាមាតាភ្លេច ហើយដោយក្តីអាណិត ក៏បានចេញពីស្រោមមករៀបចំដូចលើកមុន។ ព្រះនាងចន្ទទេវីដែលពួននៅក្រោយខ្ទមក៏ស្ទុះចេញមកឱបក្រសោបបុត្រលួងលោមគ្រប់បែបយ៉ាងមិនឲ្យខ្យង

ស័ង្ខចូលក្នុងស្រោមវិញ។ ព្រះនាងចន្ទទេវីបានយកសំបកខ្យងទៅវាយបំបែក ព្រោះព្រះនាងភ័យខ្លាចខ្យងស័ង្ខចូលក្នុងស្រោមវិញ។ ចាប់តាំងពីថ្ងៃនោះមកប្រជាជនតែងនាំរបស់របរមកជូនព្រះនាងមិនដែលខាន។ ដំណឹងនេះបានលឺទៅដល់ព្រះនាងឆន្ទាដែលមានបុត្រី ដោយសេចក្តីភ័យខ្លាចការវិលត្រឡប់របស់ខ្យងស័ង្ខ និងចន្ទទេវីមកសោយរាជ្យសម្បត្តិ ព្រះនាងឆន្ទាបានប្រើឧបាយកលដោយប្រាប់ព្រះបាទយសវិមលរាជថាព្រះនាងចន្ទទេវី ជាស្ត្រីដែលភិតក្បត់មានសាហាយ ហើយបង្កើតបានកូនប្រុសម្នាក់ ដែលកូនប្រុសនេះជាសាហាយរបស់ព្រះនាងចន្ទទេវី។

ក្រោយពីលឺដំណឹងនេះព្រះបាទយសវិមលរាជទ្រង់ បានបញ្ជាឲ្យគេទៅចាប់ខ្យងស័ង្ខយកមកសម្លាប់។ ពេជ្ឃឃាដចាប់ខ្យងស័ង្ខបាន គេចងដៃចងជើងខ្យងស័ង្ខដូចជាអ្នកទោស។ បន្ទាប់មកពេជ្ឃឃាដយកដាវមកកាប់ករបស់ខ្យងស័ង្ខ ប៉ុន្តែដោយអំណាចអានិសង្ស អាវុធនោះបានប្រែក្លាយទៅជាពុកផុយ បាក់ខ្ទេចខ្ទីអស់។ ពេជ្ឃឃាដក៏យកលំពែងមកចាក់រាជកុមារ លំពែងនោះទៀតសោតក៏ក្លាយជាផ្កាទៅវិញ។ ព្រះវិមលរាជ ក៏ប្រើពេជ្ឃឃាដយករាជកុមារចងដៃចងជើងបោះទំលាក់ចូលទឹក។ ព្រះនាងចន្ទទេវីឃើញបុត្របណ្តូលចិត្តរបស់ទ្រង់ត្រូវបិតាប្រើពេជ្ឃឃាដសម្លាប់ដូចនោះ ទ្រង់ទួញយំឥតស្រាកស្រាន្ត។ គួរឲ្យអនិច្ចាណាស់ ព្រះពោធិសត្វកាលត្រូវពេជ្ឃឃាដចងទម្លាក់ចូលទឹកមិនស្លាប់ទៀត ព្រះវិមលរាជក៏ប្រើពេជ្ឃឃាដចងរាជកុមារ នឹងដុំថ្មធំៗទម្លាក់ចូលទឹកជម្រៅ ២០០០ព្យាមទៀត។ ពេលរាជកុមារធ្លាក់ចូលទឹក ធ្វើឲ្យក្តៅក្រហាយដល់ឋានបាតាល ស្តេចនាគក៏និម្មិតផ្កាឈូកក៏ធំទ្រទទួលព្រះរាជកុមារខ្យងស័ង្ខ រួចនាំយកទៅឋានបាតាលធ្វើជាបុត្រធម៌ ហើយស្តេចនាគទ្រង់សព្វព្រះទ័យខ្លាំងណាស់។ តែខ្យងស័ង្ខមិនអាចគង់នៅជាមួយបានឡើយ ស្តេចនាគក៏និម្មិតសំពៅមាសមួយរចនាដោយគ្រឿងលម្អ មានប្រដាប់ប្រដាប្រើប្រាស់សព្វបែបយ៉ាង ដាក់រាជកុមារសំដៅនគរយក្សដើម្បីឲ្យនាងពន្ធរសចិញ្ចឹម។ សំពៅនោះអណ្តែតបានមួយខែកន្លះមកទើនឹងកន្លែងឥសី។ ខ្យងស័ង្ខក៏បានរៀបរាប់ពីដំណើរដើមទងប្រាប់តាបសៗក៏បានជូនពរសព្វសាធុការដល់ខ្យងស័ង្ខ និងបានយកឈើច្រត់រុញសំពៅមានល្បឿនលឿនពេកក្រៃដល់នគរតាលវ៍ន។ ពួកយក្សប្រុងចាប់រាជកុមារស៊ីជាចំណី ប៉ុន្តែយក្សទាំងនោះលិចទឹកក្ស័យជន្មអស់ ១៩០០០នាក់។ ដំណឹងនេះបានលឺដល់នាងពន្ធរស នាងក៏ឲ្យគេយកដំរីកាឡាហត្ថីទៅទទួលរាជកុមារ។ នាងពន្ធរសសព្វព្រះទ័យនឹងខ្យងស័ង្ខណាស់។ ជំងឺមិនឃ្លានអាហាររបស់យក្សពន្ធរសក៏ស្រាប់តែជាសះស្បើយឡើងវិញ ព្រះនាងត្រេកអរណាស់ រឹតតែស្រឡាញ់រាជកុមារខ្លាំងឡើង។ មុនពេលទៅរកចំណី នាងតែងផ្តាំបុត្រថាកុំឲ្យទៅលេងស្រះបោក្ខរណី រាជកុមារក៏លបលួចទៅលេង ឃើញមានស្រះមាស ស្រះប្រាក់។ ថ្ងៃក្រោយមកទៀតនាងបានផ្តាំទៅខ្យងស័ង្ខថាមិនឲ្យទៅលេងនៅប្រាសាទខាងលើ ព្រោះមានខ្មោចងោះ ដែលជាខ្មោចកាចសាហាវខ្លាំងណាស់ ប៉ុន្តែលើកនេះក្រោយពីម្តាយខ្លួនចាកចេញទៅខ្យងស័ង្ខក៏បានឡើងទៅលើប្រាសាទ រួចឃើញស្រោមងោះ និងឈើច្រត់។ ខ្យងស័ង្ខក៏ពាក់ស្រោមងោះ ព្រមទាំងជិះឈើច្រត់ហោះលេងលើអាកាស។ ការរស់នៅរបស់ខ្យងស័ង្ខប្រព្រឹត្តទៅអស់រយៈពេល១០ឆ្នាំ ដោយការរស់នៅឆ្ងាយពីម្តាយ ដោយនឹករលឹកដល់ព្រះមាតាចន្ទទេវី ខ្យងស័ង្ខក៏សម្រេចចិត្តចាកចេញពីម្តាយធម៌។ តែមុនពេលចាកចេញខ្យងស័ង្ខក៏បានចុះទៅស្រង់ទឹកនៅក្នុងស្រះបោក្ខរណី ជាតិជាមាសបន្ទាប់មកពាក់ស្រោមងោះ ហើយយកស្បែកជើងកែងពាក់ និងឡើងគង់លើឈើច្រត់ ហើយចេញពីនគរយក្សទៅ។

យក្សពន្ធរសបានយាងមកពីប្រពាតព្រៃវិញមិនបានឃើញខ្យងស័ង្ខមកទទួលខ្លួនដូចសព្វដង ក៏គិតថាប្រហែលជាខ្យងស័ង្ខរត់ចោលខ្លួនក៏ហោះចេញតាមរក។ ពេលទៅតាមទាន់ក៏បបួលលួងលោមឲ្យខ្យងស័ង្ខវិលត្រឡប់មកនគរវិញ ប៉ុន្តែខ្យងស័ង្ខមិនព្រម គឺគេប្តេជ្ញាថាទៅតាមរកមាតាចន្ទទេវី។ ដោយអស់មធ្យោបាយក្នុងការឃាត់ខ្យងស័ង្ខ ព្រះនាងក៏បានប្រាប់ពីវិធីប្រើប្រាស់វត្ថុអាថ៌កំបាំងសក្តិសិទ្ធិទាំងបីដល់ខ្យងស័ង្ខ ហើយព្រះនាងបានប្រាប់ពីមន្តវិជ្ជាការហោះមហាចិន្តានូវសិល្ប៍សាស្ត្រដែលអាចហៅត្រី សត្វនានា និងសម្បត្តិកែវកងផ្សេងៗ បានបន្ទាប់មកព្រះនាងក៏ដាច់ខ្យល់ស្លាប់បាត់ទៅ។ រាជកុមារក៏ប្រើខុនមារពលសេនាយក្សឲ្យលើកសពព្រះមាតាដាក់មឈូសមាស ធ្វើបុណ្យតាមប្រពៃណី បូជាព្រះភ្លើង រួចរើសព្រះធាតុដាក់ក្នុងកោដិមាសតាំងក្នុងព្រះចេតិយ ហើយក៏ក្រាបបង្គំលាបីដង។ ទ្រង់ក៏ឈរលើឈើច្រត់ ពាក់ស្រោមងោះហោះទៅលើអាកាសចេញពីនគរយក្សបាន៧ថ្ងៃដល់សាមលមហានគរ។

## ភ.អត្ថន័យខ្លឹមសារ

អត្ថន័យអត្ថ .ប្រយោជន៍.អត្ថន័យ .ការណែនាំអត្ថាធិប្បាយសេចក្តីពន្យល់.អត្ថន័យជាគំនិតសំខាន់ៗរបស់អ្នកនិពន្ធដែលលាតត្រដាងនៅក្នុងដំណើររឿង ហើយគេអាចហៅវាថាជាជម្រៅនៃរឿង។

ក្នុងផ្នែកអត្ថន័យមាន ប្រធានរឿង មូលបញ្ហារឿងនិងឧត្តមគតិរឿង។

## ខ.ប្រធានរឿង មូលន័យ

ប្រធានរឿងឬមូលន័យ គឺជាគំនិតសំខាន់ៗរបស់រឿង។ ប្រតិឬជាបញ្ហារួមរបស់រឿង។ តែអ្នកនិពន្ធចង់បង្ហាញដល់អ្នកអានប្រធានរឿងជាបញ្ហារួបផ្តុំបំផុតដែលអ្នកនិពន្ធលើកយកមកសរសេរឬជ្រើសរើសជាប្រធានបទហើយដែលមានមូលបញ្ហារឿងឋិតនៅក្នុងនោះ។

ប្រធានរឿងបង្ហាញនៅចំហររបស់អ្នកនិពន្ធវាជាមូលដ្ឋានដើមរបស់អ្នកនិពន្ធក្នុងការចាប់ផ្តើមសរសេរឡើង។មុនពេលចាប់ផ្តើមសរសេរឡើង។អ្នកនិពន្ធគ្រប់រូបត្រូវកំណត់ថាតើគាត់ត្រូវសរសេរអំពីអ្វី។អំពីជីវិតសង្គមសង្គ្រាមស្នេហារឿងជំនឿទនៀមទម្លាប់ប្រពៃណីចម្លើយរបស់សំណួរនេះហើយជាប្រធានរឿង។ តាមរយះរឿង ហង្សយន្ត និយាយរៀបរាប់ពីដំណើរជីវិតរបស់ខ្យងស័ង្ខ ។

## គ.មូលបញ្ហារឿង

មូលបញ្ហារឿងគឺជាភាពចំណែកនៃប្រធានរឿងជាទិដ្ឋភាពផ្សេងៗរបស់យើង។វាជាការចូលជ្រៅទៅក្នុងប្រធានរឿង។

ជុំវិញប្រធានរឿងនេះ យើងបានកំណត់បញ្ហាជាច្រើន ដែលនៅជុំវិញការកសាងសីលបារមីរបស់ព្រះពោធិសត្វ។ បញ្ហាទាំងនោះរួមមានៈ

## ទី១ បញ្ហាការចង់បានបុត្រ

នៅពេលព្រះ បាទវិមលរាជ សោយរាជពុំមានប្រុ ស្នងរាជចន្ទទេ ។ ក្រោយមក្រះបាទវិមលរាជស្រឡាញ់ព្រះមហេសីខ្លាំងណាស់ ព្រះអង្គបានឱ្យមហេសីធ្វើពិធីសុំបុត្រ ចំណែកមហេសីទាំងចប្ទទេវីបានរៀបចំពិធីដោយការភាវនារក្សាសិល្ប៍យ៉ាងខ្ជាប់ខ្ជួន ពេលនោះបានក្តៅងល់ព្រះឥន្ទសុំយាងព្រះពោធិសត្វមកចាប់កំណើតនៅផ្ទៃព្រះនាងទេវី ។ ចំណែកព្រះនាងចន្ទាវិញធ្វើការបួងសួងនៅដើមព្រៃជ្រៃ ពេលនោះទេវតានៅរក្សាដើមជ្រៃបានមកចាប់កំណើតព្រះនាងចន្ទា។ ក្រោយមកព្រះបាទវិមលរាជសង្កេតឃើញទឹកមុខមហេសីទាំងពីរខុសប្រក្តីក៏សួរមហេសីទាំងពីរ បានដឹងថាព្រះនាងទ្រង់គភ៌ ។ ព្រះបាទវិមលរាជបានៃួរមហេសីទាំងពីរពីការយល់សុបិណ្ឌហេតុដែល មានបុត្រព្រះនាងចទេវីបានយល់សុបិណ្ឌឃើញព្រះចន្ទយករាហូមកឱ្យព្រះនាងៗបានទទួលយកដោយត្រេកអរពេចនោះប្រែជាងដឹកសូនសុងព្រះព្រាតចេញពីដៃព្រះនាងយំខ្លួលរហូតដល់ក្ស័យព្រះជន្ម ក្រោយមករាហូក៏នាំព្រហចន្ទមកឱ្យព្រះនាងមកវិញ។ ព្រនាងចន្រ្ទទេវីមានបុត្រា ស្នងរាជជំនួសព្រះអង្គ។ ព្រះនាងពួបែបនោះមានចិត្តច្រណែនបានទៅរកគ្រូស្នេហ៍ យាយស្នេរជា ដាក់ព្រះបាទវិមលរាជ ពេលព្រះបាទវិមលរាជត្រូវស្នេហ៍ព្រះនាងចន្ទាបានស្តាប់តាមពាក្យញួសញ៉ង់ ព្រះនាងចន្ទាបានបណ្តេញព្រះនាងចន្ទទេវីចេញពីព្រះនគរ។បន្ទាប់មកប្រះនាងចន្ទទេវីចេញពីនគរបានទៅជួបនិងដូចាស់ម្នាក់ស្នាក់នៅជាមួយ ដោយព្រះនាងប្រកបរបរកាប់អូសលក់ ។ ខ្យងស័ង្ខបាន ឃើញព្រះមាតាប្រកបកាងារដោយលំបាកព្រះអង្គបានងធិស្ថានថា បើព្រះអង្គជាពោធិសត្វមែនសូមពេលកើតមកឱ្យមានខ្យងស័ង្ខស្រោបមកជាមួយ ។ នោះដល់បេលប្រសូតមករុំស្រោបដោយសំបកខ្យងមានពន្លឺភ្លឺរលោង ព្រះនាងបានយកទៅដេកអោប។ ពេលព្រះនាងចេញទៅកាប់អូសភ្លេចទុកអង្ករមិនប្រយ័ត្នមាន់បានចឹកស៊ីព្រះខ្យងស័ង្ខបានចេញពីក្នុងខ្យងមកទុកដាក់អង្ករអោយស្រួល។ ពេលព្រះមាតាមកពីកាប់អូសវិញឆ្ងល់ ឮណាស់តើនរណាមករៀបចំទុកដាក់ឱ្យ ថ្ងៃក្រោយមកព្រះនាងធ្វើជាភ្លេចចាំលបមើល ព្រះកុមារខ្យងស័ង្ខចេញមករៀបចំទុកដាក់ឱ្យទៀត ព្រះនាងលបមកពីក្រោយចាប់អោបព្រះកុមារជាប់សុំអង្វរបុត្រឈប់ចូលទៅក្នុងខ្យងស័ង្ខ។

សរុបមកការខ្វះការពិចារណាធ្វើឱ្យខ្លួន បានប្រព្រត្តិអំពើខុសដោយមិនដឹងខ្លួន មុននិងជឿទៅលើនរណាម្នាក់ត្រូវគិតពិចារណាឱ្យបានវែងឆ្ងាយ។

## ទី២បញ្ហាការតាមព្យាបាទ

ព្រះនាងចន្ទាបានដំណឹង ពីព្រះនាងចន្ទទេវីនិងបុត្រ ខ្លាចការវិលត្រឡប់មកឡើងស្នងរាជវិញ បានប្រាប់ព្រះបាទវិមលរាជ ឱ្យចាប់ខ្យងស័ង្ខមកប្រហារជីវិតដោយចោទថាព្រះនាងចន្ទទេវីមានសាហាយ ។ ព្រះបាទវិមលរាជបានចាប់ខ្យងស័ង្ខ យកមកសម្លាប់ដោយឱ្យពេជ្ឃយកអារុំតមកកាត់ករខ្យងស័ង្ខ អារុំតនោះបានពុកផុយ កយល់ពែងមកសម្លាប់ក្លាយពាផ្កាពេជ្ឃឃាតចងដៃចងជើងបោះទន្លាក់ចូលក្នុងទឹកតែពុំស្លាប់ទៀត និងយកចងដៃចងជើងចងដុំថ្មទំលាកទឹកម្តងទៀតបានក្តៅដល់ឋានបាដាស្តេចនាគនិមិតផ្កាឈូកដ៏ធំទ្រព្រះរាជកុមាររួចយកទៅឋាននាគបានដឹងរឿងរួចធ្វើជាកូនធម៌ ប៉ុន្តែមិនអាចគង់នៅឋាននាគបានស្តេចនាគនិមិតសំពៅមាសដ៏ធំមួយមានគ្រឿងប្រើប្រាស់គ្រប់សព្វ ។ ក្រោយមកស្តេចនាគបានបញ្ជូនព្រះរាជកុមារសំដៅនគរយក្សឱ្យនាងពន្ធរសចិញ្ចឹម ។ លុះអស់ពៅអណ្តែតបានមួយខែកម្លះមកទើរនៅកន្លែងតសី ៗ បានដឹងការពិតមានចិត្តអាណិតព្រះរាជកុមារ បានឱ្យពរសព្វសាធិការដល់ខ្យងដ័ង្ខក៏បានរុញសំពៅទៅនគរសាវន្ទ ពួកយក្សបានឃើញប្រុងចាប់យកស៊ីជាចំណី ដោយពរតាបសប្រទាន យក្សទាំងនោះបានស្លាប់អស់មួយម៉ឺនប្រាំមួនពាន់នាក់ ។ ក្រោយមកបានឮដល់ នាងពន្ធរស បានយកដំរី ក្រឡាហត្ថី ទៅទទួលរាជកុមារ ។នាងពន្ធរសមានចំងឺមិនឃ្លានអាហារប្រែជាឃ្លានអាងារវិញ។ មុនពេលទៅរកចំណីនាងតែងផ្តាំព្រះរាជកុមារមិនឱ្យទៅលេងស្រះបោក្ខណី ។ព្រះរាជកុមារានទៅលេងឃើញស្រះមាស ស្រះប្រាក់។ ថ្ងៃក្រោយមកទៀត នាងផ្តាំមិនឱ្យទៅលេងនៅប្រាសាទខាងលើ មានខ្មោចងូសជាខ្មោចកាចសាហាវខ្លាំងណាស់ ។ ក្រោយពីម្តាយចេញទៅខ្យងដ័ង្ខបានទៅលើ ឃើញស្រោបងូស និងឈើច្រត ក៏ពាក់ងោះលេងលើអាកាស។ បន្ទាប់មករសនៅរយៈពេល១០ឆ្នាំខ្យងស័ង្ខបានរលឹកមាតា បានទៅស្រះមាសងូតទឹក ទៅយកស្បែកជើងមាស និងឈើច្រតហោះចេញទៅ។

សរុបសេចក្តីមកការតាមធ្វើបាបអ្នកដ៏ទៃនាំឱ្យខ្លួនឯងវិនាស យើងចេះកែប្រែចិត្តចេះអធ្យាស្រ័យគ្នារស់នៅប្រកបដោយសុភមង្គល។

## ទី៣បញ្ហាស្នេហានិងការរើសអើង

ក្រោយមកព្រះបាទសាមលរាជបានរៀបចំវិធីរើសបុត្រសុរិសារឱ្យបុត្រីទាំងប្រាំពីរ ដែលមានរូបសម្បត្តិស្រស់ស្អាតគ្រប់អង្គ។ បើបុត្រីពេញចិត្តរាជបុត្រណាឱ្យយកកម្រងផ្កាទៅពាក់ឱ្យបុរសនោះទៅ ។ ចំណែកបុត្រីទាំងប្រាំមួយបានរើសមួយម្នាក់ ។ ឯព្រះនាងពៅរើសមិនបានសោះ ព្រះបាទយសវិមលរាជ បានឱ្យអាបាត្រប៉ោរគងប៉ោរឃ្មោះស្វែងរកបុរសឱ្យបុត្រី បើបុត្រពេញចិត្តបុរសណាឱ្យពាក់កម្រងផ្កាទៅបុរសនោះ បុត្រីនៅតែមិនពេញចិត្តទៀត ។ ក្រោយមកព្រះបាទយសវិមលរាជឱ្យអាមាត្រហៅ អស់បុរសទាំងចាស់ទាំងក្មេងមកទៀតនៅតែមិនត្រូវ ។ ដោយនោក្នុងនគរទាំងនមូលនៅសល់តែបុរសមួយរូបដែលមានមុខអាក្រក់គួរឱ្យខ្លាច។ បន្ទាប់ទៀតព្រះបាទ យសវិមលរាជ បានឱអាមាត្រហៅ មនុស្សងូសមក ។ គ្រាដែលមនុស្សងូសនៅទល់មុខ ព្រះនាងពៅរចនាទេវី មនុស្សងោះបានអធិដ្ឋានថា ប្រសិនបើអាត្មាអញនៅក្នុងស្រោមងោះសូមឱ្យនាងយល់ផង។ ពេលនោះប្រះនាងបានយល់រូបព្រះអង្គនៅក្នុងស្រោមងោះ មានរូបឆោមលោមពណ៌ស្រស់ត្រកាល ព្រះនាងត្រង់យាងទៅកានប្រះអង្គ ដោយបំពាក់កម្រងផ្កាទៅលើដៃចៅងោះ។ ព្រះបាទយសវិមលរាជខឹងត្រឡោតខ្នាស់ងស់ពួករាស្រ្តមន្រ្តី បានបញ្ជាឱ្យអាមាត្រសងខ្ទមឱ្យព្រះនាងនិងចៅងោះទៅនៅក្រៅនគរ ។ ព្រះបាទយសវិមលរាជចង់សម្លាប់ចៅងោះ បានប្រើឱ្យបុត្រប្រសាទាំងងស់ចេញទៅរកសត្វព្រៃ បើរកុំិនបានទេនិងប្រហារជីវិត។ បុត្រទាងអស់បានចេញទៅរកសត្វព្រៃ ចៅងោះបានសេបមន្តហៅដត្វព្រៃទាំងអស់មកចាប់បានសត្វ។ ចំណែកកូនប្រសាបងៗរកបានម្នាក់មួយខ្លហក៏ស្អុយខូចទៅហើយថែមទាំងចាញ់ប្រាជ្ញចៅងោះកាត់ច្រមុះដើម្បីដូរយកសត្វព្រះ។ លើកទីពីរបុត្រប្រសារទាំងប្រាំមួយរកបានត្រីមួយសុទ្ធតែត្រីងាប់ទាំងអស់ ហើយកាត់ស្លឹកត្រចៀក្រិបច្រមុះផង។លុះព្រឹកព្រះបាតវិមលរាជ ប្រាប់អាមត្រឱ្យទៅប្រាប់បុត្រទាំងប្រាំមួយឱ្យរៀបចំខ្លួនដោយឱ្យស្លៀកបាក់ឱ្យស្អាតប្រាដាប់ដោយគ្រឿងអលង្ការគ្រប់ប្រភេទ។ ព្រះស័ង្ខមិនខ្ចីខ្វាយខ្វល់និងសេចក្តីស្លាប់ ព្រះនាងបានងង្វរព្រះស័ង្ខ តែព្រះស័ង្ខមិនយល់ព្រម ក្រោយមកព្រាំពីរថ្កុសព្រះនាងសោទិរង្គត់ទៅ ។ ព្រះឥន្ទបានជួយឱ្យនាងរស់ឡើងវិញ ។ ព្រះឥន្ទបានត្រាស់បង្គមឱ្យព្រះវិស្ណុកាធ្វើជាទូតគៅសុំប្រគួតវាយឃ្លីជាមួយព្រះបាទវិមលរាជ ដោយដាក់នគរ ព្រះអង្គបានប្រាប់បុត្រថាបើក្រកួតចាញ់នឹងស្លាប់ ព្រះឥន្ទយកឈ្នះលើបុត្រទាំងប្រាំមួយ ។ ព្រះមាតាបានទៅរកបុត្រីនិងខ្យងស័ង្ខ រៀបរាប់ប្រាប់តាមដំណើររឿង។ ព្រះខ្យង់ស័ង្ខក៏យល់ព្រម បានទៅប្រគួតដោយអងអាចក្លាហាន។ ពួកទេវតានិងមនុស្សជាច្រើនបានងបអរសាទរ ហើយព្រះស័ង្ខក៏យកឈ្នះលើព្រះឥន្ទ។

សរុបមកយើងមិនត្រូវរើសអើងប្រកាន់វណ្ណៈ លើអ្នកណាម្នាក់នោះឡើយ ត្រូវរស់នៅដោយស្មើរភាពគ្នានិតទួលបាននូវសេចក្តីសុខ។

### ទី៤ ការទទួលកម្មផល

នៅក្នុងរាត្រីមួយព្រះបាទវិមលរាជបានយល់សុបិណ្ឌ ព្រះឥន្ទបានកាន់ដំបងនិយាយទៅកាន់ប្រះបាទវិមលរាជថា ជាស្តេចល្ងង់ខ្លៅមិនស្គាល់ខុសត្រូវជឿតាមពាក្យញុសញង់របស់នាងចន្ទាកំណាច បើមិនទៅយាងប្រះនាងចន្ទទេវីមកវិញទេ ប្រាំពីររាត្រីទៀតនឹងវាយក្បាលបែកជាប្រាំពីរចំណែក ព្រះឥន្ទប្រាប់ថា ខ្ទង់ស័ង្ខមិនស្លាប់ទេ ព្រឹកលើងព្រះបាទវុមលរាជរុះរាសទៅទទួលព្រះនាងចន្ទទេវីមកនគរវិញ។ ព្រះនាងចន្ទទេវីមិនយល់ព្រមមកនគរវិញ មកពីនាងចន្ទា និងយាយធ្មេធាដាក់ស្នេហ៍មកលើទ្រង់ បានបញ្ជាឱ្យសេនាចាប់ខ្លួនអ្នកទាំងពីរ យកទៅប្រហារជីវិតដោយឱ្យដំរីចុះប្រេងជាន់ស្លាប់។

សរុបមកការបៀនបៀតគេ តែងនាំសេចក្តីវិនាសមករកខ្លួនវិញជាក់ជាមិនខាន និងត្រូវរស់នៅប្រកបដោយសុខសន្តិភាពជាមួយគ្នា។

### ឃ.ឧត្តមគតិរឿងគំនិតដឹកនាំរឿងតម្លៃអប់រំ

ឧត្តមគតិរឿងគឺជាឧត្តមគតិរបស់អ្នកនិពន្ធ។ឧត្តមគតិរឿងគឺយកកត្តាប្រធានវិស័យដែលបញ្ហាដែលបញ្ជាក់ពីគោលជំហរសតិអារម្មណ៍របស់អ្នកនិពន្ធដែលស្តែងឡើងតាមរយៈសកម្មភាពរបស់តួអង្គ។

- អប់រំមនុស្សឱ្យចេះត្រិះរិះពិចារណាមុននិងធ្វើអ្វីមួយ
- អប់រំមនុស្សឱ្យចេះយោកយល់អធ្យាស្រ័យគ្នា
- ងប់រំឱ្យមនុស្សចេះជួយគ្នា
- អប់រំមនុស្សឱ្យមានប្រជ្ញា
- អប់រំមនុស្សឱ្យចេះភ្ញាក់ខ្លួយន
- អប់រំមនុស្សឱ្យស្គាល់កម្មផល
- អប់រំមនុស្សចេះស្រឡាញ់ក្រុមគ្រួសារ។

សរុបជារួមមកតាមរយៈរឿងខ្ចង់ស័ង្ខ បានបង្ហាញឱ្យយើងឃើញពីភាពកតញ្ញូកូនចំពោះអ្នកមានគុណ បានជួយឱ្យបុគ្គលម្នាក់ៗមានការអនុវត្តិតាម មិនមានការរើសអើងគ្នាទៅវិញទៅមក និងធ្វើឱ្យប្រទេសជាតិមួយមានការរីកចម្រើននិងមានសុខសន្តិភាព។

# សង្ខេបរឿង ស័ង្ខសិល្បជ័យ

ព្រះបាទកុត្តរាជ សោយរាជ្យបញ្ចាលបុរីមានព្រះអគ្គមហេសីព្រះនាមសុមន្ទា មានព្រះរាជបុត្រច្បងព្រះនាមសេនាកុត្តរាជ ព្រះរាជបុត្រីប្អូនព្រះនាមកេសរសុមន្ទា។ លុះព្រះបាទកុត្តរាជទ្រង់ព្រះទិវង្គតទៅ ព្រះនាងសុមន្ទាទ្រង់អភិសេកព្រះរាជកុមារសេនាកុត្តរាជ ជាមហេក្សត្រឡើងគ្រងរាជ្យ ហើយព្រះបាទសេនាកុត្តរាជ ទ្រង់ឲ្យហោរាទាយជតារាសីឲ្យព្រះនាងកេសរសុមន្ទាជាព្រះកនិដ្ឋា ហោរទាយថា"វេលាព្រះនាងមានព្រះជន្ម១៥វស្សា និងមានយក្ស១មកចាប់ទៅធ្វើជាភរិយានៅក្នុងព្រៃ"។

ក្រោយមកព្រះនាងកេសរសុមន្ទាចូលក្រាបបង្គំលាព្រះរៀមចេញទៅក្រសាលឧទ្យាន។ ព្រះរាមទ្រង់ឃាត់ពុំស្ដាប់ ក៏ទ្រង់ជូនព្រះកនិដ្ឋាទៅដោយពួកពលជាច្រើន។ ក្នុងពេលកំពុងក្រសាល មានយក្សកម្លោះមួយឈ្មោះកុម្ភណ្ឌ ឋិតនៅប្រាសាទក្នុងព្រៃហេមពាន្តចេញមកលេងព្រៃដែរ។ លុះមកដល់បញ្ចាលនគរ កុម្ភណ្ឌបានឃើញព្រះនាងកេសរសុមន្ទាកំពុងក្រសាលឧទ្យានក៏ស្នេហា ហើយកាឡាខ្លួនជាមនុស្សចូលទៅលាយឡំជាមួយបរិពារនោះ ហើយចាប់ពហោះយកព្រះនាងទៅធ្វើជាភរិយា នៅក្នុងប្រាសាទនាព្រៃហេមពាន្ត។

ថ្ងៃមួយកុម្ភណ្ឌលាព្រះនាងកេសរសុមន្ទាទៅគាល់ព្រះនារាយណ៍ក្រាបទូលសព្វគ្រប់រឿងដែលខ្លួនបានភរិយាជាទីពេញចិត្ត។ ព្រះនារាយណ៍ទ្រង់ប្រទានព្រះសភ័គមួយចងដៃ ស្បែកុម្ភណ្ឌយកព្រះនាងជាភរិយា។ នៅរួមគ្នាមិនយូរប៉ុន្មាន បានព្រះរាជបុត្រីមួយ ព្រះនាមថាសុពណ៌ទេវី។

សម័យមួយ កុម្ភណ្ឌទៅលេងបាស្កាភ្នាល់នឹងស្ដេចនាគឯនាគពិភព ស្ដេចនាគដាក់នគរជាតំណាង កុម្ភណ្ឌដាក់រាជបុត្រីជាតំណាង កុម្ភណ្ឌចាញ់នាគៗក៏យកព្រះនាងសុពណ៌ទេវីជាភរិយា។

ឯព្រះបាទសេនាកុត្តរាជ ក្រោយដែលកុម្ភណ្ឌលួចយព្រះនាងកេសរសុមន្ទាទៅ ទ្រង់ចាត់ឲ្យរកសព្វទិសាពុំឃើញសោះ ស្ដេចទ្រង់ព្រះវិយោគ ទ្រង់សង្វេគ ទ្រង់លះរាជសម្បត្តិចេញបួសជាបព្វជិតនៅវត្តមួយ។

វេលាទ្រង់ព្រះផ្នួសហើយ មានស្រុកមួយឈ្មោះនិគ្រោធគ្រាម មានដូនចាស់ម្នាក់មានបុត្រី៧នាក់។ នៅថ្ងៃសីលមួយ បុត្រីទាំង៧នាក់នោះ នាំគ្នាបេះផ្កាយកទៅថ្វាយព្រះពុទ្ធនៅវត្តដែលមានព្រះរាជាគង់។ ព្រះរាជាទតឃើញទ្រង់មានព្រះទ័យប្រតិព័ទ្ធ។ លុះនាងទាំង៧ត្រឡប់ទៅផ្ទះវិញ ព្រះរាជាទ្រង់លាចាកសិក្ខាបទ ហើយស្ដេចយាងទៅកាន់ស្រុកនិគ្រោធគ្រាមនោះ សុំដណ្ដឹងនាងទាំង៧នាក់អំពីតាចាស់ដូនចាស់ជាមាតាបិតា។ កាលដូនតាបានថ្វាយហើយ ទ្រង់នាំនាងទាំង៧នាក់នោះមក្នុងនគរអភិសេកជាមហេសី។

មិនយូរប៉ុន្មាន នាងបងៗទាំង៦ប្រសូតព្រះរាជបុត្រាមួយម្នាក់ៗ ព្រមគ្នាក្នុងមួយថ្ងៃ។

លំដាប់ពីនោះ នាងកេសរបុប្ផា ជាព្រះស្នំឯកប្រសូតបុត្រមួយមកជាសត្វរាជសីហ៍។

ព្រះនាងបុទមាជាប្អូនពៅ ប្រសូតបុត្រាមួយមកមានដៃម្ខាងកាន់ធ្នូសិល្បជ័យ ដៃម្ខាងកាន់ខ្យងស័ង្ខ ព្រោះហេតុនោះបានជាថ្វាយព្រះនាមថា "ស័ង្ខសីលជ័យ"។

ព្រះរាជាទ្រង់ឲ្យហោរគន់គូរ ហោរដោយបានសំណូកពីនាងបងៗទាំង៦ក៏ទូលថាអាភេទនេះជាឧត្បាទនាំឲ្យមានគ្រោះថ្នាក់ដល់ព្រះអង្គ ដល់បណ្ដារាស្ត្រ និងដល់ព្រះនគរ។ ដោយសេចក្ដីញុះញង់អំពីនាងទាំង៦ និងអំពីហោរាខ្លាំងពេក ទ្រង់ក៏ព្រះរាជបញ្ជាឲ្យនិរទេសព្រះនាងបទុមា នាងកេសរបុប្ផា និងស័ង្ខសីលជ័យព្រមទាំងរាជសីហ៍ចេញចាកព្រះនគរឲ្យទៅនៅព្រៃ។ ដោយបុណ្យបារមីស័ង្ខសិល្បជ័យជាពោធិសត្វ ព្រះឥន្ទ្រប្រើព្រះពិស្ណុការមកនិម្មិតនគរថ្វាយជានគរ មានប្រាង្គប្រាសាទទាំងបន្ទាយព័ទ្ធជុំវិញ ព្រមទាំងសួនច្បារ ទាំងប្រដាប់ប្រដាសព្វគ្រប់សន្មតនាមថា "ពិស្ណុនគរ"។ ព្រះស័ង្ខសិល្បជ័យក៏គង់នៅជាសុខសប្បាយជាមួយព្រះមាតា។ ថ្ងៃក្រោយមកពួកបងៗទាំង៦បានដឹងព្រឹត្តហេតុនោះ ដោយព្រានព្រៃក៏ធ្វើឧបាយយ៉ាងច្រើនយ៉ាង មាននំចំណី និងស្លាដាក់ថ្នាំពុលជាដើម ឲ្យកូនទាំង៦នាក់យកទៅថ្វាយព្រះស័ង្ខសិល្បជ័យ តែព្រះអង្គមិនសោយ។ ថ្ងៃក្រោយមកទៀត នាងទាំង៦នាំគ្នាទូលព្រះបាទសេនាកុត្តរាជសុំរាជ្យឲ្យកូនខ្លួន។ ព្រះរាជាទ្រង់មានព្រះបន្ទូលថា បើកូនចង់សោយរាជ្យ លុះតែកូនទៅរកសត្វបក្សាម្រឹគា និងមច្ឆាពីព្រៃហេមពាន្តមកឲ្យឪពុក ទើបកូនសោយរាជ្យបាន។ កុមារទាំង៦ទៅ

ឲ្យព្រះស័ង្ខសិល្បជ័យរកឲ្យព្រះស័ង្ខសិល្បជ័យថ្លែងសរកើតជាសត្វ បក្សា ម្រឹគា និងមច្ឆាឲ្យយកទៅថ្វាយព្រះបិតាៗទ្រង់ទត ទ្រង់ស្គាល់ថាជាឫទ្ធិរបស់ព្រះស័ង្ខសិល្បជ័យ។

ពេលដែលកុមារទាំងប្រាំមួយ ទូលសូមរាជ្យព្រះបិតាទ្រង់មានព្រះបន្ទូលថាលុះតែអ្នកទៅរកនាងកេសរសុមន្ទាជាព្រះមាតុច្ឆាបានមក ទើបយើងឲ្យអ្នកសោយរាជ្យ។ កុមារទាំង៦ក៏ប្រាប់ព្រះស័ង្ខសិល្បជ័យៗលាព្រះមាតា ជិះលើរាជសីហ៍ទៅជាមួយនឹងបងៗទាំង៦នាក់ ដោយខ្យងស័ង្ខជាអ្នកនាំមុខ ទីណាពុំមានផ្លូវ ខ្យងស័ង្ខក៏ដល់ធ្វើផ្លូវថ្វាយឲ្យស្តេចទៅដោយស្រួល។ ព្រះស័ង្ខសិល្បជ័យឲ្យបងៗ ទាំងប្រាំមួយ នៅចាំត្រង់ស្ទឹងធំមួយ ហើយស្តេចយាងឆ្លងស្ទឹងទៅជាមួយរាជសីហ៍ និងស័ង្ខ ស្តេចផ្សងថា បើព្រះមាតុច្ឆានៅទីណា សូមស័ង្ខនាំទៅកាន់ទីនោះ។ ក្នុងព្រះដំណើរកាត់ភ្នំកាត់ព្រៃនោះ ទោះទីមានសត្វសាហាវ យក្សកំណាច បិសាច ព្រាយមាយាយីយ៉ាងណាក៏ស័ង្ខ និងរាជសីហ៍បោលទង្គិចឲ្យខ្ទេចខ្ទីយកជ័យជំនះទៅបាន។

កាលព្រះស័ង្ខសិល្បជ័យទៅជិតដល់ កុម្ភណ្ឌចេញទៅលេងព្រៃទុកព្រះនាងកេសរសុមន្ទានៅក្នុងប្រាសាទ។

ព្រះស័ង្ខសិល្បជ័យទ្រង់ហោះទៅដល់ប្រាសាទនោះ បានជ្រាបដំណឹងដោយពួកទេវតាថានេះហើយជាប្រាសាទកុម្ភណ្ឌ ដែលព្រះនាងកេសរសុមន្ទាគង់នៅ។ ស្តេចជ្រាបហើយក៏ទ្រង់ឈរក្បែរប្រាសាទស្រែកហៅព្រះមាតុច្ឆា។ ព្រះនាងសាកសួរព្រះរាជកុមារៗក្រាបទូលប្រវត្តិការណ៍ដោយសព្វគ្រប់។

ពេលនោះ ហេតុតែបុណ្យបារមីព្រះស័ង្ខសិល្បជ័យ បណ្តាលឲ្យកុម្ភណ្ឌឈឺក្បាល ដើរដួលជ្រុលជ្រកនៅក្នុងព្រៃ ខំត្រដរត្រឡប់មកកាន់ប្រាសាទវិញមកដល់ប្រាសាទហើយ កុម្ភណ្ឌកំពុងតែដេកលក់ ព្រះស័ង្ខសិល្បជ័យក៏នាំយកព្រះមាតុច្ឆា ចេញចាកប្រាសាទទៅទាំងស័ង្ខ។

កាលព្រះស័ង្ខសិល្បជ័យនាំព្រះមាតុច្ឆាទៅដល់កណ្តាលផ្លូវ ទ្រង់ទុកព្រះនាងក្នុងគុហាកែវមួយ ហើយទ្រង់វិលទៅសម្លាប់កុម្ភណ្ឌ លុះសម្លាប់ច្រើនលើកហើយទ្រង់ក៏ត្រឡប់មករកព្រះមាតុច្ឆាវិញ។ ក្រោយមកកុម្ភណ្ឌកើតឡើងទៀត ហើយនាំពួកពលច្រើនជាអនេកមកច្បាំងទៀតជាច្រើនដង ច្រើនគ្រា។ ព្រះស័ង្ខសិល្បជ័យមានជ័យជំនះសម្លាប់កុម្ភណ្ឌ ព្រមទាំងពួកពលបាន។ វេលាកុម្ភណ្ឌស្លាប់លើកក្រោយបំផុត ព្រះស័ង្ខសិល្បជ័យឃើញព្រះមាតុច្ឆាសោកនឹងស្វាមីខ្លាំងពេកក៏ទ្រង់ថ្លែងសរកើតជាប្រាសាទកែវបញ្ចុះសពកុម្ភណ្ឌនៅទីនោះ ហើយសូមស្មាលាទោសកុំឲ្យមានពៀរតទៅ។

កាលព្រះស័ង្ខសិល្បជ័យបានជ័យជំនះហើយ ទ្រង់មានបំណងនឹងនាំព្រះមាតុច្ឆាទៅតែព្រះមាតុច្ឆាថាសូមកូនទៅយកនាងសុពណ៌ទេវីជាប្អូននៅឯពិភពនាគមកសិន។ ព្រះរាជកុមារក៏ទុកព្រះមាតុច្ឆានៅប្រាង្គប្រាសាទដែលមានដើមកុលព្រឹក្សអាចផ្តល់នូវចំណីអាហារគ្រប់យ៉ាងតាមប្រាថ្នា ហើយទ្រង់លាព្រះមាតុច្ឆាទៅ មុននឹងទៅទ្រង់យកស័ង្ខមកផ្សងថាបើឋាននាគជាលំនៅនាងសុពណ៌ទេវីនៅទីណា សូមឲ្យស័ង្ខនាំទៅត្រង់ទៅទីនោះ ហើយទ្រង់គង់លើស័ង្ខទៅ។ លុះស្តេចទៅដល់ពិភពនាគទ្រង់ច្បាំងដណ្តើមយកព្រះអនុជាក្សត្រីមកបានដូចព្រះបំណងហើយ ទ្រង់វិលមកនាំព្រះមាតុច្ឆា និងព្រះអនុជាក្សត្រីទៅដោយសេចក្តីលំបាក។

លុះវិលមកជួបកុមារទាំង៦ៗនាំព្រះស័ង្ខសិល្បជ័យទៅបេះផ្លែផ្កាលើកំពូលភ្នំ ហើយល្បួងឲ្យទុករាជសីហ៍ ទុកស័ង្ខ ទុកធ្នូនៅទីនោះក៏នាំទៅ ហើយព្រួតគ្នាច្រានព្រះអង្គទម្លាក់ទៅក្នុងជ្រោះភ្នំលើកថ្មសន្ធប់ រួចមកទូលព្រះនាងសុមន្ទាថា ស័ង្ខសិល្បជ័យធ្លាក់ជ្រោះស្លាប់ទៅហើយ។

ព្រះនាងសុមន្ទា និងព្រះនាងសុពណ៌ទេវីទ្រង់ព្រះកន្សែងសោករត់រកសព្វច្រកល្ហកពុំឃើញសោះ ហើយព្រះនាងសុមន្ទាទ្រង់យកព្រះកេសាដែលបានពីព្រះឥសូរ ព្រះនាងសុពណ៌ទេវីទ្រង់យកស្នៀតព្រះកេសាដែលបានពីកុម្ភណ្ឌមកផ្សងនឹងទេវតាថា "បើព្រះស័ង្ខសិល្បជ័យនៅរស់ សូមឲ្យមានគេយកស្បៃ និងស្នៀតសក់នេះទៅឲ្យដល់ខ្លុំឯស្រុក បើស្លាប់ឲ្យបាត់ស្ងាត់ទៅចុះ" ។

ព្រះនាងត្រឡប់មកកាន់កន្លែងដើមវិញ ស្តេចពាលទាំងប្រាំមួយចូលចាប់ព្រះហស្តព្រះនាងទាំងពីរ បង្ខំនាំយកទៅ។

ឯរាជសីហ៍វិលមកវិញពុំឃើញព្រះស័ង្ខសិល្បជ័យ ក៏ហោះរកសព្វទិសទី ហើយខាំព្រះខាន់ធ្នូនាំស័ង្ខហោះទៅកាន់ពិស្ណុនគរ។ កាលព្រះនាងកេសរបទុមា កេសរបុប្ផា សាកសួររាជសីហ៍ទូលតាមដំណើរសព្វគ្រប់ហើយ ព្រះនាងទាំង២ឡើងគង់លើរាជសីហ៍ទៅរកព្រះរាជបុត្រ។ វេលានោះ

ហេតុតែបារមីព្រះរាជកុមារ ក៏ក្តៅក្រហាយទៅដល់ព្រះឥន្ទ្រទ្រង់ហែកមេឃ បើកថ្មដែលស្តេចពាលសន្ធប់មាត់ជ្រោះនោះចុះទៅស្រង់យកព្រះអង្គមកស្រោចស្រពដោយទិព្វវារិ ព្រះអង្គក៏ល្អលើសមុន ហើយទ្រង់នាំព្រះអង្គទៅដាក់ដល់ពិស្ណុនគរ ជួបជុំនឹងព្រះនាងទាំង២អង្គដោយសិរីសួស្តី។ និយាយពីស្តេចពាលទាំង៦ កាលដែលនាំព្រះនាងសុមន្ទា និងនាងសុពណ៌ទេវីទៅកាន់បញ្ចាលនគរនោះ មុននឹងទៅបានបង្គំឲ្យព្រះនាងទូលព្រះបាទសេនាកត្តរាជថាខ្លួនទាំង៦នាក់ជាអ្នកទៅច្បាំងនឹងយក្ស និងនាគនាំយកព្រះនាងមក តែលុះទៅដល់នគរ ព្រះមហាក្សត្រត្រាស់សួរព្រះនាងបែរជាទូលថាព្រះស័ង្ខសិល្បជ័យវិញ។ ឯស្តេចពាលទាំងប្រាំមួយទូលថាខ្លួនជាអ្នកបានជួយនាងនេះឆ្កួតហើយនិយាយខុសគ្នាត្រូវស្លះសិន "។គ្រានោះ ព្រះបាទសេនាកត្តរាជកំពុងតែធ្វើមង្គលចងដៃក្សត្រីទាំងពីរអង្គ ស្រាប់តែឃើញនាយសំពៅដែលរើសបានស្បែនិងស្នៀតសក់នោះ យកទៅថ្វាយក្សត្រីទាំងពីរព្រះអង្គ។ ព្រះនាងទ្រង់ទតឃើញស្គាល់ជាក់ ទ្រង់ទូលព្រះរាជាអំពីព្រះនាងផ្សងថា ហើយបើព្រះស័ង្ខនៅសូមឱ្យឃើញស្បែនិងស្នៀតសក់មានគេយកមកឱ្យដល់ព្រះរាជវាំងរស់សូមឱ្យខើញស្បែវិញ។ព្រះនាងទាំងពីរអង្គគង់នៅប្រាសាទជាទីសប្បាយ។ តែទោះបីជាដូច្នោះព្រះនាងពុំបាត់សោក។ ឯស្តេចពាលទាំងប្រាំមួយ ទូលព្រះរាជាថាព្រះនាងឆ្កួតហើយឱ្យរកមេមុតបញ្ចូនទើបានជា មេមត់ប្រឹងចងព្រះនាងទាក់ទាំងដួលផងក្រោយមកមានគេយកស្បែនិងស្នៀតសកមកឱ្យព្រះនាងប្រាប់ព្រះរាជាថា ព្រះស័ង្ខមិនទានស្លាបទេ។

មុនពេលដែលព្រះបាទសេនាកត្តរាជចូលទៅជួបនឹងព្រះស័ង្ខសិល្បជ័យ ព្រះឥន្ទ្រនិម្មិតវាំងប្រាសាទឲ្យល្អលើសដើមមានជាបរិវារច្រើនលើសគណនា ស្តេចទាំង៥ព្រះអង្គទ្រង់ក្រសាហើយត្រឡប់ចូលកាន់ព្រះនគរបញ្ចាលដោយសួស្តី។

កាលស្តេចដល់ព្រះនគរទ្រង់អភិសេកព្រះស័ង្ខសិល្បជ័យ និងព្រះនាងសុពណ៌ទេវីជាព្រះអគ្គមហេសី ព្រមទាំងព្រះនាងសុរអមច្ចរណា ព្រះរាជបុត្រីនគរដទៃជាព្រះមហេសីបន្ទាប់ យ៉ាងមហោឡារឹកអស់រយៈពេល៧ថ្ងៃ៧យប់ តាមព្រះរាជប្រពៃណី។

បន្ទាប់ពីនោះ ព្រះបាទសេនាកុត្តរាជទ្រង់ឲ្យហៅស្តេចពាលទាំង៦មកសួរដេញដោលពីរឿងដែលស្តេចទាំងនោះអួតថាខ្លួនទៅយកព្រះនាងសុមន្ទាពីកុម្ភណ្ឌ ព្រះនាងសុពណ៌ទេវីពីនាគ។

ទីបំផុតព្រះស័ង្ខសិល្បជ័យសូមសម្តែងឫទ្ធិចំពោះព្រះភ័ក្ត្រព្រះរាជា។ ស្តេចពាលទាំអ៦ក៏បាក់បបខ្លបខ្លាចុះចាញ់។ ព្រះរាជាខ្ញាល់ឲ្យពេជ្ឈឃាដនាំទាំងម្តាយទាំងកូនទៅសម្លាប់ តែដោយសារតាយាយចាស់មកសុំទោស ទ្រង់ក៏អត់ទោសឲ្យគ្រាន់តែឲ្យចុះចេញប្រាសាទផ្លាស់ជាតិទៅជារាស្ត្រសាមញ្ញកំព្រាអនាថា។

ក្រោយពីទ្រង់កំសត់កម្រច្រើនដងច្រើនគ្រាមក ព្រះស័ង្ខសិល្បជ័យទ្រង់សោយរាជ្យប្រកបដោយសេចក្តីសុខក្សេមក្សាន្ត។ ព្រះនាងសុពណ៌ទេវីមានព្រះរាជបុត្រា១អង្គសន្មតព្រះនាមថា "វិជ័យកុមារ" ព្រះនាងសុរអមច្ចរណា មានព្រះរាជបុត្រី១សន្មតនាមថា "សីលរ័តន៍ទេវី" ។

លុះអំឡុងតមក ព្រះបាទសេនាកុត្តរាជជាព្រះបិតាព្រមទាំងព្រះនាងជាព្រះមាតាទ្រង់ចូលទិវង្គតព្រះវិលាល័យទៅ ព្រះស័ង្ខសិល្បជ័យទ្រង់ចាត់ការបុជាព្រះបរមសពដោយពិធីបុណ្យដ៏ឱឡារឹកតាមរាជបវេណី។

ចំណេរកាលមក ព្រះស័ង្ខសិល្បជ័យទ្រង់អភិសេកព្រះវិជ័យរាជកុមារ និងព្រះនាងសីលរ័តន៍ទេវីឲ្យសោយរាជ្យស្នងព្រះអង្គជាបរមសុខតទៅ។

### ១.សេចក្តីវិភាគរឿង

### ក.អត្ថន័យខ្លឹមសារ

អត្ថន័យអត្ថ .ប្រយោជន៍.អត្ថន័យ .ការណែនាំអត្ថាធិប្បាយសេចក្តីពន្យល់.អត្ថន័យជាគំនិតសំខាន់ៗរបស់អ្នកនិពន្ធដែលលាតត្រដាងនៅក្នុងដំណើររឿង ហើយគេអាចហៅវាថាជាជម្រៅនៃរឿង។

ក្នុងផ្នែកអត្ថន័យមាន ប្រធានរឿង មូលបញ្ហារឿងនិងឧត្តមគតិរឿង។

## ខ.ប្រធានរឿង មូលន័យ

ប្រធានរឿងឬមូលន័យ គឺជាគំនិតសំខាន់ៗរបស់រឿង។ ប្រតិឬជាបញ្ហារួមរបស់រឿង។ តែអ្នកនិពន្ធចង់បង្ហាញដល់អ្នកអានប្រធានរឿងជាបញ្ហារូបផ្តុំបំផុតដែលអ្នកនិពន្ធលើកយកមកសរសេរឬជ្រើសរើសជាប្រធានបទហើយដែលមានមូលបញ្ហារឿងឋិតនៅក្នុងនោះ។

ប្រធានរឿងបង្ហាញនៅចំហររបស់អ្នកនិពន្ធវាជាមូលដ្ឋានដើមរបស់អ្នកនិពន្ធក្នុងការចាប់ផ្តើមសរសេរឡើង។មុនពេលចាប់ផ្តើមសរសេរឡើង។អ្នកនិពន្ធគ្រប់រូបត្រូវកំណត់ថាតើគាត់ត្រូវសរសេរអំពីអ្វី។អំពីជីវិតសង្គមសង្គ្រាមស្នេហារឿងជំនឿទនៀមទម្លាប់ប្រពៃណីចម្លើយរបស់សំណួរនេះហើយជាប្រធានរឿង។ តាមរយៈរឿង ស័ង្ខសិល្ប៍ជ័យ និយាយរៀបរាប់ពីដំណើរជីវិត ពោធិសត្វ .ស័ង្ខសិល្ប៍ជ័យ. ។

## គ.មូលបញ្ហារឿង

មូលបញ្ហារឿងគឺជាភាពចំណែកនៃប្រធានរឿងជាទិដ្ឋភាពផ្សេងៗរបស់យើង។វាជាការចូលជ្រៅទៅក្នុងប្រធានរឿង។

ជុំវិញប្រធានរឿងនេះ យើងបានកំណត់បញ្ហាជាច្រើន ដែលនៅជុំវិញការកសាងសីលបារមីរបស់ព្រះពោធិសត្វ។ បញ្ហាទាំងនោះរួមមានៈ

### ទី១ បញ្ហាការច្រណែនឈ្នានីស

ព្រះបាទកុត្តរាជក្រោយពីលាចាកសិក្ខាបទហើយ បានចូលស្តីដណ្តឹងនាងទាំងប្រាំពីរនាក់ពីដូនចាស់ម្នាក់ហើយព្រះរាជាបាននាំទៅនគរ។ ថ្ងៃក្រោយមកព្រះនាងទាំងអស់បានប្រសូត្រមកម្នាក់មួយៗ ឯស្ដុំឯកេសរបុប្ផា បានប្រសូត្របុត្រមួយដែរជារាជសី ។ ចំណែកព្រះនាង បុទុមា ប្អូនពៅបានប្រសូត្តាមួយអង្គដែរ ដៃម្ខាងកាន់ ធ្នូសិល្ប៍ជ័យ ដៃម្ខាងកាន់ខ្យងស័ង្ខ មាននាមថា ស័ង្ខសិល្ប៍ជ័យ ។ ពេលនោះព្រះបាទកុត្តរាជបាឱ្យហោទាយពីសិល្ប៍ជ័យ ហោរាបានទទួលសំណូកពីបងៗទាយថា មានអុតក្បាតងគ្រែដល់ព្រះអង្គ និងដល់ប្រជារាស្ត្រ ។ ព្រះរាជាបានបំបរបងព្រះនាងបុទមាបុត្រានិង ព្រះនាងកេសរបុប្ផានិងបុត្រចេញពីនគរ ។ ព្រះឥន្ទបានឱ្យវិស្សកាទេពបុត្រចុះមកនិមិត្តប្រាសាទថ្វាយព្រះនាងនិងបុត្រ។ ក្រោយមកបានទទួលដំណឹងពីព្រានព្រៃពីព្រះស័ង្ខសិល្ប៍ជ័យ បានប្រើបុត្រយកបាយ នំឱ្យស័ង្ខសិល្ប៍ជ័យសោយតែព្រះស័ង្ខសិល្ប៍ជ័យមិនសោយ។ ពួកនាងទាំងប្រាំមួយបានសុំរាជពីព្រះបាទកុត្តរាជ ។ ព្រហអង្គបានប្រាប់ថា ឱ្យទៅយកបក្សាពីព្រៃហេនិពាន្តមកឱ្យទើបឡើងសោយរាជបាន។ កុមារទាំងប្រាំមួយប្រើឱ្យសិង្ខសិល្ប៍ជ័យយកឱ្យព្រះបាទកុត្តរាជដឹងថា ជាស្នាដៃស័ង្ខសិល្ប៍ជ័យ។ ក្រោយមកពួកនាងសុំទៀត ព្រះអង្គបានបង្គាប់ថា ឱ្យទៅរកព្រះនាងសុមន្ទា បុត្រទាំងប្រាំមួយក៏ទៅ ឱ្យស័ង្ខសិល្ប៍ជ័យទៅរក។ ស័ង្ខសិល្ប៍ច័យបានលាមាតា ទៅដោយជិះរាជសី ខ្យងស័ង្ខអ្នកបង្ហាញផ្លូវ ពេលនោះព្រះស័ង្ខសិល្ប៍ជ័យបាបទៅដល់ទុកបុត្រពាលទាំងប្រាំមួយក្បែរបឹងធំមួយ ។ព្រះកុមារបានឃើញព្រះមាតិច្ឆារស់នៅ ដោយទេវតាប្រាប់ យក្សយក្ស កុម្ភណ្ឌ បានឈឺក្បាលដើរដួល ខំដើររហូតដល់ព្រះរាជវាំងក៏ផ្តុំលក់ទៅ។ ព្រះស័ង្ខសិល្ប៉ជ័យបាននាំនាងមកបាន។ ព្រះសិង្ខសិល្ប៍ជ័យ បានទៅសម្លកាប់យក្សស្លាប់ ។បន្ទាប់មកព្រះនាង កេសរសុមន្ទាបានឱ្យសិង្ខសិល្ប៍ជ័យទៅយកបុត្រីនៅឋាននាគពេលទៅដល់បានច្បាំងជាមួយនាគយកឈ្នះបាន។ រាជកុមារក៏យកបាន ព្រះនាងសុពណ៌ទេវីបាន។ រួចមកជួបស្តេចពាលទាំងប្រាំមួយ ក៏បាននាំព្រះមុមារទៅបោះផ្លែឈើលើកំពូលភ្នំ បានច្រានទម្លាកពីលើភ្នំទៅក្នុងជ្រះ។ ក្រោយមកពួកគេបានតៅប្រាប់ ព្រះនាង សុពណ៌ទេវីនិង ព្រះនាងកេសរសុមន្ទាថា ព្រះសិង្ខសិល្ប៍ជ័យស្លាប់ហើយ ព្រះនាងនិងរាជសីខំដើររកតែរកមិនឃើញ។ ពេលនោះព្រះនាងកេសរសុមន្ទាបានយកព្រះសុភាគ .ស្បៃ. និងប្រះនាងសុពណ៌ទេវីបានយកស្ថិតសក់បាននាំគ្នាផ្សងថា បើសិង្ខសិល្ប៍ជ័យនៅរស់ឱ្យមានគេយកឱ្យដល់រាជវាំង។ ព្រះស័ង្ខសិល្ប៍ជ័យបៅរស់ដោយមានការជួយពីព្រះឥន្ទ ។ ពេលព្រះនាងនិងស្តេចពាលទៅដល់រាជវាំងហើយព្រះបាទកុត្តរាជបានសួរអ្នកជួយព្រះនាងទាំងពីរ ព្រះនាងឆ្លើយថា ស័ង្ខសិល្ប៍ជ័យ ស្តេចពាលទូលថា ពួកខ្លួនជាអ្នកជួយ។ ព្រះបានកុត្តរាជបានឮដូច្នោះមិនជឿមួយណាទេ។

សរុបមកការច្រណែនឈ្នាសនីសគ្នាទៅវិញទៅមកនាំឱ្យ កើតសេចក្តីវិនាសគ្រប់យ៉ាង យើងគួរនិងប្រព្រឹត្តអំពើល្អគ្រប់យ៉ាង។

## ទី២ បញ្ហាទទួលកម្មផល

ព្រះបាទកុត្តរាជបានទៅយាងព្រះនាងនិង ព្រះរាជបុត្រចូលនគរវិញ។ព្រះបាទកុត្តរាជទៅហៅបុត្រពាលទាំងប្រាំមួយមកចូលគល់បានសួរពីដំណើរទៅយកព្រះនាងទាំងពីរ ។ ចំណែកសង្ខសិល្ប៍ជ័យបានសម្តែងពីរិទ្ធផ្ទាយព្រះបាទកុត្តរាជមើល ហើយបុត្រាទាំងព្រាំមួយសុំចុះចាញ។ ហើយបានដាក់ទោសសម្លាប់ចោលទាំងបុត្រទាំងប្រាំមួយនិងនាងបងៗទាំងប្រាំមួយ ។ ប៉ុន្តែមានការសុំអង្វរពីដូនចាស់ ព្រះបាទកុត្តរាជក៏យល់ព្រម ។ បណ្តេញចេញពីនគរជាអ្នកកំព្រាអនាថាទៅវញ។

សរុបមកការប្រព្រឹត្តនូវអំពើអាក្រក់ ដែលបានធ្វើបាបទៅបុគ្គលណាមួយ វានៃឱ្យអ្នកប្រព្រឹត្តនិងទទួលកម្មផលនោះមកវិញ។

## ឃ.ឧត្តមគតិរឿងគំនិតដឹកនាំរឿងតម្លៃអប់រំ

ឧត្តមគតិរឿងគឺជាឧត្តមគតិរបស់អ្នកនិពន្ធ។ឧត្តមគតិរឿងគឺយកកក្តាប្រធានវិស័យដែលបញ្ហាដែលបញ្ជាក់ពីគោលជំហរសតិអារម្មណ៍របស់អ្នកនិពន្ធដែលស្តែងឡើងតាមរយៈសកម្មភាពរបស់តួអង្គ។

- អប់រំមនុស្សឱ្យហានទទួលនូវកំហុសរបស់ខ្លួន
- អប់រំមនុស្សមិនឱ្យចង់បានអ្វីដែលជាមិនមេនជារបស់ខ្លួន
- អប់រំមនុស្សឱ្យមានចិត្តជ៍មេត្តា
- អប់រំមនុស្សឱ្យចេះគោរពអ្នកនមានគុណ
- អប់រំមនុស្សឱ្យចេះគិតត្រឹមត្រូវ
- អប់រំមនុស្សឱ្យចេះធ្វើអំពើល្អចំពោះអ្នកជួយខ្លួន
- អប់រំមនុស្សឱ្យជឿលើកម្មផល។

សរុបជារួមមករឿងស័ង្ខសិល្ប៍ជ័យបានបង្ហាញឱ្យមនុស្សចេះរកវិធីដោះស្រាយរឿងដែលបានកើតឡើង ដោយប្រាជ្ញា មិនឱ្យមានការច្រណែនឈ្នាសរិះគ្នាទៅវិញទៅមក មានធម៌ខន្តីចំពោះគ្នានិងការចេះជួយគ្នាផលដែរ។

# សង្ខេបរឿង ៖ មរណមាតា

កាលព្រះបរមសាស្តាគង់នៅវត្តវេឡុវ័នទៀបក្រុងរាជគ្រឹះព្រះអនុរុទ្ធ ស្ថេរ បានទូលសួរអំពីកំណើតសត្វដែលផ្សេងគ្នាដោយអាយុ រូបរាង និងទ្រព្យសម្បត្តិ។ល។ ព្រះអង្គទ្រង់សំដែងថា "ជនណាបានពិចារណាទ្វត្តិង្សាការ កម្ម- ដ្ឋាន មានកេសា លោមា នខា ទន្តា តចោ ជាដើម ជននោះនឹងបានរួចចាកទុក្ខដូចនាងមរណមាតាដែលបានភាវនា ហទយំៗ នាងកើតឡើងជាមនុស្សមានចិត្ត ទិព្វល្អ ទោះបីមានជនចិត្តអាក្រក់ធ្វើបាបនាងយ៉ាងណាក៏គង់រួចចាកទុក្ខបាន"ហើយទ្រង់នាំអតីតនិទានថា៖

ក្នុងកាលកន្លងទៅយូរហើយមានព្រះរាជាមួយព្រះអង្គព្រះនាមវិមលធម្មរាជ សោយរាជ្យក្នុងវិទេហនគរ។ គ្រានោះមានបុរសម្នាក់ឈ្មោះ កុល្លិយៈ ប្រពន្ធឈ្មោះនាង កែវភេសី ជារាជបម្រើ។ ព្រះរាជាទ្រង់តាំងឲ្យ ធ្វើជាមេស្រុកនៅស្រុកមួយ កុល្លិយៈ និងនាងកែវក មានកូនស្រីមួយ ឈ្មោះ កុលកេសី។ ) នៅជិតផ្ទះនោះមានបុរសកម្សត់ម្នាក់មានកូនប្រុសមួយ កុដុម្ពិក៍កុមារ។ កុមារបានស្រឡាញ់នាងកុលកេសីក្នុងពេលដែល ទៅចាំចាបឯស្រែ។ អ្នកទាំងពីរបានពង្រត់គ្នាទៅនៅក្នុងជនបទមួយឈ្មោះកាសី ជាស្រុកចោរ។ ពួកចោរចាប់ចងកុដុម្ពិក៍ , នាងកុលកេសីយកចិញ្ចៀនមាសមួយ ទៅជូនមេស្រុកសុំលោះប្តី មេស្រុកបង្គាប់ពួកចោរឲ្យដោះលែង។ អ្នកទាំងពីរ សុំមេស្រុកធ្វើជាឪពុកធម៌។ មេស្រុកប្រគល់ទ្រព្យសម្បត្តិ និងទាសីកម្មករឲ្យ។ នាងកុលកេសីបានសុំឪពុកធម៌ទៅតាំងនៅភូមិថ្មីមួយ ក្លាយជាអ្នកមានទ្រព្យ សម្បត្តិស្តុកស្តម្ភ ដោយកុដុម្ពិក៍មានប្រាក់រាប់កោដិ អ្នកស្រុកឲ្យឈ្មោះថា កុលកោដិកុដុម្ពិក៍ៗ មានកូនស្រីមួយឲ្យឈ្មោះនាង កុមារី។ ក្រោយពី មេស្រុកដែលជាឪពុកធម៌ស្លាប់ទៅ កុលកោដិកុដុម្ពិក៍បានជាធំក្នុងស្រុកនោះ។ កាលនាងកុមារីបានអាយុ៧ឆ្នាំ មានស្ត្រីមេម៉ាយឈ្មោះ កាឡី មានកូន ស្រីពីរនាក់ កូនបងឈ្មោះ ចន្ទី កូនប្អូនឈ្មោះ ចន្ទាសាលិនី។ មេកាឡីមាន បងស្រីម្នាក់ឈ្មោះ កាលីនិយា។ មេកាឡីចេះតែមកប្រលោមកុលកោដិកុដុម្ពិក៍។

កុលកោដិកុដុម្ពិក៍យកមកាឡីនោះជាប្រពន្ធចុង មិនយូរប៉ុន្មានកុលកោដិ កុដុម្ពិក៍ធ្លាក់ខ្លួនជាអ្នកក្រ ដោយមេកាឡីមួលបង្កាច់ កុដុម្ពិក៍ក៏ជេរវាយនាង " កុលកេសីរាល់ថ្ងៃ ទីបំផុត កុដុម្ពិក៍នាំនាងកុលកេសីទៅបង់ ហើយវាយ ទម្លាក់ទឹកស្លាប់ទៅ។ នាងកើតជាត្រីដំរីនៅកំពង់ទឹកនោះ។លុះកុដុម្ពិក៍ត្រឡប់មកផ្ទះវិញ នាងកុមារីពុំឃើញម្តាយក៏យំរត់ទៅរកឯកំពង់ទឹក បានដឹងដោយនាងទេពធីតាប្រាប់ថា ម្តាយស្លាប់កើតទៅជាត្រីដំរី ហើយ នាងស្រែកហៅម្តាយៗហែលមកជិតប្រាប់កូនអំពីប្រវត្តិខ្លួនសព្វគ្រប់។ តាំងពីនោះមកគេហៅនាងកុមារីជា មរណមាតា។ នាងតែងធ្វើការផ្សេងៗ មានឃ្វាលគោជាដើមដោយកម្សត់ពន់ពេករាល់ថ្ងៃ នាងតែងយកកន្ទក់ទៅ បាចឲ្យត្រីដំរី .. មេកាឡីឲ្យកូនយកកន្ទក់ទៅបញ្ឆោតចាប់ត្រីដំរីមកសម្លាប់។ គ្រានោះមានទាញីមួយហួរស្រកាពីរទៅដាក់នៅមុខនាងៗស្គាល់ជាស្រកាម្តាយនាងក៏យកទៅដាំដុះជាដើមគប់ពីរដើមមានផ្លែផ្កាល្អ ហើយនាងគោរពបណ្ឌិ- ប័តន៍រាល់ថ្ងៃ។ -មេកាឡីដឹង យកដើមគ្រប់ទាំងឫសគល់ទៅបុកក្នុងត្បាល់។ គ្រានោះមានឆ្មាញីមួយពាំឫសគ្រប់ពីរទុកឲ្យនាងៗយកឫសគប់ទាំងពីរនោះ ទៅដាំ ដោយអំណាចអានិសង្សដែលនាងបានភាវនាទ្វត្តិង្សាការកម្មដ្ឋានថា ហទយំៗពីជាតិមុន គេឲ្យនាងមានជាតិជាទិព្វ នាងបួងសួងដល់មាតាហើយ ដាំទៅ ឫសគ្រប់នោះដុះភ្លាមកើតជាដើមរលួសពីរដើម មានស្លឹកពណ៌ល្អដូចមាស ហើយមាតានាងកើតជាទេព្តានៅចាំរក្សាទីនោះ ។ ស្លឹករលួសនោះខ្យល់ បក់មកឮសូរដូចប្រគំតន្ត្រី។ នាងមរណមាតានមស្ការដើមរលួសរាល់ព្រឹកល្ងាច។

វេលាមួយព្រះបាទវិបលធម្មរាជ ស្តេចចេញប្រពាតព្រៃ ទ្រង់ទតឃើញ ដើមរលួសនោះ ទ្រង់ជ្រាបថាជារបស់នាងមរណមាតា ទ្រង់ឲ្យហៅនាង។ នាងក៏ទៅថ្វាយបង្គំស្តេច។ ទ្រង់សុំដើមរលួសនោះ រួចទ្រង់ឲ្យពលជីកគាស់ ត ពុំរបើក លុះតនាងមរណមាតាបួងសួងទើបរលួសដុះឡើង អណ្តែតលើអាកាស តាមស្តេចទៅព្រះរាជវាំង ដល់ហើយដើមរលួសឋិតនៅលើអាកាសមិនចុះមកដី លុះតែព្រះរាជាឲ្យយកនាងមរណមាតាទៅក្នុងព្រះរាជវាំង នាងបួងសួង ទើបរលួសនោះចុះមកដីឋិតនៅក្នុងអាងមាស សន្មតឈ្មោះសុវណ្ណរាជព្រឹក្ស រាជាទ្រង់អភិសេកនាងមរណមាតាជាអគ្គមហេសី ហើយទ្រង់សួរប្រវត្តិព្រះ នាងៗក្រាបទូលតាំងពីដើមរហូតដល់ចប់។

ក្រោយមកព្រះរាជាទ្រង់ស្តេចទៅទាក់ដំរី។ មេកាឡីរកឧបាយសម្លាប់ ព្រះនាងមរណមាតា វាចាត់ការឲ្យរកអុសជីកគុកដាំប្រេងដូងមួយខ្ទះធំ ធ្វើបន្ទប់ ដាក់ក្តារគ្របពីលើ ដើម្បីឲ្យនាងដើរជាន់ ធ្លាក់ខ្លួនទៅក្នុងខ្ទះស្លាប់។ ធ្វើស្រេច ឲ្យកូនស្រីពីរនាក់ទៅបញ្ឆោតនាងមរណមាតាថាឪពុកឈឺទៀបស្លាប់ចង់ជួបនាង។ ពួកស្រីក្នុងវាំងក៏ហែហមព្រះនាងមរណមាតាទៅ

ផ្ទះឪពុក។ មុននឹងទៅ ជួបឪពុក គេឲ្យព្រះនាងដោះគ្រឿងប្រដាប់ស្រង់ទឹកសិន លុះចូលទៅក្នុង បន្ទប់ស្រង់ទឹក ព្រះនាងជាន់ក្តាភ្លាត់ធ្លាក់ព្រះអង្គទៅក្នុងខ្ទះប្រេងដួងក្តៅសុគត មេកាឡីយកគ្រឿងអលង្ការនោះបំពាក់មេចន្ទាសាលិនីជាកូនឲ្យទៅជំនួស។ ពួកស្រីស្នំមិនបានជាពិនិត្យក៏នាំចូលព្រះរាជវាំង។ ឯរាជព្រឹក្សទាំង គួស្រពោនជ្រុះស្លឹកបាក់មែករស់រលីង។ ក្រោយមករវាងបីថ្ងៃ ព្រះរាជាទ្រង់ យាងត្រឡប់មកព្រះរាជវាំងវិញ ទ្រង់ឆ្ងល់ ទ្រង់រកឱកាសដើម្បីនឹងចាប់ថ្នាក់ឲ្យបាន។

ក្រោយពីនាងមរណមាតាសុគតទៅ ដែលគេយកអដ្ឋិធាតុទៅចោលក្នុង ព្រៃស្មសាន ហើយនាងទេពធីតាមួយអង្គឈ្មោះ គិរីមេខលា ឋិតនៅដើមជ ក្នុងព្រៃនោះបានយកឱសថទិព្វមកដាក់ឲ្យរស់ឡើងវិញល្អលើសដើម។

នាងទេពធីតាប្រាប់ព្រះនាងថា បើទៅជាមនុស្ស ពេលទៅនគរវិញគេពុំជឿទេ ត្រូវ ព្រះនាងបរិភោគឱសថឲ្យក្លាយទៅជាសារិកាទើបចូលទៅបាន។ លុះបរិភោគ ឱសថក្លាយទៅជាសារិកាហើយ ទើបហើរចូលទៅក្នុងវាំង។ នាងសារិកា ទូលប្រវត្តិរបស់ព្រះនាងថ្វាយព្រះមហាក្សត្រជ្រាបសព្វគ្រប់ព្រះរាជាទ្រង់ស្រឡាញ់ ទ្រង់យកចិញ្ចៀនមាសមួយវង់បំពាក់ជើងដាក់ក្នុងទ្រុងមាសនៅក្នុង ព្រះរាជវាំង។ នាងសារិកាបួងសួងសុំដើមរាជព្រឹក្សៗក៏លូតលាស់ មានស្លឹក ផ្លែផ្កាល្អដូចដើម។

ព្រះរាជាទ្រង់ឲ្យពេជ្ឈឃាដសម្លាប់មេចន្ទាសាលិនី ធ្វើផ្អកដាក់ពាងទាំង ក្បាលផ្ញើទៅម្តាយឪពុកប្រាប់ថាកូនផ្ញើមកជូនកុងម្ពិក៍លួកដឹងថាកូនស្លាប់ក៏ ប្រញាប់នាំកូន និងប្រពន្ធទៅជ្រកក្នុងព្រៃស្មសាន គ្រោះជួបនឹងតាបសម្នាក់ ហើយនៅក្នុងពនោះទៅ។ព្រះរាជាឲ្យអាមាត្យវិនិច្ឆ័យក្តីយាយអក៍ដែលឲ្យគេបញ្ឆោតយកព្រះ នាងមរណមាតាទៅសម្លាប់។ អាមាត្យកាត់សេចក្តីថា យាយរអក៍នោះត្រូវ មានទោសដល់ស្លាប់។ យាយអក៍នោះមានកូនស្រីមួយឈ្មោះនាងឆន្ទៈ ជា សាវឡិកព្រះរាជាដែលត្រូវស្តេចបណ្តេញចេញដែរ នាងនោះខឹងថា មកពីនាង សារិកាអុចអាលបានជាគេសម្លាប់ម្តាយខ្លួន ក៏គុំសម្លាប់នាងសារិកា។

ថ្ងៃមួយ ព្រះវិមលធម្មរាជស្តេចចេញទៅបង្ក្រាបចោរនៅជនបទ ទុក នាងឆន្ទាបានឱកាសក៏ចូលទៅលួចនាងសារិកាបាននាងសារិកានៅក្នុងវាំង។ឲ្យទៅទាសីសម្រាប់ស្លស៊ី។ ទាសីបោចសារិកាហើយចុះទៅដី នាងសារិកាលប រត់ចូលទៅក្នុងរូងកណ្តុរស។ស្តេចកណ្តុរសយកនាងទៅចិញ្ចឹមទាល់តែដុះស្លាបឡើងវិញ។ ស្តេចកណ្តុរសខឹងណាស់ ទៅខាំនាងឆន្ទាដាច់ច្រមុះស្លាប់ទៅ។ នាងសារិកា និងស្តេចកណ្តុរសចេញទៅជួបពស់មួយធំប៉ងនឹងចឹកនាង តបានតាដក់ធំមួយខាំពស់នោះស្លាប់ទៅ។ បន្ទាប់ពីនោះមក ព្រះឥន្ទ្របើកទិព្វចក្ខុមក ឃើញនាងសារិកា ក៏ចុះមកនិម្មិតជាខ្លាធំមួយ លោតឡើងមែកជ្រៃ ស៊ីផ្លែជ មែកទិសបស្ចឹមក្លាយជាបក្សីៗលោតទៅស៊ីផ្លែជ្រៃមែកទិសឧត្តរ ក្លាយជាបើស មាសៗស៊ីផ្លែជ្រៃទិសបូព៌ា ក្លាយជាស្វាៗស៊ីផ្លែជ្រៃទិសទក្សិណ ក្លាយជាមនុស្ស រូបល្អ ព្រមទាំងមានគ្រឿងអលង្ការ នាងសារិកាឃើញសព្វគ្រប់បានធ្វើ គ្រាប់តាមលំដាប់ ក៏ក្លាយជារូបរាងផ្សេងៗ ទីបំផុតក្លាយជាមនុស្សស្រី ហើយ បេះផ្លែជ្រៃវេចទុកដើរទៅជួបតាបសម្នាក់ឈ្មោះមិត្តជិនៗសួរហេតុសព្វគ្រប់ ក៏នាំនាងទៅចិញ្ចឹមនៅក្នុងអាស្រម ។

ក្រោយមក តាបសមិត្តជិន ទៅកាន់ព្រះបោក្ខរណី បានឃើញ កុមារមួយរូបកើតក្នុងផ្កាឈូក បានយកមកឲ្យនាងចិញ្ចឹមឲ្យឈ្មោះបទុមកុមារៗ ធំឡើងសាកសួរនាងៗប្រាប់ប្រវត្តិសព្វគ្រប់បទុមកុមារលាមាតា និងមហាឫសីទៅរកព្រះបិតាឯវិទេហនគរ យកទាំងព្រះទម្រង់ដែលចងនឹងព្រះមាតា កាលនៅជាសារិកានិងផ្លែជទៅផង។ វេលានោះមានស្តេចបើសមាសមួយ មកធ្វើជាជំនិះបញ្ជីកុមារទៅរកព្រះបិតា។ លុះបានជួបព្រះបិតាហើយ ក៏យាង ព្រះបិតាបកហែហមព្រះមាតាទៅសោយរាជ្យក្នុងវិទេហនគរប្រកបដោយទស ពិធរាជធម៌។ កាលបើព្រះនាងបានជួបព្រះភស្តា ហើយបានសោយរាជ្យជាសុខព្រះនាងនឹកដល់គុណ និងស្តេចកណ្តុរក៏ព្រះរាជទានទំចំណី ដល់សត្វ ទាំងនោះ ព្រមទាំងចំណាយព្រះរាជទ្រព្យ ព្រះរាជទានដល់អ្នកកម្សត់ទុក៌តជា និរន្តរ៍ ហើយគង់នៅជាសុខសប្បាយដរាបដល់សោយព្រះវិលាល័យទៅហោ។

## ១.សេចក្តីវិភាគរឿង

### ក.អត្ថន័យខ្លឹមសារ

អត្ថន័យអត្ថ .ប្រយោជន៍.អត្ថន័យ .ការណែនាំអត្ថាធិប្បាយសេចក្ដីពន្យល់.អត្ថន័យជាគំនិតសំខាន់ៗរបស់អ្នកនិពន្ធដែលលាតត្រដាងនៅក្នុងដំណើររឿង ហើយគេអាចហៅវាថាជាជម្រៅនៃរឿង។

ក្នុងផ្នែកអត្ថន័យមាន ប្រធានរឿង មូលបញ្ហារឿងនិងឧត្តមគតិរឿង។

## ខ.ប្រធានរឿង មូលន័យ

ប្រធានរឿងឬមូលន័យ គឺជាគំនិតសំខាន់ៗរបស់រឿង។ប្រតិឬជាបញ្ហារួមរបស់រឿង។តែអ្នកនិពន្ធចង់បង្ហាញដល់អ្នកអានប្រធានរឿងជាបញ្ហារូបផ្តុំបំផុតដែលអ្នកនិពន្ធលើកយកមកសរសេរឬជ្រើសរើសជាប្រធានបទហើយដែលមានមូលបញ្ហារឿងឋិតនៅក្នុងនោះ។

ប្រធានរឿងបង្ហាញនៅចំហររបស់អ្នកនិពន្ធវាជាមូលដ្ឋានដើមរបស់អ្នកនិពន្ធក្នុងការចាប់ផ្តើមសរសេរឡើង។ មុនពេលចាប់ផ្តើមសរសេរឡើង។ អ្នកនិពន្ធគ្រប់រូបត្រូវកំណត់ថាតើគាត់ត្រូវសរសេរអំពីអ្វី។អំពីជីវិតសង្គមសង្គ្រាមស្នេហារឿងជំនឿទនៀមទម្លាប់ប្រពៃណីចម្លើយរបស់សំណួរនេះហើយជាប្រធានរឿង។ តាមរយៈរឿង ស័ង្ខសិល្ប៍ជ័យ និយាយរៀបរាប់ពីដំណើរជីវិត របស់នាងមរណមាតា។

## គ.មូលបញ្ហារឿង

មូលបញ្ហារឿងគឺជាភាពចំណែកនៃប្រធានរឿងជាទិដ្ឋភាពផ្សេងៗរបស់យើង។ វាជាការចូលជ្រៅទៅក្នុងប្រធានរឿង។

ជុំវិញប្រធានរឿងនេះ យើងបានកំណត់បញ្ហាជាច្រើន ដែលនៅជុំវិញដំណើរជីវិតនាងមរណៈមាតា។ បញ្ហាទាំងនោះរួមមានៈ

### ទី១ បញ្ហាការបាត់បង់ម្តាយនាងមរណៈមាតា

តាមរយៈរឿងមរណៈមាតាដែលបានធ្វើឱ្យនាងមរណមាតាទទួលរងទុកវេទនាគ្រប់បែបយ៉ាងបីការធ្វើបាបពីឪពុក បង្កើតនិងម្តាយចុងបងប្អូន ពីព្រោះនាងបានបាត់បងម្តាយបង្កើត ការផិតប្តីប្រពន្ធ បណ្តាលឱ្យគ្រួសារវិនាស កូនៗរងទុក្ខវេទនា ភាពមិនរឹងមាំរបស់មេគ្រួសារការឈ្នានីសលើកូនដើមពីសំណាក់ម្តាយ និងកូនចុងសកម្មភាពតស៊ូរបស់នាងកុមារីដែរស្លាប់ម្តាយ ហើយឪពុក ជឿរសំដីប្រពន្ធចុង បោះបង់ និងធ្វើបាបនាង ប៉ុន្តែដោយការព្យាយាមមិនរួញរា ធ្វើឱ្យនាងរួចចាកទុក្ខទោស និងទទួលបានការអាណិយអាសូស្រឡាញ់រាប់អានរពីអ្នកជិតខាង។

សរុបមកការតស៊ូព្យាយាមបានជួឱ្យយើងបានរយចចាកបុរក្តីលំបាកគ្រាប់យ៉ាងបាននិងជួយឱ្យអនាកត់បានប្រសើរទៀតផល។

### ទី២ បញ្ហានាងមរណៈក្លាយជាមហេសី ព្រះបាទវិមលរាជ

នៅពេលព្រះបាទវិមលធម្មរាជ បានទៅប្រពាតព្រៃស្តេចឃើញដើមរលួសនោះចង់បានហើយសុំនាងមរណៈមាតា ។ ដើមរលាស់នោះអណ្តែតលើអាកាសហោះទៅរាជវាំង ប៉ុន្តែមិនព្រមចុះឡើយ ។ ស្តេចបាននាំនាងមរណៈមាតាទៅរស់នៅក្នុងវាងអភិសេកជាអគ្គមហេសីនាងសុំដើមរលាស់មកដុះក្នុងរាជវាំង។ ក្រោយមកស្តេចបានទៅទាក់ដំរី មេកាឡីរកឧបាយកលសម្លាប់ព្រះនាងមរណៈមាតា បានឱ្យគេរកអូស ជីកគុបដាំប្រេងដូង មួយខ្ទះធំ ធ្វើបន្ទប់ដាកក្តារគ្រប់ពីលើ ដើម្បីឱ្យនាងដើរជាន់ធ្លាក់ទៅក្នុងខ្ទះស្លាប់។ នាងកាឡីបានប្រើល្បិចកលប្រាប់នាងមរណៈមាតាថា ឪពុកនាងឈឺឱ្យនាងមកផ្ទះ យាយអកនិងសេនាបាននាំនាងមរណៈមតាមក មុននិងជួបឪពុក គេឱយដោះគ្រឿងប្រដាប់ស្រង់ទឹកសិន ហើយព្រះនាងបានធ្លាក់ចុលទៅក្នុងខ្ទះដូងសុគតទៅ។

សរុបមក ការកសាងនូវអំពើល្អមិនយូមិនឆាប់ អំពើនោះនិងតាមជួយអ្នកដែលបានប្រព្រឹត្តិល្អ និងរក្សាមិនឱ្យលិចលង់ឡើយ។

### ទី៣ បញ្ហាកម្មផលគ្រួសារមេកាឡី

នៅពេលនាងចន្ទាសាលីនីបានទៅរស់នៅក្នុងរាជវាំង ស្ដេចបានស័ង្សថា មិនមែននាងមរណៈមាតា ដូចតាមដានក៏បានដឹងការពិត ។ បានឱ្យសេនាចាប់នាងយកទៅសម្លាប់ចោលធ្វើក្អកផ្ញើទៅឱ្យឪពុក ម្ដាយនាង ។ មាកាឡីនិងក្រុមគ្រួសារមានការត្រេកអរយ៉ាងខ្លាំងពេលស្ដេចផ្ញើក្អកកុម្ភីក៏ៗលួកដឹងថាកូនស្លាប់ក៏ពួកគេមានការភិតភ័យខ្លាចជាខ្លាំងបានប្រញាប់នាំកូន និងប្រពន្ធទៅជ្រកក្នុងព្រៃស្មសាន គ្រោះជួបនឹងតាបសម្នាក់ ហើយនៅក្នុងពនោះទៅ។

### ឃ.ឧត្តមគតិរឿងគំនិតដឹកនាំរឿងតម្លៃអប់រំ

ឧត្ដមគតិរឿងគឺជាឧត្ដមគតិរបស់អ្នកនិពន្ធ។ឧត្ដមគតិរឿងគឺយកកត្ដាប្រធានវិស័យដែលបញ្ហាដែលបញ្ជាក់ពីគោលជំហរសតិអារម្មណ៍របស់អ្នកនិពន្ធដែលស្ដែងឡើងតាមរយៈសកម្មភាពរបស់តួអង្គ។

- នៅក្នុងស្នាដៃរឿងមរណមាតានៅក្នុងនានាជាតកនេះបានបង្ហាញពីកសរគស្ម័ក្នុងឆាកជីវិតរបស់នាងមរណមាតា នៅពេលម្ដាយបានស្លាប់ចោលនាងទៅ ធ្វើឱ្យជីវិតនាងរងទុកវេទនាគ្រប់បេបយ៉ាង រឿងនេះអប់រំយើងឱ្យចេះរស់នៅមានភពអត់ធ្មត់គ្រប់បែបយ៉ាងមានទាំងធម៌ខន្តីពាររំងាប់ដោយការមិនចងពារដូចនាងមរណមាតាពារលនៅរូបរាងជាសារិកាត្រូវស្នំរបស់ស្ដេចឱ្យភិលៀងយកទៅសម្លាប់ ស្ដេចកណ្ដុលសរទៅសងសឹកឱ្យនាង នាងបានឃាត់កុំចងពារនិងគ្នានាំមានកម្មពៀរ

- អប់រំឱ្យយើងចេះថ្លឹងថ្លែងបុននិងជឿទៅលើបុគ្គលណាម្នាក់ងាយពេក ដូចឪពុករបស់នាងមរណមាតា ជឿតាមការញុះញង់ពាក្យសម្ដីមេកាឡីបានវាយធ្វើបាបនាងកុលកេសិរហូតយកទៅសម្លាប់ទៀតផង

- អប់រំឱ្យជឿទៅលើការកាសាងអំពើល្អនិងទទួលបានផលល្អដូចបានបង្ហាញតួអង្គនាងមរណមាតានាងប្រព្រឹត្តិតែអំពើល្អក៏ទទួលបានផលល្អ ប្រហមហាក្សត្របានរៀបអភិសេកតែងតាំនាងជាអគ្គមហេសី ពេលមានទុក្ខលំបាកមានគេជួយយកអាសារគ្រប់ពេលវេលាស្ដេចកណ្ដុលសរបានចយយនាងដេរ ការកសាងអំពើអាក្រក់និងទទួលបានផលអាក្រក់វិញជាមិនខាន ដូចក្រុមគ្រួសារនាងកាឡីនាងចន្ទបានស្លាប់ នាងចន្ទី នាងកាឡី និងកិដុម្ពីរបានរតចេញពីស្រុកកំណើតរបស់ខ្លួនទៅរស់នៅរសាតអណ្ដែតគ្មានគោលដៅ រស់នៅយ៉ាងលំបាកវេទនា ពីព្រោះតែកម្មពៀរដែលពួកគេបានប្រព្រឹត្តិដោយការសម្លាប់ជីវិតរបស់អ្នកដ៏ទៃ កម្មផលដែលបានប្រព្រឹត្តិងុចឱ្យភ្លាមៗមិនចាំជាតិក្រោយនោះឡើយ។

សរុបជារួមកមតាមរយៈស្នាដៃអក្សរសិល្ប៍រឿងនាងមរណមាតាបានអប់រំឱ្យយើងចេះប្រព្រឹត្តអំពើជាកុសល ចេះដឹងគុណចំពោះអ្នកមានគុណ ការមិនខឹងក្រោត ពៀររម្ងាប់ដោយការមិនចងពៀរ ខ្លួនទីបឹងខ្លួន ឱ្យយើងជឿទៅលើទស្សនៈកម្មផលក្នុងព្រះពុទ្ធសានាមានការកើតចាស់ឈឺស្លាប់និងការសរជាតិស្លាប់ហើយកើតជាថ្មីម្ដងតៀត។

# សង្ខេបរឿង កាកី

ក្នុងកាលកន្លងមក ពេលដែលព្រះមហាពោធិសត្វយកកំណើតជាគ្រុឌ មួយដែលបានឫទ្ធិបារមីខ្លាំងអស្ចារ្យ ស្ថិតនៅឯលើភ្នំព្រះសុមេរុ ។

ក្នុងគ្រានោះដែរ ក៏មានព្រះមហាក្សត្រមួយអង្គព្រះនាម ព្រហ្មទត្ត សោយរាជ្យសម្បត្តិនៅនគរពារាណសី ។ ទ្រង់មានភិលៀងម្នាក់ឈ្មោះថា ពន្ធ័ន មានឫទ្ធិសិល្បសាស្រ្តដ៏ខ្លាំងពូកែ ល្បីពេញអស់ភពផែនផងទាំងឡាយមិនតែប៉ុណ្ណោះគន្ធ័នថេរទាំងដេញពិណ ចេះទាំងច្រៀងល្បិចល្បាយតែងកាព្យ បានយ៉ាងស្ទាត់ជំនាញទៀតផង។ ព្រះអង្គមានមហេសីមួយអង្គឈ្មោះមានរូបឆោមលោមពណ៌យ៉ាងស្រស់សោភាល្អគ្មានស្រីណាផ្ទឹមបានឡើយ ។ កាកីបានកើតកាយចេញពីផ្កាកណិកាដែលមានតាគសីជាបិតាចិញ្ចឹម ដូច្នេះ ហើយទើបខ្លួនប្រាណនាងមានជាប់ក្លិនក្រអូបឈ្ងុយឈ្ងុបដោយលំអងគន្ធកាកី។

ក្នុងកាលនោះ ស្តេចក្នុង ដែលស្ថិតនៅចុងសិម្ពលីដាទីស្ថាន និង តេជៈបារមី តែងហោះផ្លោះឆ្លងទៅកម្សាន្តបាស្កាជាមួយមហាក្សត្រជាញឹកញយ ប៉ុន្តែមិនដែលចាញ់ឈ្នះទេ ជួនកាលគ្រុឌសម្រាកកម្សាន្តជាមួយព្រះមហា ក្សត្រទៀតផង លុះដល់វេលាទើបមកវិញ។

កាលនោះដែរ នាងកែវកាកីបានដើរទៅដល់ចុងរាជរោងហើយឈរ រេរានៅទីនោះ នាងបានគយគន់សព្វប្រាណរបស់គ្រុឌដែលប្រែក្រឡាជាបុរស សង្ហ ក៏ពេញចិត្តពេកក្រៃ ថែមទាំងចង់បានជាស្វាមីទៀតផង ។ គាប់ជួនពេល នោះមាណពរូបសង្ហារដើបភ័ក្ត្រឡើងត្រង់ក៏ប្រទះឃើញនាងកែវកាកី ហើយ កើតចិត្តគុំរួចលួចបតីក្នុងចិត្ត ។ គ្រុឌបកសម្លឹងកាកីមិនដាក់ភ្នែកសម្លឹងកាន់ តែយូរ កាន់តែមានចិត្តស្រឡាញ់ខ្លាំងឡើងៗ ចំណែកឯកាកីញញឹមដៀងភ្នែកមើលចំហៀងផង ចំផង ធ្វើឱ្យគ្រុឌញ័រអស់ហឫទ័យកើតសេចក្តីស្នេហាចំពោះ នាងជាពន់ពេក ។ ចំណែកអង្គក្សត្រព្រហ្មទត្តទ្រង់ក្រសាលបាស្កាយ៉ាងសប្បាយ ពុំបានចាប់អារម្មណ៍នឹងមហេសីដែលលបលួចប្រើខ្សែភ្នែកដាក់មាណពរូបសង្ហ នៅចំពោះមុខព្រះអង្គឡើយ ។ លុះព្រះសូរិយាទន់ទេ កែវកាកីក៏វិលទៅរាជ ដំណាក់វិញទុកឱ្យមាណពនៅខ្វល់ខ្វាយក្នុងចិត្តម្នាក់ឯងយ៉ាងក្រៃលែង ក្នុងចិត្ត គិតថាត្រូវតែយកអគ្គមហេសីនេះទៅឱ្យបានក្នុងពេលនេះ ។ គិតស្រេចមាណពក៏យល់ព្រមត្រឡប់យ៉ាងឆាប់ ។ ដល់ដើមជ្រៃភ្លាម មាណពបង្ករជាព្យុះភ្លៀងរយ៉ាងធំសំបើម ហោះឡើងទៅលើ ព្រះអង្គព្រហ្មទត្ត ឃើញហេតុការណ៍មកពេកអស្ចារ្យ ទ្រង់យាងទៅគង់មុខនាម៉ឺនសព្វមុខមន្ត្រី និងសេនាបតីទាំងឡាយដែលកំពុងផ្អើលហេតុការណ៍ដ៏ចម្លែកនេះ ។ ចំណែកជ្រុះចោរល្អាងរំលងរបស់ភពដី រួចហើយក៏ចុះចូលទៅដល់ កន្លែងរបស់កែវកាកី ហើយនិយាយលួងលោមនាង។ ពេលនោះនាងធ្វើពត់ជា លងលក់បណ្តាលឱ្យគ្រុឌផ្ទុះហោះនាំនាងទៅកាន់ទីស្ថានរបស់ខ្លួនដោយគ្មាននរណា ម្នាក់បានដឹងជាសោះឡើយ ។ ដល់ហើយ គ្រុឌបានដាក់កែវកាកី លើទីទែន ហើយក៏ប្រែប្រាណជាទេវបុត្រមួយរូបដ៏ស្រស់សង្ហាចូលទៅបបោស អង្អែលថៃថើប កាកី ដោយក្តីស្រឡាញ់ពេកកន្លង ចំណែកកាកីធ្វើកិរិយាធ្វើនាងរុញច្រាររូបអង្គទេវបុត្រ តែអង្គទេវបុត្រនិយាយលួងលោមនាងរហូតទាល់ តែនាងលង់ចិត្ត ។

ឯព្រះរាជវាំងវិញម្តង ក្រោយពេលមេឃងងឹតព្យុះភ្លៀងត្រូវបានស្ងប់ ស្ងាត់ហើយនោះ ព្រះអង្គព្រហ្មទត្តយាងចូលក្រឡាបន្ទំដើម្បីរកព្រះមហេសី កែវកាកី ស្រាប់តែស្ងាត់ឈឹង ទ្រង់ស្លុតអស់អង្គកាយ ដណ្តឹងសួរអស់ស្រីស្នំ ភីលៀងទាំងឡាយគ្មាននរណាម្នាក់បានដឹងឡើយ ។ ព្រះអង្គទ្រង់ចាត់ឱ្យរត់រក គ្រប់ទីកន្លែងតែរកមិនឃើញទៀត ទីបំផុតព្រះអង្គព្រហ្មទត្តទ្រង់ព្រះកន្សែង នឹកស្តាយកែវកាកីជាពន់ពេក ក៏ត្រាស់បញ្ជាឱ្យហៅគន្ធនមកចូលគាល់ព្រះអង្គ ហើយទ្រង់បានប្រាប់រឿងដែលកែវកាកីបានបាត់ពីប្រាសាទ ។ គន្ធនស្តាប់ហើយ ក៏ប្រាប់ឱ្យព្រះអង្គរង់ចាំ៧ថ្ងៃសិនចាំតាមដានចៅមាណពឱ្យបានដឹងការពិត បើយ៉ាងណាដើម្បីឱ្យគេជួនព្រះមហសីត្រឡប់មកវិញ ។ ព្រះអង្គស្តាប់ ហើយក៏ធូរស្បើយក្នុងអារម្មណ៍ខ្លះ ។

លុះគម្រប់៧ថ្ងៃ ស្តេចគ្រុឌមកលេងបាស្កាជាមួយព្រះអង្គព្រហ្មទត្ត ទៀតដើម្បីកុំឱ្យគេសង្ស័យ ដោយបានសូត្រមន្តចងទ្វារប្រាសាទកុំឱ្យនរណា មកយាយីកាកី បាន ព្រះមហាក្សត្រទតឃើញមកដល់ដូច្នេះ មានសេចក្តី ក្រោធយ៉ាងខ្លាំង តែខំរម្ងាប់ធ្វើមិនដឹង ហើយលេងធម្មតា ។ លុះដល់ល្ងាច មាណពធ្វើដំណើរត្រឡប់ទៅដើមជ្រៃវិញ ដោយមិនដឹងថាគន្ធ័នដើរតាមពីក្រោយទេ ។ ដល់ដើមជ្រៃមាណពក៏ប្រែប្រាណជាគ្រុឌ ចំណែកគន្ធ័នវិញក៏ប្រែកាលាជាស្រមោចដ៏តូចមួយទុំលើរោមគ្រុឌ ។ ដោយក្នុងចិត្តនឹកទៅដល់កាកី ហើយប្រញាប់ត្រឡប់ទៅវិញនោះគ្រុឌមិនបានចាប់អារម្មណ៍ដឹងថាមានអ្វីតោងខ្លួន នោះឡើយ ។ ដល់ហើយក៏ស្រាយមន្តបើក

ទ្វារប្រាសាទហើយចូលទៅរកនាង កាកីដោយក្តីសប្បាយរីករាយក្នុងចិត្តឥតឧបមា ព្រឹកព្រាងភ្លឺស្វាង គ្រុឌចេញទៅរកចំណី ។ ពេលនោះគន្ធ័នក៏ប្រែប្រាណមកវិញ កាកីបានឃើញគន្ធ័នក៏ធ្វើជាព្រួយចិត្តសួរគន្ធ័នអំពីព្រះអង្គ គន្ធ័ននិយាយបែបថែចង់កាកីទៅវិញ ធ្វើឱ្យនាងត្រេកអរក្នុងចិត្ត តែនៅធ្វើជាស្មោះចំពោះព្រះអង្គ គន្ធ័ននិយាយ បញ្ចុះបញ្ចូលកាកីឱ្យលង់ចិត្ត រួចអ្នកទាំងពីរក៏រួមរ័កនឹងគ្នាធ្វើឱ្យកាកីភ្លេច សង្សារថ្មោងថ្មីទៀត ។

លុះដល់ពេលល្ងាច គន្ធ័នប្រែកាយជាសភាពដើមកុំឱ្យគ្រុឌសង្ស័យ ហើយគ្រុឌក៏បន្តរួមរស់ជាមួយកាកីជាធម្មតាដោយមិនដឹងរឿង ។ ថ្ងៃទី៧ក៏ចូល មកដល់ គ្រុឌរៀបចំទៅលេងបាស្កាជាមួយនឹងព្រះអង្គ គន្ធ័នដឹង ការក៏តោង រោមគ្រុឌទៅជាមួយ ។ ពេលគ្រុឌត្រឡប់ទៅវិញ ព្រះអង្គសួរគន្ធ័នពីដំណឹងកាកីហើយគន្ធ័នក៏ទូលប្រាប់តាមការពិត គន្ធ័នគិតថានឹងច្រៀងបញ្ឈឺស្តេចគ្រុឌ ដើម្បីឱ្យនាំកាក៏មកវិញ ។ ព្រះអង្គក៏សប្បាយព្រះទ័យឡើងវិញ។ នៅថ្ងៃគ្រុឌមកម្តងទៀត គន្ធ័នចាប់ពិណនា មកដេញលេងជាភ្លេងយ៉ាងរណ្តំ ហើយច្រៀង សរសើរពីកាកី និងរៀបរាប់ពីទីស្ថានរបស់គ្រុឌ ធ្វើឱ្យគ្រុឌកើតក្តីខឹងពេញឱរ៉ា ហើយធ្វើជាសួរទៅគន្ធ័នអំពីទំនុកច្រៀងដ៏ប្លែកនេះ គន្ធ័ននិយាយប្រាប់ថា ខ្លួនបានទៅដល់ទីស្ថានគ្រុឌមួយដោយតោងរោមគ្រុឌនោះ ហើយបានរួមស្នេហា ជាមួយកាកីទៀតផង ។ ស្តាប់ចប់គ្រុឌក៏លាទៅវិញ រួចសួរកាកីដោយវាចា ធម្មតាថា មាននរណាបន្លំខ្លួនចូលមកក្នុងប្រាសាទនៃបនិត្យជិតកាយនាងឬទេ ។ កាកីឆ្លើយដោះសារថាគ្មានទេ គ្រុឌស្តាប់ហើយ និយាយទម្លាយរឿងទំនាក់ ទំនងគន្ធ័ននិងនាង ផ្ទុយមកវិញនាងនៅតែឆ្លើយដោះសារថាគ្មានទៀត ធ្វើឱ្យ គ្រុឌរឹតតែខឹងហើយនាំនាងទៅរាជវាំងវិញក្នុងរាត្រីនោះភ្លាម គ្រុឌបានដាក់ កាកីនៅមុខទីលានព្រះព្រហ្មទត្តតែម្នាក់ឯង ។

ពេលព្រឹកឡើងស្តេចព្រហ្មទត្តយាងចេញមកក្រៅ ឃើញកាកីអង្គុយ តែម្នាក់ឯង ក៏មានបន្ទូលចំអកចំអន់នាងថា នាងជាស្រីសារ៉ា។ កាកីលុតជង្គង់ លើកដៃសំពះ ហើយនៅតែឆ្លើយដោះសារយករួចខ្លួនទៀត ថានាងជាស្រីទន់ ខ្សោយ មានកម្លាំងឯណាតទល់ជាមួយគ្រុឌនោះហើយពុំដឹងថាគន្ធ័នធ្វើអ្វីលើ ខ្លួនទេ ព្រោះនាងបានសម្លប់ពេល ឮគន្ធ័ននិយាយថាព្រះអង្គកើតទុក្ខ ។ ចំណែក ស្តេចព្រហ្មទត្តមិនខ្វល់នឹងនាងឡើយ បញ្ជាឱ្យអាមាត្យយកកាកីទៅដាក់ពោង ពាយទៅ ។ អាមាត្យក៏ម្ចីម្នានាំនាងទៅកំពង់ទឹកដាក់បណ្តែតនាងក្នុងពោងពាយហើយប្រាានចេញយ៉ាងលឿនស្លេវផុតពីកំពង់ទឹក ។

កាកីត្រូវខ្យល់បក់រសាត់ផាត់កណ្តោចកណ្តែងតែឯកឯងនឹកស្តាយសព្វសារពើ ស្តាយអ្វីៗទាំងអស់ មិនគួរកម្មអ្វីប្រាសព្រាត់មកនៅ លើពោងពាយទៅវិញ នាងយំរៀបរាប់មិនឈប់ហើយប្រះខ្លួនននៀលបាត់ ស្មារតីទៅ ។ លុះគម្រប់៧ថ្ងៃ ពោងពាយក៏ត្រូវរលកបក់បោកខ្ចាត់ខ្ចាយពីគ្នា នាំយករូបកាកីឱ្យលិចលង់ក្ស័យជីវិតក្នុងមហាសាគរដ៏សែនជ្រៅនោះជារៀងរហូត ។

## ១.សេចក្តីវិភាពរឿង

### ក.អត្ថន័យខ្លឹមសារ

អត្ថន័យអត្ថ .ប្រយោជន៍.អត្ថន័យ .ការណែនាំអត្ថាធិប្បាយសេចក្តីពន្យល់.អត្ថន័យជាគំនិតសំខាន់ៗរបស់អ្នកនិពន្ធដែលលាតត្រដាងនៅក្នុងដំណើររឿង ហើយគេអាចហៅវាថាជាជម្រៅនៃរឿង។

ក្នុងផ្នែកអត្ថន័យមាន ប្រធានរឿង មូលបញ្ហារឿងនិងឧត្តមគតិរឿង។

### ខ.ប្រធានរឿង មូលន័យ

ប្រធានរឿងឬមូលន័យ គឺជាគំនិតសំខាន់ៗរបស់រឿង។ ប្រតិឬជាបញ្ហារួមរបស់រឿង។ តែអ្នកនិពន្ធចង់បង្ហាញដល់អ្នកអានប្រធានរឿងជាបញ្ហារូបផ្តុំបំផុតដែលអ្នកនិពន្ធលើកយកមកសរសេរឬជ្រើសរើសជាប្រធានបទហើយដែលមានមូលបញ្ហារឿងឋិតនៅក្នុងនោះ។

ប្រធានរឿងបង្ហាញនៅចំហររបស់អ្នកនិពន្ធវាជាមូលដ្ឋានដើមរបស់អ្នកនិពន្ធក្នុងការចាប់ផ្តើមសរសេរឡើង។មុនពេលចាប់ផ្តើមសរសេរឡើង។អ្នកនិពន្ធគ្រប់រូបត្រូវកំណត់ថាតើគាត់ត្រូវសរសេរអំពីអ្វី។ អំពីជីវិតសង្គមសង្គ្រាមស្នេហារឿងជំនឿទនៀមទម្លាប់ប្រពៃណី

ចម្លើយរបស់សំណួរនេះហើយជាប្រធានរឿង។ តាមរយៈរឿង កាកី និយាយរៀបរាប់ពីដំណើរជីវិតនិងការប្រព្រឹត្តខុសនាងកាកី ។

## គ.មូលបញ្ហារឿង

មូលបញ្ហារឿងគឺជាភាពចំណែកនៃប្រធានរឿងជាទិដ្ឋភាពផ្សេងៗរបស់យើង។វាជាការចូលជ្រៅទៅក្នុងប្រធានរឿង។

ជុំវិញប្រធានរឿងនេះ យើងបានកំណត់បញ្ហាជាច្រើន ដែលនៅជុំវិញការកសាងសីលបារមីរបស់ព្រះពោធិសត្វ បញ្ហាទាំងនោះរួមមានៈ

### ទី១បញ្ហាស្តេចគ្រុឌចាប់ខ្លួនកាកី

នៅពេលព្រះបាទព្រហ្មទត្តបានលេងបាស្កាជាមួយស្ដេចគ្រុឌ នាងកាកីបានមកឃើញស្ដេចគ្រុឌបានធ្វើកិតិយាមាយាទ បង្ហាញរាងបង្ហាញ កន្ទុយភ្នែកឱ្យស្ដេចគ្រុឌមើល ។ ស្ដេចគ្រុឌឃើញហើយចាប់ចិត្តស្រឡាញ់ ។ ស្ដេចគ្រុឌបានប្រែកាឡាជាគ្រុឌវិញ ហើយហោះឡើងទៅលើមេឃបង្កជាខ្យល់ព្យុះងងឹតអស់ទាំងមេឃផែនដី ។ រួចហោះទៅយកនាងកាកី ទៅកន្លែងរបស់ខ្លួនបានប្រែកាឡាជាទេវបុត្រស្រស់សង្ហាមួយរូប។ បន្ទាប់មកបានលោងលោមនាង កាកីរហូតនាងបានព្រមស្រលាញ់។ ពេលព្រះបាទប្រហ្មទត្ត បានមករកកាកីប៉ុន្តែមិនឃើញ បានឱ្យគន្ធ័នចូលគាល់។ គន្ធ័នបានទូលប្រាប់ស្ដេចថា ចាំប្រាំពីរថ្ងៃសិនតាមដានថៅមាណពឱ្យដឹងការពិត ។លុហគម្រប់ប្រាំពីរថ្ងៃ ស្ដេចគ្រុឌបានមកលេងបាស្កាជាមួយព្រះបាទព្រហ្មទត្តតាមធម្មតា។ ស្ដេចគ្រុឌទៅវិញគុន្ធ័នទៅជាមួយ បានដល់ទ្វាហើយសេបមន្តបើកទ្វាចូលទៅរកកាកីដោយសម្ងាយ ។ គុន្ធ័នខើញកាកីបានលោងលោមនាងយល់ព្រមពួកគេបានរួមមេត្រីទៅ។ ថ្ងៃទីប្រាំពីរបានមកដល់គ្រុឌទៅលេងបាស្កាជាមួយព្រះបាទព្រហ្មទត្ត គុន្ធ័នបានទៅវិញជាមួយស្ដេចគ្រុឌ។ ពេលលេងបាស្កាគុន្ធ័នបានចៀងរៀបរាប់ខ្លួនបានតៅហានគ្រុឌបានជួបនិងកាកី។

### ទី២ បញ្ហាកម្មរបស់នាងកាកី

ស្ដេចគ្រុឌបានខឹងនិងនាង កាកីបាននាំយកនាងមកឱ្យប្រះបាទព្រហ្មទត្តវិញ ។ ពេលព្រះបាទព្រហ្មទត្តបានឃើញកាកី ព្រះងង្គខ្ញាល់និងនាង កាកីជាខ្លាំង បានដាក់ទោសនាងដោយបណ្ដែតពោពាយនៅលើក្បូន បណ្ដែតនៅលើមហាសាគរ ។ លុះបានចំនួនប្រាំពីរថ្ងៃក្បូននោះក៏បែកធ្លុងធ្លាយអស់ នាង កាកីនិងបានលង់ទឹកស្លាប់នៅកណ្ដាលសាគរបាតរនោះទៅ។

សរុបមកជាស្ត្រីមិនត្រូវប្រព្រឹត្តនូវអំពើដែល ខុសប្រពៃណីនោះទេ នាំឱ្យមានកេរ៏ឈ្មោះអសោចន៍និង នាំឱ្យខ្លួនអន្រោយទៀតផល។

## ឃ.ឧត្តមគតិរឿងគំនិតដឹកនាំរឿងតម្លៃអប់រំ

ឧត្តមគតិរឿង គឺជាឧត្តមគតិរបស់អ្នកនិពន្ធ។ ឧត្តមគតិរឿង គឺយកកត្តាប្រធានវិស័យដែលបញ្ហាដែលបញ្ជាក់ពីគោលជំហរ សតិអារម្មណ៍របស់អ្នកនិពន្ធដែលស្ដែងឡើងតាមរយៈសកម្មភាពរបស់តួអង្គ។

- អប់រំមនុស្សឱ្យចេះស្មោះត្រង់ចំពោះ ប្ដីនិង ប្រពន្ធ
- អប់រំមនុស្សមិនត្រូវមានចិត្តផិតក្បត់ស្វាមីខ្លួន
- អប់រំមនុស្សឱ្យចេះប្រើប្រាជ្ញា
- អប់រំមនុស្សឱ្យចេះរកដំណោះស្រាយ
- អប់រំមនុស្សឱ្យចេះសង្កេតស្ថានការន៍
- ងប់រមមនុស្សឱ្យមានភាពស្មោហត្រង់
- អប់រំមនុស្សជឿលើកម្មផល។

សរុបជារួមមករឿងកាកី បានបង្ហាញមិនឱ្យស្ត្រីមានចិត្តផិតក្បត់ស្វាមី មានភាពស្មោះត្រង់ កុំឱ្យមានការលោបលន់ចង់បានរបស់អ្នកដទៃ និងធ្វើឱ្យមនុស្សដឹងកំហុសរបស់ខ្លួន។

# សង្ខេបរឿង ចៅស្រទបចេក

កាលនោះមានសេដ្ឋីម្នាក់ឈ្មោះ ធនសេដ្ឋី នៅស្រុកនិគមក្រោម នានគរហង្សាវត្តី ដែលមានទ្រព្យសម្បត្តិច្រើនរហូតដល់៨០កោដិឃ្លាំង ។ នៅស្រុកមួយទៀតក្នុងនគរដ៏ដែល គឺស្រុកបច្ចន្តក្រោម មានសេដ្ឋីម្នាក់ទៀតឈ្មោះ ថា ភោគសេដ្ឋី គឺជាអ្នកមានស្តុកស្តម្ភដូចគ្នា តែអភ័ព្វត្រង់គ្មានកូនស្នង ត្រកូល ។ ក្រោយមកឮដំណឹងថានៅវត្តព្រះធាតុសក្តិសិទ្ធិ អ្នកគ្មានកូនចៅទៅ បន់ស្រន់បានដូចចិត្តសេដ្ឋីទាំងពីរបានទៅដល់ទីនោះដំណាលគ្នាដើម្បីបន់ស្រន់សុំបុត្រ ហើយក៏បានសុំគ្នាធ្វើក្លើម្រាក់ដោយសន្យាថា បើម្នាក់មានកូន ប្រុស ម្នាក់ទៀតមានកូនស្រីនឹងធ្វើជាដន្លងនឹងគ្នា តែបើប្រុសឬស្រីដូចគ្នានឹង ធ្វើជាក្លើម្រាក់នឹងគ្នា។ ក្រោយមកធនសេដ្ឋីមានកូនប្រុសមួយដែលជាតួអង្គ ពោធិសត្វ ។ ចំណែកឯនាងដែលជាកន្សែសារពេជ្ជក៏មកចាប់កំណើតនឹងភោគសេដ្ឋី ពួកគេបានដឹងដំណឹងពីគ្នាទៅវិញទៅមកអំពីបុត្រ ដោយហេតុថា ទេវបុត្រដែលមកចាប់កំណើតក្នុងផ្ទៃនៃភរិយាធនសេដ្ឋីជាអនាគតនអង្គពោធិសត្វបានបណ្តាលឱ្យធនសេដ្ឋីកើតមានសេចក្តីជ្រះថ្លា ហើយក៏បានបរិច្ចាគទ្រព្យ ធនដែលខ្លួនមានទៅដល់ជនក្រីក្រស្លួមយាចក ចំណេរកាលក្រោយមកធន សេដ្ឋីក៏រលំរលាយអស់ទ្រព្យសម្បត្តិគ្មានសល់ គាប់ជួននៅពេលនោះព្រះឥន្ទ្រ។ ន្ទ្រាធិរាជចាស់ត្រូវអស់បុណ្យដែលជាហេតុនាំឱ្យគេទៅអញ្ជើញធនសដ្ឋីឡើងទៅសោយរាជ្យនៅឋានលើ ។

នៅពេលធនសេដ្ឋីស្លាប់ទៅ នាងជាប្រពន្ធគ្មានសល់ទ្រព្យសម្បត្តិអ្វីធ្វើបុណ្យ ហើយក៏រស់នៅជាអ្នកសុំទានគេពីស្រុកមួយទៅស្រុកមួយយ៉ាងក្រលំបាកពន់ពេក នាងជាម្តាយក៏នឹកឃើញអតីតក្លើម្រាក់របស់សេដ្ឋី ជាប្តីក៏ធ្វើដំណើរទៅដល់ផ្ទះលោកភោគសេដ្ឋី ជួបនឹងអ្នកយាម អ្នកយាមក៏ទៅ ប្រាប់ភោគសេដ្ឋី ភោគសេដ្ឋីគិតថាពីមុនវាមិនអីទេ តែឥឡូវដល់ថ្នាក់សុំទាន គេទៅហើយម្តេចកើត ក៏ឱ្យអ្នកយាមទៅប្រាប់ថា គាត់មិនស្គាល់មិនដែល នឹងដឹងអ្វីទេ។ ដោយសារតែនាងចេះតែចចេសចង់ជួបមុខសេដ្ឋី លោកសដ្ឋីក៏បាន ឱ្យអ្នកយាមវាយធ្វើបាបទៅលើនាងជាម្តាយជាទម្ងន់ ហើយក្រោយមកក៏ត្រូវ ស្លាប់នៅក្នុងព្រៃ ។ ចៅស្រទបចេកក៏អស់ទីពឹងពាក់ ។ ដោយចង់រកលុយដើម្បី បការសនម្តាយ ចៅស្រទបចេកក៏បានយកបន្ទោងដែលនៅជាប់នឹងកទៅលក់ ដើម្បីទិញក្តារមឈូស និងជួលគេឱ្យជួយបញ្ចុះសពម្តាយ ។ ដោយគ្មានអ្វីទ្រាប់ បាតមឈូសវាក៏ដោះសម្លៀកបំពាក់របស់វាយកទៅទ្រាប់បាតមឈូសឱ្យម្តាយទៀត ហើយវាយកស្រទបចេកមកចងដើម្បីបិទបាំងរាងកាយ ។ ចៅស្រទបចេកបានដេកចាំផ្នូររបស់ម្តាយ ហើយនៅថ្ងៃមួយវាបាននឹកឃើញដល់បណ្តាំ ម្តាយផ្តាំថា សុំឱ្យវាទៅរកគ្រូអាចារ្យម្នាក់សុំស្នាក់អាស្រ័យ និងរៀនសូត្រផង ។

ក្រោយមក ចៅចេកក៏ធ្វើដំណើរទៅដល់ផ្ទះគ្រូអាចារ្យទិសាបាមោក្ខដើម្បីធ្វើជាអ្នកបម្រើគេ ហើយពីដំបូងនេះឥតបានរៀនសូត្រអ្វីទេ ។ និយាយពីបុត្រីរបស់លោកភោគសេដ្ឋីឈ្មោះនាង កេសរមាលា នៅ ពេលដែលនាងឃើញឪពុកឱ្យអ្នកយាមវាយធ្វើបាបលើអ្នកទាំងនោះនាងមានចិត្តអាណិតអាសូរ ហើយនាងចំណាំមុខយ៉ាងច្បាស់តែនាងពុំដឹងជាធ្វើដូចម្តេច ហើយការអាណិតអាសូរពីមួយថ្ងៃទៅមួយថ្ងៃកើនឡើង ក៏បណ្តាលឱ្យនាងមានទំងឺ លោកសេដ្ឋីពុំដឹងធ្វើម៉េចឱ្យកូនរបស់ខ្លួនជាសះស្បើយ នៅថ្ងៃមួយ នាងនឹកឃើញថាបើនាងទៅនៅឯផ្សារប្រហែលជានាងមានឱកាសជួបចៅស្រទបចេកម្តងទៀត ។ នាងក៏បានសុំឪពុកធ្វើហាងលក់ដូរមួយនៅឯផ្សារ ហើយ លោកភោគសេដ្ឋីក៏បានអនុញ្ញាតដែរ តាមពិតទៅគឺនាងមានបំណងដើម្បី ស៊ើបរកចៅស្រទបចេកនេះឯង ។ ក្រោយមកនាងក៏បានស៊ើបដឹងតាមរយៈកូន សិស្សម្នាក់នៃលោកអាចារ្យ ហើយនាងក៏ឱ្យសិស្សម្នាក់នោះហៅចៅស្រទបចកមកដើម្បីនាងបានធ្វើទានជាសម្លៀកបំពាក់ ។ ឮដល់លោកអាចារ្យ គាត់ក៏ ដេញចៅស្រទបចេកឱ្យទៅ តែចៅស្រទបចេកពុំហ៊ានចូលទ ៌ ព្រោះពេល ឃើញនាងកសរមាលា វាក៏នឹកឃើញដល់លោកភោគសេដ្ឋីចិត្តមារ ក៏រត់គេច ទៅសាលាវិញ លោកអាចារ្យក៏ស្តីបន្ទោសឱ្យវា។ វាក៏ដោះស្រាយថា សម្លៀក បំពាក់មិនសក្តិសមនឹងខ្លួន ហើយវាក៏នឹងមានគ្រោះថ្នាក់ ។ ក្រោយមក នាង កេសរមាលាក៏បានបើឱ្យទាសីរបស់នាងទៅហៅដល់សាលា តចៅស្រទប- ចេកនៅតែមិនព្រមទៅ ។ ដល់ពេលរដូវចូលឆ្នាំមកដល់ លោកអាចារ្យក៏មាន ចិត្តធម៌មេត្តាឱ្យលុយ១កាក់ទៅដើរលេងសប្បាយជាមួយគ ។ ពេលបានលុយ ចៅចេកក៏នឹកឃើញចង់ទៅទិញនំទៅសែនផ្នូរម្តាយ តែខ្លាចជួបនាងកេសរមាលា ។ នាងកេសរមាលាក៏ឱ្យគេចាប់ចៅស្រទបចេកនៅកន្លែងលក់នំដើម្បី បង្ហាញពីទឹកចិត្តរបស់នាងថានាងមិនដូចជាឪពុកនាងទេពេលចាប់ចៅចេក ចូលដល់ក្នុងផ្ទះ នាងបានលត់ជង្គង់ ហើយសំពះតាមអាការៈជាស្រីគ្រប់លក្ខណ៍ និងអង្វរករឱ្យចៅស្រទបចេកទទួលយកនំចំណីសម្លៀកបំពាក់ពីនាង ។

ត្រឡប់មកផ្ទះវិញចៅស្រទបចេកក៏សុំលោកអាចារ្យចេញរកស៊ី លោកអាចារ្យក៏ឱ្យចៅចេកលក់នំអាកោរ ។ ក្រោយមកក៏ឱ្យចៅចេកបានរៀនសូត្រនឹងគេ ។ ដោយហេតុថាចៅស្រទបចេកជាតួរង្គពោធិសត្វ វាក៏រៀនពូក ជាងសិស្សឯទៀតៗ ។

សម័យថ្ងៃមួយព្រះរាជាឈានចូលដល់វ័យចំណាស់ ទ្រង់កើតមានគំនិតរកអ្នកស្នងរាជ្យ ទ្រង់ក៏ដាក់បញ្ជាឱ្យគេរកមនុស្សមានបុណ្យដោយផ្សង ដំរីមកដល់ស្រុកដែលចៅស្រទបចេករស់នៅ តាអាចារ្យបាននាំសិស្សទាំង អស់ទៅគាល់ស្តេចដើម្បីធ្វើការជ្រើសរើស ចៅស្រទបចេកក៏ត្រូវទៅដែរ ។ ទៅជិតដល់រាជដំណាក់ លោកអាចារ្យបានឃាត់ចៅចេកឱ្យនៅមើលអីវ៉ាន់រៀន ។

និយាយពីព្រះឥន្ទ្រាធិរាជថ្មីនៅពេលបានជួបនឹងប្រពន្ធវិញគឺនាង សុជាតា ទ្រង់នឹកគិតទៅដល់បុត្ររបស់ព្រះអង្គ ហើយនៅពេលទតឃើញថា បុត្រកម្សត់ខ្លាំងពេក ទ្រង់ក៏បានកាឡាខ្លួនជាតាចាស់ម្នាក់ចុះមក យកបង្វិចមក ផ្ញើចៅស្រទបចេកផងដែរ ។ នៅពេលមានហ្វូងដំរីសេះចូលមកនិងដោយមាន អីវ៉ាន់ច្រើនផង ពិបាកកាន់ហើយខ្លាចបាត់ ចៅចេកក៏រើយកបង្វិចរបស់តាចាស់ មកពាក់តាមបណ្តាំ ។ ស្លៀកពាក់រួច ដំរីជ័យក៏មកដល់ល្មម ហើយលុតជង្គង់ នៅចំពោះមុខចៅស្រទបចេក ចៅស្រទបចេកក៏ត្រូវបានអភិសេកជាស្តេចយ៉ាងគគ្រឹកគគ្រេងក្រោមការបាចផ្កាជូនពរជ័យពីទេវតាផង ដោយមាននាមថា ទេវវង្សកុមារ ។ ពេលចប់ព្រះរាជពិធីទៅ ចៅស្រទបចេកនៅតែកើតទុក្ខ ហើយនៅតែនឹកឃើញដល់នាងកេសរមាលា ពុំសោយអ្វី ពុំនិយាយអ្វី ។ ព្រះនាង កេសរបុប្ផា ជាមហេសីក៏ដណ្តឹងសួរព្រះស្វាមីយល់សេចក្តីសព្វគ្រប់ ប្រការ ។ ទេវវង្សកុមារនិងមហេសីក៏ធ្វើដំណើរទៅស្រុកបច្ចន្តគ្រាម ជាស្រុក ភោគសេដ្ឋី ទ្រង់កើតឈឺចិត្តចង់រកយុត្តិធម៌ឱ្យមាតា ពេលនោះទ្រង់ក្លែងខ្លួនរើជាប្រជារាស្ត្រសាមញ្ញ ហើយបានពឹងមេស្រុកទៅស្តីដណ្តឹងកូនសេដ្ឋី។ ថ្ងៃមួយ លោកសេដ្ឋីយល់ដល់មុខចៅហ្វាយស្រុក គេឱ្យមកវិញ ។ ថ្ងៃទីពីរទៅដណ្តឹងម្តង ទៀត ត្រូវគេជេរប្រទេច ។ ថ្ងៃទីបីទៅទៀត ចង់ប៉ើងទាំងមេស្រុក ហើយចង់ ទិញក្បាលអ្នកដែលចង់ដណ្តឹងកូនគាត់កាប់ចោល ទ្រង់ក៏ចេះកត់បណ្តើរៗ បានភ័ស្តុតាងសព្វគ្រប់ ក៏បើកសវនាការបញ្ជាឱ្យគេនាំខ្លួនភោគសេដ្ឋីមក។ នៅ ពេលអ្នកទាំងនោះទៅដល់ផ្ទះសេដ្ឋី សេដ្ឋីក៏សុំជូន៥ណែន ក្រោយមក១ពែង ហាបប្រាក់ តតតមាននរណាហ៊ានទទួល។ សេដ្ឋីទាមទារសាក្សី ពេលនោះគ ក៏យកនាងកេសរមាលាមកធ្វើជាសាក្សី ប្រសិនបើនាងឆ្លើយថាមិនដឹងទង់ នឹងឱ្យគេកាត់សិរសាដោតលើឈើ ពេលនោះសេដ្ឋីអរណាស់ព្រោះយកកូន ស្រីមកធ្វើសាក្សី នាងកេសរមាលាចូលដល់ទីសវនាការ នាងអត់មាត់កអ្វី ទាំងអស់ ព្រោះបើនាងនិយាយច្បាស់ជាមាននរណាម្នាក់ស្លាប់ជាមិនខាន ។ ក្រោយមកនាងក៏សុំឱ្យព្រះអង្គប្រទានពរ នាងសុំតែមួយគឺសត្វដែលត្រូវបាត់ បង់ជីវិត ត្រូវឱ្យលើកលែងទោស ហើយនាងក៏បានប្រាប់តាមត្រង់នូវអ្វីដែលនាងបានដឹង ។

ភោគសេដ្ឋីចាញ់ក្តី ក៏ត្រូវធ្វើទារុណកម្ម តែមិនឱ្យស្លាប់ទេ ហើយ បណ្តើរតាមផ្សារមិនឱ្យអ្នកស្រុកយកតម្រាប់តាម ។ ក្រោយមកចៅស្រទប ចេកទ្រង់ព្រះភស្តាជាព្រះមហាក្សត្រ ហើយក៏ចាត់អភិសេកយ៉ាងអធិកអធម សមរម្យតាមប្រពៃណី ។ ដើម្បីស្រោចស្រង់កិត្តិយសឪពុកនាងក៏សំណូមពរ ឱ្យទ្រង់ដោះលែងឪពុក ។ រីឯលោកមេស្រុកក៏បានឡើងជាមហាតលិក ហើយឪពុកក្មេកឡើងជាមេស្រុក រួចទ្រង់ក៏វិលចូលព្រះបរមរាជវាំងវិញរស់នៅយ៉ាង សុខសាន្តតរៀងទៅ ។

## ១.សេចក្តីវិភាគរឿង

### ក.អត្ថន័យខ្លឹមសារ

អត្ថន័យអត្ថប្រយោជន៍ អត្ថន័យ ការណែនាំ អត្ថាធិប្បាយ សេចក្តីពន្យល់ អត្ថន័យ ជាគំនិត សំខាន់ៗរបស់អ្នកនិពន្ធ ដែលលាតត្រដាងនៅក្នុងដំណើររឿង ហើយគេអាចហៅវាថាជាជម្រៅនៃរឿង។ ក្នុងផ្នែកអត្ថន័យមាន ប្រធានរឿង មូលបញ្ហារឿងនិងឧត្តមគតិរឿង។

### ខ.ប្រធានរឿង មូលន័យ

ប្រធានរឿងឬមូលន័យ គឺជាគំនិតសំខាន់ៗរបស់រឿង។ ប្រតិឬជាបញ្ហារួមរបស់រឿង។ តែអ្នកនិពន្ធចង់បង្ហាញដល់អ្នកអានប្រធានរឿងជាបញ្ហារួបផ្តុំបំផុតដែលអ្នកនិពន្ធលើកយកមកសរសេរឬជ្រើសរើសជាប្រធានបទហើយដែលមានមូលបញ្ហារឿងឋិតនៅក្នុងនោះ។

ប្រធានរឿងបង្ហាញនៅចំហររបស់អ្នកនិពន្ធវាជាមូលដ្ឋានដើមរបស់អ្នកនិពន្ធក្នុងការចាប់ផ្តើមសរសេរឡើង។មុនពេលចាប់ផ្តើមសរសេរឡើង។អ្នកនិពន្ធគ្រប់រូបត្រូវកំណត់ថាតើគាត់ត្រូវសរសេរអំពីអ្វី។អំពីជីវិតសង្គមសង្គ្រាមស្នេហារឿងជំនឿទនៀមទម្លាប់ប្រពៃណី ចម្លើយរបស់សំណួរនេះហើយជាប្រធានរឿង។

តាមរយៈរឿងចៅស្រទាប់ចេក និយាយរៀបរាប់ពីដំណើរជីវិតចៅស្រទាប់ចេក ព្រះពោធិសត្វ។

## គ.មូលបញ្ហារឿង

មូលបញ្ហារឿងគឺជាភាពចំណែកនៃប្រធានរឿងជាទិដ្ឋភាពផ្សេងៗរបស់យើង។វាជាការចូលជ្រៅទៅក្នុងប្រធានរឿង។

ជុំវិញប្រធានរឿងនេះ យើងបានកំណត់បញ្ហាជាច្រើន ដែលនៅជុំវិញការកសាងសីលបារមីរបស់ព្រះពោធិសត្វ។ បញ្ហាទាំងនោះរួមមានៈ

### ទី១ បញ្ហាដើរសុំទាន

នៅពេលជនសីដ្ឋីនៅរស់បានធ្វើបុណ្យដាក់ទាន ដល់ស្មូមយាចក និងអ្នកកម្សត់ទុគតរហូតអស់ទ្រព្យពីខ្លួន។ បន្ទាប់មកជនសេដ្ឋីបានស្លាប់ទៅនាងជាប្រពន្ធគ្មានទ្រព្យសម្បត្តិអ្វីក៏ដើរសុំទានគេ។ នាងម្តាយបាននឹកឃើញក្លើមម្រាក់ខ្លើសេដ្ឋីបានទៅផ្ទះសេដ្ឋី ។ ភោគសេដ្ឋីថាមិនស្គាល់ឱ្យអ្នកបម្រើវាយធ្វើបាបម្តាយជាទម្ងន់ហើយម្តាយក៏ស្លាប់ទៅ។ ចៅស្រទាប់ចេកបានដោះសម្លៀកបំពាក់ព្រោះគ្មានអ្វីទ្រប់បាតបឈូសឱ្យម្តាយ ចៅចេកបានយកស្រទាប់ចេកមកស្លៀកបិតបាំងរាងកាយ។

សរុបមកភាពកតញ្ញូចំពោះ អ្នកមានគុណដែលយើងគួរធ្វើរាល់រូប ជាអំពើដែលមិនសាបសូន្យ និងឱ្យផលមកយើងវិញគ្រប់ពេលវេលា។

### ទី២បញ្ហាមករស់នៅជាមួយអាចារ្យ

នៅពេលដែលចៅស្រទាប់ចេក បានទៅរស់នៅជាមួយគ្រូអាចរ្យ ដើម្បីរស់នៅ និងរៀនសូត្រ មុនដំបូងធ្វើជាអ្នកបម្រើគេ ។ បន្ទាប់មកបានរៀនសូត្រ ហេតុតែតួអង្គព្រះពោធិសត្វបានរៀនពូកែលើសសិស្សឯទៀត។ ក្រោយមកបុត្រីភោគសេដ្ឋីនាងកេសរមាលា បាននឹកឃើញបញ្ហាឱ្យអ្នកបម្រើធ្វើបាបម្តាយចៅចេកមានចិត្តអាណិតរហូតដល់ថ្លាក់ខ្លួនឈឺ បានសុំសេដ្ឋីជាឪពុក តៅលក់ដូនៅឯផ្សាបំណងតាមរកចៅចេក ។ នាងបានដំណឹងចៅចេកឱ្យមកយកសម្លៀកបំពាក់តែចៅចេកមិនមកយក។ ពេលចុលឆ្នាំអាចារ្យឱ្យលុយចៅចេកមួយណែនដើរលេងចូលឆ្នាំ តែចៅចេកបានយកលុយនោះទៅទិញនំអាកោឱ្យម្តាយ ។ នាងកេសរមាលាបានណើញចៅចេកបានបញ្ហាអ្នកបម្រើឱ្យទៅចាប់ចៅចេកបានសុំអង្វរចៅចេកក៏ព្រមទទួលយក។

ការចេះរស់នៅ ជាមួយអ្នកដ៏ទៃបានជួយឱ្យយើងបាននូវអ្វីដែលថ្មីៗ និងជាបទពិសោធក្នុងជីវិតក្នុងការរស់នៅផងដែរ។

### ទី៣ បញ្ហាឡើងសោយរាជ្យ

សម័យថ្ងៃមួយព្រះរាជាចូលរ័យចំណាស់បានមានគំនិតរកអ្នកមានបន្តស្នងរាជ ដោយដំរីផ្សងរកអ្នកមានបុណ្យ បានមកដល់ស្រុកដែលចៅចេករស់នៅ។ អចារ្យបាននាំសិស្សទាំងអស់ទៅគាល់ស្តេច ប៉ុន្តែចៅចេកនៅចាំសម្ភារៈមិនបានចូលទៅទេ។ ព្រះឥន្ទបានមើលមកបុត្រឃើញបុតមរកសត់វេទនាបានបាននិម្មិតជាព្រានចាស់យកបង្វិចឱ្យចៅចេកផ្តាំឱ្យស្លៀកពាក់ ចៅក៏ធ្វើតាមពេលស្លៀកពាក់រួចដំរីបានមកលុតជង្គងថ្វាយបង្គំ ក៏បានអភិសេកឡើងសោយរាជ្យជាស្តេចទៅ។ បន្ទាប់មកចៅចេកនឹកនាងកេសរមាលាមិនសោយ មិននិយាយ ព្រះនាងកេសរបុប្ផាបានសួរដឹងរឿង។ ទេវវង្សកុមារនិង មហេសី ធ្វើដមណើរទៅស្រុកបច្ចន្តគ្រាមបានតែងខ្លួន ជារាស្ត្រសាមញ្ញបានពឹងមេស្រុកឱ្យទៅស្តីដណ្តឹងនាងកេសរមាលាសេដ្ឋីមិនយល់ព្រម។ ពេលបានភ័សតាំងហើយបើកសារនាការយកនាងកេសរបុប្ផាធ្វើជាសាក្សី នាងបាននិយាយការពិតសេដ្ឋីក៏ចាញ់ក្តីទៅ។

សរុបមកអ្នកដឹកនាំ គួរធ្វើនូវអ្វីដែលស្មោះត្រង់សុចរិតត្រឹមត្រូវ ចំពោះអ្នកដទៃនិងខ្លួនឯង និងធ្វើឱ្យជួបតែសេចក្តីសុខសាន្តគ្រប់ទីកន្លែង។

## ឃ.ឧត្តមគតិរឿងគំនិតដឹកនាំរឿងតម្លៃអប់រំ

ឧត្តមគតិរឿងគឺជាឧត្តមគតិរបស់អ្នកនិពន្ធ។ឧត្តមគតិរឿងគឺយកកក្តាប្រធានវិស័យដែលបញ្ហាដែលបញ្ជាក់ពីគោលជំហរសតិអារម្មណ៍របស់អ្នកនិពន្ធដែលស្តែងឡើងតាមរយៈសកម្មភាពរបស់តួអង្គ។

- អប់រំមនុស្សឱ្យចេះទទួលស្គាលនូវកំហុសខ្លួនឯង
- អប់រំមនុស្សឱ្យមានភាពកតញ្ញូ
- អប់រំមនុស្សឱ្យមានចក្តអាណិតអាសូរ
- អប់រមមនុស្សមិនឱ្យរើសអើងគ្នា
- ងប់រំមនុស្សឱ្យចេះស្តាបញដំបូន្មានង្នកមានគុណ
- អប់រំមនុស្សឱ្យជឿលើកម្មផល។

សរុបជារួមមករឿងចៅស្រទាប់ចេកបាន បង្ហាញពីភាពតស៊ូ អំណត់ព្យាយាម ភាពកតញ្ញូចំពោះអ្នកមានគុណ និងមានធម៌ខន្តីធ្វើឱ្យមនុស្សប្រព្រឹត្តអំពើល្អគ្រាប់យ៉ាង។

# សង្ខេបរឿង ពុទ្ធសែននាងកង្រី

កាលនោះមានសេដ្ឋីពីរនាក់ប្តីប្រពន្ធមានទ្រព្យសម្បត្តិស្តុកស្តម្ភ ប៉ុន្តែគ្មានកូនសោះ។ គិតហើយ ពីរនាក់ប្រពន្ធក៏សម្រេចទៅបួងសួងសុំកូនពីរទេវតាដើមជ្រៃមួយ។ ក្រោយមកប្តីប្រពន្ធទាំងពីរក៏កើតបានកូនស្រី ១២នាក់។ តាំងពីកើតបានកូនទាំង១២នាក់មក ទ្រព្យសម្បត្តិសេដ្ឋីក៏បានថយចុះបន្តិចម្តងៗ ដោយសារចំណាយទៅលើការផ្គត់ផ្គង់ចំពោះកូនស្រីទាំង ១២នាក់។ ពួកគេបានធ្លាក់ខ្លួនក្រលំបាកដោយស៊ូទ្រាំនឹងជីវភាពដូច្នេះពុំបាន ពួកគេក៏បានសម្រេចចិត្តយកកូនទាំង១២ទៅបំបោះបង់ចោលនៅក្នុងព្រៃ។ មុនដំបូងឪពុកថាចង់ទុកកូនពៅនៅជាមួយ តែខ្លាចពួកបងៗគិតថាឪពុកម្តាយលម្អៀងក៏បំបោះបង់កូនទាំង១២ទៅ។ នាងទាំង១២ក្រោយពីដឹងថាត្រូវឪពុកម្តាយបំបោះបង់ខ្លួនចោល ពួកនាងនាំគ្នាយំស្រែកយ៉ាងខ្លាំងដោយមិនដឹងថាគួរធ្វើយ៉ាងណានៅថ្ងៃក្រោយឡើយ។ បន្ទាប់មកពួកនាងបានធ្វើដំណើរទៅមុខដោយគ្មានគោលដៅ បេះស្លឹកឈើ និងផ្លែឈើព្រៃធ្វើជាអាហារ។ ពេលមួយពួកនាងបានចុះចាប់ត្រីក្នុងបឹងមួយ ពួកបងៗទាំង១១នាក់សុទ្ធតែដោយភ្នែកត្រីទាំងសងខាង មានតែនាងពៅទេដែលដោយភ្នែកត្រីតែម្ខាង នាំគ្នាឆីរួចក៏បន្តដំណើរទៅមុខទៀត។ លុះធ្វើដំណើរយូរខែយូរឆ្នាំទៅក៏បានទៅដល់នគរយក្សសន្ធមារ។ កាលបើយក្ខសន្ធរមារឃើញនាងទាំង១២ យក្សសន្ធមារប្រាប់កង្រីជាកូនឲ្យក្រឡាខ្លួនជាក្មេងអាយុ៣ឆ្នាំគេងក្នុងអង្រឹងទៅ ហើយម្តាយនាងសុំឲ្យពួកនាងជួយមើល។ យក្ខសន្ធមារដោយបានលឺថានាងទាំង១២ជាកូនកំព្រានាងសប្បាយចិត្តណាស់ ហើយបានឃាត់ពួកនាងឲ្យនៅជាមួយធ្វើឲ្យនាងទាំង១២មានចិត្តត្រេកអរណាស។ យក្ខសន្ធមារបានហាមឃាត់មិនឲ្យពួកនាងទៅលេងឃ្លាំងទក្សិណទេ ដោយសារជាកន្លែងទុកចំណីអាហាររបស់ខ្លួន តែសន្ធមារបានកុហកពួកនាងថាជាកន្លែងមានគ្រោះថ្នាក់ រីឯទឹកស្រះអាចឲ្យកើតរមាស់។ ថ្ងៃមួយនាងពៅបានធ្វើឲ្យបាយក្រពប់ពេញដី ពេលនោះមានខ្មោចចេញមកស៊ីបាយទាំងនោះ ធ្វើឲ្យនាងពៅភ័យស្រែកប្រាប់បងៗឲ្យចេញពីកន្លែងនោះ ដោយបានដឹងពីល្បិចរបស់យក្ខ ដែលចិញ្ចឹមពួកនាងទុកសម្រាប់ធ្វើជាចំណីនៅថ្ងៃក្រោយ។ ចំណែកឯឃ្លាំង និងស្រះដែលយក្ខមិនឲ្យពួកនាងទៅនោះ សុទ្ធតែជាសាកសព និងគ្រោងឆ្អឹងមនុស្ស ហើយមានស្រះពោរពេញទៅដោយឈាម។ បន្ទាប់ពីដឹងរឿងរ៉ាវពិតប្រាកដមក ហេតុតែមានចិត្តភ័យខ្លាចនឹងយក្ខ ពួកនាងក៏បានសម្រេចចិត្តលួចចេញពីនគរយក្ខ ដោយបានលួចយកម្ជុលម្នាក់មួយទៅជាមួយ ហើយរត់សំដៅទៅក្នុងព្រៃជ្រៅ។ ពេលនោះក្អែកដែលសន្ធមារចិញ្ចឹមបានប្រទះឃើញនាងទាំង១២លួចរត់ ក៏យកដំណឹងនេះទៅប្រាប់សន្ធមារ សន្ធមារខឹងយ៉ាងខ្លាំង ហើយក៏ចេញទៅចាប់ពួកនាងមកវិញ។ ពេលនាងទាំង១២ លឺសូរសន្ធឹកយក្សហោះមក ក៏បានរត់ទៅជួបនឹងដំរី គោ និងឈ្លូស។ សត្វទាំងនោះបានជួយពួកនាងឲ្យគេចផុតពីភ្នែកយក្ខដោយលេបពួកនាងចូលពោះ ហើយបាននិយាយបំភ័យយក្ខឲ្យចេញ។ ពួកនាងធ្វើដំណើរទាំងថ្ងៃទាំងយប់ក៏ទៅដល់នគរគន្ធបត្តបុរី ហើយក៏បានជួបស្រះមួយដែលមានទឹកថ្លាឈ្វេង ពួកនាងយកម្ជុលដែលលួចពីយក្ខមកពាក់រៀងៗខ្លួន ពេលនោះមានអ្នកបម្រើរបស់សេដ្ឋីម្នាក់បានប្រទះឃើញពួកនាងហាក់បីដូចជាទេពអប្សរទាំង១២ មានសម្រស់ដូចស្រីសួគ៌ ហើយក៏យកដំណឹងនេះទៅប្រាប់សេដ្ឋី ចំណែកឯសេដ្ឋីក៏យកដំណឹងនេះទៅទូលស្តេចបន្តទៀត។ ពេលព្រះបាទរថសិទ្ធិជួបនឹងនាងទាំង១២ ទ្រង់បានស្ព័ដណ្តឹងពួកនាងជាមហេសី កន្លងប៉ុន្មានខែក្រោយមកនាងទាំង១២ ក៏មានគភ៌ ដំណឹងនេះបានលេចលឺដល់យក្ខសន្ធមារ នាងខឹងខ្លាំងណាស់ក៏ក្រឡាខ្លួនជាស្រីស្អាតមកពង្វក់ព្រះបាទរថសិទ្ធិ បន្ទាប់មកសន្ធមារបាននៅក្បែរខ្លួនស្តេចរហូត។ មានថ្ងៃមួយយក្ខសន្ធមារមានកលល្បិចបានកុហកស្តេចថាខ្លួនឈឺ ហើយបានប្រាប់រាជពេទ្យឲ្យកុហកស្តេចថាត្រូវការភ្នែករបស់នាងទាំង១២មកព្យាបាលទើបជា។ ដោយសារឈ្លក់វង្វេងនឹងនាងខ្លាំងពេក ព្រះបាទរថសិទ្ធិបានធ្វើតាមសម្តីរបស់រាជពេទ្យ ខ្វេះភ្នែកនាងទាំង១២។ ពេលនោះបងទាំង១១សុទ្ធតែត្រូវគេឆ្កៀលភ្នែកទាំងសងខាង មានតែនាងពៅទេដែលត្រូវគេឆ្កៀលភ្នែកតែម្ខាង។ បន្ទាប់មកពួកនាងត្រូវបានបណ្តេញចេញពីរាជវាំងឲ្យទៅរស់នៅក្នុងល្អាងមួយ។ នាងពៅដែលនៅមានភ្នែកម្ខាងជាអ្នកមើលថែទាំពួកបងៗ។ ចំណែកឯភ្នែករបស់នាងទាំង១២ សន្ធមារបានយកទៅផ្ញើកង្រីឲ្យថែរក្សាទុកនៅនគរយក្ខ។

ដល់ពេលបុត្ររបស់នាងទាំង១២ប្រសូត ដោយការស្រេកឃ្លាន ពួកនាងបានយកបុត្ររបស់ខ្លួនហែកចែកគ្នាធ្វើជាចំណី មានតែនាងពៅទេបានលាក់សាច់ទុក ហើយនៅពេលដែលនាងប្រសូតបុត្រ នាងបានទុកកូនរបស់ខ្លួន និងយកសាច់ដែលខ្លួនទុកនោះចែកបងៗឆីនាងខិតខំចិញ្ចឹមបីបាច់កូនមិនឲ្យបងៗដឹងឡើយ។ នាងពៅដាក់ឈ្មោះរបស់កូនថាពុទ្ធិសែ

ន។ ដោយសារពុទ្ធិសែនជាតួអង្គព្រះពោធិសត្វមកចាប់ជាតិទើបមានទេវតាតាមថែរក្សាមករហូត។

ពេលពុទ្ធសែនអាយុបាន៧ឆ្នាំ ព្រះអង្គបានជជីកសួរពីមូលហេតុដែលមករស់នៅក្នុងល្អាងបែបនេះ នាងពៅបានប្រាប់កូនពីដំណើររឿង ពេលស្តាប់ហើយពុទ្ធសែនរន្ធត់ចិត្តអាណិតមាតាក្រៃលែង។ ដោយសារចង់ដឹងពីពិភពខាងក្រៅ ពុទ្ធិសែនបានសុំមាតាមកលេងខាងក្រៅ ដើម្បីស្គាល់គេឯង ហើយចង់ស៊ើបដំណឹងបិតារបស់ខ្លួន។ ពេលចេញមកក្រៅដើម្បីស្គាល់គេឯងវាបានជួបក្មេងមួយក្រុម ហើយបបួលគ្នាលេងបាញ់អង្គុញ គេភ្នាល់គ្នាថាបើពុទ្ធសែនចាញ់ នឹងត្រូវបម្រើពួកក្មេងៗ ទាំងនោះ តែបើពុទ្ធសែនឈ្នះគេសុំតែបាយ១២កញ្ចប់ទេ។ ជារៀងរាល់ថ្ងៃពុទ្ធសែនតែងតែឈ្នះបានបាយ១២កញ្ចប់យកទៅឲ្យមាតា និងព្រះមាតុច្ឆាទាំង១១អង្គ ធ្វើឲ្យបងៗមានចម្ងល់ជាខ្លាំង មិនយូរប៉ុន្មាននាងពៅក៏បានបកស្រាយចម្ងល់របស់បងៗ។ ជ័យជំនះរបស់ពុទ្ធសែនក្នុងការលេងបាញ់អង្គុញបានលេចលឺដល់ព្រះមហាក្សត្រ។ ព្រះបាទរថសិទ្ធិឲ្យអាមាត្យហៅពុទ្ធសែនចូលក្នុងរាជវាំង ពុទ្ធសែនគ្រាន់តែបានជួបភ្លាមព្រះអង្គក៏ដឹងថានេះហើយជាព្រះបិតារបស់ខ្លួន។ ដោយសារតែទេវតាជួយពុទ្ធសែនបានយកឈ្នះព្រះបិតារបស់ខ្លួន។ ព្រះបាទរថសិទ្ធិបានបញ្ជាឲ្យគេទៅស៊ើបពីប្រវត្តិរបស់ពុទ្ធសែន ចុងក្រោយទើបដឹងថាពុទ្ធសែនជាបុត្របង្កើតរបស់ខ្លួន។ លុះដល់ស្អែកឡើង ព្រះបាទរថសិទ្ធិក៏បញ្ជាឲ្យអាមាត្យនាំកុមារពុទ្ធិសែនចូលវាំង ហើយទទួលស្គាល់ពុទ្ធិសែនជាបុត្រ ដំណឹងនេះបានធ្វើឲ្យសន្ទមារខឹងយ៉ាងខ្លាំង នាងបានចូលទៅជិតពុទ្ធសែន ធ្វើជាស្រឡាញ់ពុទ្ធសែនណាស់ តែតាមពិតទោគឺកំពុងតែរកល្បិចកលអាក្រក់ដើម្បីធ្វើបាបកុមារម្នាក់នេះ។ ច្រើនឆ្នាំកន្លងមក ពុទ្ធិសែនពេញរូបពេញរាង យក្ខសន្ទមារបានឲ្យពុទ្ធសែនទៅយកថ្នាំនៅនគររបស់ខ្លួន ដោយសារតែចង់ព្យាបាលព្រះរោគព្រះបាទរថសិទ្ធិ នាងបានភ្ជាប់សំបុត្រមួយទៅជាមួយផង។ ក្នុងការធ្វើដំណើរពុទ្ធសែនបានជ្រើសរើសសេះមណីកែវ ជាសេះអាចនិយាយភាសាមនុស្សបានទៅជាមួយ។ ពុទ្ធសែនបានក្រាបលាមាតា និងព្រះមាតុច្ឆា ហើយក៏ចេញទៅ។

ពេលធ្វើដំណើរតាមផ្លូវពុទ្ធសែនបានជួបនឹងខ្យល់យ៉ាងធំមួយធ្វើឲ្យពុទ្ធសែនសន្លប់នៅលើខ្នងសេះ ហើយមណីកែវបានហោះទៅកាន់អាស្រមតាឥសី។ តាឥសីបានបើកមើលសំបុត្រដែលនៅលើខ្លួនរបស់ពុទ្ធសែន ហើយបានជួយពុទ្ធសែនប្រែសារនោះពីទៅដល់ថ្ងៃសម្លាប់ថ្ងៃ ទៅដល់យប់សម្លាប់យប់មកទៅដល់ថ្ងៃរៀបការថ្ងៃទៅដល់យប់រៀបកាយប់ ពុទ្ធិសែនបន្តដំណើរទៅមុខទៀត។ទៅដល់ហើយកង្រីចាប់ផ្តើមរៀបពិធីអភិសេកក៏កើតឡើងរវាងកង្រីនិងពុទ្ធសែន។ ចាប់ពីពេលនោះមកពុទ្ធសែនបានសោយរាជ្យយ៉ាងសុខសាន្ត ហើយមានបុត្រាពីរអង្គជាមួយនឹងនាងកង្រីមានព្រះនាមថា រថសែននិងជ័យសែន។ព្រអនាងបានប្រាប់ពីវត្ថុទេព្វមាន ស្គរជ័យគោះទៅមានអារុតចេញមក ជាពិសេសកែវភ្នែកនាងទាំង១២។

នៅពេលមានឱកាសល្អ ពុទ្ធិសែនបានចូលទៅលួចកែវភ្នែកនាងទាំង១២ និងបេះថ្នាំស័ក្តិសិទ្ធិព្រមទាំងស្គរជ័យទៅជាមួយ ក្នុងគោលបំណងទៅជួយមាតា និងព្រះមាតុច្ឆារបស់ខ្លួន។ ពេលដែលពុទ្ធិសែនចេញបានបន្តិច នាងកង្រីបានដឹងហើយខំស្រែកអង្វរស្វាមីឲ្យត្រឡប់មកវិញ តែដោយសារសេះមណីកែវហោះយ៉ាងលឿន ធ្វើឲ្យនាងកង្រីតាមមិនទាន់។ ពុទ្ធិសែនបានទៅដល់នគរគន្ធបត្តបុរី សន្ទមារបានដឹងរឿងរ៉ាវទាំងអស់ដែលកើតឡើង ហើយក៏ក្លាយជារូបេពិតបំណងចង់សម្លាប់ពុទ្ធិសែនចោល តែពុទ្ធសែនបានដឹងមុនក៏យកស្គរជ័យគោះ បណ្តាលឲ្យអាវុធហោះចេញទៅចាក់សម្លាប់យក្ខសន្ទមារមួយរំពេច។ ព្រះអង្គរថសិទ្ធិបានភ្ញាក់រលឹកដឹងនូវកំហុសរបស់ខ្លួន ក៏ទទួលមហេសីទាំង១២ចូលមកក្នុងរាជវាំងវិញ ហើយពុទ្ធិសែនបានយកថ្នាំមកព្យាបាលភ្នែកមាតា និងព្រះមាតុច្ឆា។ ពេលបានបញ្ចប់ភារកិច្ចសព្វគ្រប់ហើយពុទ្ធិសែនបានសុំលាមាតាបិតាដើម្បីទៅរកមហេសី និងបុត្ររបស់ខ្លួនវិញ តែជាអកុសលនាងកង្រីបានស្លាប់បាត់បង់ជីវិតទៅហើយ ពុទ្ធិសែនឈឺចិត្តក្រៃលែង ទ្រង់បានធ្វើពិធីបុណ្យសពឲ្យមហេសីរបស់ខ្លួន។ ក្រោយពីពិធីបុណ្យសពរួចរាល់ ពុទ្ធិសែនបានត្រឡប់ទៅនគរមាតាបិតាវិញ។ បន្ទាប់មកទៀតព្រះបាទរថសិទ្ធិក៏បានឲ្យពុទ្ធិសែនបន្តសោយរាជ្យជំនួសព្រះអង្គ ហើយរស់នៅយ៉ាងសុខសាន្ត។

## ១.សេចក្តីវិភាគរឿង

### ក.អត្ថន័យខ្លឹមសារ

អត្ថន័យអត្ថ .ប្រយោជន៍.អត្ថន័យ .ការណែនាំអត្ថាធិប្បាយសេចក្តីពន្យល់.អត្ថន័យជាគំនិតសំខាន់ៗរបស់អ្នកនិពន្ធដែលលាតត្រដាងនៅក្នុងដំណើររឿង ហើយគេអាចហៅវាថាជាជម្រៅនៃរឿង។

ក្នុងផ្នែកអត្ថន័យមាន ប្រធានរឿង មូលបញ្ហារឿងនិងឧត្តមគតិរឿង។

## ខ.ប្រធានរឿង មូលន័យ

ប្រធានរឿងឬមូលន័យ គឺជាគំនិតសំខាន់ៗរបស់រឿង។ ប្រតិឬជាបញ្ហារួមរបស់រឿង។ តែអ្នកនិពន្ធចង់បង្ហាញដល់អ្នកអានប្រធានរឿងជាបញ្ហារូបផ្តុំបំផុតដែលអ្នកនិពន្ធលើកយកមកសរសេរឬជ្រើសរើសជាប្រធានបទហើយដែលមានមូលបញ្ហារឿងឋិតនៅក្នុងនោះ។

ប្រធានរឿងបង្ហាញនៅចំហររបស់អ្នកនិពន្ធ វាជាមូលដ្ឋានដើមរបស់អ្នកនិពន្ធ ក្នុងការចាប់ផ្តើមសរសេរឡើង។មុនពេលចាប់ផ្តើមសរសេរឡើង។អ្នកនិពន្ធគ្រប់រូបត្រូវកំណត់ថាតើគាត់ត្រូវសរសេរអំពីអ្វី។ អំពីជីវិតសង្គមសង្គ្រាមស្នេហារឿងជំនឿទនៀមទម្លាប់ប្រពៃណី ចម្លើយរបស់សំណួរនេះហើយជាប្រធានរឿង។

តាមរយៈរឿង ពុទ្ធិសែននាងកង្រី និយាយរៀបរាប់ពីដំណើរជីវិតនាងទាំងដប់ពីរ និងពុទ្ធសែន ។

## គ.មូលបញ្ហារឿង

មូលបញ្ហារឿងគឺជាភាពចំណែកនៃប្រធានរឿងជាទិដ្ឋភាពផ្សេងៗរបស់យើង។វាជាការចូលជ្រៅទៅក្នុងប្រធានរឿង។

ជុំវិញប្រធានរឿងនេះ យើងបានកំណត់បញ្ហាជាច្រើន ដែលនៅជុំវិញការកសាងសីលបារមីរបស់ព្រះពោធិសត្វ បញ្ហាទាំងនោះរួមមាន៖

## ទី១ បញ្ហានាងទាំងដប់ពីរត្រូវបំបរបង់ចោល

ពេលនាងទាំងដប់ពីរបានចេញពីផ្ទះម្តាយឪពុក បំបរបង់ចោល ពួករស់នៅក្នុងព្រៃយ៉ាងលំបាកវេទនា ដើរៗទៅបានឃើញស្ទឹង ចាប់បានត្រីចង្វាម្នាក់មួយ នាងទាំងដប់មួយបានដោតភ្នែកត្រីទាំងសងខាង ចំណែកនាងពៅបានដោតភ្នែកត្រីតែម្ខាង។ ក្រោយមកពួកគេបានទៅរស់នៅនគរយក្ស ដោយពុំបានដឹងថាជានគរយក្សនោះទេ ពេលដែលនាងពៅបរិភោគបាយជ្រះមានខ្មោចប្រេតចេញមកស៊ីបាយ ពួកនាងបាឃើញមានការភ័យជាខ្លាំង។ បន្ទាប់មកពួកនាងបានទៅលេងនៅស្រះខាងក្រោយបានឃើញសព និងឆ្អឹងមនុស្ស តក់ស្លុតក្រៃលែង បាននាំគ្នាលួចរតចេញពីទីនោះបាន ដែលយក្សសនិម្មាដឹងតាមរកតែមិនឃើញ។

សរុបមក មនុស្សយើងត្រូវចិតចំប្រព្រឹត្តអំពើល្អ កុំឃាយីជីតអ្នកដ៏ទៃ នាំឱ្យវិនាសខ្លួនឯងដូចនាងទាំង១២ និងយក្សសធរមាត្រូវប្រព្រឹត្តិអំពើជាកុសលជានិច្ច។

## ទី២ បញ្ហានាងទាំងដប់ពីរបានក្លាយជាមហេសីស្តេច

នៅពេលនាងទាំងដប់ពីរបានជួបនិងស្តេចព្រះអង្គបានយកនាងទាំងដប់ពីរទៅក្នុងវាំងអភិសេកជាអគ្គមហេសីទាំងអស់។ ដំណឹងនេះបានឮដល់យក្សសនិម្មា នាងមានការសងសឹកនិងនាងទាំងដប់ពីរ បានប្រែកាលាជាស្រីស្អាតមកនៅក្បែរស្តេចៗពេញចិត្តនិងយក្សជាខ្លាំង។ពួកនាងទាំងដប់ពីរមានគក៏យក្សបានដឹង ក៏ប្រើល្បិចប្រាប់ស្តេចៗបានជឿហើយចាប់នាងទៅឃាំទុកក្នុងរូងភ្នំមួយ។ ពេលនោះយក្សប្រាប់ស្តេចថា នាងឈឺទាល់តែយកកែវភ្នែកនាងទាំងដប់ពីរមកធ្វើថ្នាំព្យាបាលតើបជា ពេលនោះយក្សបានបញ្ជាឱ្យសេនាខ្វិះភ្នែកនាងទាំងដប់ពីរនាងបងៗខ្វះភ្នែកទាំងសងខាង នាងពៅខ្វះតែមួយម្ខាង ។ ពេលនោះនាងបងៗសម្រាកលកូនដោយសេចក្តីស្រេកឃ្លានខ្លាំងពេក្តួកនាងបានសម្លាប់បុត្រហែកចែកគ្នាស៊ី ។ ពេលនាងពៅលាក់សាច់នោះទុកមិនបរិភោគទេ ។ពេលនាងពៅប្រសូត្របុត្រនាងលាក់ពីបងៗហើយយកសាច់ដែលនាងលាក់ទុកនោះឱ្យបងៗបរិភោគ បានដាក់ឈ្មោះ បុត្រថាពុទ្ធិសែន។

សរុបមកការចងកម្មពៀរគ្នាតែងនាំឱ្យបុគ្គលគ្រប់រូបជួបសេចក្តីវិនាស ដូនេះយើងមិនត្រូវមានការចងពៀរវេរានិងគ្នាឡើយ។

## ទី៣ បញ្ហាភាពកតញ្ញូនិងកម្មពៀរ

នៅពេលពុទ្ធិសែនបានធំដឹងក្តី បានដឹងរឿងព្រះមាតានិងព្រះមតិច្ឆាការពិតមានចិត្តជួយសង្រោះអ្នកទាំងអស់គ្នា ។ យក្សសនិម្មាបានប្រើឧបាយកលឱ្យពុទ្ធិសែនយកទៅនគតរបស់ខ្លួនសរសេរដាក់ក្នុងសំបុត្រថាបើពុទ្ធិសែនទៅដល់យប់ឱ្យសម្លាប់ទាំងយប់ បើទៅដល់ថ្ងៃឱ្យសម្លាប់ទាំងថ្ងៃ សេះមណីកែវបានធ្វើឧណើរកាត់ព្យុះទៅកន្លែងឥសី ៗបានបើកមើលសំបុត្របានដឹងក៏ប្រែជា ទៅដល់ថ្ងៃសម្លាប់ថ្ងៃ ទៅដល់យប់សម្លាប់យប់ ប្រែមក ទៅដល់ថ្ងៃរៀបការទាំងថ្ងៃ ទៅដល់យប់រៀបការទាំងយប់។ ពេលទៅដល់នគរ ឥន្ទបត្តបុរី នាងកង្រីបានឃើញសំបុត្រម្តាយក៏ធ្វើតាមរៀបចំការអភិសេកភ្លាម។ ពុទ្ធិសែននិងនាងកង្រីបានមានបុត្រពីនាក់ជា ពេលនោះនាងកង្រីបានប្រាប់ពីកន្លែងដាក់ស្គរជ័យគោះពេលណាមានអារុធចេញមក និងកន្លែងលាក់កែវភ្នែកនាងទាំង១២និងថ្នាំទេព ពុទ្ធិសេនបានឱកាសល្អបានលយចយករបស់ទាំងនោះបានហើយរតចេញពីនគរនោះ នាងកង្រីបានដឹងដេញតាមពុទ្ធិសែនតែមិនទាន់នាងបានស្លាប់បាត់ទៅ។យក្សសន្ធមាដឹងបានមកសម្លាប់ពុទ្ធិសែនតែត្រូវពុទ្ធិសែនសម្លាប់បាន។ ក្រោយមកបានយកកែវភ្នែកនិងថ្នាំទេពមកដាក់ឱ្យមាតានិងព្រះមាតុច្ឆាបានភ្លឺដូចដើម ។

សរុបមកភាពកតញ្ញូចំពោះអ្នកមានគុណ ជួយឱ្យបានសម្រេចគ្រប់កាងារទាំងអស់ ការប្រព្រឹត្តអំពើអាក្រក់និងទទួលផលនោះមករកអ្នកបានសាងវិញ។

## ឃ.ឧត្តមគតិរឿងគំនិតដឹកនាំរឿងតម្លៃអប់រំ

ឧត្តមគតិរឿងគឺជាឧត្តមគតិរបស់អ្នកនិពន្ធ។ ឧត្តមគតិរឿងគឺយកកត្តាប្រធានវិស័យដែលបញ្ហាដែលបញ្ជាក់ពីគោលជំហរសតិអារម្មណ៍របស់អ្នកនិពន្ធដែលស្តែងឡើងតាមរយៈសកម្មភាពរបស់តួអង្គ។

រីឯរឿងពុទ្ធិសែនវិញនៅពេលលោកសេដ្ឋីប្តីប្រពន្ធគ្មានកូន បានទៅសុំកូននៅវត្តក៏បានដូចបំណងទៅ១២នាក់ ក្រោយមកទ្រព្យសម្បត្តិអស់បានបំបោះបង់កូនចោល ធ្វើឱ្យពួកនាងជួបឧសគ្គគ្រប់បែបយ៉ាង ពួកនាងដើរក្នុងព្រៃអត់អាហារ បាននាំគ្នាទៅចាប់ត្រីចង្វាម្នាក់មួយនៅក្នុងបឹង។ ចំណេកនាងបងៗទាំង១១បនដោតភ្នែកត្រីទាំងសងខាង មានតែនាងពៅមួយប៉ុណ្ណោះដោតផ្នែកត្រីតែម្ខាង ពួកនាងបានកសាងបាបកម្មដ៏ធ្ងន់ធ្ងរមួយនេះបានធ្វើឱ្យជីវិតពួកនាងជួបតែរឿងទុក្ខវេទនាមិនចេះស្រាក់ស្រាន រហូតនាបបានក្លាយតៅជាមហេសីស្តេចទៅហើយ នៅតែរស់នៅគ្មានក្តីសុខសាន្តទៀត។ មានមារដេញតាមព្យាបាទជារ៉ងរហូត ដូចយក្សខន្តីទៅតាមសម្លាប់ខ្វេសភ្នែកទាំអស់គ្នានាងបងៗខ្វេសភ្នែកទាំងសងខាង ដោយបានកម្មពួកនាងបានខ្វេសភ្នែកត្រីទាំងសងខាងដែរ ចំណែកនាងពៅខ្វេសភ្នែកត្រីតែម្ខាងគេក៏ខ្◌េសភ្នែកនាងតែម្ខាងដែរ។ យក្សខនីវិញដោយបាបកម្មតាមសម្លាប់ជីវិតអ្នកដ៏ទៃចុងក្រោយពុទ្ធិសែនជាកូនកតញ្ញូចំពោះអ្នកមានគុណបានសងសឹកជូនអ្នកមានគុណបានសម្លាប់យក្សខន្ទីវិញនេះបានបង្ហាញពីពីបាបកម្មធ្វើនោបច្ចុប្បន្នជាតិហើយក៏បានទទួលផលភ្លាមៗដែរ ។

- អប់រមមនុស្សឱ្យមានការដឹងគុណកតញ្ញូចំពោះអ្នកមានគុណ
- អប់រំមនុស្សឱ្យមានសេចក្តីព្យាយាម
- អប់រំមនុស្សឱ្យស្រឡាញ់យុត្តិធម៌
- អប់រំមនុស្សឱ្យចេះជួយគ្នា
- អប់រំមនុស្សឱ្យដើរក្នុងផ្លូវត្រឹមត្រូវ
- អប់រំមនុស្សឱ្យជឿលើកម្មផល។

សរុបជារួមមកមនុស្សយើងត្រូវចេះប្រព្រឹត្តអំពើល្អកុំយាយីជីវិតអ្នកដ៏ទៃនាំឱ្យវិនាសខ្លួនឯងដូចនាងទាំង១២និងយក្សសន្ធមាបាបកម្មបានត្រូវស្លាប់ ។

# សង្ខេបរឿង ព្រះគោព្រះកែវ

នៅស្រុកលង្វែកមានគ្រួសារមួយរស់នៅពីរនាក់ប្តី ប្រពន្ធជាអ្នកប្រកបរបរជាអ្នកធ្វើស្រែចម្ការ។នាងជាប្រពន្ធមានផ្ទៃពោះនោះដល់យប់មួយបានយល់សុបិនឃើញថា នាងបានចិញ្ចៀនបីវង់មកពាក់ហើយក៏បាត់ទៅវិញ។នាងភ្ញាក់ឡើងភ័យអរផងឲ្យប្តីទៅរកគ្រូទាយ។ បុរសជាប្តីបានទៅរកគ្រូទាយតាមដំណើរសុបិរបស់ប្រពន្ធលោករកគ្រូទាយក៏គាត់គូរមើលតាមក្បួនតម្រាលហើយក៏ប្រាប់ទៅមាណពថា បើតាមសុបិននេះល្អណាស់គឺ មានអ្នកមានបុណ្យមកចាប់កំណើតតែត្រូវឲ្យនាងតមកុំបរិភោគស្វាយខ្ចីបើមិនដូច្នោះនិងមានគ្រោះថ្នាក់សូមក្តួយចាំសម្តីមើលដោយខ្លួនឯងចុះ។ ត្រឡប់មកផ្ទះវិញក៏ប្រាប់ប្រពន្ធដែលគ្រូទាយបានប្រាប់ព្រមនិងហាមប្រព័ន្ធមិនឲ្យបរិភោគផ្លែស្វាយខ្ចី។ លុះពរពោះបានគ្រប់ខែហើយនាងចេះតែនឹកចង់ស្វាយខ្ចីយ៉ាងខ្លាំង។ ពេលមួយនាងក៏ដើរមកមើលឃើញផ្លែស្វាយមួយក៏ប្រាប់ឲ្យប្តីឡើងបេះតែមាណពមិនព្រមឡើងបេះដោយធ្វើជាទៅចំការបាត។ដោយនឹកចង់ស្វាយខ្ចីខ្លាំងពេករហូតដល់ទ្រាំលែងបានក៏ដើរទៅរកបេះដោយខ្លួនឯង។ នាងក៏ប្រវេះប្រវាស់ឡើងដើមស្វាយម្នាក់ឯងពេលទៅដល់លើនាងតោងចង់មេយពុកមួយស្រាប់តែបាក់ធ្លាក់ចុះមកលើដីស្លាប់មួយរំពេចពេលនោះធ្លាយពោះចេញកូនៗមួយគោកូនប្រុសមួយពីរផ្ទៃរបស់នាងគាត់ដើរមួយរំពេចចំ ណែកឯកូនក៏រត់ទៅរកឪពុកឲ្យមកជួយប្អូននៅក្រោមដើមស្វាយ។មាណពបានឃើញឃើញកូនគោបានដើរតាមរហូតទៅឃើញប្រព័ន្ធដេកស្លាប់ក្រោមដើមស្វាយក៏យំសោកអាណិតប្រព័ន្ធជាពន់ពេក។ព្រះគោបានប្រាប់ឲ្យឪពុកលើកប្អូនចេញមកបានយកកូននោះទៅផ្ទះ។

លុះព្រឹកឡើងបី កូនដើរសុំទឹកដោះពីរនាក់ស្រុកឱ្យកូនបៅអ្នកស្រុកបានសាកសួរមាណពថានេះជាកូនអ្នកណាបានជាក្តួយដើររកទៅដោះឲ្យបៅដូច្នេះនេះនេះជាកូនរបស់ខ្ញុំចុះម្តាយវាទៅណាបានជាមិនឱ្យវាម៉ៅប្រពន្ធរបស់ខ្ញុំធ្លាក់ពីលើដើមស្វាយស្លាប់បាត់ហើយ។ ក្នុងពោះរបស់នាងមានកូនគោនិងកូនមួយនេះឯងឮដូច្នេះអ្នកស្រុកនាំគ្នាផ្អើលចង់មើល។ពេលអ្នកស្រុកមកមើលឃើញមនុស្សបីកូនមួយមានទាំងកូនៗនៅក្បែរផង។ គេនាំគ្នាឆ្ងល់យ៉ាងខ្លាំង។ហើយដឹងថាមានកូនកើតមកជាសត្វគោឯម្តាយបែកពណ៌ស្លាប់ខុសគេខុសឯងដូច្នេះក៏អ្នកស្រុកយល់ថានឹងនាំឲ្យចង្រៃដល់ភូមិស្រុកក៏នាំគ្នាដេរវាតាមវាបិទដឹងមាននោះនឹងកូនលែងឲ្យមកក្បែរភូមិ។

មាណពនិងកូនទាំងពីរទៅរស់នៅក្នុងព្រៃឆ្ងាយដាច់ពីគេឯងដោយមិនហ៊ានសង់ផ្ទះសម្រាប់ជ្រកកោនអ្វីឡើយ។មាណពនាំកូនទៅជ្រកតែក្រោមដើមឈើធំៗ ហើយដើរបេះផ្លែឈើបរិភោគជាអាហា។ ក្រោយមកព្រះគោនិងព្រះកែវរាំងធំល្មមដឹងក្តីថ្ងៃមួយពីរនាក់បងប្អូនចេញមកវាលមួយបានឃើញពួកក្មេងឃ្វាលគោមួយហ្វូងកំពុងលេងយ៉ាងសប្បាយ។ ព្រះកែវបានសុំបងចូលទៅលេងជាមួយពួកគេដែរ។ ដោយបោចវល្លិលុះដល់ពេលបាយក្មេងទាំងនោះនាំគ្នាស៊ីបាយជុំគ្នា។ឯព្រះគោគ្មានបាយក៏ដើរទៅសុំគេ។ខ្ញុំ សុំស៊ីផង ទេអុញមិនឲ្យទេ ។ យី អានេះមកពីណាបានជាសុំបាយគេស៊ី?

ពេលគេស៊ីបាយរួចព្រះកែវឃើញគ្រាប់បាយនៅជាប់នឹងស្លឹកចេកក៏សុំគេទៀតតែពួកក្មេងញីចោលរួចដេញវាយដេរព្រះកែវចេញទៅ។ព្រះកែវបានរត់មកប្រាប់ព្រះគោដោយយំខ្សឹកខ្សួលនិងពួកគេពួកក្មេងគង្វាលចោលរួចដេញវាយដេរមកលើខ្លួន។ ព្រះគោបានអាណិតប្អូមយ៉ោងខ្លាំង។ព្រះគោឃើញប្អូនឃ្លានបាយហើយត្រូវគេដេញគេដេញវាយធ្វើបាបព្រមទាំងដៀលដូច្នេះក៏តាំងរោទ៍បីដងស្រាប់តែ។ ផ្លែចេញជាម្ហូបអាហារទិព្វដែលមានចាន ពែង ចូស្លាបព្រា សុទ្ធតែគ្រឿងមាសប្រាក់ឲ្យប្អូនបរិភោគម្នាក់ឯង។

ហេតុអ្វីបានជាបងមិនក្អែរអាហានេះឲ្យពុកយើងផង។ មិនបានទេ ! អាហានេះគឺសម្រាប់តែប្អូនម្នាក់ប៉ុណ្ណេះ។ ពួកក្មេងឃ្វាលគោលបមើលឃើញព្រះគោក្អែរចេញអាហារនិងរបស់ប្រើប្រាស់សុទ្ធតែគ្រឿងមាសប្រាក់ដូច្នេះក៏ចាំលបមើលដល់ព្រះគោលេបគ្រឿងមាសប្រាក់ទាំងអស់នោះចូលក្នុងពោះវិញ។ ក្មេងៗ បាននាំគ្នាទៅប្រាប់ឪពុកម្តាយរៀងៗ ខ្លួនធ្វើឲ្យចាស់ៗ ក្នុងភូមិឆ្ងល់ពីហេតុការណ៍នេះអ្នកភូមិបាននាំគ្នាផ្អើលឆោរឡោកាន់កាំបិតពូថៅដំបងទៅចាប់ព្រះគោដើម្បីនឹងវះយករវត្ថុទិព្វទាំងអស់នោះ។ លុះចាប់បានព្រះគោហើយគេក៏ដឹកយកមកចងជាប់នឹងដើមកណ្តោលធំមួយមានមនុស្សផ្អើលមកឈរមើលព្រះគោដោយសេចក្តីងឿងឆ្ងល់មនុស្សនិងនឹកចង់បានទ្រព្យរបស់ដែលមាននៅក្នុងពោះព្រះគោ។ ពេលអ្នកស្រុកចូលបម្រុងនឹងធ្វើបាបព្រះគោភ្លាមនោះព្រះគោបានឲ្យប្អូនតោងកន្ទុយឲ្យជាប់ហើយក៏ហោះឡើងកណ្តាលដើម

កណ្ដាលដើមកណ្ដាលរលំបាកលើពួកទាំងអស់នោះ។ធ្វើឲ្យអ្នកខ្លះត្រូវបាក់ដៃបាក់ជើងបែកក្បាលស្ទើរគ្រប់ៗគ្នា។ ហើយព្រះគោបានស្រែកប្រាប់ទៅអ្នកស្រុកដែលត្រូវរបួសថាឲ្យយកដើមកណ្ដាលទៅដាំ។ និងជាវិញហើយពេលឮដូច្នោះអ្នកស្រុកក៏បានកាប់យកឬកណ្ដាលទៅដាំផឹកជាយ៉ាងសាកសិទ្ធមែន។ ក៏នាំគ្នា នឹកដល់ព្រះគោដែលមានវិទ្ធាបារមីខ្លាំងពូកែលែងហ៊ានធ្វើបាបនិយាយពីឪពុករបស់ព្រះគោព្រះគោទៀត។ព្រះគោបានហោះទៅនៅក្នុងព្រៃដ៏ជ្រៅឆ្ងាយពីភូមិស្រុកនានាហើយរស់នៅតែពីរនាក់បងប្អូនក្បែរស្រះទឹកមួយយ៉ាងល្អ។ និយាយពីឪពុករបស់ព្រះគោព្រះកែវបាត់កូនមិនឃើញត្រឡប់មកកន្លែងដើមវិញក៏ខំស្រែកហៅជុំវិញទីនោះ។ មិនឃើញសោះនឹកកូនឥតឧបមាបានដើររកស្ទើរគ្រប់កន្លែងនៅតែមិនឃើញទៀតមាណពថ្លែងពីបុត្រីទាំងប្រាំអង្គរបស់ស្ដេចនាងដែលជាបុត្រីពៅមានរូបឆោមស្អាតនិងមានចរិយាស្លូតបូតជាងគេ។ ថ្ងៃមួយទាំងអស់គ្នាអផ្សុកនឹកចង់ចេញទៅលេងព្រៃដែរនៅឆ្ងាយពីព្រះរាជវាំងក៏បានទូលសូមអនុញ្ញាតពីព្រះបិតារួចចេញដំណើរទៅ។

លុះទៅដល់ស្រះទឹកមួយកណ្ដាលព្រៃក្បែរកន្លែងព្រះគោព្រះកែវស្នាក់នៅបុត្រីស្ដេចទាំងអស់និងពួកភិលៀងហែហមទាំងឡាយនាំគ្នាឈប់សម្រាកនិងងូតទឹកលេងសប្បាយក្នុងស្រះទឹកនោះព្រះកែវ ឮសូរមាត់មនុស្សអូអរក៏ចេញមក។ លោបមើលឃើញបុត្រីស្ដេចទាំង ៥អង្គព្រះកែវបានចាប់ចិត្តស្រឡាញ់នាងពៅតែដោយខ្លួនគ្មានសម្លៀកបំពាក់ត្រឹមត្រូវបានរត់មកនិយាយប្រាប់បង។ ព្រះគោឮប្អូននិយាយប្រាប់ក៏ក្អែសំលៀកបំពាក់និងគ្រឿងអលង្ការទិព្វឲ្យព្រះកែវស្លៀកពាក់យ៉ាងស្អាតហើយចេញទៅ។ បុត្រីស្ដេចទាំងនោះឃើញព្រះកែវភ្លាមនាំគ្នាលួចស្រឡាញ់ហើយៗ ចុះទៅងូតទឹកលេងល្បែងដេញចាប់កូនអណ្ដែងពេលព្រះកែវចាប់បានដេញចាប់នាងពៅហើយពេលនាងពៅចាប់បានក៏ដេញជុះតែព្រះកែវវិញលេងបានយូរបន្តិចទៅនាងពៅៗ បានព្រមទាំងនិយាយរឿងនេះទៅប្រាប់បិតា។ពេលត្រឡប់ទៅដល់វាំងវិញបងៗរបស់នាងពៅចូលទៅគាត់ព្រះបិតាផម្ទតាដោយពុំឃើញនាងពៅចូលគាល់ស្ដេចក៏ស៊ូរក។

.នាងពៅទៅណាបានជាមិនឃើញដូច្នេះ

.ព្រះបិតានាងមិនហ៊ានចូលគាល់ព្រះអង្គទេ?

.តើមានរឿងហេតុអ្វីបានជាមិនហ៊ានចូលមក។

.ព្រះបិតាពេលទៅស្រង់ទឹកលេងនោះនាងពៅបានប្រឡែងលេងជាមួយបុរសម្នាក់ដោយគ្មានខ្លាចក្រែងអ្វីឡើយ។

ស្ដេចស្ដាប់កូនបងៗ ទូលដូច្នោះក៏ខ្ញាល់នឹងនាងពៅដែលហ៊ានធ្វើផ្ដេសផ្ដាសឥតខ្លាស់ក្រែងព្រះអង្គ។ ព្រះអង្គបានបញ្ជាឲ្យរទេះនាងពៅចេញពីវាំងទៅរស់នៅក្នុងព្រៃនាងបានធ្វើដំណើរក្នុងព្រៃដោយសោយតែផ្លែឈើរហូតដល់បានជួបនឹងព្រះកែវព្រះក៏បានរៀបអភិសេកព្រះកែវនិងនាងពៅរួចបានក្អែរចេញប្រាសាទយ៉ាងល្អសម្រាប់ប្អូនរស់នៅទាំងអស់គ្នា។

និយាយពីស្ដេចសៀមបានប្រើរាជទូតនាំសារមកទូលថ្វាយស្ដេចខ្មែរបបួលប្រជល់មាន់ដាក់ពល ប្រជារាស្ត្រ ទាហាននិងទ្រព្យសម្បត្តិ។ ការដាក់នៃស្ដេចស៊ីមជាអ្នកឈ្នះតែស្ដេចខ្មែរបានសុំដល់ជល់មាន់ម្ដងទៀត។ លើកក្រោយនេះស្ដេចមានការព្រួយព្រះទ័យយ៉ាងខ្លាំង។ព្រោះមិនដឹងថារកមាន់ឯណាមកជល់ឈ្នះមាន់ស្ដេចស៊ីនព្រះអង្គបានឲ្យពួកសេនាស្វែងរកមាន់ខ្លាំងពូកែគ្រប់កន្លែងលូតដល់ដើរទៅបានជួបនិងនាងពៅ។ ហើយបាននិយាយតាមដំណើររឿង។ព្រមទាំងត្រឡប់មកវិញយកដំណឹងនេះទូលថ្វាយដល់ស្ដេច។ពេលនោះស្ដេចនឹងបុត្រីទាំងអស់បានយល់ឃើញថាត្រូវឲ្យនាងពៅជាទារមួយព្រះកែវដោះស្រាយរឿនេះ។ព្រះកែវបានយករឿងនេះទៅប្រាប់បងពេលនោះព្រះគោសុខចិត្តប្រែកាលាជាសត្វមាន់ដើម្បីជួយដល់នគរទាំងមូល។ ពេលជួលលើកនេះមានខាងស្ដេចខ្មែរឈ្នះខាងស្ដេចស៊ីមធ្វើឲ្យស្ដេចស៊ីមខឹងណាស់ឆ្ងល់ថាហេតុអ្វីបានជាមាន់ស្ដេចខ្មែរមានមាឌតូចសោះអាចសម្លាប់មាន់ក៏ធំរបស់យើងនេះប្រហែលជាមានវិទ្ធាបារមី អ្វីហើយមើលទៅស្ដេចស៊ីមមិនអស់ចិត្តក៏បបួលប្រជល់ដំរីម្ដង។

ពេលនោះព្រះគោត្រូវប្រើកាឡាជាដំរីដើម្បីជួលម្ដងទៀត។លើកនេះដំរីខ្មែរឈ្នះដំរីស៊ីមដដែលធ្វើឲ្យស្ដេចស៊ីមកាន់តែខឹងនឹងចង់ដឹងថែមទៀត។ ពេលក្រោយស៊ីនបានរៀបចំគោយន្តធ្វើពីដែកហើយមកបកប្ដូស្ដេចខ្មែរប្រជល់ទៀត។លើកនេះព្រះក៏ដឹងថាច្បាស់ជាចន្ទគេហើយក៏និយាយប្រាប់ប្អូនឲ្យប្រឹងប្រយ័ត្ននាំនាងទៅចូលមកក្បែរព្រលានប្រយុទ្ធហើយត្រៀមគោងកន្ទុយដើម្បីហោះរតចេញ។ លក់ដល់ពេលជួលព្រះគោព្យាយាមជល់ជាមួយគោយន្ត យ៉ាងខ្លាំងព្រះគោបានបោលបុកគោយន្តបីដងដឹងថាមិនអាចយកឈ្នះបានក៏រត់មករកប្អូនភ្លា

ម។ ព្រះកែវនាំនាងពៅតោងកន្ទុយបងហើយព្រះគោហោះពីងចេញទៅធ្វើឲ្យផ្អើលអស់ទាំងខ្មែរទាំងសៀមតាមមើលហើយស្តេចសៀមនឹកចង់បានព្រះគោយ៉ាងខ្លាំង។ ក៏នាំពលទាហានដេញតាមចាប់ចំណែកនាងពៅតោងកន្ទុយព្រះគោយូរៗ ទៅក៏ធ្លាក់ចុះមកដី។ ព្រះកែវឃើញដូច្នេះក៏លែងដៃចុះមកតាមនាងពៅ។ ពេលធ្លាក់ចុះមកដល់ដីទៅបានផ្តាំព្រះៗកែវឲ្យរត់ចេញទៅព្រោះពួកសៀមតាមជាប់មកពីក្រោយហើយហើយនាងក៏ដាច់ខ្យល់ស្លាប់មួយរំពេចព្រះកែវរតចេញទៅឯព្រះគោដឹងថាប្អូនធ្លាក់ចុះមកតាមជួយនឹងព្រះកែវក៏នាំគ្នារត់គេចពីពួកសៀមជានិច្ច។ និយាយពីព្រះឥន្ទ្រក្តៅក្រហាយនៅមិនបានក៏ប្រមើលមើលមកក្រោមឃើញនាងពៅដេកស្លាប់កណ្តាលព្រៃដូច្នេះក៏យកទឹកមកស្រោចពីលើសពនាងក្លាយជាថ្មីនិងនាំព្រលឹងទៅគង់នៅឯឋានសួរ។

ចំណែកព្រះគោចេះតែនាំប្អូនរដ្ឋគេចរហូតដល់កន្លែងមួយមានព្រៃច្រើនក្រាស់គ្រាន់បើក៏ពួនៅទីនោះ។ ចាប់ពីព្រះគោទៅនៅត្រង់នោះមកធ្វើឲ្យដើមឈើទាំងឡាយមានផ្លែផ្កាស្រស់បំព្រងសត្វផងទាំងពួងក៏ដូចអ្នកភូមិក្បែរក្បែរនោះបានសប្បុរសប្បាយប្លែកពីធម្មតាតំណឹងនេះបានលេចឮទៅដល់ស្តេចសៀមគេបានឲ្យហោរាទាយដឹងថាមានព្រះគោនៅទីត្រង់នោះក៏នាំទាហានដេញតាមចាប់បន្តទៀតដោយចង់បានព្រះគោទៅនៅក្នុងស្រុករបស់គេខ្លាំងពេកក៏ចេះតែតាមចាប់គ្រប់ពេលវេលា។ព្រះគោនាំប្អូនហោះគេទៅដល់មន្ទាយលង្វែកមានព្រៃឬស្សីដុះយ៉ាងក្រាស់ព័ទ្ធជុំវិញក៏នាំគ្នាលាក់ខ្លួនពួននៅទីនោះ។ ស្តេចសៀមបានឲ្យហោរាទាយដឹងថាព្រះគោនៅទីនោះក៏លើកគ្នាមកតាមតែចូលមិនបានដោយមានត្រីឬស្សីច្រើនពេក។ ក៏រកល្បិចយកប្រាក់ដូងមកច្រកក្នុងកាំភ្លើងបញ្ចូលព្រៃឬស្សីនោះហើយត្រឡប់ទៅវិញ។ ពេលក្នុងពេលក្មេងគោដើរកន្លែងនោះបានប្រាក់។នៅតាមកុំឬស្សីក៏នាំគ្នាប្រាប់ឪពុកម្តាយធ្វើឱ្យអ្នកស្រុកនាំគ្នាកាប់ព្រៃឬស្សីដើម្បីយកប្រាក់ មិនយូប៉ុន្មានឬស្សីទាំងនោះខ្ទេចខ្ទីអស់។ សៀមបានលើកទ័ពមកម្តងទៀតពេលនោះព្រះគោព្រះកែវប្រែកាលាជាសត្វក្របីហើយដែលចូលក្នុងហ្វូងក្របីដើម្បីបន្លំពួកសៀនស្តេចសៀមបានយកព្រាត់ស្បែក្របីព័ទ្ធជាសីមាជុំវិញបងក្របីដើម្បីចាំមើលក្របីទាំងនោះលោតរំលងព្រាត់រដ្ឋបាលអស់ទៅពេលពួកសៀមដេញវាយតែព្រះគោនិងព្រះកែវមិនព្រមលោតរំលងព្រាត់ក៏ឈរនៅស្ងាត់ព្រោះខ្លាចសាបសីលមន្តវិជ្ជាវាជាផ្សេងៗពួកសៀនចាំបានវាយដេញហើយយកទៅដាក់ឃុំទុកនៅក្នុងស្រុកស៊ានបាត់ទៅ។

ពេលវេលាយប់មួយព្រះគោព្រះកែវលួចរតមកដល់ស្រុកខ្មែរវិញពួកសៀមបានលើកសេនាតាមចាប់ព្រះគោព្រះកែវស្ទើរគ្រប់តំបន់រហូតដល់ចាប់បានម្តងទៀតលែងហ៊ានវាយដេរតែបែរជាសង់ប្រាសាទយ៉ាងស្អាតឱ្យព្រះគោព្រះកែវគង់នៅហើយមានអ្នកយាមខណ្ឌប្រាំពីរជាន់ហ្នឹងមានអ្នកយាមចាំងត្រឹមត្រូវដោយខ្លាចព្រះគោលួចរតពួកសៀងយល់ថាការយកបានព្រះគោគង់នៅទីណាទីនោះនឹងបានសុខផ្សេងៗ ដូច្នេះហើយបានចាប់ពីពេលនោះមកព្រះគោព្រះកែវលែងបានបើត្រឡប់មកស្រុកខ្មែរវិញរហូតដល់សព្វថ្ងៃ។

# ១.សេចក្តីវិភាគរឿង

## ក.អត្ថន័យខ្លឹមសារ

អត្ថន័យអត្ថ .ប្រយោជន៍.អត្ថន័យ .ការណែនាំអត្ថាធិប្បាយសេចក្តីពន្យល់.អត្ថន័យជាគំនិតសំខាន់ៗរបស់អ្នកនិពន្ធដែលលាតត្រដាងនៅក្នុងដំណើររឿង ហើយគេអាចហៅវាថាជាជម្រៅនៃរឿង។

ក្នុងផ្នែកអត្ថន័យមាន ប្រធានរឿង មូលបញ្ហារឿងនិងឧត្តមគតិរឿង។

## ខ.ប្រធានរឿង មូលន័យ

ប្រធានរឿងឬមូលន័យ គឺជាគំនិតសំខាន់ៗរបស់រឿង។ ប្រតិឬជាបញ្ហារួមរបស់រឿង។ តែអ្នកនិពន្ធចង់បង្ហាញដល់អ្នកអានប្រធានរឿងជាបញ្ហារូបផ្តុំបំផុតដែលអ្នកនិពន្ធលើកយកមកសរសេរឬជ្រើសរើសជាប្រធានបទហើយដែលមានមូលបញ្ហារឿងឋិតនៅក្នុងនោះ។

ប្រធានរឿងបង្ហាញនៅចំហររបស់អ្នកនិពន្ធវាជាមូលដ្ឋានដើមរបស់អ្នកនិពន្ធក្នុងការចាប់ផ្តើមសរសេរឡើង។មុនពេលចាប់ផ្តើមសរសេរឡើង។អ្នកនិពន្ធគ្រប់រូបត្រូវកំណត់ថាតើគាត់ត្រូវសរសេរអំពីអ្វី។អំពីជីវិតសង្គមសង្គ្រាមស្នេហារឿងជំនឿទនៀមទម្លាប់ប្រពៃណីចម្លើយរបស់សំណួរនេះហើយជាប្រធានរឿង។

តាមរយះ រឿងព្រះគោ ព្រះកែវ បានបង្ហាញពី ដំណើរជីវិតព្រះគោព្រះកែវ។

## គ.មូលបញ្ហារឿង

មូលបញ្ហារឿងគឺជាភាពចំណែកនៃប្រធានរឿងជាទិដ្ឋភាពផ្សេងៗរបស់យើង។វាជាការចូលជ្រៅទៅក្នុងប្រធានរឿង។

ជុំវិញប្រធានរឿងនេះ យើងបានកំណត់បញ្ហាជាច្រើន ដែលនៅជុំវិញការកសាងសីលបារមីរបស់ព្រះពោធិសត្វ បញ្ហាទាំងនោះរួមមាន៖

### ទី១ ការស្លាប់ម្តាយព្រះគោ និងព្រះកែវស្លាប់

នៅពេលប្រពន្ធមាណពបានគល់សុបិន បានចិញ្ចៀនបីវង្ស បានឱ្យប្តីទៅរកគ្រូទាយ គ្រូទាយថា មានអ្នកមានបុណ្យមកចាប់កំណើត និងមិនឱ្យនាងហូបផ្លែស្វាយខ្ចីនាំឱ្យខ្លួនស្លាប់។ ពេលជិតប្រសូតធ្វើឱ្យនាងឃ្លានស្វាយខ្ចីកាន់តែខ្លាំងឡើង នាងបានឡើងបោះផ្លែស្វាយបានធ្លាក់បែកពោះស្លាប់ទៅ។ ព្រះគោបានប្រសូត្រមកបានទៅរកឪពុក ចៅមាណពបានមករកប្រពន្ធតាមកូនគោ បានឃើញប្រពន្ធដេកស្លាប់នៅក្រោមដើមស្វាយ។ ព្រះគោបានឱ្យឪពុកជួយប្អូនកែវនៅក្នុងពោះបាន ចៅមាណពបានទៅសុំទឹកដោះឱ្យកូនបៅពីអ្នកស្រុក គេបានដឹងថា កូនមណពកើតមកជាគោផល និងមនុស្សផលពួកគេយល់ថា ជាមនុស្សចង្រៃ ដេញតាមសម្លាប់មិនឱ្យនៅក្នុងភូមិ។ ព្រះគោ ព្រះកែវនិងឪពុកបានរស់នៅក្នុងព្រៃ ព្រះគោ ព្រះកែវបានអាយុប្រាំពីរឆ្នាំ ព្រះកែវបានសុំឪពុកទៅលេងជាមួយក្មេងគង្វាលគោ ពួកគេមិនឱ្យបាយព្រះកែវញ៉ាំទេ ។ ព្រះគោឃើញបែបនោះអាណិតប្អូន បានខ្ជាក់អាហារទេព្វមកមានចានមាស ចានប្រាក់ ពួកក្មេងបានឃើញទៅប្រាប់ឪពុក ម្តាយឱ្យសម្លាប់កូនគោយកចានមាសចានប្រាក់ ចាប់ព្រះគោដងនៅដើមកណ្តោល ព្រះគោហោះឡើងរតគេចខ្លួនបាន។

សរុបមកមនុស្សយើងមិនត្រូវមានចិត្តលោបលន់នោះទេ និងមិនគួរចង់បានអ្វីដែលមិនមែនជារបស់ខ្លួន ឡើយ។

### ទី២ បញ្ហាការភ្នាល់គ្នា

ស្តេចសៀមបានមកប្រជល់មានភ្នាល់ជាមួយ ព្រះរាជាខ្មែរ បើស្តេចសៀមចាញ់និងប្រគល់ទ្រព្យសម្បត្តិ ពលសេនានិងសំពៅឱ្យស្តេចខ្មែរ បើស្តេចខ្មែរចាញ់សុំយកតែព្រះគោ និងព្រហកែវទៅរស់នៅនៅប្រទេសសៀម។ មានស្តេចខ្មែរបានជល់ចាញ់មាន់សៀម ព្រះរាជាខ្មែរបានសុំប្រជលលើក្រោយ មានការជួយពីព្រះគោឈ្នះមាន់សៀម ។ សៀមមិនងស់ចិត្តសុំប្រជល់ជាមួយដំរីព្រះគោតំណែងខ្លួនជាដំរីជល់ឈ្នះទៀត លើកទីបីសៀមបានយកដែកធ្វើកោយន្តមកជល់ជាមួយព្រះគោ ព្រះគោបានចាញ់គោយន្ត សៀមតាមចាប់ព្រះគោ ព្រះកែវរហូតដល់ចាប់បានយកទៅស្រុកវា។

សរុបមកអ្នកដឹកនាំត្រូវមានទំនួញខុសត្រូវជំពោះការសម្រេចចិត្តដើរតាមផ្លូវដោយភាពស្មោះត្រង់ និងស្រឡាញ់ការពារប្រជារាស្ត្ររបស់ខ្លួន បានរស់នៅប្រកបដោយសេចក្តីសុខ។

## ឃ.ឧត្តមគតិរឿងគំនិតដឹកនាំរឿងតម្លៃអប់រំ

ឧត្តមគតិរឿងគឺជាឧត្តមគតិរបស់អ្នកនិពន្ធ។ឧត្តមគតិរឿងគឺយកកត្តាប្រធានវិស័យដែលបញ្ហាដែលបញ្ជាក់ពីគោលជំហរសតិអារម្មណ៍របស់អ្នកនិពន្ធដែលស្តែងឡើងតាមរយៈសកម្មភាពរបស់តួអង្គ។

រឿងព្រះគោព្រះកែវបានបង្ហាញឱ្យយើងឃើញពីការ លោបលន់ពីសំណាក់ជនបរទេសមកលើមកលើប្រទេសខ្មែរ ពួកសៀមបានមានបំណងចង់បានទឹកដីខ្មែរ នៅពេលដែលភ្នាល់គ្នាជាមួយព្រះមហាក្សត្រដាក់ប្រទេសខ្មែរបើខ្មែរចាញ់និងបានទៅសៀម ។ នៅពេលភ្នាល់មាន់ស្តេចខ្មែរចាញ់មាន់ស្តេចសៀម ក្រោយមកមានការជួយពីព្រះគោបានឈ្នះស្តេចសៀមវិញ ។

នេះបានបង្ហាញពីភាពចេះជួយគ្នានៅពេលមានអាសន្ន ព្រះគោព្រះកែវជាអ្នកមានបុណ្យបារមីខ្ពស់ធ្វើឱ្យព្រះគោព្រះកែវរស់នៅទីកន្លែងណានាំភាពសុខចម្រើនមកកន្លែងនោះ ដូចនៅពេលព្រះអង្គទៅរស់នៅក្នុងព្រៃរុក្ខជាតិមានផ្លែផ្កា សត្វបក្សាចក្សីរស់នៅដោយសុខសាន្ត ប្រជាជននៅទីនោះបង្ករបង្កើនផលបានបរិបូរ ប្រទេសមានការរីកចម្រើនសម្បូរសម្បាយទាំងក្នុងនគរនិងក្រៅនគរ។ មួយទៀតក៏បានបង្ហាញពីការមិនចេះសាមគ្គីជួយគ្នានៅពេលដែលសៀមបានដេញតាមចាប់ព្រះគោព្រះកែវនោះ ព្រះមហាក្សត្រខ្មែរការពារព្រះអង្គមិនបានធ្វើឱ្យកងព័ទសៀមបាន ដេញតាមចាប់បាន ពេលអត់ពីព្រះគោព្រះកែវទៅប្រទេសខ្មែរធ្លាប់តែសម្បូរសម្បាយប្រែក្លាយទៅជាប្រជាជនរស់នៅវេទនានិងប្រទេសជាតិធ្លាក់ខ្លួនដុនដាបគ្រប់វិស័យដូនេះយើងត្រូវចេះរូបរួមសាមគ្គីគ្នាគ្រប់កាលៈទេសៈទាំងអស់និងធ្វើឱ្យប្រទេសជាតិមួយមានការរីកចរើនបាន។

- អបរំមនុស្សឱ្យចេះគិតផលប្រយោចន៍រួមធំជាងប្រយោជន៍ផ្ទាល់ខ្លួទន
- អប់រំមនុស្សចេះដោះស្រាយបញ្ហានៅចំពោះមុខ
- អប់រំមនុស្សឱ្យស្រឡាញ់ប្រទេសជាតិរបស់ខ្លួន
- អប់រំមនុស្សមិនឱ្យមានការរើសអើង
- អប់រំមនុស្សមិនឱ្យមានការបៀតបៀនអ្នកដ៏ទៃ
- អប់រំមនុស្សឱ្យជឿលើកម្មផល។

សរុបជារួមមកយើងឃើញថា អក្សរសិល្ប៍ខ្មែររឿង ព្រះគោ ព្រះកែវនេះបានបង្ហាញឱ្យឃើញអំពីសកម្មភាព ទេពកោសល្យរបស់ ដើម្បីផ្តល់នូវការចេះស្រឡាញ់រួបរួមគ្នា ការពារប្រទេសជាតិឱ្យបានគង់វង្សនិងមានការរីកចម្រើន។

# សង្ខេបរឿង ក្រុងសុភមិត្រ

កាលពីព្រេងនាយ មានព្រះមហាក្សត្រមួយព្រះអង្គ ព្រះនាមព្រះបាទ ក្រុង សុភមិត្រ សោយរាជ្យនៅចម្ប៉ា ព្រះអនុជព្រះអង្គ ព្រះនាមអសុភមិត្រ មានតំណែងជាឧបរាជ ព្រះបហេសិព្រះនាមកសិធី មានព្រះរាជបុត្រាពីរព្រះអង្គ ព្រះរាជបុត្រាច្បងព្រះនាមជ័យសេនកុមារ ព្រះរាជបុត្រប្អូន ព្រះនាមជ័យទត្តកុមារ ។

ចំណេរកាលតមកអសុភមិត្រឧបរាជ មានគំនិតគិតក្បត់ចង់ដណ្តើមយករាជសម្បត្តិពីព្រះរៀម ហើយបានលើកព័រទៅប្រុងព័ទ្ធឡោមក្រុងចម្បាកនគរ ។ កាលណោះមានអាមាត្យម្នាក់របស់ក្រុងអសុភមត្រ ឡើងក្រាបទូលព្រះបាទក្រុងសុភមិត្រ ឱ្យបានទ្រង់ជ្រាបអំពីដំណើរជករាជ្យនៃក្រុងអសុភមិត្រជាព្រះអនុជសព្វគ្រប់ ។

ព្រះបាទ ក្រុងសុភមិត្រ ទ្រង់ព្រះចិន្តាថា ប្រសិនបើអញចេញច្បាំងតទល់ នឹងព្រះអនុជ មុខជាព្រះញាតិវង្សព្រមទាំងអាណាប្រជានុរាស្ត្រនឹងសេនាទាហាន វិនាសអន្តរាយ អស់ច្រើន ដូច្នេះគួរអញដោះខ្លួនគេចចេញពីព្រះរាជដ្ឋានក្នុងរាត្រី នេះ ទើបស្តេចត្រាស់លាព្រះរាជមហេសីនឹងព្រះរាជបុត្រទាំងពីរព្រះអង្គ ។ ឯព្រះនាងកេសិនីជាស្ត្រីស្វាមីភក្តីចំពោះព្រះរាជស្វាមី មិនសុខចិត្តក្រាញ នៅក្នុងព្រះរាជវាំងឡើយ ទើបព្រះនាងក្រាបទូលថា ខ្ញុំម្ចាស់សុខចិត្តតាមស្លាប់ជាមួយនឹងព្រះអង្គ ប្រសើរជាងរស់នៅ តែព្រាត់ប្រាសចាកព្រះអង្គ ខ្ញុំម្ចាស់ស៊ូត ពកូនសំឡាញ់ទាំងពីរទៅតាមព្រះភូមិ ទោះបីស្តេចត្រាច់ទៅក្នុងទីទាបទីខ្ពស់ ចំនួលយ៉ាងណា ទោះបី បានក្តីលំបាកយ៉ាងណាក៏ខ្ញុំម្ចាស់ពុំព្រមឃ្លាតព្រះអង្គឡើយ ។

គ្រានោះព្រះនាងទេវី ទ្រង់បានរៀបស្បៀងលៀងជីវិតបានខ្លះហើយទ្រង់ ពរជ័យទត្តកុមារ ព្រះរាជស្វាមី ទ្រង់ពរជ័យសេនកុមារ ស្ពាយស្បៀងភៀសព្រះអង្គ ចាកចេញអំពីព្រះនគរទៅក្នុងរាត្រីដោយសេចក្តីក្តួលក្តៅចង្អឹះក្នុងព្រះឱរា ស្តេចត្រាច់ចរទៅដោយលំដាប់ ដរាបដល់ឆ្នេរទន្លេមួយអន្លើ ទើបទ្រង់ឈប់សម្រាកព្រះអង្គក្រោមដើមទម្លាប់មួយដើមក្បែរទីនោះ ហើយទ្រង់មានព្រះឱង្ការថា “ យើងនឹងឆ្លងទន្លេនេះទៅទាំងបួននាក់ពុំបានទេ ព្រោះ មានជម្រៅមិន អាចដើរឆ្លងទៅរួចទេ ដូច្នេះបងនឹងចម្លងប្អូនទៅមុនសឹមវិលមកចម្លងបុត្រជាខាងក្រោយ ” ហើយ ទ្រង់ហែលចម្លងព្រះមហេសី ទៅដាក់ត្រើយខាងនាយ ។ ក្នុងខណៈដែលក្រុងសុភមិត្រចំឡងព្រះរាជទេវីនោះ ចួនជាមានព្រានមច្ឆា ពីរនាក់អុំទូកនេសាទមកតាមឆ្នេរទន្លេ បានឃើញព្រះកុមារតូចៗ ក៏នាំគ្នាពយក ទៅដាក់ទូករៀងខ្លួន ហើយនាំទៅផ្ទះរៀងខ្លួនទៅ ។

ព្រះរាជាទ្រង់ហែលត្រឡប់មករកព្រះរាជបុត្រវិញ រកពុំឃើញព្រះរាជបុត្រនៅទីនោះសោះ ក៏ទ្រង់ព្រះដង្ហោយហៅ រត់រកព្រះរាជបុត្រក្នុងព្រៃព្រឹក្សា គ្រាតែភ្លឺស្វាងឡើង ក៏ពុំឃើញព្រះរាជបុត្រសោះ ទ្រង់ព្រះកន្សែងសោយសោក សង្រេងសង្រៃសន្លប់បាត់ព្រះស្មារតី ។

លុះទ្រង់ភ្ញាក់រលឹកព្រះស្មារតីឡើងវិញ ទ្រង់កាត់ព្រះហឫទ័យសោកស្តាយ ព្រះរាជបុត្រហើយ ត្រឡប់ទៅរកព្រះអគ្គមហេសីវិញ ប៉ុន្តែសេចក្តីសង្ឃឹមថានឹងបានជួបព្រះមហេសីដើម្បីថ្លែងប្រាប់អំពីដំណើរបាត់រាជបុត្រនោះ ទៅជាឃ្លាងស្រឡះពីសេចក្តីសង្ឃឹមរបស់ព្រះអង្គ។ ព្រះបាទសុភមិត្រទ្រង់មានកម្ម ក្រាស់ក្រៃលែងជាងអ្នកដទៃច្រើនណាស់ ព្រោះកាលដែលទ្រង់ហែលពីត្រើយខាងនាយមករកព្រះរាជបុត្រសំឡាញ់ទាំងពីរនោះចួនជាមានសំពៅមួយបើក មកតាមឆ្នេរមហានទី ជាទីដែលព្រះនាងកេសិនីទ្រង់ស្ថិត ។ នាយសំពៅបានឃើញ ព្រះនាង ក៏ឱ្យសំពៅចូលចត .ហើយគេនាំគ្នាទៅរកព្រះនា បង្ខំឱ្យព្រះនាងចុះ សំពៅទៅជាមួយនឹងពួកគេទៅគ្រានោះ ព្រះនាងទ្រង់កន្សែងសោកបោក ប្រាណ ព្រះឱរាស្ទើរនឹងបែកសណ្តែកចេញជា៧ភាគ ដោយព្រះនាងទ្រង់នឹករលឹក ដល់ព្រះរាជបុត្រសំឡាញ់ទាំងពីរ នឹងព្រះរាជស្វាមីឥតល្ហែ ។

ឯព្រះបាទក្រុងសុភមិត្រ ស្តេចឡើងពីទឹកស្ទុះសំដៅទៅរកដើមឈើ ដែល ព្រះនាងរង់ចាំ មិនឃើញព្រះនាងសោះ ទ្រង់ស្ទុះរត់រកព្រះនាងសព្វទីកន្លែង ក៏ មិនជួបប្រទះ ព្រះនាងឡើយ ទ្រង់សោយសោកសង្រេងសង្រៃខ្លាំងពេក ក៏ទ្រង់ ដួលសន្លប់នៅទីនោះទៅ ។ លុះភ្ញាក់ព្រះស្មារតីឡើងវិញ ក៏ទ្រង់ព្រះកន្សែងរវើ រវាយ ស្ទើរតែទៅជាឆ្កួតលីលា ស្តេចត្រាច់ពីទីនោះទៅតែអង្គឯកោ អនាថោ មុខ គួឱ្យអាណិតអាណោចអធម្មណាស់ ។ ស្តេចត្រាច់តែមួយព្រះអង្គឯងដរាបដល់នគរតក្កសិលា ហើយ ទ្រង់ចូលទៅក្នុងឧទ្យាន ទ្រង់ផ្ទំសម្រាកព្រះកាយពល លើថ្មមង្គលសិលាក្រោមដើមរាំង មួយដើម ។

កាលណោះ ព្រះមហាក្សត្រនៃនគរតក្កសិលា ទ្រង់សោយទីវង្គតមក ៧. ថ្ងៃហើយ ទ្រង់គ្មានព្រះរាជបុត្រាសោះ ទើបអាមាត្យមន្ត្រធ្វើពិធី ផ្សងបុស្សរថ ដំកល់គ្រឿងបញ្ចកកុធភណ្ឌ រួចដង្ហែចេញទៅតាមក្រោយបុស្សរថ ព្រមទាំងតូរ្យតន្ត្រី ។ បុស្សរថបានសំដៅទៅឧទ្យាន ធ្វើប្រទក្សិណមង្គលសិលារួចឋិតនៅ ស្ងៀម ។ ពួកភ្លេងក៏ប្រគំភ្លេងឡើង ព្រះមហាសត្វតើនឡើងបានត្រាស់សួរហេតុ នឹងអាមាត្យមន្ត្រីទាំងនោះបានក្រាបទូល អញ្ជើញព្រះអង្គឱ្យឡើងគ្រងរាជ្យ នៅនគរតក្កសិលា ។

ឯព្រានមច្ឆាពីរនាក់ ដែលបានបីបាច់ថែរក្សាកុមារទាំងពីរអង្គ លុះធំចំរើន វ័យឡើងក៏បាននាំខ្លួនចូលទៅថ្វាយដល់ព្រះបាទក្រុងតក្កសិលាធ្វើជាមហាតលិក។ ព្រះចៅក៏ទ្រង់ប្រោសប្រាណត្រាប្រណីកុមាទាំងពីរនាក់ណាស់ ប៉ុន្តែទ្រង់មិនស្គាល់ ថា កុមារទាំងពីរនេះជាព្រះរាជបុត្ររបស់ព្រះអង្គសោះឡើយ ។

ចំណែកខាងនាយសំពៅ ដែលបាននាំព្រះនាងកេសនីទៅនោះ ដោយ បំណងចង់រួមវាសនានឹងព្រះនាង ប៉ុន្តែដោយតេជះ សច្ចះ នឹងក្តីស្វាមីភក្តិចំពោះ ព្រះស្វាមី ព្រមទាំងចេស្តាបារមីនៃព្រះបាទក្រុងសុភមិត្រ ធ្វើឱ្យនាយសំពៅមិន អាចចូលទៅជិតព្រះនាង ព្រមទាំងមានសេចក្តីគោរពកោតខ្លាច មិនអាចប្រទូស្ត ព្រះនាងបានឡើយ ។ កាលកន្លងមក ៧ ឆ្នាំនាយសំពៅបានទៅធ្វើជំនួញនៅក្រុងតក្កសិលា បាននាំភស្តុភារបណ្ណាការឡើងថ្វាយព្រះចៅតក្កសិលាហើយក្រាបបង្គំលាត្រឡប់ទៅវិញព្រះរាជាទ្រង់មានព្រះបន្ទូលថា ឱ្យពួក

នាយសំពៅរង់ចាំមើលមហោស្រព ១ យប់សិន ហើយទ្រង់មានបញ្ជាឱ្យចៅ ជយសេន នឹង ចៅជយទត្ត ជាមហាតលិកទៅនៅ,ចាំយាមសំពៅនៅក្នុងរាត្រីនោះ ។

ក្នុងពេលរាត្រីនេះ ព្រះនាងកេសិនីទ្រង់ព្រះសុបិនថា ព្រះអង្គនាងព្រះបាទ សុភមិត្រ ព្រះរាជបុត្រទាំងពីរបានជួបជុំគ្នា នៅទីសាលាវិនិច្ឆ័យ ។ មានបុរសពីរ នាក់យកផ្កាឈូកមកថ្វាយព្រះស្វាមី ប្រទានមកព្រះនាង សៀតលើព្រះកាណ៌ ហើយទ្រង់សោយលំអងផ្កាឈូកនោះ ។ ព្រះនាងតើនឡើងទ្រង់ព្រះកន្សែងទ្រង់ រំពឹងគិតថា ព្រឹកស្អែកនេះ ប្រហែលអញនឹងបានជួបព្រះស្វាមីនឹងកូនទាំងពីរ របស់អញ ។

លុះដល់អធ្រាត្ររាត្រី ជនប្រុសស្រីដេកលក់អស់ ជយទត្តលក់ទាំងអង្គុយ ជយសេនក៏ដាសខ្លួនជារឿង ជយទត្ត មិនចង់ឱ្យការងុយងោកគ្របសង្កត់ពេក ក៏បាននិយាយនឹងបងថា សូមអ្នកបងនិយាយរឿងព្រេងអ្វីមួយឱ្យប្អូនស្តាប់ផង ។ បងមិនចេះរឿងព្រេង ចេះដឹងតែរឿងរ៉ាវដែលយើងព្រាត់ប្រាសពី មាតា បិតា របស់យើង ចុះមាតា បិតាយើងនៅទេសព្វថ្ងៃនេះមិន មែនឬអ្វី ? មិនមែនទេប្អូន បងនឹងនិយាយឱ្យស្តាប់ ។ ដើមឡើយ មាតាបិតាយើងជាស្តេចគ្រងរាជ្យ នៅចម្បាកនគរ ព្រះ អនុជរបស់ព្រះអង្គ ព្រះនាមអសុភមិត្រ ទីឧបរាជបានដណ្តើមរាជ្យពីព្រះវរបិតា យើងៗ ក៏នាំយើងតូចៗ ទាំងពីរនាក់ដោះខ្លួនរត់ចោលព្រះនគរ លេចវាលចូលព្រៃ ដ៏រាបដល់ទន្លេមួយ ព្រះវរបិតា នាំព្រះវរមាតាហែលឆ្លងចន្លោះនោះទៅ បន្តិច មានព្រានមច្ឆា អុំទូកចូលមកចាប់យើងទាំងពីរនាក់យកទៅចិញ្ចឹមរក្សាត្រាតធំ ឡើង ហើយនាំខ្លួនមកថ្វាយព្រះចៅក្រុងតក្កសិលានេះឯងជ័យទត្តកុមារសួរទៀតថា ព្រះវរបិតាមាតាយើងព្រះនាបដូចម្តេច ? ។ ជយសេនឆ្លើយថា ព្រះ មាតាយើង ព្រះនាមកសិធីទេវី ។ ឯព្រះវរបិតាបងមិនហ៊ានចេញព្រះនាមព្រះ អង្គទេ ដល់ប្អូនទទូចសួរខ្លាំងពេក នឹងលាក់លៀមតទៅទៀតមិនបានទើប បងប្រាប់ទៅប្អូនថា សូមប្អូនកុំនិយាយចេញព្រះនាមឱ្យសោះ គឺ ព្រះនាមព្រះវរបិតាយើងដូចព្រះនាមស្តេចក្រុងតក្កសិលានោះឯង ព្រះនាមព្រះវរបិតាយើង គឺព្រះបាទក្រុងសុភមិត្រ ។

ឯព្រះនាងកេសនី នៅខាងក្នុងសំពៅបាន ឮសំដីកុមារទាំងពីរនិយាយ ឆ្លើយឆ្លងគ្នាដូច្នោះ ព្រះនាងទ្រង់ជ្រាបច្បាស់ថា ពិតជាបុត្រកំសត់ទាំងពីររបស់ ព្រះនាងស្របតាមសុបិនរបស់ព្រះនាង ស្ទុះចេញមករកកុមារទាំងពីរទ្រង់ព្រះកន្សែងសោក ទ្រង់ឱបព្រះរាជបុត្ររន្ធត់ក្នុងព្រះទ័យក្រៃលែង ។ ព្រះកុមារទាំង ពីរភិតភ័យស្ទុះរត់ចេញទៅ ។ ព្រះនាងមានព្រះបន្ទូលហៅព្រះរាជបុត្រថា ជយសេន ! ជយទត្ត ! កូនកំសត់ម្តាយអើយ ម្តាយនេះហើយឈ្មោះនាងកសិនី ទេវី ចូរអ្នកស្គាល់ ម្តាយចុះ ចូរអ្នកមករកម្តាយវិញ ម្តេចក៏អ្នករត់គេចចេញពី ម្តាយដូច្នេះ ?

កុមារទាំងពីរ បានដឹងជាក់ច្បាស់ជាព្រះមាតាពិតប្រាកដហើយ ក៏នាំគ្នាស្ទុះ ទៅឱបបាទជើងព្រះមាតា ទ្រង់ព្រះកន្សែងសោកមហិមា ។ ពួកអ្នកភេត្រា បានឃើញដូច្នោះ ក៏នាំសេចក្តីជំរាបដល់នាយភេត្រា ក៏ក្រាបទូលព្រះចៅក្រុងតក្កសិលាដោយចោទប្រកាន់ថា កុមារទាំងពីរនាក់ដែលត្រាស់ប្រើឱ្យទៅនៅចាំ “ យាមភេត លួចសហាយស្មន់នឹងប្រពន្ធរបស់ខ្លួន ។ ព្រះចៅ

ក្រុងតក្កសិលាទ្រង់ ព្រះពិរោធជាខ្លាំង ក៏ត្រាស់ប្រើពេជ្ឈឃាត ឱ្យចាប់កុមារទាំងពីរយកទៅពិឃាតបង់ ។ ឯពេជ្ឈឃាតក៏ចាប់ចងវាយដំកុមារទាំងពីរតែតត្រាប្រណី ហើយនាំចេញ ទៅនឹងពិឃាតតាមព្រះរាជអាជ្ញា ។ ចួនជាកាលណោះ មានបុរោហិតម្នាក់ជាអ្នក មានប្រាជ្ញា បានឃើញពេជ្ឈឃាតបណ្ដើរកុមារទាំងពីរនាក់ យកទៅពិឃាត ដូច្នោះ ក៏សង្ស័យហើយសួររកដើមហេតុ ទើបឃាត់ទុកមួយខណៈសិន ហើយ ព្រាហ្មណ៍ចូលទៅក្រាបទូលសួរថា ព្រះអង្គបានជំនុំពិចារណាទោសរួចហើយឬនៅ ឡើយទេ ? ។ ទ្រង់ត្រាស់ថា មិនទាន់ជំនុំជំរះទេ ហើយទ្រង់បញ្ជាឱ្យនាំកុមារពីរ នាក់នោះត្រឡប់ចូលមកជំនុំជំរះវិញសិន ។

ក្រោយដែលទ្រង់បានពិនិត្យសួររឿងហេតុសព្វគ្រប់ទៅ ទើបទ្រង់ជ្រាបថាកុមារទាំងពីរឥតមានកំហុសអ្វីសោះ កាលទ្រង់ជ្រាបជីវប្រវត្តិរបស់កុមារពីរនាក់ហើយ ក៏ទ្រង់យល់ជាក់ច្បាស់ថា កុមារពីនាក់ ជយសេន ជយទត្ត ពិតជាព្រះរាជ បុត្រកំសត់របស់ព្រះអង្គ ប្រាកដមែន ។ ស្ដេចស្ទុះទៅឱបព្រះរាជបុត្រ ទ្រង់ព្រះ កន្សែងសោកមហិមា ដោយអាណិតអាសូរព្រះរាជបុត្រកំសត់របស់ព្រះអង្គលើស លន់ពន់ប្រមាណ ។

ព្រះមហាក្សត្រទ្រង់សុំឱ្យព្រះរាជបុត្រ នាំទ្រង់ទៅជួបនឹងព្រះនាងកេសិនី អគ្គមហេសីឯកឯក ហើយក្សត្រាក្សត្រីទាំងបួនអង្គក៏បានជួបជុំយំសោក ស្រណោះស្រណោចយំខ្លាំង ដោយការកំសត់កម្រនឹងការព្រាត់ប្រាសនិរាសគ្នារឿងសុភមិត្តរស់កាលយូរអង្វែង ។ នៅទីបំផុតអាមាត្យមុខមន្ត្រីសេនាយោធាបានរៀបក្បួន ដង្ហែក្សត្រា ក្សត្រីទាំង ៤ ចូលមកក្នុងព្រះរាជដ្ឋាន ។ ព្រះបាទក្រុងសុភមិត្រទ្រង់ អភិសេកព្រះនាងកេសនីជាអគ្គមហេសី ។ ជយសេនកុមារជាទីឧបរាជ ជយទត្ត កុមារជាទីសេនាបតី ក្សត្រាក្សត្រីទាំង ៤ អង្គ ឋិតនៅក្នុងរាជសម្បត្តិជាសុខ មនោរម្យអស់កាលជាអង្វែងតទៅ ។

## ១.សេចក្ដីវិភាគរឿង

### ក.អត្ថន័យខ្លឹមសារ

អត្ថន័យអត្ថ .ប្រយោជន៍.អត្ថន័យ .ការណែនាំអត្ថាធិប្បាយសេចក្ដីពន្យល់.អត្ថន័យជាគំនិតសំខាន់ៗរបស់អ្នកនិពន្ធដែលលាតត្រដាងនៅក្នុងដំណើររឿង ហើយគេអាចហៅវាថាជាជម្រៅនៃរឿង។

ក្នុងផ្នែកអត្ថន័យមាន ប្រធានរឿង មូលបញ្ហារឿងនិងឧត្ដមគតិរឿង។

ខ.ប្រធានរឿង មូលន័យ

ប្រធានរឿងឬមូលន័យ គឺជាគំនិតសំខាន់ៗរបស់រឿង។ប្រតិឬជាបញ្ហារួមរបស់រឿង។តែអ្នកនិពន្ធចង់បង្ហាញដល់អ្នកអានប្រធានរឿងជាបញ្ហារួបផ្ដុំបំផុតដែលអ្នកនិពន្ធលើកយកមកសរសេរឬជ្រើសរើសជាប្រធានបទហើយដែលមានមូលបញ្ហារឿងឋិតនៅក្នុងនោះ។

ប្រធានរឿងបង្ហាញនៅចំហររបស់អ្នកនិពន្ធវាជាមូលដ្ឋានដើមរបស់អ្នកនិពន្ធក្នុងការចាប់ផ្ដើមសរសេរឡើង។មុនពេលចាប់ផ្ដើមសរសេរឡើង។អ្នកនិពន្ធគ្រប់រូបត្រូវកំណត់ថាតើគាត់ត្រូវសរសេរអំពីអ្វី។អំពីជីវិតសង្គមសង្គ្រាមស្នេហារឿងជំនឿទនៀមទម្លាប់ប្រពៃណីចម្លើយរបស់សំណួរនេះហើយជាប្រធានរឿង។

នៅក្នុងស្នាដៃរឿងបញ្ញាសជាតកតាមរយៈការអានរឿងនេះជាច្រើនលើកច្រើនសារយើងខ្ញុំរកឃើញនិង សំរេចជ្រើសរើសយក ប្រធាន រឿងដែលក្ដោបសាច់រឿងទាំងមូលនោះការបំពេញមេត្តាបារមី ព្រោះយើងឃើញ ថារឿងនេះ មិនមែនត្រឹមតែអប់រំតាមបែបពុទ្ធសាសនាប៉ុណ្ណោះ ទេ ពោលគឺទស្សនៈកម្មផល បានន័យថាកម្មបែប ណាផលបែបនោះ ។

### គ.មូលបញ្ហារឿង

មូលបញ្ហារឿងគឺជាភាពចំណែកនៃប្រធានរឿងជាទិដ្ឋភាពផ្សេងៗរបស់យើង។វាជាការចូលជ្រៅទៅក្នុងប្រធានរឿង។

ជុំវិញប្រធានរឿងនេះ យើងបានកំណត់បញ្ហាជាច្រើន ដែលនៅជុំវិញការកសាងសីលបារមីរបស់ព្រះពោធិសត្វ បញ្ហាទាំងនោះរួមមានៈ

## ទី១ បញ្ហាការដណ្តើមរាជរបស់ស្តេចអសុភមិត្រ

ការដណ្តើមរាជរបស់ស្តេចអសុភមិត្រ មកលើព្រះបាទក្រុងសុភមិត្រ ព្រះអង្គសុភមិត្រមានចិត្តអានិតមេត្តាចំពោះ ប្រជានុរាស្ត្ររបស់ព្រះអង្គ ក៏ចាកចេញពីព្រះនគរទាំងកណ្តាលរាត្រី ការធ្វើដំណើរដោយដើរទាំងបុត្រនិងមហេសី លុះដល់ឆ្នេរទន្លេបានឈប់សម្រាក បាននិយាយនិងមងេសីថា ទឹកមានជម្រៅយើងមិនអាចឆ្លងទៅទាំងអស់គ្នាបានទេ បងនិងចម្លងប្អូនទៅមុន បុត្រទាំងពីរបាននៅច្រាងម្ខាង ។ ក្រោយមកមានព្រានបច្ឆាអំទូកមកនាំយកព្រះកុមារទាំងពីរទៅចិញ្ចឹមបាត់ទៅ ។ ព្រះបាទសុភមិត្រមករកបុត្រមិនឃើញ ព្រះមហេសីបាននាយសំពៅចាប់យកទៅបាត់ដែរព្រះបាទសុភមិត្រនៅម្នាក់ឯងយំសោកសន្លប់ស្មារតី។

សរុបសេចក្តីមកយើងត្រូវមានសាគ្គីភាពជាមួយគ្នាជានិច្ច ចេះអត់អោនឱ្យគ្នា និងរស់នៅប្រកបដោយធម៌ ជួយឱ្យប្រទេសមានការអភិវឌ្ឍន៍។

ទី២ បញ្ហាការឡើងគ្រងរាជព្រះបាទសុភមិត្រនៅនគរកកតសិលា

នៅពេលព្រះបាទសុភមិត្រ បានធ្វើដំណើរដល់នគរកកតសិលា បានសម្រាកនៅទីនោះ។ ព្រះបាទនគរកកតសិលាបានសោយទិវង្គតប្រាំពីរថ្ងៃហើយទ្រង់គ្មានរាជបុត្រសោះទើបអាមាត្រមុខមន្ត្រីបានផ្សងបុរ័ត្ន ៗ បានសំដៅទៅឧទ្យានស្ថិតនៅស្ងៀម ពេលព្រះអង្គភ្ញាក់ឡើង អាមាត្រ មន្ត្រីបានរៀបចំពិធីលើកព្រះអង្គឱ្យឡើងគ្រងរាជ ។ ក្រោយមកព្រានបច្ឆាបាននាំ ជ័យសែន និងជ័យទតមកថ្វាយព្រះបាទសុភមិត្រធ្វើជាអាមាត្រ ព្រះអង្គស្រឡាញ់ពួកគេខ្លាំងណាស់។ ក្រោយមកនាយសំពៅបានមកធ្វើជំនួញនៅនគរកកតសិលា បានយកគ្រឿប្រដាប់មកថ្វាយប្រះបាទ សុភមិត្រ ព្រះអង្គឃាត់ឱ្យនៅមើលមហោស្របមួយយប់សិន បានចាត់ឱ្យជ័យសែននិងជ័យទតទៅយាមសំពៅ ។ជ័យទតលក់ទាំងអង្គុយ បងបានដាស់ប្អូនៗបានសួរបងចេះនិទានរឿងអ្វីឱ្យប្អូនស្តាប់ បងមិនចេះរឿងអ្វីទេ ដឹងតែរឿងយើងព្រាត់ពីមាតា បិតារបស់យើង ចុះមាតា បិតាយើងសព្វថ្ងៃមិនមែនទេឬ មិនមែនទេប្អូន មាតាឈ្មោះកេសនីទេវីនិងបិតាសុភមិត្រ ។ ព្រះនាងកេសនីបានឮចេញមកអោបបុត្រទាំងពីរពួកគេបានដឹងការពិតហើយបុត្រព្រះមាតា បិតាបានជួបជុំគ្នានិងរស់នៅយ៉ាងសុខសាន្ត។

សរុសេចក្តីមកការខន្តីជំពោះអ្នកបានប្រព្រឹត្តមិនល្អ បាននាំសេចក្តីសុខមករកយើងការចេះអធ្យាស្រ័យនាំឱ្យគ្មានទំនាស់ និងចេះរស់នៅចុះសម្រុងគ្នាបាន។

## ឃ.ឧត្តមគតិរឿងគំនិតដឹកនាំរឿងតម្លៃអប់រំ

ឧត្តមគតិរឿងគឺជាឧត្តមគតិរបស់អ្នកនិពន្ធ។ឧត្តមគតិរឿងគឺយកកត្តាប្រធានវិស័យដែលបញ្ហដែលបញ្ជាក់ពីគោលជំហរសតិអារម្មណ៍របស់អ្នកនិពន្ធដែលស្តែងឡើងតាមរយៈសកម្មភាពរបស់តួអង្គ។

- តម្លៃងប់រំនសរៀងក្រុងសុភមិត្រ គឺ ជួយឱ្យយើងចេះជួយសង្រោះក្នានៅពេលមានអាសន្ន ដូចបុត្រតាំងពីររបស់ស្តេចសុភមិត្រនោពេលនៅតែពីរនាក់បងប្អូនត្រូបានព្រានបច្ឆាជួយសង្គ្រោះ ចំណែកមហេសីរបស់ព្រះអង្គបាននាយសំពៅជួយសង្រោះ ព្រានព្រៃនៅពេលវង្វេងផ្លូវបានព្រះបាទសុភមិត្រ នៅពេលរសាតង អណ្តែតនៅក្នុងសមុទ្របានប្រះនាងមេខលារក្សាសមុទ្ធជួយសង្គ្រោះដូចនេះ និងយើងឃើញនៅក្នុងសង្គមខ្មែរក៏បែបនេះដែរ

- អប់រមឱ្យមានសុខសន្តិភាព គ្មានអំពើងឹង្សាកាប់សម្លាប់គ្នានាឱ្យប្រជាជនរងទុក្ខទោស នោះឡើយព្រះបាទសុភមិត្របានចេញពីនគរ។

- អប់រំឱ្យចេះត្រិះរិសពិចារណាគិតផលប្រយោជន៍រួមជាតិជាធំ មុនគិតផលប្រយោជន៍ផ្ទាល់ខ្លួន។

សរុបរយមមកអក្សរសិល៍្បពុទ្ធនិយមក្លាយ បានអប់រំដល់មនុស្សទូទៅឱ្យចេះប្រតិបត្តិតែអំពើល្អគ្រប់បែបបយ៉ាងរស់នៅចេះមានចិត្តមេត្តាករុណាចំពោះមនុស្សរស់នៅជុំវិញខ្លួន។

# សង្ខេបរឿង ទេវន្ទ

អតីត កាលក្នុងកាលកន្លងយូរអង្វែងហើយនោះ ព្រះមហាក្សត្រមួយអង្គ ព្រះនាមព្រះបាទព្រហ្មទត្តគ្រងរាជសម្បត្តិក្នុងក្រុងពារាណសី មានព្រះមហេសី ព្រះនាមវិមលាទេវី ១ តែគ្មានព្រះរាជបុត្រាបុត្រីមួយអង្គ, សោះ តមក ព្រះនាងរក្សាសីល ៥ ចាំសីល ៨ យ៉ាងបរិសុទ្ធ ដោយតាំងចិត្ត ប្រាថ្នាសុំឱ្យមានព្រះរាជបុត្រមកចាប់បដិសន្ធិ ក្នុងផ្ទៃនៃព្រះនាង ។

ព្រះឥន្ទ្រាធិរាជ បានទ្រង់ជ្រាបចំណង់នៃព្រះនាង ទ្រង់ទៅអញ្ជើញទេវបុត្ត ដែលជាតួអង្គព្រះពោធិសត្វ ឱ្យច្យុតចុះចាប់បដិសន្ធិក្នុងឋានមនុស្សលោក ។ ក្នុងរាត្រីព្រះនាងវិមលាទេវី ទ្រង់ព្រះសុបិនថា មានទេវបុត្រមួយអង្គ កាន់កែវរជី ពេជ្រ ហោះចុះមក ដាក់កែវមណីនោះលើ ព្រះហស្តព្រះនាងក៏បានទទួលយកដោយក្តីសោមនស្សក្រៃលែង។ ស្រាប់តែមានទេវបុត្តខ្វាក់មួយអង្គ ចូលមកយាយី ប្រជាជនក្នុងព្រះនគរ ហើយកែវរជីវរត្ននោះ លោវិនាសបាត់ព្រះនាងទៅ ។ លុះយូរលង់ទៅទើបរជីរនោះវិលមកនៅនឹង ព្រះនាងវិញ ហើយទេវបុត្រខ្វាក់នោះក៏វិនាសអន្តរាយទៅ ទើបព្រះនាងក្រាបបង្គំទូលព្រះរាជស្វាមី អំពីសុបិននិមិត្តចំឡែកនោះ ព្រះ រាជាត្រាស់សួរបញ្ញាក់ពួកហោរា ក្រាបទូលថា ព្រះរាជទេវីនឹងមានព្រះរាជទេវី មានព្រះរាជបុត្រ មានបុណ្យបារមីល្បីអស្ចារ្យ។ ឯទេវបុត្រខ្វាក់នោះ បានដល់ យក្ខយង់ចិត្តសាមឲ្យធ្វើឱ្យព្រះរាជបុត្រព្រាត់ប្រាសពីព្រះវរមាតាបិតា ប៉ុន្តែ ក្រោយមកពីរាជបុត្រស្តេចវិលត្រឡប់មកវិញ ទើបអាចកំចាត់យក្សយង់នោះចេញបាន ហើយទ្រង់នឹងមានព្រះកិត្តិនាមល្បីល្បាញខ្ចរខ្ចាយក្នុងសកលជម្ពូទ្វីប។

តមក ព្រះនាងទ្រង់គភ៍គ្រប់ទសមាស ប្រសូតព្រះរាជបុត្រ មានព្រះរូប ឆោមឆើតក្រៃលែង ព្រះវរបិតា ប្រទាននាមថា “ទេវន្ទកុមារ”។ លុះព្រះកុមារ ចេះដើរដួល ព្រះនាងវិមលាទ្រង់គភ៍ទៀត គ្រប់ទសមាស ព្រះនាងប្រសូតព្រះ រាជបុត្រីមួយព្រះអង្គទៀត មានរូបឆោមសោភាប្រិមប្រិយ ព្រះវរបិតា ប្រទាននាមថា “ចន្ទ្រាកុមារី” ។

ថ្ងៃមួយ ព្រះបាទព្រហ្មទត្តជាព្រះវរបិតា ស្តេចព្រះចតុរង្គសេនាចេញទៅ ប្រពាតព្រៃដើម្បីកំសាន្តព្រះហឫទ័យ ទ្រង់គង់ពាជីដេញចាប់ម្រឹគីម្រឹគាក្នុងព្រៃ។ គ្រានោះ មានយក្ស ១ រ រាស្រ័យនៅនឹងដើមជ្រៃ ១ ក្នុងព្រៃធំនោះ ឈ្មោះនន្ទិយកំពុងត្រេចស្ទុះស្វែងរកអាហារភោជនដោយក្តីស្រេកឃ្លានជាខ្លាំងស្រាប់តែបានឃើញព្រះរាជាចេញតាមចាប់ម្រឹគ យក្សត្រេកអរណាស់ ចង់ចាប់មហាក្សត្រស៊ីចំអែតផ្ទៃវា ។ យក្សយង់បានកាឡាអាត្មាជាប្រើសមាស ទៅ លោតលេងក្បែរទីព្រះពន្លាភា ហើយទៅលាក់ខ្លួនពួននៅស៊ុមទ្រុមគុម្ពឈើ មួយ ព្រះមហាក្សត្រ ទ្រង់បានទតឃើញម្រឹគមាស ទ្រង់សព្វព្រះហឫទ័យ ណាស់ ត្រាស់បង្គាប់ពួកពលសេនាឱ្យឡោមព័ទ្ធចាប់ម្រឹតមាសឱ្យបាន ។ ឯយក្ស កាឡាធ្វើអាការហាក់ដូចភិតភ័យណាស់ តាំងលោកផ្លេកផ្លោះឆ្លេឆ្លា ហើយរត់រួចទៅនៅចំពោះព្រះភក្រ្តព្រះមហាក្សត្រ មានក្តីអៀនខ្មាសពួកពលសេនា ទ្រង់បានបំផាយសេះ ដេញតាមម្រឹគនោះទៅតែមួយ ព្រះអង្គឯង ដាច់ឆ្ងាយពីរាជ បរិវារ ។ ម្រឹគមាស បានឱកាសល្អដូច្នោះ ក៏ប្រែប្រាណជាយក្សយងឃោរឃៅ មួយរំពេច ហើយវាចាប់ព្រះមហាក្សត្របរិភោគជាអាហារ វាប្រុងនឹងចាប់សេះ ស៊ីទៀត ។ ឯសេះគិតរកឧបាយបោកបញ្ឆោតយក្សវិញ ដោយនិយាយថា “ បពិត លោកដ៏មានមហិទ្ធិរឹទ្ធិ - បើលោកបរិភោគសាច់ឈាមខ្ញុំនៅពេលនេះ បានឆ្អែត ត្រឹមមួយថ្ងៃប៉ុណ្ណោះ ប្រសិនបើលោកកាឡាជាព្រះបាទព្រហ្មទត្តទៅគ្រងរាជ្យ នៅនគរពារាណសីវិញនោះ លោកនឹងមានអាហារភោជន មិនខ្វះខាត សូម អញ្ជើញលោកឡើងជិះខ្នងខ្ញុំទៅកាន់ព្រះពន្លាភាក់ ឥឡូវនេះចុះ” ។ សេះនិយាយ ដូច្នេះប្រយោជន៍ឱ្យមានជីវិតរស់នៅ ដល់ទៅក្រុងពារាណសី នឹងចូលដំណឹងពិត ដល់ព្រះរាជបុត្រនៃព្រះបាទព្រហ្មទត្ត ។

ឯនន្ទិយក្ស ក៏យល់ស្របតាមគំនិតរបស់សេះ ទើបឡើងលើខ្នងសេះ បរសំដៅទៅរកពួកពលសេនា ដង្ហែក្សត្រក្លែងក្លាយនោះ ចូលទៅក្នុងក្រុង ពារាណសី ឥតនរណាមួយ រង្កៀសសង្ស័យថាព្រះមហាក្សត្ររបស់ខ្លួន

យក្ស ចង់ឃោរឃៅសោះ ។ តមកពីរ បីថ្ងៃនន្ទិយក្សគិតឃើញថា ខ្លាចក្រែងសេះ ទោះនឹងនិយាយប្រាប់រឿងខ្លួនឱ្យអ្នកដទៃបានដឹង ឮទើបបង្គាប់អាមាត្យឱ្យចាប់ សេះដាក់ទ្រុងដែកបង្អត់ស្មៅ នន្ទិយក្ស តែងជំនុំជំរះកាត់ទោស នាហ្មឺនមន្ត្រី ដែលមានកំហុសបន្តិចបន្តួចបង្គាប់ឱ្យពេជ្ឈឃាត ចាប់ខ្លួនយកទៅដោតលើឈើ អណ្តែត ដល់ពេលយប់ស្ងាត់យក្សចេញទៅស៊ីមនុស្សដែលជាប់ទោសទាំងនោះ រៀងរាល់រាត្រី . មិនតែប៉ុណ្ណោះសោត យក្សយង់តែងឃ្លាំមើល មនុស្សខ្វាត់ ភ្លាត់ពីទីលំនៅ ឬ ពីភូមិស្រុក ទាំងចាស់ទាំងក្មេង តែងត្រូវយក្សចាប់ស៊ី

ទាំង អស់ ។ ម្ល៉ោះហើយ ប្រជារាស្ត្រទាំងប្រុសទាំងស្រី ព្រមទាំងនាហ្មឺនមន្ត្រី បានក្តី ក្តៅក្រហាយទូទៅ ទាំងជឿងឆ្ងល់ណាស់ចំពោះអង្គព្រះមហាក្សត្ររបស់ខ្លួន

ដែលពីដើមធ្លាប់មានព្រះទ័យមេត្តាករុណាប្រជារាស្ត្រ ឥឡូវប្រែជាមានព្រះទ័យ ឃោរឃៅយ៉ាងចំឡែក ថែមទាំងបាត់រូបមនុស្សក្មេងចាស់រៀងរាល់ថ្ងៃ ដោយ ឥតហេតុផលសមសួនសោះ ។ នៅខាងក្នុងរាជដ្ឋាន ក៏ដូចជាខាងក្រៅរាជដ្ឋាន ឥតនរណាមួយយល់ថា ព្រះមហាក្សត្ររបស់ខ្លួន ជាយក្សកាឡាខ្លួនមកគ្រងរាជ្យសោះ ។

ជួនជាថ្ងៃមួយ ព្រះទេវន្ទកុមារនឹងនាងចន្ទ្រាកុមារីជាអនុជ បណ្តើរគ្នាចេញ មកក្រសាលលេងខាងក្រៅព្រះរាជដ្ឋាន ទ្រង់បានទតឃើញពាជីទីនាំព្រះវរបិតា ជាប់ទ្រុងស្គាំងស្គមក៏បានយាងចូលទៅជិតទ្រុង ។ សេះអត់អាហារមកយូរថ្ងៃ ស្ទើរតែនឹងស្លាប់នោះ បានក្រឡេកឃើញព្រះរាជបុត្រយាងមកជិតទ្រុង ក៏មាន សេចក្តីត្រេកអរណាស់ ព្រោះសមដូចបំណងដែលប៉ងទុកមកក្នុងចិត្តយូរហើយ ទើបទូលសុំឱ្យព្រះកុមារឱ្យចូលមកជិតទៀត នឹងទូលការណ៍អាថ៌កំបាំងសំខាន់ បំផុតមួយឱ្យបានទ្រង់ជ្រាប ។ ព្រះរាជកុមារ កុមារី បានទ្រង់ជ្រាបអាថ៌កំបាំង ទ្រង់ជឿងឆ្ងល់ណាស់ ហើយទ្រង់តក់ស្លុតរន្ធត់ក្នុងដួងហឫទ័យក្រៃលែង ។ សេះបានទូលតទៅទៀតថាសូមព្រះរាជកុមារសំដែងអាការៈស្និទ្ធស្នាលនឹងក្រុងយក្សដូចប្រក្រតីធម្មតា សូមឱ្យសង្កេតមើលភ្នែកនៃក្រុងយក្សគ្មានរូបកូនក្រមុំក្នុង កែវភ្នែកដូចមនុស្សលោកទេ មួយវិញទៀត សូមព្រះរាជកុមារលួងលោមក្រុង យក្សឱ្យហាមាត់ឡើង ទ្រង់នឹងទតឃើញអណ្តាតភ្លើងអ្នកចេញពីក្នុងមាត់យក្ស ជាក់ស្តែង សូមទ្រង់ចុះថា ក្សត្រគ្រងរាជ្យនេះ មិនមែនព្រះវរបិតាទ្រង់ទេ គឺជា ក្រុងយក្សពិតប្រាកដ យក្សចាប់ទូលបង្គំដាក់ទ្រង់បង្អត់អាហារឱ្យស្លាប់នេះ ប្រយោជន៍បំបាត់ដានអាថ៌កំបាំងនេះឯង ព្រោះមានតែទូលបង្គំមួយទេ ដែលបាន ដឹងការណ៍អាថ៌កំបាំងរបស់វា។ មួយខទៀត សូមទ្រង់ចូលក្រុងយក្សថា " សេះ នោះព្រះវរបិតាធ្លាប់មានព្រះបន្ទូលថា នឹងព្រះរាជទានដល់ទូលព្រះបង្គំរួចទៅ ហើយនោះ ដាក់ក្តីឱ្យគ្នាវេទនាជិតស្លាប់ដូច្នោះ សូមទ្រង់មេត្តាដោះលែងចេញ ទូលព្រះបង្គំនឹងហាត់ជិះលេងកំសាន្ត" ។

ព្រះចន្ទកុមារ ក៏បានធ្វើការពិសោធន៍ដូចពាក្យសេះប្រាប់សព្វគ្រប់ បានឃើញជាក់ស្តែងដូច្នោះមែន ទើបព្រះរាជកុមារទូលសុំសេះជាប់ក្តីនោះ ។ ក្រុងយក្សត្រាស់ថា "សេះនោះមានពុតណាស់ ពេលបិតាដេញតាមប្រើសមាស វា មិនខំបោលឱ្យលឿនទេ ត្រាតែប្រើសមាសរត់រួចទៅ ទើបបិតាឱ្យដាក់ក្តីបង្អត់ អាហារវា កុំកូនចង់បានវាឡើយ សេះល្អមានច្រើនណាស់ កូនឯងរើសយក តាមចិត្ត ត្រង់សេះជាប់ទោសនោះ កុំចង់បានវាឡើយ" ។ ឯព្រះរាជកុមារទទូច អង្វរសុំតែសេះមួយនោះ នោះបីល្អអាក្រក់យ៉ាងណា ព្រះវរបិតាបានលាន់ព្រះឱស្ឋ ព្រះរាជទានហើយ សូមកុំឱ្យបង់ពាក្យសច្ចៈ ក្រុងយក្សទាល់គំនិត ក៏បានបង្គាប់ ឱ្យដោះលែងសេះនោះប្រគល់ដល់ព្រះទេវន្ទកុមារ ទ្រង់បានចំនុកបំរុងសេ ត្រាតែមានកម្លាំងជាត់ធំដូចដើមឡើងវិញ ។ ពាជីបានបង្ហាត់បង្រៀនព្រះ រាជកុមារ-រាជកុមារី ឱ្យឡើងជិះលើខ្នងខ្លួនត្រាតែចេះជិះស្ទាត់ជំនាញ ។

ថ្ងៃមួយ ពាជីទូល ព្រះរាជកុមារថា "សូមទ្រង់ទូលលាព្រះវរមាតានឹងក្រុង យក្សទៅទតឧទ្យានជាការកំសាន្ត សឹមយើងចេញទៅក្នុងព្រៃឆ្ងាយ ដើម្បីសង្កេត ចំណាំផ្លូវចេញចូលពឹងពួនអាត្មាក្នុងអធ្យា ហើយយកអាហារក្រៀមក្រស់បង្កប់ទុក ចោលនៅទីនោះខ្លះផង បង្ការក្រែងមានក្តីក្រងាយទៅថ្ងៃក្រោយ នៅពេល ដែលយើងរត់ចេញចាករាជធានី រត់ទៅជ្រកអាស្រ័យនៅប្រទេសដទៃ សឹមយើង គិតគូររកកំឡាំងទ័ពមកកំចាត់ក្រុងយក្សឃោរឃៅ ដែលបានពិឃាតព្រះវរបិតា ទ្រង់ ដើម្បីសងសឹកវាឱ្យបានសម្រេច រួចសឹមស្តេចឡើងគ្រងរាជ្យដែលជាកេរ្តិ៍មត៌ករបស់ព្រះវរបិតា ។

ព្រះទេវន្ទកុមារ ទ្រង់បានសណ្តាប់យោបល់នៃពាជី ក៏ទ្រង់យល់ស្របតាម ទាំងកើតខត្តិយមានយ៉ាងខ្លាំងក្លា ចង់ធ្វើការសងសឹកជំនួសព្រះវរបិតាឱ្យបាន សម្រេច ដល់ព្រឹកព្រាងឡើង ព្រះរាជកុមារនឹងព្រះអនុជនាំគ្នាចូលគាល់ ព្រះ វរមាតា ទូលទៅប្រពាតឧទ្យានជាការកំសាន្ត ទូលសុំបាយកញ្ចប់នឹងអាហារ ត្រៀមខ្លះ បង្ការក្រែងស្រេកឃ្លាននៅពេលល្ងាច ព្រះវរមាតាផ្តាំថា កូនទៅ លេងកំសាន្តកុំនៅយូរដល់យប់ មើលថែរក្សាប្អូនផង ថ្ងៃរសៀលវិញថ្កានម្តាយ ព្រះរាជកុមារទាំងពីរអង្គក៏បានឡើងទូលលាក្រុងយក្ស ក៏វិញកុំខាន។ អនុញ្ញាតតាមចំណង់ព្រះរាជកុមារកុមារី ឡើងគង់លើខ្នងពាជីបានសង្កត ច្រកពៃព្រៃព្រឹក្សា ។ ព្រះទេវកុមារសំណងក្នុងព្រៃ សំពាយទុកព្រះវរស់ ។ ការ ពារចាំទ្រង់វិញពារ ។ តមកក្រោយ ព្រះរាជកុមារទាំងពីរពង្សតែងទ្រង់គង់ព្រៃទៅប្រលង១០០ យោជា អាមវិលត្រឡប់មកដល់នគរនៅពេលព្រលប់វិញ ទើបទូល រំលឹកទ្រង់ថា ឥឡូវដល់ពេលហើយ ទ្រង់អាចនឹងរត់ចេញពីកណ្តាប់ដៃយក្សបាន

ហើយ ការណ៍នេះ ត្រូវស្ងាត់កំបាំងជាទីបំផុត សូម្បីព្រះវរមាតា កុំបីទូលឱ្យទ្រង់ ជ្រាបឡើយ ប្រសិនបើលេចឮឡើងមុខជាស្លាប់ទាំងអស់គ្នាពុំខាន ហេតុនេះនៅ អារាធ្រាត្រារាត្រីនេះ សូមទ្រង់នឹងព្រះអនុជមកជួបនឹងទូលព្រះបង្គំ មីងនាំទ្រង់ រត់ចេញចាកព្រះនគរចំណង់ ។

ត្រាតែផុតអំណាចនៃក្រុងយក្សយង់ឱ្យទាល់តែបានដូចព្រះទេវន្ទកុមារា ទ្រង់បានសណ្តាប់យោបល់របស់នាងក៏ទ្រង់» ព្រមទាំងមានព្រះទ័យអលអែកទ្រង់មិនចង់បែកឆ្ងាតពីព្រះវរមាតាសោះ ។ ប៉ុន្តែកាលណាទ្រង់នឹករលឹកព្រះវរបិតាដែលយក្សយង់ឆាប់ពិឃាតស៊ី ទៅតែងមានព្រះហឫទ័យឆ្អួលក្តៅក្តួលមហិមា កាត់ក្តីអាឡោះអាល័យ កើតក្តី ក្លាហានអង់អាចទ្រង់ចង់សងសឹកជំនួសព្រះវរបិតាឱ្យត្រាតែបានសម្រេច ។ ក្នុងរាត្រីនោះ ទ្រង់ស្ទើរតែពុំបានផ្ទំសោះ ទ្រង់កន្សែងសោកដោយក្តីអាឡោះអាល័យ ព្រះវរមាតានឹងព្រះរាជដ្ឋាន ដែលធ្លាប់តែបានទទួលសុខសុភមង្គលត្រ ដល់អាជ្រាត្រារាត្រី ទ្រង់ខំកាត់ក្តីអាល័យ ហើយទ្រង់ដាស់ព្រះអនុជដឹកដៃចេ ទៅរកពាជី ដែលរង់ចាំទ្រង់ៗ ឡើងគង់លើខ្នងពាជី ទាំងកន្សែងសោកជាមួយ នឹងព្រះអនុជ ។ ពាជីបានផាយយាងលឿនចេញទៅ បានចម្ងាយ ៣០ យោជន៍ក៏ភ្លឺស្វាងឡើង ហើយពាជីឈប់សម្រាកក្រោមដើមឈើមួយ ដើម្បីឱ្យរាជកុមារកុមារី សោយអាហាររួចពាជីក៏ចេញដំណើររត់ទៅទៀតដោយរួសរាន់។ សេ ធ្វើដំណើរបានចម្ងាយ ១០០ យោជន៍ ទើបដល់ពេលព្រលប់សន្ធិយា ព្រះរាជកុមារ ព្រះរាជកុមារី ចុះឈប់សម្រាកក្នុងព្រៃព្រឹក្សា ដើម្បីលាក់ខ្លួនពួនអាត្មាឱ្យផុតពី កណ្តាប់ដៃយក្សយង់ ។

ឯព្រឹត្តិការណ៍ នៅក្រុងពារាណសី ក្រោយ ព្រះកុមារ កុមារីបាត់រូបទៅមួយ ថ្ងៃដល់ ព្រលប់ទើបនាំគ្នាភ្ញាក់ផ្អើល ជ្រួលច្របល់ ព្រះនាងវិមលាទេវី កាលបានជ្រាបថា ព្រះរាជបុត្រា បុត្រីបាត់រូបមិនឃើញវិលពីក្រសាលពីព្រៃ ព្រឹក្សាដូចសព្វដង ក៏ទ្រង់ព្រះកន្សែងសោកមហិមា។ ឯក្រុងយក្សបាននិយាយ លួងលោមព្រះរាជទេវី ឱ្យបានស្បើយក្តីសោកហើយ បានចាត់អាមាត្យឱ្យរុករក សព្វទិសតំបន់ក្នុងព្រៃព្រឹក្សា ត្រាតែកន្លងកន្លះខែហើយ ក៏នៅតែមិនបានជួបប្រទះសោះ ។

ព្រះនាង មលាទេវី កាលទ្រង់បានទទួលពត៌មានថា ពួកសេនាអាមាត្យ ដែលនាំគ្នាចេញទៅរកព្រះរាជបុត្រា បុត្រីទាំងពីរ ពុំបានជួបប្រទះសោះ ព្រះ នាងទ្រង់កន្សែងសោកដោយបុត្តវិយោគយ៉ាងក្រៃលែងព្រមទាំងមន្ទំសាវជសី ស្ងំយំសោកពេញទាំងព្រះរាជដ្ឋាន ក្រុងយក្សបានពោលពាក្យលួងលោម ព្រះរាជទេពីដោយប្រការផ្សេងៗ ហើយក្រុងយក្ស បានបង្គាប់ពួកសេនាមាត្យ ទាំងពួងឱ្យខំយកចិត្តទុកដាក់ថែរក្សានគរ ក្រុងយក្សនឹងចេញទៅរកព្រះរាជកុមារ ដោយខ្លួនឯង ក្នុងកំឡុង ៧ ថ្ងៃនឹងវិលត្រឡប់មកនគរវិញ ។ ក្រុងនន្ទិយក្សបាន ចេញពីក្រុងពារាណសី ដោយមានចតុរង្គសេនាហែហម ដល់ក្រៅព្រះនគរ ហោះចេញទៅតែឯកឯងប្រែកាឡាជាយក្សមួយរំពេច និម្មិតអាត្មាឱ្យមានទំហំ នឹងមានកំពស់ដល់ ៧ ជួរត្នោតលៃក្រឡេកមើលសព្វទិសទី នៅតែមើលពុំឃើញទៀត ក៏និម្មិតនឹងពង្រីកអាត្មាឡើងទៀត ហើយហោះធ្យានឡើង ទើបបាន ឃើញពាជីនៅឆ្ងាយលន្លោច ក៏ស្ទុះផ្លោះដេញតាមទៅ ។ ឯពាជីបានឮសព្ទសន្ធឹកពន្លឹកសោះសា ក៏ក្រឡេកបែរមើលទៅក្រោយ បានឃើញក្រុងនន្ទិយក ដេញតាមមកក៏ទូល ព្រះរាជកុមារឱ្យបានជ្រាបហើយទូលសូមឱ្យទ្រង់ចុះទៅលាក់ ខ្លួនពួនក្នុងរន្ធដើមឈើ មួយដែលមានមីងពីងពាងព័ទ្ធជិតជុំរន្ធរូង ។ ឯពាជីគេចខ្លួនថយចេញឆ្ងាយពីទីពួនរបស់រាជកុមា ដើម្បីបង្វែងដានក្រុងយក្ស កុំឱ្យរកឃើញព្រះរាជកុមារ សុខចិត្តស្លាប់តែឯកឯង ទុកឱកាសឱ្យព្រះរាជកុមារធ្វើការ សងសឹកទៅថ្ងៃក្រោយ ។ ឯក្រុងយក្សគិតថា កាលណាបានជួបប្រទះនឹងចាប់ស៊ីទាំងបី មិនឱ្យមានឈាមមួយដំណក់ស្រក់ដល់ដីឡើយ ។ ក្រុងយក្សគយគន់រក ព្រះរាជកុមារនឹងសេះពុំឃើញសោះ ហើយដោះចេញពីទីនោះ ក្រឡេកមើលទៅបានឃើញពាជី ក៏ស្ទុះទៅចាប់កាច់ពាជីស៊ីក្បាលទាំងអស់នៅសល់តែដងខ្លួនចោលនៅកណ្តាលព្រៃហើយ ក្រុងយក្សរុករកព្រះរាជកុមារសព្វទីកន្លែងជិតក្បែរ ខ្មោចសេះ” ក៏ពុំឃើញសោះ ទើបគិតថា អាក្មេងពីរនាក់ ពិតមែនតែចាប់មិនបានរកមិនឃើញ ប៉ុន្តែវាគង់នឹងស្លាប់ដោយអត់អាហារឬខ្លាស៊ីពុំខានក្រុងយក្ស ក៏ឥតយកចិត្តទុកដាក់នឹងព្រះរាជកុមារ បានគេចចេញពីទីនោះទៅ រកចាប់ម្រឹគី ម្រឹគាស៊ីតាមសប្បាយ ត្រាតែដល់កំណត់សត្តទិវា ទើបយក្សាប្រែកាលាជាមហាក្សត្រ ត្រឡប់មកដល់នគរពារាណសីវិញ បានពោលពាក្យកុហកបញ្ឆោត ព្រះរាជទេវី ព្រះវរមាតា នៃព្រះរាជកុមារា កុមារី វាបានជួបបុត្រទាំងពីរនៅ អាស្រមតសីមួយ ដែលមិនបានចូលលា ក្រែងឃាត់មិនឱ្យទៅរៀនសិល្ប៍សាស្ត្រ ធ្លាតពីព្រះរាជដ្ឋាន ឥឡូវពាជីនឹងកុមារទាំងពីរសុខសប្បាយជាទេ កាលណារៀន សិល្បសាស្ត្រចេះសព្វអស់ហើយ នឹងវិលថ្កានព្រះនគរជាប្រញាប់ សូមទ្រងកុំព្រួយបារម្ភនឹងកូនយើងទាំងពីរនោះឡើយ ។ ព្រះនាងវិមលាទេវី បានស្តាប់ពាក្យ

កុហកបញ្ឆោតរបស់យក្ស ក៏ជឿជាក់ឥតសង្ស័យ ហើយបានស្បើយពីក្ដីទុក្ខសោកដោយបុត្តវិយោគបានខ្លះ ។

ឯព្រះកុមារា ព្រះកុមារី ក្រោយដែលយក្សយង់ឃ្នងចេញទៅបាត់យូរហើយនោះ ក៏នាំគ្នាចេញពីរូងជ្រៃគយគន់រកមើលពាជីពុំឃើញសោះ ហើយ ទ្រង់កន្សែងពិលាបដោយប្រការផ្សេងៗ ដោយទ្រង់យល់ឃើញថា ប្រសិនបើគ្មាន សេះជាជំនិះបន្តដំណើរទេ ទុកដូចជាមនុស្សឥតជើងដែរ ហើយមុខជានឹងក្សិណក្ស័យក្នុងព្រៃនោះឯង ។ លុះបានស្បើយសោកបន្តិច ព្រះកុមារទាំងពីរក៏បានគយគន់រកមើលស្នាមជើងពាជី ហើយទ្រង់យាងតាមដានស្នាមជើងពាជីនោះទៅក៏បានឃើញពាជីឥតក្បាលសល់តែដងខ្លួន ។ ព្រះកុមារទាំងពីរភិតភ័យរន្ធត់ព្រមឱរ៉ាទាំងសេចក្ដីសោកស្ដាយពាជីលើសលន់ពន់ប្រមាណ ត្រាតែដល់នូវវិសញ្ញីភាព ទាំងពីរប្រាណ ក្បែរពាជីកំបុតក្បាល ។

កាលណោះលេចតាចាស់ម្នាក់ចូលទៅរកព្រះកុមារ ហើយយកទឹកប្រស់ព្រំព្រះកុមារត្រាតែភ្ញាក់រលឹកដឹងខ្លួនប្រាណឡើងវិញ ហើយគាត់បានសាកសួរ ព្រះកុមារទាំងពីរអំពីដំណើរចូលមកក្នុងព្រៃរហោឋានដូច្នេះ ព្រះទេវន្ទកុមារ បានសាសព្វប្រាប់តាមដំណើរសព្វគ្រប់ ហើយទ្រង់បានបញ្ជាក់ពីបំណងបន្តដំណើរ ទៅមុខទៀត ។ តាចាស់ចិត្តសប្បុរសបាននិយាយថាសូមឱ្យចៅទាំងពីរចេញទៅរកក្បាលសត្វអ្វីមួយ ដែលទើបស្លាប់ថ្មី យកមកឱ្យតា នឹងតភ្ជាប់វាឱ្យរស់ឡើងវិញ ព្រះកុមារមានសេចក្ដីត្រេកអរណាស់ នាំគ្នាចេញទៅរកក្បាល សត្វចតុប្បាទក្នុងព្រៃ មិនយូរប៉ុន្មានបានឃើញរាជសីហ៍ឈ្មោលមួយស្លាប់ក្នុង ទ្រូងព្រៃ ទើបទ្រង់កាត់ក្បាលយកមកជូនតាចាស់តភ្ជាប់នឹងដងខ្លួនពាជី ស្រោចទឹកទិព្វមន្តលើក្បាលសីង្ហ ស្រាប់តែពាជីក្បាលសិង្ហរស់រានមានជីវិតឡើងវិញភ្លាមយ៉ាងអស្ចារ្យ ឯតាចាស់ក៏ក្លាយជាព្រះឥន្ទ្រាធិរាជមួយរំពេចទ្រ ។ ត្រាស់ថា ពាជីនេះមានឫទ្ធិអានុភាពអាចហោះហើរ លើអាកាសបាន មាន កម្លាំងលើសលែងសត្វចតុប្បាទទាំងអស់ ហើយ ព្រះអង្គទ្រង់ប្រទានព្រះពរដល់ ព្រះកុមារ ព្រះកុមារី ក្រាបថ្វាយបង្គំព្រះឥន្ទ្រាធិរាជដោយក្ដីគោរព ព្រះទេវន្ទ កុមារ ក្រាបបង្គំទូលសូមព្រះពរ ៤ ប្រការ

- ព្រះពរមួយ សូមឱ្យមានជ័យជំនះឈ្នះយក្សយង់ឃ្នង ។
- ព្រះពរមួយ សូមឱ្យមានឫទ្ធិឈ្នះបច្ចាមិត្តសព្វទិស ។
- ព្រះពរ មួយ សូមឱ្យបានជួបជុំព្រះវរមាតា បានគ្រងរាជស្នងព្រះវរបិតា ។

ព្រះពរមួយ ទោះបីមនុស្សក្ដី សត្វក្ដី ទើបស្លាប់ថ្មីៗ សូមឱ្យមានឫទ្ធិពិសេស អាចប្រស់ឱ្យបានរស់រានជីវិតឡើងវិញ ។ ប្រសិនបើស្អាងស្អាតនឹងគេហដ្ឋានទាំងឡាយ តែពុំមានមនុស្សសោះ ទ្រង់សង្ស័យ ណាស់ ប្រាប់ពាជីឱ្យបន្ទាបចុះចូលទៅក្នុងទីលានព្រះរាជវាំង ឃើញស្ងាត់ជ្រៀប | ➳ងចម្លែកណាស់ ទ្រង់យាងទៅក្នុងប្រាសាទរាជដ្ឋាន ទ្រង់ទតឃើញគ្រឿង លង្ការពេជ្រនិលចិន្ដាព្រះពស្ត្រភូសា ( មាសប្រាក់ កែវកង សូរ្យកាន្តផ្សេងៗ ច្រើនអនេក តែឥតមានមនុស្សម្នាក់គ្រប់គ្រងរក្សាទ្រព្យសម្បត្តិទាំងនោះសោះ

គួរឱ្យមានក្ដីងឿងឆ្ងល់ពន់ពេក ។

ឯពាជីបានទូល ព្រះកុមារថា សូមទ្រង់ឱ្យព្រះអនុជ គង់រង់ចាំក្នុងព្រះ ដំណាក់នេះចុះ ទូលព្រះបង្គំនឹងនាំទ្រង់ទៅស្វែងរកបេះផលាផលក្នុងពយកមក សោយជាអាហារ ព្រះរៀមបន្ទូលលួងលោមព្រះអនុជឱ្យគង់រង់ចាំទ្រង់ក្នុង សំណាក់ បិទទ្វារដំណាក់ឱ្យជិត កុំភ័យកុំព្រួយអ្វីឡើយ ដល់រសៀលល្ងាចទ្រង់ នឹងនាំយកផលាផលពីព្រៃ មកប្រទានឱ្យព្រះអនុជសោយ ។ ព្រះទេវន្ទកុមារ តែដល់ពេលព្រឹកឡើងកាលណា តែងចេញទៅព្រៃជាមួយនឹងពាជីរៀងរាល់ថ្ងៃ ។ ឯព្រះអនុជកុមារីនៅក្នុងដំណាក់តែឯងអង្គ មានក្ដីអផ្សុកពន់ពេក ក្រោយព្រះរៀមចេញទៅព្រៃផុតទៅ ក៏យាងទតមើលទីដំណាក់ នឹងប្រាសាទនានាក្នុងព្រះ រាជដ្ឋានស្រាប់តែបានទតឃើញស្គរធំចំឡែក ១ ដំកល់ទុកក្នុងទីមួយខាងក្នុងប្រាសាទ។ ព្រះនាងពិនិត្យមើលឃើញមានទ្វារចេញចូលមួយ ក៏ចាប់ទ្វារទាញចេញ ទ្វារក៏របើកឡើងមើលទៅខាងក្នុង បានឃើញព្រះរាជកុមារ ១ អង្គគង់នៅខាងក្នុងតែឯកឯង ។ ទ្រង់បានទតឃើញប្រះកុមារីមានរូបឆោមប្រិបប្រិយ គួរឱ្យចាប់ចិត្តស្នេហាងឿងឆ្ងល់ណាស់ប៉ុន្តែទ្រង់ស្មានថា មិនមែនជាផ្ទើមនុស្សទេកាឡាជាស្រីមនុស្ស ព្រោះនៅក្នុងនគរនោះក្មេងចាស់មួយគ្មាននៅរស់សោះ មានតែទ្រង់ម្នាក់ឯងគាត់ទើបទ្រង់ មានជំនួរទៅព្រះនាងថា នាងជាអ្វី មកពីទីតំបន់ណា ឬជាអ្នកស្រុកនេះ ? ព្រះនាងបានថ្លែងរៀបរាប់អំពីជីវប្រវត្តិរបស់ព្រះនាងនឹងព្រះរៀមទើបសព្វគ្រប់សួរព្រះរាជកុមារវិញថា "ចុះរូបអ្នកជាអ្វី ហេតុអីក៏មកនៅក្នុងស្គរមួយវិញទៀត នៅនគរនេះ មានគ្រឿងឧបភោគ

បរិភោគ ធ្វើអពាហ៍សមផាលំនៅមនុស្សច្រើនណាស់ ចុះហេតុអីក៏ស្ងាត់ស្ងូនឡឹង “ ព្រះរាជកុមារឆ្លើយតបថា “ បងនេះ ឈ្មោះអភ័យកុមារជាមានរាជបុត្រព្រះរាជាទហេមន្តរាជ គ្រងរាជសម្បត្តិនៅនគរនេះឯង ។. ព្រះវរមាតា បិតា ព្រមទាំងនាហ្មឺនសព្វមុខមន្ត្រីនឹងប្រជារាស្ត្រមានក្តីសុខ សប្បាយទូទៅ ។ ថ្ងៃមួយ នៅនគរនេះ មានកើតវិបត្តិអន្តរាយយ៉ាងឃោរឃៅ ដោយមានសត្វគន្ទ្រីញីឈ្មោលមួយគូមកពីព្រៃហេមពាន្ត ចាប់មនុស្សប្រុស ស្រី ស៊ីជាអាហារវារៀងរាល់ថ្ងៃ ប្រជារាស្ត្រភិតភ័យរត់ទៅលាក់ខ្លួនពួនក្នុងព្រៃព្រះវរបិតាបងបានយកបងមកលាក់បំពួនក្នុងស្តូរធំនេះ ព្រមទាំងអាហារ ភោជនាដូចប្អូនបានឃើញស្រាប់ ។ ឯទ្រង់ស៊ូប្តូរព្រះជន្ទជាមួយនឹងប្រជារាស្ត្រមិនព្រមគេចរត់ទៅពួននៅទីណាឡើយ ហេតុនេះហើយ បានជានគរនេះស្ងាត់ស្ងូនឡឹងម្ល៉េះ ។

ឯព្រះកុមារ ព្រះកុមារីបានទ្រង់ជ្រាបជីវប្រវត្តិទៅវិញទៅមកដូច្នេះរហើយ ក៏កើតព្រះទ័យប្រតិព័ទ្ធស្នេហាគ្នាទៅវិញទៅមក នៅទីបំផុតមានសេចក្តីស្នេហាទៅតាមចំណង់នៃព្រះកាមទេព ។ ព្រះនាងចន្ទាកុមារីនៅក្នុង ស្គរធំជាមួយនឹងព្រះអភ័យកុមារ គ្រាតែដល់រសៀលទើបនាងវិលមក ដំណាក់គង់រង់ចាំព្រះរៀមត្រឡប់ពីព្រៃ ។ ក្នុងថ្ងៃតៗ មក តែព្រះរៀមចេញទៅ រកផ្លែឈើ ព្រៃជាមួយនឹងពាជី ព្រះនាងក៏ចេញទៅរកគូសង្សាររៀងរាល់ថ្ងៃ ។ តមក ថ្ងៃមួយ ព្រះនាងថ្លែងក្តីទុក្ខព្រួយចំពោះគូសង្សារថា “រឿងយើងទាំងពីររូប ដែលបានប្រព្រឹត្តក្បត់ចិត្តព្រះរាមខ្ញុំឥតបានទ្រង់ជ្រាបសោះ បើបានទ្រង់ជ្រាប កាលណា មុខជាជីវិតយើងពុំរស់ទេ ដូច្នេះសូមឱ្យទ្រង់ជួយរកមធ្យោបាយដោះ ស្រាយឱ្យបានផុតពីក្តីទុក្ខព្រួយនេះ ” ។ ព្រះរាជកុមារ ត្រាស់លួងលោមថា “សូម ប្អូនកុំព្រួយបារម្ភឱ្យសោះ ចំពោះរឿងយើងនេះ ដ្បិតនៅខាងត្បូងនគរនេះមានចំការអំពៅមួយមានដើមធំ មានរសជាតិផ្អែមដូចស្ករ មានស្តេចស្វាសមួយ ព្រមទាំងបរិវារជាច្រើនម៉ឺននៅថែរក្សា នៅពេលរាត្រីនេះ ពេលតើនបង្ហំឡើង សូមឱ្យប្អូនធ្វើជាទ្រង់ព្រះកន្សែងសោកខ្សឹកខ្សួលបើព្រះរៀមសួរប្អូនទូលថា យល់សប្តិបានសោយអំពៅមានរសជាតិឆ្ងាញ់ពិសារណាស់ នៅច្បារខាងត្បូង ព្រះនគរនេះ សូមប្អូនអង្វរ ព្រះរៀម សុំឱ្យស្តេចទៅកាប់អំពៅមួយដើមយកមក មុខជាព្រះរៀមនឹងធ្វើតាមពាក្យប្អូន ហើយ ព្រះរៀមនឹងពាជី នឹងដល់នូវ កាលកិរិយាដោយដៃពួកពានរពុំខាន ហើយយើងទាំងពីររូបបានសប្បាយ ឥតក្តី ភ័យព្រួយអ្វីតទៅទៀត” ។

ព្រះរាជកុមារី ដោយក្ងេងលងនឹងសេចក្តីស្នេហាចំពោះគូរសង្សា ព្រះនាងខ្វះវិចារណញ្ញាណ ក៏បានធ្វើតាមមធ្យោបាយនេះ ។ ឯព្រះរៀមក៏មានបន្ទូល លោមព្រះអនុជកុមារី ហើយស្តេចចេញទៅព្រៃសំដៅទៅទិសខាងត្បូង ក៏ បានប្រទះនឹងច្បារអំពៅដ៏ធំធេង ដូចព្រះអនុជបានយល់សុបិនឃើញដូច្នោះ ពួកពានរមានស្តេចស្វាសជ្រាបបានប្រុងចូលលុក ក្រញីពាជីក្បាលសិង្ហក៏បញ្ចេញសម្រែកទាំងអស់តែស្តេចពានរនឹងពួកពលដួលដេកអស់ទៅ ។ ព្រះទេវន្ទ ឃើញដូច្នោះ ក៏មានព្រះទ័យអាណិតអាសូរណាស់ ទ្រង់បានប្រស់ស្តេច នឹងពួកពលឱ្យបានរស់ជីវិតឡើងវិញ ។ ស្តេចស្វាសសូមថ្វាយខ្លួនជាសេនាទូលថា “ ៧. ថ្ងៃនឹងនាំស្លួយ អំពៅយកទៅថ្វាយម្តង កុំបាច់ស្តេចព្រួយយាងថាឡើយ ព្រះរៀមមកដល់ ព្រមទាំងអំពៅមួយបាច់ធំ ព្រះនាងក្លែងធ្វើជារីករាយយកបាច់អំពៅពីព្រះរៀម ប៉ុន្តែក្នុងចិត្ត ព្រួយក្រៃលែង។ ក្រោយព្រះរៀមរទៅព្រៃ ព្រះនាងបានយកអំពៅមួយដើមទៅថ្វាយ ព្រះអភ័យកុមារ ផ្ទួសហើយប្រាប់ថា ព្រះរៀមបានពួកពលពានរជាច្រើនហ្មឺនជាបរិវារ ។ ព្រះរាជគុមារត្រាស់ថា “សូមប្អូនកុំព្រួយបារម្ភថ្វីដ្បិតនៅទិសខាងជើងផាលំនៅនៃសត្វខ្លាឃ្មុំរាប់ពាន់រាប់ហ្មឺន ហើយនៅទីនោះសម្បូណ៍ឃ្មុំណាស់ប្អូនក្លែងនិយាយថា យល់សុបិនបានសោយឃ្មុំផ្អិត នៅទិសខាងជើងនគរ ព្រះរៀមទៅរកមកឱ្យទាន ក្រែងបានដូចជាយល់សប្តិ ព្រះនាងក៏ធ្វើជាទាមធ្យោបាយនេះ ព្រះរៀមឡើងគង់ពាជីហោះសំដៅទៅទិសខាងជើង ក៏បានជួបប្រទះឃើញឃ្មុំច្រើនសម្បើមណាស់ ប៉ុន្តែមានស្តេចខ្លាឃ្មុំ ព្រមពលចោមជុំជិត ប្រុងប្រហារជីវិតអ្នកដែលចូលទៅរុករានដល់ទីនោះ ។ ពាជីកំពុងបញ្ចេញ សម្រែករាជសីហ៍ឡើង ស្តេចនឹងពួកពលក៏ដួលសន្លប់អស់ ។ ព្រះទេវន្ទ ក៏មានព្រះទ័យមេត្តាទ្រង់ប្រស់ឱ្យបានរស់រាន មានជីវិតឡើងដូចដើមវិញ។ ពួកខ្លាឃ្មុំបានថ្វាយខ្លួនជាបរិវារ សន្យាថា នឹងនាំស្លួយឃ្មុំទៅថ្វាយរាល់សប្តាហ៍ កុំបីស្តេចព្រួយយាងមករកឡើយ ទ្រង់យាងត្រឡប់មកវិញទ្រង់បានប្រទានឃ្មុំព្រះនាងអនុ ហើយទ្រង់មានបន្ទូលប្រាប់ថា ពួកខ្លាឃ្មុំបានថ្វាយខ្លួនជាសេនាព្រះអង្គ ។

ដល់ព្រឹកឡើង ព្រះរៀមចេញទៅព្រៃ ព្រះនាងយាងទៅជួបនឹងព្រះស្វាមី ដំណាលរឿងប្រាប់ ព្រះស្វាមី ត្រាស់ថា “សូមប្អូនទូលព្រះរៀមថា បានសោយ បុទមធំ ទំហំប៉ុនកងរាជរថនឹងផ្លែក្រចាប់ ទំហំប៉ុនក្បាលក្របី នៅព្រៃហេមពាន្ត ក្នុងស្រះបោក្ខរណី” ។ ទីនោះមានកុម្ភណ្ឌ ៤ រូបនៅថែរក្សា មនុស្សក្តី សត្វក្តី ចុះទៅក្នុងស្រះនោះកាលណា កុម្ភណ្ឌចាប់ស៊ីជាអាហារពុំដែល

ខានឡើយ ។ ព្រះនាងក៏បានធ្វើតាមឧបាយកលព្រះស្វាមី ព្រះរៀមក៏បានឡើងគង់លើ ខ្នងពាជីហោះសំដៅទៅព្រៃហេមពាន្ត ទ្រង់បានទតឃើញស្រះធំដេរដាសដោយ បញ្ចបទុមា មានផ្លែមានផ្ការីកស្គុះស្គាយមានផ្លែក្រចាប់ធំ ប៉ុនក្បាលក្របី ព្រះចក្រីទ្រង់បានបេះសោយផលាផលក្នុងស្រះស្រង់ ទ្រង់ស្រង់ទ្រង់ផ្ទូតពាជីរួចស្រេច ទ្រង់ខ្ចប់ចងបាច់ផលាផលទុកផ្ញើព្រះអនុជតាមចំណង់ព្រះនាង ។ កាលណោះជួនជាកុម្ភណ្ឌ ៤ រូបវិលពីព្រៃ បានប្រទះទ្រង់នឹងពាជីមានអាប្បកិរិយាក្លាហាន ឥតភ្លឹកឥតខ្លាច ហាក់ដូចរាជសីហ៍បានប្រទះនឹងម្រឹគដូច្នោះ វាពុំទាន់ហ៊ានចាប់ ក្រញី ស៊ីភ្លាមទេ បែរជាចូលទៅជិតនិយាយដោយស្រួលវិញថា " នែមាណពកម្លោះមានរូបឆោមស្រស់បស់ អ្នកបានចុះបេះបោចដំណាំរបស់យើង ត្រូវយើងបានរូបអ្នក ជាចំណីអាហារយើង តែយើងអាណិតចៅរូបរាងឆ្មេញល្មៅក្រែងក្ស័យជីវិត ទើបយើងគិតប្រណី យើងសូមសួរថាតើចៅចេះធម៌ឬទេ បើចៅចេះសំដែងធម៌ យើង នឹងលែងចៅឱ្យបានរួចខ្លួនដោយសេរី ចូរចៅសំដែងមកធម៌ព្រះរាជកុមារ ឡើងគង់លើគ្រែធម្មាសនៈ ដែលយក្ស ទ្រង់បានបង្គាប់ឱ្យយក្សទាំង ៤ សុខចិត្តទទួលសីល៥ ឱ្យលើកអញ្ជលីប្រណមស្តាប់ធម៌ដែលទ្រង់សំដែងដោយក្តីគោរព ហើយទ្រង់បានទូន្មានយក្សប្រកាន់ខ្ជាប់អំពើទុច្ចរិត ១០ ប្រការ ដែលចែកចេញជាកាយទុច្ចរិត ៣.មនោទុច្ចរិត ៣ ហើយទ្រង់ទូន្មានឱ្យយក្សប្រកាន់ខ្ជាប់នូវអំពើសុត ១០ គឺ កាយសុចរិត ៣ វចីសុចរិត ៤ នឹងមនោសុចរិត ៣ ប្រការ ព្រមទាំងនៃការប្រព្រឹត្តិល្មើសធម៌ ១០ ប្រការនឹងអានិសង្សនៃការប្រព្រឹត្តិទាំង ១០ ប្រការនេះ ។ នៅពេលចប់ធម៌ទេសនា យក្សទាំង ៤ មានសេចក្តីជ្រះថ្លាថ្វាយខ្លួនជារាជ បរិវារព្រះកុមារដោយស្ម័គ្រចិត្តនឹងភក្តីភាព ព្រះរាជកុមារត្រាស់ថា យើងសូមអរគុណអ្នករាល់គ្នាណាស់ ដ្បិតយើងសព្វថ្ងៃកំព្រា មានគ្នាតែរូបបីនឹងពជី ព្រះនេះ ដូច្នេះចូរអ្នករាល់គ្នាអាណិតមេត្តានាំផលាផលនឹងទឹកស្រះស្រង់នេះទៅថ្វាយកូនហើយយើងរាល់ថ្ងៃ ។ យក្សទូលថា សូមទ្រង់កុំព្រួយព្រះហឫទ័យ ត្រង់ភារៈនេះយើងខ្ញុំទូលបង្គំទទួលយកអាសានាំយកផលាផលនឹងក្រឳឈូក យកទៅថ្វាយទ្រង់រៀងរាល់ថ្ងៃសូមទ្រង់កុំបីព្រួយព្រះហឫទ័យឡើយ ។

ក្រោយព្រះទេវន្ទកុមារ លាត្រឡប់ហេមន្តនគរវិញហើយ កុម្ភណ្ឌទាំង ៤ ក៏បានជំនុំគ្នាថាគ្នាយើងទាំង ៤ នាក់ គួរចាត់,២ នាក់ឱ្យកាឡាជាមនុស្សទៅនៅ ជាមួយថែរក្សាព្រះអង្គរាល់ទិវារាត្រីកុំឱ្យមានសត្រូវណាមួយចូលទៅយាយីព្រះអង្គ "ហើយក្រែងព្រះអង្គទ្រង់ប្រឈួនដោយរោគអ្វីមួយ បើយើងនៅឆ្ងាយមិនអាចដឹងបានឡើយ ម្នាក់ទៀតត្រូវទទួលភារៈជាអ្នកនាំផលាផលទៅថ្វាយកុំ ឱ្យខ្វះខាត ម្នាក់ទៀតនៅយាមរក្សាស្រះស្រង់បំរុងផលាផលក្នុងវារិជាតទុកថ្វាយព្រះអង្គ ។ ព្រះអនុជកុមារីបានឃើញព្រឹត្តិការណ៍ប្រែប្រួលខុសពីបំណងដូច្នោះ ភ័យព្រួយក្នុងហឫទ័យយ៉ាងក្រៃលែង តែព្រះនាងក្លែងធ្វើជារីករាយរាក់ទាក់ដូចសព្វដល់ ព្រឹកឡើង ព្រះនាងទូលព្រះរៀមថា សុំឱ្យបេះផ្លែស្វាយទុំនៅហេមពាន្តបានមួយផ្ញើព្រះនាង . រដូវនេះមិនជារដូវស្វាយទុំទេ តែព្រះទេវន្ទកុមារ នៅតែទ្រង់ទទួលភារៈនេះ ហើយទ្រង់បញ្ជាឱ្យកុម្ភណ្ឌទាំង ៤ ជួយស្វែងរកផង ។

ថ្លែងឯព្រះអនុជកុមារី ក្រោយព្រះរៀមព្រមទាំងពាជី នឹងកុម្ភណ្ឌទាំងពីរ ចេញផុតពីប្រាង្គប្រាសាទទៅ ដើម្បីស្វែងរកផ្លែស្វាយ ក្នុងព្រៃហេមពាន្តតាម ព្រះនាងក៏បានយាងទៅថ្នានព្រះរាជកុមារសង្សារព្រះនាងដឹង បំណងព្រះនាងនោះភ្លាម ហើយបានថ្លែងប្រាប់តាមដំណើរសព្វគ្រប់ ព្រមទាំងសេចក្តីទុក្ខព្រួយបារម្ភ យ៉ាងក្រៃលែង ចំពោះអំពើឆ្កាំឆ្គងជាទម្ងន់ចំពោះព្រះរៀម ព្រះនាងយល់ឃើញថា មិនយូរមិនឆាប់រូបព្រះនាងនឹងសង្សារមុខជាក្ស័យជីវិតទាំងអស់គ្នា កាលណាបែកការណ៍ឡើង ។ ព្រះអភ័យកុមារសង្សារព្រះនាង ថ្លែងពាក្យលួងលោមដោយ សេចក្តីស្នេហាថា "សូមប្អូនកុំព្រួយបារម្ភឱ្យសោះ រៀមបងនៅមានមធ្យោបាយ មួយទៀតមុខជានឹងបានសម្រេចដូចបំណង មានរថយន្តរលីងស្អាត សម្រាប់ពិឃាតជីវិតអ្នកទោសដែលមានទោសឧក្រិដ្ឋក្នុងពន្ធនាគា យើងនាំគ្នា សែងក្តារយន្តនោះ ទៅដាក់ក្នុងបន្ទប់ស្រង់របស់ព្រះរៀម ហើយអញ្ជើញព្រះរៀមចូលស្រង់ នៅពេលដែលទ្រង់ត្រឡប់ពីព្រៃហេមពាន្តកាលបើព្រះរៀមចូល ទៅក្នុងបន្ទប់ស្រង់ ទ្រង់ជាន់ក្តារយន្តនោះសូមឱ្យប្អូនត្រហែមឡើង បងនឹងទាញខ្សែពានដែលចងភ្ជាប់ចូលទៅក្នុងស្ករបង លំពែងយន្តនឹងស្ទុះចេញចាក់ព្រះរៀមដល់នូវកាលកិរិយាក្នុងទីនោះពុំខានដល់ពេរសៀល ព្រះនាងលាគូសង្សារ វិលមកប្រាសាទ គង់រង់ចាំព្រះរៀមដូចសព្វដង ។

ព្រះទេវន្ទកុមារ ទ្រង់បានស្វះស្វែងរកផ្លែស្វាយទុំជាមួយពាជី ត្រាតែដល់ពេលរសៀលសូរិយាទើបបានប្រទះឃើញដើមស្វាយមួយដើមធំ ទ្រង់ទតឃើញ សំបុកអង្រ្កងមួយធំ មានក្អែកមួយទុំជិតសំបុក ទំនងចង់ចឹកសំបុកនោះ ទើបទ្រង់បង្គាប់ពាជីឱ្យហោះបន្ទាប់ទៅទៀតជិតសំបុកអង្រ្កង ស្រាប់តែបានទតឃើញផ្លែ ស្វាយទុំក្រហមឆ្អៅ នៅខាងក្នុងសំបុកអង្រ្កង ទ្រង់

បេះបានហើយ ទ្រង់បង្គំពាជី ឱ្យហោះត្រឡប់មកប្រាសាទវិញដោយរួសរាន់ ។ ឯយក្សយង់ទាំង ៤ ក៏នាំគ្នាស្វះស្វែងរកស្វាយទុំក្នុងព្រៃហេមពាន្តដែរ តែឥតបានជួបប្រទះសោះ ។ ដល់ថ្ងៃរសៀលទន្ទាបក៏បានវិលត្រឡប់ទៅកាន់មុខការរៀងខ្លួនវិញ ព្រះរាជកុមារទ្រងបានមកដល់ប្រាសាទព្រះអនុជកុមារី ក៏បានចេញទៅទទួលព្រះរៀមដោយរាក់ទាក់មានទឹកមុខរីករាយដូចសព្វដង តែក្នុងចិត្តក្រៀមក្រំឥតឧបមាទើបព្រះ នាងទូលសុំអញ្ជើញព្រះរៀមឱ្យចូលស្រង់ជម្រះព្រះអង្គក្នុងបន្ទប់ទ្រង់ដែលមាន ក្ការយន្តនោះលុះទ្រង់ចូលទៅក្នុងបន្ទប់ បានទតឃើញបន្ទះក្តារចំឡែក ក៏ត្រាស់ សួរព្រះអនុជ១ ទូលថា ព្រះនាងបានឃើញបន្ទះក្តាររលីងស្អាតនេះនៅក្នុងបន្ទប់ ប្រាសាទឯណោះ ហើយព្រះនាងយកមកទុកថ្វាយព្រះរៀមគង់ស្រង់ស្គានព្រះអង្គ ព្រះទេវន្ទកុមារ ក៏បានយាងចូលទៅក្នុងបន្ទប់ក្តារយន្ត ព្រះអនុជបានតហែមឱ្យ សញ្ញាដល់សង្សាររបស់ខាង ។ ព្រះអភ័យកុមដែលពួនក្នុងស្តារនោះ ក៏បាន ចាប់ទាញកន្ត្រាក់ខ្សែពាន គន្លឹះយន្តធ្លាក់ លំពែងក៏ស្ទុះមកចាក់ព្រះរាជកុមា តែពុំត្រូវព្រះអង្គ ទ្រង់លុបលាងរួចហើយ ស្តេចចេញពីបន្ទប់ស្រង់មក ទ្រង់ត្រាស់សួរ រកមុខដោយ មធុរវាចាថា “ ឱអញឥតឆ្លងឥតទោសអ្វីផង នឹងអ្នកឯណា ទោះមកហ៊ានធ្វើ អំពើមាយា ឱ្យអញមរណា តើញាំងទោសអ្វីអ្វី ? ។

ឯអនុជកុមារី មានក្តីស្ញប់ស្ញែងបារមីនៃព្រះរៀមមហិមា ភិតភ័យរន្ធត់ក្នុងអង្គប្រាណរត់ចូលទៅពួនក្នុងប្រាសាទ ញ័រចំប្រប់ដូចកូនសត្វដែលគេបានកំចាត់ ចេញពីសំបុកវា ព្រះនាងខ្លាចព្រះរៀមមិនទុកជីវិត ព្រោះព្រះនាងគិតប៉ុនប៉ងប្រហារជីវិតព្រះរៀម ដែលជាកំហុសឧក្រិដ្ឋក្រៃលែង ។ ជួនជាពេលនោះ កុម្ភណ្ឌ ទាំងពីររូបក៏បានមកដល់ បានឃើញព្រឹត្តិការណ៍ដូច្នោះ ក៏ខឹងជាខ្លាំងម្នាក់ហោះរកសត្រូវលើអាកាស ម្នាក់ទៀតជ្រែកដីក៏ពុំបានប្រទះសោះ ទើបនាំគ្នាចូលទៅ ពិនិត្យបន្ទប់ស្រង់បានឃើញខ្សែពានមួយ ក៏នាំគ្នាកាឡាជាស្រមោចខ្មៅសៀរស៊ូ ទៅចូលដល់ក្នុងស្តារបានឃើញអភ័យកុមារ ទើបយក្សចាប់ទះតប់ចងនាំខ្លួន មកថ្វាយព្រះទេវន្ទកុមារ ទូលថា “មាណពនេះឯងជាអ្នកធ្វើកលប៉ងប្រហារព្រះជន្មព្រះអង្គ ទូលបង្គំសូមអនុញ្ញាតប្រហារជីវិតវាចេញ” ។ ព្រះទេវន្ទកុមារ ទ្រង់ បានឃាត់ហាមយក្សសេនា ហើយត្រាស់សួរព្រះអភ័យកុមារថា ”នៃមាណពអ្នក នឹងខ្ញុំមិនដែលស្គាល់គ្នាសោះ ទាំងមិនដែលបានឃើញរូបគ្នាម្តងណាសោះ ចុះអ្នក មានគំនុំគុំគួននឹងយើងដោយរឿងអ្វី បានជាធ្វើកលប៉ងពិឃាតជីវិតយើង ? មួយ វិញទៀត អ្នកឈ្មោះអ្វី មកពីឋានណា មាតាបិតាអ្នកនៅឯណា ឬមួយជាអ្នកនគរនេះ ចុះហេតុអ្វីក៏មកនៅត្រមោចត្រមង់តែម្នាក់ឯងដូច្នេះ ? “ ។ ព្រះអភ័យកុមារ បានក្រាបទូលសូមទោស សូមជីវិត សូមឱ្យទុកធ្វើជាខ្ញុំ ព្រះបាទា ហើយក្រាបទូលពីស្ថានការណ៍នៃហេមន្តនគរដែលស្ងាត់សូន្យឈឹងជីវប្រវត្តិរបស់ទ្រង់ នឹងការលួចស្រឡាញ់គ្នាដោយលាក់លៀមនឹងការភ័យខ្លួននៃព្រះអនុជកុមារី ក្រែងព្រះរៀមមិនត្រាប្រណីប្រហារជីវិតបង់ ទើបក្លែងធ្វើឧបាយផ្សេងៗ ដើម្បីកំចាត់ព្រះរៀមចេញ ការទាំងនេះជាកំហុសធំណាស់មិន គួរត្រាប្រណីទេ ប៉ុន្តែសូមព្រះរៀមព្រះរាជទានអភ័យទោសប្រោសប្រណីទុក ជីវិតសម្រាប់ធ្វើជាខ្ញុំព្រះបាទតទៅទៀតចុះ សេចក្តីដែលក្រាបបង្គំចូលមកនេះជាសេចក្តីពិតត្រង់ទាំងអស់ សូមទ្រង់ជ្រាប ។

ដោយព្រះទ័យសប្បុរសនឹងមេត្តាធម៌នៃព្រះពោធិសត្វ ទ្រង់ឥតមានចង គំនុំក្រេវក្រោធឡើយ ហើយទ្រង់ព្រះសម្រួលក្អាកក្អាយទៅវិញ ទ្រង់មានបន្ទូល ហៅព្រះអនុជកុមារី ទាំងភិតភ័យតក្កមាទាំងអៀនខ្មាសដ៏លើសលុបចំពោះ ព្រះរៀម ប៉ុន្តែមិនហ៊ានរឹងទទឹង ព្រះនាងចូលមកថ្វាយបង្គំព្រះរៀមព្រះភក្ត្រនៅស្ញៀម ព្រះពោធិសត្វ បានទូន្មានព្រះអនុជកុមារី នឹងព្រះអរភ័យ កុមារតាមគន្លងធម៌ ព្រះបានផ្សំផ្គុំព្រះអនុជកុមារីនឹងព្រះអភ័យកុមារទ្រង់បាន ប្រទានពរជ័យផ្សេងៗ ដើម្បីជាសិរីសួស្តីដល់គូសង្សារថ្មីនេះ ។ ព្រះកុមារី មានក្តីស្វាមីភក្តិ នឹងសេចក្តីគោរពកោតខ្លាចព្រះចេស្តាបារមីនៃព្រះម ហើយតែងនាំគ្នាគាល់បំរើព្រះរៀមជានិរន្តរ៍ ។

ចំណេរកាលតមក ព្រះទេវន្ទកុមារ ទ្រង់បាននឹករលឹកដល់ព្រះវរមាតាជាខ្លាំង ដោយខ្លាចក្រែងយក្សយង់ ធ្វើទុក្ខទោសដល់ព្រះវរមាតា ឬមួយជាន តែងស្រី ប្រឈួនដោយ ព្រះរោគអ្វីមួយ ឬសុខសប្បាយជាទេ។ ក្នុងពេលរាត្រីទ្រង់ព្រះកន្សែងនឹក ដល់ព្រះវរមាតា ដោយក្តីរលឹកអាឡោះអាល័យយ៉ាងក្រៃលែង ។ ដល់ភ្លឺស្វាងឡើង ទ្រង់ត្រាស់បង្គាប់ពាជីឱ្យទៅហៅស្តេចស្វាស្តេចខ្លាឃ្មុំ ព្រមទាំង បរិវារឱ្យចូលមកគាល់ ព្រះអង្គ ព្រមទាំងកុម្ភណ្ឌ ៤ រូបឱ្យចូលមកគាល់ទ្រង់ឱ្យបានព្រមគ្នា ទ្រង់បានត្រាស់ដំណាលកាលព្រះបាទព្រហ្មទត្តនៃក្រុងពារាណសី ឯព្រះវរបិតាទ្រង់ស្តេចចេញទៅប្រពាតព្រៃព្រឹក្សា ត្រូវទន្និយក្សចាប់ទ្រងបរិភោគ ជាអាហារវា ហើយប្រុងចាប់សេះស៊ីទៀត តែសេះមានប្រាជ្ញាដោះខ្លួនរួចដ៏រាបដល់នាំគ្នារត់ចេញចាកនគរ មកឋិតនៅទីនេះដោយពិស្តារ ឱ្យពួករាជបរិវាបានស្តាប់ពត៌មាននោះដោយសព្វគ្រប់ ហើយទ្រង់ត្រាស់សំដែងអំពីព្រះចិន្តាទ្រង់ចង់ លើកទ័ពចេញប្រយុទ្ធនឹងនន្ទិយក្សឃោរឃៅ ហើយ

គ្រប់គ្រងរាជសម្បត្តិជារាជាទើបព្រះវរបិតារក្សាអាណាប្រជានុរាស្ត្រឱ្យបានក្តីសុខក្សេមក្សាន្ត ឱ្យបានជួបជុំព្រះញាតិវង្ស តើអ្នករាល់គ្នាស្ម័គ្រចិត្តទទួលយកអាសាយើងទេ ?

កាលណោះកុម្ភណ្ឌទាំង ៤ រូបព្រមទាំងស្តេចស្វាស នឹងស្តេចខ្លាឃ្មុំសឹងនាំគ្នាក្រាបទូលសូមយកអាសាព្រះរាជកុមារដោយស្មោះទាំងអស់ រាជកុមារត្រាស់ថា ក្នុងនគរនេះ មានសំពត់អាវសាវស្បៃនឹងមាសប្រាក់ច្រើន អនេកអវ័ត្ស តែឥតមាននមនុស្សម្នាក់សោះ នៅគ្រប់គ្រងថែរក្សានឹងខូចអសារ ឥតការ ដូច្នេះ ចូរស្តេចស្វាបញ្ជាដល់ពួកពលពានរឱ្យនាំគ្នារវេចស្តាយវត្ថុភស្តុភារទាំងនេះ មួយសំពាយម្នាក់ យកទៅសម្រាប់ចែកចាយដល់ស្មូមយាចក នឹងអ្នក កំសត់ទុគ៌តទាំងឡាយ ដែលមានហូរហែតាមផ្លូវរៀង១ ទៅ ដរាបដល់ទៅនគរ ពារាណសី ។ លុះបានរៀបចំដូច្នេះហើយ ទើបទ្រង់បញ្ជាឱ្យព្រះអនុជថ្លៃ ព្រះនាមអភ័យកុមារ គង់ស្តេចស្វាយោងមុខទ័ព ទ្រង់ត្រាស់ឱ្យព្រះនាងចន្ទ្រាកុមារី គង់ស្តេចខ្លឃ្មុំ ឯព្រះអង្គគង់តាជីដោយមានកុម្ភណ្ឌទាំងបួន ហែហមអមព្រះអង្គ ជាខាងក្រោយ លុះលើកទៅដល់ជាយក្រុងពារាណសី ទ្រង់ឱ្យបោះទ័ពសំចត ស្ទៀមចាំប្រយុទ្ធ ហើយទ្រង់ចាត់កុម្ភណ្ឌ១រូបឱ្យចូលទៅថ្លែងសារប្រាប់នន្ទិយក្ស ថា "យើងគឺព្រះទេវន្ទកុមារ យាត្រាទ័ពមកនឹងពិឃាតនន្ទិយក្សចិត្តចោរសាមាន្យ ហ៊ានក្នុងខ្លួនធ្វើជាព្រះវរបិតាទ្រង់គ្រប់គ្រងរាជសីមារបស់ព្រះអង្គ ឥឡូវ ទ្រង់ លើកទ័ពមកប្រយុទ្ធ ពិឃាតជីវិតប្រស្តែងបង" ។

កុម្ភណ្ឌកាឡាជាមាណពចូលទៅឡើងលើប្រាសាទ ដោយឥតកោតខ្លាច នន្ទិយក្សបន្ទិចឡើង ហើយបានថ្លែងសារឱ្យយក្សស្តាប់ ។ នន្ទិយក្សខឹងខ្លាំងស្ទុះមកទះកំផ្លៀងទូតមួយ ដងយ ងធូន់ មាណព ទ្រតដួលទៅ ហើយក្លាយរូបជា កុម្ភណ្ឌ ស្ទុះលោតទៅទះនន្ទិយក្សយ៉ាងខ្លាំង ធ្លាក់ពីលើរត្នសង្ហារផ្ទារស្រទាងកើត ពត៌មាន ជាយក្សយង់ឃោរឃៅមួយរំពេច ស្ទុះហោះផ្លោះទៅដើមជឆក់យកដំបង ធ្វើចម្បូ វិសេសរបស់ខ្លួន ។ ឯព្រះនាងវិមលា ស្រីស្នំស្រីង្គារ ស្រែកយំកងរំពង ហើយនាំ អាមាត ឆ្មារត់ចេញប្រសេកប្រសាច ខ្លះរត់ជាន់គ្នាដួលផ្កាប់ដួលផ្ងារ ដោយក្តីភិតភ័យ ... កុមារី តក្កមា មិនដឹងនរណាជានរណា ... ឯជនានុជនទាំងឡាយនាំគ្នារត់ពពាក់ពពូន ចូលបំពួនខ្លួនក្នុងផ្ទះសំបែងរៀងខ្លួន ពួកខ្លួនគេចរត់បំពួនខ្លួននៅក្នុងព្រៃខ្លួន ទៀតដែលក្លាហានគ្រាន់បើខំប្រវាឡើងដើមឈើលបចាំមើលយក្សច្បាំងគ្នា។

ឯមាណពកុម្ភណ្ឌជារាជទូតគិតថា បើតតាំងច្បាំងនឹងនន្ទិយក្សកណ្តាលក្រុង នឹងនាំឱ្យប្រជាជនស្លាប់អស់ច្រើន ដូច្នេះ គួរថយចេញទៅប្រយុទ្ធនៅខាងក្រៅក្រុងវិញ នន្ទិយក្សឆក់បានដំបងហើយក៏វិលត្រឡប់មកវិញ ដោយបំណងប៉ង ចាប់សម្លាប់ទូតនោះ ហើយបានហោះដេញតាមកុម្ភណ្ឌនោះ ។ ឯកុម្ភណ្ឌ "៣ រូបទៀតបានឃើញដូច្នោះ ក៏កាន់អាវុធរៀងខ្លួនចេញទៅ ហើយស្រែកសន្ទាប់ ដាក់គ្នាទៅវិញទៅមក ហើយចូលប្រយុទ្ធតទល់គ្នាទៅវិញទៅមកគគ្រឹកគគ្រេង។ ឯពាជីក្បាលសិង្ហស្ទុះហោះឡើងទៅប្រយុទ្ធនឹងយក្ស រាជសីក្បាលសិង្ហច្រមនឹងជើងខាំនឹងមាត់ពួកពលពានរនឹងពលខ្លាឃ្មុំ ក៏ព័ទ្ធឡោមចោមជុំវិញ ។ នន្ទិយក្សទ្រាំទ្រពុំបានក៏ដោះ ខ្លួនរត់ឡើងទៅលើកំពូលភ្នំ ដកដុំសិលាគ្រវែងទៅ ។ ពួកពលព្រះទេវន្ទកុមារកាលណោះពួកពលដេញតាមទៅឡោមព័ទ្ធទៀត នៅទីបំផុត កុម្ភណ្ឌមួយរូបវាយនន្ទិយក្សត្រូវចំ ស្មា ជើងមួយរូបទៀតវាយចំក្បាលមួយរូបទៀតវាយត្រូវខ្នង មួយរូបទៀត វាយត្រូវទ្រូង នន្ទិយក្សក៏ធ្លាក់ពីលើកំពូលភ្នំស្លាប់ក្នុងខណៈនោះឯង ។

លុះនន្ទិយក្សស្លាប់ហើយ ព្រះទេវន្ទកុមារ ទ្រង់បានឱ្យប្រកាសផ្សាយ ពត៌មានដល់អ្នកនគរថា ឥឡូវស្តេចនន្ទិយក្សស្លាប់ហើយ តើអ្នករាល់គ្នាសុខចិត្តនឹង ធ្វើចម្បាំងតទៅទៀត ឬសុខចិត្តថ្វាយរាជសម្បត្តិដល់យើង អាមាត្យមុខមន្ត្រី មានសេនាបតីជាដើម បានដឹងច្បាស់ថា ព្រះរាជកុមារ ព្រះរាជកុមារី ស្តេចត្រឡប់មកដល់នគរ ព្រមទាំងមានជ័យជំនះលើនន្ទិយក្សឃោរឃៅផង ក៏មានសេចក្តីត្រេកអររាល់គ្នា ហើយបានឡើងក្រាបទូលពត៌មានដល់ ព្រះនាងវិមលាទេវី ជាព្រះរាជមាតាមានព្រះហឫទ័យត្រេកអរមហិមា ទេវន្ទកុមារទ្រង់បញ្ជាឱ្យព្រះអនុជកុមារីគង់លើស្តេចខ្លាឃ្មុំព្រះអនុជថ្ងៃ គង់លើស្តេចពានរចេញជាក្បួនទៅមុន ឯទ្រង់គង់លើកកុម្ភណ្ឌ មានកុម្ភ៣ រូបហែហមអមព្រះអង្គ ពាជីក្បាលសិង្ហដើរតាមក្រោយ ។ ព្រះពួកអ្នកនគរនាំគ្នាស្រុះស្រួលទទួលព្រះរាជកុមា បានស្រុកថ្វាយព្រះពរ សព្ទសាធុការទ្រហឹងអឹងកង ។ ឯពួកអ្នកស្រុកដែលភៀសខ្លួនទៅពួនក៏នាំគ្នាត្រឡប់ចូលមកនៅក្នុងស្រុកយ៉ាងកកកុញ ដោយចិត្តរីករាយសាទរ ។ ព្រះទេវន្ទកុមារនឹងអនុជ បានចូលទៅក្រាបថ្វាយបង្គំព្រះវរមាតាន ដោយក្តីនឹករលឹកអាឡោះអាល័យក្រៃលែង ទាំងបីអង្គទ្រង់ព្រះកន្សែង សាយសោកដោយក្តីវិយោគលើសលន់ពល់ប្រមាណ លុះស្វាងលោក ហើយពួកអាមាត្យមុខមន្ត្រីនឹងប្រជារាស្ត្រនាំគ្នាក្រាបទូលអញ្ជើញព្រះរាជកុមារឡើងគ្រងរាជ្យសម្បត្តិ ។ ព្រះមទេវន្ទក្រោយទ្រង់បានចាត់ចែងរាជការ

គ្រប់គ្រងឱ្យមានរបៀបរៀបរយហើយ ទើបទ្រង់ចាត់បញ្ជូនកុម្ពលទាំង ៤ នឹងស្តេចស្វា ស្តេចខ្លាឃ្មុំ ព្រមទាំងពួកពលបរិវារឱ្យវិលត្រឡប់ទៅកាន់ទីលំនៅពិរៀងៗ ខ្លួនវិញ ។

ថ្ងៃមួយព្រះមទេវន្ទទ្រង់បានផ្ញើរាជសម្បត្តិដល់ព្រះវរមាតា ចូលចេញទៅស្ងួនស្វែងរកកុមារីណាមួយឱ្យសមជាអគ្គមហេសីរបស់ព្រះអង្គ។ ទ្រង់បានឡើងគង់ពាហោះចេញទៅបានដល់ទៅរាជឧទ្យាននៃនគរមួយស្តេចចូលទៅសុំស្នាក់នៅនឹងដូនចាស់ម្នាក់ ជាអ្នកក្រងកម្រងផ្កាថ្វាយព្រះរាជបុត្រី នៃព្រះមហាក្សត្រគ្រងរាជ្យនៃនគរនោះ ។ ដូនចាស់តែងក្រងកម្រងផ្កាថ្វាយព្រះ រាជធីតារាល់ថ្ងៃ ។ ព្រះបាទទេវន្ទទ្រង់សុំដូនចាស់ក្រងថ្វាយជំនួសគាត់ព្រះរាជបុត្រីបានទតឃើញកម្រងផ្កាវិចិត្រប្លែកខុសប្រក្រតី ត្រាស់ដេញដោលសួរដូនចាស់ ក៏ក្រាបទូលថាមានមាណពកំឡោះម្នាក់មកពីបរទេសឈ្មោះទេវន្ទកុមារ។ ព្រះរាជធីតាគ្រាន់តែបានទ្រង់សណ្តាប់ព្រះនាមនេះក៏ចាប់ព្រះទ័យស្នេហាចំឡែក ទ្រងចង់ទតឱ្យឃើញជាក់ច្បាស់ ។ នឹងព្រះនេត្រនូវព្រះរូបឆោមនៃទេវន្ទកុមារ ទើបព្រះនាងរកមធ្យោបាយទៅ ប្រពាតនៅសួរឧទ្យានក្រែងបានជួបប្រទះនឹងព្រះរាជកុមារដែលស្នាក់នៅផ្ទះ។ ដូនចាស់ ក្នុងព្រះរាជឧទ្យាននោះ ។ ព្រះនាងត្រិះរិះដូច្នេះហើយ ក៏យាងចូល គាល់ក្រាបទូលព្រះវរបិតា សូមព្រះរាជានុញ្ញាតទៅប្រពាតឧទ្យានជាការកំសាន្ត ព្រះវរបិតា ក៏ទ្រង់អនុញ្ញាត ទើបព្រះរាជធីតាព្រមដោយ ព្រះហឫទ័យរីរាយភីលៀងសាវដៃជាច្រើន ចូលទៅក្រសាលព្រះរាជឧទ្យានក្បែរផ្ទះដូនចាស់ដោយមានបំណងចង់ទតរូបឆោមព្រះរាជកុមារឱ្យបានជាក់ស្តែងនឹង ព្រះនេត្រ ព្រះនាង ត្រិះរិះរកមធ្យោបាយបង្កើតល្បែងបិទពួនឡើង ហើយទ្រង់ត្រាស់នឹងពួកស្រីជាបរិវារថា យើងនាំគ្នាលេងបិទពួនឱ្យសប្បាយហើយ ព្រះនាងបង្គាប់ឱ្យស្រីទាំងនោះបិទភ្នែក ហើយព្រះនាងរត់ទៅពួនក្បែរផ្ទះដូនចាស់ ជួនជាព្រះរាជកុមារបើក បង្អួច បានទតឃើញព្រះរាជធីតាក៏បានទតឃើញរូបឆោមព្រះរាជកុមារ សេចក្តីស្នេហាក៏កើតឡើងក្នុងខណៈនោះ ។ ក្សត្រាក្សត្រីទាំងពីរអង្គ ក៏បានចោទ សួរប្រស្នាគ្នាផ្សេងៗ ដោយគ្រាន់តែធ្វើកាយវិការទៅវិញទៅមក កុមារទ្រង់ជ្រាបថា ព្រះរាជធីតាមានប្រាជ្ញា ទ្រង់យល់ប្រស្នារបស់ទ្រង់ ។ ឯព្រះរាជធីតា ក៏ទ្រង់ជ្រាបជាក់ច្បាស់ថា បុរសនេះ មានប្រាជ្ញាណាស់ហើយ ព្រះនាង ផ្ញើប្រស្នាគឱ្យទ្រង់ចូលទៅរកព្រះនាងក្នុងពេលរាត្រីនោះ ។

ព្រះទេវន្ទកុមារ “ ទ្រង់បានជ្រាបប្រស្នានោះហើយ ទ្រង់បានបញ្ជានឹង ពាជីថា “បងពាជីនៅពេលអាធ្រាត្ររាត្រីនេះចូរបងនាំខ្ញុំទៅផ្គានប្រាសាទ ព្រះ រាជធីតាកុំខាន ដល់រំលងអាធ្រាត្របន្តិច ពាជីនាំទ្រង់ហោះទៅដល់ទ្វារខាង លើបង្អួស់ នៅល្វែងខាងលើនេះ មានស្រីភីលៀងសាវដៃដេកលក់គ្រៀមត្រា មានកាយវិការផ្សេងៗ គួរឱ្យធុញទ្រាន់ ទ្រង់យាងចូលទៅដល់ក្រឡាបន្ទំព្រះរាជធីតាដោយក្លាហាន ទ្រង់មានបន្ទូលដាស់ព្រះនាងតើនឡើងហើយ ព្រះនាងមានសវនីយ៍សួរថា៖

- “ទ្រង់យាងមកអំពីទីណា ?”

- បងមិនដឹងទេ ” ។

- ចុះយាងទៅក្នុងទីណាទៀត ? ”

- “បងមិនទាន់ដឹងទេ” ។

“ចុះខ្ញុំសួរថា ទ្រង់មកពីទីឋានណា ទ្រង់ឆ្លើយថា បងមិនដឹងទេ ចុះពាក្យ

នេះ មានន័យដូចម្តេច ?

- បងមិនបានដឹងថា មកពីឋាននរក ឬ ឋានសួគ៏ទេ ហេតុនេះ បានជាបង ឆ្លើយថា បងមិនដឹងទេ ។

- “ចុះខ្ញុំសួរថា ទៅកាន់ទីណា ចុះម្តេចក៏ទ្រង់ឆ្លើយថា បងមិនដឹងដែរ” ។ “ បងមិនបានដឹងជាមុនថា “ ច្យុតពីមនុស្សលោកនេះទៅកាន់ឋានសួគ៏បូ ឋាននករទ ហេតុនេះបានជាបងឆ្លើយថា បងមិនដឹងដែរ” ។

ដូចម្តេច ?“ចុះទ្រង់យាងមកអំពីនគរណា ជាបុត្ររបស់ស្តេចណា មានព្រះនាមព្រះទេវន្ទ ទ្រង់មានបន្ទូលថ្លែងសាស័ព្ទប្រាប់តាមដំណើរសព្វគ្រប់ហើយត្រាស់ថា នឹងនាំព្រះនាងទៅធ្វើជាឯកអគ្គមហេសីរបស់ព្រះអង្គឯក្រុងពារាណសី ។ ព្រះបាទទេវន្ទត្រាស់ថា “ សូមប្អូនសរសេរលិខិតមួយទុកថ្វាយព្រះអង្គ ប្អូនបានស្ម័គ្រចិត្តទៅជាមួយនឹងព្រះរាជស្វាមី ព្រះបាទទេវន្ទកុមារសូមក្រាប ថ្វាយបង្គំព្រះបាទា ព្រះវរមាតា បិតាអស់កំឡុង ៧ ឆ្នាំនឹងវិលត្រឡប់មកវិញ

សូមព្រះរាជទានអភ័យទោសន្តោសប្រោសប្រណី សូមព្រះគុណធូន់ទាំងពីរអង្គកុំព្រួយ បារម្ភ ឱ្យសោះ ”។

ក្សត្រា ទ្រង់បានឡើងគង់ពាជី ហោះសំដៅទៅក្រុងពារាណសី ដល់រសៀលទន់ទាបព្រះសុរិយា ក៏បានដល់ទៅដើមជ្រៃមួយដើមធំ ជិតក្រុង ពារាណសី ព្រះបាទទេវន្ទ ទ្រង់មានព្របំណងចង់ចាត់ក្បួនដង្ហែព្រះរាជទេពី ចូលទីក្រុង ឱ្យសម ព្រះកិត្តិយស ព្រះនាង ទើបទ្រង់ចូលឈប់សម្រាកក្រោមម្លប់ ជ្រៃនោះ ហើយទ្រង់មានព្រះបន្ទូលនឹងព្រះទេពីថា “សុំឱ្យព្រះនាងគង់រង់ចាំនៅទី នេះសិន បងនឹងនាំក្បួនដង្ហែជាកិត្តិយសមកទទួលព្រះនាង” ហើយស្តេចឡើងគង់ ពាជីបរចូលទៅក្នុងក្រុងពារាណសី ក្រាបបង្គំទូលព្រះវរមាតាឱ្យបានទ្រង់ជ្រាប តាមដំណើរ ។

ក្រោយព្រះជាទទេវន្ទយាងចេញផុតទៅ មាននាងយក្ខិនីមួយត្រាច់ក្នុងព្រៃ។ ស្ទុះស្វែងរកប្ដីដោយកាមកិលេសដុតរោលជាខ្លាំង បានដើរមកដល់ដើមជ្រៃនោះក្រឡេកមើលទៅលើដើមបានឃើញនាងទេវីលើមែកជ្រៃ ក៏សួរថា “នាង ជាអ្វី មកពីទីណា ហេតុអីក៏មកនៅទីនេះ?” ។

ព្រះនាងទេវីឆ្លើយថា ខ្ញុំជាស្រីមនុស្សឈ្មោះ សុវណ្ណកេសរាទេវី មហេសី ព្រះបាទទេវន្ទ ក្រុងពារាណសី ហើយ ព្រះនាងបានថ្លែងសាស័ព្ទប្រាប់តាមដំណើរសព្វគ្រប់ ។

នាងយក្ខិនីគិតថា “ បើអញសម្លាប់នាងនេះចោលទៅ កាឡារូបជារាជ,មហេសីជំនួសនាងនេះ អញមុខជាបានក្ដីសុខសប្បាយ អាហារភោជនមិនខ្វះ បរិភោគ មុខដោយទួលសុភមង្គលគ្រប់យ៉ង គិតហើយនាងយក្ខិជី ក៏តាំងដើរ ស្ដីថា ព្រះនាងលួចប្ដីវា ហើយវាចាប់ព្រះនាងវាយតប់ទ ធ្លាក់សន្លប់ យក្សស្មានថា ព្រះនាងស្លាប់ ទើបចាប់ព្រះនាងបោះចោលក្នុងទន្លេទៅវាកាឡាជារូបព្រះទេវីឡើងទៅអង្គុយលើមែកជ្រៃជំនួសព្រះនាង ។

ឯព្រះនាងអណ្តែតទៅតាមខ្សែទឹក ហើយទៅទើរនៅស្ពានមួយ ដែលមាន ដូន តា ពីរនាក់ កំពុងដួតទឹកនៅទីនោះព្រះនាងមានស្មារតីឡើង វិញ ទ្រង់បានប្រហែមឡើងធ្វើឱ្យដូនតាបានឃើញបានដឹងថា មានមនុស្សលង់ទឹក អណ្តែតមកទើរនៅចុងស្ពានគាត់ ពីរនាក់ប្ដីប្រពន្ធជួយ ស្រង់ព្រះនាងឡើងហើយ បានសាកសួរពីដំណើរដើមទង ។ ព្រះនាងក៏បានថ្លែងប្រាប់ពីដំណើររបស់ព្រះនាង ឱ្យដូនតាបានជ្រាបតាមដំណើរសព្វគ្រប់ ។

ឯព្រះបាទទេវន្ទកុមារ ទ្រង់បានចាត់ឱ្យអាមាត្យមន្ត្រី នឹងពួកស្នំស្រីគ្គារ ជាច្រើន ទៅដង្ហែព្រះនាងទេវីពីដើមជ្រៃ ចូលមកក្នុងព្រះរាជវាំង” ។ ទ្រង់បាន នាំព្រះរាជទេពីចូលទៅក្រាបថ្វាយបង្គំព្រះវរមាតាព្រះអង្គ តាមទំនៀម ប៉ុន្តែក្នុង ព្រះហឫទ័យហាក់ដូចជាចំឡែក មិនមានក្ដីស្នេហាប្រតិព័ទ្ធចំពោះព្រះនាងសោះ មានក្ដីរសាប់រសល់អល់អែកក្នុងដួងហឫទ័យ មិនអស់មិនហើយ ហើយ ព្រះអង្គ មានក្ដីសង្ស័យចំពោះព្រះនាងទេវីរបស់ព្រះអង្គពន់ពេក ។ ក្នុងរាត្រីមួយ ទេវតា រក្សាស្វេតច្ឆត្រ បានទូលពត៌មានក្នុងព្រះសុបិនថា បើព្រះអង្គចង់ជួបនឹងព្រះនាង សុវណ្ណកេសរាទេវីរបស់ព្រះអង្គ សូមឱ្យទ្រង់សង់សាលាសម្រាប់សំដែងធម៌ ១ ខ្នង ហើយឱ្យប្រកាសផ្សាយដល់អ្នកនគរស្ត្រីណាមួយអាចសំដែងធម៌ថ្វាយដល់ ព្រះមហាក្សត្របាន ទ្រង់នឹងព្រះរាជទានថង់មាសមួយពាន់ដំឡឹងជារង្វាន់ ។ អាមាត្យលើកថង់មាសដាក់លើខ្នងដំរី បានប្រកាសផ្សាយតាមព្រះរាជឱង្គារ អស់គម្រប់បីថ្ងៃក៏គ្មានស្ត្រីណាមួយឆ្លើយទទួលភារៈនោះសោះ។ ថ្ងៃក្រោយមក អាមាត្យក៏ចេញទៅប្រកាសផ្សាយខាងក្រៅក្រុងទៀត ហើយបានទៅជិតទីលំនៅ របស់ដូនតា ព្រះរាជទេវី សុវណ្ណកេសរា បានទ្រង់ជ្រាបពីមាននោះហើយ បានទ្រង់ជ្រាបក្នុងព្រះហឫទ័យថា ព្រះរាជស្វាមីចង់ជួបនឹងព្រះនាង ហើយព្រះ នាងមានព្រះសវនីយនឹងដូនតាថា សុំឱ្យឆ្លើយប្រាប់ទៅអាមាត្យនោះថា ព្រះនាង ចេះសំដែងធម៌ថ្វាយ ព្រះមហាក្សត្របាន អាមាត្យបានប្រគល់មាសមួយពាន់ ដំឡឹងដល់ដូនចាស់ ហើយនាំពត៌មាន ក្រាបបង្គំទូលដល់ព្រះបាទទេវន្ទ ត្រាស់ បង្គាប់អាមាត្យមុខមន្ត្រី នឹងប្រជាជនឱ្យចូលជំនុំស្ដាប់ធម៌ នៅមហាសាលាក្នុង វេលាព្រឹកស្អែក ។ ព្រះរាជាទ្រង់ចាត់ឱ្យយករាជយានទៅទទួលព្រះរាជទេវី អំពីផ្ទះដូនតា ព្រះរាជាស្ដេចយាងទៅព្រះរាជាធិបតីនៃពិធីស្ដាប់ធម៌ក្នុងគ្រានោះដែរ ។

ព្រះនាងទេវី ទ្រង់កាន់វិជនី ឡើងគង់លើខ្នាសនៈ ហើយបានទ្រង់សំដែង អំពីមិត្តធម៌ ១០ ប្រការ ។ លុះចប់ធម្មទេសនាមហាជន បាន ស្រុកថ្វាយពរ - សព្ទសាធុការទ្រហឹងអឺងកង ។ ព្រះរាជាទ្រង់គង់ស្ដាប់ធម៌ខាងក្រៅព្រះសន្ទិយា គ្រាតែចប់ ទ្រង់បានសណ្ដាប់សូរសំឡេងទ្រង់សង្ស័យថា ជាសំឡេងព្រះរាជាទេវី សុវណ្ណកេសរា ទើបទ្រង់ផើយព្រះសន្ទិយាឡើង ហើយទ្រង់ត្រាស់សួរនាងថានាង ឈ្មោះអី ? ។

ព្រះរាជាត្រង់សណ្ដាប់ ទ្រង់គ្រេវក្រោធយ៉ាងខ្លាំងត្រាស់បង្គាប់ឱ្យកុម្ភណ្ឌចាប់នាងយក្ខិនីយកទៅប្រហារជីវិតបង់ ប៉ុន្តែព្រះនាងកេសរាទេវី ក្រាបបង្គំទូលសុំទោសកុំឱ្យប្រហារជីវិតពីព្រោះអកុសកកម្មនាងផ្តល់ព្រះនាងឱ្យរងទុកវេទនាដូច្នោះឯង។ ព្រះអង្គត្រាស់នឹងកុម្ភល្បីថា រូបនាងយក្ខិនីមួយនេះស្រេច ទៅអធ្យាស្រ័យរបស់អ្នករាល់គ្នាចុះ ។ កុម្ភណ្ឌទាំង ៤ នាំខ្លួននាងយក្ខិនីទៅហេមពាន្ត ឱ្យធ្វើជាភរិយានៃខ្លួនទាំង ៤ រូប ។

ព្រះបាទេវន្ទ ទ្រង់បញ្ជាឱ្យចាត់ចែងធ្វើមង្គលអភិសេកព្រះនាងសុវណ្ណកេសរាទេវី ជាអគ្គមហេសីរបស់ព្រះអង្គ ។ ទ្រង់តែងសង្គ្រោះប្រជាពលរដ្ឋរបស់ ព្រះអង្គដោយសង្គហវត្ថុ ៤ ប្រការ ទ្រង់បានចាត់សាងសាលា ឆទាន នៅទ្វារ ព្រះនគរទាំងបួន នៅកណ្ដាលព្រះនគរ ១ ក្បែរទ្វារព្រះរាជវាំង ១ ទ្រង់បានចំណាយទានដល់ស្មូមយាចក ទ្រង់បានរក្សានិច្ចសីលជានិរន្តរ៍ ។ ថ្ងៃមួយព្រះអគ្គមហេសី ទ្រង់បាននឹករលឹកដល់ព្រះវរមាតា បិតា របស់ព្រះនាងជាខ្លាំង ទើបក្រាបទូលព្រះរាជស្វាមីថា “តឡូវកន្លង ៧ ឆ្នាំហើយ ខ្ញុំម្ចាស់មិនបានជួបព្រះភក្ត្រព្រះវរមាតា បិតាសោះ សូមទ្រង់អនុគ្រោះនាំខ្ញុំម្ចាស់ ទៅថ្កានដែលកោសេយ្យរដ្ឋថ្វាយបង្គំព្រះវរមាតា បិតា” ព្រះបាទទេវន្ទ ទ្រង់បញ្ជាឱ្យពួកជាងតសំពៅ ៥០០ រយជាក្បួនដង្ហែព្រះនាងយាងទៅតាមផ្លូវសមុទទ្រង់ផ្ទុកគ្រឿងរាជបណ្ណាការផ្សេងៗ ក្នុងសំពៅ សម្រាប់ជាដង្វាយដល់ព្រះវរ មាតា-បិតាក្មេករបស់ ព្រះអង្គ ។ ព្រះអង្គបានប្រគល់រាជសម្បត្តិដល់ព្រះអភ័យ កុមារជាព្រះអនុជ ឱ្យគ្រប់គ្រងថែរក្សាតាងព្រះអង្គ ព្រះរាជានឹងព្រះ អគ្គមហេសី ទ្រង់យាងចុះក្នុងមហានាវា ព្រមដោយសំពៅ ៥០០ បរចេញទៅក្នុងសមុទ្រធំធេង អស់ថិរវេលាកន្លះខែ ព្រះរាជាទេពី ដែលមានគផ្ទៃខែ ក៏ទ្រង់បានប្រសូត្រព្រះរាជបុត្តក្នុងមហានាវា នាកណ្តាលសមុទ្រព្រះវរ បិតាព្រះទានព្រះនាមថា ចៅសាគរកុមារ ។ អស់កំឡុង ១ខែ សំពៅក៏បានដល់កោសេយ្យនគរដោយសួស្តី ។

ឯព្រះបាទកោសេយ្យរាជ កាលទ្រង់ជ្រាបពត៌មានថា ព្រះរាជាបុត្រីនឹង ព្រះរាជបុត្រប្រសា ស្ដេចយាងមកដល់ឆ្នេរកំពុងសមុទ្រទ្រង់មានព្រះទ័យត្រេក អរណាស់ ទ្រង់បានឱ្យរៀបទទួលស្វាគមន៍ជាឧឡារិកអធិកអធម ហើយនៅទីបំផុតទ្រង់ឱ្យចាត់ចែងពិធីរាជាភិសេកព្រះបាទទេវន្ទនឹងព្រះរាជបុត្រីសុវណ្ណ- កេសរា ឱ្យគ្រប់គ្រងរាជសម្បត្តិក្នុងកោសល្យនគរ ដោយមានព្រះបំណងចង់ ចងហឫទ័យនៃរាជបុត្រប្រសានឹងរាជបុត្រី កុំឱ្យឃ្លាតចេញពីព្រះអង្គ ព្រមទាំង ប្រទានសុភមង្គលគ្រប់យ៉ាងផ្តល់ព្រះរាជបុត្រទាំងពីរព្រះអង្គ ។

តមក ព្រះនាងសុវណ្ណកេសរាទេវី បានប្រសូត្រព្រះរាជបុត្រមួយអង្គ ទៀត មា3កាន់ក្តាប់សរមួយក្នុងព្រះហស្តផង ។ តាមនិមិត្រនេះ ទើបព្រះវរបិតា ប្រទាននាមថា “ចៅសហស្សសរកុមារ” លុះព្រះរាជកុមារទាំងពីរអង្គ ទ្រង់ចំរើន វ័យហើយ ព្រះបាទទេវន្ទមហារាជត្រាស់នឹងព្រះរាជបុត្រទាំងពីរថា “ បាទាំងពីរ មានចំណេះដឹងចេះស្ទាត់ជំនាញខាងសិល្បៈធ្នូពិតមែន តែសិល្ប៍វិជ្ជាផ្សេងៗ ទៀត មិនទាន់បានសិក្សាសោះ ដូច្នេះចូរបាចេញទៅស្វែងរករៀនវិជ្ជានៅសំណាក់អាចារ្យ ទិសាបាមោក្ខ ឯនគរតក្កសិលា ព្រះរាជកុមារទាំងពីរអង្គក៏ទទួលប្រតិបត្តិ តាមព្រះរាជឱង្ការនៃព្រះវរបិតាដោយសេចក្តីគោរព ។ ព្រះសាគរកុមារ នឹងព្រះ សហស្សសរកុមារ បានចេញចរយាត្រា ត្រាតបានទៅដល់នគរតក្កសិលា បានចូល ទៅសុំសិក្សាវិជ្ជាផ្សេងៗ អស់កំឡុងយូរឆ្នាំ ត្រាតែបានចេះចប់សព្វគ្រប់ ទើប ទ្រង់លាអាចារ្យទិសាបាមោក្ខត្រឡប់មកនគរវិញ “។

ព្រះរាជកុមារទាំងពីរអង្គ បានធ្វើដំណើរឆ្ងាយលន្លង់លន្លោចបានចូលព ចេញវាលហើយវង្វេងចូលទៅក្នុងព្រៃធំ ហើយបានប្រទះអាស្រមឥសី ១ រូបបានទូលសួរផ្លូវទៅកាន់កោសយ្យនគរតាបសមានចិត្តសប្បុរស បានសុំឱ្យទ្រង់ស្នាក់នៅអាស្រមលោកមួយរាត្រីសិងព្រឹកឡើងលោកនឹងចង្អុលបង្ហាញផ្លូវ

ដែលត្រូវធ្វើដំណើរទៅកោសេយ្យនគរ ។ ព្រះរាជកុមារទ្រង់បាននមស្សការលា តាបស ហើយត្រាច់ទៅតាមផ្លូវទិសដែលតាបសបានចង្អុលប្រាប់ លុះបានធ្វើ ដំណើរឆ្ងាយពីទីអាស្រម ដល់ថ្ងៃរសៀលទ្រង់បានឃើញដើមជ្រៃមួយធំក្នុងទ្រូង ព ក៏បានចូលទៅសម្រាកព្រះអង្គក្រោមម្លប់ជ្រៃនោះ ។

កាលណោះ មានស្ដេចយក្ស ១ ឈ្មោះកុដុន្តរាជ គ្រងរាជ្យនៅកុជិន្តនគរ បានហោះមកក្បែរដើម បានឃើញព្រះរាជកុមារទាំងពីរ មានរូបឆោមប្រសើរ ថ្ងៃ ក៏មានចិត្តស្រឡាញ់ពេញចិត្តណាស់ ទើបក្រុងយក្សសណ្តំព្រះរាជកុមារ ទាំងពីរអង្គ ពារហោះទៅកុដម្ពនគរដោយយល់ឃើញថា រាជកុមារទាំងពីរនេះ មានរូបឆោមសមសួនឹងធីតារបស់ខ្លួន ក្រុងយក្សបានដាក់ទ្រង់ឱ្យផ្ទុំលើក្រឡា បន្ទំក្នុងសុវណ្ណ ប្រាសាទ ហើយឱ្យហៅរាជធីតាឈ្មោះអសុរិន្ទនារី ឱ្យចូលទៅគយ គន់រូបឆោមព្រះរាជកុមារ តើពេញចិត្តឬមិនពេញចិត្តទេ ។ នាងអសុរិន្ទនារី កើតចិត្ត

ប្រតិព័ទ្ធស្នេហា ចំពោះព្រះសាគៈកុមារណាស់ បានបបោសអង្អែលដោយ ក្ដីស្នេហា ហើយបានដាស់ព្រះរាជកុមារឱ្យរលឹកឡើង ។ ព្រះសាគរកុមារ បានតើនឡើង ក្រឡេកឃើញនារីមានរូបឆោមប្រិយ ប្រ័យគួរជាទីស្នេហាក្រៃលែង ព្រមទាំងប្រាសាទរាជដ្ឋាន ដ៏ស្អាងស្អាតចិញ្ចាចចិញ្ចែង ក៏មានសេចក្ដីងឿងឆ្ងល់ ណាស់ ទើបទ្រង់ត្រាស់សួររាជធីតានៃក្រុងយក្សថា ទ្រង់ពីរនាក់បងប្អូន សម្រាកក្រោមដើមជ្រៃក្នុងព្រៃរហោឋាន ចុះដូចម្ដេចបានជាយើងមកនៅក្នុងទី នេះវិញ នាងអសុរិន្ទនារី ក៏បានសាស័ព្ទប្រាប់តាមដំណើរ ព្រះរាជកុមារ ត្រាស់សួរថា ហៃប្អូនស្រី ចុះនាមព្រះនាងដូចម្ដេច ?

- ខ្ញុំម្ចាស់ឈ្មោះអសុរិន្ទាជារី ។

- ចុះព្រះវរបិតានាង ព្រះនាមដូចម្ដេច ? ។

ព្រះបាទកុជិន្ទរាជ ។

- ចុះនគរនេះ មានឈ្មោះដូចម្ដេច ? ។

- ឈ្មោះកុជន្ទនគរ ។

ក្រោយបានថ្លែងជីវប្រវត្តិប្រាប់គ្នាទៅវិញទៅមក ហើយនៅទីបំផុតព្រះ ក៏បានស្ម័គ្ររួមរសមេត្រីស្នេហាជាមួយគ្ន រាជកុមារនឹងរាជធីតានៃក្រុងយក្សដោយក្ដីរីករាយតាមប្រពៃណី ។ ដល់ថ្ងៃស្អែកឡើង ព្រះបាទកុជិន្ទរាជ បានត្រាស់បង្គាប់ឱ្យពលយក្សនឹងមន្ត្រីទាំងប៉ុន្មានឱ្យកាឡាអាត្មាជាមនុស្សលោកទាំងអស់ ។ ព្រះសាគរកុមារ ឋិតនៅក្នុងនគរយក្សនោះ បានទទួលសេចក្ដីសុខមនោរម្យ នឹង សុភមង្គលគ្រប់យ៉ាងលែងនឹករលឹកដល់ព្រះវរមាតា-បិតាសោះ សហស្សសតកុមារតែងចូលរំលឹកព្រះរៀម អង្វរព្រះរៀមសូមលាទៅនគរវិញ ដោយក្ដីនឹករលឹកព្រះវរមាតា បិតាជាខ្លាំងព្រះរៀមសូមឃាត់ព្រះអនុជឱ្យរង់ចាំបន្តិចទៀត ដល់ឆ្នាំក្រោយសឹមយើងនាំគ្នាទៅថ្វាយបង្គំព្រះវរមាតាបិតា យើងហើយទ្រង់នាំអនុជទៅប្រពាតឧទ្យាន ព្រះបោក្ខរណីព្រៃព្រឹក្សា ។ល ។ ដើម្បីឱ្យព្រះអនុជ សប្បាយព្រះទ័យ លែងទឹករលឹកទៅស្រុក ។

ចំណេរកាលតមក មានស្ដេចយក្សមួយឈ្មោះ៖ សច្ចពន្ធរាជ លុះបានដឹងថា យក្ស កុជិន្ទរា លើករាជធីតាឱ្យទៅព្រះរាជកុមារជាតិមនុស្សលោកក៏ក្រេវក្រោធមហិមា ដោយចោទប្រកាន់ថា ក្រុងកុជិព្រះរាជ យល់ព្រមូ ទាំងអសុរិន្ទនារី មកកូនកម្លោះខ្លួនរួចទៅហើយ ម្ដេចឡើងត្រឡប់ប្រែជាលើកទូទៅមនុស្សលោកវិញ រាជ ។ទើបកេណ្ឌទ័ពយក្សលើកចេញទៅប្រយុទ្ធនឹងក្រុង ឯទ័ពនៃក្រុងកុជន្ទរាជដោយមានព្រះរាជកុមារដ៏មានឬទ្ធទាំងពីរ អង្គជួយច្បាំងផងធ្វើឱ្យមានជ័យជំនះឈ្នះកងទ័ព ស្ដេចយក្សសច្ចពន្ធរាជបានកួនប្រសាដោយងាយ ក្រុងកុជិន្ទរា បានឃើញឬទ្ធីចេតស្ដាអស្ចារ្យនៃព្រះសាគរកុមារ ក៏មាសេចក្ដីពេញចិត្តណាស់ ទើបធ្វើពិធីរាជាភិសេកព្រះសាគរកុមារឱ្យ ឡើងគ្រងរាជក្នុងកុជិន្ទនគរ ។ ឯព្រះសហស្សសរកុមា បានទូលលាព្រះរៀប ព្រះបាទសាគររាជទៅកាន់មាតុភូមិ ដើម្បីថ្វាយបង្គំព្រះវរមាតាបិតា ព្រះ រៀមក៏បានយល់ព្រមទៅជាមួយនឹងព្រះអនុជ ។ ក្រុងកុជិន្ទរាជ ក៏មានបំណងចង់ ទៅជាមួយដែរ -ក្សត្រទាំង ៤ អង្គ បានទៅដល់កោសយ្យនគរដោយសួស្ដី ហើយបានជួបជុំព្រះរាជវង្សានុវង្ស ។ ក្រុងកុជិន្ទរាជ បានស្នាក់នៅក្នុងកោសយ្យ នគរអស់កំឡុង ៣ ខែ ទើបទ្រង់ទូលលាព្រះបាទទេវន្ទរាជ នាំព្រះបាទសាធររាជ នឹងរាជបុត្រី ត្រឡប់ទៅកុជិន្ទនគរវិញ ។

ព្រះនាងសុវណ្ណកេសរាទេវី បានប្រសូតព្រះរាជបុត្រីមួយអង្គទៀត ព្រះវរ ព្រះជរា ទ្រង់បានប្រគល់រាជសម្បត្តិទៅព្រះសហស្សសរកុមារឱ្យគ្រប់គ្រង ព្រះបិតាប្រទានព្រះនាមថា "សុវណ្ណបភា។ អំណើះកាលតមក ព្រះបាទទេវន្ទ ទ្រង់ព្រះជរា ទ្រង់បានប្រគល់រាជសម្បត្តិទៅប្រះសហស្សសរកុមារឱ្យគ្រប់គ្រង ព្រះអង្គស្ដេចចៅទ្រង់ព្រះផ្នួសជាតសីនៅព្រៃហេមពាន្ត ។

ព្រះបាទសហស្សសររាងពួកអាមាត្យមុខមន្ត្រីបានជំនុំព្រមព្រៀងគ្នាថា ព្រះមហាក្សត្រនៃយើង ពុំទាន់មានព្រះអគ្គមហេសីសោះ ដូច្នេះគួរយើងគិតគូរ ផ្សំផ្គុំព្រះអនុជកុមារីអភិសេកជាអគ្គមហេសីព្រះរាជាយើងទើបសមសក្តិ សម នឹងរាជត្រកូលដ៏ខ្ពង់ខ្ពស់ សមជាទីគោរពសក្ការៈនៃប្រជាពលរដ្ឋទាំងឡាយ ។ លុះជំនុំព្រមគ្នាដូច្នេះហើយ ក៏នាំយកសេចក្ដីជំនុំនេះក្រាបទូលដល់ ក្សត្រាក្សត្រី ទាំងពីរព្រះអង្គ ក្រោយបានទទួលព្រះរាជានុញ្ញាតហើយ ទើបគេចាត់ចែងពិធី អភិសេកព្រះនាងសុវណ្ណប ជាអគ្គមហេសីព្រះបាទសហស្សសរមហារាជ ។ ក្សត្រាក្សត្រទាំងពីរអង្គបានទទួលសុភមង្គលជាទីមនោរម្យ ទាំងខេត្ត ដែនក៏បាន ក្ដីក្សេមក្សាន្តសុខសន្តិភាព រៀងដរាបតទៅ។

## ១.សេចក្តីវិភាគរឿង

### ក.អត្ថន័យខ្លឹមសារ

អត្ថន័យអត្ថ .ប្រយោជន៍.អត្ថន័យ .ការណែនាំអត្ថាធិប្បាយសេចក្តីពន្យល់.អត្ថន័យជាគំនិតសំខាន់ៗរបស់អ្នកនិពន្ធដែលលាតត្រដាងនៅក្នុងដំណើររឿង ហើយគេអាចហៅវាថាជាជម្រៅនៃរឿង។

ក្នុងផ្នែកអត្ថន័យមាន ប្រធានរឿង មូលបញ្ហារឿងនិងឧត្តមគតិរឿង។

### ខ.ប្រធានរឿង មូលន័យ

ប្រធានរឿងឬមូលន័យ គឺជាគំនិតសំខាន់ៗរបស់រឿង។ ប្រតិឬជាបញ្ហារួមរបស់រឿង។ តែអ្នកនិពន្ធចង់បង្ហាញដល់អ្នកអានប្រធានរឿងជាបញ្ហារូបផ្តុំបំផុតដែលអ្នកនិពន្ធលើកយកមកសរសេរឬជ្រើសរើសជាប្រធានបទហើយដែលមានមូលបញ្ហារឿងឋិតនៅក្នុងនោះ។

ប្រធានរឿង បង្ហាញនៅចំហររបស់អ្នកនិពន្ធ វាជាមូលដ្ឋានដើមរបស់អ្នកនិពន្ធក្នុងការចាប់ផ្តើមសរសេរឡើង។ មុនពេលចាប់ផ្តើមសរសេរឡើង។អ្នកនិពន្ធគ្រប់រូបត្រូវកំណត់ថាតើគាត់ត្រូវសរសេរអំពីអ្វី។ អំពីជីវិតសង្គមសង្គ្រាមស្នេហារឿងជំនឿទនៀមទម្លាប់ប្រពៃណីចម្លើយរបស់សំណួរនេះហើយជាប្រធានរឿង។

នៅក្នុងស្នាដៃរឿងបញ្ញាសជាតកតាមរយៈការអានរឿងនេះជាច្រើនលើកច្រើនសារ យើងខ្ញុំរកឃើញនិង សំរេចជ្រើសរើសយក ដំណើរជីវិតនិងការសងសឹករបស់ ព្រះទេវន្ទកុមារ។

### គ.មូលបញ្ហារឿង

មូលបញ្ហារឿង គឺជាភាពចំណែកនៃប្រធានរឿងជាទិដ្ឋភាពផ្សេងៗរបស់យើង។វាជាការចូលជ្រៅទៅក្នុងប្រធានរឿង។

ជុំវិញប្រធានរឿងនេះ យើងបានកំណត់បញ្ហាជាច្រើន ដែលនៅជុំវិញការកសាងសីលបារមីរបស់ព្រះពោធិសត្វ បញ្ហាទាំងនោះរួមមានៈ

#### ទី១ បញ្ហាយក្សនន្ទិសម្លាប់ព្រះបាទព្រហ្មទត

យក្សនន្ទិបានប្រើល្បិចកលមាយាធ្វើជាប្រើសមាសឱ្យព្រះបាទព្រហ្មទតខើញ ព្រះអង្គបានឃើញហើយមានចិត្តចង់បានក៏ដេញតាមចាប់ ចំណែកសេះសេនាក៏បានដេញដែរ ពេលសេះព្រះបាទព្រហ្មទតបោលយ៉ាងលឿនទៅម្នាក់ពេលនោះប្រើសប្រែជារូបដើមវិញក្លាយទៅជាយក្សបានសម្លាប់ព្រះបាទព្រហ្មទតជាព្រះបិតារបស់ព្រះទេវន្ទ ហើយបានទៅកាន់ឡាខ្លួនបន្លំធ្វើជាស្តេចសោយរាជ្យក្នុងព្រះនគរ បង្កជា បញ្ហាផ្សេងៗជាច្រើនបានចោទពួកមន្ត្រីថា បានធ្វើខុសរឿងនេះរឿងនោះមិនចេះចប់មិនចេះហើយ តាមពិតជាល្បិចចាប់មនុស្សទៅធ្វើជាចំណីវាសោះ ជាពិសេសសម្លាប់មនុស្សក្នុងនគរធ្វើជាចំជារៀងរាល់រាត្រី។

សរុបមកនៅពេលជួបបញ្ហានៅចំពោះមុខយើងត្រូវចេះដោះស្រាយ ដោយការរិះរកកិតឱ្យបានវែងឆ្ងាយកុំដូចព្រះបាទព្រហម្មទតមានការចង់បានខ្វះការពិចារណាធ្វើឱ្យខ្លួនអន្រោយនិងត្រូវយក្សសម្លាប់ទៀតផង។

#### ទី២ បញ្ហាព្រះទេវន្តទៅសងសឹកយក្ស

ព្រះរាជកុមារទេវន្ទបានប្រមូលហៅ ស្តេចស្វាសរ ស្តេចខ្លាឃ្មុំ ព្រមទាំងបរិវា និងគុម្ភណទាំងមួនរូបចូលគាល់ ព្រះកុមារបាននិយាយប្រាប់ពីដំណើររឿង ព្រះបាទព្រហ្មទតត្រូវយក្សចាប់ស៊ី ហើយប្រុងចាប់សេះស៊ីទៀត ហើយព្រះអង្គនិងចន្ទាកុមារីក៏បានមកនៅទីនេះ ។ ព្រះអង្គបាននិយាយពីគោលបំណងចង់ទៅច្បាំងសម្លាប់យក្សយកនគរវិញ ជួយដល់មាតានិងប្រជារាស្ត្រ តើអស់អ្នកជួយយើងទេ ។ពួកខ្លាឃ្មុំសុទ្ធចង់ទៅជួយយកអសារព្រះរាជកុមារ ទើបព្រះរាជកុមារត្រាសថា នគរនេះមានសំពត់សាស្បៃ មានប្រាក់ឱ្យពួកស្វាយកទៅចែកបងប្អូនអ្នកស្រុកក្រីក្រ ដែលមានហូរហែរតាមមផ្លូវ ។ ព្រះអង្គបានត្រាស់ឱ្យអភ័យកុមារនិង ស្តេចស្វាសរចេញនាំមុខទ័ព ឯចន្ទាកុមារីគង់ស្តេចខ្លាឃ្មុំ ឯគង់ពាជីដោយមានគោភណ្ឌទាំងបួនហែះម

ពីក្រោយ។ ដល់ជាយក្រុងនគរពារាសីហើយបានបោះកន្លែងឈប់ទ័ព បានចាក់គុភណ្ឌម្នាក់ឱ្យជូនសារទៅនន្ទិយក្ស យើងទេវទូតកុមារមកពិឃាតនន្ទិយក្សចិត្តសាមាណហានក្លាងខ្លួនធ្វើជាបិតាទ្រង ឥឡូវនេះទ្រង់យាងមកពិឃាតប្រះស្តែងបង់គុភណ្ឌបានឡើងលើប្រាសាទថ្លែងសារឱ្យយក្សស្តាប់។ នន្ទិយក្សខឹងខ្លាំងណាស់ហោះមកទះកម្លៀងគុភណ្ឌមួយដៃធ្លាក់មកក្លាយជាយក្សមួយរំពេចហើរទៅដើមជ្រៃយកដំបងពិសេសរបស់ខ្លួន។ ពេលនោះស្រីស្នំស្រែកយំកងរំពងនាំគ្នារតជាន់គ្នា ឯនាជនទាំងឡាយនាំគ្នារតពពាក់ពពួន។ គុភណ្ឌបានចេញទៅប្រយុទ្ធក្រៅក្រុងវិញ ឯគុភណ្ឌផ្សេងទៀតបានឃើញនាំគ្នាទៅយកអាវុធមកច្បាំជាមួយយក្ស ចំណែកពាជីវិញបានទៅច្បាំងជាមួយនិងយក្សច្រំជើងខាំនិងមាត់ ។ពួកពានរវិញពួកខ្លាឃ្មុំបានទៅព័ទ្ធវាយដែរ យក្សទ្រាំមិនបានក៏រតឡើងកំពូលភ្នំដកដើមសិលាក្រវាងទៅ។ ពួកគុភណ្ឌបានវាយយក្សត្រុវជើង ក្បាលខ្នង ទ្រូងយក្សបានធ្លាក់ពីលើភ្នំស្លាប់ទៅ។

សរុបមកអំពើអាក្រក់ឃោឃៅរបស់យក្សនន្ទិយក្ស បានទទួលអំពើដែលខ្លួនបានប្រព្រឹត្តវិញ អំពើល្អតែងយកឈ្នះអំពើអាក្រក់គ្រប់ពេលវេលា។

## ឃ.ឧត្តមគតិរឿងគំនិតដឹកនាំរឿងតម្លៃអប់រំ

ឧត្តមគតិរឿង គឺជាឧត្តមគតិរបស់អ្នកនិពន្ធ។ ឧត្តមគតិរឿងគឺយកកត្តាប្រធានវិស័យដែលបញ្ហាដែលបញ្ជាក់ពីគោលជំហរ សតិអារម្មណ៍របស់អ្នកនិពន្ធ ដែលស្តែងឡើងតាមរយៈសកម្មភាពរបស់តួអង្គ។

- បានអប់រំធ្វើឱ្យមនុស្សយើងមុននិងធ្វើការសម្រេចចិត្តធ្វើអ្វីមួយត្រូវរិះគិតពិចារណាឱ្យបានល្អិតល្អន់មុននិងធ្វើអ្វីមួយ

- បានអប់រំមនុស្សឱ្យចេះប្រើប្រាស់ប្រាស់ប្រាជ្ញា ក្នុងការដោះស្រាយបញ្ហាដូចសេះរបស់ស្តេចព្រះបាទព្រហ្មទត្ត បានប្រើប្រាជ្ញាជួយរំដោះខ្លួនដោយរួចពីមរណៈភ័យ ក្រោមកន្ទាប់ដៃនៃយក្

- អប់រំធ្វើឱ្យមនុស្សចេះប្រើប្រាស់យុទ្ធសាស្ត្រក្នុងការដោហស្រាយបញ្ហានៅចំពោះមុខដូចយក្សខន្ទីបប្រើល្បិចកលសម្លាប់មនុស្សនៅក្នុងនគរពារាណសី

- អប់រំកុំឱ្យយើងចង់បាននូវអ្វីដែលមិនមែនជារបស់ខ្លួននាំឱ្យវង្វេងដល់ខ្លួន ដូចព្រះបាទព្រហ្មទត្តចង់បានប្រោសមាសដោយមិនបានគិតពិចារណា ប្រោសនោះជាយក្សខន្ទីប្រែកាឡាសោះ នៅពេលព្រះបាទព្រហ្មទត្តរតតាមសេះ យក្សខន្ទីប្រែកាឡាជាយក្សចាប់ឆីព្រះអង្គទៅ។

សរុបសេចក្តីមកតាមរយៈស្នាដៃអក្សរសិល្ប៍ពុទ្ធនិយមក្លាយហ្លួសហេតុ ឬបញ្ញាសជាតកបានអប់រំធ្វើឱ្យមនុស្សគ្រប់រូបចេះដោហស្រាយនូវបញ្ហាដែលបានកើតឡើងនៅចំពោះមុខដោយចេះប្រើប្រាស់នូវប្រាជ្ញាញាណរបស់ខ្លួនគ្រប់ពេលវេលា ។

# ជំពូក ៥ វិភាគក្យាលើលិទ្ធិផលស្រាវជ្រាវ

## ៥.១ តម្លៃអប់រំនៃរឿងអក្សរសិល៍្បពុទ្ធនិយម

ដូចយើងដឹងហើយថា នៅក្នុងសម័យបច្ចុប្បន្ននេះ គឺជាសម័យដែលមនុស្សយកចិត្ត ទុកដាក់ទៅលើអក្សរសិល្បពុទ្ធនិយម ។ អក្សរសិល្ប៍ទ្ធនិយម បានផ្តល់តម្លៃអប់រំ ដ៏មានសារៈសំខាន់មហាសាល ដល់មនុស្សដែលរស់នៅលើភពផែនដី ។ តន្ទឹមនិងនេះ អក្សរសិល្ប៍ពុទ្ធនិយម បានទទួលរងនូវសម្លៀតពីសាសនាដ៏ទៃជាច្រើនសតវត្សមកហើយ។

ហេតុនេះ ទើបនាំឱ្យអ្នកអក្សរសិល្ប៍សម័យថ្មីបានចាប់ផ្តើមចាប់អារម្មណ៍សិក្សាពីតម្លៃអប់រំ នៅក្នុងស្នាដៃ អក្សរសិល្ប៍ពុទ្ធនិយម ដោយឈរលើទ្រឹស្តីនៃការវិភាគតម្លៃអប់រំ ដែលមានមូលដ្ឋានកើតចេញពី ចេតនាភ្ជាក់រឭកផ្តល់តម្លៃចំពោះអក្សរសិល្ប៍ពុទ្ធនិយមទៀតផង។ ក្នុងនោះអ្នកនិពន្ធបានបង្ហាញពីតម្លៃអប់រំចំពោះអក្សរសិល្ប៍ពុទ្ធនិយមដែលនិង មាននៅក្នុងលោកនេះ។

យោងតាមទ្រឹស្តីនៃការវិភាគអក្សរសិល្ប៍ពុទ្ធនិយម បានលើកយកទាក់ទងទៅនិងតម្លៃអប់រំនៃរឿងក្នុងស្នាដៃអក្សរសិល្ប៍ពុទ្ធនិយម។

- តម្លៃអប់រំពីសីលធម៌៖ អក្សរសិល្ប៍ពុទ្ធនិយមសង្កត់ធ្ងន់លើការប្រព្រឹត្តិធម៌តាមគោលការណ៍ដូចជា អរិយមគ្គ អរិយសច្ច និង សីលប្រាំ។ ការបង្រៀនទាំងនេះលើកតម្កើងតម្លៃដូចជា មេត្តា (ករុណា) សេចក្តីសប្បុរស (មេត្តា) និងសតិសម្បជញ្ញៈ ដែលផ្តល់នូវក្របខ័ណ្ឌសីលធម៌សម្រាប់ការអភិវឌ្ឍន៍ផ្ទាល់ខ្លួន និងទំនួលខុសត្រូវសង្គម។

- តម្លៃអប់រំឱ្យយើងចេះរក្សាស្រឡាញ់សន្តិភាព៖ ក្នុងទ្រឹស្តីព្រហពុទ្ធសាសនា អក្សរសិល្ប៍ពុទ្ធនិយមនៅពេលដែលមានទំនាស់បានកើតឡើង អ្នកនិពួបានដោះស្រាយដោយអហិង្សា ដើម្បីឱ្យពុទ្ធបរិសត្វរៀនសុត្រតាម។ ជាពិសេសអប់រំដល់មនុស្សឱ្យជៀសវាងក្នុងការប្រប្រត្តិដំពើមិនល្អគ្រប់បែបយ៉ាងដែលជាមាគ៌ានាំមនុស្សទៅរកសុភមង្គល។ រាល់ដំណោះស្រាយក្នុងអក្សរសិល៍ពុទ្ធនិយមសុត្តដោះស្រាយដោយអហិង្សាឬ ដោយសន្តិភាពនិងអំពើបាបឈ្លានពានគ្រប់បែបយ៉ាង ។ ឥទ្ធិពលនេះបានងប់រំឱ្យជនជាតិខ្មែរស្រឡាញ់សន្តិភាពគ្មានគំនិតឈ្លានពានអ្នកដ៏ទៃ។

- តម្លៃអប់រំការយល់ដឹងអំពីវប្បធម៌៖ ការសិក្សារឿងអក្សរសិល្ប៍ពុទ្ធនិយមជួយឱ្យបុគ្គលយល់អំពីបរិបទវប្បធម៌ដែលព្រះពុទ្ធសាសនាបានអភិវឌ្ឍ និងរីកចម្រើន។ នេះរួមបញ្ចូលទាំងការយល់ដឹងអំពីសិល្បៈ អក្សរសិល្ប៍ និងប្រពៃណីព្រះពុទ្ធសាសនាផ្សេងៗគ្នា ដែលជំរុញឱ្យមានការដឹងគុណចំពោះការអនុវត្តវប្បធម៌ចម្រុះ។

- តម្លៃអប់រំ ការយល់ឃើញខាងផ្លូវចិត្ត៖ តាមរយៈអក្សរសិល្ប៍ពុទ្ធនិយមជាច្រើនផ្តោតលើស្ថានភាពផ្លូវចិត្ត សេចក្តីសុខផ្លូវចិត្ត និងធម្មជាតិនៃទុក្ខ។ គោលគំនិតដូចជាសតិសម្បជញ្ញៈ និងសមាធិ បានទទួលការពេញនិយមនៅក្នុងចិត្តវិទ្យាសហសម័យ និងការអនុវត្តសុខភាព ដោយផ្តល់នូវឧបករណ៍ជាក់ស្តែងសម្រាប់ការកាត់បន្ថយភាពតានតឹង ការគ្រប់គ្រងអារម្មណ៍ និងការយល់ដឹងពីខ្លួនឯង។

- តម្លៃអប់រំពីបរិបទប្រវត្តិសាស្ត្រ៖ អក្សរសិល្ប៍ពុទ្ធនិយមបានផ្តល់នូវដំណើររឿងប្រវត្តិសាស្ត្រនៃការវិវត្តន៍នៃគំនិតរបស់មនុស្ស និងការអនុវត្តព្រះពុទ្ធសាសនាក្នុងរយៈពេលជាច្រើនសតវត្ស។ វាផ្តល់នូវការយល់ដឹងអំពីរបៀបដែលព្រះពុទ្ធសាសនាមានអន្តរកម្មជាមួយប្រព័ន្ធទស្សនវិជ្ជា ដែលរួមចំណែកដល់ការយល់ដឹងទូលំទូលាយអំពីប្រវត្តិសាស្ត្របញ្ញារបស់មនុស្ស។

- តម្លៃអប់រំចិត្តគំនិតមិនមានលោបលន់៖កាមយណ្ហាជារងើកភ្លើងផ្តល់នូវចំនងឱ្យចង់មាន ចង់បានដែលជាហេតុជាប្រភពនាំឱ្យវិនាសដល់ ទ្រព្យសម្បត្តិ អាយុជីវិត ឬក្រុមគ្រួសារដែលបានបង្ហាញឱ្យយើងឃើញតាមរយៈវណ្ណកម្មអ្នកនិពន្ធក្នុងអក្សរសិល្ប៍ពុទ្ធនិយមជាច្រើនហូហែរផងដែរ។

- តម្លៃអប់រំអក្សរសិល្ប៍ពុទ្ធនិយមជំនាញអន្តរបុគ្គល៖ ការសង្កត់ធ្ងន់លើការអាណិតអាសូរ ការយល់ចិត្ត និងការយល់ដឹងក្នុងអក្សរសិល្ប៍ពុទ្ធនិយមអាចបង្កើនជំនាញអន្តរបុគ្គល។ ការចូលរួមជាមួយអត្ថបទទាំងនេះលើកទឹកចិត្តអ្នកអានឱ្យបង្កើតទំនាក់ទំនងកាន់តែប្រសើរឡើងជាមួយអ្នកដទៃ និងអភិវឌ្ឍជំនាញដោះស្រាយជម្លោះ។

- តម្លៃអប់រំចេះធ្វើបុណ្យឱ្យទានៈ អក្សរសិល្ប៍ពុទ្ធនិយមជាច្រើនបានចំរុញឱ្យចេះជួយគ្នាទៅវិញទៅមក អ្នកក្រលំបាកកំសត់ទុគត៌ ស្មូមយាចរ និងអ្នកគ្មានទីពឹង។

- តម្លៃអប់រំមានចិត្តមេត្តាចេះចែករំលែកទានៈនៅក្នុងស្នាដៃអក្សរសិល្ប៍ពុទ្ធនិយមសុត្តសាជ និងពុទ្ធនិយមក្លាយ ជួយឱ្យមនុស្សមានព្រហ្មវិហារធម៌ចំពោះគ្នា ចេះចែករំលែកសេចក្តីសុខ ទ្រព្យសម្បត្តិដល់គ្នាឱ្យបានរស់នៅសុខស្រួលដូចគ្នានៅក្នុងសង្គមតាមរយៈមានរឿងហូរហែរជាច្រើន។

- តម្លៃអប់រំការរីកចម្រើនផ្ទាល់ខ្លួនៈ អត្ថបទអក្សរសិល្ប៍ពុទ្ធនិយមជាច្រើនបានជំរុញឱ្យមានការត្រិះរិះពិចារណា និងការរីកចម្រើនផ្ទាល់ខ្លួន។ ពួកគេជំរុញអ្នកអានឱ្យពិនិត្យមើលជំនឿ អាកប្បកិរិយា និងការលើកទឹកចិត្តរបស់ពួកគេនិង ជំរុញដំណើរឆ្ពោះទៅរកការកែលម្អខ្លួនឯង ។

- តម្លៃអប់រំកាយ វាចានិងចិត្តៈ លិទ្ធព្រះពុទ្ធសាសនា ក៏ដូចអក្សរសិល្ប៍ពុទ្ធនិយមដែរបណ្តុះទឹកចិត្តពុទ្ធសាសនិកឱ្យប្រព្រឹត្តអំពើល្អទាំងកាយវិចាចិត្ត។

- តម្លៃអប់រំការអនុវត្តសតិសម្បជញ្ញៈ៖ អក្សរសិល្ប៍ស្តីពីសមាធិ និងសតិសម្បជញ្ញៈ ផ្តល់នូវការណែនាំជាក់ស្តែងសម្រាប់ការអភិវឌ្ឍការអនុវត្តទាំងនេះ ដែលមានប្រយោជន៍សម្រាប់សុខភាពផ្លូវចិត្ត ការផ្តោតអារម្មណ៍ និងសុខុមាលភាពទូទៅ។

- តម្លៃអប់រំឱ្យជឿលើទស្សនៈកម្មផលៈ នៅក្នុងស្នាដៃអក្សរសិល្ប៍ពុទ្ធនិយមគ្រប់ស្នាដៃទាំងអស់ ចាប់ផ្តើមពីមុនដំបូងរហូតដល់ទីចុងបញ្ចប់បានបង្ហាញឱ្យយើងដឹងពីទស្សនៈកម្មផលគ្រប់សម័យកាល ពោលគឺ ធ្វើអំពើល្អទទួលបានមកវិញល្អ ប្រព្រឹត្តិធ្វើអំពើអាក្រក់បានផលអាក្រក់ កម្មទាំងនោះបានហុចផលឱ្យងក្នុងការប្រព្រឹត្តិមិនអាចជៀសផុតបានឡើយ វានិងហុចផលក្នុង អតិតជាតិ បច្ចុប្បន្នជាតិ និងងនាកតជាតិ។ មិនតែប៉ុនោះតម្លៃអប់រំក្នុងទស្សនៈព្រះពុទ្ធសាសនា បានអប់រំមនុស្សឱ្យប្រព្រឹត្តិ អំពើល្អជាកុសល ដើម្បីបានទៅកើតនៅក្នុងឋានសួគ៌ ឱ្យជៀសវាងប្រប្រត្តិរាល់អំពើអាក្រក់ ដើម្បីកុំឱ្យកើតក្នុងឋាននរក ប្រេតរងទុក្ខវេទនា គ្រប់បែបយ៉ាង ឱ្យមនុស្សចេះរក្សាសិលប្រាំចាំសិលប្រាំបី សមាធិភានាផងដែរ។

- រីឯនៅក្នុងតម្លៃអប់រំរឿងអក្សរសិល្ប៍ពុទ្ធនិយម វិញអ្នកនិពន្ធបានបង្ហាញតាមរយៈរឿងជាច្រើនដូចជាៈ

រឿង រតនប្បជោត នៅពេលដែលព្រះនាង សិរិរតនអាភា បានយល់សុបិនឃើញព្រះនាងទ្រង់ព្រះសុបិនថា មានបុរសម្នាក់ សប្បុរខ្មៅ ភ្នែកក្រហម ពាក់សំពត់ក្រហម ដៃកាន់អាវុធមុតថ្លា មកពីទិសខាងលិច ចូលដល់ ក្រឡាបន្ទំ ពុះទ្រូងរូងយកសាច់បេះដូង ហើយដើរចេញទៅទិសខាងលិចវិញពេលនោះព្រះនាងភិតភ័យយ៉ាងខ្លាំងបានទូលប្រាប់ព្រះរាជជា ព្រះរាជាបានហៅហោរា ដែលចេះទាយនិមិត្ត ហោរក្រាបទូលថាតាមព្រះសុបិននេះ មានទំនាយថា ព្រះករុណាជាម្ចាស់ជីវិតនឹងព្រះរាជទីពីរ នឹងព្រាត់ប្រាសគ្នាមហាមេឃនឹងបង្អុរភ្លៀងធ្លាក់ចុះមកលើផែនដី ដល់កំពស់ប្រាំពីរ ត្នោតលៃ។ ត្រង់នេះបានបញ្ជាក់ពអប់រំបញ្ជាក់ពីជំនឿជឿទៅលើការទស្សទាយន៍។

រឿងនៅក្នុងអក្សរសិល្ប៍ពុទ្ធនិយមក្លាយរឿងព្រះសុធនកុមារ នៅពេលព្រះបាទអាទិច្ចវង្ស បានយល់សុបិនឃើញពោះវៀនធំផ្លាយចេញអំពីព្រះឧទរទៅរុំព័ទ្ធ ទ្វិបព័ទ្ធបីជុំរួចត្រឡប់ចូលព្រះឧទរវិញ។ស្តេចសួរទៅព្រហ្មណ៍បុរោហិត ព្រហ្មណ៍ទូលថា ត្រូវធ្វើវិធីបូជាយញ្ញព្រះអង្គក៏ធ្វើតាម។ ត្រង់នេះបានអប់រំបញ្ជាក់ពីជំនឿជឿទៅលើការទស្សទាយន៍។

នៅក្នុងអក្សរសិល្ប៍ពុទ្ធនិយមក្លាយបញ្ញាសជាតករឿង រតនប្បជ្ជោត នៅពេលដែលព្រះនាង សិរិរតនអាភា បានយល់សុបិនឃើញព្រះនាងទ្រង់ព្រះសុបិនថា មានបុរសម្នាក់ សប្បុរខ្មៅ ភ្នែកក្រហម ពាក់សំពត់ក្រហម ដៃកាន់អាវុធមុតថ្លា មកពីទិសខាងលិច ចូលដល់ ក្រឡាបន្ទំ ពុះទ្រូងរូងយកសាច់បេះដូង ហើយដើរចេញទៅទិសខាងលិចវិញពេលនោះព្រះនាងភិតភ័យយ៉ាដខ្លាំងបានទូលប្រាប់ព្រះរាជជា ព្រះរាជាបានហៅហោរា ដែលចេះទាយនិមិត្ត ហោក្រាបទូលថាតាមព្រះសុបិននេះ មានទំនាយថា ព្រះករុណាជាម្ចាស់ជីវិតនឹងព្រះរាជទីពីរ នឹងព្រាត់ប្រាសគ្នាមហាមេឃនឹងបង្អុរភ្លៀងធ្លាក់ចុះមកលើផែនដី ដល់កំពស់ ប្រាំពីរត្នោតលៃ។ ត្រង់នេះបានបញ្ជាក់ពីរម្លៃអប់រំពីជំនឿជឿទៅលើការទស្សទាយន៍។

រឿងព្រះវេស្សន្តរក្នុងអក្សរសិល្ប៍ទសជាតកបានអប់រំការគោរពប្រពៃណី ការឡើងគ្រងរាជសម្បត្តិរបស់ស្តេចមានការរៀបចំគ្រឿងរណ្តាប់ផ្សេងៗដែរ មួយវិញទៀតនៅពេលព្រះវេស្សន្តរនិងព្រះនាងមេទ្រីបានរៀបភិសេកជាមួយគ្នាមាន ព្រះមាតា ព្រះបិតា ចាស់ទុំ ញាត្តិពង់ផៅទាំងឡាយបានចូលរួម មានការប្រគុំភ្លេងផងដែរ មិនត្រឹមតែអប់រំផ្តល់ទស្សនៈល្អនោះទេបានផ្សារភ្ជាប់ផ្សព្វផ្សាយនិង សង្គមវប្បធម៌ផងដែរ។

រឿងនាងបដាចាក៏បានបង្ហាញការអប់រំគោរពប្រពៃណីនៅរដូវបុណ្យចូលឆ្នាំ នាងបដាចានិងអ្នកបម្រើស្រីបានធ្វើចង្ហាន់ទៅប្រគេនព្រះសង្ឃនៅវត្ត និងចៅមានពក៏បានយកចង្ហាន់ទៅប្រគេនព្រះសង្ឃឧទ្ទិសមគ្គផលជូនឪពុក ម្តាយ ដែលបានចែកឋានទៅហើយទន្ទឹមនិងនេះផងដែរយើងឃើញនៅពេលសព្វថ្ងៃក៏បមានការគោរពប្រពៃណីនៅពេលដល់រដូវបុណ្យចូលឆ្នាំខ្មែរយើងតែងទៅធ្វើបុណ្យនៅទីវត្តអារាមទៀតផង។

រឿងព្រះសុធនុកុមារក៏បានបង្ហាញពីតម្លៃអប់រំឱ្យចេះស្រឡាញ់សិល្បៈៗបាញ់ធ្នូ ព្រះសុធនុកុមារចេងសិល្ប៍ល្បៈយ៉ាងស្ទាត់ជំនាញ់គ្មានអ្នកណាមានថ្វីដៃបៀបបានឡើយនៅពេលព្រះបាទសេតរាជបានរៀបចំកម្មវិធីប្រឡងបាញ់ធ្នូព្រះសុធនុកុមារបានចូលរួមបានប្រគួតឈ្នះមនុស្សផងទាំងពួងគ្មានអ្នកណាមានថ្វីដៃបៀបផ្ទឹមនិង ព្រះអង្គបានឡើយ។

រឿងហង្សយន្តបានបង្ហាញអប់រំពីសិល្បៈចំលាក់នៅពេលព្រះបាទអាទិត្យវង្សាបានប្រើជាងឱ្យធ្វើហង្សយន្តមួយជាងនោះក៏ធ្វើបានហង្សយន្តបានយ៉ាងល្អឯកអាចហោះហើរលើអាកាសបានព្រះសុវន្នកុមារបានជិះហង្សយន្តនោះទៅគ្រប់ទឹកន្លែងបានទាំងអស់។

រឿងព្រះសមុទ្ទឃោសបានអប់រំសិល្បៈគំនូនៅពេលព្រះនាងវិន្ទមតីបានព្រាតគ្នាព្រះសមុទ្ទឃោស ព្រះនាងបានកសាងសាលាឆទានផ្តត់ផ្គង់ភុជន ដល់ស្មូមយាចរ ង្នកសំសត់ទុគតឱ្យជាងគំនូរគូររឿងរ៉ាវដែលព្រះនាងបានបែកបាក់ពីព្រះស្វាមី។ ក្រោយមកព្រះកុមារបានទៅស្វែងរកព្រះនាងនៅសាលាឆទានបានឃើញគំនូរទាំងនោះហើយក្សត្រទាំងពីរក៏បានជួបជុំគ្នា។

រឿងវិធុរបណ្ឌិតបានអប់រំឱ្យចេះរក្សាសិល៍ នៅក្នុងអក្សរសិល្ប៍ពុទ្ធនិយម ព្រះរាជាធនញ្ជ័យ ទ្រង់បានធ្វើរក្សាសិល៍សមណធម៍ក្នុងរាជឧទ្យាន បានជួប ស្តេចនាគ វរុណ ស្តេចគ្រុឌ វិនតេយ្យ និងស្តេចទេវតា សក្កៈ ។ ពេលនោះស្តេចទាំងបួនសរសើរអំពីសិលរបស់ខ្លួនរៀងៗខ្លួនរហូត កើតវិវាទ ទៅរកវិធុរបណ្ឌិតឱ្យកាត់សេចក្តី វិធុរថា “គ្មានសីលព្រះអង្គណាល្អជាងសីលព្រះអង្គណាឡើយ សីលរបស់ ព្រះអង្គគឺសុទ្ធតែប្រសើរទាំងអស់ព្រោះទាល់តែលះបង់កិលេស បានដូចគ្នាទើបរក្សាសីលកើត” ។ វិនិច្ឆ័យដូច្នេះក៏សម្តែងធម៍ទេសនា ស្តេចទាំងបួនត្រេកអរក ក៏បានបូជាវត្ថុមានតម្លៃផ្សេងៗ ដល់វិធុរ ព្រះឥន្ទ្របូជាសំពត់ទិព្វទុកុលព័ស្ត្រ ស្តេច គ្រុឌបូជាដោយព្រះសុវណ្ណមាលា ស្តេចនាគបូជានូវកែវមុណី និង ព្រះបាទធនញ្ជ័យបូជាដោយគោមួយពាន់ ហើយស្តេចទាំងបួនក៏ លាទៅរាជនិវេសន៍ទីទៃៗរៀងខ្លួន។

រឿង សិរិធរ បានអបរំឱ្យចេះធ្វើបុណ្យទាន នៅពេល ព្រះបច្ចេកពុទ្ធ បានដើរបិណ្ឌបាត្រមហាសេដ្ឋីបានដាក់បាត្រដោយសទ្ធាជ្រះថ្លា ហើយបានកើតអាហារទិព្វ ហូបស្កប់ស្កល់ ចែករំលែកដល់អ្នកផងទាំងពួង បានបរិភោគឆ្អែតគ្រប់គ្នា ជនទាំងឡាយបានមកជួបជុំជាច្រើននៅផ្ទះសេដ្ឋី ហើយនាំគ្នា ពោលសរសើរភ័ព្វសំណាងនឹងផលទានរបស់សេដ្ឋីៗ បានសំដែងផលានិសង្សនៃទានដូច្នេះថា :“អ្នកទាំងឡាយចូរមើលលទ្ធផលការបរិច្ចាគទានដោយសទ្ធាបាយរមែងឱ្យបានសម្រេចសេចក្តីប្រាថ្នាទាំងពួងទាំងក្នុងបរលោកនិងក្នុងលោកិយ“ឱ្យទានបាយជាទាននាំមកនូវលទ្ធផល គឺ អាយុ វណ្ណៈ សុខៈ ពលៈ មានយស ឱ្យមានកិត្តិស័ព្ទ នឹងបរិភោណទាំងក្នុងលោកិយ ទាំងក្នុងបរលោក ។ “ដោយហេតុនេះ អ្នកមានប្រាជ្ញា កាលបើឃើញច្បាស់នូវសារប្រយោជ របស់ខ្លួន បរិច្ចារមាន មិនគប្បីលុះដោយសេចក្តីកំណាញ់ ដ្បិតសេចក្តី កំណាញ់ជាកំហុសមួយ ដែលយើងត្រូវលះបង់ចេញឱ្យដាច់ខាត។

រឿង តេមិយ បានអប់រំរក្សាសិល៍ធ្វើបុណ្យទាន នៅពេលព្រះតេមិយកុមារបានសាងព្រះផ្នួសក្នុងព្រៃ ព្រះមាតា បិតា ក្រោយពីបានស្តាប់ការទូន្មាន អំពីការប្រព្រឹត្តនូវព្រហ្មចរិយធម៍ដើម្បីបានសេចក្តីសុខ។ កាលនោះព្រះបាទកាសិករាជ និងព្រះនាងចន្ទទេវី ទាំងមួយម៉ឺនប្រាំមួយពាន់ រួមទាំងបរិវារសព្វព្រះទ័យនឹងសាងព្រះផ្នួស ទើបទ្រង់ឱ្យចំហទ្វារឃ្លាំងទាំងអស់និងទ្វារផ្សារ ហើយទៅកសាង បុណ្យកុសលនៅពេញអាសនៈដែលព្រះឥន្ទ្រនិម្មិតថ្វាយ បានសម្រេចនូវសមាបត្តិប្រាំបី និងអភិញ្ញាប្រាំទាំង អស់គ្នា ។ ចំណែកពួកសាមន្តរាជទាំងឡាយ

ដែលមកប្រជែងយក រាជសម្បត្តិនៅក្នុងនគរពារាណសីក៏ប្រែព្រះទ័យសាងព្រះផ្នួសទាំងអស់ ហើយបានសម្រេចនូវសមាបត្តិដូចៗគ្នា ។

រឿងសុវន្ណសាម បានបង្ហាញតម្លៃអបរំ ឱ្យមានថម៌កតញ្ញូចំពោះអ្នកមានគុណ នៅពេលដែលឥសី ប្តី ប្រពន្ធបានត្រូវពស់ចឹកខ្វាក់ភ្នែកទាំងពីរ ។ សុវណ្ណសាមបានមានចិត្តអាណិតអាសូរ អ្នកទាំងពីរជាខ្លាំង បានខិតខំបម្រើព្រឹកល្ងាចយប់ថ្ងៃគ្រប់បែបយ៉ាង មានទាំងបោកសម្លៀកបំពាក់ ទឹកក្តៅ ត្រជាក់ ភោគជនាអាហារ គុគច្របាច់គ្រប់បែបយ៉ាងមិនឱ្យអ្នកទាំងពីរមានប៉ងឡើយ។

រឿង សិរីវិបុលកិត្តិ បានអប់រំឱ្យមានធម៌កតញ្ញូចំពោះអ្នកមានគុណ នៅពេលសិរីវិបុលកិត្តិ បានមកដល់វាំងជួបស្តេចអធម៌ព្រាប់ឱ្យស្តេចដោះលែង បិតារបស់ខ្លួនៗជាអ្នកទទូលទោសជំនួសបិតា ទោះព្រះអង្គសម្លាប់ៗទុលបង្គំចុះ។ ស្តេចអធម៌ក៏ព្រមបានឱ្យគេចាប់ចងដោយចនងប្រាំប្រការ រួចឱ្យពេជ្ឈឃាតចាប់ចង យកទៅពិឃាតដោយធម៌កតញ្ញូកតទេទីថែរក្សាព្រះរាជកុមារ ដាវលំពែងរបស់ពេជ្ឈឃាតបាកបែកវិនាសអន្រាយ ស្តេចអធម៏យកដំរីព្រិចទៅសម្លាប់ទៀតក៏ពុំហានដែរ បោះចូលរំដៅល្ងើកភ្លើងក៏មិនមានអន្រាដែរ ។ មួយវិញទៀតនោពេលព្រះមាតាបានចូលទិវង្គត់ព្រះកុមារមានធម៌កតញ្ញូចំពោះមាតា បានសុំបិតាទៅស្លាប់ជាមួយព្រះមាតា ព្រះបិតាយត់យ៉ាងណាព្រះកុមារមិនស្តាប់បានចូលទៅគេងក្រោមមឈូមាសព្រះមាតា ឱ្យគេបូជាភ្លើងព្រះអគ្គីមិនហានប៉ះពាល់ដល់ព្រះកុមារឡើយ សពព្រះមាតាព្រះអគ្គិរំលាយលុះត្រាតែអស់ រាងកាយព្រះកុមារឡើងពណ៌ក្រហមដូចមាស ដោយធម៌កតញ្ញូមិនមានអ្វីកើតឡើងដល់ព្រះរាជកុមារឡើយ។

រឿងរនប្បផ្តោត បានងប់រំឱ្យមានកយញ្ញូចំពោះអ្នកមានគុណ នៅពេលព្រះមាតានាមសិរិតនាភាត្រូវយក្សចាប់ខ្លួនព្រះកុមារបានចេញតាមរកគ្រប់ទីកន្លែងបានប្រកូប្រកាស ស្រែកហៅដើរជិតដល់ដើមជ្រៃព្រះនាងក៏ឆ្លយតប ព្រះកុមារបានឃើញមាតានៅក្រោមដើព្រៃ ។ ប្រះរាជកុមារបាននិយាយជាមួយយក្ស សូមអ្នកដោះលែងម្តាយខ្ញុំទៅបើអ្នកត្រូវការសាច់ឈាមជាអាហារបរិភោគខ្ញុំទៅយក្សក៏យល់ព្រម ។ ព្រះរាជកុមារបានពុះទ្រូងរូងយកបេះដូងដាក់លើដៃយក្សហើយក៏ស្លាប់ទៅដោយធម៌កតញ្ញូព្រះឥន្ទបានគំរាមយក្សនិងសម្លាបបើមិនឱ្យព្រះកុមារដឹងខ្លួនវិញ យក្សបានធ្វើឱ្យព្រះរាជកុមារបានដឹងខ្លួនឡើងវិញដោយធម៌កតញ្ញូ។

រឿងក្រុងសុភមិត្របានអប់រំឱ្យមានសិលធម៌ នៅពេលព្រះបាតសុភមិត្របានចាកចេញពីនគរ បានលះបងរាជសម្បត្តិឱ្យក្រុងអសុផមិត្រសោយរាជ។ ព្រះអង្គបានលាព្រះមហេសីទៅនៅក្នុងព្រៃ ដោយទុកបុត្រទាំងពីរនិងព្រះនាងឱ្យនៅក្នុងរាជវាំង ។ ព្រះនាងបានឮព្រះស្វាមីពោលដូច្នោះព្រះនាងសុំទៅជាមួយដែរ រួមទាំងពុត្រាទាំងពីរ ទោះព្រះបាទសុភមិត្រទីព្រៃលំបាកក្តីព្រះនាងស៊ូពារកូនទាំងពីរតាមព្រះអង្គប្រះបាទសុភមិត្រក៏យល់ព្រមឱ្យទៅជាមួយ។

រឿងវិបុលកិត្ត នៅពេលស្តេចអធម៌បានមកដណ្តើមរាជ ប្រះបាទវិបុលកិត្តិមិនតបតឡើយ បាននាំមហេសីចេញទៅរស់នៅក្នុងព្រៃ។ពេលព្រានព្រៃវង្វេងផ្លូវបានជួយយកអាសរឱ្យបាយទឹកស្នាក់នៅប្រាពីរថ្ងៃបាននាំចេញពីព្រៃវិញ។ ក្រោយមកព្រានព្រៃមានចិត្តលោបលន់ម្តងទៀតបានប្រាប់ស្តេចអធម៌ពីកន្លែងព្រះបាទវិបុលកិត្តស្នាកនៅ ។ព្រានព្រៃបាននាំទ័ពទៅចាប់ព្រះបាទវិបុលកិត្តៗចេញមកដោយអង់អាចក្លានហានពុំមានប្រទូសរាយឬខឹងពួកគេឡើយ។

រឿងមហាវេសន្តរជាតក បានអប់រំឱ្យមានគុណធម៌ នៅពេលព្រះវេសន្តរបានប្រទានដំរីបច្ច័យនាគេន្ទ្រទៅអ្នកស្រុកកលិង្គរាស្ត្រ ។ ពេកនោះហើយនាឱ្យអ្នកស្រុកស្រីពិរាស្ត្របះបោរឡើង ហើយទៅទូលព្រះបាទស្រីសញ្ជ័យឱ្យបំបរបង់ព្រះវេសន្តរចេញពីនគរទៅភ្នំឡិតីវង្គត បានបំពេញតួនាទីជាបុត្រល្អ កុំឱ្យមានជម្លោះជាមួយអ្នកស្រុក ព្រះអង្គមានអំណាចក៏មិនបានប្រើដាក់រាស្ត្ររបស់ត្រង់ដែរ មិនខឹងប្រទូសរាយនិងនាំឱ្យអ្នកស្រុកខឹងក្តៅក្រហាយនោះដែរ។

រឿងសុវណ្ណសាម បានអប់រំស្មារតីសន្តិភាព នៅពេលដែលសុវណ្ណសាមបានត្រូវព្រួញព្រះបាទបិលយក្សដូលស្តូកស្ទឹងនៅក្បែរស្ទឹងមិគសម្មតា ។មិនបានខឹងនិងយក្សបានពោលដោយវិចាផ្អែមល្ហែមទៅវិញ លោកណាអើយចាញខ្ញុំកំពុងដងទឹក ..។ទាំងកាយវិចាចិត្តក៏មិនមានតបតទៅព្រះបាតបិលយក្ស ធ្វើឱ្យព្រះនាងទេវតាពហុសុន្ទរី និង មាតា បិតាធ្វើឱ្យសុវណ្ណសាមរស់ដឹងខ្លួនមកវិញ។

រឿងមរណៈមាតាបានអប់រំ ពុទ្ធិនិងស្មារតី នៅពេលនាងកុលកែសីបានចេញពីផ្ទះ បានជួបចោរនាងបានរកវិធីដោះស្រាយ ដោយមេស្រុកជាអ្នកមានអំណាចជាងគេនៅទីនោះ ជីវិតទាំងពីរនាក់ស្លាប់រស់ស្ថិតលើមេស្រុក ។ លុហកិច្ចរួចហើយ នាងបានជូនចិញ្ចៀនមេស្រុក និងសុំធ្វើជាឪពុកធម៌។ នាក់ទាំងពីរបានរស់នៅជាមួយមេស្រុក នាងមានគំនិតឆ្លាតបាន គិតរកកន្លែរកស៊ីលក់ដូរនាងលួចមើលតម្រិះគេរកស៊ីជួញដូ ។ក្រោយមកនាងបានរកស៊ីខ្លួនឯងបានជួញដូររហូតក្លាយជាសេដ្ឋី។

## ៥.២ តម្លៃអប់រំចរិយាសាស្រ្ត

អក្សរសិល្ប៍ពុទ្ធនិយម នាសម័យកណ្តាលបានអប់រំសំខាន់នៅក្នុងការក្រិត គូសវង់នូវការប្រព្រឹត្តរបស់ មនុស្សឱ្យដើរតាមផ្លូវមួយដ៏ល្អ ក្លាយជាពលរដ្ឋប្រពៃសម្រាប់សង្គមជាតិ។ ភាពចម្រុះពណ៌នៃការអប់រំទៅលើសីលធម៌ របស់មនុស្សនេះហើយបានធ្វើឱ្យអក្សរសិល្ប៍ពុទ្ធនិយមនេះបានបន្តអត្ថិភាពមកបច្ចុប្បន្នយើងនេះផងដែរ។ ជាការពិតណាស់ការរស់នៅក្នុងសង្គមមិនសំងំយកតែសុខបានតែម្នាក់ឯងឡើយ ពោលគឺយើងត្រូវពឹងពាក់ ជួយគ្នាទៅវិញទៅមកទើបយើងអាចរស់នៅប្រកបដោយក្តីសុខ តម្លៃអប់រំអក្សរសិល្ប៍ពុទ្ធនិយមក្រោយសម័យអង្គរអាចឱ្យមនុស្សចេះគោរពសិទ្ធគ្នាទៅវិញទៅមកចេះជួយគ្នា គ្រាប់ស្ថានការណ៍ ។ ការឈានចូលមកដល់របស់អក្សរសិល្ប៍ពុទ្ធនិយមនេះ ជួយឱ្យមនុស្សបានបន្ធូរអារម្មណ៍ ធ្វើឱ្យមនុស្សរសាយនូវកង្វល់ទាំងឡាយដែលញាំញីដោយវិបត្តិសង្គម។ ពិតណាស់ថាអក្សរសិល្ប៍ ពុទ្ធនិយមបានបណ្តុះនូវទស្សនៈគំនិតឱ្យជឿលើពុទ្ធសាសនាក្តី តែរឿងពុទ្ធនិយមបានចូលរួមចំណែកដ៏សំខាន់ក្នុង កិច្ចការអប់រំចរិយាសាស្រ្ត សីលធម៌ គុណធម៌របស់មនុស្សនាគ្រប់សម័យ។ ត្រង់នេះពុទ្ធសាសនាហាក់បីដូចជារាំងននមួយ តែបើយើងបើករាំងននោះចេញយើងនឹងឃើញតម្លៃទស្សនវិជ្ជាដ៏ច្រើនសម្បូរបែបសម្រាប់អប់រំមនុស្សដូចជាបញ្ហាការ ឆ្ពោះទៅរកសន្តិភាពជាដើម ។ អក្សរសិល្ប៍ពុទ្ធនិយមបានអប់រំឱ្យមនុស្សឱ្យចេះគោរពទនៀមតម្លាប់ប្រពៃណីដ៏ល្អផូផងរបស់ជាតិខ្មែរផងដែរ។

អក្សរសិល្ប៍ពុទ្ធនិយមក៏បានបង្កប់តម្លៃងប់រំនិងបង្ហាញពីលក្ខណៈជាតិដ៏ច្រើនសម្បូរបែប មានដូចជាជំនឿ ទំនៀមទម្លាប់ ប្រពៃណីរបស់ក្សត្រ របស់អ្នកស្រុកឱ្យចេះគោរពព្រះពុទ្ធសាសនា ចេះធ្វើបុណ្យធ្វើទាន សាងអំពើល្អជាកុសល ដើម្បីបច្ចុប្បន្នជាតិនិង អនាគត់ជាតិ គេជឿថាទស្សនៈកម្មផលនៅក្នុងលិទ្ធិព្រះពុទ្ធសាសនាពិតជាមានមែន អ្នកដែលបានប្រព្រឹត្តនូវអំពើល្អនិងទទួលបានផលល្អជាក់ពិតប្រាកដមែន។ ការចេះគោរពចំពោះអ្នកមានគុណ មាតា បិតា លោកគ្រូ អ្នកគ្រូ ចាសទុំរៀមច្បងពេលជួបគ្នាដោយលើកដៃជំរាបសួរសុខទុកគ្នាទៅវិញទៅមក។

ការស្លៀកពាក់តាមបែបប្រពៃណីរបស់ដូនតាខ្មែរដែលលោកបានបន្សល់ទុកឱ្យ សមរម្យថ្លៃថ្នូសុភាពរាបសារគ្រប់ពេលវេលា ទាំងនេះបានបង្ហាញឱ្យយើងឃើញពីវប្បធម៌ អរិយធម៌របស់ខ្មែរយើង តាមរយៈស្នាដៃរឿងអក្សរសិល្ប៍។

ជាស្នាដៃដ៏ល្អរបស់ អ្នកប្រាជ្ញ បណ្ឌិត កវីជំនាន់មុន។ មិនត្រឹមតែប៉ុណ្ណោះ វាបានលើកតម្លៃអក្សរសាស្ត្រជាតិ ជាជាងទៅចម្លងរឿងពីបរទេសមកនាំឱ្យគេមាក់ងាយនិងតិះដៀលគំនិតរបស់ជនជាតិយើងទៀតផង។

ដូច្នោះ ខាងក្រោមនេះគឺជាលិទ្ធផលដែលបានបង្ហាញពី តម្លៃអប់រំអក្សរសិល្ប៍ពុទ្ធនិយមក្រោយសម័យអង្គរនិងលក្ខណៈនៃការបង្កើតតាមរយៈរឿងក្នុងស្នាដៃអក្សរសិល្ប៍ពុទ្ធនិយមក្នុងលក្ខតម្លៃអប់រំអក្សរសិល្ប៍ពុទ្ធនិយម។

## ៥.២.តម្លៃអប់រំចរិយាសាស្រ្ត

តាមរយៈរឿងអក្សរសិល្ប៍ពុទ្ធនិយមអ្នកនិពន្ធបានយកតម្លៃអប់រំទូន្មានដ៏មានសារៈសំខាន់ នៅក្នុងការរស់នៅប្រចាំថ្ងៃរបស់មនុស្ស តែងមានការរួមរស់នៅជាមួយគ្នាមានប្រាស្រ័យទាក់ទងគ្នា មិនជនជាតិណា ៗនោះទេ តែងមានសិលធម៌ជាមួយគ្នាជានិច្ច។ ពេលជួបគ្នាមានការគោរពទៅតាមទនៀមទំលាប់របស់ពួកគេរៀងៗខ្លួន ។ ខ្មែរយើងនៅពេលជួប

គ្នាតែងលើកដៃជំរាបសួរសំពះគោរពតាមវ័យ តាំឋានៈ ចេះអោនលំទោន ចេះជួយគ្នា រស់នៅចេះយោគយល់អធ្យាស្រ័យគ្នា ចេះស្គាល់បុណ្យបាបនិង ល្អអាក្រក់ផងដែរ។

- តម្លៃអប់រំសិលធម៌៖ អក្សរសិល្ប៍ពុទ្ធនិយជួយឱ្យមនុស្សបានដើរតាមផ្លូវមួយដ៏ល្អ ជៀសវាងប្រព្រឹត្តិអំពើអាក្រក់ដែលបណ្តាលឱ្យប៉ះពាល់ដល់មនុស្សដែលបានរស់នៅក្បែងខ្លួន មិនតែប៉ុណ្ណោះបានជួយដល់សង្គមជាតិ ។ ភាពសមបូររបែបរបស់មនុស្សគ្រាប់រូប នៃការអប់រំនេហហើយបានធ្វើឱ្យអក្សរសិល្ប៍មានការរីកចម្រើនកាន់តែខ្លាំងបានបន្តឱ្យយើងឃើញរហូតមកដល់បច្ចុប្បន្នផងដែរ។ យើងរស់នៅសព្វថ្ងៃត្រូវចេះជួយគ្នាទៅវិញទៅមកនៅពេលដែលមានអ្នកជួបតុកលំបាកគ្រប់បែបយ៉ាង ដល់ជនក្រីក្រគោកយ៉ាក អ្នកគ្មានទីពឹង ជួយជាសមភារៈ សម្លៀកបំពាក់ គ្រឿងឧបភោគបរិភោគ លុយកាក់ជួយសម្រាលបន្ទុកពួកគាត់។ បានជួយឱ្យយើងមានសិល៍ធម៌ចំពោះខ្លួនឯង សំដៅលើការចេះយល់ដឹងពីការប្រព្រឹត្តិអំពើផ្សេងៗឱ្យយើងស្គាល់ពីការខុសត្រូវ ស្គាល់ល្អអាក្រក់ មិននិយាយញុះញង់ធ្វើឱ្យគេមានទុក្ខដោយសារខ្លួននោះទេនិង ឱ្យចេះរាប់អានមនុស្សល្អ ។មួយវិញទៀតនៅពេលមានមនុស្សបានប្រប្រត្តិនូវអំពើមិនល្អមកលើខ្លួនយើងតែងចេះអត់អោនឱ្យគ្នាមិនចងគំនុំព្យាបាតគ្នានាំឱ្យមានកម្មពៀរ អ្នកដែលបានប្រព្រឹត្តិខុសបានដឹងនូវកំហុសខ្លួនឯង ជាការភ្ញាក់រលឹកដ៏ល្អបំផុតដែលបុគ្គលគ្រប់រូបបានធ្វើ។ ពេលយើងស្ថិតក្នុងពេលយុវវ័យមុននិងប្រប្រឹត្តិរឿងអ្វីមួយត្រូវគិតឱ្យបានវែងឆ្ងាយពីព្រោះពេលយើងនៅក្មេងមានគួរសង្ស័បានប្រព្រឹត្តិនូវអ្វីដែលខុសប្រពៃណីនាំជួបរឿងមិនល្អយើងត្រូវធ្វើជាមនុស្សល្អជួយដល់សង្គមជាតិ។

- តម្លៃអប់រំសិលធម៌យុវជនឱ្យចេះយោគ្លលព់គ្នាស្គាលក់តម្លៃសន្តិភាព ស្គាល់ផ្លូវនៃជីវិតផ្លូវលោកផ្លូវធម៌

ចេះស្គាល់បុណ្យបាប ល្អអាក្រក់

- អប់រំមនុស្សឱ្យចេះរៀនរស់នៅសុខដុមរម្យនាជាមួយអ្នកដ៏ទៃនៅក្នុងសង្គមមនុស្សមានការអភិវឌ្ឍន៍ពីគ្រប់វិស័យទាំងផ្នែកស្មារតិនិងសម្ភារៈចេះបង្កើតវត្ថុថ្មីៗ

- អប់រំឱ្យចេះបំពេញ នូវទួនាទី ស្គាល់គោរពខ្លួនឯង អ្នកដ៏ទៃ ស្គាល់តម្លៃសិទ្ធិ សិទ្ធិសេរីភាពជាមូលដ្ឋាន ស្គាល់ពិធីរភាពពិត និងការវិវត្តនៅក្នុងសង្គមនីៗមួយ

- តម្លៃអប់រំគុណធម៌ បានជួយឱ្យមនុស្សមានការចេះដឹង ក្នុងការរស់នៅប្រចាំថ្ងៃដោយមានការប្រាស្រយ័ទាក់ទងគ្នា និងចេះជួយគ្នា ។ក៏បានអប់រំឱ្យមនុស្សចេះជួយគ្នាដែលយើងបានឃើញនៅក្នុងរឿងអក្សរសិល្ប៍ និងបានចង្អាញឱ្យយើងឃើញនៅពេលបច្ចុប្បន្ននៅក្នុងសង្គមខ្មែរជាក់ស្តែង នោពេលមានគ្រោះធម្មជាតិបានកើតឡើងមកដល់ប្រជាជនតែងមានការជួយឧបត្ថម សប្បុរសជននានា នៅក្នុងប្រទេសកម្ពុជា។

ដូចនេះ យោងតាមរយៈការបង្ហាញលិទ្ធផលខាងលើ បានបញ្ជាក់ថា នៅក្នុងស្នាដៃអក្សរសិល្ប៍ពុទ្ធនិយមខ្មែរ បានអប់រំមួយក្នុងការបង្ហាញ ឱ្យឃើញពីតម្លៃអប់រំរបស់មនុស្ស ឱ្យចេះរៀនរស់នៅមានការគោរពគ្នាទៅវិញទៅមក ការចេះជួយគ្នាគ្រប់គ្រាលំបាក ចេះអធ្យាស្រ័យ និងមនុស្សទាំងអស់។ តម្លៃអប់រំអក្សរសិល្ប៍មិនអាចបែងចេញពីមនុស្សមិនឱ្យមានគំនិតធ្វើតាមនោះការអប់រំរបស់អក្សរសិល្ប៍ផ្សារភ្ជាប់ជាមួយមនុស្ស ៗដើរតាមកែប្រែក្លាយខ្លួនជាអ្នកមានតម្លៃក្នុងសង្គម។

## ៥.៣.តម្លៃអប់រំពុទ្ធិសោភ័ណជីវិត

នៅក្នុងស្នាដៃរឿងអក្សរសិល្ប៍ពុទ្ធនិយម អ្នកនិពន្ធបានប្រើការអប់រំដល់មនុស្សទូទៅ ឱ្យចេះប្រើប្រាស់ ពុទ្ធិដឹកនាំជីវិតក្នុងការរស់នៅប្រចាំថ្ងៃប្រកបដោយភាពចម្រុងចម្រើន ដោយមានប្រជ្ញាការស្វាធ្យាយ ខិតខំបង្កើតនូវជំនាញមួយបិតប្រាកដក្នុងការរកស៊ីចិញ្ចឹមជីវិត ដោយភាពស្មោះត្រង់មិនមានចិត្តលោបលន់ និងប្តព្រឹត្តិអំពើអាក្រក់ឡើយ។ ស្នាដៃអក្សរសិល្ប៍បុទពុនិយមជួយឱ្យមនុស្សមានស្មារតីស្មោះត្រង់តស៊ូក្នុងដំណើរជីវិត គ្រប់កាលៈទេសៈ ។ អក្សរសិល្បទាំងនោះបានដក់ជាប់ក្នុងក្រអៅបេះដូងកូនខ្មែរគ្រប់រូបនិង គ្រប់ស្រទាប់វណ្ណៈឱ្យទទួលបានសោភ័ណ្ឌជីវិតពិតប្រាកដ។ អប់រំឱ្យស្រឡាញ់សោភ័ណ្ឌជីវិតនាំឱ្យមានការតស៊ូរាល់ការលំបាកក្នុងការរស់នៅក្នុងជីវិតប្រចាំថ្ងៃរបស់មនុស្ស ចេះរួមរស់នៅក្នុងសង្គម។ ប្រទេសខ្មែរមានទឹកដីសម្បូរបែបមានសម្បត្តិនានាមិនចេះខ្វះមានតាំងពីសម័យបុរាណយូលង់ណាស់មកហើយ កូនចៅគ្រប់ជំនាន់តែងថែរក្សាជារៀងរហូតដល់សព្វថ្ងៃនេះ។

- តម្លៃអប់រំសោភ័ណ្ឌចិត្តកាយក្នុងការគោរពសាសនា តាមការវិភាគទិន្នន័យស្រាវជ្រាវខាងលើ បានបង្ហាញថា នៅក្នុងស្នាដៃអក្សរសិល្ប៍ពុទ្ធនិយមខ្មែរ អ្នកនិពន្ធបង្កើតកាអប់រំសោភ័ណ្ឌចិត្ត ដើរតាមមាគ៌ាដ៏ត្រឹមត្រូវតាមសាសនា ធ្វើឱ្យមនុស្សរស់នៅប្រកបដោយចិត្តជ្រះថ្លាក្នុងការសន្សំបុណ្យកុសល បានជួយដល់អ្នកដែលមានការខ្វះខាត ទាំងផ្នែកសំភារៈ ជួបទុកលំបាកអត់ឃ្លាន ជួយដោយការពេញចិត្ត ក្នុងនាមជាមនុស្សជាតិ ប្រព្រឹត្តិអំពើសុចរិតត្រឹមត្រូវនៅពេលប្រកបការងាររកស៊ីប្រចាំថ្ងៃ តាមសម្មាអាជីវោ មិនមានចិត្តចង់បាននូវអ្វីដែលមិនមែនជារបស់ខ្លួន ជីវិតរស់នៅប្រកបដោយចិត្តស្ងប់សុខ ។ មួយវិញទៀតសោភ័ណ្ឌចិត្តកាយបានជួយឱ្យមានសន្ទាជ្រះថ្លា ក្នុងការចេះរក្សាសិលប្រាំ ចាំសិលប្រាំបី ជឿជាក់ក្នុងព្រះពុទ្ធសាសនាកាន់សិលភាវនា និងជីវិតបានលះបង់កិលេសតណ្ហា អបាយមុខទាំងបី ល្បែង ស្រី ស្រាជាដើម។ ជីវិតរស់នៅដោយមិនមានចិត្តច្រណែនឈ្នានីសទៅលើបុគ្គលណាមួយ ជីវិតរស់នៅភ្លឺស្វាងនិង គ្មានសត្រូវណាមកបៀតបៀននោះទេ។ បន្ទាប់មកបន្ទាលឱ្យមានចិត្តជួយកសាងដល់ទីវត្តអារាមជាកន្លែងសន្សំនូវបុណ្យកុសល ដែលមនុស្សទាំងឡាយតែងគោរពប្រត្តិបត្តិនិងធ្វើឱ្យជីវិតរីករាយក្នុងព្រះពុទ្ធសាសនា។

- សោភ័ណ្ឌទឹកដីព្រៃព្រឹក្សា បានជួយដល់ជីវិតគ្រប់បែបយ៉ាងនៅលើភពផែនដី ក្នុងការរសនៅរបស់មនុស្សលោកទាំងមូល មនុស្សមានចិត្តសប្បាយរីករាយបានបានកើតមករស់នៅលើភពផែនដី ដែលបានផ្តល់នូវអ្វីៗគ្រប់យ៉ាងមានទាំងសត្វ ៗបានជួយសម្រួលឱ្យជីវិតមនុស្សរស់នៅបានផ្តល់ម្ហូបអាហារ ទ្រទ្រង់ជីវិត ។ មិនតែប៉ុណ្ណោះធម្មជាតិបានជួយផ្តល់ឱ្យមានសោភណ្ឌជីវិតស្រស់បំព្រង ការទស្សនាកំសាន្តអារម្មណ៍ ជាគ្រឿងឧភោគបរិភោគនិងផ្តល់ឱ្យមានសុខភាពល្អថែមទៀតផង។

- ពុទ្ធិសោភ័ណ្ឌ បានជួយឱ្យយើងមាននូវចំណេះប្រាជ្ញា អាចដោះស្រាយបញ្ហានៅចំពោះមុខបាន និងមានគំនិតអាចបង្កើតនូវអ្វីដែលថ្មីបំពេញតម្រូវការផ្នែកសម្ភារៈ ទំនើបៗមិនចេះខ្វះនិងធ្វើឱ្យសប្បាយចិត្តក្នុងការកើនប្រាជ្ញាថ្មីមិនចេះមិនចេះហើយនោហដែរ។

យោងតាមការបង្ហាញលទ្ធផលខាងលើនេះបានបញ្ជាក់ថាវណ្ណកម្មរឿអក្សរសិល្ប៍ពុទ្ធនិយមអ្នកនិពន្ធបានយកតម្លៃងប់រំអក្សរសិល៍ បៀបធៀបនិងអ្វីមួយនូវក្នុងស្នាដៃរឿងអក្សរសិលដើម្បីជួយដល់មនុស្សស្ថិតក្នុងបរិបទក្នុងសង្គមណាមួយឱ្យចេះអនុវត្តន៍និងរស់នៅក្នុងសោភ័ណ្ឌជីវិត ដោយផ្តល់ស្នាមញញឹម មានមនោសញ្ចេតនាដែលបុគ្គលគ្រប់រូបបានជុបប្រះលើវិថីជីវិត នាំឱ្យមនុស្សស្គាល់ភាបផ្អែមល្ហែម ពេលខ្លះក៏កំសត់ជូចតទៅតាមដំណើរជីវិតរស់នៅ ការជួបប្រទះ តាមរយៈសោភ័ណ្ឌជីវិតធ្វើឱ្យសង្គមជាតិទាំងមូលក៏មានការរីកចម្រើនផងដែរ។

## ៥.៤.តម្លៃអប់រំឱ្យស្រឡាញ់សន្តិភាពនិងការអភិវឌ្ឍន៍សង្គម

នៅក្នុងស្នាដៃរឿង អក្សរសិល្ប៍ពុទ្ធនិយមអ្នកនិពតែងតែលើកយកពីតម្លៃអប់រំ ឱ្យមនុស្សចេះស្រឡាញ់សន្តិភាពនិងជួយចូលរួមដល់ការអភិវឌ្ឍន៍សង្គមជាតិមួយកម្រិត ។ នៅពេលសង្គមបានជួបបញ្ហាអ្វីមួយ គេបានជួយសម្របសម្រួល ដោយអហឹង្សា ដើម្បីមនុស្សទូទៅនិងអ្នកសិក្សារៀនសូត្រធ្វើជាគំរូអនុវត្តតាមជៀសវាងនូវជំលាស់វិវាតគ្នានិងគ្នាបាន នៅពេលដែលមានសន្តិភាពហើយ សង្គមទាំងមូលនិងមានការរីកចម្រើនជាក់ជាមិនខាន។ លើពីនេះទៅទៀត អប់រំមនុស្សឱ្យជៀសវាងក្នុងការប្រព្រឹត្តិរាល់អំពើផ្តាំផ្គងទាំងឡាយ ដែលជាមាគ៌ាញ៉ាំមនុស្សឱ្យទៅរកសេចក្តីសុខសុភមង្គលពិតប្រកដ។ តទ្ធិពលនេះជនានុជនទាំងគ្រប់វ័យ គ្រប់ស្រទាប់វណ្ណៈស្មោះត្រង់ចេះស្រឡាញ់សន្តិភាពការអភិវឌ្ឍន៍និងមិនមានចិត្តឈ្លានពានអ្នកដ៏ទៃដែរ។ នៅពេលមានសន្តិភាពហើយ ប្រជាជនខ្មែរមិនភ្លេចនូវការស្ថាប្រទេសជាតិឡើងវិញនោះទេ ក្នុងស្នាដៃអក្សរសិល្ប៍ពុទ្ធនិយមក្រោយសម័យអង្គរ បានរស់រានមានជីវិតឡើងវិញគិចផុតពីសច្ចាមិត្តឈ្លានពានទឹកដី។បន្ថែមពិនេះទៅទៀតស្នាដៃអក្សរសិល្ប៍ទាងនេះ បានជួយអប់រំចំរើន ទាំងផ្នែកស្មារតី ចិត្តគំនិតច្នៃប្រឌិត ចេះធ្វើនូវសម្ភារៈសព្វបែបយ៉ាងនិងការអភិវឌ្ឍន៍សង្គម។ ដោយមានការអប់រំជាច្រើនតាមរយៈរឿងក្នុងអក្សរសិល្ប៍ពុទ្ធនិយម ខ្មែរបានប្រែចិត្តដើរតាមព្រះពុទ្ធសាសនា ទោះជាលិទ្ធិពុទ្ធសាសនាអប់រំឱ្យជឿលើទស្សនៈកម្មផល ក៏ខ្មែរយើងមិនផ្តេកផ្តួលទាំងស្រុងដែរ ។ តម្លៃអប់រំអក្សរសិល្ប៍ក្នុងសាសនាខ្មែរយើងបានខិតខំប្រឹងប្រែងតស៊ូក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ការប្រកបរបរកស៊ីចិញ្ចឹមជិវិតដោយខ្លួនឯងនិងទាំងកម្លាំងកាយកម្លាងចិត្តទទួលផលបានបរិបូរជាំទីពេញចិត្ត។ ប្រជាជនខ្មែរគ្រប់រូបតែងមានសុឆន្ទៈស្រឡាញ់ការពារមាតុប្រទេសរបស់ខ្លួនមិនឱ្យជនបរទេសឈ្លានពានយកបានៗបង្ហាញនៅក្នុងសម័យបច្ចុប្បន្ន នៅពេលប្រទេសសៀមឈ្លានពានចង់

បានប្រាសាទព្រះវិហារ សម្តេចអគ្គសេនាតីតេជោ ហ៊ុន សែន បានលះបង់កម្លាំងកាយកម្លាំងចិត្តសាច់ឈាមអាយុជីវិតខិតខំការពារនិងកេណ្ឌកងទ័ពទៅតទល់ជាមួយជនជាតសៀម ដោយចិត្តអង់អាចក្លាហានតទលជាមួយសត្រូវឈ្លានពានរហូតទទួលបានជោគជ័យនិងធ្វើឱ្យប្រទេសជាតិមានការរីកចម្រើនគ្រប់វិស័យទាំងអស់។

- ការគោរពសិទ្ធិមនុស្ស៖ ការយល់ដឹង និងការលើកកម្ពស់សិទ្ធិជាមូលដ្ឋានរបស់បុគ្គលគ្រប់រូប គឺចាំបាច់សម្រាប់ការបង្កើតសង្គមមួយប្រកបដោយយុត្តិធម៌ និងសមធម៌។

- ការយល់ចិត្ត និងការអាណិតអាសូរ៖ ការលើកទឹកចិត្តសិស្សឱ្យយល់ និងចែករំលែកអារម្មណ៍របស់អ្នកដទៃ ជួយបណ្តុះវប្បធម៌នៃសេចក្តីសប្បុរស និងការគាំទ្រ។

- ការត្រិះរិះពិចារណា៖ ការអភិវឌ្ឍន៍សមត្ថភាពក្នុងការវិភាគព័ត៌មាន ការសន្មតសំណួរ និងការគិតដោយឯករាជ្យ គឺជាកត្តាសំខាន់សម្រាប់ការសម្រេចចិត្តប្រកបដោយការយល់ដឹង និងការដោះស្រាយជម្លោះ។

- ការដោះស្រាយជម្លោះ៖ ការបង្រៀនវិធីសាស្ត្រដោយសន្តិវិធីសម្រាប់ការដោះស្រាយការខ្វែងគំនិតគ្នា និងជម្លោះជំរុញឱ្យមានវប្បធម៌នៃការសន្ទនាជាជាងអំពើហិង្សា។

- យុត្តិធម៌សង្គម៖ ការលើកកម្ពស់សមធម៌ និងយុត្តិធម៌ក្នុងសង្គម លើកទឹកចិត្តសិស្សានុសិស្សឱ្យតស៊ូមតិសម្រាប់សហគមន៍ដែលខ្វះខាត និងធ្វើការឆ្ពោះទៅរកការលុបបំបាត់វិសមភាពជាប្រព័ន្ធ។

- ការចូលរួមរបស់ពលរដ្ឋ៖ ការលើកទឹកចិត្តឱ្យមានការចូលរួមយ៉ាងសកម្មនៅក្នុងសហគមន៍ និងជីវិតពលរដ្ឋ ជួយឱ្យបុគ្គលយល់អំពីតួនាទីរបស់ពួកគេក្នុងការរៀបចំសង្គមប្រកបដោយសន្តិភាព។

- តម្លៃអប់រំធ្វើឱ្យមនុស្សចេះអំណត់ឧស្សាព្យាយាមៈនៅក្នុងអក្សរសសិល្ប៍ពុទ្ធនិយម ក៏បានអប់រំផ្លូវចិត្តដល់មនុស្សគ្រប់រូបឱ្យចេះប្រកបការងារផ្សេងៗ ទោះជួបការលំបាកចេះតស៊ូឧស្សាព្យាយាមរកស៊ីចិញ្ចឹមជីវិតនិង ធ្វើឱ្យជីវិតមានសុភមង្គល។

- ភាពជាពលរដ្ឋសកល៖ ការជំរុញការយល់ដឹងអំពីទំនាក់ទំនងអន្តរជាសកល លើកកម្ពស់ការយល់ដឹងអំពីវប្បធម៌ និងទស្សនៈចម្រុះ ជំរុញកិច្ចសហប្រតិបត្តិការឆ្លងព្រំដែន។

- និរន្តរភាព៖ ការសង្កត់ធ្ងន់លើសារៈសំខាន់នៃការគ្រប់គ្រងបរិស្ថានរួមចំណែកដល់សន្តិភាពយូរអង្វែងតាមរយៈការដោះស្រាយបញ្ហាទាក់ទងនឹងកង្វះធនធាន និងការប្រែប្រួលអាកាសធាតុ។

- កិច្ចសហការ និងការងារជាក្រុម៖ ការលើកទឹកចិត្តឱ្យមានបទពិសោធន៍សិក្សាដោយសហការជួយបង្កើតជំនាញចាំបាច់សម្រាប់ធ្វើការរួមគ្នាឆ្ពោះទៅរកគោលដៅរួម។

- អហឹង្សា៖ ការជំរុញគោលការណ៍នៃការប្រាស្រ័យទាក់ទងគ្នាដោយអហិង្សា និងសកម្មភាពផ្តល់អំណាចដល់បុគ្គលម្នាក់ៗក្នុងការតស៊ូមតិដើម្បីការផ្លាស់ប្តូរដោយមិនប្រើការឈ្លានពាន។

- ការយល់ដឹងអំពីវប្បធម៌៖ ការយល់ដឹង និងការឲ្យតម្លៃលើភាពចម្រុះនៃវប្បធម៌ ជំរុញការអត់ឱន និងកាត់បន្ថយការរើសអើង រួមចំណែកដល់ការរួបរួមក្នុងសង្គម។

- ទំនួលខុសត្រូវផ្ទាល់ខ្លួន៖ ការលើកទឹកចិត្តបុគ្គលឱ្យទទួលខុសត្រូវចំពោះសកម្មភាពរបស់ពួកគេ លើកកម្ពស់ការទទួលខុសត្រូវ និងអាកប្បកិរិយាប្រកបដោយសីលធម៌ទាំងក្នុងបរិបទផ្ទាល់ខ្លួន និងសង្គម។

ដូច្នោះក្នុងផ្នែកមួយនេះ ស្នាដៃអក្សរសិល្ប៍ពុទ្ធនិយមខ្មែរ អ្នកនិពន្ធបានប្រើប្រាស់ ដោយយកតម្លៃអប់រំដល់មនុស្សឱ្យចេះរស់នៅធ្វើជាបុគ្គលមានប្រយោជន៍សម្រាប់ខ្លួនឯងនិង បានជួយដល់សង្គមជាតិ។អប់រំមានចំណេះដឹងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងប្តេជ្ញាចិត្តក្នុងការលើកកម្ពស់សន្តិភាព យុត្តិធម៌ និងការអភិវឌ្ឍប្រកបដោយចីរភាពនៅក្នុងសង្គមជាតិរបស់ខ្លួន។

## ៥.៥.តម្លៃអប់រំការព្យាបាលផ្លូវចិត្តនិងកំសាន្តអារម្មណ៍

នៅក្នុងស្នាដៃអក្សរសិល្ប៍ពុទ្ធនិយមក្រោយសម័យអង្គរ បានជួយដល់ការរស់នៅរបស់ប្រជាជនខ្មែរនៅពេលដែលពួកគេ បានជួបនូវបញ្ហាអ្វីមួយ ប៉ះពាល់ផ្លូវចិត្តតែងតែកមជួយសង្គ្រោះ បៀបដូចជាឱសថទេព្វដ៏ពូកែស័ក្តិសិទ្ធិមកជួយសង្គ្រោះធ្វើឱ្យយើងនិងបានធូស្រាកពីជម្ងឺអ៊ុចឹងដែរ។ នៅពេលដែរមនុស្សបានជួបនូវវិបត្តិផ្លូវចិត្តភាពអស់សង្ឃឹម ក្នុងបញ្ហាប្រទេសជាតិបានជួបសង្គ្រាមក្នុងស្រុកនិង បរទេសឈ្លានពានរាំរ៉ៃ មនុស្សរស់នៅដោយការភ័យខ្លាចតក់ស្លុត អស់សង្ឃឹមមិនដឹងថា ពេលណាទើបប្រទេសបានមានក្តីសុខសាន្តឡើងវិញ ។

បន្ទាប់មកអក្សរសិល្ប៍ពុទ្ធនិយមមានតម្លៃដែលមិនអាចកាត់ថ្លៃបានតែងតែជួយចម្រុះចោលនូវក្តីទុក្ខកង្វល់ទាំងឡាយបាន ។ អក្សរសិល្ប៍បានជួយព្យាបាលបញ្ហាសតិអារម្មណ៍របស់មនុស្សតាមរយៈស្នាដៃអក្សរសិល្ប៍ នៅពេលដែលមនុស្សបានអានឬ ស្តាប់បានជួយឱ្យមានស្មារតីភ្ញាក់រឭកឡើងវិញ។ មួយវិញទៀត ពេលយើងបានមានអារម្មណ៍ធុញថប់តប់ប្រមល់ខ្លាំងដង់មើលកសាន្តកែអផ្សុក ក៏បានជួយធ្វើឱ្យយើងបានសម្បាយធូស្បើយអារម្មណ៍បានផងដែរ។ មិនត្រឹមតែប៉ុណ្ណោះអក្សរសិល្ប៍បានជួយបំបាត់ភាពនឿយហត់របស់ប្រជាជនពីការងារស្រែចម្ការ ពេលពួកគាត់សម្រាក់និង បាននិទានរឿងដែលបានចងចាំពួកគាត់ស្តាប់ដ៏បានធូរសម្បាយអារម្មណ៍បានមួយកម្រិតផងដែរ។មិនតែប៉ុនោះអក្សរសិល្ប៍បានជួយដល់យើងពេលប្រព្រឹត្តិនូវអំបើមិនល្អទៅលើនរណាម្នាក់ បានជួយណែនាំដាស់តឿនយើងឱ្យចេះភ្ញាក់រឭកដឹងកំហុសរបស់ខ្លួនដែលបានសាងមិនល្អដោយប្រកាណាមួយពេលបានដឹងកំហុសហើយជួយឱ្យសម្បាយរីករាយចិត្តវិញ។ នៅក្រោយសម័យអង្គរប្រតេសជាតិបានជួបនិងសង្គ្រាមផ្ទៃក្នុងរាំរ៉ៃ ធ្វើឱ្យប្រជាជនខ្មែរមានវិបត្តិផ្លូវចិត្តអស់សង្ឃឹមយ៉ាងធូន់ធូរ ដើម្បីលោងលោមឱ្យបានជាសោះស្បើយ អក្សរសិល្ប៍ពុទ្ធនិយមបានជួតាមរយៈសាសនា មនុស្សបានមានជំនឿជឿគោរពទៅលកព្រះរតនត្រ័យមាន ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ បានជួយជម្រះក្តីសៅម៉ងនៅក្នុងចិត្តធ្វើឱ្យមានកម្លាំងចិត្តក្នុងការរស់នៅប្រកបរបបចិញ្ចឹមជីវិតបានហើយនេះជាព្រលឹងជាតិនិងសាសនាផងដែរ។បន្ទាប់មកទៀតវត្តអារាមក៏បានជួយសម្រាលដល់ផ្លូវចិត្តជួយឱ្យយើងមានចំណេះជំនាញក្នុងការសិក្សារៀនសូត្រ ការងហត្ថកម្មនិង សិល្បៈថាប្រពៃណីរបស់ខ្មែរយើងបានបន្សល់ទុករហូតមកដល់សព្វថ្ងៃ។

សរុបសេចក្តីមកអក្សរសិល្ប៍ពុទ្ធនិយម បានជួយដល់មនុស្សដែលមានវិបត្តិក្នុងផ្លូវចិត្តដោយរឿងបញ្ហាជាច្រើនស្មុកស្មាញចាក់ស្រះគ្នាមិនចេះអស់មិនចេះហើយ ជួយឱ្យមានអារម្មន៍បានធូរស្បើយឡើងវិញបាន។

# ជំពូក ៦  សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ៦.១.សង្ខេបលទ្ធផល

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវ វិភាគវែកញែកយ៉ាងល្អិតល្អន់ទៅលើ តម្លៃអប់រំអក្សរសិល្ប៍ពុទ្ធនិយមក្រោយសម័យអង្គរ រួចមក យើងឃើញថា តម្លៃអប់រំអក្សរសិល្ប៍ពុទ្ធនិយម ពិតជាដើរតួនាទីសំខាន់បំផុតនៅក្នុងស្នាដៃអក្សរសិល្ប៍។ម្យ៉ាងវិញទៀតអក្សរសិល្ប៍គឺជាផ្នែកមួយក្នុងការដែលមិនអាចញែកចេញពីមនុស្សក្នុងការអប់រំនោះឡើយ មិនត្រឹមតែប៉ុណ្ណោះ បានជួយឱ្យចេះប្រព្រឹត្តិអំពើល្អ ចេះដឹងគុណ ចំពោះអ្នកបានជួយខ្លួន ឱ្យចេះធ្វើបុណ្យធ្វើទាន ជួយអ្នកដ៏ទៃផងដែរ។ មួយវិញទៀតតាមរយៈស្នាដៃនេះ សុទ្ធតែបានបង្ហាញឱ្យបុគ្គលគ្រប់រូបបានឃើញពីអ្វីដែរជាព្រលឹងជាតិខ្មែរ យើងនេះទាំងប្រវត្តិ សាស្ត្រ ភូមិសាស្ត្រ ជាតិសាសន៍ ជំនឿ ទំនៀមទម្លាប់ប្រពៃណី វប្បធម៌ អត្តសញ្ញាណជាតិ។ ម្យ៉ាងវិញទៀត អក្សរសិល្ប៍សម័យនេះ បានបន្សល់ទុកនូវស្នាដៃឯកសារជាច្រើន គម្ពីរ ក្បួនខ្នាត បន្សល់ជាកេរ្តិ៍ដំណែលតម្លៃខ្លឹមសារនៃអប់រំ។

ពិសេសឱ្យអ្នកសិក្សាជំនាន់ក្រោយបានដឹងពីរឿងអក្សរសិល្ប៍ពុទ្ធនិយម។ មានតម្លៃអប់រំខ្លាំងក្លាទាំងផ្នែក ស្មារតីនិង ពុទ្ធិ ភាបចម្រុះពណ៌នេះហើយបានធ្វើឱ្យអ្នកនិពន្ធបានកែច្នៃរឿង ជាសិល្បៈ គំនូរ ល្ខោន ចម្រៀង ភាពយន្ត ដើម្បីបន្តយកទស្សនៈអប់រំនៃរឿងអក្សរសិល្ប៍ពុទ្ធនិយម និពន្ធជាស្នាដៃនោះមកបង្ហាញដល់កូនខ្មែរជំនាន់ក្រោយឱ្យបានដឹងកាន់តែស៊ីជម្រៅថែមទៀត។ ចំណែកអក្សសិល្ប៍ពុទ្ធនិយម ទសជាតក វិញបានរួមចំណែក បណ្តុះការអប់រំតាមតួនាទីបានបង្ហាញមនុស្សឱ្យបានឃើញបានយល់ពីទុក្ខលំបាកវេទនានៃជីវិតសត្វលោក មានតែការរក្សាសិល ការចេញទៅកសាងព្រះផ្នួសនៃសច្ចះភាពធម្មជាតិផងដែរ។ បន្ទាប់មកអក្សរសិលល្ប៍បញ្ញាសជាតក នានាជាតកឬសាស្ត្រល្បែង គឺបានរួមចំណែកបន្ទូភាពស្រ្តេស តាមតឹងតប់ប្របល សម្លាធ៍វិបត្តិផ្លូវចិត្ត របស់មនុស្សជួយឱ្យបានស្រាកស្រានមួយកម្រិត។ ត្រង់នេះ ទំនោររបស់ព្រះពុទ្ធសាសនា បានចាក់ស្រេះជាដើមចងផ្សារភ្ជាប់ជាមួយ ផ្នត់គំនិតជំនឿទនៀមទម្លាប់ ប្រពៃណីរបស់ជនជាតិខ្មែរបានកប់យ៉ាងជ្រៅក្នុងក្រអៅបេះដូងតាមរយៈការប្រើប្រាសអក្សរសិល្ប៍ពុទ្ធនិយម ធ្វើជាឱសថសម្រាប់ ព្យាបាលផ្លូវចិត្តនិងលោងលោមអារម្មណ៍ឱ្យបានធូស្បើយពីទីក្ខកង្វល់ទាំងនោះបាន។ បន្ថែមលើសពីនេះទៅទៀត ស្នាដៃរឿងក្នុងអក្សរសិល្ប៍ពុទ្ធនិយមអ្នកនិពន្ធបានចូលរួមចំណែកឆ្លុះបញ្ចាំងពីសង្គមជាក់ស្តែងផល និងផ្តល់ផលប្រយោជន៍ដល់ជាតិមាតុភូមិផងដែរ។

រីឯស្នាដៃអក្សរសិល្ប៍ខ្មែរបែបពុទ្ធ អ្នកនិពន្ធបានសរសេរក្នុងស្នាដៃរបស់ខ្លួន គឺទាក់នឹងការបំពេញបារមីរបស់ព្រះពោធិសត្វបានត្រាស់ ជាព្រះសម្មាសម្ពុទ្ធ ការធ្វើទាន កសាងអំពើជាកុសលរបស់ពោធិ សត្វ កម្មពៀរនិង បាបនិងបុណ្យ ជាដើម។ បន្ទាប់មកការផ្សព្វផ្សាយវប្បធម៌ អក្សរសាស្ត្រ អក្សរសិល្ប៍ និងព្រឹត្តិការណ៍សង្គមផ្សេងៗនៅសម័យនោះ គឺតាមរយៈសាស្ត្រា ដែលគេតម្កល់នៅក្នុង វត្តសម្រាប់បង្រៀនសិស្ស ក្រាំងព្រះសង្ឃទេសនាភារនានិយាយរឿងប្រាប់គ្នាតៗជាដើម។ មិនតែប៉ុណ្ណោះ សិស្សរៀនក្នុងសាលាវត្ត ក្រោយពីទទួលបានចំណេះដឹងពីព្រះសង្ឃសព្វគ្រប់ពួកគេត្រូវចារសាស្ត្រាចែកជូនតាមវត្តអារាមឱ្យអ្នកសិក្សា បានរៀនសូត្រស្នាដៃនីមួយៗ ការអប់រំឱ្យមនុស្សប្រព្រឹត្តនូវអំពើល្អ បណ្តុះស្មារតីអហិង្សាក្នុងការប្រាស្រ័យទាក់ទ្នា នៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។ ស្នាដៃនេះទទួលការពេញចិត្តពីសំណាក់ប្រជា ពលរដ្ឋខ្មែរគ្រប់រហូតដល់សម័យបច្ចុប្បន្នមានឥទ្ធិពលយ៉ាងខ្លាំងលើសង្គម វប្បធម៌ខ្មែរ ក្នុងវិស័យហោរាសាស្ត្រ វិស័យសិល្បៈ វិស័យគុលាការ វិស័យនយោបាយនិង វិស័យច្បាប់ ។

សរុបមក អក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយម នៅសម័យកណ្តាល ជាស្នាដៃយ៉ាងសំខាន់បំផុតក្នុងការរួមចំណែកអភិវឌ្ឍរតកវប្បធម៌ អក្សរសាស្ត្រ អក្សរសិល្ប៍ឱ្យរីកចម្រើន និងជាខឿនដ៏រឹងមាំរបស់វប្បធម៌អរិយធម៌ខ្មែរ។

## ៦.២.អនុសាសន៍

ឆ្លងតាមការពិភាក្សាស្រេវជ្រាវ និងសន្និដ្ឋានទៅលើលទ្ធផលកាសិក្សាអំពី តម្លៃអប់រំអក្សរសិល្ប៍ពុទ្ធក្រោយសម័យអង្គរ រួចមក នាងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ជនទូទៅក៏ដូចជាអ្នកសិក្សាគ្រប់រូបងាកមកចាប់អរម្មណ៍ផ្តល់តម្លៃចំពោះ ស្នាដៃអក្សរសិល្ប៍ពុទ្ធនិយម ព្រមទាំងមានស្មារតីចូលចិត្តយកចិត្តទុកដាក់ ស្រឡាញ់រៀនសូត្រ ចូលរួមលើកស្ទួយអភិរក្សស្នាដៃអក្សរ

សិល្បៈដែលមាននៅក្នុងនិងក្រៅប្រទេស ជាពិសេសនៅប្រទេសសកម្ពុជា ពីព្រោះបានផ្តល់សារៈប្រយោជន៍មហិមារវិសេសវិសាលដល់ជនគ្រប់រូប បានយល់ពីតម្លៃងប់រំអក្សរសិល្ប៍ពុទ្ធនិយម ចេះប្រព្រឹត្តិអំពើល្អ ចេះខ្លាចអំពើបាប មានជំនឿជឿថាមានកម្មផល ចេះធ្វើបុណ្យដាក់ទាន មានធម៌កតញ្ញូចំពោះអ្នកមានកុណ ចេះគោរពទំនៀមទម្លាប់ប្រពៃណី ចេះរស់នៅប្រកបដោយសីលធម៌ និងសន្តិភាពក្នុងសង្គមជាតិទាំងមូល។ មួយវិញទៀតស្មេរសង្ឃឹមថាកិច្ចការស្រាវជ្រាវមួយនេះអាចជាទុនមួយជួយសម្រួលនិង ជួយចូលរួមជាចំណែកយោបល់ ដល់អ្នកសិក្សាជំនាន់ក្រោយៗ ទៀត សម្រាប់វិភាគទៅលើការបង្ហាញពី តម្លៃអប់រំអក្សរសិល្ប៍ពុទ្ធនិយមតាមរយៈការប្រើប្រាស់ស្នាដៃ ក្នុងគោលបំណងឈានទៅរកការសិក្សាលំម្អិតជាងនេះទៅទៀត។

ជាចុងក្រោយ ដោយមើលឃើញនូវចំណុចអវិជ្ជមាន និងកន្លែងខ្វះខាតក្នុងការសិក្សាស្រាវជ្រាវខាងលើនេះ យើងខ្ញុំសូមដល់អ្នកសិក្សាគ្រប់មជ្ឈដ្ឋាន ដែលចូលចិត្តស្រឡាញ់ស្នាដៃអក្សរសិល្ប៍ សាស្ត្រាចារ្យបណ្ឌិត កវីអ្នកប្រាជ្ញ លោកគ្រូ អ្នកគ្រូ និងអ្នកសិក្សាគ្រប់រូប ជួយពិនិត្យកែលម្អនូវរាល់កន្លែងខ្វះខាតទាំងឡាយដែលកើតមានឡើងដោយអចេតនាដើម្បីឱ្យកិច្ចការស្រាវជ្រាវមួយនេះមានភាពទាក់ទាញកាន់តែល្អប្រសើរថែមទៀត។

# ឯកសារយោង


- សៀវភៅថ្នាក់ទី១២មេរៀនទី៣ អក្សរសិល្ប៍ពុទ្ធនិយម
- សិក្សាអក្សរសិល្ប៍ពុទ្ធនិយម
- ក្រសួងអប់រំយុវជននិងកីឡា ភាសាខ្មែរថ្នាក់ទី១០.២០១០.ទំព័រ ៦៩
- និងអក្សរសាស្ត្រខ្មែរថ្នាក់ទី១២.២០១០ .ទំព័រ៩៦
- ក្រសួងអប់រំយុវជននិងកីឡា ឧក្សរសាស្ត្រខ្មែរថ្នាក់ទី១១.២០១០.៦.១៣៣
- សៀវភៅរលឹកទ្រឹស្តីឧក្សរសិល្ប៍ លោកគ្រូ វៃ បូរី
- ឈឹមស៊ុម អត្ថនិទស្សន៍ ១៩៦៤.ទំព័រ ១
- ឈឹម ស៊ុម អត្ថទស្សន៍ ១៩៦៤ ទំព័រអារម្ភកថា
- បណ្ឌិត ញ៉ុក ថែម មហាវេស្សន្តរជាតក ទំព័រ២៣ . ១៩៦៣
- ត្រឹងងារ អរិយធម៌ខ្មែរ ១៩៧៥ទំព័រ ៩៣
- ឃីង ហុកឌី ទិដ្ឋភាពទូទៅនៃអក្សរសាស្ត្រខ្មែរឆ្នាំ១៩៧៧ទំព័រ២៣
- ស្រាវជ្រាវចងក្រងដោយលោក គិន ធារាសមាគមន៍អ្នកអក្សរសាស្ត្រខ្មែរ ៣ .៨ .២០១៩
- ប្រវត្តិអក្សរសាស្ត្រខ្មែរទំព័រ ២១២.២១៨
- សៀវភៅសិក្សាអក្សរសិល្ប៍ពុទ្ធនិយមទសជាតក ព.ស ២៥៦៦.គ.ស ២០២៣ គង់ សុខហេង ញ៉ុក ថែមសៀវភៅបញ្ញាសជាតក ញ៉ុក ថែម មហាវិទ្យាល័យ អក្សរសាស្ត្រនិងវិត្យាសាស្ត្រមនុស្សជាតិ ក្រុងភ្នំពេញ ២៦.មិនា ១៩៦៣
- សៀវភៅអក្សរសិល្ប៍ខ្មែរអត្ថបទរឿងសង្ខេប គង់ សុខហេង ព.ស២៥៦២. គ.ស ៣០១៩
- រឿងខ្ចង់ស័ង្ខ

https://csheducational.blogspot.com/2015/09/blog-post.html
- រឿងមរណៈមាតា

https://csheducational.blogspot.com/2015/05/blog-post.html
- រឿង ពុទ្ធសែននាងកង្រី

https://csheducational.blogspot.com/2015/03/blog-post_22.html
- រឿងស័ង្ខសិល្បជ័យ

https://csheducational.blogspot.com/2015/05/blog-post_17.html#more